EUROCHAM
CAMBODIA



# សៀវភៅស

## អនុសាសន៍គោលនយោបាយសម្រាប់ការវិនិយោគ និងពាណិជ្ជកម្ម

# ២០១៩

ISBN: 978-9924-9081-42
បោះពុម្ពនៅកម្ពុជា ខែមិថុនា ឆ្នាំ២០១៩

រូបថតគម្របដោយ៖ Lang Sodina

សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាត្រូវបានសម្ពោធឡើងនៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១១ ដោយមានការឧបត្ថម្ភគាំទ្រពីសំណាក់ស្ថាបនិកបីដែលជាសមាគមធុរកិច្ចអឺរ៉ុប៖ សភាពាណិជ្ជកម្មបារាំង-កម្ពុជា (Chambre de Commerce Franco-Cambodgienne/CCFC), សមាគមធុរកិច្ចអង់គ្លេសប្រចាំកម្ពុជា (British Business Association in Cambodia/BBAC) និងក្រុមធុរកិច្ចអាល្លឺម៉ង់ (Arbeitskreis Deutsche Wirtschaft/ADW)។ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាត្រូវបានបង្កើតឡើងក្នុងគោលបំណងលើកកម្ពស់ផលប្រយោជន៍បណ្ដាធុរកិច្ចអឺរ៉ុបដែលកំពុងប្រតិបត្តិការក្នុងប្រទេសកម្ពុជាជួយសម្រួលការចូលរបស់ក្រុមហ៊ុនអឺរ៉ុបមកប្រកបអាជីវកម្មក្នុងទីផ្សារកម្ពុជានិងបង្កើតជាបណ្ដាញជួយគ្នាទៅវិញទៅមកក្នុងចំណោមសមាជិករបស់ខ្លួនជាសាជីវកម្មក្ដី ជាបុគ្គលក្ដី។

សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា (EuroCham) សូមថ្លែងអំណរគុណចំពោះក្រុមហ៊ុនសមាជិករបស់យើងទាំងអស់ ដែលបានធ្វើវិភាគទាននូវធាតុចូលនានានិងផ្ដល់ការគាំទ្រដទៃទៀត ដើម្បីធ្វើឲ្យយើងឈានទៅសម្រេចក្នុងការបោះពុម្ពផ្សាយសៀវភៅសនេះ។


**សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា**

www.eurocham-cambodia.org
អ៊ីម៉ែល: info@eurocham-cambodia.org
ទូរសព្ទ: +៨៥៥ ០២៣ ៩៦៤ ១៤១

អគារលេខ ៣០ មហាវិថីព្រះនរោត្តម
អគារធនាគារ Bred ជាន់ទី៣
ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា


*សៀវភៅស២០១៩នេះ ប្រមូលផ្តុំការឆ្លុះបញ្ចាំងទស្សនៈរួមរបស់ក្រុមហ៊ុនសមាជិកនៃសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា នៅលើទិដ្ឋភាពនានាជុំវិញបរិស្ថានធុរកិច្ចក្នុងប្រទេស។ ព័ត៌មាន និងទស្សនៈទាំងឡាយនៅក្នុងសៀវភៅនេះ មានគោលបំណងតែមួយគត់ គឺសំដៅលើកកម្ពស់ឲ្យមានកិច្ចសន្ទនាក្នុងន័យស្ថាបនា ហើយលើកសំណើរកដំណោះស្រាយសម្រាប់ធ្វើឲ្យទំនាក់ទំនងធុរកិច្ចរវាងកម្ពុជា និងសហភាពអឺរ៉ុបកាន់តែមានភាពប្រសើរឡើងថែមទៀត។ ផ្អែកលើចំណេះដឹងនិងជំនឿរបស់យើង សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាបានខិតខំគ្រប់លទ្ធភាព ដើម្បីធ្វើយ៉ាងណាឲ្យព័ត៌មានក្នុងសៀវភៅស ២០១៩ នេះ មានភាពត្រឹមត្រូវមុននឹងធ្វើការបោះពុម្ពផ្សាយ។ ប៉ុន្តែ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាមិនទទួលខុសត្រូវលើផ្នែកណាមួយនៃខ្លឹមសាររួមក្នុងសៀវភៅស២០១៩នេះ និង/ឬ ក៏ផលដែលកើតចេញពីសេចក្តីសម្រេចណាមួយក្រោយពីសៀវភៅនេះត្រូវបានបោះពុម្ពផ្សាយឡើយ។*

*ស្នាដៃនេះត្រូវបានបោះពុម្ពឡើងដោយមានជំនួយឧបត្ថម្ភពីសហភាពអឺរ៉ុប។ ខ្លឹមសារក្នុងសៀវភៅនេះ ឆ្លុះបញ្ចាំងសម្លេងក្រុមធុរកិច្ចអឺរ៉ុប ដែលតំណាងដោយសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា និងមិនត្រូវយក ទោះជាក្នុងរូបភាពណាក៏ដោយ ទៅឆ្លុះបញ្ចាំងទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។*

# សៀវភៅស
# ២០១៩

អនុសាសន៍គោលនយោបាយសម្រាប់ការវិនិយោគ និងពាណិជ្ជកម្ម

EUROCHAM
CAMBODIA

# មាតិកា


ពាក្យកាត់ ............ ២៨៤

វិធីសាស្ត្រ ............ ០៥

សាររបស់ប្រធាន ............ ០៦
អនុសាសន៍គោល នយោបាយសម្រាប់ឆ្នាំ ២០១៩ ............ ១០
ការឆ្លើយតបទៅនឹងគោលនយោបាយឆ្នាំ២០១៧-២០១៨ ............ ១៨
វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន៖ ក្រុមការងារវិស័យទេសចរណ៍ ............ ៤៣
ឯកសារយោង ............ ២៨៦

## វិស័យការពារការវិនិយោគ ៤៨

យន្តការពិនិត្យផ្លូវច្បាប់ឡើងវិញ ............ ៥២
ការរៀបចំតាក់តែងច្បាប់ថ្មី ............ ៥៨
ការការពារកម្មសិទ្ធិបញ្ញា ............ ៦៦

## វិស័យធនធានមនុស្ស ៧៨

ការជួលនិយោជិតជាជនបរទេស ............ ៨០
គិលានដ្ឋាននៅតាមសហគ្រាស ............ ៨៣
ការពិនិត្យមើលឡើងវិញនូវលក្ខខណ្ឌតម្រូវសម្រាប់ការហ្វឹកហ្វឺន
កូនជាង ............ ៨៦
ការប្រាស្រ័យទាក់ទងរវាងស្ថាប័នសាធារណៈនិងវិស័យឯកជន ............ ៩៤

## វិស័យពន្ធដារ ៩៦

ការរៀបចំតាក់តែងក្របខ័ណ្ឌនិយ័តកម្មមូលបត្រ ............ ១០០
ការគាំទ្រដល់ក្រុមហ៊ុនដែលគោរពកាតព្វកិច្ចពន្ធនៅក្នុងដំណើរការរៀបចំ
ប្រព័ន្ធសារពើពន្ធជាផ្លូវការ ............ ១០៥
អាករលើតម្លៃបន្ថែម ............ ១០៩
ការអនុវត្តពន្ធមិនស្មើភាព ............ ១១២
គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ............ ១១៤

## វិស័យគយ ការដឹកជញ្ជូន និងភ័ស្តុភារ ១១៨

វិស័យគយ ............ ១២២
ការដឹកជញ្ជូន និងភ័ស្តុភារ ............ ១៣០

## វិស័យយានយន្ត ១៣២

បទប្បញ្ញត្តិសម្រាប់ការនាំចូល ............ ១៣៦
កិច្ចការពារអ្នកប្រើប្រាស់ ............ ១៣៩
គោលនយោបាយសារពើពន្ធ ............ ១៤២

## វិស័យធុរកិច្ចកសិកម្ម ១៤៦

សារធាតុហាមឃាត់ ............ ១៥០
ការប្រយុទ្ធប្រឆាំងនឹងសម្ភារកសិកម្មខុសច្បាប់ ............ ១៥៣
បទប្បញ្ញត្តិការងារ ............ ១៥៦
ពិពិធកម្មកសិកម្ម ............ ១៥៩
ការធ្វើតេស្តបរិស្ថានតាមលក្ខខណ្ឌតម្រូវផ្លូវច្បាប់ ............ ១៦២

## វិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ១៦៤

ការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ............ ១៦៨
ទូរគមនាគមន៍ ............ ១៧៨

## វិស័យធុរកិច្ចបៃតង ១៨៤

ការរៀបចំបញ្ចប់ស្ថាពរ នូវក្រមបរិស្ថាន និងធនធានធម្មជាតិ នៃប្រទេស
កម្ពុជា ............ ១៨៨
ការគាំទ្រការធ្វើអន្តរកាលទៅជាសេដ្ឋកិច្ចបៃតង ............ ១៩៨

## វិស័យសុខាភិបាល ២១២

ការទទួលបានជីវផលិតផល ............ ២១៦
ឱសថមិនចាំបាច់មានវេជ្ជបញ្ជា ............ ២១៩
ការហាមឃាត់ផលិតផលមិនបានចុះបញ្ជិកា ............ ២២១
ការចុះបញ្ជិកានិងការបន្តសុពលភាព ............ ២២៥

## វិស័យអចលនទ្រព្យ និងសំណង់ ២៤៤

ការអភិវឌ្ឍសុរិយោដី និងអចលនទ្រព្យ ............ ២៤៨
ការរៀបចំដែនដី និងនគរូបនីយកម្ម ............ ២៥៥
ការធ្វើទំនើបកម្មបទប្បញ្ញត្តិស្តីពីអចលនទ្រព្យលំនៅដ្ឋាន ............ ២៥៩
វិស័យសំណង់ ............ ២៧២

# វិធីសាស្ត្រ

*នៅក្នុងសៀវភៅ ស សំណៅបោះពុម្ពផ្សាយលើកទីបីនេះ បានលើកឡើងអំពីសំណើគោលនយោបាយចំនួន ៦៩ ចំណុចដែលមានគោលបំណងជួយធ្វើឱ្យបរិយាកាសធុរកិច្ច និងក្របខណ្ឌច្បាប់ធុរកិច្ចនៅក្នុងប្រទេសកម្ពុជាកាន់តែមានភាពល្អប្រសើរ ថែមមួយកម្រិតទៀត។*

*យើងខ្ញុំបានបង្កើតសំណើទាំងនេះឡើង បន្ទាប់ពីយើងខ្ញុំបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយនឹងសមាជិកសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ដែលសុទ្ធតែជាអ្នកបានចូលរួមនៅក្នុងគណៈកម្មាធិការតាមវិស័យទាំង ១០ របស់យើង។*

*ដោយសារតែយើងខ្ញុំមានគោលបំណងធ្វើជាដៃគូដ៏ល្អរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកែលម្អបរិយាកាសធុរកិច្ចឱ្យកាន់តែល្អប្រសើរថែមទៀតនោះ ទើបគ្រប់បញ្ហាទាំងអស់ដែលបានលើកឡើងនៅក្នុងសៀវភៅ ស នេះ សុទ្ធតែមានផ្តល់ជាដំណោះស្រាយដែលអាចអនុវត្តបានដោយអាជ្ញាធរពាក់ព័ន្ធនៅក្នុងរយៈពេលខ្លី និងរយៈពេលមធ្យមផងដែរ។*

*អាស្រ័យហេតុនេះ អនុសាសន៍របស់យើងខ្ញុំមានទម្រង់ដូចខាងក្រោម៖*

**ស្ថានភាពអនុសាសន៍**

*បង្ហាញថាតើសំណើគោលនយោបាយឆ្នាំមុនត្រូវបាន* ***រក្សាទុក*** *ឬ* ***ធ្វើបច្ចុប្បន្នភាព*** *ឬជា* ***សំណើសុំថ្មី*** *សម្រាប់ឆ្នាំ២០១៩។*

**អនុសាសន៍ និងការឆ្លើយតបទៅនឹងគោលនយោបាយកាលពីឆ្នាំមុន**

*សេចក្តីសង្ខេបអនុសាសន៍គោលនយោបាយកាលពីឆ្នាំមុន និងការឆ្លើយតបជាបន្តបន្ទាប់ដែលផ្តល់ជូនដោយរាជរដ្ឋាភិបាល។*

**ពិពណ៌នាបញ្ហា**

*រៀបរាប់លម្អិតអំពីស្ថានភាពបច្ចុប្បន្ន និងបង្ហាញអំពីរបៀបដែលបញ្ហាទាំងនោះអាចប៉ះពាល់ដល់វិស័យឯកជន។*

**ផលប៉ះពាល់លើកម្ពុជា**

*បង្ហាញអំពីមូលហេតុដែលបញ្ជាក់ថាការដោះស្រាយបញ្ហាទាំងនេះអាចមានផលប្រយោជន៍ដល់រាជរដ្ឋាភិបាលកម្ពុជា។*

**អនុសាសន៍ឆ្នាំ២០១៩**

*បង្ហាញនូវវិធានការដាក់លាក់ដែលអាចធ្វើឱ្យស្ថានភាពនេះមានភាពល្អប្រសើរសម្រាប់គ្រប់ភាគីទាំងអស់។*



**វិស័យពន្ធដារ** | អាករលើតម្លៃបន្ថែម

២២

អាករលើតម្លៃបន្ថែមលើសេវានាំចេញ

ធ្វើបច្ចុប្បន្នភាព

**អនុសាសន៍ឆ្នាំ ២០១៦**

សូមផ្តល់ការណែនាំឲ្យបានជាក់លាក់ថែមទៀតអំពីតម្រូវការបង់អាករលើតម្លៃបន្ថែមសម្រាប់សេវាដែលត្រូវបាននាំចេញ។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*នៅក្នុងលិខិតទៅកាន់ប្រធានសភាពពាណិជ្ជកម្មអឺរ៉ុបប្រចាំកម្ពុជា ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ (លេខ១៤២២៤០ អពដ) អគ្គនាយកដ្ឋានពន្ធដារ បានប្តេជ្ញាថានឹងធ្វើការសិក្សាស្រាវជ្រាវបន្តទៀត ដើម្បីផ្តល់និយមន័យឲ្យបានច្បាស់ជាងនេះលើពាក្យថា«សេវានាំចេញ» ហើយធានាថាការអនុវត្តអាករលើតម្លៃបន្ថែមលើសេវានាំចេញ ត្រូវដើរស្របគ្នាទៅនឹងការវិវឌ្ឍន៍របស់ធុរកិច្ចនិងបច្ចេកវិទ្យា។*

**ពិពណ៌នាបញ្ហា**

*មាត្រា៦៣ នៃច្បាប់ស្តីពីពន្ធដារចែងថា សេវាកម្មត្រូវបានចាត់ទុកថាបាន «កើតឡើង» ក្នុងវង្វង់ប្រទេសកម្ពុជា ប្រសិនបើវាត្រូវបាន «ធ្វើ/ផ្តល់» ក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងចេញតែ ការផ្តល់សេវានោះទាក់ទងនឹងអចលនទ្រព្យស្ថិតនៅបរទេស ឬការ ផ្តល់សេវាដឹកជញ្ជូននៅក្រៅប្រទេស។ បន្ទាប់មកទៀតមាត្រា៦៤ធ្វើការសម្រាយលម្អិតថា បណ្តាសេវាផ្តល់នៅក្រៅព្រះរាជាណាចក្រកម្ពុជា (សេវានាំចេញត្រូវ ជាប់អាករលើតម្លៃបន្ថែមក្នុងអត្រា០%។*

**ផលប៉ះពាល់លើកម្ពុជា**

*ភាពស្រពេចស្រពិល បង្កើតជាហានិភ័យផ្នែកបទបញ្ញត្តិច្រើន សម្រាប់បណ្តាក្រុមហ៊ុននាំចេញសេវាពីប្រទេសកម្ពុជា ដោយសារតែគ្មានការណែនាំជាក់លាក់ ក្នុងច្បាប់ដើម្បីឲ្យគេអាចដឹងបានប្រាកដថា តើសេវារបស់គេជាប់អាករលើតម្លៃបន្ថែម ឬទេ។ កង្វះភាពច្បាស់លាស់នេះ ធ្វើឲ្យមន្ត្រីពន្ធដារធ្វើការវាយតម្លៃបែបស្មានមិនទៀងទាត់ ដោយគ្មានគោលការណ៍ណែនាំច្បាស់លាស់ ដែលអាចបណ្តាលឲ្យគ្មានសង្គតិភាព ឬបង្កឱកាសឲ្យមានទម្លាប់អនុវត្តខ្វះតម្លាភាព។*

**អនុសាសន៍ឆ្នាំ ២០១៧**

✓ សូមផ្តល់ការណែនាំឲ្យបានជាក់លាក់ថែមទៀតអំពីតម្រូវការបង់អាករលើតម្លៃបន្ថែម សម្រាប់សេវាដែលត្រូវបាននាំចេញ។

*សូមផ្តល់គោលការណ៍ណែនាំឲ្យបានជាក់លាក់ ថាតើពាក្យ «ប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា» មានន័យដូចម្តេច សម្រាប់សេវាដែលត្រូវបាននាំចេញ។ ជាអនុសាសន៍យើងខ្ញុំចង់បាននិយមន័យដែលបង្ហាញសណ្តានចិត្តល្អ និងអំណោយផល*

# សារ
# របស់ប្រធាន

*អារណូ ដាក*

*តាងនាមឱ្យសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា* (EuroCham) *និងបណ្ដាក្រុមហ៊ុនជាសមាជិករបស់យើងដែលកំពុងមានកំណើនកាន់តែច្រើន ខ្ញុំមានសេចក្ដីសោមនស្ស សូមបង្ហាញជូនសៀវភៅ ស បោះពុម្ពផ្សាយលើកទី ៣ របស់យើង ដែលជាកម្រងអនុសាសន៍ស្ដីពីគោល-នយោបាយពាណិជ្ជកម្ម និងការវិនិយោគ ដែលសមាជិករបស់យើងបានរៀបចំចងក្រងរួមគ្នាឡើងដើម្បីដាក់ជូនរាជរដ្ឋាភិបាលកម្ពុជាធ្វើការពិចារណា។ ការបោះពុម្ពផ្សាយដែលបានធ្វើបច្ចុប្បន្នភាពនេះគឺជាលទ្ធផលនៃការពិនិត្យឡើងវិញតាមវិធីសាស្ត្រក្នុងរយៈពេល ១៨ ខែចុងក្រោយនេះ ក្រោមការណែនាំ និងជំនាញឯកទេសពីគណៈកម្មាធិការវិស័យទាំង ១០ របស់យើង ដើម្បីផ្ដល់នូវដំណោះស្រាយដែលមានភាពប្រាកដនិយមដើម្បីជម្នះឧបសគ្គផ្នែកបទប្បញ្ញត្តិ និងរចនាសម្ព័ន្ធ ដែលជួបប្រទះនៅពេលធ្វើធុរកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ យើងរំពឹងទុកថា នៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ កំណែទម្រង់ដែលយើងចង់បានតាមរយៈសៀវភៅ ស នេះនឹងជួយធ្វើឱ្យបរិយាកាសធុរកិច្ចនៅកម្ពុជាកាន់តែល្អប្រសើរឡើងថែមទៀត ហើយជាចុងក្រោយនឹងជួយជំរុញកំណើនលំហូរចូលនូវពាណិជ្ជកម្ម និងការវិនិយោគកាន់តែច្រើនថែមទៀតទាំងទៅនិងមកពីតំបន់ទ្វីបអឺរ៉ុប និងតំបន់ឆ្ងាយជាងនេះទៀត។*

ខណៈដែលកម្ពុជាបន្តពង្រឹងជំហររបស់ខ្លួននៅក្នុងទីផ្សារសកលដែលកាន់តែអស្ថេរភាពនាពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាយល់ច្បាស់អំពីសារៈសំខាន់នៃអនុវត្តកំណែទម្រង់ដ៏មានអត្ថន័យដើម្បីធានាថាកម្ពុជានៅតែមានសមត្ថភាពប្រកួតប្រជែងជាប់រហូត។ កាលពីដើមឆ្នាំ២០១៩ សម្តេចនាយករដ្ឋមន្ត្រី បានអនុម័តយ៉ាងត្រឹមត្រូវនូវកញ្ចប់កម្មវិធីកំណែទម្រង់ប្រកបដោយមហិច្ឆតាខ្ពស់បំផុត នៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (G-PSF) ទើបបានរៀបចំឡើងវិញ ហើយកញ្ចប់កម្មវិធីកំណែទម្រង់នេះមានគោលបំណងពង្រឹងសមត្ថភាពប្រកួតប្រជែង និងជំរុញដល់កិច្ចសម្រួលពាណិជ្ជកម្មដើម្បីលើកកម្ពស់ ពិពិធកម្មសេដ្ឋកិច្ចឱ្យកាន់តែខ្លាំងឡើងថែមទៀត។ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា បានសម្តែងការស្វាគមន៍ចំពោះការដាក់ចេញនូវកម្មវិធីកំណែទម្រង់ទាំងនេះ និងចំពោះសេចក្តីសម្រេចរបស់សម្តេចនាយករដ្ឋមន្ត្រីក្នុងការវិលត្រឡប់មកធ្វើជាប្រធានវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនឡើងវិញ ដោយសារតែវេទិកានេះគឺជាយន្តការដ៏មានតម្លៃ និងអាចជឿជាក់បានសម្រាប់កិច្ចសន្ទនារវាងរាជរដ្ឋាភិបាល និងវិស័យឯកជន និងដែលបានដាក់ចេញនូវដំណោះស្រាយសំខាន់ៗជាច្រើន បន្ទាប់ពីមានកិច្ចសន្ទនាម្តងៗ។

នេះជាការលើកទឹកចិត្តមួយដែលយើងបានឃើញបញ្ហាមួយចំនួននៅក្នុងសៀវភៅ ស របស់យើងត្រូវបានដោះស្រាយតាមរយៈរបៀបវារៈកំណែទម្រង់គ្រប់ជ្រុងជ្រោយនេះ ជាពិសេស គឺអនុសាសន៍នៅក្នុងជំពូកស្តីពីវិស័យគយ ដឹកជញ្ជូន និងភស្តុភាររបស់យើង។ នេះបង្ហាញឱ្យឃើញអំពីការទទួលស្គាល់ និងការឱ្យតម្លៃកាន់តែខ្លាំងឡើងទៅលើសៀវភៅ ស របស់យើង ដែលអាចឱ្យ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ទទួលបានការឆ្លើយតប ក្នុងអត្រា ៧៥% ពីរាជរដ្ឋាភិបាលចំពោះអនុសាសន៍នានាដែលសមាជិករបស់យើងបានស្នើឡើងកាលពីឆ្នាំ២០១៧ ហើយនេះបង្ហាញអំពីភាពល្អប្រសើរពីសៀវភៅ ស ដំបូងរបស់យើង។ ការឆ្លើយតបទាំងនេះមានបង្ហាញនៅក្នុងផ្នែក «ការឆ្លើយតបផ្នែកគោលនយោបាយ» ដែលរាយនាមអនុសាសន៍ចំនួន ១១ ចំណុចដែលបានដោះស្រាយរួចរាល់ តាមរយៈការអនុវត្តការកែប្រែរបស់រាជរដ្ឋាភិបាល។ លទ្ធផលគួរជាទីចាប់អារម្មណ៍នេះ ពង្រឹងការជឿជាក់របស់យើងដែលថា វិស័យឯកជនមានតួនាទីបុព្វសិទ្ធិមួយដែលដើរតួនាទីជា

អ្នកចូលរួមចំណែកដ៏សំខាន់ចំពោះការតាក់តែងបង្កើតគោលនយោបាយដោយផ្តល់នូវមតិត្រឡប់ និងជាតុចូលដាក់ស្តែង។

នៅក្នុងសៀវភៅ ស បោះពុម្ពផ្សាយឆ្នាំនេះ មានអនុសាសន៍គោលនយោបាយចំនួន ៦៥ ចំណុច ដែលរួមបញ្ចូលទាំងអនុសាសន៍ថ្មី អនុសាសន៍ដែលបានធ្វើបច្ចុប្បន្នភាព និងអនុសាសន៍បន្តរក្សាទុកពីអនុសាសន៍លើកមុន ដោយគ្របដណ្តប់ទៅលើវិស័យជាច្រើន ហើយក្នុងនោះយើងបានដាក់បញ្ចូលនូវគណៈកម្មាធិការវិស័យថ្មីបំផុតមួយ និងជំពូកស្តីពីវិស័យធុរកិច្ចកសិកម្ម។ ការពង្រីកគណៈកម្មាធិការតាមវិស័យរបស់យើង ជាសញ្ញាបង្ហាញអំពីបំណងរបស់សហគមន៍ធុរកិច្ចរបស់យើង ដែលចង់បានកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធថែមទៀតជាមួយនឹងរាជរដ្ឋាភិបាលដើម្បីជម្នះភាពប្រឈមផ្នែកនិយ័តកម្មមួយចំនួនដែលនៅតែបន្តកើតមាន។ គណៈកម្មាធិការតាមវិស័យ និងអន្តរវិស័យនីមួយៗ បានលើកឡើងនូវបញ្ហាជាក់លាក់សម្រាប់វិស័យតាមជំនាញរបស់ខ្លួន និងលើកឡើងអំពីរបៀបដែលសំណើកែលម្អទាំងនោះ នឹងជួយលើកកម្ពស់អនុលោមភាព ការប្រកួតប្រជែង និងការវិនិយោគ។ នៅក្នុងបរិបទនេះ យើងបានកំណត់អត្តសញ្ញាណប្រធានបទសំខាន់មួយ ដែលថាបរិយាកាសកាន់តែស្មើភាពគ្នាអាចសម្រេចបានតាមរយៈការពង្រឹងការអនុវត្តឱ្យបានខ្លាំងក្លា ឱ្យមានភាពស៊ីសង្វាក់គ្នា និងឱ្យមានតម្លាភាព នូវក្របខ័ណ្ឌគតិយុត្តិរបស់ព្រះរាជាណាចក្រកម្ពុជា ដែលគួរតែខិតខំធ្វើយ៉ាងណាទទួលស្គាល់ និងលើកទឹកចិត្តដល់ការអនុវត្តទាំងឡាយដែលមានអនុលោមភាព។ យើងជឿជាក់ថា ការអនុវត្តនូវអនុសាសន៍ទាំងនេះនឹងធានាបាននូវការឆ្លើយតបកាន់តែរឹងមាំ និងប្រកបដោយថាមវន្តថែមទៀតពីសំណាក់វិស័យឯកជនចំពោះតម្រូវការដែលកំពុងមានការប្រែប្រួលនៃទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ។

ឆន្ទៈក្នុងការស្វាគមន៍ និងទទួលយកការកែប្រែតាមរយៈការអនុវត្តកម្មវិធីកំណែទម្រង់ដ៏មានអត្ថន័យគឺជាកត្តាដ៏សំខាន់ជាចាំបាច់សម្រាប់ប្រទេសកម្ពុជាអាចមានលទ្ធភាពធ្វើដំណើរឆ្ពោះទៅមុខដោយខ្លួនឯង ដោយត្រូវឆ្លងកាត់ទិដ្ឋភាពភូមិសាស្ត្រនយោបាយរំខានជាច្រើន ដែលជាការគំរាមកំហែងដល់សេដ្ឋកិច្ចបច្ចុប្បន្ន។ នៅក្នុងកាលៈទេសៈទាំងនេះ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា សង្ឃឹមថា សៀវភៅ ស ច្បាប់បោះពុម្ពផ្សាយលើកទី ៣ របស់យើងនេះនឹងទទួលបានការស្វាគមន៍ជាថ្មីម្តងទៀតពីសំណាក់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធនៅក្នុងការអភិវឌ្ឍន៍របស់កម្ពុជា ដោយក្លាយជាមធ្យោបាយមួយដើម្បីបំផុស និងជំរុញឱ្យមានកិច្ចពិភាក្សា

គ្នា។ យើងរង់ចាំស្វាគមន៍កិច្ចសន្ទនាមួយជុំទៀត ដែលនឹងបង្កើតជាលទ្ធផលដែលគាំទ្រដល់រាជរដ្ឋាភិបាលក្នុងការអនុវត្តយុទ្ធសាស្ត្រធ្វើគោលនយោបាយដែលមានលក្ខណៈជាប្រព័ន្ធ និងបំពេញបន្ថែមដែលនឹងជំរុញឱ្យបរិយាកាសធុរកិច្ច និងបរិយាកាសគតិយុត្តិកាន់តែមានលក្ខណៈអំណោយផលថែមទៀត។

សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា សូមសម្តែងនូវការថ្លែងអំណរគុណដ៏ស្មោះចំពោះអ្នកដែលបានចូលរួមចំណែកនៅក្នុងការរៀបចំបោះពុម្ពសៀវភៅ ស នេះ។ ប្រសិនបើយើងមិនមានចំណេះដឹង ជំនាញ និងការគាំទ្រមិនរាថយរបស់អ្នកទាំងអស់គ្នានេះទេ កម្មវិធីតស៊ូមតិរបស់យើងក៏នឹងមិនអាចប្រព្រឹត្តទៅបានឡើយ។ ឥឡូវនេះ យើងសូមអំពាវនាវដល់សមាជិកទាំងអស់នៃសហគមន៍ធុរកិច្ចកម្ពុជាឱ្យចាប់យកឱកាសនេះដើម្បីបញ្ចេញសំឡេងតាមរយៈការចូលរួមនៅក្នុងកិច្ចប្រជុំពិភាក្សា និងកិច្ចប្រជុំពិគ្រោះយោបល់ដែលនឹងប្រព្រឹត្តទៅនៅឆ្នាំក្រោយ។ យើងនៅតែបន្តប្តេជ្ញាចិត្តយ៉ាងមុតមាំដដែលក្នុងការគាំទ្រដល់ក្រុមហ៊ុនឯកជនដែលមានអនុលោមភាព និងក្នុងការធ្វើការងារជាដៃគូជាមួយរាជរដ្ឋាភិបាលដើម្បីធានានូវកំណើនសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព និងវិបុលភាព។



# អនុសាសន៍គោលនយោបាយ សម្រាប់ឆ្នាំ២០១៩

*ទិដ្ឋភាពរួមនៃសំណើរបស់សមាជិកសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាដែលបានលើកឡើងសម្រាប់ឆ្នាំ២០១៩*

## វិស័យការពារការវិនិយោគ

| | |
|---|---|
| យន្តការពិនិត្យផ្លូវច្បាប់ឡើងវិញ | ១. សូមផ្តល់ការធានាថា ច្បាប់ និងបទប្បញ្ញត្តិនាពេលអនាគត មានដាក់បញ្ចូលនូវបទប្បញ្ញត្តិ អន្តរកាលជាក់ស្តែង ហើយលិខិតូបករណ៍ថ្មីៗ មិនគប្បីអនុវត្តដើម្បីដាក់ពិន័យប្រតិសកម្ម សម្រាប់ការមិន អនុវត្តតាមឡើយ។<br>២. សូមស្នើឱ្យបង្កើតយន្តការពិនិត្យឡើងវិញមានលក្ខណៈឯករាជ្យនៅតាមក្រសួង និងស្ថាប័ន សាធារណៈពាក់ព័ន្ធដែលទទួលខុសត្រូវក្នុងការចាត់ចែង និងធ្វើសេចក្តីសម្រេចលើពាក្យស្នើ សុំរបស់អង្គភាពឯកជន និងបង្កើតតុលាការរដ្ឋបាលកំពូលមួយផងដែរ។ |
| ការរៀបចំតាក់តែងច្បាប់ថ្មី | ៣. សូមស្នើផ្តល់ការធានា ការលើកទឹកចិត្ត និងជំនួយច្រើនជាងមុនដល់វិនិយោគិនតាម រយៈច្បាប់ថ្មីស្តីពីការវិនិយោគ ដោយការបញ្ចូលនូវអនុសាសន៍ ពីសំណាក់វិស័យឯកជនផងដែរ។<br>៤. សូមស្នើឱ្យផ្តល់អាទិភាព លើការបញ្ចប់ច្បាប់ស្តីពីការប្រកួតប្រជែង ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម និងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និង ប្តេជ្ញាអនុម័តច្បាប់ទាំងនេះឱ្យបានមុនដំណាច់ឆ្នាំ២០១៩។ |
| ការការពារកម្មសិទ្ធិបញ្ញា | ៥. សូមស្នើឱ្យដាក់ចេញនូវលក្ខខណ្ឌតម្រូវដែលកំណត់ឱ្យធ្វើការផ្សព្វផ្សាយមុនពេលចុះបញ្ជី សម្រាប់ពាណិជ្ជសញ្ញាថ្មីដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី។<br>៦. សូមស្នើឱ្យបង្កើតក្របខ័ណ្ឌច្បាប់កាន់តែពិស្តារដើម្បីដាក់ចេញនូវវិធានការបណ្តោះអាសន្នរឹងមាំជាងមុននៅក្នុងកិច្ចការពារកម្មសិទ្ធិបញ្ញា។<br>៧. សូមស្នើឱ្យផ្តល់សិទ្ធិអំណាចនៅកម្រិតរដ្ឋបាលដល់អគ្គនាយកដ្ឋានគយ និងរដ្ឋាករដើម្បីទប់ស្កាត់ទំនិញក្លែងក្លាយ និងការលួចលាក់នាំចូលទំនិញមកកាន់ប្រទេសកម្ពុជា។<br>៨. សូមស្នើឱ្យធ្វើការពិគ្រោះយោបល់ជាមួយនឹងវិស័យឯកជនដើម្បីបង្កើតលិខិតូបករណ៍ សម្រាប់កំណត់ឧបាស្រ័យជាក់លាក់ដើម្បីដោះស្រាយករណីរំលោភលើកម្មសិទ្ធិបញ្ញា។<br>៩. សូមស្នើឱ្យបង្កើតដំណើរការផ្លូវការសម្រាប់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដើម្បីដោះស្រាយរាល់ករណីរំលោភលើសិទ្ធិពាណិជ្ជសញ្ញាតាមរយៈក្រសួងពាក់ព័ន្ធ។ |

# វិស័យធនធានមនុស្ស

| | |
|---|---|
| ការជួលនិយោជិតជាជនបរទេស | ១០.*សូមស្នើឱ្យផ្លាស់ប្តូរគំរូកិច្ចសន្យាកំណត់ជាមុន សម្រាប់កម្មករនិយោជិតជាជនបរទេស ដោយជំនួសមកវិញនូវទម្រង់បទដ្ឋានតាមប្រព័ន្ធអនឡាញដែលមានព័ត៌មានលម្អិតជាមូលដ្ឋានអំពីកិច្ចសន្យាការងារផ្លូវការ។* |
| គិលានដ្ឋាននៅតាមសហគ្រាស | ១១.*សូមស្នើឱ្យធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ ដើម្បីអនុញ្ញាតឱ្យមានការកែសម្រួលឡើងវិញនូវលក្ខខណ្ឌតម្រូវដែលតម្រូវឱ្យសហគ្រាសដែលមានកម្មករនិយោជិតលើសពី ៥០ នាក់ឡើងទៅត្រូវមានគិលានដ្ឋានប្រចាំការនៅតាមសហគ្រាសរបស់ខ្លួន។* |
| ការពិនិត្យមើលឡើងវិញនូវលក្ខខណ្ឌតម្រូវសម្រាប់ការហ្វឹកហ្វឺនកូនជាង | ១២.*សូមស្នើឱ្យមានការទទួលស្គាល់កម្មវិធីហាត់ការសមស្របជាផ្លូវការដើម្បីធ្វើជាជម្រើស មានសុពលភាពជំនួសឱ្យកម្មវិធីហ្វឹកហ្វឺនកូនជាងនៅពេលវាយតម្លៃលើការអនុវត្តតាមប្រកាសលេខ ០០៤។*<br>១៣.*សូមស្នើឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបង្កើតអង្គភាពពិគ្រោះយោបល់ដើម្បីឱ្យវិស័យឯកជនចូលរួមក្នុងការរៀបចំផែនការ និងការគ្រប់គ្រងមូលនិធិដែលប្រមូលបានពីពន្ធអាករហ្វឹកហ្វឺនកូនជាង។*<br>១៤.*សូមអនុញ្ញាតឱ្យសហគ្រាស កាត់ចំណាយសមស្របលើការហ្វឹកហ្វឺន ដែលប្រើប្រាស់ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវហ្វឹកហ្វឺនកូនជាងនៃច្បាប់ស្តីពីការងារ តាមមូលដ្ឋានសមាមាត្រចេញពី ពន្ធអាករហ្វឹកហ្វឺនកូនជាងដែលពាក់ព័ន្ធ។* |
| ការប្រាស្រ័យទាក់ទងរវាងស្ថាប័នសាធារណៈ និងវិស័យឯកជន | ១៥.*សូមស្នើឱ្យធ្វើការពិចារណាពង្រីកប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មបរទេស ដើម្បីអាចឱ្យបំពេញនីតិវិធីរដ្ឋបាលការងារទាំងអស់បានតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។* |

## វិស័យពន្ធដារ

| | |
|---|---|
| ការរៀបចំតាក់តែងក្របខ័ណ្ឌនិយ័តកម្មមូលបត្រ | ១៦.សូមស្នើឱ្យពិចារណា អនុវត្តប្រព័ន្ធធ្វើតេស្តភាគហ៊ុនិក (Shareholder Continuity Test) ដើម្បីកំណត់វិសាលភាពនៃការផ្លាស់ប្តូរកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនបោះភាគហ៊ុន។<br>១៧.សូមស្នើឱ្យមានការទទួលស្គាល់ថាពន្ធតែមប្រើមិនគួរអនុវត្តឡើយនៅពេល ដែលភាគហ៊ុនិក ណាម្នាក់បានបង្កើនដើមទុនតាមរបៀបអសមាមាត្រ ដោយសារតែចំនួនភាគហ៊ុនរបស់ភាគហ៊ុនិកផ្សេងទៀតពុំមានការផ្លាស់ប្តូរកម្មសិទ្ធិឡើយ។ |
| ការគាំទ្រដល់ក្រុមហ៊ុនដែលគោរពកាតព្វកិច្ចពន្ធនៅក្នុងដំណើរការរៀបចំប្រព័ន្ធសារពើពន្ធជាផ្លូវការ | ១៨.សូមស្នើឱ្យពិចារណាសម្រាលការពិន័យ ចំពោះអ្នកជាប់ពន្ធទាំងឡាយណាដែលបាន រាយការណ៍ដោយស្ម័គ្រចិត្ត អំពីភាពមិនប្រក្រតីនៃការបង់ពន្ធពីមុនរបស់ខ្លួន នៅមុនពេល ទទួលបានការជូនដំណឹងអំពីការធ្វើសវនកម្ម។ |
| អាករលើតម្លៃបន្ថែម | ១៩.សូមស្នើឱ្យធ្វើការពិចារណាដាក់បញ្ចូលបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែមដាក់លាក់តាម វិស័យសម្រាប់ភ្នាក់ងារទេសចរណ៍ ដើម្បីឆ្លុះបញ្ចាំងបានកាន់តែត្រឹមត្រូវអំពីលក្ខណៈនៃ ធុរកិច្ចទាំងនេះ។ |
| ការអនុវត្តពន្ធមិនស្មើភាព | ២០.សូមស្នើឱ្យកែសម្រួលឡើងវិញ នូវសារាចរណែនាំលេខ ០០៣ សហវ ដើម្បីដកចេញនូវ លក្ខខណ្ឌសញ្ជាតិខ្មែរ ដើម្បីធានាឱ្យមានការអនុវត្តពន្ធដោយស្មើភាពនៃប្រាក់បំណាច់ អតីតភាពការងារ ។ |
| គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | ២១.សូមស្នើឱ្យធ្វើការពិចារណាដាក់ឱ្យអនុវត្តឡើងវិញ នូវការលើកលែងពន្ធ អប្បបរមាដោយស្វ័យប្រវត្តិសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងរយៈពេលលើកលែងពន្ធរបស់ខ្លួន។ |

## វិស័យគយ ការដឹកជញ្ជូន និងភ័ស្តុភារ

| | |
|---|---|
| វិស័យគយ | ២២.សូមស្នើឱ្យផ្តល់អាទិភាពលើការអនុម័តដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំសម្រាប់ការ បញ្ចេញទំនិញពីគយរហ័សក្លាមៗរបស់អង្គការគយពិភពលោកដើម្បីសម្រួលនីតិវិធីបំពេញបែបបទបញ្ចេញទំនិញ ពីគយឱ្យមានភាពសាមញ្ញ។<br>២៣.សូមស្នើឱ្យផ្តល់អាទិភាពប្រើប្រព័ន្ធបង់ប្រាក់តាមប្រព័ន្ធអ៊ីនធឺណិតមានសុវត្ថិភាព និង ការពង្រីក សមត្ថភាពប្រព័ន្ធឯកសារតាមប្រព័ន្ធអ៊ីនធឺណិតដើម្បីសម្រួលនីតិវិធីគយឱ្យកាន់តែមាន ប្រសិទ្ធភាព។ |

| | |
|---|---|
| វិស័យដឹកជញ្ជូន និងភ័ស្តុភារ | ២៤.សូមស្នើឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ធ្វើបច្ចុប្បន្នភាពនីតិវិធីដែលវិស័យឯកជនអាចលើកបញ្ហា និងស្នើឱ្យពិនិត្យមើលឡើងវិញ លើសេចក្តីសម្រេចរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ។ |

## វិស័យយានយន្ត

| | |
|---|---|
| បទប្បញ្ញត្តិសម្រាប់ការនាំចូល | ២៥.សូមស្នើឱ្យធានាថាប្រកាសលេខ ១៩០ នឹងត្រូវអនុវត្តជាសកលសម្រាប់គ្រប់យានយន្តទាំងអស់ដែលនាំចូលមកកាន់ប្រទេសកម្ពុជាដោយស្របតាមប្រកាសលេខ ៩៩។ |
| កិច្ចការពារអ្នកប្រើប្រាស់ | ២៦.សូមស្នើឱ្យនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកផ្តល់លេខអត្តសញ្ញាណយានយន្តនៃយានយន្តដែលបានចុះបញ្ជីដល់ក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ក្នុងមួយត្រីមាស ម្តងដើម្បីឱ្យក្រុមហ៊ុន អាចធ្វើការជូនដំណឹងដល់នាយកដ្ឋានក្នុងករណីដែលមានការប្រមូលផលិតផលត្រលប់មកវិញ។ |
| គោលនយោបាយសារពើពន្ធ | ២៧.សូមស្នើ ឱ្យធ្វើវិចារណកម្មលើគោលនយោបាយសារពើពន្ធសម្រាប់យានយន្តដើម្បីលើកទឹកចិត្តឱ្យមានការប្រើយានយន្តកាន់តែសមស្រប និងមិនប៉ះពាល់ដល់បរិស្ថានកម្ពុជា។ |

## វិស័យធុរកិច្ចកសិកម្ម

| | |
|---|---|
| សារធាតុហាមឃាត់ | ២៨.សូមស្នើឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំណត់បញ្ជីសារធាតុហាមឃាត់ដែលមានចែងនៅក្នុងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងផ្តល់ការធានាថាបញ្ជីនោះមានដាក់បញ្ចូលឈ្មោះថ្នាំបេតាអាហ្គូនីសផងដែរ។ |
| ការប្រយុទ្ធប្រឆាំង នឹងសម្ភារកសិកម្មខុសច្បាប់ | ២៩.ស្នើស្នើឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអនុវត្តវិធានការអនុវត្តច្បាប់ឱ្យបានតឹងរ៉ឹងនៅពេលចុះត្រួតពិនិត្យនៅតាមចំណុចចែកចាយផលិតផលសម្ភារកសិកម្ម។ |
| បទប្បញ្ញត្តិការងារ | ៣០.សូមស្នើឱ្យផ្តល់ការធានាថារាជរដ្ឋាភិបាលនឹងធ្វើការពិចារណាលើអត្ថ-ប្រយោជន៍បន្ថែម និងលក្ខខណ្ឌការងារដែលក្រុមហ៊ុនធុរកិច្ចកសិកម្មបានផ្តល់ជូនកន្លងមក នៅពេលអនុវត្តកម្មវិធីកំណែទម្រង់ការងារថ្មី។ |
| ពិពិធកម្មកសិកម្ម | ៣១.សូមពិចារណាផ្តល់ការអនុញ្ញាតឱ្យពូជស្រូវកូនកាត់អាចដាំដុះ និងចុះបញ្ជីដោយស្របច្បាប់នៅក្នុងប្រទេសកម្ពុជា។ |

ការធ្វើតេស្តបរិស្ថាន តាមលក្ខខណ្ឌតម្រូវផ្លូវច្បាប់

៣២.ស្នើសុំការបញ្ជាក់ថា តើក្រុមហ៊ុនធុរកិច្ចចាំបាច់ត្រូវប្រើមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ដើម្បីធ្វើការធ្វើតេស្តគុណភាពទឹកដែរឬទេ។

## វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

ការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល

៣៣.សូមស្នើឱ្យផ្តល់អាទិភាពដល់ការអនុម័តច្បាប់ ស្តីពីការការពារទិន្នន័យ និងឯកជនភាពនៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីមានដំណើរការពិគ្រោះយោបល់រវាងវិស័យសាធារណៈនិងវិស័យឯកជនប្រកបដោយប្រសិទ្ធភាពរួច ហើយនោះ។

៣៤.សូមស្នើឱ្យធ្វើការពិចារណា អនុវត្តគោលនយោបាយបើកចំហ ឱ្យមានប្រព័ន្ធប្តូរប្រតិបត្តិករ លេខទូរសព្ទចល័ត (mobile phone number portability) និងបណ្តាញប្រូដប៊ែន (broadband) ដើម្បីផ្តល់ជាជម្រើសកាន់តែច្រើនដល់អតិថិជន និងការប្រកួតប្រជែងកាន់តែយុត្តិធម៌នៅក្នុងវិស័យទូរគមនាគមន៍ក្នុងប្រទេសកម្ពុជា។

៣៥.សូមស្នើឱ្យលើកកម្ពស់ការចូលរួមកាន់តែច្រើនថែមទៀត ពីសំណាក់អ្នកផ្តល់សេវាបណ្តុះបណ្តាល និងវិស័យឯកជន ដើម្បីកែលម្អវគ្គបណ្តុះបណ្តាលបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងការទទួលស្គាល់ ដើម្បីដោះស្រាយបញ្ហាគម្លាតជំនាញក្នុងវិស័យនេះ។

ទូរគមនាគមន៍

៣៦.សូមស្នើឱ្យមានការបន្តរៀបចំឱ្យមានការចូលរួមនៅក្នុងការពិគ្រោះយោបល់ស៊ីជម្រៅជាមួយនឹងវិស័យឯកជនជាមុនសិន មុននឹងអនុម័តដំណើរការបន្តអាជ្ញាប័ណ្ណផ្នែកទូរគមនាគមន៍សាជាថ្មីឡើងវិញ ព្រមទាំងពិនិត្យរកឱកាសផ្តល់ការលើកទឹកចិត្តដល់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ផងដែរ។

៣៧.សូមស្នើឱ្យមានការដេញថ្លៃវិសាលគមនាពេលអនាគត អនុវត្តសម្រាប់តែការផ្តល់ជូនវិសាលគមថ្មីប៉ុណ្ណោះ និងត្រូវធានាថាមានការត្រួតពិនិត្យត្រឹមត្រូវលើអ្នកដេញថ្លៃ។

## វិស័យធុរកិច្ចបៃតង

ការរៀបចំបញ្ចប់ស្តាពរនូវក្រមបរិស្ថាន និងធនធានធម្មជាតិនៃប្រទេសកម្ពុជា

៣៨.សូមស្នើឱ្យកំណត់អាទិភាពរៀបចំបញ្ចប់ក្រមបរិស្ថាន និងធនធានធម្មជាតិកម្ពុជា។

៣៩.សូមស្នើឱ្យផ្តល់ការធានាថា ការលើកទឹកចិត្តដល់ការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ ដែលមាននៅក្នុងសេចក្តីព្រាងលើកទី១១ នៃក្រមបរិស្ថាន និងធនធានធម្មជាតិកម្ពុជា នៅតែរក្សាទុក នៅក្នុងសេចក្តីព្រាងស្តាពរ។

៤០.សូមស្នើឱ្យផ្តល់ការធានាថា លក្ខខណ្ឌតម្រូវសញ្ជាតិ សម្រាប់ក្រុមហ៊ុនប្រឹក្សាវាយតម្លៃ ហេតុប៉ះពាល់បរិស្ថាន នឹងមិនដាក់បញ្ចូលនៅក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិកម្ពុជា ស្តាពរឡើយ។

| | |
|---|---|
| ការគាំទ្រការធ្វើអន្តរកាលទៅជាសេដ្ឋកិច្ចបៃតង | *៤១.សូមស្នើឱ្យធ្វើការពិចារណាគាំទ្រ ដល់ការបង្កើតក្រុមប្រឹក្សាអគារបៃតងកម្ពុជា ដើម្បីអាចក្លាយជាសមាជិកភាពរបស់ក្រុមប្រឹក្សាអគារបៃតងពិភពលោក។* <br> *៤២.សូមស្នើឱ្យផ្តល់អាទិភាពបង្កើតកម្មវិធីជាតិដាក់ស្លាកសញ្ញាបរិស្ថាននៅកម្ពុជា។* <br> *៤៣.សូមពិចារណាពង្រីកអាទិភាព របស់ធនាគារសហគ្រាសខ្នាតតូច និងមធ្យមថ្មី ដើម្បីដាក់ បញ្ចូលការវិនិយោគ លើការអភិវឌ្ឍន៍កាបូនទាបរបស់សហគ្រាសខ្នាតតូច និងមធ្យម។* <br> *៤៤.បង្កើតលិខិតូបករណ៍សារពើពន្ធ និងមិនមែនសារពើពន្ធដើម្បីទទួលស្គាល់ ជំរុញ និងលើកទឹកចិត្តដល់គំនិតផ្តួចផ្តើមរបស់វិស័យឯកជនក្នុងការកាត់បន្ថយ ញែក និងកែច្នៃសំណល់ ឡើងវិញ។* |

## វិស័យសុខាភិបាល

| | |
|---|---|
| ការទទួលបាន ជីវផលិតផល | *៤៥.សូមស្នើឱ្យក្រសួងសុខាភិបាលពង្រីកការទទួលយកជីវផលិតផលដាក់ ក្នុងផលិតផលដែលអនុម័តដោយរដ្ឋបាលឱសថ និងចំណីអាហារ សហរដ្ឋអាមេរិក និង/ឬទីភ្នាក់ងារឱសថអឺរ៉ុប។* |
| ឱសថមិនចាំបាច់មានវេជ្ជបញ្ជា | *៤៦.សូមស្នើឱ្យបន្សើលក្ខណៈវិនិច្ឆ័យស្របច្បាប់ និងដំណើរការពាក់ព័ន្ធនឹងការចាត់ចំណាត់ថ្នាក់ផលិតផលឱសថមានវេជ្ជបញ្ជា ទៅជាផលិតផលឱសថមិនចាំបាច់មានវេជ្ជបញ្ជានៅក្នុងប្រទេសកម្ពុជាដោយស្របតាមការអនុវត្តរបស់អាស៊ាន។* |
| ការហាមឃាត់ផលិតផលមិនបានចុះបញ្ជិកា | *៤៧.សូមស្នើឱ្យផ្តល់អាទិភាពលើការបង្កើតកិច្ចសម្របសម្រួលអន្តរក្រសួងរវាងក្រសួងសុខាភិបាលនិងអគ្គនាយកដ្ឋានគយនិងរដ្ឋាករដើម្បីអនុវត្តវិធានការបន្ថែមទៀតក្នុងការទប់ស្កាត់ការនាំចូលផលិតផលឱសថ ដែលមិនបានចុះបញ្ជិកានិងមិនបានធ្វើតេស្តមកកាន់ទីផ្សារកម្ពុជា។* |

**ការចុះបញ្ជិកា និងការបន្តសុពលភាព**

៨៨.សូមស្នើឱ្យផ្តល់អាទិភាពលើការអនុវត្តប្រព័ន្ធចុះបញ្ជិកាតាមអនឡាញ (E-Registration) និងប្រព័ន្ធនាំចូលតាមអនឡាញ (E-Importation) របស់ក្រសួងសុខាភិបាល និងឱ្យវិស័យឯកជនចូលរួមនៅក្នុងដំណើរការនៃការបង្កើតកម្មវិធីទាំងនេះ។

៨៩.សូមស្នើឱ្យធ្វើការពិចារណាចេញបទប្បញ្ញត្តិ ដែលនឹងអនុញ្ញាតឱ្យមានការចុះបញ្ជិការួមសម្រាប់ឧបករណ៍បរិក្ខារពេទ្យដែលស្ថិតនៅក្នុងក្រុមនិងប្រភេទតែមួយ។

៩០.សូមស្នើឱ្យសម្រួលប្រភេទចំណាត់ថ្នាក់ និងគោលការណ៍ណែនាំ ស្តីពីការចុះបញ្ជិកាឧបករណ៍ បរិក្ខារពេទ្យ ឱ្យស្របជាមួយនឹងចំណាត់ថ្នាក់ និងគោល-ការណ៍ណែនាំដែលមានចែងក្នុងកិច្ច ព្រមព្រៀងស្តីពីឧបករណ៍បរិក្ខារពេទ្យអាស៊ាន (ASEAN Medical Device Directive)។

៩១.សូមស្នើឱ្យមានការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីគោលការណ៍ណែនាំដែលក្រុមហ៊ុនថែទាំសុខភាពត្រូវអនុវត្តតាមដើម្បីស្នើសុំការអនុញ្ញាតពីក្រសួងសុខាភិបាលសម្រាប់សកម្មភាពផ្សព្វផ្សាយផលិតផល។

៩២.សូមបញ្ជាក់ជាថ្មីអំពីបណ្តាញ (CHANNEL) ណាមួយសម្រាប់ឱ្យក្រុមហ៊ុនដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណនាំចូលបន្ទាន់សម្រាប់ផលិតផលដែលកំពុងរង់ចាំការសុំបន្តសុពលភាព ឬការចុះបញ្ជិកា តាមរយៈការអនុវត្តដំណើរការដាក់ពាក្យសុំផ្លូវការ ដែលមានគោលការណ៍ណែនាំច្បាស់ លាស់បង្ហាញអំពីលក្ខខណ្ឌតម្រូវនៃការទទួលបានអាជ្ញាប័ណ្ណនេះ។

៩៣.សូមស្នើឱ្យគណៈកម្មការបញ្ជិកា និងបន្តសុពលភាពរបស់ក្រសួងសុខាភិបាលរៀបចំកិច្ចប្រជុំឱ្យ បានយ៉ាងតិចណាស់ម្តងក្នុងមួយខែ ដោយយោងតាមកាល-វិភាគដាក់លាក់ដែលបានផ្សព្វផ្សាយ។

# វិស័យអចលនទ្រព្យ និងសំណង់

**ការអភិវឌ្ឍវិស័យសុរិយោដី និងអចលនទ្រព្យ**

៩៤.សូមស្នើឱ្យធ្វើការពិចារណា លើការកំណត់ជាលក្ខខណ្ឌតម្រូវឱ្យអ្នកពិគ្រោះយោបល់ទាំងអស់ ដែលចូលរួមក្នុងគម្រោងសាងសង់នៅក្នុងប្រទេសកម្ពុជាត្រូវតែមានធានារ៉ាប់រងទំនួលខុសត្រូវស៊ីវិលជាកាតព្វកិច្ច។

៩៥.សូមស្នើឱ្យមានការដាក់ចេញនូវស្តង់ដារជាសកល សម្រាប់ការវាស់វែងនៅក្នុងវិស័យអចលនទ្រព្យ។

៩៦.សូមស្នើឱ្យធ្វើការពិចារណាបង្កើនការគ្រប់គ្រងហិរញ្ញវត្ថុ ដែលបង្កើតឡើងសម្រាប់គម្រោងអភិវឌ្ឍន៍លំនៅដ្ឋាន ដោយស្របតាមការអនុវត្តរបស់បណ្តាប្រទេសសមាជិកអាស៊ានផ្សេងទៀត ដើម្បីផ្តល់នូវកិច្ចការពារគ្រប់គ្រាន់ដល់អតិថិជន នៅក្នុងករណីដែលគម្រោងដួលរលំ។

**ការរៀបចំដែនដី និងនគរូបនីយកម្ម**

៩៧.សូមស្នើឱ្យផ្តល់អាទិភាពដល់ការអនុម័តក្របខ័ណ្ឌច្បាប់ថ្មីសម្រាប់ការអភិវឌ្ឍនិងការ គ្រប់គ្រងតំបន់ឆ្នេរ និងសូមស្នើឱ្យធ្វើការពិចារណាអនុញ្ញាតឱ្យមាន "គម្រោងគំរូ" ដើម្បី បង្ហាញដល់វិនិយោគិនថា ការអភិវឌ្ឍតំបន់ឆ្នេរទៅតាមស្តង់ដារអន្តរជាតិ គឺជាលទ្ធភាពមួយដែលអាចធ្វើបាននៅក្នុងប្រទេសកម្ពុជា។

---

**ការធ្វើទំនើបកម្មបទប្បញ្ញត្តិស្តីពីអចលនទ្រព្យលំនៅដ្ឋាន**

៥៨.សូមស្នើឱ្យមានការបញ្ជាក់ច្បាស់លាស់ អំពីដំណើរការបំលែងអគារស្នាក់នៅដែលបានសាងសង់ឡើងនៅមុនពេលចេញអនុក្រឹត្យលេខ ១២៦ ទៅជាចំណែកឯកជននៅក្នុងអគារ សហកម្មសិទ្ធិ និងបញ្ជាក់អំពីវិធីសាស្ត្រដែលម្ចាស់អចលនទ្រព្យអាចស្នើសុំប័ណ្ណកម្មសិទ្ធិរួមថ្មី រៀងៗខ្លួន។

៥៩.សូមស្នើឱ្យអនុម័តបទប្បញ្ញត្តិ ដែលអនុញ្ញាតឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ ចាត់ចែងទីធ្លាចំណតយានយន្តនៅក្នុងបរិវេណខុនដូជាចំណែកឯកជន និង អនុញ្ញាតឱ្យមានការចេញប័ណ្ណសម្គាល់កម្មសិទ្ធិឯកជនសម្រាប់ចំណតយានយន្ត។

៦០.សូមស្នើឱ្យធ្វើការពិចារណាអនុម័តក្របខ័ណ្ឌនិយ័តកម្ម ដើម្បីគ្រប់គ្រងលើវិស័យគ្រប់គ្រង អចលនទ្រព្យនៅកម្ពុជា និងស្នើឱ្យពិគ្រោះយោបល់ជាមួយនឹងវិស័យឯកជនដើម្បីបង្កើតជាសំណុំឯកសារបទដ្ឋាននីតិវិធីប្រតិបត្តិ។

៦១.សូមស្នើឱ្យផ្តល់អាទិភាព ដល់ការបង្កើតឌីជីថលនីយកម្ម នៃដំណើរការផ្ទេរកម្មសិទ្ធិអចលន ទ្រព្យតាមរយៈការដាក់ឱ្យដំណើរការកម្មវិធីតាមប្រព័ន្ធអនឡាញ។

---

**វិស័យសំណង់**

៦២.សូមស្នើឱ្យពិគ្រោះយោបល់ជាមួយវិស័យឯកជន ដើម្បីធានានូវការបង្កើតសំណុំស្តង់ដារ អគារ ដែលមានលក្ខណៈប្រាកដប្រជា។

៦៣.សូមស្នើថាមុនពេលមានការអនុម័តក្រមសាងសង់អគារ (Building Code) គប្បីមានការពិគ្រោះយោបល់ជាមួយនឹងផ្នែកឯកជនជាមុនសិន ដើម្បីកំណត់លក្ខណៈវិនិច្ឆ័យអន្តរការី សម្រាប់សុវត្ថិភាពអគ្គិភ័យ ដែលនឹងបង្កើតបានជាមូលដ្ឋានសម្រាប់អធិការកិច្ច និងដំណើរការអនុម័ត ដោយស្របតាមលក្ខខណ្ឌតម្រូវកំណត់ដោយប្រកាសលេខ ៨៧។

៦៤.សូមស្នើកំណត់លក្ខខណ្ឌតម្រូវឱ្យគ្រប់ក្រុមហ៊ុនសំណង់ទាំងអស់ដែលប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាត្រូវតែមានបុគ្គលិកផ្នែកសុវត្ថិភាព ដែលទទួលបានការបណ្តុះបណ្តាលអំពីសុខភាព និងសុវត្ថិភាពការងារដែលតម្រូវដោយច្បាប់មុនពេលចាប់ផ្តើមគម្រោងថ្មី។

៦៥.សូមស្នើឱ្យពិចារណាអនុវត្តបទប្បញ្ញត្តិ ដែលតម្រូវឱ្យសម្ភារសំណង់គ្រឿងបង្គុំអគារដែល ផលិតនៅក្នុងប្រទេសកម្ពុជា ត្រូវឆ្លងកាត់ការធ្វើតេស្តធានាគុណភាពឯករាជ្យជាមុនសិនមុននឹងដាក់លក់នៅលើទីផ្សារ។

# ការឆ្លើយតបទៅនឹងអនុសាសន៍ ឆ្នាំ២០១៧-២០១៨

*សេចក្តីសង្ខេបអំពីការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះអនុសាសន៍គោលនយោបាយក្នុងឆ្នាំ២០១៧ និង ឆ្នាំ២០១៨។*

## វិស័យការពារការវិនិយោគ

**យន្តការពិនិត្យផ្លូវច្បាប់ឡើងវិញ**

១. *ការបង្កើតយន្តការពិនិត្យឡើងវិញ មានលក្ខណៈឯករាជ្យ នៅតាមក្រសួង និងស្ថាប័នសាធារណៈពាក់ព័ន្ធ ដែលទទួលខុសត្រូវក្នុងការចាត់ការ និងធ្វើសេចក្តីសម្រេចលើពាក្យស្នើសុំរបស់អង្គភាពឯកជននឹងបង្កើតតុលាការរដ្ឋបាលកំពូលមួយផង។*

មិនទាន់មាន ការឆ្លើយតប

២. *សូមធានាឲ្យបានថា ច្បាប់និងបទប្បញ្ញត្តិថ្មីៗ ចាំបាច់ត្រូវមានប្រការអន្តរកាលជាក់ស្តែង ហើយលិខិតូបករណ៍ថ្មីៗ ក៏មិនត្រូវយកមកអនុវត្តបែបប្រតិសកម្មឡើយក្នុងការពិន័យអន្តរកាលចំពោះការមិនអនុលោមតាមច្បាប់។*

មិនទាន់មាន ការឆ្លើយតប

**ការរៀបចំតាក់តែងច្បាប់ថ្មី**

៣. *សូមផ្តល់អាទិភាពដល់ការធ្វើច្បាប់ ស្តីពីកិច្ចសន្យាពាណិជ្ជកម្មសម្រាប់ជួលអគារធ្វើស្នាក់ការ បន្ទាប់ពីមានការពិគ្រោះយោបល់ប្រកបដោយផ្លែផ្កាជាមួយវិស័យឯកជន។*

មិនទាន់មាន ការឆ្លើយតប

៤. *សូមធ្វើការពិគ្រោះយោបល់ជាមួយវិស័យឯកជនដើម្បីធ្វើច្បាប់ស្តីពីការប្រកួតប្រជែងមួយ ដែលមានលក្ខណៈច្បាស់លាស់ ហើយគ្រប់ជ្រុងជ្រោយជាងសេចក្តីព្រាងដែលមានក្នុងពេលបច្ចុប្បន្ន។*

ការឆ្លើយតប

ក្រសួងពាណិជ្ជកម្មកំពុងខិតជិតដល់ដំណាក់កាលបញ្ចប់ការរៀបចំច្បាប់ស្តីពីការប្រកួតប្រជែងរបស់ប្រទេសកម្ពុជា ដែលសេចក្តីព្រាងស្ពាពរនៃច្បាប់នេះកំពុងស្ថិតក្រោមការពិនិត្យមើលឡើងវិញដោយគណៈរដ្ឋមន្ត្រី និងក្រុមប្រឹក្សា អ្នកច្បាប់ ហើយមានការរំពឹងថាច្បាប់នេះនឹងត្រូវអនុម័តនៅក្នុងឆ្នាំ២០១៩ នេះ។

៥. *សូមផ្តល់ការធានាការលើកទឹកចិត្តនិងជំនួយច្រើនជាងមុនដល់វិនិយោគិនតាមរយៈច្បាប់វិនិយោគថ្មីដោយរួមបញ្ចូលអនុសាសន៍ពីវិស័យឯកជនផង។*

ការឆ្លើយតប

*បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកំពុងរៀបចំធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌច្បាប់ ដើម្បីគ្រប់គ្រងការវិនិយោគបរទេស និងក្នុងស្រុក នៅក្នុងប្រទេសកម្ពុជា តាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពីការវិនិយោគ និងការបង្កើតច្បាប់ថ្មីស្តីពីតំបន់សេដ្ឋកិច្ចពិសេស។ តាមរយៈវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ដែលបានធ្វើឡើងនៅក្នុងខែមីនា ឆ្នាំ២០១៩ ក៏មានការបញ្ជាក់ផងដែរថាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាស្ថាប័នដឹកនាំដំណើរការនេះបានបង្ហាញការប្តេជ្ញាចិត្តបញ្ចប់ជាស្ថាពរនូវសេចក្តីព្រាងវិសោធនកម្មច្បាប់នេះឱ្យបានត្រឹមចុងខែមិថុនា ឆ្នាំ២០១៩ នេះ បន្ទាប់មកនឹងត្រូវបញ្ជូនទៅកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យមើលរួច ទើបបញ្ជូនទៅកាន់គណៈរដ្ឋមន្ត្រី និងក្រុមប្រឹក្សាអ្នកច្បាប់។*

## ការការពារកម្មសិទ្ធិបញ្ញា

៦. *សូមធ្វើការផ្សព្វផ្សាយបញ្ជីពាក្យស្នើសុំចុះបញ្ជីម៉ាកពាណិជ្ជសញ្ញាថ្មីជាមុនសិនមុននឹងធ្វើសេចក្តីសម្រេចលើពាក្យស្នើសុំនីមួយៗ។*

ការឆ្លើយតបមិនទាន់មាន

៧. *សូមបង្កើតក្របខ័ណ្ឌច្បាប់ពិស្តារមួយ ដើម្បីបង្កលក្ខណៈឲ្យមានវិធានការបណ្តោះអាសន្នកាន់តែរឹងមាំក្នុងការការពារកម្មសិទ្ធិបញ្ញា។*

ការឆ្លើយតប

*ដោយអនុវត្តតាមកិច្ចព្រមព្រៀងរវាងប្រទេសកម្ពុជា និងស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប (EPO) ដែលបានចុះកាលពីខែមករា ឆ្នាំ២០១៧ ការទទួលស្គាល់សុពលភាពនៃកិច្ចព្រមព្រៀងប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនេះបានចូលជាធរមាននៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ដែលធ្វើឱ្យប្រទេសកម្ពុជា ក្លាយជាប្រទេសអាស៊ីដំបូងគេបង្អស់ដែលផ្តល់សុពលភាពដល់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប។ ប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលផ្តល់ដោយស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប និងត្រូវផ្តល់សុពលភាពនៅកម្ពុជា នឹងមានសុពលភាពផ្លូវច្បាប់ដូចគ្នាទៅនឹងប្រកាសនីយបត្រតក្កកម្មរបស់កម្ពុជា និងអនុលោមតាមច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មកម្ពុជាដែរ។*

៨. *សូមផ្តល់សិទ្ធិអំណាចផ្នែករដ្ឋបាលថែមទៀត ដល់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដើម្បីទប់ស្កាត់ការហូរចូលទំនិញក្លែងក្លាយ និងទំនិញនាំចូលលួចលាក់មកក្នុងប្រទេសកម្ពុជា។*

ការឆ្លើយតប

*ដើម្បីលើកកម្ពស់ការប្រកួតប្រជែង និងកាត់បន្ថយថ្លៃចំណាយនៅក្នុងដំណើរការអាជីវកម្ម អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ អាហារីណ ទីហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្មកម្ពុជា ត្រូវបានដកកាតព្វកិច្ច មិនឱ្យធ្វើការត្រួតពិនិត្យនៅតាមច្រកព្រំដែន កំពង់ផែសមុទ្រ តំបន់សេដ្ឋកិច្ចពិសេស និងតំបន់ត្រួតពិនិត្យផ្សេងទៀត។ ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ តទៅ អគ្គនាយកដ្ឋានគយ និងរដ្ឋាករបានក្លាយជាស្ថាប័នរដ្ឋបាលតែមួយគត់ដែលមានសិទ្ធិក្នុងការត្រួតពិនិត្យទំនិញនៅតាមច្រកចូលមកកាន់ប្រទេសកម្ពុជា។*

៩. *សូមពិគ្រោះយោបល់ជាមួយវិស័យឯកជន ដើម្បីបង្កើតលិខិតូបករណ៍ផ្លូវច្បាប់សម្រាប់រកដំណោះស្រាយជាក់លាក់ ក្នុងការផ្ដល់សំណងចំពោះការខូចខាតធុរកិច្ចក្នុងករណីរំលោភកម្មសិទ្ធិបញ្ញា។*

គ្មានការឆ្លើយតប

១០. *សូមស្នើប្រែក្លាយវិធីដោះស្រាយវិវាទដំហានដំបូង ក្រៅប្រព័ន្ធតុលាការ (Preliminary Alternative Disputes Resolution) ឲ្យទៅជានីតិវិធីផ្លូវការសម្រាប់ប្រើនៅតាមក្រសួងពាក់ព័ន្ធ ក្នុងការស្វែងរកដំណោះស្រាយករណីរំលោភកម្មសិទ្ធិបញ្ញា។*

ការឆ្លើយតប

*ក្រសួងពាណិជ្ជកម្មកំពុងរៀបចំសេចក្ដីព្រាងប្រកាសថ្មីមួយ ដើម្បីបង្កើតក្រុមប្រឹក្សាដោះស្រាយបណ្ដឹងតវ៉ា ជាពិសេសដើម្បីដោះស្រាយបណ្ដឹងតវ៉ានឹងសិទ្ធិកម្មសិទ្ធិបញ្ញានៅពេលដែលភាគីពាក់ព័ន្ធណាមួយមិនពេញចិត្តចំពោះសេចក្ដីសម្រេចរបស់ស្ថាប័នចុះបញ្ជីកាពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជសញ្ញារបស់ខ្លួន។*

# វិស័យធនធានមនុស្ស

## ការគាំទ្រដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច

១១. *សូមគាំទ្រឲ្យមានការប្រើប្រាស់ទូលំទូលាយ នូវយន្តការ ការចរចាអនុសញ្ញារួម ដើម្បីបកស្រាយច្បាប់ការងារនៅកម្រិតឧស្សាហកម្ម។*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែមេសា ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានបញ្ជាក់ជាថ្មីម្ដងទៀតថាសហជីពត្រូវដាក់ពាក្យសុំការទទួលស្គាល់ថាជាសហជីព «ដែលមានភាពជាតំណាងបំផុត» ទើបអាចតំណាងឱ្យកម្មករនិយោជិតនៅក្នុងអនុសញ្ញារួមដោយស្របតាមច្បាប់ស្ដីពីសហជីព។ ក្រសួងក៏បានបញ្ជាក់ផងដែរថា គិតត្រឹមខែមេសា ឆ្នាំ២០១៨ មិនមានសហជីពណាមួយបានដាក់ពាក្យសុំ ឬត្រូវបានទទួលស្គាល់ថា «មានភាពជាតំណាងបំផុត» ដោយស្របតាមការបកស្រាយរបស់ក្រសួងនោះទេ។*

### ការជួល និយោជិតបរទេស

១២.

*សូមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុញ្ញាតឲ្យនិយោជកដាក់ ជូនច្បាប់ចម្លងផ្លូវការនៃកិច្ចសន្យាការងារជាភាសាខ្មែរ របស់គេជាមួយនិយោជិតបរទេសជំនួសឲ្យការបំពេញទម្រង់បែបបទកិច្ចសន្យាការងារដែលក្រសួងកំណត់ឲ្យប្រើ។*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែមេសា ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ថានិយោជកមិនត្រូវបានតម្រូវឱ្យដាច់ខាតត្រូវតែប្រើទម្រង់កិច្ចសន្យាការងារកំណត់ជាមុនសម្រាប់និយោជិតបរទេសដែលបានផ្តល់ជូនដោយនាយកដ្ឋានមុខរបរ និងហត្ថពលកម្មនោះទេ ផ្ទុយទៅវិញទម្រង់នេះត្រូវបានប្រើប្រាស់ក្នុងគោលបំណងជាគំរូបទដ្ឋានអប្បបរមាដែលបានតម្រូវតែប៉ុណ្ណោះ។ ជាគោលការណ៍ ទោះបីជាការស្រាយបញ្ជាក់នេះមានខ្លឹមសារដូចគ្នាទៅនឹងការបកស្រាយច្បាប់របស់ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាក៏ដោយ ក៏ប៉ុន្តែសមាជិករបស់យើងបានរាយការណ៍ថា មិនមានការអនុវត្តដូចដែលបានលើកឡើងនេះទេ ហើយនិយោជកត្រូវតែបន្តប្រើប្រាស់ទម្រង់របស់ក្រសួងដដែល។*

### គិលានដ្ឋាននៅតាម សហគ្រាសធុរកិច្ច

១៣.

*សូមកែសម្រួលឡើងវិញ នូវតម្រូវការឲ្យធុរកិច្ច ដែលប្រើប្រាស់កម្មករនិយោជិតលើសពី៥០នាក់ឡើងទៅ ថាត្រូវតែមានគិលានដ្ឋានប្រចាំកានៅនឹងគ្រឹះស្ថានរបស់ខ្លួន។*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែមេសា ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលស្គាល់ថាទោះបីជាច្បាប់ស្តីពីការងារតម្រូវឱ្យធុរកិច្ចដែលមានកម្មករនិយោជិតចាប់ ៥០ នាក់ឡើងទៅ ត្រូវតែមានគិលានដ្ឋានតាមសហគ្រាសផ្ទាល់ខ្លួនក្តី ប៉ុន្តែកត្តានេះនឹងជះឥទ្ធិពលដល់វិស័យឯកជននៅពេលដែលសេដ្ឋកិច្ចប្រទេសកម្ពុជាមានការរីកចម្រើនជាងនេះ។ ដោយសារតែនៅក្នុងច្បាប់ស្តីពីការងារមានចែងអំពីលក្ខខណ្ឌតម្រូវនេះ យើងមិនអាចពិនិត្យមើលឡើងវិញលើប្រការនេះ ដោយមិនមានការធ្វើវិសោធនកម្មច្បាប់ស្តីពីការងារជាមុនបានឡើយ។ ក្រសួងមានគោលបំណងពិចារណា និងពិភាក្សាបន្ថែមនៅកម្រិតបច្ចេកទេសជាមួយនឹងមន្ត្រីជំនាញផ្នែកសុខភាព និងសុវត្ថិភាពនៅកន្លែងការងារ។*

### ជំនាញនិង ការបណ្តុះបណ្តាល

១៤.

*សូមគាំទ្រដល់វិស័យឯកជន ក្នុងការចូលរួមបង្កើតក្របខ័ណ្ឌគុណវុឌ្ឍិជាតិសម្រាប់ការអប់រំបច្ចេកទេសវិជ្ជាជីវៈ និងការបណ្តុះបណ្តាល នៅកម្រិតឧស្សាហកម្ម។*

ការឆ្លើយតប

*ពង្រឹងបន្ថែមទៅលើជំហានវិជ្ជមានជាច្រើនដែលរាជរដ្ឋាភិបាលបានអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន ប្រទេសកម្ពុជាដោយសហការជាមួយប្រទេសថៃ បានជ្រើសរើសការងារអាទិភាពចំនួនពីរសម្រាប់ការ អនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់ជំនាញគ្នាទៅវិញទៅមក (MRS) គឺការងារកំបោរ និងការតបណ្តាញអគ្គិសនីក្នុងអគារ។ អង្គការពលកម្មអន្តរជាតិ បានដាក់សំណើសុំមូលនិធិដើម្បីធានាឱ្យមានការគាំទ្រជាប្រចាំដល់គម្រោងនេះពីសាធារណៈរដ្ឋកូរ៉េ បន្ទាប់មកនឹងអនុវត្តផែនការសកម្មភាពថ្មីដើម្បីបន្តអនុវត្ត កិច្ចព្រមព្រៀងទទួលស្គាល់ជំនាញគ្នាទៅវិញទៅមក (MRS) រវាងប្រទេសកម្ពុជា និងថៃជាបន្តបន្ទាប់ទៀត។*

១៥. *ធានាធ្វើយ៉ាងណាឲ្យជំនាញដែលទទួលបានតាមរយៈការរៀនចេះក្រៅប្រព័ន្ធ និងមិនផ្លូវការមានការទទួលស្គាល់ ហើយត្រូវបានដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌនេះដែរ។*

គ្មានការឆ្លើយតប

## ការប្រាស្រ័យទាក់ទងរវាងស្ថាប័នសាធារណៈ និងវិស័យឯកជន

១៦. *សូមផ្តល់ការគាំទ្របន្ថែមទៀត ដល់វិស័យឯកជនក្នុងការព្យាយាមបង្កើនការយល់ដឹងអំពីច្បាប់ និងបទប្បញ្ញត្តិថ្មីៗ។*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែមេសា ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានលើកឡើងអំពីដំណើរការការងារកំពុងបន្តរបស់ក្រសួងនៅក្នុងការដោះស្រាយបញ្ហានេះតាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពជូនមន្រ្តីអធិការកិច្ចការងារ ដែលវគ្គបណ្តុះបណ្តាលបន្ថែមទៀតក៏បានគ្រោងនឹងធ្វើឡើង នៅពេលអនាគតផងដែរ។ ស្របជាមួយនឹងកិច្ចខិតខំប្រឹងប្រែងបូរេសកម្ម ដើម្បីជំរុញឱ្យមានការដាក់ពាក្យសុំកូតា និងប័ណ្ណការងារជនបរទេសតាមប្រព័ន្ធអនឡាញ បច្ចុប្បន្ននេះក្រសួងបានដាក់បញ្ចូលច្បាប់ បទប្បញ្ញត្តិ និងទម្រង់បែបបទពាក់ព័ន្ធនៅលើវេបសាយត៍របស់ខ្លួនដើម្បីងាយស្រួលផ្សព្វផ្សាយព័ត៌មានទាំងនេះ និងផ្តល់លទ្ធភាពទទួលបានព័ត៌មានកាន់តែល្អប្រសើរថែមទៀត។*

## តម្រូវការការហ្វឹកហ្វឺន

១៧. *សូមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើការបោះពុម្ពផ្សាយគោលការណ៍ណែនាំអនុវត្តជាក់ស្តែង ដោយមានការណែនាំច្បាស់លាស់ផង សម្រាប់និយោជកយកទៅអនុលោមតាមតម្រូវការរបស់ក្រសួង ក្នុងការហ្វឹកហ្វឺនកូនជាង។*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែមេសា ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ជាថ្មីម្តងទៀតអំពីលក្ខខណ្ឌសម្រាប់ការហ្វឹកហ្វឺនកូនជាងដែលមានចែងនៅក្នុងច្បាប់ស្តីពីការងារ ដែលចែងថាសហគ្រាសដែលមានកម្មករនិយោជិតច្រើនជាង ៦០ នាក់ ត្រូវតែមានកូនជាងនៅក្នុង ចំនួនភាគរយជាក់លាក់ណាមួយនៃចំនួនកម្មករនិយោជិតសរុបនៅក្នុងសហគ្រាសនោះ។ ដើម្បីពង្រឹងការអនុវត្តប្រកាសលេខ ០០៤ ក្រសួងបានផ្តល់ការណែនាំជាក់លាក់សម្រាប់សហគ្រាស អំពីកាតព្វកិច្ចពាក់ព័ន្ធនឹងកម្មវិធីហ្វឹតហ្វឺនកូនជាងដើម្បីជៀសវាងកុំឱ្យរងទណ្ឌកម្មពិន័យណាមួយ តាមរយៈសេចក្តីណែនាំលេខ ៤២/១៥។*

១៨. *សូមក្រសួងកុំធ្វើការផាកពិន័យដល់ធុរកិច្ចលើបញ្ហានេះមុននឹងក្រសួងចេញផ្សាយគោលការណ៍ណែនាំអនុវត្តជាក់ស្តែង ហើយធ្វើយ៉ាងណាក៏កុំឲ្យមានការផាកពិន័យជាប្រតិសកម្មជុំវិញបញ្ហានេះដែរ។*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែមេសា ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ច្បាស់លាស់ថាមានការពិន័យទៅលើសហគ្រាសទាំងឡាយណាដែលមិនអនុលោមតាមលក្ខខណ្ឌតម្រូវសម្រាប់ហ្វឹកហ្វឺនកូនជាងដូចមានចែងនៅក្នុងច្បាប់ស្តីពីការងារ។*

*ការពិន័យពាក់ព័ន្ធនឹងការមិនអនុលោមតាមប្រការនេះគឺត្រូវរង ពិន័យជាប្រាក់ចំនួន ១.៦៨.០០០ រៀល (ប្រហាក់ប្រហែលនឹង ៤៥០ ដុល្លារអាមេរិក)។ ជាជម្រើស សហគ្រាសអាចស្នើសុំការលើកលែងការពិន័យនេះ តាមរយៈការបង់ពន្ធអាករសម្រាប់ការហ្វឹកហ្វឺនកូនជាង ដែលស្មើនឹង ១% នៃប្រាក់បៀវត្សប្រចាំឆ្នាំរបស់និយោជិតទាំងអស់។*

## វិស័យពន្ធដារ

• • • • •

ការគាំទ្រដល់ក្រុមហ៊ុនដែលគោរពកាតព្វកិច្ចពន្ធនៅក្នុងដំណើរការរៀបចំប្រព័ន្ធសារពើពន្ធជាផ្លូវការ

១៩. *សូមកែសម្រួលឡើងវិញ នូវបទប្បញ្ញត្តិពន្ធកាត់ទុក ដើម្បីជួយសម្រាលបន្ទុកអម្រែករបស់បណ្តាធុរកិច្ចដែលអនុលោមសារពើពន្ធត្រឹមត្រូវ។*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែមេសា ឆ្នាំ២០១៨ អគ្គនាយកដ្ឋានពន្ធដារ បានបង្ហាញការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការរក្សាទុកប្រព័ន្ធពន្ធកាត់ទុកនៅក្នុងប្រទេសកម្ពុជា ដោយលើកឡើងថានេះគឺជាការអនុវត្តទូទៅ នៅតាមបណ្តាប្រទេសផ្សេងៗដែលមានស្ថានភាពអភិវឌ្ឍន៍ប្រហាក់ប្រហែលគ្នានឹងប្រទេសកម្ពុជាដែរ។ អគ្គនាយកដ្ឋានពន្ធដារ ក៏បានបញ្ជាក់ច្បាស់លាស់ដោយឯកភាពជាមួយនឹងសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាថានៅក្នុងវិក្កយបត្រក្រុមហ៊ុនផ្គត់ផ្គង់ ត្រូវតែបញ្ជាក់អំពីភាពខុសគ្នាឱ្យបានច្បាស់លាស់រវាងតម្លៃផលិតផល និងតម្លៃសេវាកម្ម ហើយថាពន្ធកាត់ទុកត្រូវអនុវត្តចំពោះតែសមាសភាគសេវាកម្មប៉ុណ្ណោះ។ អគ្គនាយកដ្ឋា នពន្ធដារ មិនអាចផ្តល់បញ្ជីសេវាកម្មដែលអនុគ្រោះពន្ធពីការតម្រូវឱ្យបង់ពន្ធកាត់ទុកបាននោះទេ ដោយសារតែច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត មិនមានចែងបញ្ញត្តិឱ្យធ្វើបែបនេះឡើយ។*

២០.

> *សូមបញ្ឈប់ការអនុវត្តការយកពន្ធកាត់ទុកផង និងអាករលើតម្លៃបន្ថែមផង លើការជួលទ្រព្យពីក្រុមហ៊ុន។*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា កាលពីខែមេសា ឆ្នាំ២០១៨ អគ្គនាយកដ្ឋានពន្ធដារបានបញ្ជាក់ថាសម្រាប់អចលនទ្រព្យជួល ភាគីម្ចាស់ទ្រព្យត្រូវទទួលខុសត្រូវបង់ពន្ធកាត់ទុក ចំណែកភាគីជួលត្រូវទទួលខុសត្រូវបង់ថ្លៃសេវាអាករ លើតម្លៃបន្ថែម។ រាល់អាករលើតម្លៃបន្ថែមដែលបានបង់ជូនត្រូវបានចាត់ទុកជាឥណទានអាករជាតុចូលពន្ធប្រចាំ ហើយពន្ធកាត់ទុកក៏ជាឥណទានអាកររបស់ភាគីម្ចាស់ទ្រព្យ ដើម្បីកាត់កងជាមួយពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។ ប៉ុន្តែការឆ្លើយតបរបស់ពួកគាត់ មិនយោងទៅតាមលក្ខខណ្ឌពាក់ព័ន្ធនឹងការជួលអចលនទ្រព្យពីក្រុមហ៊ុនចុះបញ្ជីនោះទេ។*

២១.

> *សូមធ្វើការស្រាយបំភ្លឺអំពីការទទួលខុសត្រូវ ចំពោះពន្ធកាត់ទុកនៅពេលបង់ប្រាក់សម្រាប់ថ្លៃសេវាគ្រប់គ្រង និងបច្ចេកទេសឲ្យអ្នកជាប់ពន្ធអនិវាសនជន។*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែមេសា ឆ្នាំ២០១៨ អគ្គនាយកដ្ឋានពន្ធដារបានបង្ហាញ គោលបំណងរបស់ខ្លួនក្នុងការចេញសេចក្តីណែនាំជាក់លាក់ អំពីឯកសារតម្រូវដែលសហគ្រាសត្រូវដាក់ជូនជាឯកសារគាំទ្រ ដើម្បីបញ្ជាក់ថាសេវាកម្មរបស់ខ្លួនពិតជាត្រូវបានប្រើប្រាស់នៅក្រៅប្រទេសពិតមែនដើម្បីអាចបំពេញទំនួលខុសត្រូវពន្ធសមស្របប៉ុន។ លុះត្រាតែសេចក្តីណែនាំដែលនឹងចេញក្នុងពេលខាងមុខនេះ មានចែងជាក់លាក់អំពីការទូទាត់ដែលបានធ្វើឡើងសម្រាប់សេវាគ្រប់គ្រង និងសេវាបច្ចេកទេសដល់អ្នកជាប់ពន្ធអនិវាសនជន និងបញ្ជាក់អំពីលក្ខខណ្ឌពន្ធកាត់ទុកផ្សេងពីនេះ ទើបអនុសាសន៍នេះអាចដោះស្រាយបញ្ហានេះបាន។*

## អាករលើតម្លៃបន្ថែម

២២.

> *សូមផ្តល់ការណែនាំឲ្យបានជាក់លាក់ថែមទៀត អំពីតម្រូវការបង់អាករលើតម្លៃបន្ថែមសម្រាប់សេវាដែលត្រូវបាននាំចេញ។*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែមេសា ឆ្នាំ២០១៨ អគ្គនាយកដ្ឋានពន្ធដារបានបង្ហាញគោលបំណងរបស់ខ្លួន ក្នុងការចេញសេចក្តីណែនាំជាក់លាក់អំពីឯកសារតម្រូវដែលសហគ្រាសត្រូវដាក់ជូនជាឯកសារគាំទ្រ ដើម្បីបញ្ជាក់ថាសេវាកម្មរបស់ខ្លួនពិតជាត្រូវបានប្រើប្រាស់នៅក្រៅប្រទេសពិតមែនដើម្បីអាចអនុវត្តអត្រាអាករលើតម្លៃបន្ថែម ០% បាន។ លុះត្រាតែសេចក្តីណែនាំដែលចេញនាពេលខាងមុខលើកឡើងអំពីអត្ថន័យនៃសេវាកម្ម ដែលត្រូវបាន "ប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា" ហើយថាការអនុវត្តអាករលើតម្លៃបន្ថែមលើសេវានាំចេញត្រូវតែស្របតាមទម្លាប់ការងារបច្ចុប្បន្ន ទើបអនុសាសន៍នេះអាចដោះស្រាយបញ្ហានេះបាន។*

២៣.

> *សូមអនុញ្ញាតឲ្យធុរកិច្ចដែលធ្វើការផ្គត់ផ្គង់ទំនិញ និងសេវាជាប់ពន្ធ និងរួចពន្ធ ឲ្យទទួលបានការកាត់កង១០០% នៃអាករលើធាតុចូល ដែលបានបង់ហើយ ជាមួយនឹងអាករលើធាតុចេញដែលរដ្ឋប្រមូលបាន។*

ការឆ្លើយតប

*តាមរយៈការឆ្លើយតបទៅនឹងអនុសាសន៍លើកមុនរបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា អគ្គនាយដ្ឋានពន្ធដារ បានផ្តល់ការពន្យល់លម្អិតអំពីបទប្បញ្ញត្តិបច្ចុប្បន្នពាក់ព័ន្ធនឹងបញ្ហានេះ ដោយយោងទៅរកអនុក្រឹត្យលេខ ១១៤ ស្តីពីអាករលើតម្លៃបន្ថែម ចុះនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ មាត្រា ៣២ ដល់ ៤០។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះការបញ្ជាក់នេះ និងយល់ស្របថាបទប្បញ្ញត្តិដែលមានស្រាប់ គឺមានភាពច្បាស់លាស់ និងជាក់លាក់។ សម្រាប់ករណីនេះ យើងនៅតែរក្សាគោលជំហរថាខ្លឹមសារនៃបទប្បញ្ញត្តិទាំងនេះ ដាក់បន្ទុកបន្ថែមទៅលើក្រុមហ៊ុនដែលមានបរិមាណលក់ភាគច្រើន ទៅឱ្យអតិថិជនដែលត្រូវបានអនុគ្រោះពន្ធ ដែលក្នុងន័យនេះក្រុមហ៊ុនទាំងនេះត្រូវបង់អាករលើតម្លៃបន្ថែមក្នុងអត្រាខ្ពស់ជាងក្រុមហ៊ុនផ្សេងទៀត។*

២៤.

> *សូមធ្វើយ៉ាងណាសម្រួលឲ្យធុរកិច្ចដែលបំពេញបានតាមតម្រូវការបែបបទឯកសាររបស់អគ្គនាយកដ្ឋានពន្ធដារ មានលទ្ធភាពទទួលការទូទាត់សងអាករលើតម្លៃបន្ថែមវិញឲ្យបានទាន់ពេលវេលានិងជាប់ដោយឡែកដោយមិនចាំបាច់គិតថាតើអ្នកផ្គត់ផ្គង់ទំនិញបានអនុលោមតាម ត្រឹមត្រូវ ឬអត់ នៅក្នុងឯកសារ និងវិក្កយបត្របង់ប្រាក់ដែលគេបានដាក់ជូនអគ្គនាយកដ្ឋានពន្ធដារ។*

បានដោះស្រាយរួចហើយ

*នៅក្នុងខែមិថុនា ឆ្នាំ២០១៨ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាសលេខ ៥៧៦ និងប្រកាសលេខ ៥៧៧ ដើម្បីធ្វើការបង្វិលសងអាករលើតម្លៃបន្ថែមប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលចំពោះក្រុមហ៊ុននានាដែលជាអ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធតូច។*

*បញ្ញត្តិទាំងនេះមានរៀបរាប់យ៉ាងលម្អិតអំពីនីតិវិធី និងដំណើរការស្នើសុំការអនុញ្ញាតការបង្វិលសងអាករលើតម្លៃបន្ថែម លក្ខណៈវិនិច្ឆ័យមានសិទ្ធិ ពេលវេលារំពឹងទុក និងការផ្តល់សិទ្ធិអនុញ្ញាតឱ្យអគ្គនាយកដ្ឋានពន្ធដារចេញចំណាត់ការបង្វិលសងអាករលើតម្លៃបន្ថែម។*

*សហគ្រាសមានអនុលោមភាពពន្ធ ដែលបានអនុវត្តតាមដំណើរការដែលបានកំណត់ និងបានដាក់ឯកសារតម្រូវគ្រប់គ្រាន់ អាចរំពឹងថានឹងទទួលបានការទូទាត់បង្វិលសងអាករលើតម្លៃបន្ថែមនៅក្នុងរយៈពេល ៤០ ថ្ងៃធ្វើការសម្រាប់ក្រុមហ៊ុនឯកជន និងនៅក្នុងរយៈពេល ១៥ ថ្ងៃធ្វើការសម្រាប់អង្គការមិនរកប្រាក់ចំណេញ (ដូចជា អង្គការមិនមែនរដ្ឋាភិបាល ទីភ្នាក់ងារបំពេញបេសកកម្មការទូត និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស) គិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។*

២៥. *សូមពិចារណាដាក់ចេញបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែមសម្រាប់ភ្នាក់ងារក្រុមហ៊ុនធ្វើដំណើរដែលមាន «ទំនាក់ទំនងទីភ្នាក់ងារ» ជិតស្និទ្ធជាមួយគ្នាដើម្បីជំរុញបញ្ចាំងជាតុដាក់ស្តែង របស់ធុរកិច្ចទាំងនេះឲ្យមានភាពយុត្តិធម៌ជាងមុន។*

ការឆ្លើយតប

*នៅក្នុងខែមិថុនា ឆ្នាំ២០១៨ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាសលេខ ៥៩៧ ដែលបានផ្តល់ជាគោលការណ៍ណែនាំ និងការទទួលស្គាល់ទំនាក់ទំនងរវាងភ្នាក់ងារផ្គត់ផ្គង់ទំនិញ និងសេវាកម្ម ក្នុងនាមជាសហគ្រាសដើម និងកាតព្វកិច្ចបង់ពន្ធរបស់ខ្លួន។ ប្រកាសនេះមានគោលបំណងផ្តល់សុពលភាពចំពោះទំនាក់ទំនងរវាងភ្នាក់ងារ និងសហគ្រាសដើមជាប់ពន្ធជានិវេសនជនកម្ពុជាតែប៉ុណ្ណោះ ប៉ុន្តែមិនទទួលស្គាល់ទំនាក់ទំនងជាមួយនឹងសហគ្រាសដើមក្រៅប្រទេសឡើយ។ ក្រោមបញ្ញត្តិនៃប្រកាសនេះ ភ្នាក់ងារជាប់ពន្ធតែលើកម្រៃជើងសារដែលបានទទួលពីការលក់ប៉ុណ្ណោះ ពោលគឺមិនមែនគិតលើចំនួនដុលនៅលើវិក្កយបត្រនោះទេ។*

ពន្ធលើប្រាក់ចំណេញ

២៦. *សូមពិចារណាលើកលែងពន្ធលើអត្ថប្រយោជន៍បន្ថែម ដោយឈរលើគោលការណ៍តាមរយៈការងារ និងអតីតភាពការងាររបស់និយោជិតជាជាងកំណត់ចំនួនទឹកប្រាក់លើកលែងនីងថ្លៃមួយសម្រាប់និយោជិតគ្រប់រូបនៅក្នុងក្រុមហ៊ុនហើយសូមស្រាយបំភ្លឺអំពីតម្រូវការដែលក្រុមហ៊ុនត្រូវបំពេញដើម្បីទទួលបានការអនុម័តលើការលើកលែងពន្ធបែបនេះ។*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា កាលពីខែមេសា ឆ្នាំ២០១៨ អគ្គនាយកដ្ឋានពន្ធដារបានបង្ហាញថា ខ្លួនមិនអាចផ្តល់ការលើកលែងពន្ធលើអត្ថប្រយោជន៍បន្ថែមដោយផ្អែកលើអតីតភាពការងាររបស់និយោជិតតាមការស្នើសុំ បានឡើយ ដើម្បីធានាការអនុវត្តស្មើភាពគ្នានៃសារាចរណ៍ណែនាំលេខ ០១១ ដែលបានចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទោះបីជា សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាទទួលស្គាល់នូវសារៈសំខាន់នៃការអនុវត្តបទប្បញ្ញត្តិស្មើភាពគ្នា តែយើងខ្ញុំនៅតែរក្សាជំហរថាការធ្វើវិចារណកម្មបទប្បញ្ញត្តិទាំងនេះអាចលើកស្ទួយភាពប្រកួតប្រជែងនៅលើឆាកអន្តរជាតិរបស់ប្រទេសកម្ពុជាឱ្យកាន់តែល្អប្រសើរ។*

២៧. *សូមធានាឲ្យមានការអនុវត្តអត្រាពន្ធលើប្រាក់ចំណេញ តាមកំណើនទៅលើគ្រឹះស្ថានធុរកិច្ចទាំងអស់ក្នុងប្រទេសកម្ពុជា ដូចមានចែងក្នុងច្បាប់គ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៧ ដើម្បីធានាឲ្យមានការប្រកួតប្រជែងស្មើភាព និងលើកទឹកចិត្តធុរកិច្ចឲ្យយកប្រាក់ចំណេញទៅធ្វើការវិនិយោគថែមទៀតក្នុងការធ្វើធុរកិច្ចរបស់ខ្លួន។*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែមេសា ឆ្នាំ២០១៨ អគ្គនាយកដ្ឋានពន្ធដារបានបញ្ជាក់ជាថ្មីម្តងទៀតថា ការគិតពន្ធលើប្រាក់ចំណេញតាមអត្រាកំណើនតាមថ្នាក់ដែលមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ អាចអនុវត្តបានតែចំពោះរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅប៉ុណ្ណោះ។ អគ្គនាយកដ្ឋានពន្ធដារបានកត់សម្គាល់ថាបញ្ញត្តិទាំងនេះមានគោលដៅលើកទឹកចិត្តដល់សហគ្រាសធុនតូចឱ្យមានការរីកចម្រើន និងគាំទ្រដល់សហគ្រាសទាំងនោះឱ្យបង្កើនចំនួនមូលធនក្នុងពេលចាប់ផ្តើមដំបូងនៃដំណើរការអាជីវកម្ម។*

២៨.

> *សូមពិនិត្យកែសម្រួលឡើងវិញ នូវប្រការលើកទឹកចិត្តគម្រោងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ពិសេសប្រការពាក់ព័ន្ធពន្ធលើប្រាក់ ចំណេញ ដើម្បីផ្តល់ឧត្តមភាពប្រៀបធៀបផ្នែកពន្ធឲ្យកាន់តែមានលក្ខណៈប្រកួតប្រជែងថែមទៀតដល់បណ្តាវិនិយោគិន។*

ការឆ្លើយតប

*រាជរដ្ឋាភិបាលកំពុងរៀបចំធ្វើបច្ចុប្បន្នភាពច្បាប់ស្តីពីការវិនិយោគដើម្បីអាចឆ្លុះបញ្ចាំងកាន់តែច្បាស់លាស់អំពីមហិច្ឆតាបង្កើនកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាឱ្យកាន់តែល្អប្រសើរ និងបានប្តេជ្ញាចិត្តបញ្ចប់សេចក្តីព្រាងនេះជាស្ថាពរឱ្យបានត្រឹមចុងខែមិថុនា ឆ្នាំ២០១៩។ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាទន្ទឹងរង់ចាំមើលវិសោធនកម្មច្បាប់ថ្មីនេះ ជាពិសេសត្រង់ចំណុចកែសម្រួលការលើកទឹកចិត្ត សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីផ្តល់ជាឧត្តមភាពប្រកួតប្រជែងផ្នែកសារពើពន្ធ កាន់តែល្អប្រសើរជូនវិនិយោគិន។*

២៩.

> *សូមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការពិគ្រោះយោបល់ ជាមួយវិស័យឯកជនក្នុងការរកវិធីកំណត់ពិតានប្រាក់ឧបត្ថម្ភសម្រាប់ចំណាយលើការកម្សាន្តដែលអាចរួចពន្ធ ដើម្បីឲ្យធុរកិច្ចយកទៅអនុវត្តតាម។*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា កាលពីខែមេសា ឆ្នាំ២០១៨ អគ្គនាយកដ្ឋានពន្ធដារ បានបង្ហាញភាពស្ទាក់ស្ទើរក្នុងការពិចារណាអនុញ្ញាតឱ្យសហគ្រាសដាក់ចំណាយលើការកម្សាន្ត ជាចំណាយអាចកាត់កងពន្ធបាន ដោយហេតុថានេះអាចបង្កើតឱកាស ឱ្យសហគ្រាសបន្ទំការចំណាយ និងបំប៉ោងចំណាយនេះហួសពីការពិត និងធ្វើឱ្យការបង់ប្រាក់លើពន្ធប្រាក់ចំណេញមានការថយចុះ។ បច្ចុប្បន្ន អគ្គនាយកដ្ឋានពន្ធដារមិនអាចពិចារណាអនុវត្តប្រព័ន្ធកំណត់ពិតានប្រាក់ឧបត្ថម្ភ ដែលសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាបានស្នើឡើងនោះទេ ដោយសារតែមាត្រា ១៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងបានចែងយ៉ាងច្បាស់ថាចំណាយមិនអាចប្រើប្រាស់ក្នុងគោលបំណងកម្សាន្តបានឡើយ។*

## សំណើសុំបទប្បញ្ញត្តិពន្ធថ្មី

៣០.

> *សូមពិគ្រោះជាមួយវិស័យឯកជនដើម្បីរៀបចំបទប្បញ្ញត្តិច្បាស់លាស់ និងមិនស្រពេចស្រពិលអំពីការផ្ទេរថ្លៃ (Transfer Pricing)។*

**បានដោះស្រាយរួចហើយ**

*នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៩៨៦ សហវ ស្តីពីវិធាន និងនីតិវិធីសម្រាប់បែងចែកចំណូល និងចំណាយក្នុងចំណោមបុគ្គលទាក់ទិន។ ប្រកាសដែលបានបង្កើតឡើងដោយមានការគាំទ្រផ្នែកបច្ចេកទេសពី OECD និងធនាគារពិភពលោកនេះ បានលើកឡើងអំពីគោលការណ៍ណែនាំ និងនីតិវិធីសម្រាប់វិធីសាស្ត្រធ្វើការផ្ទេរថ្លៃដែលបានអនុញ្ញាត និងទោសទណ្ឌចំពោះការមិនអនុលោមតាមសម្រាប់សហគ្រាសដែលធ្វើប្រតិបត្តិការជាមួយនឹងភាគីទាក់ទិន។*

# វិស័យគយ ការដឹកជញ្ជូន និងភស្តុភារ

ផ្នែកគយ

៣១. *សូមពង្រីកបញ្ជីថ្លៃសោហ៊ុយ និងថ្លៃសេវាដើម្បីបញ្ចូលប្រភេទសេវាក្រៅម៉ោងធ្វើការ និងចំណាយសមហេតុផលសម្រាប់មន្ត្រីគយ។*

បានដោះស្រាយរួចហើយ

*បន្ទាប់ពីបានប្រកាស ចាត់ទុកថាជាផ្នែកមួយនៃរបៀបវារៈកំណែទម្រង់គ្រប់ជ្រុងជ្រោយ ដើម្បី ធ្វើឱ្យការសម្រួលពាណិជ្ជកម្ម និងការប្រកួតប្រជែងកាន់តែល្អប្រសើរឡើងនៅក្នុងខែមករា ឆ្នាំ២០១៩ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបញ្ជាក់ថាប្រកាសលេខ១៦០៨ ស្តីពីការយកកម្រៃផ្លូវការសម្រាប់ការផ្តល់សេវាក្រៅម៉ោងធ្វើការ និងការចំណាយខាងក្រៅ ត្រូវបានរៀបចំបញ្ចប់ជាស្ថាពរនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ ហើយនឹងចូលជាធរមាននៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩។ សំខាន់ជាងនេះទៅទៀត ក៏មានការបញ្ជាក់ផងដែរថាការទូទាត់សម្រាប់សេវាទាំងនេះ ត្រូវមានអមជាមួយនឹងវិក្កយបត្រជាទម្រង់អេឡិចត្រូនិចពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករ។*

៣២. *សូមផ្តល់ការណែនាំឲ្យច្បាស់លាស់ថែមទៀត អំពីដំណើរការដែលអ្នកផ្គត់ផ្គង់ទំនិញឲ្យគម្រោង QIP អាចទទួលបានអត្ថប្រយោជន៍ ពីការលើកលែងអត្រាពន្ធនាំចូលសម្រាប់គម្រោង QIP។*

មិនទាន់មានការឆ្លើយតប

៣៣. *សូមផ្តល់អាទិភាពដល់ការប្រើប្រព័ន្ធបង់ប្រាក់អនឡាញមានសុវត្ថិភាព និងដល់ការពង្រីកសមត្ថភាពប្រព័ន្ធបញ្ជូនឯកសារតាមអនឡាញរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ។*

ការឆ្លើយតប

*រាជរដ្ឋាភិបាលកំពុងខិតខំធ្វើទំនើបកម្មនីតិវិធីគយយ៉ាងសកម្ម និងបន្តដាក់ចេញនូវដំណើរការស្វ័យប្រវត្តិកម្មកាន់តែទំនើបជាងមុនតាមរយៈការអភិវឌ្ឍជាបន្តបន្ទាប់នូវបញ្ជរតែមួយជាតិរបស់ប្រទេសកម្ពុជា។ គម្រោងសមាហរណកម្មនេះនឹងជំរុញប្រសិទ្ធភាព និងធ្វើឌីជីថលកម្មដំណើរការនាំចេញ និងលក្ខខណ្ឌតម្រូវឯកសារ ដោយស្របតាមការប្តេជ្ញាចិត្តអាស៊ានរបស់កម្ពុជា ដែលនឹងឆ្លុះបញ្ចាំងតាមរយៈការបង្កើតបញ្ជរតែមួយអាស៊ាន។ រាជរដ្ឋាភិបាលមានគោលបំណងដាក់ឱ្យដំណើរការបញ្ជរតែមួយជាតិកម្ពុជានៅដើមខែមិថុនា ឆ្នាំ២០១៩ នេះ។*

៣៤. *សូមអគ្គនាយកដ្ឋានគយ និងរដ្ឋាករ បង្កើតឲ្យមានដំណើរការមួយច្បាស់លាស់ និងមានលក្ខណៈជាប្រព័ន្ធ ដែលវិស័យឯកជនអាចប្រើបានសម្រាប់លើកបញ្ហាដល់អ្នកគ្រប់គ្រង មានឋានានុក្រមជាន់ខ្ពស់របស់អគ្គនាយកដ្ឋាន ដើម្បីស្នើសុំសេចក្តីសម្រេចធ្វើការពិនិត្យឡើងវិញក្នុងករណីមានការជំទាស់។*

ការឆ្លើយតប

*នាឱកាសនៃកម្មវិធីអាហារថ្ងៃត្រង់របស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ ឯកឧត្តម បណ្ឌិត គុណ ញឹមអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករ បានលើកឡើងជាថ្មីម្តងទៀតអំពីដំណើរការលើកបញ្ហានានាដែលពាក់ព័ន្ធនឹងបញ្ហាគយ ដូចដែលមានកំណត់នៅក្នុងច្បាប់ស្តីពីគយ។ ច្បាប់ស្តីពីគយបានចែងថា ប្រសិនបើបុគ្គលណាម្នាក់មិនពេញចិត្តចំពោះការសម្រេចនូវចំណាត់ថ្នាក់តាមតារាង ដើមកំណើត ឬតម្លៃគិតពន្ធគយ បុគ្គលនោះអាចជំទាស់ទៅនឹងការសម្រេចនេះជាលាយលក្ខណ៍អក្សរទៅកាន់ អគ្គនាយក នៅក្នុងរយៈពេល ៣០ ថ្ងៃគិតចាប់ពីពេលទទួលបានការជូនដំណឹងពីអគ្គនាយកដ្ឋានគយ។ បន្ទាប់មក អគ្គនាយក នៃអគ្គនាយកដ្ឋានគយ ត្រូវផ្ញើសេចក្តីសម្រេចលើការជំទាស់នោះ នៅក្នុងរយៈពេល ៦០ ថ្ងៃ បើមិនដូច្នោះទេ ការជំទាស់នឹងត្រូវចាត់ទុកថា បានយល់ព្រម។*

៣៥. *សូមស្នើឲ្យមានការអនុវត្តសារាចរណែនាំលេខ០០៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យបានពេញលេញលើរបប «ទំនិញតម្លៃទាប» និងសហការជាមួយក្រុមហ៊ុនដឹកជញ្ជូនទំនិញឆាប់រហ័សដើម្បីធ្វើការសម្របសម្រួលយកទំនិញចេញពីគយហើយបញ្ជូនឲ្យដល់អតិថិជនតាមតម្រូវការពេលវេលារបស់គេ។*

បានដោះស្រាយរួចហើយ

*នៅក្នុងឆ្នាំ២០១៨ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ បានអនុវត្តយ៉ាងពេញលេញនូវរបប "ទំនិញតម្លៃទាប" សម្រាប់ការដឹកជញ្ជូនទាំងអស់ដែលមានតម្លៃក្រោមកម្រិតកំណត់ ៥០ ដុល្លារអាមេរិក ហើយសមាជិករបស់យើងបានរាយការណ៍ថាក្រុមហ៊ុនធុរកិច្ចបានមើលឃើញអំពីភាពល្អប្រសើរយ៉ាងខ្លាំង ជាពិសេសគឺចំនួនឯកសារដែលតម្រូវសម្រាប់ការដឹកជញ្ជូន ត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់។ សមាជិករបស់យើងក៏បានកោតសរសើរចំពោះភាពជោគជ័យនៅក្នុងការអនុវត្តនេះផងដែរ ដោយសារតែក្រុមហ៊ុនបញ្ជូនទំនិញត្រូវបានអនុញ្ញាតឱ្យដាក់ បញ្ជីទំនិញរួមគ្នាសម្រាប់ការដឹកជញ្ជូនទំនិញតម្លៃទាបជារៀងរាល់ថ្ងៃ ជាជាងការដាក់ដាច់ដោយឡែកដូចការរំពឹងទុកពីដំបូង។*

ការដឹកជញ្ជូន និងភ័ស្តុភារ

៣៦. *សូមបន្តពិភាក្សារកដំណោះស្រាយដល់បញ្ហាថ្លៃចំណាយខ្ពស់ ក្នុងការដឹកទំនិញអន្តរជាតិចូលមកនិងចេញពីប្រទេសកម្ពុជា។*

បានដោះស្រាយរួចហើយ

*ដើម្បីបំពេញបន្ថែមលើឥទ្ធិពលនៃការគំរាមកំហែងខាងក្រៅ មកលើកិច្ចព្រមព្រៀងពាណិជ្ជកម្មអនុគ្រោះពន្ធគយ កាលពីខែមករា ឆ្នាំ២០១៩ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានពន្យល់អំពីរបៀបវារៈបន្ថែមនៃការធ្វើកំណែទម្រង់។ របៀបវារៈនេះរួមបញ្ចូលទាំងការលុបបំបាត់កម្រៃសេវាគ្រប់គ្រងការនាំចេញ និងវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ការលុបបំបាត់ទីភ្នាក់ងារកម្ពុជានាវាចរ "កាំសាប" កាត់បន្ថយកម្រៃសេវាស្វែនកុងតឺន័រចំនួន ៥០% ការដកចេញនូវអគ្គនាយកដ្ឋាន ត្រួតពិនិត្យ ទំនិញ នីហរណ៍-អាហរណ៍ និងបង្រ្កាបការក្លែងបន្លំ (កាំកុងត្រូល) ពីការងារត្រួតពិនិត្យនៅប៉ុស្តិ៍ត្រួតពិនិត្យតាមព្រំដែន។ កំណែទម្រង់នេះ ត្រូវបានរំពឹងថានឹងជួយសន្សំសំចៃថ្លៃចំណាយរបស់ក្រុមហ៊ុនធុរកិច្ចយ៉ាងច្រើន ខណៈដែលរាជរដ្ឋាភិបាលបានប៉ាន់ស្មានការ ខាតបង់ទឹកប្រាក់ប្រមាណជា ៦០ លានដុល្លារនៅក្នុងប្រាក់ចំណូលប្រចាំឆ្នាំ។*

៣៧. សូមអនុញ្ញាតឲ្យមានក្រុមហ៊ុនឯកជនផ្សេងទៀត ក្រៅពីភ្នាក់ងារកម្ពុជា នាវាចរ កាំសាបចូលរួមផ្តល់សេវាកម្មលើកដាក់ទំនិញឡើងចុះពីនាវាផងដែរ។

**បានដោះស្រាយរួចហើយ**

ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានរំលាយភ្នាក់ងារកម្ពុជានាវាចរ "កាំសាប" ជាស្ថាប័នរបស់រដ្ឋ ដែលពីមុនជាស្ថាប័នផ្តល់សេវាទីភ្នាក់ងារដឹកជញ្ជូនផ្តាច់មុខ។ ការលុបចោលនូវទីភ្នាក់ងារកាំសាបនេះរដ្ឋាភិបាលបានខាតបង់ប្រាក់ចំណូលប្រចាំឆ្នាំបន្ថែមចំនួនប្រមាណ ៥០០.០០០ ដុល្លារ។

៣៨. សូមបន្តជួយក្រុមហ៊ុននាវាក្នុងការយកកុងតឺន័រទំនិញ ដែលអត់ម្ចាស់មកទទួល ចេញពីកំពង់ផែត្រឡប់ទៅវិញ។

ការឆ្លើយតប មិនទាន់មាន

តំបន់សេដ្ឋកិច្ចពិសេស

៣៩. សូមតម្រូវឲ្យតំបន់សេដ្ឋកិច្ចពិសេសធ្វើការសម្របសម្រួល កិច្ចប្រជុំទៀងទាត់រវាងវិនិយោគិនអគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងស្ថាប័នសាធារណៈពាក់ព័ន្ធផ្សេងទៀត ហើយសូមឲ្យពិចារណាធ្វើការសាកល្បងប្រើឧបករណ៍ថ្មីសម្រាប់បម្រើដល់កិច្ចសហការរវាងស្ថាប័នសាធារណៈ និងវិស័យឯកជននៅក្នុងរង្វង់តំបន់សេដ្ឋកិច្ចពិសេសដែរ។

ការឆ្លើយតប មិនទាន់មាន

## វិស័យយានយន្ត

បទប្បញ្ញត្តិនាំចូល

៤០. សូមអនុវត្តវិធានផ្នែកនិយ័តកម្មនានា សម្រាប់ទប់ស្កាត់ការ នាំចូលរថយន្តដែលមិនសមស្របនឹងបរិស្ថានរបស់កម្ពុជា។

ការឆ្លើយតប

នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានចេញប្រកាសលេខ ៩៩ ដើម្បីពង្រីកវិសាលភាពនៃពន្យារការពេលអនុវត្តប្រកាសលេខ ១៥០ ស្តីពីបទប្បញ្ញត្តិបច្ចេកទេសសម្រាប់ផលិតផលយានយន្តទាំង ១៩ សម្រាប់ផលិតផលយានយន្តរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។ លើសពីនេះទៅទៀត ប្រកាសលេខ ៩៩ ក៏បានលើកឡើងថាក្រុមហ៊ុនធុរកិច្ចនានាដែលបានចូលរួមក្នុងផលិតកម្ម អន្តរកម្ម ការនាំចូល និងការលក់ផលិតផលនេះត្រូវតែអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសម្រាប់ផលិតផលយានយន្តទាំង ១៩ សម្រាប់ផលិតផលយានយន្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ តទៅ។ ខណៈដែលការអនុវត្តកម្មវិធីនេះនឹងកំណត់ដោយការប្រកាសជាចំពីគ្នា បញ្ញត្តិនេះទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅ ដោយសារតែបញ្ញត្តិនេះបានបញ្ជាក់ចំណុចច្បាស់លាស់ជាច្រើនដែលត្រូវការជាចាំបាច់សម្រាប់វិស័យយានយន្ត។

**កិច្ចការពារអ្នកប្រើប្រាស់**

៨១. *សូមស្នើឲ្យនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ធ្វើការជូនដំណឹងក្នុងមួយត្រីមាសម្តងៗ ដល់សាខាចែកចាយម៉ាកយីហោនានា នូវព័ត៌មានស្តីពីបញ្ជីរថយន្តថ្មីឬការផ្ទេររថយន្តដែលប្រើរួចហើយជាប្រយោជន៍ជួយសម្រួលដល់ការហៅប្រមូលត្រឡប់មកវិញក្នុងករណីមានបញ្ហាបច្ចេកទេស។*

ការឆ្លើយតប
មិនទាន់មាន

៨២. *សូមបន្តអនុវត្តឲ្យបានកាន់តែប្រសើរថែមទៀត នូវតម្រូវការត្រួតពិនិត្យបច្ចេកទេសយានយន្តដែលមានស្រាប់។*

**បានដោះស្រាយរួចហើយ**

*ក្រសួងសាធារណការ និងដឹកជញ្ជូន បានអនុវត្តគំនិតផ្តួចផ្តើមសំខាន់ៗជាច្រើនដើម្បីដោះស្រាយបញ្ហាយានយន្តកំពុងប្រើប្រាស់មិនមានសុវត្ថិភាពនៅក្នុងប្រទេសកម្ពុជា ដែលកិច្ចការនេះរាប់បញ្ចូលទាំង ការពង្រីកការចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តចល័តទៅគ្រប់ខេត្តទាំងអស់ ការដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មអនឡាយសម្រាប់ការចុះបញ្ជីការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ក៏ដូចជាការបង្កើតកិច្ចសហការជាមួយនឹងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ដើម្បីពង្រឹងស្តង់ដារត្រួតពិនិត្យយានយន្តផងដែរ។*

**គោលនយោបាយសារពើពន្ធ**

៨៣. *សូមធ្វើវិចារណកម្មឡើងវិញ នូវគោលនយោបាយសារពើពន្ធលើរថយន្តដើម្បីគាំទ្រដល់ការលូតលាស់របស់អាជីវកម្មផ្លូវការស្របច្បាប់នៅក្នុងវិស័យនេះ។*

ការឆ្លើយតប
មិនទាន់មាន

# វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

គាំទ្រការអភិវឌ្ឍឧស្សាហកម្មបច្ចេកវិទ្យាថ្មី

៤៨.

> *សូមធ្វើការពិនិត្យជាថ្មីការឡើងវិញនូវយន្តការសម្រាប់ការពិគ្រោះយោបល់រវាងស្ថាប័នសាធារណៈ និងឯកជន នៅក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍។*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែតុលា ឆ្នាំ២០១៨ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានទទួលស្គាល់តួនាទីដ៏សំខាន់របស់វិស័យឯកជន និងអ្នកប្រើប្រាស់ក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍគោលនយោបាយ និងបទប្បញ្ញត្តិដើម្បីគ្រប់គ្រងវិស័យបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដែលកំពុងរីកចម្រើនខ្លាំងនៅក្នុងប្រទេសកម្ពុជា និងទិដ្ឋភាពរួមនៃសកម្មភាពប្រជុំពិគ្រោះយោបល់ដែលបានអនុវត្តកន្លងមក។ គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍របស់សភាពាណិជ្ជ-កម្មអឺរ៉ុបនៅកម្ពុជាបានមើលឃើញកិច្ចខិតខំប្រឹងប្រែងយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលក្នុងការចូលរួមជាមួយវិស័យឯកជន ព្រមទាំងមានបំណងបន្តផ្តល់ការណែនាំបែបស្ថាបនា និងការគាំទ្រដល់ក្រសួងពាក់ព័ន្ធលើទិដ្ឋភាពច្បាប់នាពេលអនាគតផងដែរ។*

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

៤៩.

> *សូមរៀបចំឲ្យមានក្របខ័ណ្ឌច្បាប់ ដើម្បីគាំទ្រដល់ការលូតលាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករួមមានច្បាប់ស្តីអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងច្បាប់ថ្មីមួយទៀតអំពីការការពារអ្នកប្រើប្រាស់។*

ការឆ្លើយតប

*សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា មានក្តីសោមនស្សរស្សូមរាយការណ៍អំពីការចូលរួមកាន់តែល្អប្រសើររបស់ក្រសួងពាណិជ្ជកម្មចំពោះវិស័យឯកជន ពាក់ព័ន្ធនឹងការបង្កើតជាបន្តបន្ទាប់នូវច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។*

*គណៈកម្មការបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍របស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា មានឱកាសជាច្រើន ក្នុងការផ្តល់ជាមតិត្រឡប់ក្នុងន័យស្ថាបនាលើសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ក្នុងគោលបំណងជំរុញឱ្យមានកិច្ចពិភាក្សាប្រកបដោយអត្ថន័យជុំវិញគោលដៅ និងកម្មវត្ថុនៃច្បាប់ដែលនឹងត្រូវបង្កើតឡើងនេះ។ សមាជិកគណៈកម្មាធិការអាចបង្ហាញការព្រួយបារម្ភ និងយោបល់របស់ខ្លួនទៅលើមាត្រានីមួយៗនៃសេចក្តីព្រាងច្បាប់នេះ និងផ្តល់សំណូមពរលម្អិតដើម្បីគាំទ្រដល់រាជរដ្ឋាភិបាល ក្នុងការតាក់តែងសេចក្តីព្រាងច្បាប់ ដែលនឹងជំរុញឱ្យច្បាប់ស្តីពីពាណិជ្ជ-កម្មតាមប្រព័ន្ធអេឡិចត្រូនិកទទួលបានជោគជ័យ។ មតិត្រឡប់របស់សមាជិកគណៈកម្មការបានគាំទ្រដល់ការផ្ទៀងផ្ទាត់សុក្រឹតភាព នៃលក្ខណៈលម្អិតផ្នែកបច្ចេកទេស និងធានាថាបញ្ញត្តិដែលមាននៅក្នុងច្បាប់នោះ មិនធ្វើឱ្យរាំងស្ទះដល់ភាពច្នៃប្រឌិតថ្មី និងវិស័យបច្ចេកវិទ្យាដែលកំពុងរីកលូតលាស់ក្នុងប្រទេសកម្ពុជាឡើយ។*

ទូរគមនាគមន៍

៨៦. *សូមស្នើដល់រដ្ឋាភិបាល ឲ្យធ្វើការពិគ្រោះយោបល់ខ្លឹមសារស៊ីជម្រៅជាមួយវិស័យឯកជនសិនមុននឹងអនុវត្តដំណើរការចេញអាជ្ញាប័ណ្ណទូរគមនាគមន៍សារជាថ្មីឡើងវិញ។*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែតុលា ឆ្នាំ២០១៨ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានរៀបរាប់យ៉ាងលម្អិតអំពីទិដ្ឋភាពជាច្រើនដែលវិស័យឯកជនបានចូលរួមនៅក្នុងការតាក់តែងច្បាប់ថ្មីស្តីពីទូរគមនាគមន៍។ ក្រសួងក៏បានលើកឡើងជាថ្មីម្តងទៀតថា ខ្លួនមានគោលបំណងបន្តបង្កើតកិច្ចពិភាក្សាពិគ្រោះយោបល់អំពីការកែប្រែច្បាប់នានាក្នុងពេលអនាគត និងស្វាគមន៍ចំពោះគ្រប់មតិត្រឡប់ ជាតុចូលព្រមទាំងការព្រួយបារម្ភរបស់វិស័យឯកជនផងដែរ។*

៨៧. *សូមរៀបចំឲ្យមានរចនាសម្ព័ន្ធសម្រាប់អនុវត្ត «មូលនិធិកាតព្វកិច្ចសេវាកម្មសាកល» និង «មូលនិធិសម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍ» ដើម្បីគាំទ្រឲ្យមានការលូតលាស់ថែមទៀតក្នុងវិស័យនេះ។*

បានដោះស្រាយរួចហើយ

*កាលពីខែវិច្ឆិកា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលបានប្រកាសថា ក្រុមហ៊ុនទូរគមនាគមន៍ប្រមាណ ៨៧% នៅក្នុងប្រទេសកម្ពុជាបានបំពេញកាតព្វកិច្ចរបស់ខ្លួន និងបានបង់វិភាគទានទឹកប្រាក់ប្រមាណ ១៣,៥ លានដុល្លារអាមេរិក លើការកសាងសមត្ថភាព មូលនិធិស្រាវជ្រាវ និងអភិវឌ្ឍ និងមូលនិធិសេវាសកលដើម្បីពង្រីកវិសាលភាពនៃការផ្តល់សេវា និងបង្កើនភាពច្នៃប្រឌិតថ្មី។ កម្រិតនៃអនុលោមភាពនេះបង្ហាញថា បន្ទាប់ពីបានចូលរួមជាមួយនឹងក្រុមហ៊ុនទូរគមនាគមន៍ និងការផ្សព្វផ្សាយគោលការណ៍ណែនាំអនុវត្តច្បាស់លាស់ លក្ខខណ្ឌដំបូងរបស់វិស័យឯកជនជុំវិញការគ្រប់គ្រងប្រាក់ចំណូល ត្រូវបានដោះស្រាយ។*

៨៨. *សូមឲ្យមានដំណើរការសម្រិតសម្រាំង ជម្រុះអ្នកដេញថ្លៃនៅក្នុងការដាក់ដេញថ្លៃវិសាលគម។*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែតុលា ឆ្នាំ២០១៨ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានលើកឡើងអំពី សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ គ្រប់គ្រង និងការបែងចែកវិសាលគមហ្វ្រេកង់វិទ្យុ ថា ប្រសិនបើអ្នកដេញថ្លៃមិនមានលទ្ធភាពធ្វើការទូទាត់ថ្លៃឈ្នះការដេញថ្លៃទេ នោះក្រសួងនឹងរៀបចំការដេញថ្លៃថ្មីឡើងវិញនៅក្នុងរយៈពេល ៩០ ថ្ងៃបន្ទាប់ពីបានចេញលិខិតរំឭកការបង់ប្រាក់លើកចុងក្រោយ។ ប៉ុន្តែ ការធ្វើបែបនេះគឺមិនអាចដោះស្រាយបញ្ហាបានឡើយ នៅពេលដែលអ្នកដេញថ្លៃបែបប្រថុយប្រថាន ដែលមានលទ្ធភាពហិរញ្ញវត្ថុតិចតួច មកចូលរួមដេញថ្លៃ ហើយតម្លៃវិសាលគមកើនឡើង ដែលអាចធ្វើឱ្យមានភាពយឺតយ៉ាវដល់ការបែងចែក និងការពង្រីកបណ្តាញបន្ថែមទៀត។*

៤៩. សូមពិនិត្យឡើងវិញ នូវវិធីសាស្ត្រក្នុងការគណនាពន្ធលើចំណូលរបស់ក្រុមហ៊ុនទូរគមនាគមន៍។

ការឆ្លើយតប

តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែតុលា ឆ្នាំ២០១៨ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានបញ្ជាក់ថា បញ្ហាចំណូលពន្ធ គឺស្ថិតនៅខាងក្រៅដែនទំនួលខុសត្រូវ ដោយសារតែការងារពន្ធដារនេះ គឺជាទំនួលខុសត្រូវរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ផ្ទុយទៅវិញ ក៏មានការស្នើសុំឱ្យសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ពិគ្រោះយោបល់ជាមួយមន្ត្រីពាក់ព័ន្ធដើម្បីធ្វើការឆ្លើយតបផងដែរ។

# វិស័យធុរកិច្ចបៃតង

ថាមពលកកើតឡើងវិញ

៥០. សូមជួយឲ្យក្រុមហ៊ុនដីរម៉ាស់ មានចីរភាពស្របច្បាប់ មានលទ្ធភាពប្រកបអាជីវកម្ម ក្នុងស្ថានភាពតម្លៃប្រកួតប្រជែងមួយ។

ការឆ្លើយតប មិនទាន់មាន

៥១. សូមអនុវត្តវិធានការលើកទឹកចិត្តផ្នែកពន្ធ និងពិចារណាធ្វើការសាកល្បងយន្តការទូទាត់ថាមពលអគ្គិសនីពន្លឺព្រះអាទិត្យដែលនៅសល់(Net-Metering) ដើម្បីគាំទ្រដល់ការអភិវឌ្ឍឧស្សាហកម្មថាមពលប្រើពន្លឺព្រះអាទិត្យនៅកម្ពុជា។

ការឆ្លើយតប

នៅក្នុងខែមករា ឆ្នាំ២០១៨ រាជរដ្ឋាភិបាល បានអនុម័តបទប្បញ្ញត្តិពាក់ព័ន្ធជាលើកដំបូងរបស់ខ្លួន តាមរយៈអាជ្ញាធរអគ្គិសនីកម្ពុជា (EAC) ដោយបញ្ជាក់អំពីលក្ខខណ្ឌទូទៅសម្រាប់ការតភ្ជាប់ប្រភពថាមពលពន្លឺព្រះអាទិត្យ PV ទៅនឹងបណ្តាញអគ្គិសនីថ្នាក់ជាតិ។ យោងតាមបទប្បញ្ញត្តិនេះ អ្នកប្រើប្រាស់អាចដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យដោយមិនមានការរឹតត្បិតអ្វីឡើយ ប្រសិនបើប្រព័ន្ធទាំងនោះមិនតម្រូវឱ្យភ្ជាប់ទៅនឹងបណ្តាញអគ្គិសនីថ្នាក់ជាតិ។

មានតែអ្នកប្រើប្រាស់ខ្នាតធំ (តង់ស្យុងមធ្យម ចាប់ពី ៣៨០ វ៉ុល រហូតដល់ ២២,០០០ វ៉ុល) និងអ្នកប្រើប្រាស់ខ្នាតធំបំផុត (តង់ស្យុងខ្ពស់ ចាប់ពី ២២,០០០ វ៉ុល ឡើងទៅ) ប៉ុណ្ណោះដែលអាចភ្ជាប់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យជាមួយនឹងបណ្តាញអគ្គិសនីថ្នាក់ជាតិបាន ដែលក្នុងលក្ខណៈនេះ តារាងតម្លៃ និងលក្ខខណ្ឌផ្សេងទៀត អាចត្រូវបានអនុវត្ត។

៥២. *សូមរៀបចំឲ្យមានកម្មវិធីថ្នាក់ជាតិ ដែលអនុម័តដោយរដ្ឋាភិបាលសម្រាប់ធានាគុណភាពផលិតផលថាមពលប្រើពន្លឺព្រះអាទិត្យ។*

ការឆ្លើយតប

*អាជ្ញាធរអគ្គិសនីកម្ពុជា (EAC) បានចេញឯកសារស្តង់ដារបច្ចេកទេសអប្បបរមា នៅក្រោមវិសាលភាពក្របខ័ណ្ឌនិយ័តកម្ម ដើម្បីតភ្ជាប់ប្រភពបង្កើតថាមពលពន្លឺព្រះអាទិត្យជាមួយនឹង បណ្តាញអគ្គិសនីថ្នាក់ជាតិ ដែលបានភ្ជាប់ទៅនឹងក្រុមបណ្តាញរបស់ EAC ឆ្នាំ២០១៩។ ការចេញបទប្បញ្ញត្តិ និងលក្ខខណ្ឌបច្ចេកទេសអប្បបរមានេះ បង្ហាញអំពីវឌ្ឍនភាពរបស់វិស័យនេះ ក្នុងការបង្កើតស្តង់ដារដែលមានការទទួលស្គាល់ សម្រាប់ថាមពលពន្លឺព្រះអាទិត្យក្នុងប្រទេសកម្ពុជា។*

## ការទទួលខុសត្រូវអាជីវកម្ម

៥៣. *សូមផ្តល់ការណែនាំច្បាស់លាស់ និងជាសាធារណៈ អំពីថាតើបណ្តាធុរកិច្ចគួរត្រៀមលក្ខណៈបែបណាខ្លះនៅពេលមានច្បាប់វាយតម្លៃហេតុប៉ះពាល់បរិស្ថាន នាពេលខាងមុខហើយសូមធានាឲ្យមានដំណាក់កាលអន្តរកាលសមស្របមួយ ក្រោយពីច្បាប់នេះត្រូវបានអនុម័តឲ្យប្រើជាផ្លូវការ។*

ការឆ្លើយតបមិនទាន់មាន

៥៤. *សូមធានាកុំឲ្យមានតម្រូវការសញ្ជាតិ សម្រាប់ក្រុមហ៊ុនប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងសេចក្តីព្រាងចុងក្រោយរបស់ក្រមបរិស្ថាននិងធនធានធម្មជាតិកម្ពុជា ឬលិខិតូបករណ៍អមក្រមនេះទេហើយសូមពិចារណាលើពាក្យសុំការទទួលស្គាល់ផ្លូវការ ដោយផ្អែកលើសមត្ថភាពជាក់ស្តែងរបស់ក្រុមហ៊ុនដែលបានដាក់ពាក្យស្នើសុំ។*

ការឆ្លើយតប

*នៅក្នុងខែមករា ឆ្នាំ២០១៨ ក្នុងកម្មវិធី អាហារថ្ងៃត្រង់ ជាមួយឯកឧត្តមរដ្ឋមន្ត្រីក្រសួង បរិស្ថាន ឯកឧត្តមបានទទួលស្គាល់ថា នៅក្នុងពេលអនាគត កម្ពុជានឹងបន្ធូរបន្ថយការរឹតបណ្តឹងលើបញ្ហាសញ្ជាតិកម្ពុជានៅក្នុងរយៈពេលវែង ដោយសារការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជាចំពោះអង្គការពាណិជ្ជកម្មពិភពលោក ប៉ុន្តែក្នុងដំណាក់កាលនេះ យើងមិនទាន់មានផែនការអនុវត្តការងារនេះនៅឡើយទេ។ ផ្ទុយទៅវិញ ឯកឧត្តម ក៏បានស្នើឱ្យក្រុមហ៊ុនបរទេសដែលមានបំណងផ្តល់សេវាប្រឹក្សាអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុង ប្រទេសកម្ពុជាគួរចាប់ដៃគូជាមួយក្រុមហ៊ុនកម្ពុជា។*

៩៥.

> *សូមអាជ្ញាធរមូលដ្ឋានដាក់ការគិតគូរអំពីចីរភាព ជាលក្ខខណ្ឌមួយក្នុងការពិនិត្យវាយតម្លៃឡើងវិញ នូវការអនុវត្តការទទួលខុសត្រូវរបស់ក្រុមហ៊ុនម៉ៅការគ្រប់គ្រងកាកសំណល់ ធានាថាផែនការទម្លាប់អនុវត្តន៍មានចីរភាពត្រូវតែជាចំណុចមួយសម្រាប់ពិចារណាជាអាទិភាពក្នុងការដេញថ្លៃសេវាគ្រប់គ្រងកាកសំណល់នៅពេលអនាគត និងសម្រាប់ពង្រឹងការអនុវត្តច្បាប់ស្តីអំពីការគ្រប់គ្រងគុណភាពទឹក។*

ការឆ្លើយតប

*កាលពីខែតុលា ឆ្នាំ២០១៨ សាលារាជធានីភ្នំពេញ បានដាក់ចេញនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងកាកសំណល់នៅក្នុងទីក្រុងភ្នំពេញ ឆ្នាំ២០១៨-២០៣៥ ដែលបានរៀបចំឡើងតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នាជាមួយដៃគូអភិវឌ្ឍន៍។ យុទ្ធសាស្ត្រនេះនឹងដើរតួនាទី ជាគោលការណ៍ណែនាំយុទ្ធសាស្ត្រសម្រាប់សាលារាជធានីភ្នំពេញក្នុងការដោះស្រាយបញ្ហា តម្រូវការ និងបញ្ហាប្រឈមសំខាន់ៗ ពាក់ព័ន្ធនឹងការគ្រប់គ្រងសម្រាមនៅក្នុងទីក្រុង ភ្នំពេញ។*

ប្រសិទ្ធផលថាមពល

៩៦.

> *សូមបង្កើតក្រុមការងារបច្ចេកទេស រវាងស្ថាប័នសាធារណៈ និងផ្នែកឯកជនមួយ ដែលផ្តោតការងារទៅលើ ស្លាកសញ្ញាព័ត៌មាន ផលិតផលមានប្រសិទ្ធផលថាមពល។*

ការឆ្លើយតប

*នៅក្នុងឆ្នាំ២០១៨ រដ្ឋាភិបាលប្រទេសចិន បានផ្តល់ជំនួយផ្នែកកសាងសមត្ថភាពដល់ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្នុងការបង្កើតស្លាកសញ្ញាបៃតង និងកម្មវិធីស្លាកព័ត៌មានបរិស្ថានជាតិក្នុងប្រទេសកម្ពុជា។ គម្រោងនេះ ត្រូវបានដឹកនាំដោយមជ្ឈមណ្ឌលផ្តល់វិញ្ញាបនបត្រស្លាកសញ្ញាបរិស្ថានចិន (CEC) ព្រមទាំងប្រើប្រាស់បទពិសោធន៍របស់ខ្លួនក្នុងការបង្កើតស្លាកព័ត៌មានបរិស្ថានចិន និងឧត្តមានុវត្តន៍អន្តរជាតិ។*

៩៧.

> *សូមពិចារណាដាក់ចេញកម្មវិធី«រង្វាន់ឧស្សាហកម្មបៃតង» ដើម្បីទទួលស្គាល់ស្នាដៃធុរកិច្ចណាដែលបានបង្ហាញទង្វើប្រតិបត្តិល្អឥតខ្ចោះក្នុងផ្នែកប្រសិទ្ធផលថាមពល។*

ការឆ្លើយតប មិនទាន់មាន

អគារបៃតង

៩៨.

> *សូមពិចារណាស្វែងរកលទ្ធភាព បង្កើតក្រុមប្រឹក្សាអគារបៃតងនៅកម្ពុជា។*

ការឆ្លើយតប

*ក្រសួងបរិស្ថាន បានកៀរគរក្រុមការងារបច្ចេកទេសផ្នែកទីក្រុងមានចីរភាព ដែលកំពុងពិភាក្សា អំពីការបង្កើតគោលការណ៍ណែនាំសំណង់អគារបៃតង។ ដោយសារគោលបំណងនៃគំនិតផ្តួចផ្តើមនេះមានភាពស្របគ្នាជាមួយគោលបំណងនៃក្រុមប្រឹក្សាសំណង់បៃតង សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ត្រូវបានណែនាំឱ្យរៀបចំសិក្ខាសាលាមួយ ដើម្បីកៀរគរភាគីពាក់ព័ន្ធទាំងអស់មកពីខាងរដ្ឋាភិបាល និងវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ឱ្យចូលរួមពិភាក្សាគ្នាអំពីការបង្កើតក្រុមប្រឹក្សាសំណង់បៃតងនៅកម្ពុជា។*

ហិរញ្ញប្បទាន បៃតង

៥៩. សូមរៀបចំឲ្យមានចំណុចប្រមូលផ្តុំព័ត៌មានមួយ សម្រាប់កម្មវិធីហិរញ្ញប្បទានបៃតងទាំងអស់ ដែលអាចអនុវត្តបានជាមួយវិស័យឯកជនហើយ ផ្សព្វផ្សាយព័ត៌មានទាំងនោះតាមឧបករណ៍សមស្របដូចជាតាមអ៊ិនធឺណិតជាដើម។

គ្មានវឌ្ឍនភាព

# វិស័យសុខាភិបាល

ការនាំចូលដោយលួចលាក់

៦០. សូមអនុវត្តវិធានការបន្ថែម ដើម្បីទប់ស្កាត់ការនាំចូល ផលិតផលឱសថដោយលួចលាក់។

ការឆ្លើយតប

នៅក្នុងកិច្ចប្រជុំរវាងសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាជាមួយ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង កាលពីខែកក្កដា ឆ្នាំ២០១៨ កន្លងទៅ នាយកដ្ឋានបានអះអាងជាថ្មីថា យោងតាមច្បាប់កម្ពុជា ក្រុមហ៊ុនឱសថមិនអាចទទួលបានសិទ្ធិផ្តាច់មុខក្នុងការនាំចូលផលិតផលវេជ្ជសាស្ត្រចូលក្នុងប្រទេសកម្ពុជាបានឡើយ។ ក្នុងករណីក្រសួងសុខាភិបាលចេញអាជ្ញាប័ណ្ណនាំចូលជូន ក្រុមហ៊ុនទាំងនោះអាចនាំចូលបាន ដោយសារផលិតផលនោះទទួលបានសិទ្ធិចែកចាយនៅលើទីផ្សាររួចទៅហើយ ហើយក៏ទទួលបានការអនុញ្ញាតឱ្យនាំចូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករួចរាល់ផងដែរ។ ប៉ុន្តែ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង ក៏បានគូសបញ្ជាក់ផងដែរថា នីតិវិធីទាំងនេះមិនអនុវត្តចំពោះការនាំចូលផលិតផលរាក់សាំងលួចលាក់ដែលត្រូវបានហាមឃាត់ ជាទូទៅឡើយ។

ការចុះបញ្ជិកានិងការបន្តសុពលភាព

៦១. សូមបង្កើតដំណើរការមួយ សម្រាប់ក្រុមហ៊ុនថែទាំសុខភាពនៅកម្ពុជា អាចប្រើក្នុងការដាក់ពាក្យសុំអាជ្ញាប័ណ្ណនាំចូលពិសេស សម្រាប់ផលិតផលដែលមានក្នុងបញ្ជិកាហើយ ឬដែលកំពុងឆ្លងកាត់ដំណើរការសុំបន្តសុពលភាពបញ្ជិកាឡើងវិញ។

ការឆ្លើយតប

តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែសីហា ឆ្នាំ២០១៨ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង បានជូនដំណឹងដល់សភាពាណិជ្ជកម្មកម្ពុជាថា ក្រសួងសុខាភិបាលនឹងឈប់ពិចារណាផ្តល់អាជ្ញាប័ណ្ណសម្រាប់សំណើសុំនាំចូលពិសេសសម្រាប់ផលិតផលវេជ្ជសាស្ត្រទៀតហើយ។ នាយកដ្ឋាន ក៏បានបញ្ជាក់ផងដែរថា ចាប់ពីពេលនេះតទៅ ផលិតផលវេជ្ជសាស្ត្រនឹងមិន ត្រូវអនុញ្ញាតឱ្យនាំចូលក្នុងប្រទេសកម្ពុជា ដោយមិនបានទទួលអាជ្ញាប័ណ្ណចុះបញ្ជីការ មានសុពលភាពជាមុនឡើយ បើទោះបីជាផលិតផលនោះកំពុងរង់ចាំការបន្តសុពលភាពអាជ្ញាប័ណ្ណក៏ដោយ។ នាយកដ្ឋានបានលើកឡើងថា ក្រសួងនឹងចេញលិខិតបញ្ជាក់ការបន្តសុពលភាពនៅក្នុងរយៈពេល ៦ ខែ បន្ទាប់ពីទទួលបានពាក្យស្នើសុំ ហើយក្រសួងកំពុងដំឡើងកម្មវិធី

អនឡាញថ្មី សម្រាប់ការចុះបញ្ជីកាតាមប្រព័ន្ធអេឡិចត្រូនិក និងការនាំចូលតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីសម្រួលដល់ដំណើរការនេះ។

៦២.

> សូមស្នើឲ្យក្រសួងសុខាភិបាលចេញបញ្ជីតារាងតម្លៃផ្លូវការមួយ សម្រាប់ដំណើរការរដ្ឋបាល ពាក់ព័ន្ធជាមួយនឹងការកែតម្រូវព័ត៌មានផលិតផល បន្ទាប់ពីការចុះបញ្ជិការួចៗ

ការឆ្លើយតប

ក្រសួងសុខាភិបាល កំពុងពិនិត្យបញ្ចប់សេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីការកែតម្រូវក្រោយការចុះបញ្ជីកាផលិតផលឱសថ ដែលបានធ្វើសេចក្តីព្រាងស្របតាមគោលការណ៍ណែនាំស្តីពីការកែតម្រូវអាស៊ាន។ នៅពេលដែលគោលការណ៍ណែនាំនេះត្រូវបានអនុម័ត ក្រសួងមានបំណងចេញប្រកាសរួមមួយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីរចនាសម្ព័ន្ធតម្លៃសេវា សម្រាប់ការកែតម្រូវក្រោយពេលចុះបញ្ជីកាក្នុងឆ្នាំ២០១៩ នេះ។

៦៣.

> សូមឲ្យក្រសួងសុខាភិបាលចុះផ្សាយបញ្ជីប្រទេសឬស្ថាប័នដែលក្រសួងយល់ព្រមទទួលយកលទ្ធផលតេស្តលើផលិតផលសុខាភិបាលពីមន្ទីរពិសោធន៍របស់ប្រទេសឬស្ថាប័នទាំងនោះជំនួសឲ្យការធ្វើតេស្តដោយមន្ទីរពិសោធន៍នៅកម្ពុជា។

ការឆ្លើយតប

តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែកក្កដា ឆ្នាំ២០១៨ មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល នៃក្រសួងសុខាភិបាលបានបង្ហាញអំពីភាពស្ទាក់ស្ទើរក្នុងការទទួលយកលទ្ធផលតេស្តរបស់មន្ទីរពិសោធន៍សម្រាប់ផលិតផលសុខភាពពីប្រទេស ឬស្ថាប័ននៅក្រៅប្រទេសកម្ពុជា ជំនួសឱ្យការធ្វើតេស្តនៅក្នុងប្រទេស។ មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល បានលើកឡើងថា បច្ចុប្បន្ន នៅក្នុងតំបន់អាស៊ាន មិនមានប្រព័ន្ធទទួលស្គាល់ ឬធានាចំពោះការធ្វើតេស្តមន្ទីរពិសោធន៍សម្រាប់ផលិតផលសុខាភិបាលមកពីប្រទេសជាសមាជិកឡើយ។ ស្រដៀងគ្នានេះដែរ ដោយសារអាកាសធាតុក្តៅហើយសើម និងការរក្សាទុក ការដឹកជញ្ជូន និងការចែកចាយមិនបានត្រឹមត្រូវនូវផលិតផលសុខភាពក្នុងប្រទេសកម្ពុជា ទើបមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល តម្រូវឱ្យមានការធ្វើតេស្តក្នុងប្រទេស ដើម្បីធានាគុណភាព និងចីរភាពរបស់ផលិតផលក្នុងទីផ្សារកម្ពុជា។

៦៤.

> សូមក្រសួងសុខាភិបាលចុះផ្សាយកាលវិភាគច្បាស់លាស់មួយនៃកិច្ចប្រជុំរបស់គណៈកម្មការចុះបញ្ជិកា និងបន្តសុពលភាពនៅលើគេហទំព័ររបស់ក្រសួង។

ការឆ្លើយតប

តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែសីហា ឆ្នាំ២០១៨ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង បានគូសបញ្ជាក់ថា ក្រសួងសុខាភិបាល មិនអាចផ្សព្វផ្សាយកាលវិភាគជាក់លាក់សម្រាប់កិច្ចប្រជុំគណៈកម្មាធិការចុះបញ្ជី និងបន្តសុពលភាពអាជ្ញាប័ណ្ណបានទេ ដោយសារការរៀបចំពេលវេលានេះ គឺអាស្រ័យទៅលើកាលវិភាគរបស់សមាជិកម្នាក់ៗ។ នាយកដ្ឋាន អាចបញ្ជាក់ថា ខ្លួនមានបំណងរៀបចំកិច្ចប្រជុំគណៈកម្មាធិការនេះចំនួន ៥ ឬ ៦ ដងក្នុងមួយឆ្នាំ។

៦៥. *សូមក្រសួងសុខាភិបាល កំណត់ឲ្យបានច្បាស់នូវបញ្ជីចំណាត់ថ្នាក់ផលិតផលសម្រាប់ឧបករណ៍បរិក្ខារពេទ្យ ជាមួយសេចក្តីអធិប្បាយលម្អិតនៃនីតិវិធី និងឯកសារដែលជាតម្រូវការចាំបាច់សម្រាប់ផលិតផលនីមួយៗ និងបោះពុម្ពផ្សាយនីតិវិធីផ្លូវការសម្រាប់ចុះបញ្ជិកាសារធាតុសម្រាប់ធ្វើតេស្តនៅលើគេហទំព័រក្រសួងៗ*

ការឆ្លើយតប

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែសីហា ឆ្នាំ២០១៨ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង បានលើកឡើងថាប្រកាសលេខ ១២៥៨ ស្តីពីបែបបទចុះទិដ្ឋការ បញ្ជីកាឧបករណ៍ បរិក្ខារពេទ្យ ដែលតម្រូវឱ្យផលិតផលនីមួយៗត្រូវចុះបញ្ជីកា និងមិនអនុញ្ញាតឱ្យបែងចែកផលិតផលទាំងនោះជាក្រុម ឬចុះបញ្ជីជាប្រភេទណាមួយឡើយ។ នាយកដ្ឋាន បានបង្ហាញថា ក្រសួងសុខាភិបាលអាចចេញប្រកាសស្តីពីការចុះបញ្ជីការួម សម្រាប់បរិក្ខារពេទ្យក្នុងគោលបំណងកាត់បន្ថយចំណាយ និងបន្ទុកនានារបស់ក្រុមហ៊ុនដែលប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។*

## ឱសថមិនចាំបាច់មានវេជ្ជបញ្ជា

៦៦. *សូមក្រសួងសុខាភិបាលពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពបញ្ជីផលិផលឱសថមិនចាំបាច់មានវេជ្ជបញ្ជាដើម្បីឆ្លុះបញ្ចាំងឱ្យបានប្រសើរ ជាងមុននូវការវិវឌ្ឍន៍ថ្មីៗ របស់ផលិតផលដែលមាននៅលើទីផ្សារ។*

**បានដោះស្រាយរួចហើយ**

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែសីហា ឆ្នាំ២០១៨ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង បានលើកឡើងថា នាយកដ្ឋានបានកំណត់ផលិតផលឱសថមិនចាំបាច់មានវេជ្ជបញ្ជា និងឱសថត្រូវការវេជ្ជបញ្ជា តាមរយៈអ្នកកាន់បញ្ជីកាឱសថឆ្នាំ២០១៧។ នាយកដ្ឋានក៏បានបន្ថែមថា ក្រសួងសុខាភិបាលរំពឹងថានឹងធ្វើបច្ចុប្បន្នភាពការចុះបញ្ជីកាឱសថ មិនចាំបាច់មានវេជ្ជបញ្ជានៅក្នុងឆ្នាំ២០១៩ ផងដែរ បើទោះបីជាការធ្វើបច្ចុប្បន្នភាពនេះ តម្រូវឱ្យមានកិច្ចប្រជុំគណៈកម្មាធិការដើម្បីកំណត់ចំណុចសំខាន់ៗ ដែលត្រូវធ្វើបច្ចុប្បន្នភាពក៏ដោយ។ ជាមួយគ្នានេះផងដែរ ក្រុមហ៊ុននានាអាចទាក់ទងមកនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង ដើម្បីស្នើសុំបញ្ជីកាដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយ។*

## ការដេញថ្លៃសាធារណៈ

៦៧. *សូមស្នើឲ្យផាត់ចេញពីដំណើរការដេញថ្លៃជាសាធារណៈនូវក្រុមហ៊ុនណាដែលគ្មានសមត្ថភាពផ្តល់សេវាថែទាំជាប្រចាំលើបរិក្ខាពេទ្យក្រោយពីការលក់របស់ពួកគេ។*

មិនទាន់មានការឆ្លើយតប

ការប្រាស្រ័យទាក់ទងរវាងស្ថាប័នសាធារណៈ និងវិស័យឯកជន

៦៨. *សូមបង្កើតវេទិការាជរដ្ឋាភិបាល និងវិស័យឯកជនផ្លូវការមួយសម្រាប់ផ្នែកសុខាភិបាល ផ្សព្វផ្សាយព័ត៌មានច្បាប់ ដែលមានពាក់ព័ន្ធនឹងវិស័យសុខាភិបាលឲ្យបានប្រសើរ និងទូលំទូលាយថែមទៀត និងពិចារណាបង្កើតវេទិកាសន្ទនារវាង អន្តរក្រសួងសាធារណៈនិងវិស័យឯកជនដោយផ្តោតដាក់លាក់លើការនាំចូល ផលិតផលឱសថដោយលួចលាក់។*

បានដោះស្រាយរួចហើយ

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែសីហា ឆ្នាំ២០១៨ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង បានណែនាំថា ក្រុមហ៊ុននានាគួរដាក់សំណើសុំផ្លូវការមួយទៅថ្នាក់ដឹកនាំក្រសួងសុខាភិបាល ដោយសារតែនាយកដ្ឋាន មិនមានសិទ្ធិបង្កើតយន្តការទាំងនេះឡើយ។ ជារឿងល្អដែលក្នុងអំឡុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន កាលពីខែមីនា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានប្រកាសថាក្រុមការងារវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនបានពង្រីកវិសាលភាពរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្រុមការងារដាក់លាក់ផ្នែកសុខាភិបាល រួមជាមួយនឹងវិស័យអប់រំ និងសំណង់។*

## វិស័យអចលនទ្រព្យ និងសំណង់

ការអភិវឌ្ឍសុរិយោដី និងអចលនទ្រព្យ

៦៩. *សូមរាជរដ្ឋាភិបាលបន្តពង្រីកការគ្រប់គ្រងសារពើពន្ធថែមទៀត ក្នុងវិស័យអចលនទ្រព្យនិងសំណង់ ក្នុងការកំណត់ឲ្យបានកាន់តែម៉ឺងម៉ាត់ នូវតម្រូវការឲ្យមានការតម្កល់ទុនអប្បបរមា និងរបបអាជ្ញាប័ណ្ណសម្រាប់គម្រោងអភិវឌ្ឍន៍ នៅក្រៅវិស័យគម្រោងសាងសង់លំនៅដ្ឋានដែរ។*

គ្មានការឆ្លើយតប

៧០. *សូមរាជរដ្ឋាភិបាលដាក់កាតព្វកិច្ចឲ្យក្រុមហ៊ុនសំណង់ ជាអ្នកដាក់ពាក្យសុំកម្មសិទ្ធិលើចំណែកឯកជនក្នុងអគារសហកម្មសិទ្ធិជំនួសមុខឲ្យអ្នកទិញ។*

ការឆ្លើយតប

*នៅពេលដែលមិនទាន់មានការកែសម្រួលជាផ្លូវការ នូវដំណើរការដាក់ពាក្យសុំកម្មសិទ្ធិលើចំណែកឯកជន សមាជិករបស់យើងបានឱ្យដឹងថា អ្នកទិញអចលនទ្រព្យអាចចរចាជាមួយក្រុមហ៊ុនអភិវឌ្ឍន៍ ដើម្បីស្នើសុំសិទ្ធិលើចំណែកឯកជនជំនួសឱ្យខ្លួនបាន។ សេវាបន្ថែមនេះ គឺជាឆន្ទានុសិទ្ធិរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ ក្នុងការផ្តល់ជូន ហើយត្រូវតែមានការស្នើសុំពីអ្នកទិញនៅពេលពិនិត្យសម្រេចកិច្ចព្រមព្រៀងទិញលក់។*

៧១. *សូមរាជរដ្ឋាភិបាលដាក់ចេញវិធានការគ្រប់គ្រងហិរញ្ញវត្ថុ ដែលកម្រិតការវិនិយោគ ដោយទិញអចលនទ្រព្យទុកលក់យកចំណេញនៅកម្ពុជា។*

ការឆ្លើយតប មិនទាន់មាន

៧២. *សូមរាជរដ្ឋាភិបាលដាក់ចេញស្តង់ដារទូទៅមួយ សម្រាប់ការវាស់វែងនៅក្នុងឧស្សាហកម្មអចលនទ្រព្យ។*

ការឆ្លើយតប មិនទាន់មាន

## ការរៀបចំដែនដី និងនគរូបនីយកម្ម

៧៣. *សូមពិចារណាឲ្យមាន«គម្រោងគំរូ» ដើម្បីបង្ហាញដល់ វិនិយោគិនថា ការអភិវឌ្ឍតំបន់ឆ្នេរតាមស្តង់ដារអន្តរជាតិ ពិតជាមានលទ្ធភាពអាចធ្វើបាននៅ កម្ពុជា។*

ការឆ្លើយតប

*គណៈកម្មាធិការអចលនទ្រព្យ និងសំណង់របស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា បានខិតខំសហការជាមួយរាជរដ្ឋាភិបាល ដើម្បីរៀបចំសេចក្តីព្រាងក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងតំបន់ឆ្នេរ តាមរយៈការសម្របសម្រួលធាតុចូលផ្លូវច្បាប់ និងការគាំទ្រផ្នែកបច្ចេកទេសពីអ្នកជំនាញបរទេស។ ទោះបីការចូលរួមនេះ មានសារប្រយោជន៍ក្នុងការកំណត់អាទិភាពសម្រាប់និយ័តកម្មថ្មី ដូចជាការអនុម័តឯកសារច្បាប់ថ្មី ដូចជាការបែងចែកបទប្បញ្ញត្តិ និងការលើកកម្ពស់ភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងវិស័យឯកជនក៏ដោយ ក៏ដំណើរការបទប្បញ្ញត្តិថ្មីមិនសូវមានការរីកចម្រើនទៅមុខឡើយចាប់ពីពេលនោះមក។*

## សំណង់

៧៤. *សូមធ្វើការពិគ្រោះយោបល់ជាមួយវិស័យឯកជន ក្នុងការធ្វើយ៉ាងណាឲ្យមានសំណុំស្តង់ដារអគារ មានលក្ខណៈប្រាកដនិយមមួយ សម្រាប់ប្រើនៅប្រទេសកម្ពុជា។*

ការឆ្លើយតប

*ច្បាប់ស្តីពីសំណង់ និងក្រមស្តីពីការសាងសង់អម នៅស្ថិតក្នុងដំណាក់កាលធ្វើសេចក្តីព្រាងនៅឡើយ ដោយសារក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បន្តពិនិត្យយ៉ាងយកចិត្តទុកដាក់លើក្រមស្តីពីការសាងសង់ ដើម្បីពិនិត្យឱ្យច្បាស់ថា ថាអាចអនុវត្តបានចំពោះក្រមស្តីពីការសាងសង់ក្នុងប្រទេសកម្ពុជា។ សភាពាណិជ្ជកម្មកម្ពុជា ក៏មានបំណងទទួលស្គាល់ជំនួយបច្ចេកទេសដ៏មានតម្លៃដែលក្រសួង និងស្ថាប័ន ទទួលបានពីរដ្ឋាភិបាលប្រទេសជប៉ុនតាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ដែលតែងតែកៀរគរអ្នកជំនាញដើម្បីគាំទ្រដល់ការរៀបចំក្រមស្តីពីការសាងសង់ថ្មីនេះផងដែរ។*

៧៥. សូមបង្កើត អនុគណៈកម្មការមួយ នៅក្រោមដំបូលរបស់គណៈកម្មាធិការជាតិផ្នែកសុខភាព និងសុវត្ថិភាពការងារ ដែលផ្តោតការយកចិត្តទុកដាក់ទៅលើសុខភាព និងសុវត្ថិភាពនៅកន្លែងការងារ នៅតាមការដ្ឋានសំណង់។

បានដោះស្រាយរួចហើយ

កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ គណៈកម្មាធិការជាតិបច្ចេកទេសសុខភាព និងសុវត្ថិភាពនៅកន្លែងការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតក្រុមប្រឹក្សាពិគ្រោះយោបល់ ដើម្បីលើកកម្ពស់ស្តង់ដារសន្តិសុខ និងសុវត្ថិភាពការងារនៅក្នុងវិស័យសំណង់ក្នុងប្រទេសកម្ពុជា ដោយយោងតាមក្រុមប្រឹក្សាផ្តល់យោបល់លើគម្រោង។ ក្រុមប្រឹក្សាផ្តល់យោបល់លើគម្រោង ត្រូវបានបង្កើតឡើងដោយមានជំនួយពីអង្គការពលកម្មអន្តរជាតិ និងជប៉ុន រួមទាំងតំណាងមកពីរាជរដ្ឋាភិបាល វិស័យឯកជន សហជីព និងអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ គោលបំណងនៃក្រុមប្រឹក្សានេះ គឺដើម្បីចែករំលែកឧត្តមានុវត្តន៍សុខភាព និងសុវត្ថិភាពនៅកន្លែងការងារ (OHS) និងបង្កើតក្រុមខណ្ឌច្បាប់តាមរយៈដំណើរការពិគ្រោះយោបល់ ដើម្បីអនុវត្តវិធានការគ្រប់គ្រងគ្រប់គ្រាន់ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ និងការរងរបួសនៅតាមការដ្ឋានសាងសង់។

៧៦. សូមស្នើថា ទម្រាំនឹងមានការអនុម័តក្រមសំណង់អគារយកមកប្រើ គួរមានការពិគ្រោះយោបល់ជាមួយផ្នែកឯកជនសិនដើម្បីកំណត់លក្ខខណ្ឌវិនិច្ឆ័យបណ្តោះអាសន្នសម្រាប់សុវត្ថិភាពអគ្គិភ័យ ឲ្យក្លាយជាវិធានការយោងក្នុងពេលដំណាក់កាលនៃដំណើរការពិនិត្យសំណើអនុញ្ញាតការសាងសង់ និងសម្រាប់ក្រុមហ៊ុនប្រតិបត្តិការសាងសង់យកទៅអនុវត្តតាម។

ការឆ្លើយតប

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ រាជរដ្ឋាភិបាល បានចេញអនុក្រឹត្យថ្មី ដើម្បីពង្រឹងកិច្ចការពារគ្រោះអគ្គិភ័យលើអគារ ដោយតម្រូវឱ្យម្ចាស់អគារពាណិជ្ជកម្ម និងអគារប្រើប្រាស់ចម្រុះទាំងអស់នៅក្នុងប្រទេសកម្ពុជាដំឡើងប្រព័ន្ធទប់ស្កាត់អគ្គិភ័យសមស្រប ដើម្បីកាត់បន្ថយការខូចខាត និងគ្រោះថ្នាក់ដោយសារអគ្គិភ័យ។ អនុក្រឹត្យនេះ ចែងអំពីស្តង់ដារការពារអគ្គិភ័យ និងប្រព័ន្ធពន្លត់អគ្គិភ័យ ក៏ដូចជាការគ្រប់គ្រង និងការស៊ើបអង្កេតដោយមន្ត្រី ដើម្បីធានាថាប្រព័ន្ធនេះបានបំពេញទៅតាមលក្ខខណ្ឌថ្មីផងដែរ ប៉ុន្តែ ពុំទាន់មានការកំណត់ថា តើម្ចាស់អគារចាំបាច់ត្រូវបំពាក់ស្តង់ដារសុវត្ថិភាពអគ្គិភ័យ ឬប្រព័ន្ធអគារអ្វីខ្លះ ដើម្បីឆ្លងកាត់ការត្រួតពិនិត្យថ្មីនេះឡើយ។

# វេទិការាជរដ្ឋាភិបាល - ផ្នែកឯកជន

ក្រុមការងារវិស័យទេសចរណ៍

# វិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច

## កិច្ចពិគ្រោះយោបល់រវាងរដ្ឋាភិបាល និងវិស័យឯកជន

*សៀវភៅសនេះ ជាកម្រងអនុសាសន៍គោលនយោបាយ ដែលបានចងក្រងឡើងដោយគណៈកម្មាធិការ តាមវិស័យរបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាលើកលែងតែវិស័យទេសចរណ៍មួយប៉ុណ្ណោះ។*

*ថ្វីបើវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចនៅមានបញ្ហាប្រឈមជាច្រើននៅឡើយក្តី សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា និងក្រសួងទេសចរណ៍ ក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ បានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយគ្នាដើម្បីព្យាយាមដំណោះស្រាយបញ្ហាទាំងឡាយដែលវិស័យទេសចរណ៍កំពុងជួបប្រទះនៅក្នុងវង្វង់ក្របខ័ណ្ឌរបស់ក្រុមការងារ "៦" នៃវេទិការដ្ឋាភិបាល និងផ្នែកឯកជន ដែលជាក្រុមការងារ សម្រាប់ដោះស្រាយបញ្ហានៅក្នុងវិស័យទេសចរណ៍។បញ្ហាប្រឈម និងការស្នើឱ្យមានដំណោះស្រាយទាំងនេះកំពុងត្រូវបានពិភាក្សា និងដោះស្រាយជាប្រចាំដោយក្រសួងទេសចរណ៍ និងវិស័យឯកជន។ យន្តការពិគ្រោះយោបល់រវាងរដ្ឋាភិបាល និងវិស័យឯកជន ដែលជំរុញឱ្យមានកិច្ចពិភាក្សាជាបន្តបន្ទាប់នេះ និងតួនាទីរបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា មានពិពណ៌នាដូចខាងក្រោម។*

### *ការស្វែងយល់អំពីវេទិការដ្ឋាភិបាល និងផ្នែកឯកជន*

*វេទិការដ្ឋាភិបាល និងផ្នែកឯកជន* (G-PSF) *ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៩ ក្រោមគំនិតផ្តួចផ្តើមរបស់សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងផ្តល់ជាយន្តការសន្ទនាគួរឱ្យទុកចិត្តរវាងរាជរដ្ឋាភិបាល និងវិស័យឯកជនសម្រាប់ការពិគ្រោះយោបល់អំពីបញ្ហានានាពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងការវិនិយោគ។*

*វេទិកានេះ ត្រូវបានរៀបចំដោយមានក្រុមការងារទៅតាមវិស័យជាច្រើន និងមានរដ្ឋមន្ត្រីរដ្ឋាភិបាលមួយរូប និងតំណាងវិស័យឯកជនជាប់ឆ្នោតមួយរូប ធ្វើជាសហប្រធានរបស់ក្រុមការងារនីមួយៗ។ វេទិការដ្ឋាភិបាល និងផ្នែកឯកជននេះ ផ្តល់ជូនសហគមន៍ធុរកិច្ចនូវវេទិកាផ្លូវការមួយដើម្បីជួបជុំគ្នាក្នុងគោលបំណងលើកឡើងរួមគ្នាអំពីបញ្ហាប្រឈម និងស្នើឡើងនូវដំណោះស្រាយដែលអាចអនុវត្តបានជូនសមភាគីរដ្ឋាភិបាលធ្វើការពិចារណា។ បញ្ហាទាំងឡាយណាដែលមិនអាចដោះស្រាយបាននៅកម្រិតក្រសួង ត្រូវបានដាក់ជូនទៅដោះស្រាយនៅក្នុងសម័យប្រជុំពេញអង្គរបស់វេទិការដ្ឋាភិបាល និងផ្នែកឯកជន ដែលប្រព្រឹត្តទៅរៀង*

រាល់មួយឆ្នាំម្តងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រីផ្ទាល់។

ក្នុងកិច្ចប្រជុំពេញអង្គនៃវេទិការាជរដ្ឋាភិបាល និងផ្នែកឯកជនលើកទី ១៨ កាលពីខែមីនា ឆ្នាំ២០១៩ កន្លងទៅនេះ ដែលជាកិច្ចប្រជុំលើកទីមួយគិតចាប់ពីពេលដែលវេទិកានេះមិនបានធ្វើឡើងចាប់តាំងពីឆ្នាំ២០១៣ មក សម្តេចនាយករដ្ឋមន្ត្រីបានបញ្ជាក់ថាកិច្ចប្រជុំពេញអង្គនៃវេទិការដ្ឋាភិបាល និងផ្នែកឯកជននេះ នឹងត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ ហើយប្រសិនបើមានភាពចាំបាច់ ត្រូវធ្វើឡើងចំនួនពីរលើកក្នុងមួយឆ្នាំទៀតផង។ សម្តេចនាយករដ្ឋមន្ត្រីក៏បានបញ្ជាក់អំពីការពង្រីកវិសាលភាពនៃក្រុមការងារវេទិការដ្ឋាភិបាល និងផ្នែកឯកជន ដោយបានបង្កើតជាផ្លូវការនូវក្រុមការងារចំនួនបីបន្ថែមទៀតសម្រាប់វិស័យអប់រំ សុខាភិបាល និងសំណង់។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ដើរតួនាទីជាលេខាធិការដ្ឋាននៃវេទិការដ្ឋាភិបាល និងផ្នែកឯកជន ខណៈពេលដែលសភាពាណិជកម្មកម្ពុជា ធានាធ្វើជាអ្នកសម្របសម្រួលក្រុមការងារទាំងអស់នេះ។ នៅក្នុងខែមីនា ឆ្នាំ២០១៩ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ត្រូវបានចាត់តាំងឱ្យធ្វើជាអនុប្រធានក្រុមការងារសម្រាប់វិស័យទេសចរណ៍ ច្បាប់ សារពើពន្ធ និងអភិបាលកិច្ច ព្រមទាំងវិស័យរ៉ែ និងថាមពល ហើយយើងទន្ទឹងរង់ចាំចូលរួមចំណែកចំពោះកិច្ចសន្ទនាប្រកបដោយការស្ថាបនា និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងវិស័យឯកជននៅក្នុងវិស័យទាំងអស់នេះផងដែរ។

ក្រុមការងារទាំង ១៣ ជួបប្រជុំគ្នាជាទៀងទាត់ពេញមួយឆ្នាំ រួមមាន៖

ក. ក្រុមការងារផ្នែកកសិកម្ម និងកសិ-ឧស្សាហកម្ម
ខ. ក្រុមការងារផ្នែកទេសចរណ៍
គ. ក្រុមការងារផ្នែកកម្មន្តសាល សហគ្រាសធុនតូច
    និងមធ្យម និងសេវា
ឃ. ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច
ង. ក្រុមការងារផ្នែកសេវាកម្មធនាគារ និងហិរញ្ញវត្ថុ
ច. ក្រុមការងារផ្នែកដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ
ឆ. ក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ
    និងកិច្ចសម្រួលពាណិជ្ជកម្ម
ជ. ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ
ឈ. ក្រុមការងារផ្នែកស្រូវ-អង្ករ
ញ. ក្រុមការងារផ្នែកថាមពល និងធនធានរ៉ែ
ដ. ក្រុមការងារផ្នែកអប់រំ
ឋ. ក្រុមការងារផ្នែកសុខាភិបាល
ឌ. ក្រុមការងារផ្នែកសំណង់ និងអចលនទ្រព្យ

ក្រៅពីក្រុមការងារទាំង ១៣ នេះ យន្តការភាពជាដៃគូរវាងវិស័យពន្ធដារ និងវិស័យឯកជន ព្រមទាំងយន្តការភាពជាដៃគូរវាងវិស័យគយ និងវិស័យឯកជន ក៏បានបំពេញលើទិដ្ឋភាពនៃវេទិការដ្ឋាភិបាល និងផ្នែកឯកជនបន្ថែមទៀតផងដែរ។

## ក្រុមការងារវិស័យទេសចរណ៍នៃវេទិការដ្ឋាភិបាល និងផ្នែកឯកជន

នៅខែសីហា ឆ្នាំ២០១៥ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាបានតែងតាំងលោក លូ ម៉េង ដែលជាប្រធានគណៈកម្មាធិការផ្នែកទេសចរណ៍ និងជាមេចុងភៅដ៏ល្បីល្បាញម្នាក់នៅកម្ពុជាយើង ឱ្យឈរឈ្មោះក្នុងការបោះឆ្នោតជ្រើសរើសសហប្រធានក្រុមការងារវិស័យទេសចរណ៍ (ក្រុមការងារ "ខ")។ ដូច្នេះ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាត្រូវបានផ្តល់ទំនុកចិត្តឱ្យធ្វើជាលេខាធិការដ្ឋានរបស់ក្រុមការងារវិស័យឯកជនរហូតដល់ឆ្នាំ២០១៨ នៅពេលដែលយើងបានផ្ទេរទំនួលខុសត្រូវនេះជូនសហព័ន្ធទេសចរណ៍កម្ពុជា ក្នុងគោលបំណងពង្រឹងសំឡេងតែមួយនៃអង្គភាពតំណាងវិស័យឯកជន។ ការធ្វើបែបនេះគឺដើម្បីធានាថាការរួមចំណែករបស់វិស័យឯកជនក្នុងក្រុមការងារ ខ បានទទួលគំនិតយោបល់ពីធុរកិច្ចទេសចរណ៍ និងបដិសណ្ឋារកិច្ចកាន់តែទូលំទូលាយថែមទៀត។

ក្រុមការងារ ខ ត្រូវបានរៀបចំរចនាសម្ព័ន្ធទៅជាអនុក្រុមតូចៗបន្ថែមទៀតដើម្បីសម្រួលដល់កិច្ចសន្ទនារវាងរាជរដ្ឋាភិបាល និងវិស័យឯកជនគោលដៅ អំពីបញ្ហាជាក់លាក់នានាផងដែរ។ ក្រោយមកក្រុមការងាររួមមានសហលេខាធិការដ្ឋាន ដែលមានសហប្រធានមកពីសហព័ន្ធទេសចរណ៍កម្ពុជា និងអគ្គនាយកដ្ឋានទេសចរណ៍ ដែលមានក្រុមការងារពិសេសតាមវិស័យចំនួនប្រាំពីរ ដែលក្រុម

ការងារទាំងនេះ ដឹកនាំរួមគ្នាដោយតំណាងផ្នែកបច្ចេកទេសមកពីក្រសួងទេសចរណ៍ និងតំណាងតាមវិស័យដែលបានចាត់តាំងដោយលេខាធិការដ្ឋានវិស័យឯកជន។

ចាប់តាំងពីពេលនោះមក ក្រុមការងារពិសេសរដ្ឋាភិបាល និងវិស័យឯកជនទាំងប្រាំពីរ បានជួបប្រជុំគ្នាជាទៀតទាត់ក្រោមការសម្របសម្រួលដោយសហលេខាធិការដ្ឋាន ក្នុងគោលបំណងខិតខំប្រឹងប្រែងលើកកម្ពស់ប្រទេសកម្ពុជាឱ្យក្លាយទៅជាគោលដៅទេសចរណ៍ដ៏សំខាន់ និងដើម្បីបង្កើនភាពងាយស្រួលក្នុងការធ្វើធុរកិច្ចនៅក្នុងវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច។

នៅក្នុងខែសីហា ឆ្នាំ២០១៧ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានស្នើបង្កើតក្រុមការងារពិសេសថ្មីមួយទៀត ដែលផ្តោតការយកចិត្តទុកដាក់ទៅលើ "យុទ្ធសាស្ត្រត្រៀមខ្លួនទទួលទេសចរចិន" ហើយបំបែកក្រុមការងារពិសេសផ្នែក "ទីផ្សារ និងផ្សព្វផ្សាយ" ជាមួយក្រុមផ្សេងគ្នាមួយគឺផ្តោតលើភ្ញៀវក្នុងស្រុក និងភ្ញៀវអន្តរជាតិ។ ដូច្នេះ បច្ចុប្បន្ននេះ យើងមានក្រុមការងារពិសេសចំនួនប្រាំបួនក្រុម រួមមានដូចជា៖

- ឧស្សាហកម្មទេសចរណ៍
- បណ្តុះបណ្តាល
- ភាពស្អាតអនាម័យ និងទេសចរណ៍បៃតង
- ស្រាវជ្រាវ និងការអភិវឌ្ឍ
- ទីផ្សារ និងផ្សព្វផ្សាយក្នុងស្រុក
- ទីផ្សារ និងផ្សព្វផ្សាយអន្តរជាតិ
- វិនិយោគ និងការអភិវឌ្ឍផលិតផលទេសចរណ៍
- ត្រៀមខ្លួនទទួលភ្ញៀវចិន (China Ready)
- សុវត្ថិភាព និងការដឹកជញ្ជូន

## ទស្សនវិស័យទៅមុខ

សភាពាណិជ្ជកម្មអឺរ៉ុបសូមស្វាគមន៍ចំពោះការបន្តប្តេជ្ញាចិត្តរបស់ក្រសួងទេសចរណ៍ដែលបានធ្វើការងារយ៉ាងសកម្មជាមួយវិស័យឯកជនដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនៅក្នុងវិស័យនេះទាំងមូល ហើយយើងត្រៀមខ្លួនបន្តសហការគ្នាដើម្បីសម្រេចឱ្យបានសមិទ្ធផលរួមថែមទៀត តាមរយៈយន្តការពិគ្រោះយោបល់ដូចបានលើកឡើងខាងលើនៅក្នុងក្របខណ្ឌក្រុមការងារ "ខ" នៃវេទិការដ្ឋាភិបាល និងផ្នែកឯកជននេះ។ ខណៈដែលសៀវភៅ ស នេះមានគោលបំណងផ្តល់ជាមូលដ្ឋានសម្រាប់គាំទ្រ និងលើកកម្ពស់ការពិភាក្សាសំដៅសម្របសម្រួលបរិយាកាសធ្វើធុរកិច្ចនៅកម្ពុជាឱ្យកាន់តែល្អប្រសើរឡើង ការពិគ្រោះយោបល់បែបនេះកំពុងតែប្រព្រឹត្តទៅបានយ៉ាងល្អរួចទៅហើយនៅក្នុងវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចនេះ។ ដោយមានការទទួលស្គាល់ចំពោះកិច្ចសហការកំពុងបន្តដ៏ល្អនេះ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាបានសម្រេចមិនដាក់បញ្ចូលអនុសាសន៍គោលនយោបាយសម្រាប់វិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចនៅក្នុងសៀវភៅ ស នេះឡើយ។

# អនុសាសន៍ស្ដីពីគោលនយោបាយ

## សម្រាប់ពាណិជ្ជកម្ម និងការវិនិយោគនៅកម្ពុជា

# វិស័យការពារការវិនិយោគ

ចាប់តាំងពីពេលបោះពុម្ពផ្សាយសៀវភៅ ស ឆ្នាំ២០១៧របស់យើងកន្លងមក រាជរដ្ឋាភិបាលបានចាប់ផ្ដើមអនុវត្តកម្មវិធីកំណែទម្រង់រចនាសម្ព័ន្ធទ្រង់ទ្រាយធំជាបន្តបន្ទាប់ ដើម្បីធ្វើឱ្យល្អប្រសើរឡើងនូវកិច្ចការ សម្របសម្រួលពាណិជ្ជកម្ម និងបង្កើន សមត្ថភាពប្រកួតប្រជែងរបស់ប្រទេសកម្ពុជា នៅលើឆាកអន្តរជាតិ ដែលភាគច្រើនត្រូវបានបង្ហាញដោយសម្ដេចនាយករដ្ឋមន្ត្រីនៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (G-PSF) កាលពីខែមីនា ឆ្នាំ២០១៩ កន្លងទៅនេះ។ ល្បឿនក្នុងការអនុវត្តកម្មវិធីកំណែទម្រង់នេះមិនត្រឹមតែបានបង្ហាញនូវការឆ្លើយតប ទាន់ពេលវេលាចំពោះការគំរាមកំហែងពីកត្តា ខាងក្រៅមកលើកិច្ចព្រមព្រៀងអនុគ្រោះផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែក៏មានការគូសបញ្ជាក់ថា កម្មវិធីកំណែទម្រង់ទាំងនេះមានសង្គតិភាពជាមួយនឹងផែនការយុទ្ធសាស្ត្របច្ចុប្បន្ន របស់រាជរដ្ឋាភិបាលនៅក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ចឱ្យកាន់តែមានភាពទូលំទូលាយជាងមុនថែមទៀត។

ជំពូកស្ដីពីពហុវិស័យនេះ មានគោលបំណងគូសរំលេចនូវផ្នែកមួយចំនួន នៃក្របខ័ណ្ឌច្បាប់របស់កម្ពុជាដែលគប្បី ពិនិត្យមើលឡើងវិញដើម្បីពង្រឹងសមត្ថភាព ប្រកួតប្រជែងរបស់ប្រទេសកម្ពុជា ក៏ដូចជាបរិយាកាសវិនិយោគទាំងមូលផងដែរ។

ផ្នែកទីមួយនៃជំពូកនេះ យន្តការពិនិត្យឡើងវិញផ្លូវច្បាប់ រួមមានអនុសាសន៍បានធ្វើបច្ចុប្បន្នភាពចំនួនពីរ ដែលប្រសិនបើទទួលបានការអនុម័តនោះ នឹងផ្ដល់នូវការធានាសុវត្ថិភាពកាន់តែរឹងមាំជាងមុនដល់វិនិយោគិនទាំងអស់។ មានការព្រួយបារម្ភនានាត្រូវបានលើកឡើងពាក់ព័ន្ធនឹងការអនុវត្តច្បាប់ប្រតិសកម្មថ្មី ឬការអនុវត្តច្បាប់ដែលមិនបានទុករយៈពេលអន្តរកាលគ្រប់គ្រាន់បានកើតឡើងកាន់តែញឹកញាប់ ហើយចំណុចដែលគួរឱ្យកត់សម្គាល់នោះគឺ ការប្រកាសឱ្យអនុវត្តនូវប្រកាសលេខ ៤២៣ ស្ដីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ។ ច្បាប់ប្រតិសកម្មគឺមានហានិភ័យយ៉ាងធ្ងន់ធ្ងរចំពោះបរិយាកាសបទប្បញ្ញត្តិ

ដោយហេតុថាការអនុវត្តច្បាប់នេះនឹងធ្វើឱ្យកើនឡើងនូវភាពមិនច្បាស់លាស់សម្រាប់វិនិយោគិន។ ជាងនេះទៅទៀត ប្រទេសកម្ពុជានៅមិនទាន់បានដាក់ចេញនូវយន្តការ ដែលអនុញ្ញាតឱ្យក្រុមហ៊ុនធុរកិច្ចអាចស្នើសុំឱ្យមានការពិនិត្យមើលសេចក្តីសម្រេច ឬវិធានការនានាដែលបានអនុវត្តដោយមន្ត្រីសាធារណៈដើម្បីធានាថា សេចក្តីសម្រេច ឬវិធានការទាំងនោះគឺស្របទៅតាមច្បាប់កម្ពុជានៅឡើយនោះទេ។ ទោះបីជាយើងពិតជាមានភាពរីករាយដែលបានមើលឃើញវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (G-PSF) ត្រូវបានបង្កើតឱ្យដំណើរការឡើងវិញក៏ដោយ ប៉ុន្តែវិធានការនេះបានដោះស្រាយតែបញ្ហានៅកម្រិតទូទាំងវិស័យជាជាងការដោះស្រាយបញ្ហាប្រឈមផ្នែករដ្ឋបាលជាក់លាក់ដែលក្រុមហ៊ុនឯកជននីមួយៗជួប ប្រទះនោះទេ។ ប្រសិនបើយន្តការនេះត្រូវបានដាក់ឱ្យអនុវត្ត នោះនឹងធ្វើឱ្យប្រទេសកម្ពុជាមានភាពស្របគ្នាជាមួយនឹងប្រទេសជិតខាងនៅក្នុងតំបន់មួយចំនួន និងធានាឱ្យមានកិច្ចការពារដោយស្មើភាពបន្ថែមទៀតសម្រាប់វិនិយោគិនទាំងអស់ផងដែរ។

ផ្នែកទីពីរនៅក្នុងជំពូកនេះ បានលើកឡើងអំពីភាពចាំបាច់នៅក្នុងការពន្លឿនការរៀបចំច្បាប់ថ្មីដើម្បីផ្តល់ដល់វិនិយោគិននូវការធានាផ្នែកច្បាប់បន្ថែមទៀត ដោយហេតុថាពេលខ្លះដំណើរការនេះពុំមានការរីកចម្រើនទៅមុខឡើយ។ យើងខ្ញុំបានផ្តល់សំណូមពរជាបន្តបន្ទាប់ជូនដល់រាជរដ្ឋាភិបាលកម្ពុជាឱ្យបង្កើនភាពទំនុកចិត្តនៅក្នុងចំណោមវិនិយោគិនដែលមានបំណងបណ្តាក់ទុននៅកម្ពុជា និងគ្រឹះស្ថានផ្តល់ឥណទានដោយផ្តល់ការធានាការលើកទឹកចិត្ត និងការផ្តល់ជំនួយកាន់តែល្អប្រសើរ ជាងមុនតាមរយៈការធ្វើបច្ចុប្បន្នភាពច្បាប់វិនិយោគ។ ស្រដៀងគ្នានេះដែរ យើងសូមគូសបញ្ជាក់អំពីភាពចាំបាច់នៅក្នុងការផ្តល់អាទិភាពទៅលើការអនុម័តច្បាប់ពាណិជ្ជកម្មសំខាន់ៗជាច្រើន ដែលជាផ្នែកមួយនៃការប្តេជ្ញាចិត្តជាអន្តរជាតិរបស់ប្រទេសកម្ពុជា និងដើម្បីការពារធុរកិច្ចជន និងវិនិយោគិនឱ្យរួចផុតពីការអនុវត្តបែបឆ្កៀតឱកាសនិយមដែលអាចកើតមានឡើង។

ផ្នែកចុងក្រោយនៅក្នុងជំពូកនេះ រៀបរាប់អំពីការពិនិត្យមើលលម្អិតទៅលើក្របខ័ណ្ឌច្បាប់និងរដ្ឋបាលរបស់ប្រទេសកម្ពុជា សម្រាប់កិច្ចការពារកម្មសិទ្ធិបញ្ញា (IPR)។ ទោះបីជាក្របខ័ណ្ឌច្បាប់សម្រាប់កិច្ចការពារកម្មសិទ្ធិបញ្ញានៅក្នុងប្រទេសកម្ពុជាកំពុងមានការរីកចម្រើនច្រើនក៏ដោយ ប៉ុន្តែនៅតែមានបញ្ហាប្រឈមជាច្រើននៅជុំវិញការអនុវត្តកម្មសិទ្ធិបញ្ញា ហើយការគាំទ្រពីសំណាក់អាជ្ញាធររដ្ឋបាលពាក់ព័ន្ធអាចនៅមានកម្រិតនៅឡើយ។ នៅពេលដែលក្រុមហ៊ុនធុរកិច្ចជួបប្រទះការប្រើប្រាស់ម៉ាកពាណិជ្ជនាមរបស់ខ្លួនដោយខុសច្បាប់ បន្ទុកនេះនឹងធ្លាក់ទៅលើម្ចាស់ពាណិជ្ជនាមនៅក្នុងការដាក់ពាក្យបណ្ដឹងទៅតុលាការ និង/ឬអាជ្ញាធរមានសមត្ថកិច្ចក្នុងប្រទេសកម្ពុជា និងត្រូវប្រមូលភស្តុតាងដើម្បីជាអំណះអំណាងសម្រាប់បណ្ដឹងរបស់ខ្លួន។ ទោះបីយ៉ាងណាក៏ដោយក្រុមហ៊ុនដែលបានគោរពច្បាប់ត្រឹមត្រូវអាចមានការប្រយ័ត្នប្រយែងនៅក្នុងការបញ្ជូនករណីរបស់ខ្លួនទៅកាន់តុលាការដើម្បីប្ដឹងប្រឆាំងនឹងការលួចប្រើប្រាស់ផលិតរបស់ខ្លួន ដោយសារក្រុមហ៊ុនទាំងនោះបារម្ភថាខ្លួនអាចនឹងរងការប្ដឹងបក ដោយក្រុមជនល្មើសវិញ។ ដើម្បីដោះស្រាយបញ្ហានេះប្រកបដោយប្រសិទ្ធភាព យើងបានដាក់បញ្ចូលអនុសាសន៍ចំនួនប្រាំដែលកំណត់ថាតើត្រូវធ្វើកំណែទម្រង់ផ្នែកណាខ្លះនៅក្នុងដំណាក់កាលផ្សេងៗនៃរបបការពារកម្មសិទ្ធិបញ្ញា។

យើងសង្ឃឹមថា រាជរដ្ឋាភិបាលនឹងធ្វើការពិចារណានៅក្នុងការអនុម័តសំណើទាំងនេះ ដោយសារតែអនុសាសន៍ទាំងនេះនឹងជួយលើកកម្ពស់ក្របខ័ណ្ឌវិនិយោគរបស់ប្រទេសកម្ពុជាបានគ្រប់ជ្រុងជ្រោយ ដែលធ្វើឱ្យប្រទេសកម្ពុជាកាន់តែមានលក្ខណៈស្របទៅនឹងឧត្តមានុវត្តន៍អន្តរជាតិ និងលើកទឹកចិត្តឱ្យមានលំហូរចូលវិនិយោគផ្ទាល់ ពីបរទេសកាន់តែច្រើនថែមទៀតនៅក្នុងរយៈពេលប៉ុន្មានឆ្នាំទៀតខាងមុខនេះ។

១

# ការការពារពីការអនុវត្តច្បាប់ថ្មីបែបប្រតិសកម្ម

ធ្វើបច្ចុប្បន្នភាព

**ពិពណ៌នាបញ្ហា**

*ការព្រួយបារម្ភពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់ថ្មីបែបប្រតិសកម្ម ត្រូវបានលើកឡើងដោយគណៈកម្មាធិការតាមវិស័យជាច្រើនរបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ហើយនេះគឺជាបញ្ហាដ៏សំខាន់មួយដែលត្រូវបានលើកមកធ្វើការពិភាក្សានៅក្នុងសៀវភៅសរបស់យើង។ ឧទាហរណ៍មានដូចខាងក្រោម៖*

*នៅក្នុងវិស័យធនធានមនុស្ស ការដាក់ចេញដោយមិនបានរំពឹងទុកមុននូវប្រកាសលេខ ៤៤៣ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារកាលពីខែកញ្ញា ឆ្នាំ២០១៨ បានបង្កឱ្យមានភាពមិនច្បាស់លាស់យ៉ាងធ្ងន់ធ្ងរសម្រាប់វិស័យឯកជនទាំងមូល ដែលបញ្ហាភាគច្រើនគឺដោយសារតែការដាក់បញ្ចូលនូវសមាសភាគទូទាត់ប្រាក់បំណាច់អតីតភាពការងារបែបប្រតិសកម្ម។ បច្ចុប្បន្ន ប្រកាសលេខ ៤៤៣ តម្រូវឱ្យនិយោជកបង់ប្រាក់ជូនកម្មករនិយោជិតដែលមានកិច្ចសន្យាការងាររយៈពេលមិនកំណត់នូវទឹកប្រាក់ចំនួនពីរដងក្នុងមួយឆ្នាំ ដែលមានតម្លៃស្មើទៅនឹងប្រាក់បៀវត្សចំនួន ១៥ ថ្ងៃ ព្រមទាំងអត្ថប្រយោជន៍បន្ថែមផ្សេងទៀត សម្រាប់ឆ្នាំដែលបានបំពេញការងារនីមួយៗផងដែរ រហូតដល់រយៈពេល ១២ ឆ្នាំនៃការបំពេញការងាររបស់ខ្លួន។ និយោជកក៏ត្រូវបានតម្រូវឱ្យបង់ប្រាក់ជូនកម្មករនិយោជិតជាលក្ខណៈប្រតិសកម្មសម្រាប់រយៈពេលដែលពួកគាត់បានបំពេញការងារ ដែលបានបូកបង្គរនៅមុនពេលប្រកាសលេខ ៤៤៣ ត្រូវបានអនុម័តផងដែរ ដែលហៅថា ប្រាក់រំលឹកអតីតភាពការងារ។ ទោះបីជាធុរកិច្ចទទួលស្គាល់ចំពោះកិច្ចគាំពារបន្ថែម ដែលបទប្បញ្ញត្តិនេះនឹងផ្តល់ជូនដល់កម្មករនិយោជិតនៅក្នុងវិស័យមួយចំនួនក៏ដោយ ប៉ុន្តែការអនុវត្តលក្ខណៈប្រតិសកម្មបានបង្កឱ្យមានទំនួលខុសត្រូវជាបន្ទុកដែលមិនបានដឹងជាមុនសម្រាប់និយោជកទាំងអស់នៅក្នុងសេចក្តីសម្រេចចិត្តធុរកិច្ចដែលមិនទាន់បានកើតឡើង ដោយសារតែនៅមុនពេលមានបទប្បញ្ញត្តិនេះ សំណងត្រូវបានផ្តល់ជូនតែក្នុងករណីកម្មករនិយោជិតត្រូវបានបញ្ឈប់ពីការងារប៉ុណ្ណោះ ដែលករណីនេះស្រដៀងទៅនឹងបណ្តាប្រទេសជាច្រើនផ្សេងទៀតផងដែរ។*

*ទោះបីយ៉ាងនេះក្តី តាមរយៈកិច្ចពិភាក្សាប្រកបដោយផ្លែផ្ការវាងរាជរដ្ឋាភិបាល និងវិស័យឯកជន (រួមទាំងសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា សភាពាណិជ្ជកម្មកម្ពុជា និងបណ្តាសមាគមធុរកិច្ចចំនួន ៣០ ផ្សេងទៀត) ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុដែលកើតចេញពីប្រកាសលេខ ៤៤៣ នេះត្រូវបានកាត់បន្ថយសម្រាប់វិស័យផ្សេងទៀតក្រៅពីវិស័យកាត់ដេរ ស្បែកជើង និងវាយនភណ្ឌ។ កាលពីខែមីនា ឆ្នាំ២០១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញសេចក្តីណែនាំលេខ ០៤២ ដែលប្រកាសការពន្យារពេលអនុវត្តចំណុចដែលមានប្រតិសកម្មរហូតដល់ខែធ្នូ ឆ្នាំ២០២១ ទើបអនុវត្ត ហើយបានកាត់បន្ថយចំនួនថ្ងៃដែលត្រូវបង់សំណងនៅត្រឹម ៦ ថ្ងៃសម្រាប់រៀងរាល់ឆ្នាំដែលបានបំពេញការងារនៅមុនឆ្នាំ២០១៩។*

ជាងនេះទៅទៀត នៅក្នុងវិស័យអចលនទ្រព្យ និងសំណង់ កាន់តែមានភាពមិនច្បាស់លាស់ទៅលើច្បាប់ស្ដីពីការសាងសង់ដែលនឹងត្រូវអនុម័តនាពេលខាងមុខដែលមានដាក់បញ្ចូលនូវច្បាប់សាងសង់ និងលក្ខខណ្ឌតម្រូវនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយសារអ្នកអភិវឌ្ឍន៍មិនទាន់ដឹងច្បាស់ថាតើខ្លួនត្រូវមានកាតព្វកិច្ចអ្វីខ្លះនៅក្រោមច្បាប់ថ្មីទាំងនេះនោះទេ។ ជាពិសេស វិស័យទាំងនេះមានការព្រួយបារម្ភថានឹងមានការដាក់ពិន័យចំពោះការមិនគោរពតាមរបស់គម្រោងដែលបានបញ្ចប់នៅមុនពេលមានបទប្បញ្ញត្តិនោះ ឬបារម្ភអាចមានពេលវេលាមិនគ្រប់គ្រាន់សម្រាប់គម្រោងនៅក្នុងការកែប្រែ និងត្រលប់មកអនុលោមតាមបទប្បញ្ញត្តិនេះវិញនៅមុនពេលមានការដាក់ពិន័យ។

## ផលប៉ះពាល់លើកម្ពុជា

ក្រុមហ៊ុនធុរកិច្ចចាំបាច់ត្រូវការដឹងអំពីស្ថានភាពជាមុន និងលទ្ធភាពអាចព្យាករណ៍ចំពោះកាតព្វកិច្ចផ្លូវច្បាប់របស់ខ្លួនដើម្បីធ្វើការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការហិរញ្ញវត្ថុរយៈពេលវែង។ នៅពេលដែលបរិយាកាសនៃបទប្បញ្ញត្តិមិនអាចព្យាករណ៍បាន ហើយច្បាប់ថ្មីអាចអនុវត្តជាលក្ខណៈប្រតិសកម្ម ឬទុកពេលវេលាអន្តរកាលមិនគ្រប់គ្រាន់ កត្តានេះនាំឱ្យមានហានិភ័យផ្នែកបទប្បញ្ញត្តិ និងថ្លៃចំណាយបន្ថែមសម្រាប់ក្រុមហ៊ុនធុរកិច្ច។ បទប្បញ្ញត្តិថ្មី ដូចជា ប្រកាសលេខ ៤២៣ ត្រូវបានអនុម័តដោយមានការចូលរួមតិចតួចប៉ុណ្ណោះពីសំណាក់វិស័យឯកជនដែលនាំឱ្យមានបន្ទុកហិរញ្ញវត្ថុមិនបានដឹងជាមុនសម្រាប់ធុរកិច្ច ដែលអាចប៉ះពាល់ទៅដល់កិត្តិនាមប្រទេសកម្ពុជាក្នុងនាមជាប្រទេសមានបរិយាកាសល្អសម្រាប់ការវិនិយោគទៀតផង។ បញ្ហាប្រតិសកម្មនេះក៏ត្រូវបានលើកឡើងផងដែរនៅក្នុងវេទិកាពាជរដ្ឋាភិបាល-ផ្នែកឯកជន (G-PSF) ដែលមានសម្ដេចនាយករដ្ឋមន្ត្រីជាប្រធានកាលពីខែមីនា ឆ្នាំ២០១៩ កន្លងទៅ ដោយសារតែបញ្ហានេះជះឥទ្ធិពលជាអវិជ្ជមានដល់ភាព ប្រកួតប្រជែងរបស់ប្រទេសកម្ពុជា និងធ្វើឱ្យវិនិយោគិនផ្សេងទៀតមានការរារែកក្នុងការវិនិយោគ ដោយហេតុថា ធុរកិច្ចមិនអាចធានាបានថាខ្លួននឹងមិនរងការប៉ះពាល់ដោយសារផលវិបាកនៃច្បាប់នាពេលអនាគត ដែលត្រូវបានអនុវត្តជាលក្ខណៈប្រតិសកម្ម។

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមផ្តល់ការធានាថា ច្បាប់ និងបទប្បញ្ញត្តិនាពេលអនាគត មានដាក់បញ្ចូលនូវបទប្បញ្ញត្តិអន្តរកាលដាក់ស្តែង ហើយលិខិតូបករណ៍ថ្មីៗ មិនគប្បីអនុវត្តដើម្បីដាក់ពិន័យប្រតិសកម្មសម្រាប់ការមិន អនុវត្តតាមឡើយ។

*យើងខ្ញុំសូមទទួលស្គាល់ចំពោះវិធីសាស្ត្រប្រកបដោយការយោគយល់ និងស្មើភាពរបស់រាជរដ្ឋាភិបាលនៅក្នុងការលុបបំបាត់ការព្រួយបារម្ភរបស់វិស័យឯកជនពាក់ព័ន្ធនឹងប្រកាសលេខ ៤២៣ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ហើយសមាជិករបស់យើងខ្ញុំក៏សូមស្វាគមន៍ចំពោះលទ្ធផលជាវិជ្ជមានដែលកើតចេញពីការពិភាក្សាប្រកបដោយការស្តាប់នាកន្លងមកផងដែរ។*

*ពាក់ព័ន្ធនឹងការបង្កើតច្បាប់ និងបទប្បញ្ញត្តិនាពេលអនាគត យើងខ្ញុំសូមគោរពផ្តល់ជូនអនុសាសន៍ឱ្យរាជរដ្ឋាភិបាលកម្ពុជា ធ្វើការពិចារណាដាក់បញ្ចូលបញ្ញត្តិអន្តរកាលដាក់ស្តែង ហើយប្រសិនបើមានភាពចាំបាច់ គប្បីទុកពេលវេលាឱ្យបានគ្រប់គ្រាន់បន្ទាប់ពីបានអនុម័តច្បាប់ថ្មី ដើម្បីអាចឱ្យក្រុមហ៊ុនធុរកិច្ចមានឱកាសគ្រប់គ្រាន់ក្នុងការសម្របការអនុវត្តតាមលក្ខខណ្ឌតម្រូវរបស់ខ្លួនសំដៅធានាការអនុវត្តតាម ច្បាប់ទាំងនោះ។ ដំណើរការបោះពុម្ព និងផ្សព្វផ្សាយច្បាប់ថ្មីគួរតែដាក់បញ្ចូលទៅ ក្នុងដំណើរការ ពិនិត្យឡើងវិញនេះដើម្បីធានាថាវិស័យឯកជនមានការយល់ដឹងគ្រប់ គ្រាន់ និងទាន់ពេលវេលាអំពីច្បាប់ថ្មីដែលនឹងអនុម័តនោះ។ ដើម្បីបង្កើនទំនុកចិត្ត និងពង្រឹងទំនាក់ទំនងការងារជាមួយនឹងវិស័យឯកជន យើងខ្ញុំសូមលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាលធ្វើការពិចារណាដាក់បញ្ចូលភាគីពាក់ព័ន្ធឱ្យបានកាន់តែទូលំទូលាយជាងមុននៅក្នុងដំណើរការបង្កើតច្បាប់ថ្មីទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ដោយសារតែការអនុវត្តបែបនេះនឹងជំរុញឱ្យមានវិធីសាស្ត្រកាន់តែល្អិតល្អន់ និងចំគោលដៅថែមទៀតចំពោះការបង្កើតគោលនយោបាយ។*

*ជាពិសេស យើងខ្ញុំក៏សូមផ្តល់អនុសាសន៍ឱ្យរាជរដ្ឋាភិបាលធ្វើការអនុម័តគោលការណ៍ទូទៅដែលកំណត់ថា លិខិតូបករណ៍ថ្មីៗមិនគួរអនុវត្តចំពោះការដាក់ពិន័យប្រតិសកម្មចំពោះការមិនអនុវត្តតាមឡើយ ហើយការដាក់ពិន័យនោះ គប្បីអនុវត្តចំពោះតែរយៈពេលក្រោយធ្វើអន្តរកាលដែលបានកំណត់ច្បាស់លាស់ប៉ុណ្ណោះ។*

២

# លទ្ធភាពនៃការបង្កើតយន្តការឯករាជ្យសម្រាប់ពិនិត្យឡើងវិញ នូវការអនុវត្តច្បាប់

ធ្វើបច្ចុប្បន្នភាព

### ពិពណ៌នាបញ្ហា

*នៅក្នុងករណីជាក់ស្តែងមួយចំនួន គម្រោងវិនិយោគអាចជួបប្រទះឧបសគ្គ ឬមានការយឺតយ៉ាវខ្លាំងដោយសារតែការទទួលបានសេវារដ្ឋបាលធម្មតា ដូចជា ការចុះបញ្ជី និងការចេញអាជ្ញាប័ណ្ណជាដើមត្រូវបានបដិសេធដោយសារតែមូលហេតុណាមួយ ដែលទោះបីជាវិនិយោគិនបានបំពេញសព្វគ្រប់ តាមលក្ខណៈវិនិច្ឆ័យនានាសម្រាប់ការទទួលបានសេវាទាំងនោះហើយក្តី។ ឧទាហរណ៍មួយដែលត្រូវបានអះអាងថាមានបញ្ហាស្មុគស្មាញខ្លាំងកាលពីឆ្នាំកន្លងទៅនោះ គឺដំណើរការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម។ នៅក្នុងដំណើរការនេះពុំមានឡើយនូវ «រយៈពេលឆ្លើយតបអតិបរមា» សម្រាប់ក្រសួងត្រូវគោរពតាម ហើយការចុះបញ្ជីរបស់វិនិយោគិនជាច្រើនមានភាពយឺតយ៉ាវ ឬត្រូវបានបង្អប់ទុកចោលមិនចាត់ការដោយមិនមានមូលហេតុច្បាស់លាស់ទាល់តែសោះ។ លើសពីនេះទៅទៀត ដំណើរការចុះបញ្ជីពាណិជ្ជកម្មអនឡាញ (online) នោះមិនបានបំពេញមុខងារល្អតាមការគ្រោងទុកឡើយ។ ជារឿយៗ អ្នកប្រើប្រាស់ត្រូវបានតម្រូវឱ្យផ្តល់ច្បាប់ចម្លងឯកសារជាក្រដាសបន្ថែមទៅលើអ្វីដែលបានបំពេញចប់សព្វគ្រប់អស់ហើយនៅក្នុងគំរូអនឡាញ ឬបើមិនដូច្នោះទេ ត្រូវដាក់ពាក្យសារឡើងវិញដោយសារកំហុសបច្ចេកទេសរបស់ប្រព័ន្ធអនឡាញ។ ស្ថានភាពនេះបានធ្វើឱ្យមានការអូសបន្លាយពេលកាន់តែយូរសម្រាប់ដំណើរការចុះបញ្ជីទៅវិញ។*

*បច្ចុប្បន្ន ពុំទាន់មានយន្តការណាមួយដែលក្រុមហ៊ុនធុរកិច្ចអាចស្នើឱ្យមានការត្រួតពិនិត្យឡើងវិញទៅលើសេចក្តីសម្រេច ឬចំណាត់ការរបស់មន្ត្រីសាធារណៈដើម្បីធានាថាការអនុវត្តនោះពិតជាស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេស និងដើម្បីកំណត់ឱ្យបានថាតើលិខិតតូបករណ៍គតិយុត្តទាំងនោះត្រូវបានប្រើប្រាស់ប្រកបដោយសង្គតិភាព និងគ្មានការរើសអើងដែរឬយ៉ាងណានោះទេ។*

*នៅតាមបណ្តាប្រទេសជាច្រើន រួមទាំងប្រទេសជិតខាងរបស់កម្ពុជាដែលនៅក្នុងតំបន់តែមួយ ដូចជា ប្រទេសថៃ និងវៀតណាមមានប្រព័ន្ធតុលាការរដ្ឋបាលដើម្បីអនុញ្ញាតឱ្យបុគ្គលឯកជន ឬក្រុមហ៊ុនធុរកិច្ចដែលយល់ឃើញថាខ្លួនទទួលរងចំណាត់ការមិនប្រក្រតីពីសំណាក់មន្ត្រីសាធារណៈ អាចធ្វើការប្តឹងជំទាស់ ឬអាចស្នើសុំឱ្យតុលាការរដ្ឋបាលនោះពិនិត្យមើលករណីរបស់ខ្លួនឡើងវិញ។*

## ផលប៉ះពាល់លើកម្ពុជា

*កង្វះខាតយន្តការពិនិត្យឡើងវិញដោយឯករាជ្យទៅលើការអនុវត្តច្បាប់នេះ ធ្វើឱ្យមានហានិភ័យផ្លូវច្បាប់កាន់តែខ្លាំងចំពោះវិនិយោគិនថ្មីនៅពេលពួកគេធ្វើការវាយតម្លៃលើប្រទេសកម្ពុជា ដែលកត្តានេះជះឥទ្ធិពលជាអវិជ្ជមានដល់លំហូរនៃការវិនិយោគ។ ជាពិសេស ធនាគារអន្តរជាតិ និងស្ថាប័នផ្តល់ឥណទាន រឹតតែមានភាពស្ទាក់ស្ទើរក្នុងការផ្តល់មូលនិធិសម្រាប់ការវិនិយោគនៅក្នុងប្រទេសកម្ពុជា ប្រសិនបើពួកគេយល់ឃើញថាប្រទេសនេះមានហានិភ័យផ្លូវច្បាប់ខ្ពស់ពេក។*

*ការបង្កើតឱ្យមានយន្តការឯករាជ្យបែបនេះនឹងជួយពង្រឹងទំនុកចិត្តរបស់វិនិយោគិន ហើយជាងនេះទៅទៀត នឹងពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការធានាឱ្យមានការអនុវត្តច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យបង្កើតយន្តការពិនិត្យឡើងវិញមានលក្ខណៈឯករាជ្យនៅតាមក្រសួង និងស្ថាប័នសាធារណៈពាក់ព័ន្ធដែលទទួលខុសត្រូវក្នុងការចាត់ចែង និងធ្វើសេចក្តីសម្រេចលើពាក្យស្នើសុំរបស់អង្គភាពឯកជន និងបង្កើតតុលាការរដ្ឋបាលកំពូលមួយផងដែរ។

ក). *យើងខ្ញុំសូមផ្តល់ជូនអនុសាសន៍ឱ្យបង្កើតយន្តការពិនិត្យឡើងវិញដោយឯករាជ្យមួយសម្រាប់ករណីពាក់ព័ន្ធនឹងវិវាទរវាងស្ថាប័នសាធារណៈ និងអង្គភាពឯកជន។ នៅពេលដែលតុលាការរដ្ឋបាលកំពូលមួយអាចដើរតួនាទីជាអង្គភាពចុងក្រោយសម្រាប់ដោះស្រាយបណ្តឹងតវ៉ាជំទាស់ យើងខ្ញុំសូមស្នើថានៅតាមក្រសួង និងអាជ្ញាធរសាធារណៈនីមួយៗគួរតែមានយន្តការឯករាជ្យសម្រាប់ដោះស្រាយវិវាទក្នុងការចាត់ចែងពាក្យស្នើសុំ និងការអនុម័តយល់ព្រមដល់បណ្តាអង្គភាពធុរកិច្ចឯកជន។ យើងសូមលើកមកបង្ហាញនូវគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ (CTA) ដែលត្រូវបានបង្កើតឡើងកាលពីឆ្នាំកន្លងទៅដោយអនុក្រឹត្យលេខ ០៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ (ចុះនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦) ជាស្ថាប័នមានសក្តានុពលអាចដើរតួនាទីជាគំរូនៃយន្តការដោះស្រាយវិវាទបែបនេះបាន។ តាមរយៈគណៈកម្មាធិការនេះ អ្នកជាប់ពន្ធអាចប្តឹងតវ៉ាជំទាស់ទៅនឹងការបកស្រាយបទប្បញ្ញត្តិពន្ធដារដោយអគ្គនាយកដ្ឋានពន្ធដារ ឬដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករដែលពាក់ព័ន្ធនឹងកាតព្វកិច្ចពន្ធរបស់ខ្លួន ហើយតាមរយៈបណ្តឹងតវ៉ាជំទាស់នេះ អ្នកជាប់ពន្ធអាចស្នើឱ្យមានការពិនិត្យឡើងវិញដោយឯករាជ្យទៅលើករណីរបស់ខ្លួនបាន។*

២) *ដោយទទួលស្គាល់ថា ក្រសួងពាណិជ្ជកម្ម កំពុងរៀបចំធ្វើសេចក្តីព្រាងប្រកាសថ្មីដើម្បីបង្កើតក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ាស្របទៅតាមការអនុវត្តអនុក្រឹត្យនៃច្បាប់ស្តីពីពាណិជ្ជនាម យើងខ្ញុំសូមផ្តល់ជូនអនុសាសន៍ដោយស្នើឱ្យក្រសួងរៀបចំឱ្យមានការចូលរួមពីសំណាក់វិស័យឯកជននៅក្នុងដំណើរការរៀបចំសេចក្តីព្រាងនេះផងដែរ។ ការចូលរួមយ៉ាងសកម្មរបស់វិស័យឯកជននឹងធានាថាក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ានេះនឹងឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវតម្រូវការរបស់សហគមន៍ធុរកិច្ច ហើយនឹងជួយលើកកម្ពស់ភាពស្របច្បាប់នៃយន្តការដែលត្រូវបានបង្កើតឡើងនេះផងដែរ។*

គ. *ជាងនេះទៅទៀត យើងខ្ញុំសូមស្នើឱ្យក្រសួងពាណិជ្ជកម្មធ្វើការកំណត់ «រយៈពេលឆ្លើយតបអតិបរមា» សម្រាប់ការដាក់ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម និងយល់ព្រមរៀបចំឱ្យមានការពិនិត្យមើលឡើងវិញដោយឯករាជ្យក្នុងករណីហួសរយៈពេលកំណត់នេះ។*

៣

# ការបង្កើនទំនុកចិត្តពីសំណាក់វិនិយោគិនតាមរយៈការធ្វើបច្ចុប្បន្នភាពច្បាប់ស្តីពីការវិនិយោគ

ធ្វើបច្ចុប្បន្នភាព

---

**អនុសាសន៍ឆ្នាំ ២០១៧**

សូមផ្តល់ការធានាការលើកទឹកចិត្តនិងជំនួយច្រើនជាងមុនដល់វិនិយោគិនតាមរយៈច្បាប់វិនិយោគថ្មីដោយរួមបញ្ចូលអនុសាសន៍ពីវិស័យឯកជនផង។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*រាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌច្បាប់សម្រាប់គ្រប់គ្រងការវិនិយោគបរទេស និងក្នុងស្រុកនៅកម្ពុជា ដោយកំពុងរៀបចំវិសោធនកម្មច្បាប់ស្តីពីការវិនិយោគ និងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសថ្មី។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ដែលបានដឹកនាំដំណើរការនេះ បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់កាលពីខែកុម្ភៈ ឆ្នាំ២០១៩ កន្លងទៅ ដើម្បីប្រមូលធាតុចូលពីវិស័យ ឯកជន និងដៃគូពហុភាគីដើម្បីធ្វើឱ្យច្បាប់នាពេលខាងមុខកាន់តែល្អប្រសើរថែមទៀត។*

*នៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (G-PSF) ដែលដឹកនាំដោយសម្តេចនាយករដ្ឋមន្ត្រីកាលពីខែមីនា ឆ្នាំ២០១៩ កន្លងទៅនេះ បានការបញ្ជាក់ថាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានប្តេជ្ញាធ្វើការបញ្ចប់សេចក្តីព្រាងវិសោធនកម្មច្បាប់ឱ្យបាននៅមុនដំណាច់ខែមិថុនា ឆ្នាំ២០១៩ ដែលបន្ទាប់ពីនោះ សេចក្តីព្រាងនេះនឹងត្រូវពិនិត្យមើលឡើងវិញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយបន្ទាប់មកគឺគណៈរដ្ឋមន្ត្រី និងក្រុមប្រឹក្សាអ្នកច្បាប់។ នៅក្នុងវេទិកានេះក៏មានការប្រកាសផងដែរអំពីសេចក្តីសម្រេចដកចេញនូវជំពូកស្តីពីការលើកទឹកចិត្តការវិនិយោគចេញពីច្បាប់ស្តីពីការវិនិយោគ ដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ថវិកាជាតិជំនួសវិញ។ ដំណើរការបែបនេះត្រូវបានរំពឹងថានឹងផ្តល់ភាពបត់បែនជាងមុនដល់រាជរដ្ឋាភិបាលនៅក្នុងការលើកទឹកចិត្តដល់វិស័យអាទិភាពដោយអាស្រ័យទៅលើតម្រូវការនៃវិស័យសេដ្ឋកិច្ច។*

---

**ពិពណ៌នាបញ្ហា**

*ច្បាប់ស្តីពីការវិនិយោគរបស់កម្ពុជាត្រូវបានអនុម័តនៅក្នុងឆ្នាំ១៩៩៤ ហើយក្រោយមកទៀត ត្រូវបានធ្វើវិសោធនកម្មនៅក្នុងឆ្នាំ២០០៣ នៅដំណាក់កាលមួយដែលការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជានៅមានកម្រិតទាបខ្លាំងជាងអ្វីដែលយើងកំពុងមើលឃើញនាបច្ចុប្បន្ននេះ។ ទន្ទឹមនឹងកំណើនលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស (FDI) នៅក្នុងគម្រោងមានទ្រង់ទ្រាយកាន់តែធំ និងកាន់តែមានស្មុគស្មាញជាងមុន រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់នូវភាពចាំបាច់ក្នុងការធ្វើបច្ចុប្បន្នភាពច្បាប់ស្តីពីការវិនិយោគ និងបានធ្វើការពិគ្រោះយោបល់ជាមួយវិស័យឯកជន នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះដើម្បីបង្កើតច្បាប់ថ្មីមួយដែលសមស្របទៅនឹងបរិបទសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន។ ស្របពេលដែលរាជរដ្ឋាភិបាលបន្តដំណើរការពិគ្រោះយោបល់នេះ យើងខ្ញុំសូមបង្ហាញអំពីការព្រួយបារម្ភមួយចំនួននៅក្នុងវិស័យបួនដូចខាងក្រោមនេះ*

## ១. តួនាទីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ច្បាប់ស្ដីពីការវិនិយោគ (ឆ្នាំ១៩៩៤) និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការវិនិយោគ (ឆ្នាំ២០០៣) បានកំណត់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាថាជា «ច្រកសេវាចេញចូលតែមួយ» ដែលដើរតួនាទីជា «សេនាធិការរបស់រាជរដ្ឋាភិបាល» ទទួលខុសត្រូវលើការវាយតម្លៃ និងធ្វើសេចក្ដីសម្រេចរាល់សកម្មភាពស្ដារឡើងវិញ ការអភិវឌ្ឍ និងគម្រោងវិនិយោគ» នៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែជាក់ស្ដែង វិនិយោគិនតែងតែមើលឃើញថា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាចផ្ដល់ជំនួយតែក្នុងដំណាក់កាលដំបូងនៃការចុះបញ្ជីពាណិជ្ជកម្មប៉ុណ្ណោះ ហើយហាក់ដូចជាមិនអាចផ្ដល់ជំនួយនៅក្នុងការស្នើសុំអាជ្ញាប័ណ្ណដែលជាលក្ខខណ្ឌចាំបាច់របស់ក្រសួងនានាបានឡើយ។ ប្រសិនបើក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវបានផ្ដល់សិទ្ធិអំណាច និងត្រូវបានអនុញ្ញាតឱ្យធានាអាជ្ញាប័ណ្ណចាំបាច់ដោយតាំងនាមឱ្យវិនិយោគិនសម្រាប់គម្រោងដែលខ្លួនបានអនុម័តរួចហើយ នោះដំណើរការនេះនឹងមានប្រសិទ្ធភាពជាងមុន ព្រមទាំងកាត់បន្ថយការចំណាយ និងភាពយឺតយ៉ាវបានផងដែរ។

## ២. ការធានាចំពោះការវិនិយោគ

ប្រទេសកម្ពុជាបានផ្ដល់សច្ចាប័នលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយអាស៊ានស្ដីពីការវិនិយោគ (ACIA) ដែលដាក់កាតព្វកិច្ចឱ្យរដ្ឋជាសមាជិកអាស៊ានទាំង ១០ ក្នុងការផ្ដល់កិច្ចការពារនានាដល់ការវិនិយោគរបស់នីតិបុគ្គលនៅក្នុងសមាគមតំបន់នេះ។ កិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយអាស៊ានស្ដីពីការវិនិយោគនេះជាកម្រងនៃការប្ដេជ្ញាចិត្តដែលនឹងរួមចំណែកច្រើនដល់ការលើកកម្ពស់ឱ្យមានបរិយាកាសវិនិយោគដោយសេរី និងមានលក្ខណៈប្រកួតប្រជែងនៅក្នុងតំបន់អាស៊ាន ប្រសិនបើកិច្ចព្រមព្រៀង នេះត្រូវបានរដ្ឋជាសមាជិកទាំងអស់អនុវត្តតាមបានយ៉ាងពេញលេញនោះ។ ប្រទេសកម្ពុជាកំពុងតែខិតខំធ្វើការឆ្ពោះទៅអនុវត្តកិច្ចព្រមព្រៀងឱ្យបានពេញលេញ ប៉ុន្តែលទ្ធផលនៅពុំទាន់មានលទ្ធភាពចាប់យកសក្ដានុពលផលចំណេញសេដ្ឋកិច្ចឱ្យបានជាអតិបរមាដែលកិច្ចព្រមព្រៀងនេះអាចផ្ដល់ឱ្យនៅឡើយនោះទេ។ ប្រទេសកម្ពុជាក៏បានចុះហត្ថលេខាទ្វេភាគីលើអនុសញ្ញាការពារការវិនិយោគជាមួយរដ្ឋសមាជិក ១១ ប្រទេសរបស់សហភាពអឺរ៉ុបផងដែរ ដូច្នេះការចុះហត្ថលេខានេះទុកឱ្យរដ្ឋសមាជិក ១៧ ប្រទេសផ្សេងទៀតស្ថិតនៅក្រៅវិសាលភាពនៃកិច្ចការពារនេះ។

## ៣. ការលើកទឹកចិត្តការវិនិយោគ

ជំពូកទី ៥ នៃច្បាប់ស្ដីពីការវិនិយោគ (ឆ្នាំ១៩៩៤) និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការវិនិយោគ (ឆ្នាំ២០០៣) មានចែងអំពីការលើកទឹកចិត្តការវិនិយោគដែលអាចផ្ដល់ជូនគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIPs) ប៉ុន្តែ «យន្តការបង្វិលសងវិញ» នៅក្នុងមាត្រា ២៣ នៃច្បាប់ស្ដីពីសារពើពន្ធបានកាត់បន្ថយកម្រិតលើកទឹកចិត្តដែលកម្មវិធី QIP អាចផ្ដល់ជូនវិនិយោគិនឱ្យមកនៅកម្រិតទាបគួរឱ្យកត់សម្គាល់។ ប្រសិនបើគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) បានរក្សាទុកផលរបរនៅក្នុងរយៈពេល «លើកលែងពន្ធលើប្រាក់ចំណេញ» នោះអត្រាពន្ធចំនួន ២០% ដែលវិនិយោគិនទាំងនោះនឹងត្រូវបង់ប្រសិនបើពុំបាន

*បំពេញតាមលក្ខខណ្ឌតម្រូវរបស់កម្មវិធី QIP បានទេ នឹងត្រូវអនុវត្តនៅចំណុចដែលវិនិយោគិនព្យាយាមបញ្ជូនភាគលាភទៅប្រទេសរបស់ខ្លួនវិញ។ កត្តានេះនឹងធ្វើឱ្យអត្ថប្រយោជន៍រំពឹងទុកនៅក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញគ្មានប្រសិទ្ធភាព ហើយអាចនឹងធ្វើឱ្យវិនិយោគិនថ្មីមានការរារែកចិត្តក្នុងការចូលមកវិនិយោគក្នុងទីផ្សារកម្ពុជាទៀតផង។*

## *៤. វិស័យជាប់បម្រាមសម្រាប់ការវិនិយោគ*

*រាជរដ្ឋាភិបាលបានកំណត់វិស័យចំនួនបួនដែលជាប់បម្រាមសម្រាប់ការវិនិយោគ ដែលមានរាយនាមនៅក្នុងឧបសម្ព័ន្ធ ១ (បញ្ជីអវិជ្ជមាន) នៃអនុក្រឹត្យលេខ ១១១ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការវិនិយោគ។ អនុក្រឹត្យនេះបានដាក់បម្រាមលើវិស័យមួយចំនួនដូចខាងក្រោមនេះ៖*

- *ការផលិត ឬការកែច្នៃសារធាតុមានឥទ្ធិពលលើសរសៃប្រសាទ និងសារធាតុគ្រឿងញៀន។*
- *ការផលិតជាតិគីមីពុល ថ្នាំសម្លាប់សត្វឧត្បាត/សត្វល្អិតបំផ្លាញកសិកម្ម និង ទំនិញផ្សេងទៀតដែលប្រើសារធាតុគីមីដែលស្ថិតក្រោមបម្រាមរបស់បទប្បញ្ញត្តិអន្តរជាតិ ឬអង្គការសុខភាពពិភពលោក ដែលនាំឱ្យប៉ះពាល់ដល់សុខភាព និងបរិស្ថាន។*
- *ការកែច្នៃ និងការផលិតថាមពលអគ្គិសនីដោយប្រើកាកសំណល់នាំចូលពីបរទេស។*
- *ការធ្វើអាជីវកម្មព្រៃឈើដែលត្រូវបានហាមឃាត់ដោយច្បាប់ស្តីពីព្រៃឈើ។*

*ខ្លឹមសារនៅក្នុង «បញ្ជីអវិជ្ជមាន» នេះមានសារៈសំខាន់ខ្លាំងណាស់សម្រាប់វិនិយោគិន ដោយសារតែបញ្ជីនេះបានបង្កប់ន័យថា សកម្មភាពដែលគ្មាននៅក្នុងបញ្ជីនេះ (ហើយដែលមិនបំពានទៅលើច្បាប់របស់ប្រទេសកម្ពុជា) គួរតែយោងទៅតាមគោលនយោបាយចំហសម្រាប់ការវិនិយោគ។ បច្ចុប្បន្ន «បញ្ជីអវិជ្ជមាន» មានតែនៅក្នុងអនុក្រឹត្យ ហើយមិនទាន់ត្រូវបានចែងទៅជាច្បាប់នៅឡើយនោះទេ ដែលកត្តានេះងាយនឹងបង្កើនហានិភ័យផ្នែកច្បាប់សម្រាប់វិនិយោគិនដែលចង់មកបណ្តាក់ទុននៅក្នុងប្រទេសកម្ពុជា ដែលមានការធានាតិចតួចថា សកម្មភាពធុរកិច្ចរបស់ខ្លួននឹងត្រូវបានអនុញ្ញាតឱ្យបន្តនៅក្នុងថ្ងៃអនាគតទៀត។*

### ផលប៉ះពាល់លើកម្ពុជា

*ការធ្វើបច្ចុប្បន្នភាពច្បាប់ស្តីពីការវិនិយោគ និងការអនុម័តច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសថ្មីគឺជាឱកាសសម្រាប់កម្ពុជានៅក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសកាន់តែច្រើនថែមទៀត តាមរយៈការដាក់បញ្ចូលឧត្តមានុវត្តន៍អន្តរជាតិនៅក្នុងគោលនយោបាយវិនិយោគទៅក្នុងក្របខ័ណ្ឌច្បាប់របស់ខ្លួន និងការផ្តល់កិច្ចការពារ និងការធានាកាន់តែរឹងមាំដល់វិនិយោគិនថ្មីៗ ជាងនេះទៅទៀត ការធ្វើបច្ចុប្បន្នភាពនឹងបង្កើតឱកាសជំរុញឱ្យមានការអនុវត្តកាន់តែធាប់ហើសនូវការប្តេជ្ញាចិត្តជាអន្តរជាតិរបស់កម្ពុជា តាមរយៈការបញ្ចូលខ្លឹមសារនៃការប្តេជ្ញាចិត្តទាំងនេះទៅក្នុងច្បាប់តែម្តង។*

✓ សូមស្នើផ្តល់ការធានា ការលើកទឹកចិត្ត និងជំនួយច្រើនជាងមុនដល់វិនិយោគិនតាមរយៈច្បាប់ថ្មីស្តីពីការវិនិយោគ ដោយការបញ្ចូលនូវអនុសាសន៍ពីសំណាក់វិស័យឯកជនផងដែរ។

## អនុសាសន៍ឆ្នាំ ២០១៩

*សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា សូមគូសបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ខ្លួនថានឹងបន្តចូលរួមនៅក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការវិនិយោគ ដែលនឹងជួយបង្កើនទំនុកចិត្តនៅក្នុងចំណោមវិនិយោគិនថ្មី ហើយជាពិសេសក្នុងចំណោមស្ថាប័នផ្តល់ឥណទានផងដែរ។ នៅក្នុងបរិបទនេះ យើងខ្ញុំសូមផ្តល់ជូនអនុសាសន៍ដូចខាងក្រោមសម្រាប់យកទៅធ្វើការពិចារណា៖*

*ក). ច្បាប់ថ្មីស្តីពីការវិនិយោគគួរតែពង្រីកតួនាទីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីឱ្យស្ថាប័ននេះមានមូលដ្ឋានច្បាប់គ្រប់គ្រាន់ក្លាយទៅជា «ច្រកសេវាចេញចូលតែមួយ» ពិតប្រាកដមែនសម្រាប់វិនិយោគិនបរទេស តាមរយៈការផ្តល់ជំនួយបច្ចេកទេសដើម្បីបង្ហាញទិសដៅសម្រាប់ក្របខ័ណ្ឌវិនិយោគនៃកម្ពុជា ក៏ដូចជាពង្រឹងកិច្ចគាំពារការវិនិយោគផងដែរ។ យើងខ្ញុំក៏សូមផ្តល់ជូនអនុសាសន៍ដោយស្នើសុំឱ្យដាក់ចេញនូវបញ្ញត្តិទាំងឡាយសម្រាប់ឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលពិនិត្យមើលគម្រោងវិនិយោគ បរទេសធំៗ អាចដើរតួជាស្ថាប័នសម្របសម្រួលរវាងក្រសួងនានា (ជាពិសេស ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងរ៉ែ និងថាមពល) ដើម្បីធ្វើយ៉ាងណាឱ្យគម្រោងដែលបានអនុម័តរួចហើយអាចទទួលបានអាជ្ញាប័ណ្ណធុរកិច្ចបានទាន់ពេលវេលា។*

*ខ). គួរដាក់បញ្ចូលបទដ្ឋានកិច្ចគាំពារវិនិយោគ នៃកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយអាស៊ានស្តីពីការវិនិយោគទៅក្នុងច្បាប់ថ្មីស្តីពីការវិនិយោគ។ បើធ្វើបានដូច្នេះ កម្ពុជាគួរស្វែងរកការទាក់ទាញវិនិយោគិនពីតំបន់ផ្សេងទៀត ហើយគួរធានាឱ្យបានផងដែរថាច្បាប់នឹងផ្តល់ការធានាដល់វិនិយោគិនទាំងនេះនូវលក្ខខណ្ឌធ្វើធុរកិច្ច ដែលមានប្រៀបមិនចាញ់លក្ខខណ្ឌទាំងឡាយដែលវិនិយោគិនទទួលបាននៅក្រោមកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយអាស៊ានស្តីពីការវិនិយោគឡើយ។ កម្ពុជាចាំបាច់ត្រូវធ្វើការប្រកួតប្រជែងជាមួយប្រទេសគូប្រជែងដែលមានសេដ្ឋកិច្ចជឿនលឿនផ្សេងទៀតនៅក្នុងតំបន់ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសនៅទូទាំងពិភពលោក ហើយការផ្តល់ជូនជាឯកច្ឆ័ននូវកិច្ចការពារកម្រិតខ្ពស់ដល់វិនិយោគិនទាំងអស់ដោយមិនគិតពីប្រភព ប្រាកដជានឹងជួយពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់ខ្លួនឱ្យបានកាន់តែរឹងមាំថែមមួយកម្រិតទៀត។*

គ). គួរកែសម្រួលការលើកទឹកចិត្តការវិនិយោគបច្ចុប្បន្នដើម្បីផ្តល់គុណសម្បត្តិប្រកួតប្រជែងផ្នែកពន្ធដារកាន់តែមានលក្ខណៈប្រកួតប្រជែងថែមទៀតដល់វិនិយោគិន និងគួរធ្វើឱ្យប្រាកដថាមាត្រា ២៣ នៃច្បាប់ស្តីពីសារពើពន្ធត្រូវបានពិចារណាឡើងវិញស្របគ្នាទៅនឹងច្បាប់ថ្មីស្តីពីការវិនិយោគ និងបញ្ញត្តិស្តីពីការលើកទឹកចិត្តនាពេលអនាគត ប្រសិនបើមាននៅក្នុងច្បាប់ថវិកាជាតិ ដូចដែលបានស្នើឡើងនៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនដែលមានសម្តេចនាយករដ្ឋមន្ត្រីជាប្រធានកាលពីខែមីនា ឆ្នាំ២០១៩។

ឃ). ដើម្បីកាត់បន្ថយហានិភ័យផ្លូវច្បាប់របស់វិនិយោគិនថ្មី យើងខ្ញុំសូមផ្តល់ជូនអនុសាសន៍ថាគួរតែដាក់បញ្ចូល «បញ្ជីអវិជ្ជមាន» នៃសកម្មភាពវិនិយោគដែលជាប់បម្រាមទៅក្នុងច្បាប់វិនិយោគថ្មីនេះផងដែរ។

៤

# ការផ្ដល់អាទិភាពដល់ការបង្កើតច្បាប់ពាណិជ្ជកម្មថ្មី

ធ្វើបច្ចុប្បន្នភាព

**ពិពណ៌នាបញ្ហា**

មានច្បាប់ពាណិជ្ជកម្មសំខាន់ៗជាច្រើនដែលកំពុងស្ថិតនៅក្នុងដំណើរការរៀបចំអស់រយៈពេលជាយូរមកហើយ និងដែលមិនទាន់បានបញ្ចប់នៅឡើយនោះទេ ដែលកត្តានេះបានប៉ះពាល់ទៅដល់ការរីកចម្រើននៃវិស័យកំពុងងើបកើតឡើងមួយនេះ និងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។ ច្បាប់ទាំងនេះរួមមាន៖

## ច្បាប់ស្ដីពីការប្រកួតប្រជែង

ជាផ្នែកមួយនៃការប្ដេជ្ញារបស់កម្ពុជាចំពោះសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដែលប្រទេសកម្ពុជា ចាំបាច់ត្រូវដាក់ចេញនូវគោលនយោបាយ និងច្បាប់ជាតិស្ដីពីការប្រកួតប្រជែងនៅត្រឹមឆ្នាំ២០១៥ ដើម្បីធានានូវសមភាព និងវប្បធម៌ប្រកួតប្រជែងដោយស្មើភាពដែលនឹងជួយជំរុញទៅដល់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងការអនុវត្ត។ ទោះបីយ៉ាងណាក៏ដោយ ប្រទេសកម្ពុជានៅតែជារដ្ឋ សមាជិកអាស៊ានចុងក្រោយគេដែលពុំទាន់បានដាក់ឱ្យអនុវត្តច្បាប់ស្ដីពីការប្រកួតប្រជែងនេះ។ ជាការល្អដែលរាជរដ្ឋាភិបាលកម្ពុជាជិតនឹងបញ្ចប់ការរៀបចំច្បាប់ស្ដីពីការប្រកួតប្រជែងរបស់កម្ពុជា ដោយបច្ចុប្បន្ន សេចក្ដីព្រាងច្បាប់នេះកំពុងស្ថិតក្នុងដំណើរការពិនិត្យមើលដោយគណៈរដ្ឋមន្ត្រី និងក្រុមប្រឹក្សាអ្នកច្បាប់ ដោយរំពឹងថានឹងត្រូវអនុម័តនៅត្រឹមឆ្នាំ២០១៩ នេះ។ សេចក្ដីព្រាងច្បាប់ចុងក្រោយដែលបានផ្សព្វផ្សាយជាសាធារណៈ (កំណែ ៥.៧) ហាក់ដូចជាបានដាក់បញ្ចូលនូវវិស័យសំខាន់ៗមួយចំនួនដែលត្រូវបានគូសរំលេចនៅក្នុងសៀវភៅសលើកមុនរបស់យើង រួមមានដូចជាការរំលោភទៅលើដែនទីផ្សារ និងភាពចាំបាច់នៅក្នុងការអនុវត្តឱ្យបានខ្លាំងក្លានូវបញ្ញត្តិមួយចំនួនទៀត។

## ច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

បណ្ដាញទំនាក់ទំនងកាន់តែទំនើបនឹងបន្តបង្កើតនូវឱកាស និងកម្មវិធីថ្មីៗសម្រាប់ធុរកិច្ចកម្ពុជានៅក្នុងការទំនាក់ទំនងជាមួយអ្នកប្រើប្រាស់ ហើយប្រសិនបើធ្វើការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព នោះឱកាសទាំងនេះអាចនឹងចូលរួមចំណែកយ៉ាងច្រើននៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ វិស័យពាណិជ្ជកម្មអេឡិចត្រូនិកកម្ពុជាតម្រូវឱ្យមានអង្គភាពគាំទ្រផ្នែកច្បាប់ និងបទប្បញ្ញត្តិដែលនឹងផ្ដល់ក្របខ័ណ្ឌសម្រាប់ការអនុវត្តប្រតិបត្តិការឌីជីថលនៅក្នុងរបៀបមួយដែលផ្ដល់សុវត្ថិភាព និងកិច្ចការពារគ្រប់គ្រាន់ដល់អ្នកប្រើប្រាស់ ក៏ដូចជា ធុរកិច្ចផងដែរ។ រាជរដ្ឋាភិបាលសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងការរៀបចំច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយក្រសួងពាណិជ្ជកម្មដែលកំពុងដឹកនាំដំណើរការនេះមានគោលបំណងបញ្ចប់ច្បាប់នេះនៅត្រឹមដំណាច់ឆ្នាំ២០១៩ ដែលបច្ចុប្បន្នសេចក្ដីព្រាងច្បាប់នេះកំពុងស្ថិតក្រោមដំណើរការពិនិត្យមើលដោយក្រុមប្រឹក្សាអ្នកច្បាប់។ គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) របស់សភាពាណិជ្ជកម្មអឺរ៉ុបបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការធ្វើសេចក្ដីព្រាងច្បាប់តាមរយៈ

*ការពិគ្រោះយោបល់វិស័យរដ្ឋ និងឯកជន ដែលសមាជិកបានផ្តល់នូវមតិត្រឡប់ និង អនុសាសន៍លម្អិតស្តីពីទិដ្ឋភាពបច្ចេកទេស និងដើម្បីលើកកម្ពស់ការធ្វើសមា-ហរណកម្មទៅក្នុងតំបន់។*

## *ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម*

*ក្រុមហ៊ុនធុរកិច្ចដែលជួលអគារពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជាតែងតែជួបប្រទះបញ្ហានៅក្នុងការធានាកិច្ចសន្យាជួលរយៈពេលវែងប្រកបដោយទំនុកចិត្ត។ មានការប្រថុយប្រថានជាច្រើននៅក្នុងទីផ្សារអចលនទ្រព្យពាណិជ្ជកម្មជា ហើយអ្នកជួលសម្រាប់គោលបំណងពាណិជ្ជកម្មតែងតែជួបប្រទះម្ចាស់អចលនទ្រព្យដែលចង់ជួលត្រឹមតែរយៈពេលខ្លី និងព្យាយាមដំឡើងថ្លៃឈ្នួលខ្ពស់នៅពេលធ្វើការចរចាបន្តកិច្ចសន្យាជួលនីមួយៗ។ នៅក្នុងបណ្តាប្រទេសជាច្រើនផ្សេងទៀត កិច្ចព្រមព្រៀងជួលពាណិជ្ជកម្មអាចធានាបានតាមរយៈកិច្ចសន្យាជំនាញដែលផ្តល់កិច្ចការពារបន្ថែមដល់ភាគីជួលពីការអនុវត្តទាំងនេះ ដូចជា រយៈពេលធានាអប្បបរមាវែង និង/ឬ សិទ្ធិបន្តកិច្ចសន្យាឡើងវិញដោយស្វ័យប្រវត្តិ។ សម្រាប់កិច្ចសន្យាជំនាញដែលអាចអនុវត្តតាមផ្លូវច្បាប់ទាំងនេះ ត្រូវមានក្របខ័ណ្ឌការពារផ្នែកច្បាប់។ រាជរដ្ឋាភិបាលបានទទួលស្គាល់ភាពចាំបាច់ដែលត្រូវមានច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម និងសេចក្តីព្រាងច្បាប់ដែលបានដាក់ពិចារណាកាលពីប៉ុន្មានឆ្នាំមុន ប៉ុន្តែពុំមានការរីកចម្រើនថ្មីៗឆ្ពោះទៅរកការអនុម័តច្បាប់នេះនៅឡើយនោះទេ។*

## *ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់*

*នៅពេលដែលសេដ្ឋកិច្ចកម្ពុជាឈានដល់កម្រិតមួយដែលមានលក្ខណៈជំរុញកាន់តែខ្លាំងដោយអ្នកប្រើប្រាស់ កម្ពុជាចាំបាច់ត្រូវតែមានច្បាប់ដើម្បីការពារនិងលើកកម្ពស់ផលប្រយោជន៍របស់អ្នកប្រើប្រាស់ ដែលអាចឱ្យអ្នកប្រើប្រាស់ធ្វើសេចក្តីសម្រេចចិត្តទិញប្រកបដោយការយល់ដឹង និងធានាឱ្យមានទីផ្សារស្មើភាព និងលក្ខណៈប្រកួតប្រជែងសម្រាប់ធុរកិច្ច។ កិច្ចការពារអ្នកប្រើប្រាស់ត្រូវបានចាត់ទុកជាសមា-សភាគ ដ៏សំខាន់នៃកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដោយកំពុងខិតខំប្រឹងប្រែងបង្កើតគោលនយោបាយការពារអ្នកប្រើប្រាស់ទូទៅ ដូចដែលបង្ហាញនៅក្នុងផែនការសកម្មភាពយុទ្ធសាស្ត្រអាស៊ានស្តីពីកិច្ចការពារ អ្នកប្រើប្រាស់ឆ្នាំ២០១៦-២០២៥ (ASAPCP)។ យុទ្ធសាស្ត្រនេះមានគោលបំណង កសាងបន្ថែមពីលើសកម្មភាពរបស់គណៈកម្មាធិការការពារអ្នកប្រើប្រាស់អាស៊ាន តាមរយៈការលើកកម្ពស់ និងការដាក់បញ្ចូលគោលនយោបាយការពារអ្នកប្រើប្រាស់ដែលមានស្រាប់នៅក្នុងរដ្ឋជាសមាជិកអាស៊ាននីមួយៗ។ ប៉ុន្តែជាថ្មីម្តងទៀត ប្រទេសកម្ពុជានៅតែជារដ្ឋសមាជិកចុងក្រោយគេដែលគ្មានក្របខ័ណ្ឌច្បាប់ពេញលេញដែលត្រូវការចាំបាច់ ទោះបីជាសេចក្តីព្រាងច្បាប់ដែលបានរង់ចាំអស់រយៈពេលជាយូរត្រូវបានរៀបចំរួចហើយក៏ដោយ ហើយរំពឹងថានឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ២០១៩ នេះដដែល។*

## ផលប៉ះពាល់លើកម្ពុជា

*ប្រសិនបើមិនមានច្បាប់ដូចដែលបានលើកឡើងខាងលើទេ នោះអ្នកប្រើប្រាស់ក្រុមហ៊ុនធុរកិច្ច និងវិនិយោគិនងាយនឹងត្រូវទទួលរងផលប៉ះពាល់ដោយសារតែការអនុវត្តបែបឱកាសនិយម និងគ្មានក្រមសីលធម៌ ហើយបរិយាកាសធុរកិច្ចទាំងមូលអាចនឹងត្រូវមើលឃើញថាមានភាពមិនទៀងទាត់ឡើយ។ ជាងនេះទៅទៀត ប្រសិនបើប្រទេសកម្ពុជានៅតែអូសបន្លាយពេលអនុម័តច្បាប់ដែលត្រូវការជាចាំបាច់ដែលជាផ្នែកមួយនៃការប្តេជ្ញាចិត្តកម្រិតអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោករបស់ខ្លួននោះ កិត្តិសព្ទ និងមុខមាត់របស់កម្ពុជានៅក្នុងតំបន់ និងក្នុងសហគមន៍អន្តរជាតិទាំងមូលអាចនឹងរងផលប៉ះពាល់ជាក់ជាមិនខាន។ កត្តានេះអាចនឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើភាពទាក់ទាញរបស់ប្រទេសកម្ពុជាក្នុងនាមជាប្រទេសគោលដៅវិនិយោគដ៏មានសក្តានុពល និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលនៅក្នុងការសម្រេចឱ្យបាននូវពិពិធកម្មសេដ្ឋកិច្ចកាន់តែទូលំទូលាយ។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យផ្តល់អាទិភាពលើការបញ្ចប់ច្បាប់ស្តីពីការប្រកួតប្រជែង ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម និងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និង ប្តេជ្ញាអនុម័តច្បាប់ទាំងនេះឱ្យបានមុនដំណាច់ឆ្នាំ២០១៩។

*យើងខ្ញុំសូមផ្តល់ជូនដោយក្តីគោរពនូវអនុសាសន៍ឱ្យរាជរដ្ឋាភិបាលកម្ពុជាកំណត់អាទិភាពទៅលើការបញ្ចប់ច្បាប់ពាណិជ្ជកម្មដូចដែលបានលើកឡើងខាងលើ និងប្តេជ្ញាអនុម័តច្បាប់ទាំងនេះឱ្យបានមុនដំណាច់ឆ្នាំ២០១៩។ តាមរយៈការអនុម័តច្បាប់ទាំងនេះ រាជរដ្ឋាភិបាលកម្ពុជានឹងធានាបាននូវទីផ្សារស្មើភាព និងមានលក្ខណៈប្រកួតប្រជែង ព្រមទាំងបង្កើតបរិយាកាសវិនិយោគ កាន់តែអំណោយផលតាមរយៈការផ្តល់កិច្ចការពារ និងការធានាកាន់តែរឹងមាំដល់វិនិយោគិនដែលមានបំណងចង់មកបណ្តាក់ទុននៅក្នុងប្រទេសកម្ពុជា។*

៥

# ការដាក់ចេញនូវលក្ខខណ្ឌតម្រូវ ដែលកំណត់ឱ្យធ្វើការផ្សព្វផ្សាយមុនពេលចុះបញ្ជីសម្រាប់ពាណិជ្ជសញ្ញាថ្មីដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី

រក្សាទុកដដែល

**ពិពណ៌នាបញ្ហា**

*របបកម្មសិទ្ធិបញ្ញា (IPR) របស់ប្រទេសកម្ពុជាផ្តល់ឱកាសដល់បុគ្គល ឬក្រុមហ៊ុនដែលចង់ដាក់លិខិតជំទាស់ទៅនឹងការចុះបញ្ជីពាណិជ្ជសញ្ញានៅក្នុងរយៈពេល ៩០ ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទធ្វើការផ្សព្វផ្សាយអំពីពាណិជ្ជសញ្ញាដែលបានចុះបញ្ជីនោះ។ ការជំទាស់អាចដាក់ពាក្យដោយផ្អែកលើមូលហេតុថា ភាគីមួយបានចុះបញ្ជីម៉ាកពាណិជ្ជសញ្ញានៅក្នុងប្រទេសកម្ពុជាដែលភាគីជំទាស់យល់ថាខ្លួនឯងគឺជាម្ចាស់ពាណិជ្ជសញ្ញាស្របច្បាប់។ នាពេលបច្ចុប្បន្ន ទោះបីម៉ាកមួយចំនួនដែលបានដាក់ស្នើសុំតាមអនឡាញត្រូវបានបង្ហាញនៅលើឃ្លាំងទិន្នន័យអនឡាញក៏ដោយ ក៏ការផ្សព្វផ្សាយជាសាធារណៈផ្លូវការអំពីពាណិជ្ជសញ្ញាថ្មីនោះត្រូវបានធ្វើឡើងតែនៅបន្ទាប់ពីបានចុះបញ្ជីរួចហើយប៉ុណ្ណោះ ដែលធ្វើឱ្យភាគីផ្សេងៗទៀតពុំមានឱកាសពិនិត្យមើលម៉ាកពាណិជ្ជសញ្ញាដែលបានដាក់ពាក្យស្នើសុំនៅមុនពេលចុះបញ្ជីឡើយ។*

**ផលប៉ះពាល់លើកម្ពុជា**

*ការផ្តល់ឱ្យភាគីផ្សេងៗទៀតនូវឱកាសពិនិត្យមើលពាណិជ្ជសញ្ញាដែលបានដាក់ពាក្យស្នើសុំនៅមុនពេលចុះបញ្ជីនឹងធ្វើឱ្យភាគីពាក់ព័ន្ធអាចធ្វើការជំទាស់ទៅនឹងការដាក់ពាក្យស្នើសុំចុះបញ្ជីពាណិជ្ជសញ្ញាដែលដូចគ្នា ឬស្រដៀងគ្នាអាចធ្វើឱ្យមានការភាន់ច្រឡំជាមួយនឹងម៉ាករបស់ខ្លួន។ វិធានការនេះនឹងផ្តល់សុវត្ថិភាពបន្ថែមទៅដល់ម្ចាស់ម៉ាកសញ្ញាស្របច្បាប់ ហើយអាចជួយសម្រួលដំណើរការរដ្ឋបាលនៅក្នុងនាយកដ្ឋានកម្មសិទ្ធិបញ្ញា ដោយជួយទៅដល់នាយកដ្ឋាននៅក្នុងការបដិសេធពាណិជ្ជសញ្ញាដែលដូចគ្នា ឬស្រដៀងគ្នាទៅនឹងពាណិជ្ជសញ្ញាមានស្រាប់ដែលបានចុះបញ្ជីរួចហើយនៅក្នុងប្រទេសកម្ពុជា និងអាចលុបបំបាត់ភាពចាំបាច់នៅក្នុងការកំណត់ឡើងវិញដ៏ស្មុគស្មាញនៅក្រោយពេលចុះបញ្ជី។*

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យដាក់ចេញនូវលក្ខខណ្ឌតម្រូវដែលកំណត់ឱ្យធ្វើការផ្សព្វផ្សាយមុនពេលចុះបញ្ជីសម្រាប់ពាណិជ្ជសញ្ញាថ្មីដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី។

*យោងតាមឧត្តមានុវត្តន៍នៅក្នុងបណ្តាប្រទេសនៅក្នុងតំបន់អាស៊ាន និងនៅក្នុងបណ្តាប្រទេសផ្សេងទៀត យើងខ្ញុំសូមផ្តល់ជូននូវអនុសាសន៍ដោយស្នើឱ្យដាក់ចេញនូវលក្ខខណ្ឌចុះផ្សាយជាសាធារណៈនូវពាក្យស្នើសុំចុះបញ្ជីពាណិជ្ជសញ្ញាថ្មីទាំងអស់ក្នុងរយៈពេលពី ២ ទៅ ៣ ខែមុននាយកដ្ឋានកម្មសិទ្ធិបញ្ញាធ្វើការសម្រេចចិត្ត។ វិធានការនេះនឹងផ្តល់ឱកាសទៅដល់អង្គភាពពាក់ព័ន្ធ ឬភាគីទីបីផ្សេងទៀតដាក់លិខិតជំទាស់មុនពេលឈានដល់ការសម្រេចចិត្តចុះបញ្ជីពាណិជ្ជសញ្ញានោះជាផ្លូវការ។*

៦

# ការបង្កើតក្របខ័ណ្ឌច្បាប់ពិស្តារដើម្បីដាក់ចេញនូវវិធានការបណ្តោះអាសន្នឱ្យកាន់តែរឹងមាំនៅក្នុងកិច្ចការពារកម្មសិទ្ធិបញ្ញា

រក្សាទុកដដែល

---

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើឱ្យបង្កើតក្របខ័ណ្ឌច្បាប់កាន់តែលម្អិត ដើម្បីដាក់ចេញនូវវិធានការបណ្តោះអាសន្នរឹងមាំជាងមុន នៅក្នុងកិច្ចការពារកម្មសិទ្ធិបញ្ញា។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*ដោយអនុវត្តតាមកិច្ចព្រមព្រៀងរវាងប្រទេសកម្ពុជា និងស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប (EPO) ដែលបានចុះកាលពីខែមករា ឆ្នាំ២០១៧ ការទទួលស្គាល់សុពលភាពនៃកិច្ចព្រមព្រៀងប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនេះបានចូលជាធរមាននៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ដែលធ្វើឱ្យប្រទេសកម្ពុជា ក្លាយជាប្រទេសអាស៊ីដំបូងគេបង្អស់ដែលផ្តល់សុពលភាពដល់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប។ ប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលផ្តល់ដោយ ស្ថាប័នប្រកាសនីយបត្រតក្កកម្ម អឺរ៉ុប នឹងត្រូវផ្តល់សុពលភាពនៅកម្ពុជានឹងមានសុពលភាពផ្លូវច្បាប់ដូចគ្នាទៅនឹងប្រកាសនីយបត្រតក្កកម្មរបស់កម្ពុជា និងអនុលោមតាមច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មកម្ពុជាដែរ។*

---

**ពិពណ៌នាបញ្ហា**

*វិធានការបណ្តោះអាសន្នបច្ចុប្បន្នរបស់ប្រទេសកម្ពុជា ដូចមានរៀបរាប់នៅក្នុងច្បាប់ស្តីពីពាណិជ្ជនាម មិនបានចែងអំពីនីតិវិធីលម្អិត និងច្បាស់លាស់ដើម្បីឱ្យអាជ្ញាធររដ្ឋបាលពាក់ព័ន្ធអាចផ្តល់កិច្ចគាំទ្រដល់ធុរកិច្ចដែលមាកសញ្ញារបស់ខ្លួនត្រូវបានរំលោភបំពាននោះទេ៖*

- *យោងតាមច្បាប់កម្ពុជា មានតែតុលាការមានសមត្ថកិច្ចប៉ុណ្ណោះដែលអាចបញ្ជាឱ្យអនុវត្តវិធានការបណ្តោះអាសន្នទៅលើការរំលោភកម្មសិទ្ធិបញ្ញា (IPR)។ ចៅក្រមគឺជាអាជ្ញាធរតែមួយគត់ដែលមានសមត្ថកិច្ចអនុម័តទៅលើវិធានការបន្ទាន់។ ដំណើរការនីតិវិធីតុលាការនៅកម្ពុជាត្រូវបានគេយល់ឃើញថាត្រូវចំណាយប្រាក់ច្រើន និងពេលវេលាច្រើន ហើយយើងមិនដឹងច្បាស់លាស់ឡើយថាម្ចាស់កម្មសិទ្ធិលើពាណិជ្ជនាមនឹងទទួលបានវិធានការបណ្តោះអាសន្នបានភ្លាមៗ និងទាន់ពេលវេលាដើម្បីទប់ស្កាត់ការរំលោភបំពានជាក់ស្តែង ឬអាចនឹងកើតឡើង និង/ឬដើម្បីរក្សាទុកភស្តុតាង ឬយ៉ាងណានោះទេ។*

- *ជាងនេះទៅទៀត ច្បាប់ស្តីពីពាណិជ្ជនាម និងបទប្បញ្ញត្តិស្តីពីការអនុវត្តន៍ច្បាប់នេះមិនបានរៀបរាប់អំពីប្រភេទវិធានការបណ្តោះអាសន្នដែលតុលាការអាចនឹងបញ្ជាឱ្យអនុវត្តនៅពេលមានសំណើពីម្ចាស់កម្មសិទ្ធិឡើយ។ តុលាការកម្ពុជាមានបទពិសោធន៍តិចតួចនៅក្នុងការដោះស្រាយសំណុំរឿងពាក់ព័ន្ធនឹងការរំលោកលើពាណិជ្ជនាម ហើយមិនមានភាព ច្បាស់លាស់ឡើយថា ចៅក្រមអាចចេញដីការក្សាការពារបណ្តោះអាសន្នមានប្រសិទ្ធភាពដែលត្រូវបានរៀបចំឡើងស្របទៅតាមសំណុំរឿងរំលោភបំពាននីមួយៗ ឬយ៉ាងណាឡើយ។*

*នៅក្នុងបណ្តាប្រទេសជាច្រើនផ្សេងទៀត រដ្ឋមានទំនួលខុសត្រូវខ្ពស់ជាងគេនៅក្នុងការស៊ើបអង្កេតលើករណីការរំលោភលើពាណិជ្ជនាម ហើយស្ថាប័នអនុវត្តមានទំនួលខុសត្រូវក្នុងការចាប់ផ្តើមនីតិវិធីប្រឆាំងនឹងក្រុមហ៊ុនដែលបានរំលោភបំពាននោះ។ ឧទាហរណ៍ នៅក្នុងប្រទេសថៃ នាយកដ្ឋានស៊ើបអង្កេតពិសេស (DSI) ដែលជាសេនាធិការរបស់ក្រសួងយុត្តិធម៌ ជាអ្នកទទួលខុសត្រូវក្នុងការស៊ើបអង្កេតបទល្មើសសេដ្ឋកិច្ចពាក់ព័ន្ធនឹងបញ្ហាស្មុគស្មាញ ឬបច្ចេកវិទ្យា រួមមានដូចជាសំណុំរឿងរំលោភលើកម្មសិទ្ធិបញ្ញាលើចំនួនទឹកប្រាក់កំណត់ជាក់លាក់ណាមួយ។ នាយកដ្ឋានស៊ើបអង្កេតពិសេសនេះអាចបញ្ជូនសំណុំរឿងទៅតុលាការជំនាញផ្នែកកម្មសិទ្ធិបញ្ញា។ ស្រដៀងគ្នានេះដែរ នៅក្នុងសេណារីយ៉ូដែលវិធានការរឹតបន្តឹងចាំបាច់ត្រូវអនុវត្តភ្លាមៗ ដូចជា នៅពេលដែលទីតាំងផលិត ឬឃ្លាំងស្តុកទំនិញក្លែងក្លាយត្រូវបានរកឃើញ នោះភ្នាក់ងារអនុវត្តនៅក្នុងប្រទេសវៀតណាមមានសិទ្ធិអំណាចក្នុងការរឹបអូសជាបណ្តោះអាសន្ននូវទំនិញ មធ្យោបាយ និងឧបករណ៍ដែលប្រើប្រាស់សម្រាប់ករណីរំលោភបំពានស្របពេលដែលការស៊ើបអង្កេតត្រូវបានធ្វើឡើងផងដែរ។ ផ្ទុយទៅវិញនៅក្នុងប្រទេសកម្ពុជា ដីការរក្សាការពារត្រូវបានចេញតែនៅពេលដែលម្ចាស់ម៉ាកសញ្ញាដាក់ពាក្យស្នើសុំទៅតុលាការ ដែលត្រូវចំណាយពេលយូរ ដែលធ្វើឱ្យដីការរក្សាការពារមិនសូវមានប្រសិទ្ធភាព។*

**ផលប៉ះពាល់លើកម្ពុជា**

*រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថាកិច្ចការពារកម្មសិទ្ធិបញ្ញាពិតជាមានសារៈសំខាន់ មិនត្រឹមតែដើម្បីបំពេញតាមកាតព្វកិច្ចនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីផ្តល់សន្តិសុខ និងកិច្ចការពារចាំបាច់ក្នុងការផ្តល់លទ្ធភាពបន្ថែមដល់ការវិនិយោគពីវិស័យឯកជនផងដែរ។ នៅពេលដែលច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាដ៏មានប្រសិទ្ធភាពត្រូវបានអនុម័ត ប៉ុន្តែការអនុវត្ត នៅមានកម្រិតច្រើន ធ្វើឱ្យក្របខ័ណ្ឌកម្មសិទ្ធិបញ្ញាដែលកំពុងអភិវឌ្ឍរបស់កម្ពុជាលែងសូវមានប្រសិទ្ធភាពវិជ្ជមាននៅក្នុងបរិយាកាសវិនិយោគរបស់ប្រទេស និងសេដ្ឋកិច្ចជាតិផងដែរ។*

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យបង្កើតក្របខ័ណ្ឌច្បាប់កាន់តែពិស្តារដើម្បីដាក់ចេញនូវវិធានការបណ្តោះអាសន្នរឹងមាំជាងមុននៅក្នុងកិច្ចការពារកម្មសិទ្ធិបញ្ញា។

*យើងខ្ញុំសូមស្នើដោយក្តីគោរពចំពោះរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួង និងអាជ្ញាធរពាក់ព័ន្ធឱ្យបំពេញតួនាទីយ៉ាងទូលំទូលាយជាងមុននៅក្នុងការស្រាវជ្រាវលើករណីរំលោភលើកម្មសិទ្ធិបញ្ញា និងបញ្ជូនសំណុំរឿងទាំងនេះទៅកាន់តុលាការ។ អនុសាសន៍ចំនួនពីរខាងក្រោមអាចជួយក្នុងការសម្រេចគោលបំណងនេះបាន៖*

ក. ច្បាប់ស្តីពីពាណិជ្ជនាម និងបទប្បញ្ញត្តិអនុវត្តច្បាប់នេះគួរកំណត់នូវវិធានការបណ្តោះអាសន្នដែលមានប្រសិទ្ធភាពសម្រាប់ទប់ស្កាត់ការរំលោភដាក់ស្តែង ឬអាចនឹងកើតឡើង និងរក្សាទុកភស្តុតាង។ វិធានការបណ្តោះអាសន្ន ដូចជា ការរឹបអូសទំនិញក្លែងក្លាយដែលបានចោទប្រកាន់ដើម្បីទុកជាភស្តុតាង ការរឹបអូសស្តុក និងការបង្កកទ្រព្យសម្បត្តិ និងគណនីធនាគាររបស់អ្នកក្លែងបន្លំដែលបានចោទប្រកាន់ គួរមានចែងនៅក្នុងច្បាប់កម្ពុជា។

ខ. ជាងនេះទៅទៀត គួរតែពិចារណាពិនិត្យមើលលើសមត្ថកិច្ចផ្តាច់មុខរបស់តុលាការនៅក្នុងការចេញបញ្ជាឱ្យអនុវត្តវិធានការបណ្តោះអាសន្នទាំងនេះ។ ការផ្តល់សិទ្ធិអំណាចជូនដល់អាជ្ញាធររដ្ឋបាលពាក់ព័ន្ធនៅក្នុងការអនុវត្តវិធានការបណ្តោះអាសន្នដោយ ពុំចាំបាច់រង់ចាំដីការតុលាការនឹងជួយនៅក្នុងការគាំទ្រទៅដល់ម្ចាស់ពាណិជ្ជនាមនៅក្នុងសេណារីយ៉ូពាក់ព័ន្ធនឹងពេលវេលាដែលការចេញដីការរក្សាការពារភ្លាមៗនឹងជួយបញ្ឈប់សកម្មភាពរំលោភបំពានកម្មសិទ្ធិបញ្ញា និងរក្សាទុកភស្តុតាងសម្រាប់បង្ហាញជូនតុលាការនៅពេលក្រោយ។ ការកំណត់ និងការតាមដានសិទ្ធិអំណាចបន្ថែមដែលត្រូវផ្តល់ជូនអាជ្ញាធររដ្ឋបាលទាំងនេះអាចនឹងត្រូវធ្វើឡើងតាមរយៈ «អនុគណៈកម្មាធិការអនុវត្ត» នៅក្រោមគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញាដែលមានស្រាប់។

ពាក់ព័ន្ធនឹងអនុសាសន៍ទីពីរនេះ យើងខ្ញុំសូមរំឭកថាគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយដែលមានហានិភ័យខ្ពស់ចំពោះសុខភាព និងសុវត្ថិភាពសង្គម ត្រូវបានផ្តល់សិទ្ធិអំណាចរួចជាស្រេចក្នុងការអនុវត្តវិធានការចាំបាច់នានាដើម្បីលុបបំបាត់ផលិតផលក្លែងក្លាយដែលមានហានិភ័យ ខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម ដែលកំពុងចរាចរណ៍នៅក្នុងទីផ្សារកម្ពុជា។ នៅក្នុងសេណារីយ៉ូទាំងនេះ គណៈកម្មាធិការនេះមានសិទ្ធិក្នុងការរឹបអូសផលិតផលទាំងនេះ និងរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ។ ដូច្នេះគណៈកម្មាធិការនេះទទួលបានសិទ្ធិទាំងស្រុងនៅក្នុងការអនុវត្តវិធានការបណ្តោះអាសន្ន រួមទាំងការរឹបអូសផលិតផលក្លែងក្លាយផងដែរ។ សិទ្ធិអំណាចស្រដៀងគ្នានេះគួរផ្តល់ទៅឱ្យគណៈកម្មាធិការជំនាញទទួលបន្ទុកបង្ក្រាបការរំលោភបំពានផ្សេងទៀត និងទៅដល់ទីភ្នាក់ងារអនុវត្តច្បាប់ផ្សេងៗទៀតផងដែរ។

៧

# ការផ្តល់សិទ្ធិអំណាចដល់អង្គភាពគយ នៅក្នុងការទប់ស្កាត់ទំនិញក្លែងក្លាយ និងការលួចលាក់នាំចូលទំនិញមកកាន់ប្រទេសកម្ពុជា

រក្សាទុកដដែល

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើផ្តល់សិទ្ធិអំណាចបន្ថែមនៅកម្រិតរដ្ឋបាលដល់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដើម្បីទប់ស្កាត់ទំនិញក្លែងក្លាយ និងការលួចលាក់នាំចូលទំនិញមកកាន់ប្រទេសកម្ពុជា។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*ដើម្បីលើកកម្ពស់ការប្រកួតប្រជែង និងកាត់បន្ថយថ្លៃចំណាយនៅក្នុងដំណើរការអាជីវកម្ម អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ អាហារណ៍ នីហរណ៍ និងបង្រ្កាបការក្លែងបន្លំ (កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្មកម្ពុជា ត្រូវបានដកកាតព្វកិច្ចមិនឱ្យធ្វើការត្រួតពិនិត្យនៅតាមច្រកព្រំដែន កំពង់ផែសមុទ្រ តំបន់សេដ្ឋកិច្ចពិសេស និងតំបន់ត្រួតពិនិត្យផ្សេងទៀត។ ចាប់ពីថ្ងៃទី០១ ខែកុម្ភៈឆ្នាំ២០១៩ តទៅ អគ្គនាយកដ្ឋានគយ និងរដ្ឋាករគឺជាអង្គភាពតែមួយគត់ដែលមានសិទ្ធិក្នុងការត្រួតពិនិត្យទំនិញនៅតាមច្រកចូលមកកាន់ប្រទេសកម្ពុជា។*

**ពិពណ៌នាបញ្ហា**

*បច្ចុប្បន្ន មន្ត្រីអគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) មានសិទ្ធិអំណាចតិចតួចប៉ុណ្ណោះពាក់ព័ន្ធនឹងការអនុវត្តកម្មសិទ្ធិបញ្ញា (IPR) នៅតាមបណ្តោយព្រំដែនប្រទេសកម្ពុជា។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) ពុំមានលទ្ធភាព និងសិទ្ធិអំណាចនៅក្នុងការស៊ើបអង្កេត និង/ឬ កាត់បន្ថយលក្ខណៈក្លែងក្លាយរបស់ទំនិញពាក់ព័ន្ធឡើយ ហើយអាចត្រឹមតែបញ្ជាឱ្យបំផ្លាញចោលទំនិញក្លែងក្លាយនៅក្រោមនីតិវិធីព្យួរដែលចេញដោយតុលាការមានសមត្ថកិច្ចតែប៉ុណ្ណោះ។*

*នៅពេលដែលម្ចាស់ម៉ាកសញ្ញា ឬម្ចាស់សិទ្ធិអ្នកនិពន្ធបានដឹងអំពីទំនិញដែលបញ្ជូនមកប្រទេសកម្ពុជាមាននូវទំនិញដែលរំលោភទៅលើកម្មសិទ្ធិបញ្ញារបស់ខ្លួន ម្ចាស់សិទ្ធិទាំងនោះអាចដាក់ពាក្យបណ្តឹងមកកាន់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដែលបន្ទាប់មកអាចស្នើឱ្យធ្វើការព្យួរទំនិញនាំចូលរយៈពេលយ៉ាងច្រើនបំផុតចំនួន ១០ ថ្ងៃធ្វើការ។ នៅក្នុងរយៈពេលនេះ ម្ចាស់សិទ្ធិត្រូវដាក់ពាក្យប្តឹងទៅតុលាការដែលស្នើឱ្យអនុវត្តវិធានការបណ្តោះអាសន្ន និងឬចាប់ផ្តើមនីតិវិធីតុលាការដែលឈានទៅដល់សេចក្តីសម្រេចលើសំណុំរឿង។ ប្រសិនបើសំណុំរឿងមិនត្រូវបានបញ្ជូនទៅតុលាការ នៅក្នុងរយៈពេលកំណត់នេះទេ នោះទំនិញដែលបានព្យួរនឹងត្រូវអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដោះលែងនៅពេលផុតកំណត់រយៈពេលព្យួរ។*

*រយៈពេលរហូតដល់ ១០ ថ្ងៃធ្វើការជាទូទៅត្រូវបានបញ្ជាក់ថាជាពេលវេលាមិនគ្រប់គ្រាន់ដើម្បីឱ្យម្ចាស់សិទ្ធិចាប់ផ្តើមនីតិវិធីតុលាការដើម្បីផ្តល់សិទ្ធិឱ្យបន្តការព្យួរទំនិញ ឬឱ្យធ្វើការបញ្ជាក់លក្ខណៈក្លែងក្លាយនៃទំនិញដែលបានព្យួរ។ នៅក្នុងករណីនេះ ជាទូទៅទំនិញ នឹងត្រូវដោះលែងបន្ទាប់ពីផុតរយៈពេលព្យួរដំបូង ដូច្នេះកិច្ចខិតខំប្រឹង*

*ប្រែងរបស់ម្ចាស់ម៉ាកសញ្ញានៅក្នុងការស្វែងរកភស្តុតាងចាំបាច់នឹងក្លាយជាអសារបង់ដាក់ជាមិនខាន។*

*ទំនិញក្លែងក្លាយ និងការលួចលាក់នាំចូលទំនិញគួរមានការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពជាងមុនដោយនាយកដ្ឋានគយដែលមានសិទ្ធិក្នុងការពិនិត្យមើលបណ្តឹងរបស់ម្ចាស់ម៉ាកដែលបានចុះបញ្ជី ឬម្ចាស់ស្របច្បាប់នៃសិទ្ធិអ្នកនិពន្ធ និងចាត់វិធានការចាំបាច់ដើម្បីការពារម្ចាស់សិទ្ធិ។ ដើម្បីបំពេញទំនួលខុសត្រូវនេះឱ្យមានប្រសិទ្ធភាព អគ្គនាយកដ្ឋានគយ និងរដ្ឋាករ គួរតែមាននូវរាល់ព័ត៌មានដែលត្រូវការជាចាំបាច់ទាំងអស់ពាក់ព័ន្ធនឹងម៉ាកសញ្ញាចុះបញ្ជីក្នុងប្រទេសកម្ពុជា ក៏ដូចជាផលិតផលពាក់ព័ន្ធ ព្រមទាំងព័ត៌មានទាំងអស់ដែលពាក់ព័ន្ធនឹងម្ចាស់សិទ្ធិផងដែរ។ បច្ចុប្បន្ន ប្រទេសកម្ពុជាពុំមានប្រព័ន្ធកត់ត្រាម៉ាកសញ្ញាដែលអាចឱ្យម្ចាស់ម៉ាកសញ្ញាកត់ត្រាការចុះបញ្ជីម៉ាកសញ្ញារបស់ខ្លួនជាមួយនឹងអគ្គនាយកដ្ឋានគយ និងរដ្ឋាករដើម្បីឱ្យមន្ត្រីអាចទទួលបានព័ត៌មានអំពីម្ចាស់ម៉ាកសញ្ញាតាមរយៈឃ្លាំងទិន្នន័យមជ្ឈិម។ ចំណុចនេះត្រូវបានកំណត់ថាជាសិទ្ធិអំណាចនៅមានកម្រិតនៅក្នុងគណៈកម្មាធិការតាមវិស័យរបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ឧទាហរណ៍ មន្ត្រី អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ពុំមានភាពងាយស្រួលនៅក្នុងការទទួលបានព័ត៌មានអំពីលក្ខណៈបច្ចេកទេសដែលបានចុះបញ្ជីសម្រាប់ផលិតផលឱសថដើម្បីកំណត់ថាតើទំនិញដែលកំពុងដឹកចូលមកកម្ពុជានោះគួរតែធ្វើការបញ្ចេញពីគយដែរឬទេ។*

**ផលប៉ះពាល់លើកម្ពុជា**

*ដូចដែលពិភាក្សាពីខាងដើមហើយថា ការការពារកម្មសិទ្ធិបញ្ញា គឺជាសសរស្តម្ភដ៏មានសារៈសំខាន់សម្រាប់កំណើនសេដ្ឋកិច្ច ហើយក៏ត្រូវបានរាជរដ្ឋាភិបាលទទួលស្គាល់ថាជាចំណុចអាទិភាពដ៏សំខាន់ផងដែរ។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដែលទទួលបានសិទ្ធិអំណាចគ្រប់គ្រាន់នឹងមានសក្តានុពលក្នុងការផ្តល់ "ខ្សែការពារ" ដ៏រឹងមាំដើម្បីប្រឆាំងនឹងទំនិញក្លែងក្លាយ និងការលួចលាក់នាំចូលទំនិញដែលកំពុងដឹកជញ្ជូនពីបរទេសមកកាន់ព្រះរាជាណាចក្រកម្ពុជា ដែលអាចជួយកាត់បន្ថយបានយ៉ាងច្រើននូវការរីកសាយភាយនូវទំនិញក្លែងក្លាយនៅលើទីផ្សារកម្ពុជា និងធ្វើឱ្យស្ថានភាពកម្មសិទ្ធិបញ្ញារបស់ប្រទេសកម្ពុជាកាន់តែល្អប្រសើរ។*

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យផ្តល់សិទ្ធិអំណាចនៅកម្រិតរដ្ឋបាលដល់អគ្គនាយកដ្ឋានគយ និងរដ្ឋាករដើម្បីទប់ស្កាត់ទំនិញក្លែងក្លាយ និងការលួចលាក់នាំចូលទំនិញមកកាន់ប្រទេសកម្ពុជា។

*យើងខ្ញុំសូមផ្តល់ជូនអនុសាសន៍ដោយការគោរពដល់រាជរដ្ឋាភិបាលកម្ពុជា ឱ្យធ្វើការកែសម្រួលរយៈពេលដំបូងសម្រាប់ដំណើរការព្យួរ និងផ្តល់រយៈពេលវេលាកំណត់សមស្រីបជូនដល់ម្ចាស់សញ្ញា នៅក្នុងការចាប់ផ្តើមដំណើរការតុលាការ ដែលឈានដល់ការចេញសេចក្តីសម្រេចទៅលើសំណុំរឿង ឬអនុវត្តវិធានការបណ្តោះអាសន្ន។ ទោះបីយ៉ាងណាក្តី គួរកត់សម្គាល់ផងដែរថា ការបន្ថែមរយៈពេលព្យួរដំបូងអាចនឹងត្រូវប្រើប្រាស់ដើម្បីផ្អាកការនាំចូលទំនិញដែលពុំមានផលិតផលរំលោភទៅលើម៉ាកសញ្ញា។ ដើម្បីរារាំងសកម្មភាពនេះ ចំនួនប្រាក់កក់ធានាដែលម្ចាស់សិទ្ធិត្រូវបង់គួរធ្វើការដំឡើង ហើយការរៀបចំប្រាក់ដែលមានចំនួនច្រើនជាងមុនអាចនឹងកើត ឡើងដោយសារតែអ្នកនាំចូល ប្រសិនបើពុំមានករណីរំលោភសិទ្ធិណាមួយត្រូវបានរកឃើញទេនោះ។*

*ជាងនេះទៅទៀត យើងសូមស្នើសុំឱ្យរាជរដ្ឋាភិបាលធ្វើការពិចារណាផ្តល់សិទ្ធិអំណាចបន្ថែមនៅកម្រិតរដ្ឋបាលទៅដល់អគ្គនាយកដ្ឋានគយ និងរដ្ឋាករដោយអនុវត្តតាមគំរូអនុវត្តល្អៗពីប្រទេសជិតខាងដើម្បីបង្កើនសិទ្ធិអំណាច និងសមត្ថភាពរបស់អង្គភាពគយនៅក្នុងការវាយតម្លៃទំនិញនាំចូល នឹងកំណត់ស្ថានភាពទំនិញក្លែងក្លាយ ឬការ លួចលាក់នាំចូលទំនិញ។ ក្នុងករណីនេះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករគួរតែមានសិទ្ធិនៅ ក្នុងការស៊ើបអង្កេតការចោទប្រកាន់អំពីទំនិញក្លែងក្លាយបញ្ចប់សំណុំរឿងដោយបើកសវនការ និងកំណត់លក្ខណៈក្លែងក្លាយរបស់ទំនិញនៅក្រោមនីតិវិធីព្យួរ និងសិទ្ធិនៅក្នុងការបំផ្លាញចោលទំនិញដែលបានព្យួរដោយពុំចាំបាច់រង់ចាំសេចក្តីសម្រេចពីតុលាការ នៅពេលដែលលក្ខណៈក្លែងក្លាយត្រូវបានកំណត់ច្បាស់លាស់។ វិធានការនេះអាចនាំឱ្យអនុវត្តវិធានការបានទាន់ពេលវេលាជាងមុន និងលើកកម្ពស់ការអនុវត្តកម្មសិទ្ធិបញ្ញារបស់ប្រទេសកម្ពុជា។*

*ដើម្បីគាំទ្រដល់អគ្គនាយកដ្ឋានគយ និងរដ្ឋាករនៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងកម្មសិទ្ធិបញ្ញា យើងសូមផ្តល់អនុសាសន៍ឱ្យបង្កើតប្រព័ន្ធកំណត់ត្រាម៉ាកសញ្ញា។ តាមរយៈប្រព័ន្ធនេះ ម្ចាស់ម៉ាកសញ្ញានឹងបន្តដាក់ពាក្យស្នើសុំកម្មសិទ្ធិទៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា ហើយបន្ទាប់មកមានជម្រើសនៅក្នុងការចុះម៉ាកសញ្ញារបស់ខ្លួននៅ អគ្គនាយកដ្ឋានគយ និងរដ្ឋាករដើម្បីឱ្យមន្ត្រីគយមានភាពងាយស្រួលក្នុងការចូលមើល ព័ត៌មានអំពីម៉ាកសញ្ញាទាំងនោះ។ កំណត់ត្រាគួរអនុវត្តដោយស្ម័គ្រចិត្ត ដោយម្ចាស់សិទ្ធិ លើម៉ាកសញ្ញា ឬភ្នាក់ងារស្របច្បាប់របស់ខ្លួន ហើយគួរផ្តល់ជូនអគ្គនាយកដ្ឋានគយ និងរដ្ឋាករនូវវិញ្ញាបនបត្រចុះបញ្ជីម៉ាកសញ្ញាបញ្ជីផលិតផលដែលបានចុះបញ្ជីដោយមានសំណាកគំរូ ព្រមទាំងព័ត៌មានលម្អិតអំពីម្ចាស់សិទ្ធិ និង/ឬ ភ្នាក់ងាររបស់ម្ចាស់សិទ្ធិ (រួមទាំងព័ត៌មានទំនាក់ទំនង)។ ព័ត៌មាន*

*ទាំងនេះនឹងធ្វើឱ្យអង្គភាពគយអាចស្វែងរកផលិតផលក្លែងក្លាយកាន់តែមានប្រសិទ្ធភាពនៅក្នុងពេលអនុវត្តនីតិវិធីបញ្ចេញទំនិញ ពីគយ និងផ្អាកការបញ្ចេញចំពោះទំនិញដែលសង្ស័យថាជាទំនិញក្លែងក្លាយ និងផ្តល់ព័ត៌មានទៅដល់ម្ចាស់សិទ្ធិដើម្បីអនុវត្តវិធានការផ្លូវច្បាប់បន្ថែមទៅតាមនីតិវិធី។*

*ជាចុងក្រោយ យើងបានកត់សម្គាល់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ២០១៨ របស់ក្រសួងពាណិជ្ជកម្ម ថាមានបញ្ញើច្បាប់ និងបទប្បញ្ញត្តិដែលកំពុងធ្វើសេចក្តីព្រាងដែលរួមមានអនុក្រឹត្យស្តីពីនីតិវិធីអនុវត្តកម្មសិទ្ធិបញ្ញាផងដែរ។ យើងក៏សូមផ្តល់អនុសាសន៍ឱ្យរាជរដ្ឋាភិបាលកម្ពុជាឆ្លៀតយកឱកាសនេះដើម្បីធ្វើការពិចារណាលើអនុសាសន៍របស់យើងដែលបានផ្តល់ជូននៅក្នុងផ្នែកនេះដើម្បីដាក់បញ្ចូលទៅក្នុងអនុក្រឹត្យទៅតាមលទ្ធភាពដែលអាចធ្វើបានទៅតាមបរិបទ និងប្រព័ន្ធច្បាប់កម្ពុជាតាមការគួរ។ ជាងនេះទៅទៀត វិស័យឯកជនគួរតែទទួលបានឱកាសនៅក្នុងការផ្តល់ មតិយោបល់ និងធាតុចូលផ្សេងៗ មុនពេលក្រសួងពាណិជ្ជកម្មធ្វើការអនុម័ត ហើយ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាសូមស្វាគមន៍ចំពោះឱកាសក្នុងការផ្តល់កិច្ចគាំទ្រ ដើម្បីជួយសម្របសម្រួលដំណើរការពិគ្រោះយោបល់នេះ។*

៨

# ការដាក់ចេញនូវឧបាស្រ័យដាក់លាក់សម្រាប់ករណីរំលោភលើកម្មសិទ្ធិបញ្ញា

រក្សាទុកដដែល

**ពិពណ៌នាបញ្ហា**

*នៅក្នុងបណ្តាប្រទេសជាច្រើន រួមមានដូចជាប្រទេសវៀតណាមជាដើម បានដាក់ចេញនូវមាត្រាទៅក្នុងច្បាប់ដើម្បីកំណត់អំពីសំណងខូចខាតដែលអាចទាមទារតាមរយៈតុលាការដោយម្ចាស់ម៉ាកសញ្ញាពីអង្គភាពដែលបានរំលោភទៅលើកម្មសិទ្ធិបញ្ញា (IPR) របស់ខ្លួន។ សំណងខូចខាតទាំងនេះរួមមាន "សំណងខូចខាតជាសម្ភារ" ដូចជាការបាត់បង់ឱកាសប្រាក់ចំណូល ព្រមទាំង "ការខូចខាតជាស្មារតី" ដែលសកម្មភាពរបស់ភាគីរំលោភបំពានបានបង្កការខូចខាតទៅដល់ទ្រព្យសម្បត្តិមិនមែនជាប្រាក់កាសរបស់ម្ចាស់ម៉ាកសញ្ញា ដូចជា កិត្យានុភាព និងកិត្តនាមរបស់ម៉ាកសញ្ញាជាដើម។ ប្រាក់ចំណេញដែលទទួលបានពីភាគីរំលោភល្មើសដោយសារតែសកម្មភាពរំលោភបំពានតែងតែត្រូវប្រគល់ទៅឱ្យម្ចាស់ម៉ាកសញ្ញាវិញ។*

*ប្រទេសកម្ពុជាពុំមានចែងអំពីបញ្ញត្តិទាំងនេះនោះទេ ពោលគឺថាតុលាការប្រើប្រាស់បញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីនៅពេលធ្វើការពិចារណាទៅលើសំណងខូចខាតសម្រាប់ករណីរំលោភលើកម្មសិទ្ធិបញ្ញា។ នីតិវិធីនេះនាំឱ្យមានសំណងខូចខាតតិចតួចជាងការរំពឹងទុកនៅក្នុងសំណុំរឿងប្រហាក់ប្រហែលគ្នានៅក្នុងបណ្តាប្រទេសផ្សេងៗទៀត។ ជាងនេះទៅទៀត ក្រមរដ្ឋប្បវេណីពុំមានបញ្ញត្តិណាមួយដែលតម្រូវឱ្យប្រាក់ចំណេញដែលភាគីល្មើសទទួលបានពីសកម្មភាពល្មើសរបស់ខ្លួនសងមកម្ចាស់ម៉ាកសញ្ញាវិញឡើយ។*

**ផលប៉ះពាល់លើកម្ពុជា**

*កង្វះខាតឧបាស្រ័យជាក់លាក់ដើម្បីដោះស្រាយករណីរំលោភលើកម្មសិទ្ធិបញ្ញា ដែលជាហេតុធ្វើឱ្យមានសំណងតិចតួចដល់ម្ចាស់ម៉ាកសញ្ញាតាមរយៈដំណើរការនីតិវិធីរបស់តុលាការ មានន័យថាហានិភ័យ ដែលត្រូវបង់សំណងជូនម្ចាស់ម៉ាកសញ្ញាពុំមានប្រសិទ្ធភាពធំដុំដែលអាចធ្វើឱ្យអង្គភាពរំលោភលើកម្មសិទ្ធិបញ្ញាមានការរាងចាលឡើយ។ ជាងនេះទៅទៀត ដោយហេតុថាភាគីល្មើសអាចទទួលបានប្រាក់ចំណេញពីសកម្មភាពល្មើសបែបនេះ ទើបការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ចនេះក្លាយជាកត្តាជំរុញឱ្យពួកគេចូលរួមនៅក្នុងសកម្មភាពរំលោភបំពានទាំងនេះ។ កត្តានេះបានធ្វើឱ្យមធ្យោបាយការពារកម្មសិទ្ធិបញ្ញារបស់ម្ចាស់ម៉ាកសញ្ញាស្របច្បាប់មិនសូវមានប្រសិទ្ធភាព ។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យធ្វើការពិគ្រោះយោបល់ជាមួយនឹងវិស័យឯកជនដើម្បីបង្កើតលិខិតូបករណ៍សម្រាប់កំណត់ ឧបាស្រ័យជាក់លាក់ដើម្បីដោះស្រាយករណីរំលោភលើកម្មសិទ្ធិបញ្ញា។

*យើងខ្ញុំសូមផ្តល់អនុសាសន៍ដោយក្តីគោរពដោយស្នើឱ្យរាជរដ្ឋាភិបាលធ្វើការពិគ្រោះយោបល់ជាមួយនឹងវិស័យឯកជនដើម្បីបង្កើតលិខិតូបករណ៍សម្រាប់កំណត់ឧបាស្រ័យជាក់លាក់ដើម្បីដោះស្រាយ ករណីរំលោភលើកម្មសិទ្ធិបញ្ញា។ លិខិតូបករណ៍នេះមានគោលបំណងផ្តល់សំណងឱ្យបានកាន់តែសមស្របដល់ម្ចាស់ម៉ាកសញ្ញាចំពោះការខូចខាតដែលខ្លួនមាន និងសម្រាប់ធ្វើជាឧបករណ៍រារាំងកុំឱ្យសកម្មភាពរំលោភលើកម្មសិទ្ធិបញ្ញាកើតឡើងទៀតនាពេលអនាគត។*

*ជាពិសេស គួរតែធ្វើវិសោធនកម្មច្បាប់ពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាដើម្បីបញ្ជាក់អំពីបញ្ហាដូចខាងក្រោមទាក់ទងនឹងករណីរំលោភកម្មសិទ្ធិបញ្ញា៖*

- *ធាតុសំខាន់ៗដែលត្រូវពិចារណាសម្រាប់ការគណនាសំណងរដ្ឋប្បវេណី។*
- *គំរូសម្រាប់ការកំណត់សំណងខូចខាត។*
- *ប្រភេទនៃសំណងខូចខាត។*

*ជាងនេះទៅទៀត គួរតែធ្វើការពិចារណាអំពីជម្រើសដាក់ចេញនូវសំណងជំងឺចិត្តបន្ថែមលើការខូចខាតក្នុងករណីមានការរំលោភបំពានធ្ងន់ធ្ងរ ឬការរំលោភដែលប្រព្រឹត្តដោយក្រុមជនល្មើសដែលមានអង្គការចាត់តាំង។ គួរកត់សម្គាល់ផងដែរថា សំណងជំងឺចិត្តបន្ថែមលើការខូចខាតមានគោលបំណងដាក់ទោសទណ្ឌដល់ជនល្មើសនៅក្នុងសំណុំរឿងរដ្ឋប្បវេណី និងធ្វើឱ្យជនល្មើសរាងចាល មិនឱ្យប្រព្រឹត្តសកម្មភាពរំលោភបំពានផ្សេងទៀតនាពេលអនាគត។ ដូច្នេះ ក្រៅពីសំណងសម្រាប់ការខូចខាតជាក់ស្តែងដែលបង្កឡើងដោយសកម្មភាពរំលោភបំពាននេះ ចៅក្រមអាចបង្គាប់ឱ្យជនល្មើសប្រគល់រាល់ប្រាក់ចំណេញដែលទទួលបានពីការរំលោភបំពានទៅឱ្យម្ចាស់សិទ្ធិស្របច្បាប់ថែមទៀតផង។ សំណងនេះអាចមានជាសម្ភារ ឬឧបករណ៍ដែលបានប្រើប្រាស់នៅក្នុងការប្រព្រឹត្តសកម្មភាពរំលោភបំពានផងដែរ។*

៩

# ការបង្កើតដំណើរការផ្លូវការសម្រាប់ដោះស្រាយវិវាទក្រៅប្រព័ន្ធ តុលាការនៅតាមកម្រិតក្រសួងដែលពាក់ព័ន្ធ

រក្សាទុកដដែល

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើឱ្យបង្កើតដំណើរការផ្លូវការ សម្រាប់ការដោះស្រាយវិវាទក្រៅប្រពន្ធតុលាការ ដើម្បីដោះស្រាយរាល់ករណីរំលោភលើសិទ្ធិពាណិជ្ជសញ្ញាតាមរយៈក្រសួងពាក់ព័ន្ធ។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*យើងមានក្តីសោមនស្សរីករាយសូមជម្រាបជូនថាក្រសួងពាណិជ្ជកម្មកំពុងដំណើរការរៀបចំធ្វើសេចក្តីព្រាងប្រកាសថ្មីដើម្បីបង្កើតក្រុមប្រឹក្សាឧទ្ធរណ៍ទទួលដោះស្រាយបណ្តឹងលើករណីកម្មសិទ្ធិបញ្ញា (IPR) នៅពេលដែលភាគីពាក់ ព័ន្ធមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់មន្ត្រីចុះបញ្ជីពាក់ព័ន្ធទៅនឹងការចុះបញ្ជីពាណិជ្ជសញ្ញារបស់ខ្លួន។ ការដាក់ចេញនូវយន្តការពិនិត្យមើលនេះគឺជាការវិវត្តដ៏សំខាន់នៅក្នុងការពង្រឹងកម្មសិទ្ធិបញ្ញាក្នុងប្រទេសកម្ពុជា ហើយយើង ក៏សូមលើកទឹកចិត្តក្រសួងពាណិជ្ជកម្មរៀបចំឱ្យមានការចូលរួមពីសំណាក់វិស័យឯកជនដើម្បីធានាថាយន្តការនេះ ឆ្លុះ បញ្ចាំងច្បាស់លាស់អំពីតម្រូវការនៅក្នុងវិស័យនីមួយៗ ដែលសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជានឹងស្វាគមន៍ចំពោះឱកាស ក្នុងការជួយសម្របសម្រួលដំណើរការនេះ។*

**ពិពណ៌នាបញ្ហា**

*នាយកដ្ឋានកម្មសិទ្ធិបញ្ញានៅក្រោមក្រសួងពាណិជ្ជកម្ម បានបង្កើតនីតិវិធី "កូនកាត់ពិសេស" (Hybrid procedure) ដែលមានគោលដៅជួយស្វែងរកដំណោះស្រាយសម្រាប់ករណីរំលោភសិទ្ធិពាណិជ្ជសញ្ញាតាមរយៈការដោះស្រាយវិវាទក្រៅប្រពន្ធតុលាការ ពោលគឺនីតិវិធីដោះស្រាយវិវាទដំហានដំបូងក្រៅប្រព័ន្ធតុលាការ (PADR)។ ការអនុវត្ត PADR ពិតជាទទួលបានជោគជ័យគួរឱ្យកត់សម្គាល់ខ្លាំងណាស់។*

*ទោះជាយ៉ាងនេះក្តី ភាពច្បាស់លាស់ ភាពអាចព្យាករណ៍បាន និងតម្លាភាពនៃ PADR អាចចោទជាបញ្ហាដោយសារតែបច្ចុប្បន្ននៅពុំទាន់មានបទប្បញ្ញត្តិណាមួយចែងលម្អិតអំពីនីតិវិធី និងទំនួលខុសត្រូវរបស់ភាគីនីមួយៗនៅក្នុងដំណើរការបែបនេះនៅឡើយនោះទេ។*

**ផលប៉ះពាល់លើកម្ពុជា**

*ដំណើរការ PADR មានសក្តានុពលយ៉ាងខ្លាំងនៅក្នុងការលើកកម្ពស់ទិដ្ឋភាពនៃកម្មសិទ្ធិបញ្ញា (IPR) នៅក្នុងប្រទេសកម្ពុជា តាមរយៈការផ្តល់មធ្យោបាយមានប្រសិទ្ធផល និងប្រសិទ្ធភាពថ្លៃចំណាយនៅក្នុងការដោះស្រាយវិវាទសិទ្ធិពាណិជ្ជសញ្ញារវាងគូភាគីនៅក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្ម។ នៅក្នុងការអនុវត្តជាក់ស្តែង ក្រុមហ៊ុនធុរកិច្ចមួយចំនួនទំនងជាមានការប្រុងប្រយ័ត្ននៅក្នុងការចូលរួមដំណើរការដែលពុំមានបទប្បញ្ញត្តិបញ្ជាក់អំពីនីតិវិធី និងរៀបរាប់ច្បាស់លាស់ពាក់ព័ន្ធនឹងតួនាទីរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានេះ។ ការដាក់ចេញនូវដំណើរការផ្លូវបន្ថែមទៀតនឹងជួយធ្វើឱ្យ PADR កាន់តែក្លាយជាជម្រើសដែលអាចអនុវត្តបានដើម្បីគាំទ្រទៅដល់ម្ចាស់ពាណិជ្ជសញ្ញា បានកាន់តែច្រើនឡើងជាក់ជាមិនខាន។*

✓ សូមស្នើឱ្យបង្កើតដំណើរការផ្លូវការសម្រាប់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដើម្បីដោះស្រាយរាល់ករណីរំលោភលើសិទ្ធិពាណិជ្ជសញ្ញាតាមរយៈក្រសួងពាក់ព័ន្ធ។

## អនុសាសន៍ឆ្នាំ ២០១៩

*យើងខ្ញុំសូមផ្តល់អនុសាសន៍ដោយក្តីគោរពដោយស្នើឱ្យមានការរៀបចំជាផ្លូវការនូវនីតិវិធី PADR របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា តាមរយៈការអនុម័តបទប្បញ្ញត្តិដែលបញ្ជាក់អំពីនីតិវិធី PADR និងតួនាទីរបស់នាយកដ្ឋាននេះនៅក្នុងដំណើរការ PADR។*

*ជាងនេះទៅទៀត យើងខ្ញុំក៏សូមស្នើឱ្យប្រើប្រាស់នូវ PADR ផ្លូវការដែលអនុវត្តដោយនាយកដ្ឋានដើម្បីធ្វើជាគំរូសម្រាប់អាជ្ញាធររដ្ឋបាលពាក់ព័ន្ធផ្សេងទៀត រួមទាំងនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៅក្រោមក្រសួងឧស្សាហកម្ម និងសិប្បកម្ម ព្រមទាំងនាយកដ្ឋានសិទ្ធិអ្នកនិពន្ធនៅក្រោមក្រសួងវប្បធម៌ និងវិចិត្រសិល្បៈផងដែរ។ អាជ្ញាធររដ្ឋបាលពាក់ព័ន្ធទាំងនេះចាំបាច់ត្រូវតែអនុម័តបទប្បញ្ញត្តិរបស់ខ្លួនដើម្បីអនុវត្ត PADR សម្រាប់ប្រភេទកម្មសិទ្ធិបញ្ញាផ្សេងៗគ្នា។*

*ជាចុងក្រោយ យើងបានកត់សម្គាល់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ២០១៨ របស់ក្រសួងពាណិជ្ជកម្មដែលបានបញ្ជាក់ថា មានច្បាប់ និងបទប្បញ្ញត្តិមួយចំនួនកំពុងត្រូវបានរៀបចំសេចក្តីព្រាង ដែលរួមមានប្រកាសស្តីពីការបង្កើតក្រុមប្រឹក្សាឧទ្ធរណ៍ជាដើម។ យើងសូមផ្តល់អនុសាសន៍ឱ្យរាជរដ្ឋាភិបាលឆ្លៀតឱកាសនេះធ្វើការពិចារណាលើអនុសាសន៍របស់យើងដែលបានផ្តល់ជូននៅក្នុងផ្នែកនេះដើម្បីដាក់បញ្ចូលទៅក្នុងប្រកាសនៅក្នុងកម្រិតវិសាលភាពដែលអាចអនុវត្តនៅក្នុងបរិបទ និងប្រព័ន្ធច្បាប់កម្ពុជាតាមការគួរ។ ជាងនេះទៅទៀត វិស័យឯកជនគួរមានឱកាសនៅក្នុងការផ្តល់មតិយោបល់ និងធាតុចូលមុនពេលនីតិវិធីនេះត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្ម ហើយសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជានឹងស្វាគមន៍ចំពោះឱកាសក្នុងការជួយសម្របសម្រួលដំណើរការពិគ្រោះយោបល់នេះ។*

# វិស័យធនធានមនុស្ស

យើងខ្ញុំមានក្តីសោមនស្សសូមរាយការណ៍ជូនថាការចូលរួមរបស់យើងខ្ញុំជាមួយនឹងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានពង្រឹងកាន់តែល្អប្រសើរចាប់តាំងពីពេលដាក់ឱ្យប្រើប្រាស់សៀវភៅ ស សំណោលើកទីពីររបស់យើងខ្ញុំមក។ បន្ទាប់ពីបានធ្វើការផ្សព្វផ្សាយរួចក្រសួងក៏បានរៀបចំប្រជុំកម្រិតខ្ពស់ដើម្បីធ្វើការបញ្ជាក់ និងការពន្យល់បកស្រាយប្រកបដោយអត្ថប្រយោជន៍ចំពោះក្តីកង្វល់នានាដែលសមាជិកយើងបានលើកឡើង ព្រមទាំងដើម្បីពិភាក្សាអំពីផែនការសកម្មភាពរបស់ខ្លួនសម្រាប់ឆ្នាំខាងមុខ ដោយហេតុថាក្រសួងកំពុងបន្តអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ការងារឆ្នាំ២០១៤-២០១៩ ផងដែរ។ បន្ទាប់ពីកិច្ចប្រជុំស្តាបនានេះរួច ក្រសួងបានផ្ញើលិខិតជូនប្រធានសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨ ដើម្បីបង្ហាញអំពីការឆ្លើយតបលម្អិតចំពោះអនុសាសន៍នីមួយៗ ដោយយោងតាមចំណុចដែលបានពិភាក្សានៅអំឡុងពេលកិច្ចប្រជុំរបស់យើង។

ពាក់ព័ន្ធនឹងការកែលម្អជំពូកនេះ យើងអាចបញ្ជាក់ថាក្រសួងបានធ្វើការបកស្រាយច្បាប់ស្រដៀងគ្នា ពាក់ព័ន្ធនឹងការប្រើប្រាស់គំរូកិច្ចសន្យាដែលបានកំណត់ដោយក្រសួងសម្រាប់ កម្មករនិយោជិតជាជនបរទេស។ ក្រសួងបានលើកឡើងថា គំរូនេះមានគោលបំណងដើម្បីប្រើ ប្រាស់ជាសបទដ្ឋានអប្បបរមានៃកិច្ចសន្យាការងារជនបរទេសប៉ុណ្ណោះ សម្រាប់ ចំណុចដែលតម្រូវ ឱ្យមាន និងជាក្រុមហ៊ុនមាន សិទ្ធិបង្កើតទម្រង់កិច្ចសន្យាដោយខ្លួនឯង ដើម្បីឱ្យស្របតាមលក្ខខណ្ឌតម្រូវនីមួយៗទាំងនេះ។ ទោះបីនេះជាចំណុចវិជ្ជមានក្តី តែការសម្រេចនេះ ហាក់បីដូចជាមិនទាន់មានការផ្សព្វផ្សាយដល់មន្ត្រីជួរមុខនៅឡើយនោះទេ ដោយសារសមាជិកយើងបានរាយ ការណ៍មកថា សម្រាប់ការអនុវត្តជាក់ស្តែង ពួកគាត់ត្រូវបានតម្រូវឱ្យបន្តប្រើគំរូនោះជាជាងទម្រង់កិច្ចសន្យាផ្ទាល់ខ្លួនដដែល។ ស្រដៀងគ្នានេះដែរ ក្រសួងទទួលយកក្តីកង្វល់ របស់វិស័យឯកជន ទាក់ទងទៅនឹងការតម្រូវឱ្យមានគិលានដ្ឋាននៅតាមសហគ្រាសផ្ទាល់សម្រាប់សហគ្រាសណាដែលមានកម្មការនិយោជិតច្រើនជាង ៥០ នាក់ ប៉ុន្តែដោយសារតែបទប្បញ្ញត្តិនេះមានចែងដោយច្បាប់ស្តីពីការងារ ក្រសួងបានបញ្ជាក់ថារាល់ការពិនិត្យមើលឡើងវិញណាមួយអាចធ្វើទៅបាន លុះត្រាតែមានវិសោធនកម្មច្បាប់នោះជាមុនសិន។

ដោយទទួលស្គាល់ភាពមានកម្រិតទាំងនេះ អនុសាសន៍ថ្មីរបស់យើងខ្ញុំនៅឆ្នាំនេះ សូម បន្តគូសបញ្ជាក់បន្ថែមទៀតអំពីភាពចាំបាច់ ក្នុងការត្រួតពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិនៅក្នុងច្បាប់ស្តីពី ការងារនៅកម្ពុជា និងការធ្វើទំនើបកម្ម

និតិវិធីនិងប្រព័ន្ធ គ្រប់គ្រងធនធានមនុស្ស។ បច្ចុប្បន្ន កម្ពុជាមានវិស័យសក្តានុពល ហើយ ចម្រុះជាច្រើនក្រៅពីវិស័យឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើង ដែលមានការរីកចម្រើន និងបានចូលរួមចំណែកគួរឱ្យកត់សម្គាល់ចំពោះកំណើនសេដ្ឋកិច្ចជាតិ ដែលវិស័យនីមួយៗទាំងនេះមានតម្រូវការការងារ និងលក្ខខណ្ឌការងារពិសេសខុសៗគ្នា។អាស្រ័យហេតុនេះ ច្បាប់ស្តីពីការងារគួរតែខិតខំធ្វើឱ្យសម្រេចបាន និងឆ្លុះបញ្ចាំងអំពីតម្រូវការសេដ្ឋកិច្ចដែលកំពុងមានការប្រែប្រួលនេះ ដោយពិចារណាលើតម្រូវការរបស់ភាគីពាក់ព័ន្ធឱ្យបានទូលំទូលាយឡើង។ ជាបច្ច័យល្អ រាជរដ្ឋាភិបាលបានប្រកាសនៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (G-PSF) ដែលបានរៀបចំឡើងនៅខែមីនា ឆ្នាំ២០១៩ ថាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងធ្វើការពិនិត្យមើលឡើងវិញយ៉ាងល្អិតល្អន់ទៅលើច្បាប់ស្តីពីការងារ។ ជាលទ្ធផល យើងខ្ញុំសូមជូនអនុសាសន៍មួយចំនួនដើម្បីបង្ហាញអំពីក្តីកង្វល់ចំពោះការពិនិត្យមើល ឡើងវិញនេះ ជាពិសេស ពាក់ព័ន្ធទៅនឹងកាតព្វកិច្ចហ៊ីកហ៊ីនកូនជាងដែលបានដាក់បន្ទុកមកលើក្រុមហ៊ុន នោះ ដោយហេតុថាក្រុមហ៊ុនជាច្រើនយល់ឃើញថាខ្លួនមិនមានលទ្ធភាពអនុវត្តកិច្ចការនេះដើម្បីគាំទ្រដល់តម្រូវការហ៊ីកហ៊ីន និងការអភិវឌ្ឍន៍របស់ខ្លួនបានឡើយ ជាពិសេសគឺក្រុមហ៊ុននៅក្នុងវិស័យសេវាកម្មតែម្តង។

សារៈសំខាន់នៃការធានាថាច្បាប់ស្តីពីការងារនៅព្រះរាជាណាចក្រកម្ពុជាគាំពារឱ្យសេដ្ឋកិច្ច ដ៏ទូលំទូលាយត្រូវបានធ្វើឡើងបន្ទាប់ពីមានប្រកាសលេខ ៤៤៣ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ។ ប្រកាសលេខ ៤៤៣ នេះត្រូវបានរំពឹងថានឹងនាំមកនូវកិច្ចការពារបន្ថែមដល់វិស័យ មួយចំនួន ប៉ុន្តែ ផលវិបាកនៃសមាសធាតុទូទាត់អតីតភាពការងារបែបប្រតិសកម្មនេះ បានគំរាមកំហែងដល់ភាពប្រកួតប្រជែងរបស់វិស័យធុរកិច្ចជាច្រើន ហើយថែមទាំងបានធ្វើឱ្យក្រុមហ៊ុនធុរកិច្ចដែលប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាកាន់តែមានការលំបាកខ្លាំងឡើងទៀតផង។ នៅខែតុលា ឆ្នាំ២០១៨ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា គឺជាផ្នែកមួយនៃសំឡេងរួមរបស់វិស័យឯកជនដែលមានសមាគមធុរកិច្ចជាង ៣០ បានរួមគ្នាបង្ហាញពីផលវិបាកធ្ងន់ធ្ងរកើតចេញពីការអនុវត្តបទប្បញ្ញត្តិនេះ និងធ្វើការចរចាឱ្យមានការពន្យារពេលអនុវត្ត។ បន្ទាប់ពីកិច្ចប្រជុំចរចាទាំងនេះមកក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញសេចក្តីណែនាំលេខ ០៤២ នៅខែមីនា ឆ្នាំ២០១៩ ដើម្បីពន្យារពេលអនុវត្តសមាសធាតុទូទាត់អតីតភាពការងារបែបប្រតិសកម្មនេះរហូតដល់ខែធ្នូ ឆ្នាំ២០២១ និងបានកាត់បន្ថយចំនួនថ្ងៃដែលតម្រូវឱ្យទូទាត់រំលឹកសម្រាប់ប្រាក់បំណាច់អតីតភាពការងារពី ១៥ ថ្ងៃ មកត្រឹម ៦ ថ្ងៃក្នុងមួយឆ្នាំ។ ដោយសារមានការសម្រេចទាំងនេះ យើងមិនបានដាក់បញ្ចូលនូវអនុសាសន៍ជាក់លាក់ពាក់ព័ន្ធនឹងការទូទាត់ប្រាក់បំណាច់អតីតភាពការងារនៅក្នុងសៀវភៅ ស ឆ្នាំនេះឡើយ។

១០

# ការចុះបញ្ជិកាលើកិច្ចសន្យាការងារជនបរទេស

ធ្វើបច្ចុប្បន្នភាព

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុញ្ញាតឱ្យនិយោជកដាក់ជូនសំណៅកិច្ចសន្យាការងារផ្លូវការរបស់ខ្លួនជាមួយនឹងកម្មករនិយោជិតជាជនបរទេស ជាភាសាខ្មែរ ជំនួសឱ្យការបំពេញគំរូកិច្ចសន្យាការងារកំណត់ជាមុនដែលក្រសួងកំណត់ឱ្យប្រើ។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*តាមរយៈលិខិតរបស់ខ្លួនផ្ញើជូនសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា កាលពីខែមេសា ឆ្នាំ២០១៨ (ឯកសារយោងលេខ ៦១០ កប/សហអ) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជាក់ថា និយោជកមិនត្រូវបានតម្រូវឱ្យប្រើប្រាស់នូវគំរូកិច្ចសន្យាកំណត់ជាមុនដែលនាយកដ្ឋានមុខរបរ និងហត្ថពលកម្មបានផ្តល់ឱ្យនោះទេ។ គំរូកិច្ចសន្យាការងារកំណត់ជាមុននេះគឺគ្រាន់តែ ជាគំរូបទដ្ឋានអប្បបរមាដែលក្រសួងតម្រូវឱ្យមានក្នុងការបង្កើតកិច្ចសន្យាការងារជនបរទេសនៅកម្ពុជាតែប៉ុណ្ណោះ។ ក្រសួងទទួលស្គាល់ថា ក្រុមហ៊ុនធុរកិច្ចមានសិទ្ធិបង្កើតកិច្ចសន្យាផ្ទាល់ខ្លួនដើម្បីឱ្យសមស្របទៅនឹងតម្រូវការជាក់លាក់របស់ខ្លួន ប៉ុន្តែខ្លឹមសារនៃកិច្ចសន្យាការងារនោះ ចាំបាច់មិនត្រូវខ្វះនូវចំណុចណាមួយដែលមាននៅក្នុងគំរូបទដ្ឋានអប្បបរមានៃកិច្ចសន្យារបស់នាយកដ្ឋានមុខរបរ និងហត្ថពលកម្មទេ។ បន្ទាប់មក កិច្ចសន្យាការងារនោះត្រូវយកមកចុះបញ្ជិកានិងតម្កល់ទុកមួយច្បាប់នៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម។*

*ទោះបីជាយើងខ្ញុំស្វាគមន៍ចំពោះការបញ្ជាក់របស់ក្រសួងថាដូចគ្នាទៅនឹងការបកស្រាយច្បាប់ដែលបានធ្វើឡើង ដោយសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ហើយថាការអនុវត្តដំណើរការចុះបញ្ជិកាកិច្ចសន្យាការងារជនបរទេសមានភាពងាយស្រួលជាងមុនក្តី ប៉ុន្តែសមាជិករបស់យើងបានរាយការណ៍ថា ការអនុវត្តជាក់ស្តែងមិនមែនបែបនេះនោះទេ។ ទោះបីជាចំណុចនេះអាចដោយសារតែការផ្សព្វផ្សាយអំពីការបកស្រាយនេះដល់មន្ត្រីជួរមុខរបស់ក្រសួងនៅមានកម្រិតក្តី តែបញ្ហានេះនៅតែមានដូចមុនដដែល ដោយហេតុថាក្រុមហ៊ុនធុរកិច្ចនៅតែត្រូវបានតម្រូវឱ្យមានគំរូកិច្ចសន្យាការងារកំណត់ជាមុនដើម្បីចុះបញ្ជិកាកម្មករនិយោជិតជាជនបរទេសដដែល។*

**ពិពណ៌នាបញ្ហា**

*យោងតាមប្រការ ៣ នៃប្រកាសលេខ ១៩៦ ម្ចាស់ ឬប្រធានក្រុមហ៊ុនដែលមានកម្មករនិយោជិតជាជនបរទេសត្រូវចុះបញ្ជិកាកិច្ចសន្យាការងារជនបរទេសនៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្មនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬនៅមន្ទីរក្រុង/ខេត្តរបស់ក្រសួង។ ទោះបីជាពេលនេះក្រសួងបានបញ្ជាក់ថា និយោជកមិនចាំបាច់ត្រូវតែប្រើទម្រង់កិច្ចសន្យាកំណត់ជាមុននេះឡើយប្រសិនបើទម្រង់កិច្ចសន្យា ដែលខ្លួនបានបង្កើតមានព័ត៌មានលម្អិតជាក់លាក់ទាំងអស់ក៏ដោយ តែការអនុវត្ត ជាក់ស្តែង សមាជិកសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាបានរាយការណ៍ថាខ្លួននៅតែត្រូវបានតម្រូវឱ្យបំពេញទម្រង់កិច្ចសន្យាការងាររបស់ក្រសួងសម្រាប់កម្មករនិយោជិតជាជនបរទេសម្នាក់ៗដដែល។*

*ដោយសារតែទម្រង់កិច្ចសន្យានេះមានលក្ខណៈសាមញ្ញ ទើបទម្រង់នេះមិនមានព័ត៌មានលម្អិតគ្រប់គ្រាន់អំពីផ្នែកដែលជាទូទៅនិយោជកចង់ដាក់បញ្ចូលនៅក្នុងកិច្ចសន្យាការងារ នេះមានន័យថាកម្មករនិយោជិតបរទេសជាជនបរទេសត្រូវបានភ្ជា*

ប់កាតព្វកិច្ចការងារដោយកិច្ចសន្យាការងារពីរខុសពីគ្នា ដែលអាចមានខ្លឹមសារ និងលក្ខខណ្ឌការងារខ្វាស់គ្នាទៀតផង។ ស្រដៀងគ្នានេះដែរ ការប្រើទម្រង់កិច្ចសន្យាការងារនេះ បានតម្រូវឱ្យនិយោជកចុះបញ្ជិកាកម្មករនិយោជិតជាជនបរទេសនៅលើកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ដោយបានមើលរំលងត្រង់ចំណុចថាកម្មករនិយោជិតជាជនបរទេសអាចបម្រើការងារស្របច្បាប់នៅកម្ពុជាដោយមិនមានពេលកំណត់។ កត្តានេះបានតម្រូវឱ្យនិយោជកដាក់ទម្រង់កិច្ចសន្យាជាថ្មីម្តងទៀតរៀងរាល់ពីរឆ្នាំម្តង ដែលជាហេតុធ្វើឱ្យក្រុមហ៊ុនមានបន្ទុកចំណាយនិងបន្ទុករដ្ឋបាលកាន់តែច្រើនឡើង។

## ផលប៉ះពាល់លើកម្ពុជា

ដោយសារតែទម្រង់កិច្ចសន្យាការងារដែលបានផ្តល់ឱ្យដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនមានព័ត៌មានពិស្តារគ្រប់គ្រាន់ ទើបនិយោជកមិនអាចចុះបញ្ជិកាជាផ្លូវការនូវព័ត៌មានលម្អិត នៃកិច្ចព្រមព្រៀងដែលខ្លួនបានចុះជាមួយនឹងកម្មករនិយោជិត។ នេះមានន័យថា និយោជកត្រូវតម្រូវឱ្យកម្មករនិយោជិតជាជនបរទេសរបស់ខ្លួនចុះកិច្ចសន្យាការងារដាច់ដោយឡែក និងមានព័ត៌មានលម្អិតមួយផ្សេងទៀតដែលកត្តានេះបានបង្កើតឱ្យមានភាពមិនច្បាស់លាស់ដោយសារតែកិច្ចសន្យាទីពីរនេះមិនមានការទទួលស្គាល់ជាផ្លូវការឡើយ។ កត្តានេះបង្កើតឱ្យមានចន្លោះខ្វះខាតសម្រាប់ការរំលោភបំពានលើលក្ខខណ្ឌការងារ ដោយសារតែទម្រង់កិច្ច សន្យាដែលផ្តល់ឱ្យក្រសួង អាចមានព័ត៌មានលម្អិតខុសគ្នាពីកិច្ចព្រមព្រៀងផ្លូវការដូចជា ប្រាក់បៀវត្សរ៍ទាបជាងប្រាក់ខែដែលបានបើកដាក់ស្តែងឱ្យកម្មករនិយោជិត ដែលនេះគឺជាមធ្យោបាយមួយក្នុងការកាត់បន្ថយប្រាក់ពន្ធដែលត្រូវបង់។ ស្ថានភាពបច្ចុប្បន្ននេះមិនមានប្រសិទ្ធផលសម្រាប់រាជរដ្ឋាភិបាល និងនិយោជកឡើយ ដោយហេតុថាអាជ្ញាធរមិនបានឃើញកិច្ចសន្យាទាំងស្រុងដែលបានចុះរវាងនិយោជក និងកម្មករនិយោជិតផង ខណៈដែលនិយោជកពុំមានវិធីអាចធ្វើឱ្យកិច្ចសន្យាការងាររបស់ខ្លួន និងកម្មករនិយោជិតមានការទទួលស្គាល់ជាផ្លូវការដោយរាជរដ្ឋាភិបាលឡើយ។”

លើសពីនេះទៅទៀត ការរឹតបន្តឹងកម្មករនិយោជិតជាជនបរទេសឱ្យចុះកិច្ចសន្យាការងារដែល មានកំណត់ថិរវេលា បានធ្វើឱ្យកម្មករនិយោជិតដែលជាអ្នកនាំមកនូវជំនាញ និងជួយសម្រួលដល់ការផ្ទេរចំណេះដឹងសម្រាប់ជាអត្ថប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជា បាត់បង់អត្ថប្រយោជន៍ដោយមិនស្មើភាពទៅវិញ។ ទោះបីជាយើងទទួលស្គាល់ថា រាជរដ្ឋាភិបាលអាចមានបំណងធានាថា តួនាទីនេះមិនគួរបំពេញជាអចិន្ត្រៃយ៍ដោយ កម្មករនិយោជិតជាជនបរទេសឡើយ ដើម្បីផ្តល់ឱកាសសម្រាប់ពលរដ្ឋកម្ពុជាក៏ដោយ ប៉ុន្តែនិយោជកត្រូវបានតម្រូវជាស្រេចឱ្យបង់ថ្លៃឈ្នួលការងារនេះ ប្រសិនបើនិយោជក ទាំងនោះមានកូតានិយោជិតជាជនបរទេសលើសចំនួនកំណត់ ហេតុនេះក្រុមហ៊ុនទាំង នោះមិនគប្បីទទួលរងការពិន័យបន្ថែមពីលើទៀតឡើយ។ ទន្ទឹមនឹងនេះ និយោជក ក៏ត្រូវផ្តល់ឱកាសស្មើភាពគ្នាដល់និយោជិតបរទេសក្នុងការទទួលបានស្ថិរភាព និងសន្តិសុខការងារមិនមានថិរវេលាកំណត់ផងដែរដើម្បីទាក់ទាញបេក្ខភាពមានទេពកោសល្យ និងដើម្បីរៀបចំផែនការយុទ្ធសាស្ត្រធុរកិច្ចរយៈពេលវែង។

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យផ្លាស់ប្តូរគំរូកិច្ចសន្យាកំណត់ជាមុន សម្រាប់កម្មករនិយោជិតជាជនបរទេសដោយជំនួសមកវិញនូវទម្រង់បទដ្ឋានតាមប្រព័ន្ធអនឡាញដែលមានព័ត៌មានលម្អិតជាមូលដ្ឋានអំពីកិច្ចសន្យាការងារផ្លូវការ។

*ដោយទទួលស្គាល់ថាកិច្ចសន្យាការងារផ្លូវការគឺជាឯកសារគ្រប់ជ្រុងជ្រោយដែលមានខចែង និងលក្ខខណ្ឌស្មុគស្មាញ ហើយកិច្ចការនេះអាចក្លាយជាបន្ទុករដ្ឋបាលសម្រាប់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈក្នុងការរៀបចំខ្លឹមសារនៃកិច្ចសន្យានីមួយៗ អាស្រ័យហេតុនេះ យើងសូមគោរពផ្ដល់ជូននូវអនុសាសន៍ដោយស្នើឱ្យក្រសួងប្ដូរទម្រង់កិច្ចសន្យាកំណត់ជាមុន ដោយជំនួសមកវិញនូវទម្រង់កិច្ចសន្យាការងារមានបទដ្ឋានកាន់តែសាមញ្ញ សម្រាប់កម្មករនិយោជិតជាជនបរទេស។ យើងខ្ញុំរំពឹងថាទម្រង់កិច្ចសន្យាមានបទដ្ឋាននេះមានសេចក្ដីលម្អិតសំខាន់អំពីកិច្ចសន្យាការងារ និងលក្ខខណ្ឌការងារ ដូចជា ប្រាក់បៀវត្សរ៍ រយៈពេលកិច្ចសន្យា និងថ្ងៃឈប់ សម្រាកបុណ្យជាតិជាដើម រួមទាំងសេចក្ដីប្រកាសដែលបង្ហាញថារាជរដ្ឋាភិបាលមិនបានគាំទ្រឱ្យមានខ្លឹមសារក្នុងកិច្ចសន្យាការងារដើម្បីកម្រិតទំនួលខុសត្រូវនោះទេ។*

*ដើម្បីឱ្យកាន់តែមានប្រសិទ្ធផលផ្នែករដ្ឋបាលបន្ថែមទៀត ទម្រង់កិច្ចសន្យាការងារនេះអាចបំពេញ និងដាក់ជូនតាមកម្មវិធីប្រព័ន្ធអនឡាញក្នុងគេហទំព័ររបស់ក្រសួង ដោយស្របតាមប្រព័ន្ធសុំកូតាសម្រាប់កម្មករនិយោជិតជាជនបរទេស និងប័ណ្ណការងារផងដែរ។ ដំណើរការនេះនឹងបន្សុីបានយ៉ាងល្អជាមួយនឹងផែនការរបស់ក្រសួងក្នុងការធ្វើទំនើបកម្មរបៀបអនុវត្តន៍ការងាររបស់ខ្លួន ហើយថែមទាំងអាចកាត់បន្ថយបញ្ហាប្រឈមកន្លងមកពាក់ព័ន្ធនឹងការផ្សព្វផ្សាយជូនដល់មន្ត្រីជួរមុខរបស់ក្រសួងផងដែរ។ លើសពីនេះទៅទៀត ការកំណត់បទដ្ឋានដំណើរការនេះ ក៏នឹងដកការរឹតបន្តឹង ដែលបានដាក់លើនិយោជកឱ្យចុះបញ្ជិកានិយោជិតបរទេសនៅក្នុងកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ដោយសារតែទម្រង់កិច្ចសន្យាការងារថ្មីនេះនឹងយក តាមគំរូកិច្ចសន្យាផ្លូវការដែលមានសេចក្ដីលម្អិត ព្រមទាំងផ្ដល់នូវ ស្ថិរភាព និងសន្តិសុខការងារ ជូនកម្មករនិយោជិតជាជនបរទេសដូចគ្នាទៅនឹងកម្មករនិយោជិតជាជនជាតិខ្មែរផងដែរ។*

១១

# គិលានដ្ឋាននៅតាមសហគ្រាសធុនមធ្យម

**ធ្វើបច្ចុប្បន្នភាព**

---

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើឱ្យធ្វើកែសម្រួលឡើងវិញនូវលក្ខខណ្ឌតម្រូវឱ្យសហគ្រាសដែលមាននិយោជិតលើសពី ៥០ នាក់ឡើងទៅ ត្រូវតែមានគិលានដ្ឋាន ប្រចាំការនៅនឹងសហគ្រាសរបស់ខ្លួន។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*ដូចមានចែងនៅក្នុងច្បាប់ស្តីពីការងារ បច្ចុប្បន្នសហគ្រាសទាំងឡាយណាដែលមាននិយោជិតលើសពី ៥០ នាក់ឡើងទៅនៅក្នុងប្រទេសកម្ពុជា ត្រូវបានតម្រូវឱ្យមានគិលានដ្ឋានប្រចាំការនៅនឹងសហគ្រាសរបស់ខ្លួនដែលកត្តានេះអាចបង្កើនចំណាយយ៉ាងច្រើនសន្ធឹកសន្ធាប់បន្ថែមទៀតដល់និយោជក និងធ្វើឱ្យមានការប្រើប្រាស់មិនគ្រប់គ្រាន់នូវធនធានថែទាំសុខភាពដ៏មានតម្លៃ។ តាមរយៈលិខិតដែលក្រសួងបានផ្ញើមក សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែមេសា ឆ្នាំ២០១៨ កន្លងទៅ (ឯកសារយោងលេខ ៦១០ក.ប/ស.ហ.អ) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានទទួលស្គាល់ថាលក្ខខណ្ឌតម្រូវនេះកំពុងធ្វើឱ្យប៉ះពាល់ដល់វិស័យឯកជន ប៉ុន្តែដោយសារតែចំណុចនេះមានចែងនៅក្នុងច្បាប់ស្តីពីការងារ ចាំបាច់ត្រូវតែមានវិសោធនកម្មច្បាប់ស្តីពីការងារជាមុនសិន។*

*ក្រសួងបានបញ្ជាក់អំពីចេតនារបស់ខ្លួនក្នុងការទទួលយកអនុសាសន៍នេះទៅពិចារណានៅក្នុងកិច្ចប្រជុំពិភាក្សាបន្ថែមជាមួយបុគ្គលិកបច្ចេកទេសសុខភាព និងសុវត្ថិភាពនៅកន្លែងការងារ។ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាសូមស្វាគមន៍ដំណើរការវិវត្តន៍នេះ ហើយនឹងបន្តលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាលពិចារណាដកចេញនូវលក្ខខណ្ឌតម្រូវនេះសម្រាប់សហគ្រាសដែលមាននិយោជិតលើសពី ៥០ នាក់ឡើងទៅ ដែលនៅក្បែរមន្ទីរពេទ្យជាប់កិច្ចសន្យាជាមួយនឹងបេឡាជាតិរបបសន្តិសុខសង្គម (បសស)។*

---

**ពិពណ៌នាបញ្ហា**

*ប្រកាសលេខ ៣៣០ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាសចែងថា «និយោជករបស់សហគ្រាស ឬគ្រឹះស្ថានដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ការងារដែលមានបុគ្គលិកចាប់ពី ៥០ នាក់ ឬច្រើនជាងនេះ គួរបង្កើតគិលានដ្ឋានអចិន្ត្រៃយ៍មួយនៅក្នុងសហគ្រាសរបស់ខ្លួន»។ គិលានដ្ឋាននេះត្រូវមានវេជ្ជបណ្ឌិតប្រចាំការនៅនឹងកន្លែងពេញម៉ោងដែលទទួលប្រាក់ខែពីនិយោជក ហើយអាស្រ័យលើទំហំធុរកិច្ចរបស់ក្រុមហ៊ុន អាចតម្រូវឱ្យមានបុគ្គលិកថែទាំសុខភាពធ្វើការពេញម៉ោងផងដែរ។*

*យើងខ្ញុំទទួលស្គាល់នូវសារៈសំខាន់នៃបទប្បញ្ញត្តិនេះសម្រាប់ធុរកិច្ចនៅក្នុងវិស័យមួយចំនួនដែលស្ថិតនៅជនបទឆ្ងាយពីមន្ទីរពេទ្យ ប៉ុន្តែសម្រាប់ធុរកិច្ចក្នុងទីប្រជុំជនដូចជាមិនចាំបាច់ត្រូវអនុវត្តន៍បទប្បញ្ញត្តិនេះឡើយ ពីព្រោះថាករណីនេះបន្ថែមបន្ទុកចំណាយទៅលើនិយោជកថែមទៀត និងបង្វែរចេញពីធនធានថែទាំសុខភាពដ៏មានតម្លៃទៅវិញ។ សម្រាប់ធុរកិច្ចនៅរាជធានីភ្នំពេញ មានមន្ទីរពេទ្យជាប់កិច្ចសន្យាជាមួយបេឡាជាតិរបប សន្តិសុខសង្គមមួយចំនួនដែលស្ថិតនៅជិតខ្លួនរួចហើយ ដូច្នេះចំណុចនេះធ្វើឱ្យមាន ភាពមិនច្បាស់ថាតើមានអត្ថប្រយោជន៍បន្ថែមអ្វីខ្លះទៀតដែលទទួលបានពីគិលានដ្ឋាននៅនឹងសហគ្រាសផ្ទាល់នោះ។ ដូច្នេះ កត្តានេះបានបង្កើតឱ្យមានភាពមិនច្បាស់ លាស់សម្រាប់ធុរកិច្ចថាតើធុរកិច្ចនឹងត្រូវទទួលពិន័យចំពោះការមិនអនុវត្តតាមបទប្បញ្ញត្តិនេះឬទេ និងអាចបង្កើតឱ្យមានឱកាសសម្រាប់ការអនុវត្តមិនមានតម្លាភាព។*

## ផលប៉ះពាល់លើកម្ពុជា

*បទប្បញ្ញត្តិនេះតម្រូវឱ្យនិយោជកជួលគ្រូពេទ្យដែលមានវិជ្ជាជីវឱ្យធ្វើការពេញម៉ោងយ៉ាងហោចណាស់ម្នាក់ដែល ទទួលប្រាក់ខែពីនិយោជក។ ក្នុងករណីដែលមិនមានភាពចាំបាច់ក្នុងការបង្កើតគិលានដ្ឋាននៅតាមសហគ្រាស គោលនយោបាយនេះនឹងបង្កើតបន្ទុកចំណាយច្រើនថែមទៀតដល់និយោជកជាមួយនឹងអត្ថប្រយោជន៍ជាក់ស្តែងតិចតួចហើយទីបំផុតទៅ បែរជាធ្វើឱ្យប៉ះពាល់ដល់ភាពប្រកួតប្រជែងនៅលើឆាកអន្តរជាតិរបស់កម្ពុជាទៅវិញ។ លក្ខខណ្ឌតម្រូវនេះមិនត្រឹមតែជាចំណាយច្រើនសម្រាប់ក្រុមហ៊ុន ធុរកិច្ចប៉ុណ្ណោះទេ ប៉ុន្តែក៏មិនបានផ្តល់ឱ្យប្រទេសកម្ពុជា នូវបុគ្គលិកថែទាំសុខភាពដែលទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈត្រឹមត្រូវដែលត្រូវការជាចាំបាច់នោះដែរ ដោយសារគ្រូពេទ្យអាជីពដែលគេជួលមកដោយមិនមានភាពចាំបាច់នៅតាមគិលានដ្ឋានសហគ្រាស អាចយកជំនាញរបស់ខ្លួនទៅបម្រើនៅផ្នែកនានាដែលមានធនធានមិនគ្រប់គ្រាន់ដើម្បីផ្តល់អត្ថប្រយោជន៍សាធារណៈកាន់តែល្អប្រសើរជាងនេះ។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យធ្វើវិសោធនកម្មច្បាប់ស្តីពីការងារដើម្បីអនុញ្ញាតឱ្យមានការកែសម្រួលឡើងវិញនូវលក្ខខណ្ឌតម្រូវដែលតម្រូវឱ្យសហគ្រាសដែលមានកម្មករនិយោជិតលើសពី ៥០ នាក់ឡើងទៅត្រូវមានគិលានដ្ឋានប្រចាំការនៅតាមសហគ្រាសរបស់ខ្លួន។

*ដោយសារលក្ខខណ្ឌតម្រូវ សម្រាប់ធុរកិច្ចដែលមានកម្មករនិយោជិតលើសពី៥០នាក់ត្រូវមានគិលានដ្ឋានប្រចាំការនៅតាមសហគ្រាសរបស់ខ្លួន មានចែងនៅក្នុងច្បាប់ស្តីពីការងារ យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យរាជរដ្ឋាភិបាលពិចារណាធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ ដើម្បី អនុញ្ញាតឱ្យមានការកែសម្រួលឡើងវិញលើបទប្បញ្ញត្តិនេះ។ បន្ទាប់ពីវិសោធនកម្មនេះ រួច មានតែធុរកិច្ចដែលមានកម្មករនិយោជិតលើសពី ៥០ នាក់ឡើងទៅ និងមានទីតាំងស្ថិតនៅក្នុងតំបន់ដែលមិនមានមន្ទីរពេទ្យជាប់កិច្ចសន្យាជាមួយបេឡាជាតិរបបសន្តិសុខសង្គមប៉ុណ្ណោះដែលតម្រូវឱ្យបង្កើតគិលានដ្ឋានប្រចាំការនៅតាមគ្រឹះស្ថានរបស់ខ្លួន។*

*សម្រាប់ក្រុមហ៊ុនធុរកិច្ចដែលស្ថិតក្រោមបទប្បញ្ញត្តិនៃប្រកាសនេះ ហើយស្ថិតនៅក្បែរមន្ទីរពេទ្យជាប់កិច្ចសន្យាជាមួយបេឡាជាតិរបបសន្តិសុខសង្គម យើងខ្ញុំសូមស្នើឱ្យធ្វើការពិចារណាប្តូរលក្ខខណ្ឌតម្រូវឱ្យជួលវេជ្ជបណ្ឌិតប្រចាំការពេញម៉ោង មកត្រឹមលក្ខខណ្ឌតម្រូវជ្រើសតាំងយ៉ាងហោចណាស់បុគ្គលិកម្នាក់ដែលទទួលបន្ទុករៀបចំជំនួយ សង្គ្រោះបឋមជំនួសវិញ។ បុគ្គលិកដែលបំពេញតួនាទីនេះចាំបាច់ត្រូវឆ្លងកាត់ការ បណ្តុះបណ្តាលជាក់លាក់ដែលមានការទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច របស់រដ្ឋាភិបាល ហើយត្រូវទទួលខុសត្រូវលើការផ្តល់ជំនួយសង្គ្រោះបឋម សម្រាប់របួសតូចតាច និងទំនាក់ទំនងជាមួយមណ្ឌលសុខភាពដើម្បីធានានូវការទទួល បានសេវាវេជ្ជសាស្ត្រចាំបាច់ក្នុងករណីដែលមានឧបទ្ទវហេតុធ្ងន់ធ្ងរនៅនឹងកន្លែងការងារ។*

*ដោយសារតែប្រកាសនេះបានអនុញ្ញាតឱ្យសហគ្រាសមួយដែលមានកន្លែងការងារច្រើននូកន្លែងនៅក្នុងចម្ងាយ ៥ គ.ម បង្កើតគិលានដ្ឋានរួមមួយ យើងខ្ញុំស្នើសុំឱ្យក្រសួងពង្រីកវិសាលភាពបញ្ញត្តិនេះដោយអនុញ្ញាតឱ្យសហគ្រាសផ្សេងគ្នាដែលមានភូមិសាស្ត្រនៅជិតសហគ្រាសមួយទៀត (ឧ. តំបន់សេដ្ឋកិច្ចពិសេស សួនឧស្សាហកម្ម ឬនៅក្នុងតំបន់ជាក់លាក់ណាមួយ) ប្រមូលផ្តុំធនធានរបស់ខ្លួនដាក់បញ្ចូល គ្នាដើម្បីបង្កើតបានជាគិលានដ្ឋានរួមដែលមានលក្ខណៈស្រដៀងគ្នានេះដោយក្តីអនុគ្រោះ។*

# ១២

# ការទទួលស្គាល់ទម្រង់ផ្សេងទៀតនៃការរៀនសូត្រតាមរយៈការងារ

ធ្វើបច្ចុប្បន្នភាព

**ពិពណ៌នាបញ្ហា**

*ការហ្វឹកហ្វឺនកូនជាង និងការហាត់ការគឺសុទ្ធតែជាទម្រង់នៃការរៀនសូត្រតាមរយៈការងារដែលបានក្លាយជាមធ្យោបាយកាន់តែមានប្រសិទ្ធភាពក្នុងការលើកកម្ពស់ការ អប់រំ និងការអភិវឌ្ឍជំនាញរបស់និយោជិត តាមរយៈការផ្តល់ឱកាសដល់យុវជនក្នុងការផ្តល់សុពលភាពការរៀនសូត្ររបស់ខ្លួននៅក្រោមលក្ខខណ្ឌអនុវត្តការងារជាក់ស្តែងនៅទីកន្លែងធ្វើការ។ ដំណើរការនេះជួយបំពេញបន្ថែមចន្លោះខ្វះខាតផ្នែកជំនាញដែលមានរវាងចំណេះដឹងដែលបានបង្រៀននៅតាមគ្រឹះស្ថានសិក្សា និងតម្រូវការជាក់ស្តែងរបស់វិស័យឯកជន ហើយក៏អាចឱ្យក្រុមហ៊ុនធុរកិច្ចទទួលបានអត្ថប្រយោជន៍ពីកម្លាំងពលកម្មយ៉ាងច្រើនដែលកម្រិតការអប់រំល្អ និងមានប្រសិទ្ធភាពចំណាយ។*

*តាមធម្មតា ការហ្វឹកហ្វឺនកូនជាងគឺជាកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈផ្លូវការដែលជួយត្រៀមលក្ខណៈឱ្យបុគ្គលិកណាម្នាក់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់មុខជំនាញបច្ចេកទេសជាក់លាក់ ឬធ្វើការនៅក្នុងវិស័យដែលប្រើប្រាស់កម្លាំងបាយ ដូចជាវិស័យសំណង់ ឬផលិតកម្ម ហើយជាធម្មតា ត្រូវចំណាយពេលចន្លោះពីមួយឆ្នាំទៅប្រាំមួយឆ្នាំដើម្បីបញ្ចប់កម្មវិធីនោះ ដោយមានការធានាថានឹងទទួលបានការងារធ្វើនៅពេលរៀនចប់។ ប្រសិនបើយើងប្រៀបធៀប ការហាត់ការ ជាទូទៅ គឺជាការទទួលឱ្យអ្នកហាត់ការចូលធ្វើការក្នុងរយៈពេលខ្លីដែលមិនសូវមានរចនាសម្ព័ន្ធក្នុងរយៈពេលចន្លោះពីមួយខែទៅប្រាំមួយខែ ហើយជារឿយៗគឺដើម្បីនិស្សិតកំពុងសិក្សានៅសាកលវិទ្យាល័យទទួលបានបទពិសោធន៍នៅក្នុងស្ថាប័នសាធារណៈ ឬក្រុមហ៊ុនឯកជនតាមមុខជំនាញជាក់លាក់ដូចជា ការអភិវឌ្ឍធុរកិច្ច ឬការទំនាក់ទំនង ជាមួយនឹងលទ្ធភាពទទួលបានការងារធ្វើ បន្ទាប់ពីនិស្សិតនោះបញ្ចប់ការសិក្សា។*

*នៅកម្ពុជា ដោយសារតែមានការផ្តោតខ្លាំងទៅលើកម្រិតឧត្តមសិក្សា ប្រេវ៉ាឡង់នៃការហាត់ការមានកម្រិតខ្ពស់ជាងកម្មវិធីហ្វឹកហ្វឺនកូនជាង ដោយសារតែនិស្សិតជ្រើសរើសដើមតាមគន្លងអាជីពវិជ្ជាជីវៈជាជាង ជំនាញឯកទេស។ ទោះបីកម្មវិធីនីមួយៗមានគោលបំណងខុសគ្នាក្តី ក៏កម្មវិធីទាំងពីរនេះផ្តល់ការបណ្តុះបណ្តាលតាម រយៈការងារដ៏សំខាន់ដល់យុវជនក្នុងការបង្កើនសមត្ថភាពបច្ចេកទេស ហើយទន្ទឹមនឹងនោះក៏ជួយដោះស្រាយបញ្ហាគម្លាតជំនាញសម្រាប់ជាប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជាផងដែរ។*

*ទោះបីជាមានទំនោរនៃការអនុវត្តច្រើនក៏ដោយ ប៉ុន្តែការហាត់ការមិនត្រូវបានទទួលស្គាល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈថាជាកម្មវិធីដ៏ម្រើសមានសុពលភាពជំនួសកម្មវិធីហាត់ការដែលនាំឱ្យមានការលំបាកសម្រាប់ក្រុមហ៊ុនធុរកិច្ចជាច្រើនដោយសារតែបញ្ញត្តិដែលមានចែងនៅក្នុងប្រកាសលេខ ០០៤។ ប្រកាសលេខ ០០៤ ស្តីពីការហ្វឹកហ្វឺនកូនជាងបានចែងថាគ្រប់ធុរកិច្ចទាំងអស់ដែលមាននិយោជិតលើសពី ៦០ នាក់ឡើងទៅ មិនថានៅក្នុងវិស័យណាក៏ដោយ ត្រូវតែមានកូនជាងនៅក្នុងចំនួនភាគរយជាក់លាក់ណាមួយនៃចំនួនកម្មករនិយោជិតសរុបនៅក្នុងសហគ្រាសរបស់ខ្លួន ហើយសម្រាប់សហគ្រាសទាំងឡាយណាដែលមិនអនុវត្ត*

*តាមបទប្បញ្ញត្តិនេះ នឹងប្រឈមនឹងការពិន័យជាប្រាក់ចំនួន ១% នៃប្រាក់ខែនិយោជិតប្រចាំឆ្នាំសរុប។*

*ទោះបីយើងទទួលស្គាល់អំពីអត្ថប្រយោជន៍នៃការលើកទឹកចិត្តឱ្យក្រុមហ៊ុនធុរកិច្ចជួលបុគ្គលិកដែលមិនសូវមានបទពិសោធន៍ឱ្យបានច្រើនក្នុងគោលបំណងធ្វើជាការហ្វឹកហ្វឺនកូនជាងដើម្បីបណ្តុះបណ្តាលបុគ្គលិកទាំងនោះអំពីមុខជំនាញជាក់លាក់ និងសម្រាប់មុខតំណែងដែលប្រើហត្ថកម្មច្រើនក៏ដោយ ប៉ុន្តែពួកគាត់មិនស័ក្តិសមសម្រាប់ធុរកិច្ចនៅក្នុងវិស័យសេវាកម្មឡើយ។ ផ្ទុយទៅវិញ ការហាត់ការមានភាពទាក់ទាញច្រើនជាងទៅវិញសម្រាប់វិស័យសេវាកម្ម ដោយសារតែក្រុមហ៊ុនធុរកិច្ចមានភាពបត់បែនក្នុងការកែតម្រូវការកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍន៍របស់ខ្លួនឱ្យស្របតាមតម្រូវការរបស់អ្នកហាត់ការម្នាក់ៗទៀតផង។ ស្រដៀងគ្នានេះដែរ ការហាត់ការត្រូវការធនធានតិចក្នុងការគ្រប់គ្រង នៅពេលដែលប្រៀបធៀបទៅនឹងកាតព្វកិច្ចតឹងរ៉ឹងដែលនិយោជកត្រូវបំពេញតាមសម្រាប់កម្មវិធីហ្វឹកហ្វឺនកូនជាងដើម្បីទទួលបានការទទួលស្គាល់។*

*នៅពេលការរីកចម្រើនរបស់វិស័យសេវាកម្មបានក្លាយជាកត្តាចូលរួមចំណែកដ៏ធំធេងចំពោះកំណើនសេដ្ឋកិច្ចកម្ពុជា វិស័យឯកជនបានរក្សាគោលជំហរថាគោលនយោបាយសាធារណៈ គួរតែឆ្លុះបញ្ចាំង និងសម្របសម្រួលតម្រូវការរបស់វិស័យខុសៗគ្នាដែលគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងជាប្រចាំដើម្បីធ្វើ ពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពកម្លាំងពលកម្មរបស់កម្ពុជា។*

## ផលប៉ះពាល់លើកម្ពុជា

*កម្មវិធីហាត់ការផ្តល់អត្ថប្រយោជន៍ដល់ទាំងនិស្សិត សាកលវិទ្យាល័យ និងក្រុមហ៊ុនធុរកិច្ចផងដែរ ហើយជាលទ្ធផលកម្មវិធីទាំងនេះបានក្លាយជាយុទ្ធសាស្ត្រសួលរបស់វិស័យឯកជនក្នុងការដោះស្រាយបញ្ហាកង្វះជំនាញនៅកម្ពុជា។ ការហាត់ការរៀបចំត្រៀមលក្ខណៈកាន់តែប្រសើរសម្រាប់និស្សិតក្នុងការឈានជើងចូលទៅក្នុងបរិបទធុរកិច្ចតាមរយៈការផ្តល់បទពិសោធន៍ពិតជាក់ស្តែង និងជួយបង្ហាត់បង្រៀនពួកគាត់ឱ្យចេះអភិវឌ្ឍជំនាញទន់សំខាន់ៗ ព្រមទាំងបង្កើតបណ្តាញជំនាញវិជ្ជាជីវៈដែលពួកគាត់នៅមានកម្រិត ប្រសិនបើមិនបានឆ្លងកាត់ផងដែរ។ ស្រដៀងគ្នានេះដែរ ការហាត់ការអាចឱ្យសាកលវិទ្យាល័យកសាងទំនាក់ទំនងកាន់តែរឹងមាំជាមួយសហគមន៍ធុរកិច្ចដែលនាំឱ្យមានកម្មវិធីសិក្សាកាន់តែគ្រប់ជ្រុងជ្រោយ និងមាននិស្សិតមានទេពកោសល្យស្របពេលដែលក្រុមហ៊ុនធុរកិច្ចវិញទទួលបានបុគ្គលិកដែលចំណាយប្រាក់ខែសមស្រប និងមានកម្រិតវប្បធម៌ល្អដែលក្រុមហ៊ុនអាចបណ្តុះបណ្តាលបានចាប់ពីដំណាក់កាលចូលបម្រើការងារដំបូងមកម៉្លេះ។ ជាចុងក្រោយ ទំនាក់ទំនងដែលមានការពឹងផ្អែកគ្នាទៅវិញទៅមកនេះនឹងជួយពង្រឹងសមត្ថភាពដល់កម្លាំងពលកម្មរបស់កម្ពុជា ដោយកាត់បន្ថយបញ្ហាកង្វះជំនាញ និងចូលរួមចំណែកធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាកាន់តែមានភាពប្រកួតប្រជែង និងផលិតភាពថែមមួយកម្រិតទៀត។*

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យមានការទទួលស្គាល់កម្មវិធីហាត់ការសមស្របជាផ្លូវការដើម្បីធ្វើជាជម្រើសមានសុពលភាពជំនួសឱ្យកម្មវិធីហ្វឹកហ្វឺនកូនជាងនៅពេលវាយតម្លៃលើការអនុវត្តតាមប្រកាសលេខ ០០៤។

*ទោះបីយើងខ្ញុំទទួលស្គាល់ថាការបង្កើតយុទ្ធសាស្ត្របណ្តុះបណ្តាលល្អដែលសមស្របសម្រាប់គ្រប់វិស័យទាំងអស់មិនមែនជារឿងងាយស្រួលទេក៏ដោយ យើងខ្ញុំសូមគោរពផ្តល់ជូននូវអនុសាសន៍ដល់រាជរដ្ឋាភិបាលចាត់វិធានការលើកទឹកចិត្តឱ្យប្រើកម្មវិធីហាត់ការសមស្រប ដោយទទួលស្គាល់កម្មវិធីនេះជាជម្រើសមានសុពលភាពជំនួសឱ្យកម្មវិធីហ្វឹកហ្វឺនកូនជាងសម្រាប់វិស័យឯកជន។ កត្តានេះនឹងអាចឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើការពិចារណាលើកម្មវិធីហាត់ការរបស់ក្រុមហ៊ុន នៅពេលវាយតម្លៃលើការអនុវត្តប្រកាសលេខ ០០៤ របស់ក្រុមហ៊ុន និងអនុលោមតាមសេចក្តីណែនាំបន្តបន្ទាប់លេខ ០៤២/១៥ ដែលអនុញ្ញាតឱ្យក្រុមហ៊ុនជ្រើសរើសបុគ្គលិកដែលស្ថិតនៅក្នុងរយៈពេលសាកល្បងការងារ ឬបុគ្គលិកដែលកំពុងរៀនជំនាញថ្មីដើម្បីបំពេញលក្ខខណ្ឌតម្រូវហ្វឹកហ្វឺនកូនជាងប្រចាំឆ្នាំ។*

*លើសពីនេះទៅទៀត យើងខ្ញុំក៏សូមស្នើឱ្យក្រសួងធ្វើការពិគ្រោះយោបល់ជាមួយនឹងវិស័យឯកជន និងគ្រឹះស្ថានអប់រំដើម្បីរៀបចំបង្កើតគោលការណ៍ណែនាំស្តីពីការអនុវត្តជាក់ស្តែងសម្រាប់សហគ្រាសទាំងនេះអនុវត្តតាមដើម្បីបង្ហាញថា កម្មវិធីហាត់ការរបស់ខ្លួនគឺអាចបំពេញតាមលក្ខខណ្ឌតម្រូវនេះបាន។*

១៣

# ការគ្រប់គ្រងមូលនិធិសម្រាប់ហ្វឹកហ្វឺនកូនជាង

ថ្មី

## ពិពណ៌នាបញ្ហា

*ប្រការ ៨ នៃប្រកាសលេខ ០០៤ បានចែងថាសម្រាប់ក្រុមហ៊ុនដែលមិនអាច អនុវត្តតាមលក្ខខណ្ឌតម្រូវហ្វឹកហ្វឺនកូនជាង ដូចដែលបានចែងដោយច្បាប់ស្តីពីការងារក្រុមហ៊ុនទាំងនោះត្រូវបង់ពន្ធអាករសម្រាប់ហ្វឹកហ្វឺនកូនជាងចំនួន ១% នៃប្រាក់ឈ្នួលសរុបប្រចាំឆ្នាំរបស់ខ្លួន ហើយក្រុមហ៊ុនដែលមិនបានធ្វើដូច្នោះនឹងត្រូវប្រឈមនឹងការពិន័យសម្រាប់ការមិនអនុវត្តតាម។ ប្រកាសនេះក៏បានបញ្ជាក់ថាមូលនិធិដែលប្រមូលបាន ត្រូវដាក់តម្កល់ចូលទៅក្នុងមូលនិធិសាច់ប្រាក់សុទ្ធដែលក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈនឹងយកទៅប្រើសម្រាប់ការអភិវឌ្ឍកម្មវិធីហ្វឹកហ្វឺនកូនជាងដោយសហការជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងស្ថាប័នពាក់ព័ន្ធផ្សេងទៀតផងដែរ។*

*ទោះបីសមាជិករបស់យើងខ្ញុំស្វាគមន៍ចំពោះហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍជំនាញ និងការហ្វឹកហ្វឺនដែលត្រូវការជាចាំបាច់ខ្លាំងក៏ដោយ ក៏មានក្តីកង្វល់ថាប្រសិនបើមិនមានវិស័យឯកជនចូលរួមទេ នោះការប្រើប្រាស់មូលនិធិទាំងនោះអាចមើលរំលង វិស័យមួយចំនួនដោយសារតែក្រសួងមិនទាន់បានផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការប្រើប្រាស់មូលនិធិទាំងនោះនៅឡើយនោះទេ។ ដោយសារតែមូលនិធិនេះមានគោលបំណងដើម្បីបង្កើនសមត្ថភាពរបស់ប្រជាពលរដ្ឋកម្ពុជាហើយចុងក្រោយអាចបង្កើនផលិតភាព និងភាពប្រកួតប្រជែងរបស់ក្រុមហ៊ុនធុរកិច្ចវិស័យឯកជនគឺជាតួអង្គដ៏ល្អបំផុតក្នុងការណែនាំអំពីផ្នែកអាទិភាពដែលអាចទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីការហ្វឹកហ្វឺនដែលបានកែលម្អកាន់តែល្អប្រសើរ និងការផ្តល់មូលនិធិបន្ថែមទៀត។ ប្រសិនបើមិនមានការចូលរួមពីសំណាក់វិស័យឯកជនទេនោះ អាចនឹងមានហានិភ័យច្រើនដោយការផ្តល់កម្មវិធីហ្វឹកហ្វឺននោះមិនសមស្របទៅនឹងតម្រូវការរបស់វិស័យនីមួយៗ ហើយបញ្ហាគម្លាតជំនាញនាពេលបច្ចុប្បន្នដែលកំពុងមាននៅក្នុងវិស័យជាច្រើននឹងនៅតែបន្តកើតមានទៀត។*

*រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់រួចហើយចំពោះសារៈសំខាន់ និងអត្ថប្រយោជន៍នៃការដាក់បញ្ចូលឱ្យក្រុមភាគីពាក់ព័ន្ធជាច្រើនចូលរួមក្នុងការរៀបចំផែនការ និងការគ្រប់គ្រងមូលនិធិសាធារណៈ ដូចបានឃើញតាមរយៈអង្គភាពគ្រប់គ្រងដែលទទួលខុសត្រូវចំពោះការអនុវត្ត និងការគ្រប់គ្រងបេឡាជាតិរបបសន្តិសុខសង្គមថ្មីៗ អង្គភាពគ្រប់គ្រងនេះមានសមាសភាពតំណាងមកពីក្រសួងរដ្ឋាភិបាល ពាក់ព័ន្ធ និយោជក កម្មករនិយោជិត និងសហជីព ដើម្បីធានាថាគ្រប់ភាគីពាក់ព័ន្ធទាំងអស់សុទ្ធតែមានឱកាសបញ្ចេញយោបល់ក្នុងការប្រើប្រាស់មូលនិធិទាំងនោះ។*

## ផលប៉ះពាល់លើកម្ពុជា

យន្តការពិគ្រោះយោបល់មានប្រសិទ្ធភាពរវាងរាជរដ្ឋាភិបាល និងវិស័យឯកជននៅក្នុងការរៀបចំផែនការ និងការគ្រប់គ្រងមូលនិធិសម្រាប់ការហ្វឹកហ្វឺនកូនជាងនឹងអាចឱ្យក្រសួងអាចបង្កើតប្រព័ន្ធហ្វឹកហ្វឺនកូនជាង ដែលមានលក្ខណៈប្រកួតប្រជែង និងជំរុញដោយតម្រូវការ ដែលឆ្លើយតបចំពោះតម្រូវការដែលកំពុងតែមានការប្រែប្រួលក្នុងសេដ្ឋកិច្ច។ បន្ថែមពីនេះទៅទៀត ដោយសារតែមូលនិធិទាំងនោះទទួលដោយផ្ទាល់ពីក្រុមហ៊ុនធុរកិច្ច ទោះបីពួកគេមានចំណាប់អារម្មណ៍ខ្លាំងនៅក្នុងការធានានូវភាពជោគជ័យនៃកម្មវិធីហ្វឹកហ្វឺនកូនជាង ដូច្នេះគំនិតផ្តួចផ្តើមនេះនឹងផ្តល់អត្ថប្រយោជន៍ជាច្រើនពីការចូលរួមដ៏សកម្មរបស់អ្នកជំនាញនៅក្នុងវិស័យឯកជន។

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបង្កើតអង្គភាពពិគ្រោះយោបល់ដើម្បីឱ្យវិស័យឯកជនចូលរួមក្នុងការរៀបចំផែនការ និងការគ្រប់គ្រងមូលនិធិដែលប្រមូលបានពីពន្ធអាករហ្វឹកហ្វឺនកូនជាង។

យើងខ្ញុំសូមគោរពផ្តល់ជូនអនុសាសន៍ដោយស្នើឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបង្កើតអង្គភាពពិគ្រោះយោបល់ដើម្បីអាចឱ្យវិស័យឯកជនចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការ និងការគ្រប់គ្រងមូលនិធិដែលបានប្រមូលពីពន្ធអាករ ហ្វឹកហ្វឺនកូនជាងសម្រាប់ប្រើនៅក្នុងការបង្កើតកម្មវិធីហ្វឹកហ្វឺនកូនជាង និងការអភិវឌ្ឍកម្លាំងការងារកម្ពុជា។ ការធ្វើបែបនេះ ក្រសួងនឹងបង្កើនភាវនីយភាពដែលមូលនិធិ នឹងត្រូវប្រើប្រាស់សម្រាប់រៀបចំកម្មវិធីហ្វឹកហ្វឺនកូនជាងដែលបង្កើនជំនាញ និងសមត្ថភាពរបស់ប្រជាពលរដ្ឋកម្ពុជានៅក្នុងផ្នែកដែលសេដ្ឋកិច្ចមានតម្រូវការខ្ពស់បំផុត និងត្រៀមលក្ខណៈកម្លាំងពលកម្មម្នាក់ៗយ៉ាងមានប្រសិទ្ធភាពដើម្បីឈានជើងចូលនៅក្នុងទីផ្សារការងារ។ យើងខ្ញុំរំពឹងថាតាមរយៈការដាក់បញ្ចូលភាគីពាក់ព័ន្ធកាន់តែច្រើនឱ្យចូលរួមនៅក្នុងការរៀបចំផែនការ និងការគ្រប់គ្រង រាជរដ្ឋាភិបាល នឹងទទួលបានជោគជ័យដូចអ្វីដែលបានសម្រេចដោយបេឡាជាតិរបបសន្តិសុខសង្គមដូច្នោះដែរ។

១៤

# ការកាត់ចំណាយលើការហ្វឹកហ្វឺនកូនជាង

ថ្មី

**ពិពណ៌នាបញ្ហា**

*ការផ្សព្វផ្សាយសេចក្តីណែនាំលេខ ០៤២/១៩ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅខែវិច្ឆិកា ឆ្នាំ២០១៩ បានបញ្ជាក់ជាថ្មីម្តងទៀតអំពីកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ដូចដែលមានចែងដោយច្បាប់ស្តីពីការងារថា សហគ្រាសដែលមានកម្មករនិយោជិតច្រើនជាង ៦០ នាក់ ត្រូវតែមានកូនជាងចំនួនមួយភាគដប់នៃចំនួនកម្មករនិយោជិតសរុបនៅក្នុងសហគ្រាសរបស់ខ្លួន ដោយមានសមាមាត្រខុសគ្នាសម្រាប់សហគ្រាសមានទ្រង់ទ្រាយធំជាងនេះ។ ប្រសិនបើសហគ្រាសមិនអាចអនុវត្តតាមបានទេនោះ សហគ្រាសទាំងនោះត្រូវបង់ពន្ធអាករហ្វឹកហ្វឺនកូនជាងចំនួន ១% នៃប្រាក់ខែសរុបប្រចាំឆ្នាំដែលក្រុមហ៊ុនត្រូវទូទាត់ជូនកម្មករនិយោជិត ឬត្រូវរងការពិន័យផ្សេងៗទៀត។ សេចក្តីណែនាំនេះក៏បានជូនដំណឹងដល់សហគ្រាសថា ប្រសិនបើសហគ្រាសនោះមានការលំបាកនៅក្នុងរក្សាទុកបេក្ខភាពសម្រាប់ការហ្វឹកហ្វឺនកូនជាង សហគ្រាសនោះអាចបំពេញលក្ខខណ្ឌតម្រូវផ្លូវច្បាប់ដោយយកកម្មករនិយោជិតដែលកំពុងប្រើការងារនៅក្នុងរយៈពេលសាកល្បងការងាររបស់ខ្លួន ឬកម្មករនិយោជិតដែលត្រូវការជំនាញថ្មី។*

*ទោះបីជាសេចក្តីណែនាំនេះបានផ្តល់ការបញ្ជាក់ច្បាស់លាស់ច្រើនដែលត្រូវការជាចាំបាច់ក្តី ក៏នៅតែមានភាពមិនច្បាស់លាស់សម្រាប់សហគ្រាសដែលមានបំណងឱ្យកម្មវិធីហ្វឹកហ្វឺនសម្រាប់កម្មករនិយោជិតមានស្រាប់របស់ខ្លួនត្រូវបានទទួលស្គាល់ដើម្បីបំពេញលក្ខខណ្ឌតម្រូវនេះ និងថាតើការចំណាយបន្ថែមសម្រាប់ការបណ្តុះបណ្តាលនឹងត្រូវពិចារណាដែរឬទេនៅពេលធ្វើការកំណត់ពន្ធអាករហ្វឹកហ្វឺនកូនជាង។ ដោយសារតែអនុបាតលក្ខខណ្ឌតម្រូវឱ្យមានការហ្វឹកហ្វឺនកូនជាងមានលក្ខខណ្ឌពិសេសសម្រាប់សហគ្រាស ទើបសហគ្រាសខ្លះមិនអាចសម្រេចបានតាមកម្រិតដែលបានកំណត់ ដោយសារតែមានការលំបាកក្នុងការទាក់ទាញកូនជាងថ្មីដែលបណ្តាលមកពីភាពជោគជ័យនៃទីផ្សារការងារបច្ចុប្បន្នរបស់កម្ពុជា។ ដូច្នេះការអនុវត្តនេះអាចធ្វើឱ្យមានគម្លាតរវាងចំនួនកូនជាងដែលសហគ្រាសជ្រើសរើស និងចំនួនកំណត់ដែលតម្រូវដោយច្បាប់ ហើយសហគ្រាសនឹងត្រូវបង្ខំចិត្តចំណាយបន្ថែមទៀតលើការហ្វឹកហ្វឺនដែលអាចប៉ះពាល់ដល់លទ្ធភាពប្រាក់ចំណេញរបស់ខ្លួន។*

*អាស្រ័យហេតុនេះ អាចនឹងមានភាពអយុត្តិធម៌ចំពោះសហគ្រាស ដែលមានអនុលោមភាពសារពើពន្ធត្រឹមត្រូវដែលបានខិតខំបំពេញតាមលក្ខខណ្ឌតម្រូវនេះក្នុងអត្រាដូចគ្នានឹងសហគ្រាសដែលមិនបានខិតខំប្រឹងប្រែងបំពេញកាតព្វកិច្ចនេះទាល់តែសោះ ដោយសារកត្តានេះនឹងលើកទឹកចិត្តដល់*

*សហគ្រាសឱ្យចំណាយតិចជាងមុនលើការហ្វឹកហ្វឺនដើម្បីកាត់កងការចំណាយលើពន្ធអាករសម្រាប់ការហ្វឹកហ្វឺនជាង។ ផ្ទុយទៅវិញ សហគ្រាសអាចទទួលបានការអនុញ្ញាតឱ្យកាត់ជាចំណាយសម្រាប់ការហ្វឹកហ្វឺនកូនជាងរបស់ខ្លួនដើម្បីបំពេញតាមកាតព្វកិច្ចតាមអត្រាសមស្របធៀបជាមួយពន្ធ ១% ដែលបានកំណត់ ដោយសារតែកត្តានេះនឹងលើកទឹកចិត្តឱ្យក្រុមហ៊ុនចំណាយបន្ថែមលើការហ្វឹកហ្វឺន និងស្វែងរកកូនជាងកាន់តែច្រើនដោយប៉ុរេសកម្ម។*

## ផលប៉ះពាល់លើកម្ពុជា

*សហគ្រាសជាច្រើនពិតជាចង់បង្កើនចំណេះដឹង និងជំនាញរបស់កម្មករនិយោជិតរបស់ខ្លួន ហើយលើកទឹកចិត្តឱ្យយុវជនកម្ពុជាមកចូលរួមនៅក្នុងកម្មវិធីហ្វឹកហ្វឺនកូនជាងឱ្យបានច្រើន។ ទោះយ៉ាងណាក៏ដោយ ថ្លៃចំណាយបន្ថែមដែលសហគ្រាសត្រូវរ៉ាប់រងអាចជាបន្ទុកដ៏ធ្ងន់ធ្ងរខ្លាំងនៅកម្ពុជា ដោយសារតែបញ្ហាគម្លាតជំនាញដូចដែលនិយោជកភាគច្រើន នៅក្នុងវិស័យឯកជនបានរាយការណ៍។ អាស្រ័យហេតុនេះសហគ្រាសចាំបាច់ត្រូវមានការលើកទឹកចិត្តឱ្យបង្កើត និងគាំទ្រឱកាសហ្វឹកហ្វឺនដែលអាចបំពេញតាមល័ក្ខខណ្ឌតម្រូវរបស់រាជរដ្ឋាភិបាល។ បើមិនដូច្នោះទេអត្ថប្រយោជន៍នៃការចំណាយខ្ពស់ខ្លាំងនឹងពុំទទួលបានសមស្របឡើយ ដោយសារខ្លួននឹងត្រូវរងការពិន័យលើពន្ធអាករហ្វឹកហ្វឺនកូនជាង ទោះបីជាខ្លួនខិតខំអនុវត្តយ៉ាងណាក្តី។*

*ការវិនិយោគលើធនធានមនុស្សគឺជាសមាសធាតុដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ច ដោយសារតែការផ្តល់អាទិភាពលើការអភិវឌ្ឍជំនាញកម្រិតខ្ពស់ នឹងជួយធានានូវសមត្ថភាពប្រកួតប្រជែងនាពេលអនាគត របស់ទីផ្សារការងារកម្ពុជា។ ការផ្តល់ការលើកទឹកចិត្តដល់វិស័យឯកជនដើម្បីបង្កើនការចំណាយសម្រាប់កម្មវិធីហ្វឹកហ្វឺនរបស់ខ្លួនគឺជាជម្រើសដ៏មានប្រសិទ្ធភាពជំនួសឱ្យការផ្តល់មូលនិធិសាធារណៈរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចគោលដៅសេដ្ឋកិច្ចតែមួយ។ ការលើកទឹកចិត្តដល់សហគ្រាសអាចឱ្យវិស័យឯកជនទទួលខុសត្រូវបន្ថែមទៀតលើការហ្វឹកហ្វឺនកម្លាំងពលកម្ម និងធានាថាការផ្តល់ការហ្វឹកហ្វឺននេះ នឹងកំណត់គោលដៅលើតម្រូវការរបស់សហគ្រាសនៅក្នុងវិស័យដែលមានតម្រូវការទីផ្សារ។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមអនុញ្ញាតឱ្យសហគ្រាស កាត់ចំណាយសមស្របលើការហ្វឹកហ្វឺន ដែលប្រើប្រាស់ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវហ្វឹកហ្វឺនកូនជាងនៃច្បាប់ស្តីពីការងារ តាមមូលដ្ឋានសមាមាត្រចេញពីពន្ធអាករហ្វឹកហ្វឺនកូនជាងដែលពាក់ព័ន្ធ។

*យើងខ្ញុំសូមផ្តល់ជូនអនុសាសន៍ឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពិចារណាអនុញ្ញាតឱ្យសហគ្រាសកាត់ចំណាយសមស្រប ដែលបានប្រើប្រាស់ដើម្បីផ្តល់ហិរញ្ញប្បទាន ដល់ការបណ្តុះបណ្តាលបន្ថែម សម្រាប់ការបំពេញតាមលក្ខខណ្ឌតម្រូវហ្វឹកហ្វឺនកូនជាងនៃ ច្បាប់ស្តីពីការងារតាមមូលដ្ឋានសមាមាត្រធៀបនឹងពន្ធអាករហ្វឹកហ្វឺនកូនជាងដែលពាក់ព័ន្ធ។ យើងខ្ញុំសូមលើកទឹកចិត្តដោយក្តីគោរពដោយស្នើឱ្យក្រសួងអនុញ្ញាតឱ្យវិស័យឯកជនចូលរួមនៅក្នុងកិច្ចប្រជុំពិភាក្សាដើម្បីឈានដល់កិច្ចព្រមព្រៀង មួយលើចំណុចដែលគួរតែកំណត់សម្រាប់កាត់ចំណាយលើការហ្វឹកហ្វឺនសមស្រប ហើយសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា សូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះឱកាសសម្របសម្រួលការចូលរួមនេះ។*

*យើងខ្ញុំយល់ឃើញថាតាមរយៈការអនុញ្ញាតឱ្យសហគ្រាសកាត់ចំណាយសម្រាប់ការហ្វឹកហ្វឺនវិស័យឯកជននឹងទទួលបានការលើកទឹកចិត្តឱ្យបង្កើនការចំណាយលើការហ្វឹកហ្វឺនរបស់ខ្លួន និងបង្កើតឱ្យមានមុខតំណែងកម្រិតដំបូងឱ្យបានកាន់តែច្រើនថែមទៀត ដោយពង្រឹងការអភិវឌ្ឍកម្លាំងពលកម្មរបស់កម្ពុជា នឹងបន្តរក្សាកំណើនសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព។*

*យើងខ្ញុំយល់ឃើញថាតាមរយៈការអនុញ្ញាតឱ្យសហគ្រាសកាត់ចំណាយសម្រាប់ការបណ្តុះបណ្តាល វិស័យឯកជននឹងទទួលបានការលើកទឹកចិត្តឱ្យបង្កើនការចំណាយសម្រាប់ការបណ្តុះបណ្តាលរបស់ខ្លួន និងបង្កើតឱ្យមានមុខតំណែងកម្រិតដំបូងឱ្យបានកាន់តែច្រើនថែមទៀត ដោយពង្រឹងការអភិវឌ្ឍកម្លាំងពលកម្មរបស់កម្ពុជា និងបន្តរក្សាកំណើនសេដ្ឋកិច្ចកម្ពុជាឱ្យមានចីរភាព។*

# ១៥

# លទ្ធភាពទទួលបានព័ត៌មាន

ធ្វើបច្ចុប្បន្នភាព

---

**អនុសាសន៍ឆ្នាំ ២០១៧**

ផ្តល់ការគាំទ្របន្ថែមដល់វិស័យឯកជនដើម្បីបង្កើនការយល់ដឹងអំពីច្បាប់ និងបទប្បញ្ញត្តិថ្មីៗ។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា (ឯកសារយោងលេខ ៦១០ ក.ប/សហអ) កាលពីខែមេសា ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជាក់អំពីការងារកំពុងបន្តរបស់ក្រសួងក្នុងការលើកកម្ពស់ការប្រាស្រ័យទាក់ទងជាមួយនឹងវិស័យឯកជន ព្រមទាំងបង្កើនលទ្ធភាពទទួលបានព័ត៌មាន។ ក្រសួងនេះក៏បានបង្ហាញផងដែរ ថាខ្លួនបានផ្តល់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពជាច្រើនដល់មន្ត្រីអធិការកិច្ចការងាររបស់ខ្លួន ហើយមានបំណងរៀបចំវគ្គបណ្តុះបណ្តាលបន្ថែមទៀតនៅពេលអនាគត។ លើសពីនេះទៅទៀត ក្រសួងកំពុងធ្វើទំនើបកម្មវិធីសាស្ត្ររបស់ខ្លួន ក្នុងការផ្សព្វផ្សាយព័ត៌មានដូចបានមើលឃើញតាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង ក្នុងដាក់ពាក្យសុំកូតាបណ្ណការងារ និងសៀវភៅការងារជនបរទេសតាមប្រព័ន្ធទិន្នន័យស្វ័យប្រវត្តិកម្ម។ ក្រសួងក៏បានបញ្ជាក់ផងដែរថា គ្រប់ច្បាប់ បទប្បញ្ញត្តិ និងគំរូឯកសារមួយចំនួនដូចជា សំណុំឯកសារចុះបញ្ជីសហជីព និងសមាគមនិយោជកត្រូវបានដាក់បញ្ចូលទៅក្នុងគេហទំព័រ (website) របស់ក្រសួង។ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា សូមស្វាគមន៍គំនិតផ្តួចផ្តើមទាំងនេះ ហើយរំពឹងថានេះនឹងធ្វើឱ្យមានការប្រាស្រ័យទាក់ទងកាន់តែល្អ និងងាយស្រួលថែមមួយកម្រិតទៀត ដោយសារតែកិច្ចការនេះជួយកាត់បន្ថយការចំណាយពេលវេលា និងធនធានរបស់ក្រសួង និងក្រុមហ៊ុនធុរកិច្ចក្នុងការដោះស្រាយកិច្ចការរដ្ឋបាល។*

---

**ពិពណ៌នាបញ្ហា**

*សមាជិកសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា សូមស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការលើកកម្ពស់ឱ្យមានការចូលរួមជាមួយវិស័យឯកជនតាមរយៈការពង្រឹងបណ្តាញទំនាក់ទំនង និងការផ្សព្វផ្សាយព័ត៌មានប្រកបដោយប្រសិទ្ធភាពអំពីច្បាប់ និងបទប្បញ្ញត្តិថ្មីៗ។ ការកែលម្អគួរឱ្យកត់សម្គាល់បំផុតនោះគឺការដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មបរទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងដែលអាចធ្វើឱ្យក្រុមហ៊ុនធុរកិច្ចដែលមានធ្វើការស្នើសុំកូតា ប្រើប្រាស់កម្លាំងពលកម្មបរទេស និងបណ្ណការងារជនបរទេសតាមរយៈគេហទំព័រក្រសួង។*

*សេវាការិយាល័យច្រកចេញចូលតែមួយនេះ បានធ្វើឱ្យដំណើរការរដ្ឋបាលដែលពីមុនមានភាពស្មុគស្មាញ មកជាមានភាពសាមញ្ញ ហើយក្រុមហ៊ុនធុរកិច្ចមានការគ្រប់គ្រងកាន់តែប្រសើរលើកាតព្វកិច្ចនិយ័តកម្មការងាររបស់ខ្លួន។ ដោយពិចារណាដល់ភាពជោគជ័យនេះ យើងយល់ឃើញថានឹងមានអត្ថប្រយោជន៍យ៉ាងធំធេងក្នុងការពង្រីកសមត្ថភាពរបស់ខ្លួនហួសពីការគ្រប់គ្រងកម្មករនិយោជិតបរទេស ដោយផ្តល់លទ្ធភាព ដល់ការធ្វើបច្ចុប្បន្នការលក្ខខណ្ឌតម្រូវរដ្ឋបាលទាំងអស់តាមរយៈកម្មវិធីតាមប្រព័ន្ធអ៊ីនធឺណិត។ នេះអាចរាប់បញ្ចូលទាំងដំណើរការ ដូចជា ការធ្វើបច្ចុប្បន្នភាពក្រសួងអំពីការចាកចេញរបស់បុគ្គលិក និងការជ្រើសរើសបុគ្គលិកថ្មី លក្ខខណ្ឌតម្រូវសម្រាប់ការបន្ថែមម៉ោង និងការចុះបញ្ជិកាលើកិច្ចសន្យាការងារជនបរទេស។*

## ផលប៉ះពាល់លើកម្ពុជា

ការធ្វើឌីជីថលនីយកម្មដំណើរការរដ្ឋបាលការងារតាមរយៈការពង្រីកកម្មវិធីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម នឹងនាំឱ្យមានអត្ថប្រយោជន៍ជាច្រើន សម្រាប់ទាំងវិស័យឯកជន និងក្រសួង។ ដោយសារតែកម្មវិធីតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះអាចរៀបចំឡើងដើម្បីធានាពីការអនុវត្តតាមនីតិវិធី និងបង្កើតការតាមដានសវនកម្មកម្មវិធីនេះ នឹងជួយសម្រួលអភិបាលកិច្ច និងការត្រួតពិនិត្យកាន់តែមានប្រសិទ្ធផលថែមទៀត ដែលអាចកសាងទំនុកចិត្តចំពោះសុចរិតភាពនៃប្រព័ន្ធរដ្ឋបាល ដែលនាំឱ្យមានអត្រាកំណើនអនុលោមភាពនីតិវិធីកាន់តែមានច្រើនឡើងពីសំណាក់ក្រុមហ៊ុនធុរកិច្ច។ លើសពីនេះទៅទៀត ដោយសារតែការចំណាយពេលវេលា និងការប្រើប្រាស់ធនធានជាច្រើននៅក្នុងការដាក់ និងដំណើរការឯកសារទាក់ទងនឹងការងារ អាចកាត់បន្ថយបានច្រើនសម្រាប់ទាំងក្រុមហ៊ុនធុរកិច្ច និងក្រសួង ហើយក៏អាចជួយកាត់បន្ថយឧបសគ្គ និងបន្ទុកទាក់ទងនឹងការអនុវត្តតាមនីតិវិធីបានកាន់តែច្រើនឡើងផងដែរ។

ការពង្រីកការប្រើប្រាស់កម្មវិធីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ក៏នឹងផ្តល់ភាពបត់បែនកាន់តែច្រើនដល់ក្រសួងនៅក្នុងការផ្សព្វផ្សាយព័ត៌មាន និងការកែសម្រួលក្នុងខណ្ឌតម្រូវសម្រាប់ការដាក់ពាក្យស្នើ ដោយសារតែក្រសួងនឹងមានការគ្រប់គ្រងពេញលេញលើខ្លឹមសារដែលបានចែករំលែកតាមកម្មវិធីនោះ។ កម្មវិធីនេះមានប្រយោជន៍ខ្លាំងណាស់ ដោយសារតែកាតព្វកិច្ចផ្លូវច្បាប់ និងនិយ័តកម្មជាច្រើននៅក្នុងប្រទេសកម្ពុជានឹងត្រូវឆ្លងកាត់រយៈពេលអន្តរកាល និងការបង្កើតជាផ្លូវការដែលពេលខ្លះមិនបានផ្សព្វ-ផ្សាយបានពេញលេញដល់វិស័យឯកជន ឬដល់មន្ត្រីថ្នាក់ក្រោម។ ស្រដៀងគ្នានេះដែរ នេះក៏ជួយកាត់បន្ថយឱកាសនៃការអនុវត្តមិនមានតម្លាភាព ដោយការបន្ថយប្រតិ-បត្តិការជួបមុខផ្ទាល់ ការបញ្ជៀបការតាមដានការទូទាត់ និងគណនេយ្យភាព។

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យធ្វើការពិចារណាពង្រីកប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មបរទេសដើម្បីអាចឱ្យបំពេញនីតិវិធីរដ្ឋបាលការងារទាំងអស់បានតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

បន្ទាប់ពីទទួលបានជោគជ័យនៅក្នុងការអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មបរទេសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យក្រសួងធ្វើការពិចារណា ពង្រីកសមត្ថភាពកម្មវិធីដើម្បីអាចឱ្យបំពេញ នីតិវិធីរដ្ឋបាលដែលពាក់ព័ន្ធការងារទាំងអស់តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

# វិស័យពន្ធដារ

សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា មានក្តីសោមនស្សសូមរាយការណ៍ជូនថាការចូលរួមប្រកបដោយភាពវិជ្ជមានរបស់យើងជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពន្ធដារ (អពដ) បានបន្តដំណើរការពាក់ព័ន្ធនឹងជំពូកស្តីពីពន្ធដារនៃសៀវភៅ ស នេះ។ ជាថ្មីម្តងទៀត តាមរយៈការឆ្លើយតបចំពោះអនុសាសន៍ក្នុងសៀវភៅ ស អគ្គនាយកដ្ឋានពន្ធដារបានផ្តល់នូវសេចក្តីពន្យល់ និងមូលហេតុដ៏សមស្របសម្រាប់គ្រប់ចំណុចនៅក្នុងលិខិតចុះនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ ដែលផ្ញើជូនប្រធានសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា។ កិច្ចសហការក្នុងន័យស្ថាបនានេះបានឈានដល់ចំណុចកំពូលបំផុតនៅក្នុងកម្មវិធីវេទិកាពន្ធដារដ៏ជោគជ័យជាបន្តបន្ទាប់របស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា នៅក្នុងខេត្តសៀមរាប និងរាជធានីភ្នំពេញ ដែលមានអ្នកចូលរួមពីស្ថាប័នផ្សេងៗប្រមាណជាង ៧០០ នាក់។ នៅក្នុងវេទិកានៅរាជធានីភ្នំពេញ ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានសម្តែងនូវការកោតសរសើរចំពោះកិច្ចសន្ទនាបើកចំហដែលសម្របសម្រួលដោយសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ដោយសារតែកិច្ចសន្ទនានេះមានភាពស្របគ្នាជាមួយអាណត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ នៅក្នុងការជំរុញ និងផ្សព្វផ្សាយសារៈសំខាន់នៃវិស័យសារពើពន្ធទៅដល់ក្រុមហ៊ុនសាជីវកម្មនៅកម្ពុជា។

បើនិយាយអំពីវឌ្ឍនភាព យើងបានដកចេញនូវអនុសាសន៍មួយចំនួនពីសៀវភៅ ស ច្បាប់មុន ដោយសារតែបញ្ហាទាំងនេះត្រូវបានដោះស្រាយរួចរាល់អស់ហើយ ឬមានការផ្តល់ហេតុផលសមរម្យពីសំណាក់អគ្គនាយកដ្ឋានពន្ធដារ។ ជាដំបូង សំណើរបស់យើងដែលស្នើឱ្យ អគ្គនាយកដ្ឋានពន្ធដារ ធ្វើការបង្វិលសងអាករលើតម្លៃបន្ថែមទៅដល់ក្រុមហ៊ុនធុរកិច្ចឱ្យបានទាន់ពេលវេលាត្រូវបានបំពេញ បន្ទាប់ពីការចេញនូវប្រកាសលេខ ៥៧៦ និង ៥៧៧។ បទប្បញ្ញត្តិទាំងនេះបានកំណត់ថា ចំពោះសហគ្រាសដែលបានបំពេញកាតព្វកិច្ចពន្ធបានត្រឹមត្រូវ និងបានអនុវត្តទៅតាម

គោលការណ៍ដែលបានកំណត់ គួរតែទទួលបានការសងត្រឡប់នូវអាករលើតម្លៃបន្ថែមនៅក្នុងរយៈពេលប្រមាណ ៤០ ថ្ងៃសម្រាប់វិស័យឯកជន និងរយៈពេល ១៥ ថ្ងៃសម្រាប់វិស័យមិនស្វែងរកប្រាក់ចំណេញ គិតចាប់ពីថ្ងៃដែលបានដាក់សំណើនោះ។ ដើម្បីបំពេញទៅលើចំណុចនេះដូចដែលបានប្រកាសនៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (G-PSF) កាលពីខែមីនា ឆ្នាំ២០១៩ ការបង្វិលសងអាករលើតម្លៃបន្ថែមនឹងត្រូវរៀបចំតាមប្រព័ន្ធអេឡិចត្រូនិកជូនដល់អ្នកជាប់ពន្ធតាមរយៈកម្មវិធីអនឡាញថ្មីដែលនឹងជួយបង្កើនប្រសិទ្ធភាព និង តម្លាភាពនៃដំណើរការនេះបានយ៉ាងធំធេងផងដែរ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានឆ្លើយតបចំពោះតម្រូវការឱ្យមានបទប្បញ្ញត្តិស្ដីពីថ្ងៃផ្ទេរដ៏រឹងមាំដោយមានការអនុវត្តប្រកាសលេខ ៩៨៦។ ប្រកាសដែលបានរៀបចំឡើងដោយមានជំនួយផ្នែកបច្ចេកទេសពីអង្គការសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការសេដ្ឋកិច្ច និងធនាគារពិភពលោក បានលើកឡើងអំពីវិធីសាស្ត្រថ្លៃផ្ទេរ និងនីតិវិធីអនុលោមភាពដែលបានអនុម័ត ហើយរំពឹងថានឹងជួយបង្កើនតម្លាភាព ប្រឆាំងនឹងការបញ្ចៀសពន្ធ និងធ្វើឱ្យប្រព័ន្ធសារពើពន្ធកម្ពុជាកាន់តែមានកម្រិតជិតស្មើនឹងប្រទេសនៅក្នុងតំបន់។ អនុសាសន៍របស់យើងពាក់ព័ន្ធនឹងកាតព្វកិច្ចអាករលើតម្លៃបន្ថែម និងពន្ធកាត់ទុកសម្រាប់ទឹកប្រាក់បង់ជូនអនិវេសនជន ឬសម្រាប់សេវានាំចេញក៏ត្រូវបានទទួលស្គាល់ដោយ អគ្គនាយកដ្ឋានពន្ធដារ ហើយស្ថាប័ននេះក៏បង្ហាញអំពីគោលបំណងក្នុងការចេញសេចក្ដីណែនាំដាក់លាក់ស្ដីពីលក្ខខណ្ឌតម្រូវផ្នែកភស្តុតាងដើម្បីធានាថា ក្រុមហ៊ុនធុរកិច្ចទទួលបានបំណុលពន្ធដែលបានកំណត់ត្រឹមត្រូវ។

អនុសាសន៍ថ្មីៗជាច្រើននៅក្នុងឆ្នាំនេះមានគោលបំណងគាំទ្រដល់ការរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់វិស័យរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញក្រុមហ៊ុនដែលមានការរីកចម្រើន បន្ទាប់ពីមានកំណើនយ៉ាងរឹងមាំដែលកត់ត្រាដោយទីផ្សារមូលបត្រ

កម្ពុជា។ ដោយសារទីផ្សារមូលបត្រនៅក្នុងប្រទេសកម្ពុជានៅតែមានលក្ខណៈថ្មីថ្មោងនៅឡើយ វិស័យនេះនៅតែទាមទារឱ្យមានបទប្បញ្ញត្តិគ្រប់ជ្រុងជ្រោយស្តីពីបញ្ហាស្មុគស្មាញមួយចំនួនពាក់ព័ន្ធនឹងកម្មសិទ្ធិភាគហ៊ុនដើម្បីធានាថា ប្រតិបត្តិការនោះត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ។ ដូច្នេះ យើងបានដាក់បញ្ចូលអនុសាសន៍ចំនួនពីរដើម្បីគូសបញ្ជាក់អំពីផ្នែកដែលសមាជិករបស់យើងសង្កេតឃើញថាមានចន្លោះខ្វះខាតនៅក្នុងបទប្បញ្ញត្តិបច្ចុប្បន្ន។

ទោះបីជាអគ្គនាយកដ្ឋានពន្ធដារ សម្រេចបាននូវវឌ្ឍនភាពយ៉ាងធំធេងនៅក្នុងការរៀបចំជាផ្លូវការនូវរបបសារពើពន្ធរបស់ប្រទេស និងបានបង្កើនប្រាក់ចំណូលរហូតដល់ ២,២ ពាន់លានដុល្លារនៅក្នុងឆ្នាំ២០១៨ ក៏ដោយ ប៉ុន្តែវិធីសាស្ត្រកំពុងប្រើប្រាស់នាបច្ចុប្បន្ន ដើម្បីសម្រេចនូវគោលដៅនេះបានបង្កឱ្យមានការលំបាកមួយចំនួនដល់ក្រុមហ៊ុនដែលបានបំពេញកាតព្វកិច្ចពន្ធបានត្រឹមត្រូវ។

កាលពីពេលថ្មីៗនេះរាជរដ្ឋាភិបាលបានទទួលស្គាល់ការព្រួយបារម្ភទាំងនេះនៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (G-PSF) ហើយបានចេញប្រកាសលេខ ២៧០ ស្តីពីសវនកម្មពន្ធ ដែលលើកឡើងអំពីវិធានការ និងនីតិវិធីក្នុងការលុបបំបាត់ទំនួលខុសត្រូវសនកម្មជាន់គ្នានៅក្នុងអគ្គនាយកដ្ឋានពន្ធដារ។ ប្រកាសនេះបានបន្ថយរយៈពេលកំណត់ពន្ធសម្រាប់ការធ្វើសវនកម្មពេញលេញរហូតដល់បីឆ្នាំ និងកាត់បន្ថយការប្រាក់ប្រចាំខែសម្រាប់ការបង់ពន្ធយឺតយ៉ាវចាប់ពី ២% មកត្រឹម ១,៥%។ វិធានការនេះទទួលបានការស្វាគមន៍យ៉ាងពេញទំហឹង និងបានបង្ហាញអំពីការប្តេជ្ញាចិត្តយ៉ាងមោះមុតរបស់រាជរដ្ឋាភិបាលនៅក្នុងការលើកកម្ពស់បរិយាកាសធុរកិច្ចនៅក្នុងប្រទេសកម្ពុជា។ ដើម្បីបន្តវិធីសាស្ត្រនេះ យើងបាន ផ្តល់អនុសាសន៍ដោយស្នើឱ្យដាក់ចេញនូវផែនការរាយការណ៍ដោយស្មគ្រចិត្តដើម្បីទទួលបានមកវិញនូវការសម្រាលការពិន័យដោយសារវិធានការនេះលើកទឹកចិត្តឱ្យ មានការបំពេញកាតព្វកិច្ចពន្ធកាន់តែល្អប្រសើរថែមទៀត ហើយក៏ជាវិធីសាស្ត្រដែលត្រូវបានអនុវត្តជាទូទៅនៅក្នុងបណ្តាប្រទេសជាច្រើនផ្សេងទៀតផងដែរ។

ជាចុងក្រោយយើងបានផ្ដើបច្ចុប្បន្នភាពអនុសាសន៍លើកមុនចំនួនពីរ បន្ទាប់ពីបានការរៀបចំបទប្បញ្ញត្តិកាលពីពេលថ្មីៗនេះ។ បន្ទាប់ពីការប្រកាសឱ្យប្រើប្រាស់នូវប្រកាសលេខ ៥៩៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅពេលនេះបានទទួលស្គាល់ជាផ្លូវការនូវ ទំនាក់ទំនងរវាងភ្នាក់ងារ និងសហគ្រាសដើម និងបានបញ្ជាក់អំពីកាតព្វកិច្ចពាក់ព័ន្ធនឹងពន្ធ ប៉ុន្តែប្រកាសនេះអនុវត្តសម្រាប់តែទំនាក់ ទំនងមានមូលដ្ឋាននៅកម្ពុជា ហើយបទប្បញ្ញត្តិ នេះហាក់ដូចជាមិនសមស្របសម្រាប់ភ្នាក់ងារទេសចរណ៍ឡើយ។ ដូច្នេះយើងខ្ញុំសូមស្នើឱ្យរាជរដ្ឋា ភិបាល ធ្វើការពិចារណាដាក់ចេញនូវបទប្បញ្ញត្តិស្ដីពីអាករលើតម្លៃបន្ថែមជាក់លាក់តាមវិស័យសម្រាប់ភ្នាក់ងារទេសចរណ៍ដើម្បីធ្វើបញ្ជាំងបានកាន់តែត្រឹមត្រូវអំពីលក្ខណៈធុរកិច្ចនៃភ្នាក់ងារទាំងនោះ។ ស្រដៀងគ្នា នេះដែរយើងខ្ញុំក៏សូមផ្ដល់អនុសាសន៍ឱ្យ ធ្វើការពិចារណាអនុវត្តឡើងវិញនូវការលើកលែងដែលបានអនុវត្តដោយស្វ័យប្រវត្តិសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់(QIP) ដើម្បីកាត់បន្ថយបន្ទុករដ្ឋបាលទៅលើក្រុមហ៊ុនអាជីវកម្មទាំងនេះ ដោយសារបច្ចុប្បន្នគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ត្រូវបានតម្រូវឱ្យដាក់ពាក្យមកអគ្គនាយកដ្ឋានពន្ធដារដាច់ដោយឡែកដើម្បីទទួលការលើកទឹកចិត្តនេះបន្ទាប់ពីបានចេញប្រកាសលេខ ៦៣៨ រួចមក។

១៦

# ការយោងការខាតបង់សារពើពន្ធនៅពេលប្តូរកម្មសិទ្ធិករ

ថ្មី

**ពិពណ៌នាបញ្ហា**

នៅក្នុងដំណាក់កាលផ្សេងៗនៃវដ្តជីវិតរបស់អាជីវកម្ម អាចមានរយៈពេលណាមួយដែលចំណាយសរុបមានចំនួនច្រើនជាងចំណូលសរុប ដែលក្នុងស្ថានភាពនេះសហគ្រាសនឹងដំណើរការទាំងខាតបង់។ ការខាតបង់ទាំងនេះអាចកើតឡើងដោយសារតែមូលហេតុជាច្រើន រួមទាំង ចំណាយខ្ពស់ក្នុងការបើកក្រុមហ៊ុនថ្មី ផ្តល់ទឹកប្រាក់សម្រាប់ផែនការពង្រីកក្រុមហ៊ុន ឬនៅក្នុងករណីដែលក្រុមហ៊ុនប្រឈមនឹងរយៈពេលដែលមានតម្រូវការទាបនៅលើទីផ្សារៗ បន្ទាប់ពីរយៈពេលនេះ មានការទទួលស្គាល់ជាទូទៅថាក្រុមហ៊ុនអាចកាត់កងការខាតបង់នៅក្នុងរយៈពេលនេះជាមួយនឹងប្រាក់ពន្ធត្រូវបង់ក្នុងការិយបរិច្ឆេទ គណនេយ្យអនាគតដើម្បីកម្រិតទំនួលខុសត្រូវបង់ពន្ធរបស់ខ្លួនតែលើប្រាក់ចំណេញសុទ្ធ និងកាត់បន្ថយបំណុលពន្ធសរុប។

នៅក្នុងប្រទេសកម្ពុជា ប្រសិនបើក្រុមហ៊ុនជួបប្រទះនូវការខាតបង់ នោះការខាតបង់នេះអាចបូកយោងដើម្បីផ្តល់ជូនក្រុមហ៊ុននូវការអនុគ្រោះពន្ធក្នុងរយៈពេលរហូតដល់ប្រាំឆ្នាំ។ គោលការណ៍នេះនឹងត្រូវអនុវត្តតែក្នុងករណីដែលក្រុមហ៊ុនអាជីវកម្មមិនទាន់បានផ្លាស់ប្តូរសកម្មភាពអាជីវកម្មរបស់ខ្លួន ហើយការខាតបង់នោះបានកត់ត្រាច្បាស់លាស់នៅក្នុងលិខិតប្រកាសពន្ធ ហើយពុំធ្លាប់ត្រូវបានអគ្គនាយកដ្ឋានពន្ធដារ (អពដ) ចេញការកំណត់ពន្ធដោយឯកតោភាគីទៅលើឆ្នាំដែលមានការខាតបង់នោះតែប៉ុណ្ណោះ។ ជាងនេះទៅទៀត ប្រសិនបើក្រុមហ៊ុនធ្លាប់បានផ្លាស់ប្តូររចនាសម្ព័ន្ធកម្មសិទ្ធិរបស់ខ្លួន ទោះបីការផ្លាស់ប្តូរនោះមានទំហំប៉ុណ្ណាក៏ដោយ ក្រុមហ៊ុននោះនឹងបាត់បង់លទ្ធភាពក្នុងការប្រើប្រាស់ការខាតនេះសម្រាប់កាត់កងជាមួយនឹងចំណូលជាប់ពន្ធក្នុងពេលអនាគត។

សម្រាប់ក្រុមហ៊ុនជាកម្មសិទ្ធិរបស់ក្រុមហ៊ុនឯកត្តជន ឬសហកម្មសិទ្ធិ លក្ខខណ្ឌចុងក្រោយនេះអាចមានលក្ខណៈសមហេតុផលដោយសារការផ្លាស់ប្តូរកម្មសិទ្ធិអាចប៉ះពាល់ទៅដល់សកម្មភាពអាជីវកម្ម។ ប៉ុន្តែ សម្រាប់ក្រុមហ៊ុនធុរកិច្ចដែលជាកម្មសិទ្ធិរបស់ពហុភាគហ៊ុនិក នោះផលវិបាកនៃការផ្លាស់ប្តូរកម្មសិទ្ធិមិនសូវមានភាពច្បាស់លាស់ប៉ុន្មានឡើយ។ នៅក្នុងករណីនេះ ដរាបណាភាគហ៊ុនិកពុំទាន់បានទិញភាគហ៊ុនត្រួតត្រាណាមួយដែលផ្តល់ឱ្យខ្លួននូវចំនួនភាគហ៊ុនលើសលុបលើភាគហ៊ុនិកដទៃទៀតទេ នោះ មានន័យថាពុំមានការផ្លាស់ប្តូរពិតប្រាកដចំពោះរចនាសម្ព័ន្ធកម្មសិទ្ធិសហគ្រាសឡើយ ហើយសកម្មភាពរបស់ក្រុមហ៊ុននេះហាក់ដូចជានៅដដែលដូចពីមុនដូច្នោះដែរ។

អាជ្ញាធរសារពើពន្ធនៅក្នុងប្រទេសជាច្រើនផ្សេងទៀតដូចជា ប្រទេសថៃ ប្រទេសម៉ាឡេស៊ី និងសិង្ហបុរីអនុវត្តប្រព័ន្ធមួយហៅថា ប្រព័ន្ធធ្វើតេស្តភាគហ៊ុនិក (Shareholder Continuity Test) ដើម្បីកំណត់ថាតើក្រុមហ៊ុនដែលមានភាហ៊ុនិកជាម្ចាស់កម្មសិទ្ធិអាចបូកយោងការខាតបង់ពន្ធពីមុនដែរឬទេ ប្រសិនបើមានការផ្លាស់ប្តូរកម្មសិទ្ធិក្រុមហ៊ុន។ ដើម្បីកំណត់

ថាតើការផ្លាស់ប្តូរកម្មសិទ្ធិជាក់ស្តែងបានឡើងដែរឬទេ នោះ ប្រព័ន្ធធ្វើតេស្តភាគហ៊ុនិក (Shareholder Continuity Test) នេះ តម្រូវឱ្យមានការផ្លាស់ប្តូរធំដុំចំពោះកម្មសិទ្ធិដែលជាទូទៅមានចំនួនលើសពី ៤៩% នៃភាគហ៊ុនសរុបដើលមាន។ ក្នុងករណីដែលការផ្លាស់ប្តូរកម្មសិទ្ធិធំជាងចំនួនកំណត់នេះនៅក្នុងរយៈពេលជាក់លាក់ណាមួយ នោះក្រុមហ៊ុននឹងបាត់បង់ពន្ធខាតយោងទាំងស្រុង។

ដោយសាររាជរដ្ឋាភិបាលពុំទាន់បានកំណត់វិសាលភាពដែលខ្លួនគិតថាជាការផ្លាស់ប្តូរកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនបោះភាគហ៊ុន នោះមានភាពមិនច្បាស់លាស់ នៅក្នុងការកំណត់ទៅដែលជាការផ្លាស់ប្តូរកម្មសិទ្ធិពិតប្រាកដនៅក្នុងប្រទេសកម្ពុជា។ ដូច្នេះកត្តានេះបានរឹតត្បិតលទ្ធភាពរបស់ អគ្គនាយកដ្ឋានពន្ធដារ នៅក្នុងការអនុញ្ញាតឱ្យប្តូកខាតយោងរបស់ក្រុមហ៊ុនពីការិយបរិច្ឆេទគណនេយ្យមុនៗ ប្រសិនបើមានភាគហ៊ុនណាមួយត្រូវបានប្តូរម្ចាស់កាន់កាប់នោះ។

## ផលប៉ះពាល់លើកម្ពុជា

ទោះបីប្រាក់ចំណេញត្រូវជាប់ពន្ធនៅពេលទទួលបានក៏ដោយ ប៉ុន្តែក្រុមហ៊ុនអាជីវកម្មពុំទទួលបានសំណងភ្លាមៗឡើយប្រសិនបើខ្លួនទទួលរងនូវការខាតបង់ ដូច្នេះក្រុមហ៊ុនអាជីវកម្មអាចប្រើប្រាស់ការខាតបង់ទាំងនេះដើម្បីកាត់កងប្រាក់ចំណេញអនាគតរបស់ខ្លួនដើម្បីទទួលបានការអនុគ្រោះពន្ធ។ លទ្ធភាព ក្នុងការប្តូកយោងការខាតបង់ពន្ធនេះបង្កើតផលវិជ្ជមានទៅលើការវិនិយោគ តាមរយៈការលើកទឹកចិត្តឱ្យក្រុមហ៊ុនហ៊ានបណ្តាក់ទុនច្រើនជាងមុន ដែលជាទូទៅទទួលបានចំណេញខ្ពស់ជាង ដោយសារហានិភ័យហិរញ្ញវត្ថុរបស់ខ្លួនត្រូវបានកាត់បន្ថយដោយសារតែទឹកប្រាក់ពន្ធត្រូវបង់មានការថយចុះតិចជាងមុនៗ វិធានការនេះមានសារៈសំខាន់ចំពោះក្រុមហ៊ុនដែលតម្រូវឱ្យមានចំណាយច្រើននៅពេលចាប់ផ្តើមដំណើរការ ហើយលទ្ធភាពនៃការខាតបង់មានកម្រិតខ្ពស់ ដូចជា វិស័យកម្មន្តសាលជាដើម ដែលនេះគឺជាចំណុចគន្លឹះសម្រាប់ចីរភាពកំណើនសេដ្ឋកិច្ចកម្ពុជា។ ស្រដៀងគ្នានេះដែរ ការដកចេញនូវការអនុគ្រោះពន្ធចំពោះការខាតបង់ក្នុងករណីមានការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ អាចធ្វើឱ្យក្រុមហ៊ុនមានការរារែកចិត្តនៅក្នុងការបោះទុនវិនិយោគ ដែលកត្តានេះប៉ះពាល់ទៅដល់ផែនការកំណើន និងការបង្កើតការងារសម្រាប់ពលរដ្ឋកម្ពុជាផងដែរ។ ស្ថានភាពនេះនឹងធ្វើឱ្យទីផ្សារមូលបត្រកម្ពុជាមានកំណើនយឺត ដោយសារតែក្រុមហ៊ុនអាចមានភាពស្ទាក់ស្ទើរនៅក្នុងការទទួលយកភាគហ៊ុនិកថ្មី ប្រសិនបើខ្លួនបាត់បង់អត្ថប្រយោជន៍ពន្ធនោះ។ ប្រសិនបើប្រទេសកម្ពុជានៅតែបន្តយកការផ្លាស់ប្តូរកម្មសិទ្ធិធ្វើជាមូលដ្ឋាននៃការបោះបង់ខាតយោងសារពើពន្ធនៅក្នុងចំនួនណាមួយ នោះនឹងមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើសេចក្តីសម្រេចចិត្តរបស់ក្រុមហ៊ុននាពេលអនាគត ព្រមទាំងប៉ះពាល់ទៅដល់សមត្ថភាពប្រកួតប្រជែងរបស់ប្រទេសកម្ពុជាក្នុងនាមជាប្រទេសគោលដៅវិនិយោគដ៏ទាក់ទាញទៀតផង។

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើសូមស្នើឱ្យពិចារណាអនុវត្តប្រព័ន្ធធ្វើតេស្តភាគហ៊ុនិក (Shareholder Continuity Test) ដើម្បីកំណត់វិសាលភាពនៃការផ្លាស់ប្តូរកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនបោះភាគហ៊ុន។

*ដោយទទួលស្គាល់ថា គួរមានការកម្រិតទៅលើលទ្ធភាពក្នុងការកាត់កងការខាតមុនៗជាមួយនឹងប្រាក់ចំណេញអនាគតដើម្បីកាត់បន្ថយការរំលោភបំពាន សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាសូមគោរពជូនអនុសាសន៍ដោយស្នើឱ្យរាជរដ្ឋាភិបាលគួរពិចារណាអនុវត្តប្រព័ន្ធ ធ្វើតេស្តភាគហ៊ុនិក* (Shareholder Continuity Test) *ដើម្បីកំណត់វិសាលភាពនៃការផ្លាស់ប្តូរ កម្មសិទ្ធិនៅក្នុងក្រុមហ៊ុនបោះភាគហ៊ុន។ តាមរយៈវិធានការនេះ អគ្គនាយកដ្ឋានពន្ធដារ នឹងបន្សើយន្តការកំណត់ពន្ធរបស់ខ្លួនជាមួយនឹងវិធីសាស្ត្រដែលអនុវត្តជាទូទៅនៅក្នុងបណ្តាប្រទេសជាច្រើនផ្សេងទៀត។ ដាំងនេះទៅទៀត ដើម្បីកំហិតទៅលើការរំលោភបំពានដែលអាចមាន អគ្គនាយកដ្ឋានពន្ធដារ គួរគណនាការបោះបង់ខាតយោងសារពើពន្ធទៅតាមសមាមាត្រដោយអាស្រ័យទៅលើកម្រិតនៃការប្តូរកម្មសិទ្ធិដែលបានកើតឡើងជាក់ស្តែង។*

១៧

# ពន្ធតែមប្រ៍ទៅលើការបង្កើនដើមទុន

ថ្មី

**ពិពណ៌នាបញ្ហា**

*ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយបានដាក់ចេញនូវបទបញ្ញត្តិដែលកំណត់ឱ្យការផ្ទេរភាគហ៊ុននៅក្នុងក្រុមហ៊ុនកម្ពុជាត្រូវបង់ពន្ធតែមប្រ៍ចំនួន ០,១% នៃតម្លៃភាគហ៊ុន។ ទោះបីការអនុវត្តនេះ ស្របជាមួយបណ្តាប្រទេសជាច្រើនក៏ដោយ ប៉ុន្តែសមាជិករបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាបានឱ្យដឹងថា អគ្គនាយកដ្ឋានពន្ធដារ (អពដ) ក៏បានអនុវត្តពន្ធតែមប្រ៍នេះនៅក្នុងករណីដែលភាគហ៊ុនិកចាស់បានបង្កើនដើមទុនរបស់ខ្លួននៅក្នុងក្រុមហ៊ុនបោះភាគហ៊ុន ដែលភាគហ៊ុនិកដទៃទៀតពុំបានបង្កើនដើមទុនរបស់ខ្លួនក៏ដោយ។*

*កត្តានេះមានន័យថា ទោះបីចំនួនភាគហ៊ុនសរុបរបស់ភាគហ៊ុនិកដែលពុំបានកំណត់ថានឹងបង្កើនដើមទុនក៏ដោយ ក៏អគ្គនាយកដ្ឋានពន្ធដារ បានកំណត់ថាក្នុងករណីដែលភាគរយនៃកម្មសិទ្ធិមានការប្រែប្រួល នោះភាគហ៊ុនិកដែលធ្វើការបង្កើនដើមទុនចាំបាច់ត្រូវបង់ពន្ធតែមប្រ៍ចំនួន ០,១% នៃតម្លៃភាគហ៊ុន។ នៅក្នុងការអនុវត្តជាក់ស្តែងអគ្គនាយកដ្ឋានពន្ធដារ ចាត់ទុកភាគរយនៃការបង្កើនដើមទុនរបស់ភាគហ៊ុនិកម្នាក់ថាជាការផ្លាស់ប្តូរពិតប្រាកដចំពោះកម្មសិទ្ធិរបស់ក្រុមហ៊ុន ជាជាងពិចារណាទៅលើការកាន់កាប់ជាក់ស្តែងរបស់ភាគហ៊ុនិកនីមួយៗ។*

*សូមលើឧទាហរណ៍ខាងក្រោមដើម្បីបង្ហាញអំពីបញ្ហានេះ៖*

*ភាគហ៊ុនិក ក កាន់កាប់ ១០០ ភាគហ៊ុនដែលមានតម្លៃ ១ លានដុល្លារ = កម្មសិទ្ធិ ៥០%*
*ភាគហ៊ុនិក ខ កាន់កាប់ ១០០ ភាគហ៊ុនដែលមានតម្លៃ ១ លានដុល្លារ = កម្មសិទ្ធិ ៥០%*
*ប្រសិនបើភាគហ៊ុនិក ខ បង្កើនដើមទុនរបស់ខ្លួនចំនួន ៥០០.០០០ ដុល្លារ*
*ភាគហ៊ុនិក ក នៅតែកាន់កាប់ ១០០ ភាគហ៊ុនដែលមានតម្លៃ ១ លានដុល្លារ = កម្មសិទ្ធិ ៣៣%*
*ពេលនេះ ភាគហ៊ុនិក ខ កាន់កាប់ ១៥០ ភាគហ៊ុនដែលមានតម្លៃ ១,៥ លានដុល្លារ = ៦៧%*

*នៅក្នុងឧទាហរណ៍នេះ ការបង្កើនដើមទុនរបស់ភាគហ៊ុនិក ខ បានបន្ថយតម្លៃកម្មសិទ្ធិរបស់ភាគហ៊ុនិក ក ដោយសារភាគហ៊ុនថ្មីត្រូវបានចេញដែលអនុញ្ញាតឱ្យភាគហ៊ុនិក ខ មានចំនួនភាគហ៊ុនច្រើនលើសភាគី ក នៅក្នុងក្រុមហ៊ុន។ ទោះជាយ៉ាងនេះក្តី ដោយសារពុំមានការផ្ទេរភាគហ៊ុនពិតប្រាកដរវាងភាគីទាំងពីរ និងដោយសារចំនួនភាគសរុបរបស់ភាគហ៊ុនិក ក ពុំមានការប្រែប្រួល នោះពុំគួរអនុវត្តពន្ធតែមប្រ៍ឡើយ។*

## ផលប៉ះពាល់លើកម្ពុជា

*ការបកស្រាយរបស់អគ្គនាយកដ្ឋានពន្ធដារបានធ្វើឱ្យមានភាពមិនច្បាស់លាស់សម្រាប់អ្នកជាប់ពន្ធដែលបានបំពេញកាតព្វកិច្ចត្រឹមត្រូវ និងបានដាក់បន្ទុកហិរញ្ញវត្ថុបន្ថែមទៅលើភាគហ៊ុនិក ដោយធ្វើឱ្យចំណាយលើអាជីវកម្មរបស់ពួកគេមានការ កើនឡើង។ បើតាមទស្សនៈរបស់វិនិយោគិន ការបកស្រាយនេះគឺជាការដាក់បន្ទុកពន្ធទៅលើវិនិយោគិនដែលកំពុងស្វែងរកឱកាសធ្វើការវិនិយោគនៅក្នុងប្រទេសកម្ពុជា ហើយថែមទាំងអាចធ្វើឱ្យពួកគេមានការរារែកចិត្តនៅក្នុងការបោះទុនវិនិយោគបន្ថែមនៅកម្ពុជា ដោយសារវិធានការនេះពុំបានពិចារណាទៅលើមូលហេតុដែលភាគហ៊ុនិកអាចនឹងបង្កើនដើមទុនរបស់ខ្លួន ដូចជា ដើម្បីផ្តល់មូលនិធិសម្រាប់ផែនការកំណើនដែលនឹងជួយបង្កើតឱកាសការងារថ្មីៗសម្រាប់ប្រជាពលរដ្ឋជាដើម។*

*កាលពីមុន ទីក្រុងហុងកុងក៏បានយក "ពន្ធតែមប្រ៍" ទៅលើក្រុមហ៊ុនដែលបានបង្កើនដើមទុនភាគហ៊ុនរបស់ខ្លួនដែរ ប៉ុន្តែវិធានការនេះត្រូវបានលុបចោលវិញកាលពីឆ្នាំ២០១២ ដើម្បីបង្កើនភាពទាក់ទាញពីវិនិយោគិន និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់ទីក្រុងហុងកុងក្នុងនាមជាមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យមានការទទួលស្គាល់ថាពន្ធតែមប្រ៍មិនគួរអនុវត្តឡើយនៅពេលដែលភាគហ៊ុនិកណាម្នាក់បានបង្កើនដើមទុនតាមរបៀបអសមាមាត្រ ដោយសារតែចំនួនភាគហ៊ុនរបស់ភាគហ៊ុនិកផ្សេងទៀតពុំមានការផ្លាស់ប្តូរកម្មសិទ្ធិឡើយ។

*យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យ អគ្គនាយកដ្ឋានពន្ធដារ ធ្វើការពិចារណាលើការអនុវត្តពន្ធតែមប្រ៍ទៅលើការបង្កើនដើមទុននៅពេលដែលភាគហ៊ុនិកណាម្នាក់បង្កើនដើមទុន ដោយសារតែចំនួនភាគហ៊ុនជាក់ស្តែងរបស់ភាគហ៊ុនិកផ្សេងទៀតពុំមានការប្រែប្រួលឡើយ។ ការធ្វើដូច្នេះ អគ្គនាយកដ្ឋានពន្ធដារ នឹងជួយលើកទឹកចិត្តដល់ការវិនិយោគបន្ថែមទៀតទៅលើធុរកិច្ចកម្ពុជា តាមរយៈការកាត់បន្ថយថ្លៃដើមនៅក្នុងការធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា។*

១៨

# ករណីសម្រាប់ការរាយការណ៍ដោយស្ម័គ្រចិត្ត

ថ្មី

**ពិពណ៌នាបញ្ហា**

*អគ្គនាយកដ្ឋានពន្ធដារ (អពដ) បន្តសម្រេចបានភាពជោគជ័យជាបន្តបន្ទាប់នៅក្នុងដំណើរឆ្ពោះទៅរៀបចំជាផ្លូវការនូវប្រព័ន្ធសារពើពន្ធរបស់ប្រទេសកម្ពុជា ដូចដែលបានបង្ហាញឱ្យឃើញច្បាស់តាមរយៈកំណើនប្រាក់ចំណូលសារពើពន្ធពីមួយឆ្នាំទៅមួយឆ្នាំ ដែលខ្ពស់ជាងកំណើនផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំទៅទៀត។ ទោះបីការរៀបចំជាផ្លូវការនេះមានប្រសិទ្ធភាពនៅក្នុងការលើកកម្ពស់ប្រសិទ្ធភាពរបបពន្ធក៏ដោយ ប៉ុន្តែនៅក្នុងដំណាក់កាលអន្តរកាលនេះ មានក្រុមហ៊ុនធុរកិច្ចជាច្រើនដែលធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជាបានជួបប្រទះនូវបញ្ហាប្រឈមជាច្រើននៅក្នុងការធានាថាកាតព្វកិច្ចពន្ធរបស់ខ្លួនត្រូវបានបំពេញយ៉ាងត្រឹមត្រូវ។*

*បញ្ហាប្រឈមទាំងនេះភាគច្រើនកើតឡើងចំពោះក្រុមហ៊ុនធុរកិច្ចដែលបានដំណើរការចាប់តាំងពីពេលដែលប្រព័ន្ធសារពើពន្ធកម្ពុជានៅពុំទាន់មានរចនាសម្ព័ន្ធរៀបចំច្បាស់លាស់ហើយការអនុវត្តកាតព្វកិច្ចពន្ធពេញលេញ ក៏នៅមិនទាន់មានលក្ខណៈជាប្រព័ន្ធដែរ។ នៅក្នុងរយៈពេលនោះ ក្រុមហ៊ុនធុរកិច្ចជាច្រើនមិនបានដឹង ឬដឹងមិនច្បាស់លាស់ថាខ្លួនអាចមានបញ្ហាបង់ពន្ធមិនគ្រប់ចំនួនតាមការកំណត់ឡើយ ពោលគឺក្រុមហ៊ុនធុរកិច្ចទាំងនេះមិនបានព្យាយាមគេចវេះ មិនព្រមបង់ពន្ធដែលខ្លួនជំពាក់នោះទេ។ ចំណុចនេះសបញ្ជាក់ឱ្យឃើញច្បាស់តាម រយៈការណ៍ដែលក្រុមហ៊ុនធុរកិច្ចជាច្រើនដែលបានដំណើរចាប់តាំងពីពេលដែលការ អនុវត្តច្បាប់នៅមានកម្រិតនោះ បច្ចុប្បន្ននេះកំពុងតែខិតខំប្រឹងប្រែងបំពេញតាម រាល់កាតព្វកិច្ចផ្លូវច្បាប់ជាធរមានទាំងអស់នាពេលបច្ចុប្បន្ន។*

*ដោយពិចារណាទៅលើចំណុចនេះ បច្ចុប្បន្នក្រុមហ៊ុនធុរកិច្ចកំពុងប្រឈមនឹងការកំណត់បំណុលពន្ធឡើងវិញក្នុងចំនួនយ៉ាងច្រើនសន្ធឹកសន្ធាប់ដោយបានគិតចាប់តាំងពីពេលនោះមក។ ក្រុមហ៊ុនដែលបានបង្កើតអស់រយៈពេលជាយូរ បានរកឃើញថាបំណុលពន្ធរបស់ខ្លួនត្រូវបានគិតចាប់តាំងពីមុនពេលដែលការអនុវត្តត្រូវបានកំណត់ជាបទដ្ឋានឆ្ងាយខ្លាំងណាស់ ហើយជាលទ្ធផលក្រុមហ៊ុនទាំងនោះត្រូវបានរកឃើញថាបានបង់ពន្ធខ្វះនៅក្នុងចំនួនយ៉ាងច្រើនលើសលុប។ ម្យ៉ាងវិញទៀត ការប្រាក់ប្រចាំខែបន្ថែម និងប្រាក់ពិន័យពន្ធក៏ត្រូវបានគិតបន្ថែមទៅលើចំនួនប្រាក់ពន្ធដែលបានកំណត់ឡើងវិញនោះផងដែរ ហើយក្រុមហ៊ុនអាជីវកម្មជាច្រើនកំពុងមានការលំបាកក្នុងការខិតខំដោះស្រាយបន្ទុកហិរញ្ញវត្ថុដែលមិនបានរំពឹងទុកនេះ ខណៈដែលក្រុមហ៊ុនទាំងនេះកំពុងព្យាយាមដោះស្រាយបញ្ហាមិនអនុលោមតាមកាតព្វកិច្ចពន្ធរបស់ខ្លួននាពេលកន្លងមក។ ការប្រាក់ប្រចាំខែ និងប្រាក់ពិន័យពន្ធដែលបានអនុវត្តនោះ មានចំនួនយ៉ាងច្រើនលើសលុប ហើយក្នុងករណីខ្លះ ចំនួននេះអាចច្រើនជាងចំនួនប្រាក់ពន្ធដែលបានបង់ខ្វះនោះទៅទៀត។*

*សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ទទួលស្គាល់ថាប្រព័ន្ធសារពើពន្ធដែលមានដំណើរការល្អគឺជាកត្តាដ៏ចាំបាច់សម្រាប់ការកសាងសេដ្ឋកិច្ចឱ្យមានភាពរឹងមាំនិងប្រកបដោយចីរភាព ហើយអត្ថប្រយោជន៍ដែលកើតចេញពីប្រព័ន្ធសារពើ*

*ពន្ធមានប្រសិទ្ធភាពនេះ ក៏អាចកាត់បន្ថយថ្លៃដើមនៅក្នុងការធ្វើអាជីវកម្មផងដែរ។ ប្រសិនបើយើងពិចារណាទៅលើចំណុចនេះ មានទទ្បីករណ៍ដែលអាចបង្ហាញថាក្រុមហ៊ុននានាដែលបានចូលរួមចំណែកយ៉ាងច្រើនបំផុតនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាឱ្យមានការរីកចម្រើនតាមរយៈដំណើរការអាជីវកម្មរបស់ខ្លួននៅក្នុងប្រទេសនេះអស់រយៈពេលជាយូរណាស់មកហើយនោះ ពេលនេះកំពុងតែទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីវិធានការពិន័យសម្រាប់ការមិនអនុលោមតាមកាតព្វកិច្ចពន្ធរបស់ខ្លួនបានត្រឹមត្រូវចាប់តាំងពីពេល ដែលពុំទាន់មានការរឹតបន្តឹងនៅឡើយ។*

*កត្តានេះបានធ្វើឱ្យមានរបាយបន្ទុកពន្ធមិនស្មើភាពគ្នាចំពោះក្រុមហ៊ុនធុរកិច្ចដែលបាន រួមចំណែកនៅក្នុងការបង្កើតឱកាសការងារ ការអភិវឌ្ឍជំនាញ ប្រាក់ចំណូលពន្ធ និងបរិយាកាសធុរកិច្ចវិជ្ជមាននៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ផ្ទុយទៅវិញ ក្រុមហ៊ុនធុរកិច្ចដែលទើបតែបានបង្កើតឡើងស្របពេលដែលមានការរៀបចំប្រព័ន្ធសារពើពន្ធជាផ្លូវការនេះ អាចឈានជើងចូលទៅក្នុងទីផ្សារកម្ពុជា ដោយមានការយល់ដឹងច្បាស់លាស់អំពីកាតព្វកិច្ចផ្លូវច្បាប់ និងកាតព្វកិច្ចពន្ធដែលជាហេតុ ធ្វើឱ្យក្រុមហ៊ុនទាំងនេះមានឱកាសតិចតួចខ្លាំងណាស់ក្នុងការបង់ពន្ធមិនគ្រប់ចំនួន ហើយមិនត្រឹមតែប៉ុណ្ណោះពួកគេថែមទាំងអាចទទួលបានអត្ថប្រយោជន៍ជាច្រើនពីស្ថានភាពដ៏ល្អប្រសើរនាពេលបច្ចុប្បន្ននេះនៅក្នុងប្រទេសកម្ពុជា ទៀតផង។*

*យោងតាមបទពិសោធន៍នៅតាមបណ្តាប្រទេសជាច្រើនផ្សេងទៀត ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធទៅនឹងការមិនអនុលោមកាតព្វកិច្ចពន្ធដែលមានលក្ខណៈស្រដៀងគ្នានេះ រដ្ឋបាលសារពើពន្ធ របស់ប្រទេសទាំងនោះបានផ្តល់ឱកាសឱ្យអ្នកជាប់ពន្ធរាយការណ៍ដោយខ្លួនឯងអំពីការបង់ពន្ធមិនគ្រប់ចំនួនកាលពីពេលមុនៗដើម្បីអាចទទួលបានការសម្រាលការពិន័យប្រាក់ពន្ធ ប្រសិនបើការរាយការណ៍នោះបានធ្វើឡើងនៅមុនពេលទទួលបានការជូនដំណឹងអំពីការធ្វើសវនកម្មពីរដ្ឋបាលសារពើពន្ធ។ វិធានការនេះលើកទឹកចិត្តឱ្យអ្នកជាប់ពន្ធ ដែលមិនបានបំពេញកាតព្វកិច្ចពន្ធបានត្រឹមត្រូវនាពេលកន្លងមកមានឱកាសចេញមកធ្វើការកែតម្រូវបំណុលពន្ធរបស់ខ្លួនទៅតាមស្ថានភាពជាក់លាក់នីមួយៗ។*

*ជាងនេះទៅទៀត វិធានការនេះគឺមិនមែនជារយៈពេលលើកលែងការពិន័យពន្ធនោះទេ ដោយហេតុថាវិធានការនេះមិនមានពេលវេលាកំណត់ឡើយ ហើយអ្នកជាប់ពន្ធដែលរាយការណ៍ដោយស្ម័គ្រចិត្តអំពីបំណុលពន្ធរបស់ខ្លួន នៅតែត្រូវបង់ពន្ធក្នុងបរិមាណច្រើនជាងចំនួនដែលត្រូវបង់ប្រសិនបើបានបំពេញកាតព្វកិច្ចពន្ធបានពេញលេញដដែល ប៉ុន្តែគ្រាន់តែនឹងមិនទទួលរងការពិន័យពន្ធធ្ងន់ធ្ងរដូចជាអ្នកជាប់ពន្ធដែលមិនបានរាយការណ៍អំពីបំណុលពន្ធរបស់ខ្លួន ដែលក្រោយមកត្រូវបានរកឃើញដោយការធ្វើសវនកម្មនោះទេ។ នៅក្នុងតំបន់អាស៊ាន កម្មវិធីរាយការណ៍ដោយស្ម័គ្រចិត្តនេះ កំពុងត្រូវបានអនុវត្តនៅក្នុងប្រទេសសិង្ហបុរី និងម៉ាឡេស៊ី ដែលជាវិធីសាស្រ្តមួយលើកទឹកចិត្តដល់អ្នកជាប់ពន្ធឱ្យកែតម្រូវភាពមិនប្រក្រតី និងប្រមូលចំណូលពន្ធដែលបានបាត់បង់ត្រលប់មកវិញយ៉ាងមានប្រសិទ្ធភាព។ ចំណែកនៅក្នុងប្រទេសឥណ្ឌូនេស៊ីវិញ បន្ទាប់ពីបានផ្តល់រយៈពេលលើកលែងការពិន័យចំនួនប្រាំបួនខែដោយភាពជោគជ័យនៅក្នុងឆ្នាំ២០១៦ មក កម្មវិធីរាយការណ៍ដោយស្ម័គ្រចិត្តនេះក៏ត្រូវបានអនុវត្តរហូតដល់ខែមិថុនា ឆ្នាំ២០១៩ ដោយអនុវត្តការ*

ពិន័យពន្ធក្នុងអត្រាទាបចំពោះអ្នកជាប់ពន្ធដែលបានរាយការណ៍ដោយស្ម័គ្រចិត្ត ផ្ទុយមកវិញចំណែកអ្នកជាប់ពន្ធ ដែលត្រូវបានរកឃើញថាបានបង់ពន្ធមិនគ្រប់ចំនួនតាមរយៈការស៊ើបអង្កេតឡើងវិញ ត្រូវរងការពិន័យពន្ធរហូតទៅដល់ ២០០% នៃចំនួនប្រាក់ពន្ធដែលបានកំណត់ឡើងវិញឯណោះ។

## ផលប៉ះពាល់លើកម្ពុជា

ទោះបីជាអគ្គនាយកដ្ឋានពន្ធដារសម្រេចបាននូវវឌ្ឍនភាពយ៉ាងល្អប្រសើរនៅក្នុងការបង្កើន ចំណូលសាធារណៈ និងការរៀបចំជាផ្លូវការនូវរបបពន្ធរបស់ប្រទេសកម្ពុជាក៏ដោយ ប៉ុន្តែវិធីសាស្ត្រដែលបានប្រើប្រាស់នាពេលនេះអាចជាបន្ទុកយ៉ាងធ្ងន់ធ្ងរទៅលើ ក្រុមហ៊ុនដែលកំពុងព្យាយាមអនុវត្តកាតព្វកិច្ចពន្ធឱ្យបានពេញលេញនៅក្នុងដំណាក់កាលអន្តរកាលនេះ។ ក្រុមហ៊ុនទាំងនេះជាច្រើនបានទទួលស្គាល់ថាខ្លួនអាចបានបង់ពន្ធមិនគ្រប់ចំនួននៅក្នុងរយៈពេលពង្រឹងច្បាប់សារពើពន្ធនេះ និងកំពុងតែចាត់វិធានការដើម្បីទូទាត់បំណុលពន្ធដែលជំពាក់ទាំងនេះ ទោះបីលក្ខខណ្ឌពិន័យតាមរយៈ ការប្រាក់ប្រចាំខែ និងប្រាក់ពិន័យពន្ធកំពុងបង្កផលប៉ះពាល់ធ្ងន់ធ្ងរទៅលើដំណើរការអាជីវកម្មរបស់ខ្លួនក៏ដោយ។

ប្រសិនបើក្រុមហ៊ុនដែលបានបង្កើតអស់រយៈពេលជាច្រើនឆ្នាំមកហើយ ត្រូវបាន តម្រូវឱ្យបង់ពន្ធកំណត់ឡើងវិញដោយមានការប្រាក់ និងប្រាក់ពិន័យបន្ថែម ដែលមានចំនួនយ៉ាងច្រើនខ្លាំងជាងចំនួនដែលខ្លួនបានរំពឹងទុកពីដំបូងនោះ ភាពមិនច្បាស់លាស់នេះអាចធ្វើឱ្យក្រុមហ៊ុនធុរកិច្ចទាំងនេះធ្វើការវាយតម្លៃឡើងវិញទៅលើការវិនិយោគ ឬ សេចក្ដីសម្រេចចិត្តក្នុងការពង្រីកការវិនិយោគរបស់ខ្លួននាពេល អនាគត ឬថែមទាំងអាចធ្វើការវាយតម្លៃឡើងវិញលើទីផ្សារកម្ពុជាទៀតផង។ ជាមួយគ្នានេះដែរ ក្រុមហ៊ុនធុរកិច្ចទាំងនេះទំនងជាលែងសូវមានសមត្ថភាពប្រកួតប្រជែងដូចកាលពីមុន ហើយអាចនឹងត្រូវបង្ខំចិត្តបិទដំណើរការរបស់ខ្លួនទៀតផង ជាលទ្ធផលនឹងធ្វើឱ្យកម្ពុជាបាត់បង់ការងារ និងខាតបង់ប្រាក់ចំណូលពន្ធផងដែរ។ ប្រសិនបើករណីនេះកើតឡើងពិតមែនហេតុការណ៍បែបនេះគឺជារឿងមិនល្អនោះទេ ដោយហេតុថាកម្ពុជានឹងបាត់បង់ក្រុមហ៊ុនធុរកិច្ចដែលមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងការធ្វើអាជីវកម្ម និងដែលមានការយល់ដឹងអំពីទីផ្សារកម្ពុជាច្រើនជាងក្រុមហ៊ុនភាគច្រើនដែលទើបតែឈានជើងចូលក្នុងទីផ្សារនាពេលថ្មីៗនេះ ពីព្រោះថាក្រុមហ៊ុនទាំងនេះនៅតែបន្តដំណើរការអាជីវកម្មរបស់ខ្លួនរហូតមកដល់ពេលបច្ចុប្បន្ន ទោះបីជាកន្លងមកបានជួបប្រទះបញ្ហាប្រឈមជាច្រើននៅក្នុងការចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក៏ដោយ។

ការអនុវត្តកម្មវិធីរាយការណ៍ដោយស្ម័គ្រចិត្តនេះ មិនត្រឹមតែជួយសម្រាលកាតព្វកិច្ចហិរញ្ញវត្ថុ របស់អ្នកជាប់ពន្ធប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយរាជរដ្ឋាភិបាលក្នុងការប្រមូលចំណូលពន្ធ ដែលបានបាត់បង់ត្រឡប់មកវិញ តាមរយៈដំណើរការរដ្ឋបាលដែលប្រើប្រាស់ធនធានតិចជាងការធ្វើសវនកម្មដោយខ្លួនឯង ហើយថែមទាំងអាចបង្កើតឱ្យមានបរិយាកាសស្មើភាពគ្នាសម្រាប់អ្នកជាប់ពន្ធដែលបានបំពេញកាតព្វកិច្ចពន្ធទាំងអស់ផងដែរ។ សម្រាប់កម្ពុជា ការអនុវត្តកម្មវិធីនេះនឹងធ្វើឱ្យអគ្គនាយកដ្ឋានពន្ធដារនៅសល់ធនធានជាច្រើន ដែលអាចយកទៅប្រើប្រាស់ក្នុងការតាមដានឱ្យកាន់តែមានប្រសិទ្ធភាពទៅលើក្រុមហ៊ុនធុរកិច្ចទាំងឡាយណាដែលមានចេតនាគេចវេះកាតព្វកិច្ចពន្ធ។ នៅពេលមានការផ្សព្វផ្សាយទូលំទូលាយឱ្យអ្នកជាប់ពន្ធបានយល់

*ដឹង កម្មវិធីនេះនឹងលើកទឹកចិត្តឱ្យអ្នកជាប់ពន្ធអនុវត្តកាតព្វកិច្ចកាន់តែល្អប្រសើរជាងមុន បង្កើនឆន្ទៈក្នុងការរាយការណ៍អំពីបំណុលពន្ធ និងអាចកាត់បន្ថយការគេចវេះពន្ធជារួមបានទៀតផង ដោយហេតុថាអ្នកជាប់ពន្ធទាំងអស់នឹងយល់ដឹងថា អ្នកជាប់ពន្ធទាំងឡាយណាដែលត្រូវបានរកឃើញថាបានបង់ពន្ធមិនគ្រប់ចំនួន អាចប្រឈមទៅនឹងការពិន័យពន្ធយ៉ាងធ្ងន់ធ្ងរជាក់ជាមិនខាន។*

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យពិចារណាសម្រាលការពិន័យ ចំពោះអ្នកជាប់ពន្ធទាំងឡាយណា ដែលបានរាយការណ៍ដោយស្ម័គ្រចិត្ត អំពីភាពមិនប្រក្រតីនៃការបង់ពន្ធពីមុនរបស់ខ្លួន នៅមុនពេលទទួលបានការជូនដំណឹងអំពីការធ្វើសវនកម្ម។

*ដោយដឹងថាអគ្គនាយកដ្ឋានពន្ធដារក៏បានទទួលស្គាល់អំពីអត្ថប្រយោជន៍នៃការផ្តល់ឱកាសឱ្យអ្នកជាប់ពន្ធអនុវត្តកាតព្វកិច្ចពន្ធតាមរយៈការផ្តល់រយៈពេលអនុគ្រោះដែលស្ថាប័ននេះធ្លាប់បានផ្តល់ជូនវិស័យមួយចំនួនរួចទៅហើយកន្លងនោះ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា សូមផ្តល់ជូនអនុសាសន៍ដោយការគោរពដោយស្នើឱ្យអគ្គនាយកដ្ឋានពន្ធដារធ្វើការពិចារណាអនុវត្តកម្មវិធីរាយការណ៍ដោយស្ម័គ្រចិត្តជាបន្តបន្ទាប់ដើម្បីឱ្យអ្នកជាប់ពន្ធទាំងអស់មានឱកាសកែតម្រូវភាពមិនប្រក្រតីនៃការបង់ពន្ធពីមុនៗរបស់ខ្លួន។ ការអនុវត្តវិធីសាស្ត្រនេះ នឹងឆ្លុះបញ្ចាំងនូវភាពពិតជាក់ស្តែងនៃការអនុវត្តទាន់ពេលវេលាតាមប្រព័ន្ធសារពើពន្ធរបស់ប្រទេសកម្ពុជា និងសូមធ្វើការពិចារណាយោគយល់ចំពោះក្រុមហ៊ុននានាដែលបានបង្កើត និងបានចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំកន្លងមកផងដែរ។*

*រយៈពេលអនុវត្តកម្មវិធីនេះ គួរតែមានវិធីសាស្ត្រមានតុល្យភាពរវាងការផ្តល់ការលើកទឹកចិត្តឱ្យបានគ្រប់គ្រាន់ដើម្បីឱ្យអ្នកជាប់ពន្ធដែលពុំបានបំពេញកាតព្វកិច្ចពន្ធពីមុនចូលខ្លួនមកធ្វើការបង់ពន្ធឱ្យបានត្រឹមត្រូវនៅក្នុងរយៈពេលកំណត់ជាក់លាក់ណាមួយ ហើយទន្ទឹមនឹងនោះ ក៏មិនផ្តល់រង្វាន់ ឬមិនលើកទឹកចិត្តឱ្យមានការអនុវត្តបែបនេះតទៅទៀតចាប់តាំងពីជំហានដំបូងដែរ ហើយវិធីសាស្ត្រនេះក៏គួរតែអនុវត្តចំពោះអ្នកជាប់ពន្ធទាំងអស់ឱ្យបានស្មើភាពគ្នា។ កម្មវិធីនេះនឹងជួយបង្កើនការអនុលោមតាមកាតព្វកិច្ចពន្ធនាពេលអនាគតកាន់តែល្អប្រសើរថែមទៀត ដោយហេតុថាអ្នកជាប់ពន្ធ ដែលពុំបានអនុវត្តកាតព្វកិច្ចពន្ធកាលពីមុននឹងយល់ដឹងកាន់តែច្បាស់លាស់ ហើយទន្ទឹមនឹងនោះ ក៏ពង្រឹងឥរិយាបថអនុលោមតាមកាតព្វកិច្ចពន្ធត្រឹមត្រូវសម្រាប់អ្នកជាប់ពន្ធថ្មីថ្មោង និងអ្នកជាប់ពន្ធដែលបានបំពេញកាតព្វកិច្ចពន្ធត្រឹមត្រូវរួចមកហើយកន្លងមកផងដែរ។*

១៩

# បទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែមពាក់ព័ន្ធនឹងភ្នាក់ងារទេសចរណ៍

**ធ្វើបច្ចុប្បន្នភាព**

---

## អនុសាសន៍ឆ្នាំ ២០១៧

សូមស្នើឱ្យធ្វើការពិចារណាដាក់ចេញនូវបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែមសម្រាប់ភ្នាក់ងារទេសចរណ៍ដែលទទួលស្គាល់ "ទំនាក់ទំនងទីភ្នាក់ងារ" ដើម្បីឆ្លុះបញ្ចាំងឱ្យកាន់តែត្រឹមត្រូវអំពីលក្ខណៈនៃធុរកិច្ចទាំងនេះ។

## ការឆ្លើយតបផ្នែកគោលនយោបាយ

*នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៥៩៧ ដែលចែងអំពីគោលការណ៍ណែនាំសម្រាប់ក្រុមហ៊ុនធុរកិច្ចក្នុងការអនុវត្តតាម ដើម្បីមានទំនាក់ទំនងរបស់ខ្លួនជាភ្នាក់ងារដែលផ្គត់ផ្គង់ទំនិញ និងសេវាកម្ម តាងនាមឱ្យសហគ្រាសដើម ដែលត្រូវបានទទួលស្គាល់ដោយអគ្គនាយកដ្ឋានពន្ធដារ (អពដ) និងគូសបញ្ជាក់អំពីកាតព្វកិច្ចពន្ធពាក់ព័ន្ធរបស់ពួកគេ។ អ្វីដែលសំខាន់គឺថាបទប្បញ្ញត្តិនេះគ្រាន់តែលើកឡើងអំពីវិធាន និងនីតិវិធីពាក់ព័ន្ធនឹងភ្នាក់ងារដែលផ្គត់ផ្គង់ទំនិញ ឬសេវាកម្ម តាងនាមឱ្យសហគ្រាសដើមដែលជានិវេសនជនជាប់ពន្ធកម្ពុជា ហើយពុំបានលើកឡើងអំពីទំនាក់ទំនងរបស់ទីភ្នាក់ងារជាមួយនឹងសហគ្រាសដើមអនិវេសនជន (បរទេស)។ សម្រាប់ភ្នាក់ងារ ដែលធ្វើសកម្មភាពតាងនាមឱ្យអ្នកជាប់ពន្ធនិវេសនជនកម្ពុជា ពួកគេចាំបាច់ត្រូវតែដាក់ពាក្យផ្លូវការជាលាយលក្ខណ៍អក្សរមក អគ្គនាយកដ្ឋានពន្ធដារ ដោយបញ្ជាក់លម្អិតអំពីទំនាក់ទំនងរបស់ខ្លួនដើម្បីទទួលបានលិខិតទទួលស្គាល់ និងរាយការណ៍ឱ្យបានទៀងទាត់អំពីបរិមាណលក់ និងលំហូរនៃភាគហ៊ុន។ ការអនុវត្តនីតិវិធីនេះអនុញ្ញាតឱ្យភ្នាក់ងារជាប់ពន្ធតែលើកម្រៃជើងសារដែលបានទទួលពីការលក់ប៉ុណ្ណោះ ជាជាង ការគិតលើចំនួនសរុបនៅលើវិក្កយបត្រ។*

*សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាទទួលស្គាល់នូវអត្ថប្រយោជន៍ដែលបទប្បញ្ញត្តិនេះបានផ្តល់ភាពស្របច្បាប់ចំពោះទំនាក់ទំនងរបស់ភ្នាក់ងារដែលបំពេញតាមលក្ខខណ្ឌលម្អិត ប៉ុន្តែដោយសារតែបញ្ញត្តិនេះមិនបានអនុញ្ញាតឱ្យភ្នាក់ងារធ្វើ ប្រតិបត្តិការនៅកម្ពុជាតាងនាមឱ្យអនិវេសនជននៃសហគ្រាសដើមនោះទេ ដូចនេះក្រុមហ៊ុនធុរកិច្ចដែលធ្វើប្រតិបត្តិការនៅក្នុងស្ថានភាពទាំងនេះនៅតែប្រឈមនឹងបញ្ហាដដែល ។*

---

## ពិពណ៌នាបញ្ហា

*ភ្នាក់ងារទេសចរណ៍ដើរតួនាទីសំខាន់នៅក្នុងការអភិវឌ្ឍវិស័យទេសចរណ៍របស់ប្រទេសកម្ពុជាតាមរយៈការផ្សព្វផ្សាយអំពីប្រទេសកម្ពុជានៅក្រៅប្រទេស និងការដើរតួជាអន្តរការីរវាងអ្នកផ្តល់សេវាក្នុងស្រុក និងភ្ញៀវបរទេស។ ភ្នាក់ងារទេសចរណ៍រកប្រាក់ចំណេញពីការគិតកម្រៃជើងសារ ឬថ្លៃកក់សេវាលើប្រតិបត្តិការដែលខ្លួនសម្របសម្រួលរវាងអ្នកផ្តល់សេវា និងអ្នកប្រើប្រាស់សេវាចុងក្រោយ។នៅក្នុងករណីភាគច្រើន ភ្ញៀវបង់តម្លៃសរុប (ថ្លៃសេវាបូកនឹងកម្រៃជើងសារ) ទៅឱ្យភ្នាក់ងារទេសចរណ៍ដែលបន្ទាប់មកភ្នាក់ងារទេសចរណ៍បង់ប្រាក់ភាគច្រើនក្នុងចំណោមប្រាក់សរុបនេះទៅឱ្យសណ្ឋាគារ ភោជនីយដ្ឋាន ក្រុមហ៊ុនដឹកជញ្ជូន និងអ្នកផ្តល់សេវាទេសចរណ៍ក្នុងប្រទេសកម្ពុជា។ ដូច្នេះ ភ្នាក់ងារទេសចរណ៍ជាទូទៅមានប្រាក់ចំណូលខ្ពស់ ប៉ុន្តែទទួលបានប្រាក់ចំណេញតិច។*

*នៅក្នុងសហភាពអឺរ៉ុប បន្ទុកអាករលើតម្លៃបន្ថែម (VAT) ចំពោះភ្នាក់ងារទេសចរណ៍ត្រូវបានគណនាទៅតាម "គម្រោងសារពើពន្ធប្រាក់ចំណេញ" ដែលអាករលើតម្លៃបន្ថែម*

*(VAT) ចាំបាច់ត្រូវបង់ដោយគិតទៅលើប្រាក់ចំណេញសរុបជាជាងប្រាក់ចំណូលដែលទទួលបាន។ ប្រទេសនៅតំបន់អាស៊ីមួយចំនួន រួមទាំង ប្រទេសចិន និងប្រទេសឥណ្ឌូនេស៊ី ក៏ទទួលស្គាល់ផងដែរអំពីភាពជាក់លាក់នៃធុរកិច្ចទីភ្នាក់ងារទេសចរណ៍ ហើយបានអនុវត្តបទប្បញ្ញត្តិអាករលើតម្លៃបន្ថែមពិសេសនៅក្នុងវិស័យនេះ។ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជា ភ្នាក់ងារទេសចរណ៍ត្រូវបានតម្រូវឱ្យបង់អាករលើតម្លៃបន្ថែមទៅលើប្រាក់ចំណូលដែលមានផលអវិជ្ជមានដោយជៀសមិនផុតទៅលើភាពចំណេញរបស់ពួកគេ។*

*បញ្ហានេះមានភាពស្មុគស្មាញកាន់តែច្រើន ដោយសារតែអ្នកផ្តល់សេវានៅក្នុងប្រទេសកម្ពុជាជាច្រើនដែលភ្នាក់ងារទេសចរណ៍ទាំងនេះសហការជាមួយ ពុំទាន់បានចុះបញ្ជីពន្ធនៅឡើយនោះ ដែលមានន័យថា ការទូទាត់ដែលបានធ្វើឡើងសម្រាប់សេវារបស់ខ្លួនពុំមានចំណែកនៅក្នុងឥណទានអាករលើធាតុចូលរបស់ភ្នាក់ងារទេសចរណ៍ឡើយ។ ក្រុមហ៊ុនដែលបានបំពេញកាតព្វកិច្ចពន្ធត្រឹមត្រូវទំនងជាទទួលបន្ទុករបស់អ្នកផ្តល់សេវាដែលពុំបានបំពេញកាតព្វកិច្ចពន្ធត្រឹមត្រូវ ដោយសារភាពប្រឈមខ្លាំងក្នុងការកំណត់អ្នកផ្គត់ផ្គង់ទំនិញ និងសេវាដែលបំពេញកាតព្វកិច្ចពន្ធបានត្រឹមត្រូវនៅក្នុងវិស័យមួយចំនួន។*

*សូមពិចារណាទៅលើឧទាហរណ៍ខាងក្រោម ដែលយើងសន្មត់ថា អ្នកផ្តល់សេវាចំនួន ៦០% ដែលភ្នាក់ងារទេសចរណ៍ប្រើប្រាស់សេវាពុំអាចផ្តល់វិក័យប័ត្រជាមួយអាករលើតម្លៃបន្ថែមដែលមានសុពលភាពឡើយ។ លទ្ធផលសុទ្ធគឺគណនីអាករលើតម្លៃបន្ថែមសម្រាប់តួលេខដែលខ្ពស់ខ្លាំងចំនួន ៣៤% នៃប្រាក់ចំណេញសរុបរបស់ប្រតិបត្តិករនេះ។*

| | |
|---|---|
| តម្លៃលក់សរុប | $១.០០០.០០០ |
| តម្លៃដើម | ($៨០០.០០០) |
| ប្រាក់ចំណេញសរុប | ២០០.០០០ |
| ឥណទានអាករតម្លៃបន្ថែមលើធាតុចេញ (១០%) | ($១០០.០០០) |
| ឥណទានអាករតម្លៃបន្ថែមលើធាតុចូល<br>(១០* លើ ៤០%នៃអ្នកផ្គត់ផ្គង់តែប៉ុណ្ណោះ) | ($៣២.០០០) |
| អាករលើតម្លៃបន្ថែមដែលត្រូវបង់ | (៦៨.០០០) |
| អាករលើតម្លៃបន្ថែមដែលត្រូវបង់គិតជា %<br>នៃចំណេញសរុប | ៣៤% |

## ផលប៉ះពាល់លើកម្ពុជា

*នៅក្នុងឧទាហរណ៍ខាងលើនេះ ភ្នាក់ងារទេសចរណ៍ត្រូវរ៉ាប់រងអាករលើតម្លៃបន្ថែមចំនួន ៣៤% នៃប្រាក់ចំណេញសរុបរបស់ខ្លួន ហើយត្រូវបង់ពន្ធលើប្រាក់ចំណេញនិងពន្ធកាត់ទុកជាធម្មតា។ ដូច្នេះភ្នាក់ងារទេសចរណ៍ដែលបំពេញកាតព្វកិច្ចពន្ធបានត្រឹមត្រូវមានការលំបាកខ្លាំងណាស់ក្នុងការបន្តនិរន្តរភាពរបស់ខ្លួនក្នុងប្រទេសកម្ពុជា។*

*បន្ទុកពន្ធធ្ងន់ធ្ងរនេះអាចមានផលអវិជ្ជមានទៅលើប្រាក់ចំណូលពន្ធ ដោយភ្នាក់ងារមួយចំនួនត្រូវបង្ខំចិត្តពិចារណាប្តូរទីតាំងការិយាល័យចុះបញ្ជីរបស់ខ្លួនទៅកាន់ប្រទេសដែលមានបន្ទុកសារពើពន្ធតិច ដូចជាប្រទេសសិង្ហបុរីជាដើម ហើយធ្វើវិក្កយបត្រជូនភ្ញៀវរបស់ខ្លួនពីទីនោះវិញ។ ប្រសិនបើករណីនេះកើតឡើងពិតមែន ប្រទេសកម្ពុជាបានត្រឹមតែប្រមូលអាករលើតម្លៃបន្ថែមដែលភ្នាក់ងារទេសចរណ៍បានបង់ទៅឱ្យអ្នកផ្តល់ទំនិញ និងសេវានិវេសនជនប៉ុណ្ណោះ ចំណែកឯប្រាក់ចំណូលសាធារណៈសរុបពីវិស័យនេះនឹងមានការធ្លាក់ចុះជាក់ជាមិនខាន។*

*ផ្ទុយទៅវិញបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែមដែលបានធ្វើកំណែទម្រង់ពាក់ព័ន្ធនឹង ភ្នាក់ងារទេសចរណ៍ អាចជួយបង្កើនការប្រមូលប្រាក់ចំណូលតាមរយៈការកាត់បន្ថយចំណាយលើអនុលោមភាព ហើយអាចឱ្យភ្នាក់ងារទេសចរណ៍គណនាប្រាក់ចំណូលរបស់ខ្លួនបានកាន់តែត្រឹមត្រូវ។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យធ្វើការពិចារណាដាក់បញ្ចូលបទប្បញ្ញត្តិ ស្តីពីអាករលើតម្លៃបន្ថែមជាក់លាក់តាមវិស័យសម្រាប់ភ្នាក់ងារទេសចរណ៍ ដើម្បីឆ្លុះបញ្ចាំងបានកាន់តែត្រឹមត្រូវអំពីលក្ខណៈនៃធុរកិច្ចទាំងនេះ។

*យោងតាមបទប្បញ្ញត្តិស្រដៀងគ្នានេះនៅក្នុងសហភាពអឺរ៉ុប និងឧទាហរណ៍ពីតំបន់អាស៊ី យើងសូមស្នើឱ្យធ្វើការពិចារណាដាក់ចេញនូវបញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែមជាក់លាក់តាមវិស័យ សម្រាប់ភ្នាក់ងារទេសចរណ៍ដើម្បីឱ្យអាករលើតម្លៃបន្ថែមអាចអនុវត្តទៅតាមគម្រោងសារពើពន្ធចំណេញ ឬកាត់បន្ថយភាគរយនៃប្រាក់ចំណូលដើម្បីឆ្លុះបញ្ចាំងបានកាន់តែត្រឹមត្រូវអំពីលក្ខណៈនៃធុរកិច្ចទាំងនេះ។*

២០

# ការអនុវត្តពន្ធមិនស្មើភាពលើការទូទាត់ប្រាក់បំណាច់អតីតភាពការងារ

ថ្មី

**ពិពណ៌នាបញ្ហា**

*រាជរដ្ឋាភិបាលបានធ្វើវិសោធនកម្មជំពូក ៤ នៃច្បាប់ស្តីពីការងារ (ព្រះរាជក្រឹត្យលេខ ០៦១៨/០១០) កាលពីខែមិថុនា ឆ្នាំ២០១៨ ដើម្បីផ្លាស់ប្តូរប្រាក់បំណាច់បញ្ចប់កិច្ចសន្យាជាមួយនឹងប្រាក់បំណាច់អតីតភាពការងារប្រសិនបើកម្មករនិយោជិតត្រូវបានបញ្ឈប់ពីការងារដោយហេតុផលក្រៅពីកំហុសធ្ងន់ ឬលាឈប់ពីការងារនៅពេលកំពុងបំពេញការងារក្រោមកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC) ។ ប្រកាសលេខ ៤៤៣ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ បានបង្កើតបទប្បញ្ញត្តិវិសោធនកម្មនិងត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨។*

*ចាប់ពីខែមករា ឆ្នាំ២០១៩ មក និយោជកតម្រូវឱ្យផ្តល់ជូនកម្មករនិយោជិតទាំងអស់ដែលកំពុងបម្រើការងារក្រោមកិច្ចសន្យាការងារ មានថិរវេលាមិនកំណត់នូវប្រាក់បំណាច់អតីតភាពការងារដែលស្មើនឹងប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំចំនួន ១៥ ថ្ងៃ ដែលត្រូវទូទាត់ជាពីរដំណាក់កាលសម្រាប់ឆ្នាំនីមួយៗ។ និយោជកក៏តម្រូវឱ្យបើកប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិតតាមលក្ខណៈប្រតិសកម្មផងដែរសម្រាប់រយៈពេលបំពេញការងាររបស់កម្មករនិយោជិតដែលបានបង្គរនៅមុនប្រកាសលេខ៤៤៣ រហូតដល់សរុបចំនួន ១២ ឆ្នាំ ដែលហៅថា ប្រាក់រំពុក។ បន្ទាប់ពីមានកិច្ចពិភាក្សារចរចាជាបន្តបន្ទាប់មក និយោជកនឹងត្រូវទូទាត់ប្រាក់រំពុកអតីតភាពការងាររយៈពេលត្រឹមតែ ៦ ថ្ងៃក្នុងមួយឆ្នាំសម្រាប់ប្រាក់បំណាច់ពីមុនដោយគិតចាប់ពីខែធ្នូ ឆ្នាំ២០២១ សម្រាប់វិស័យផ្សេងក្រៅពីវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ដើម្បីកាត់បន្ថយបន្ទុកហិរញ្ញវត្ថុលើក្រុមហ៊ុនអាជីវកម្ម។*

*នៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនដែលមានសម្តេចនាយករដ្ឋមន្ត្រីជាប្រធានកាលពីខែមីនា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានបញ្ជាក់ថា ការទូទាត់ប្រាក់បំណាច់អតីតភាពការងារទាំងពីរប្រភេទនេះនឹងត្រូវលើកលែងពន្ធ ហើយសហគ្រាសនឹងត្រូវអនុញ្ញាតឱ្យកាត់ចំណាយនៅក្នុងការទូទាត់ប្រាក់ទាំងនេះ។ ទោះបីយ៉ាងណាសារាចរណែនាំលេខ០០៣ ស្តីពីការលើកលែងពន្ធលើប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ និងប្រាក់បំណាច់អតីតភាពការងារចាប់ពីឆ្នាំ២០១៩តទៅមុខ និងសេវារកការងារឱ្យធ្វើ បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករឬកម្មសិក្សាការីទៅធ្វើការនៅបរទេស ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩ បានកំណត់ថា ការលើកលែងពន្ធនឹងត្រូវអនុវត្តសម្រាប់តែការទូទាត់ ដែលផ្តល់ជូនកម្មករនិយោជិត ជាជនជាតិខ្មែរតែប៉ុណ្ណោះ ចំណែកកម្មករនិយោជិតបរទេសត្រូវតែរ៉ាប់រងបន្ទុកពន្ធសម្រាប់ប្រាក់ទូទាត់របស់ខ្លួន។*

*យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីការងារ មិនមានចែងអំពីភាពខុសគ្នារវាងសិទ្ធិរបស់ជនជាតិខ្មែរ និងជនជាតិបរទេសនោះទេ ដូចមានចែងនៅក្នុងមាត្រា១២ នៃច្បាប់ស្តីពីការងារបានចែងថា និយោជកត្រូវអនុវត្តនិងផ្តល់អត្ថប្រយោជន៍សង្គមដូចៗគ្នាជូនដល់កម្មករនិយោជិតទាំងអស់ដោយគ្មាន*

*ការរើសអើងឡើយ។ ដោយសារប្រាក់បំណាច់អតីតភាពការងារ បានជំនួសប្រាក់បំណាច់បញ្ចប់កិច្ចសន្យានៅក្នុងការច្បាប់ស្តីពីការងារ ខ្លឹមសារនៃការទូទាត់ទាំងនេះនៅតែដូចគ្នា ដោយសារការទូទាត់ប្រាក់ទាំងពីរប្រភេទនេះ គឺដើម្បីលើកកម្ពស់ជីវភាព និងលក្ខខណ្ឌការងាររបស់កម្មករនិយោជិតទាំងអស់ នៅពេលត្រូវបានបញ្ឈប់ពីការងារដោយហេតុផលក្រៅពីកំហុសធ្ងន់ និងលាឈប់ពីការងារ។*

*ដោយពិចារណាទៅលើចំណុចនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំលេខ០១១ កាលពីខែតុលា ឆ្នាំ២០១៦ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែម ដែលចែងថា "... ប្រាក់ឧបត្ថម្ភមួយចំនួនដែលកម្មករនិយោជិតទទួលបានពីការបំពេញការងារត្រូវបានអនុគ្រោះដោយមិនគិតបញ្ចូលទៅក្នុង មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស និងមិនមែនជាកម្មវត្ថុនៃពន្ធលើអត្ថប្រយោជន៍បន្ថែមទេ។ ប្រាក់ឧបត្ថម្ភទាំងនោះមានដូចខាងក្រោម៖...៦. ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ឬប្រាក់បំណាច់បញ្ឈប់លែងឱ្យធ្វើការក្នុងកម្រិតដែលបានបញ្ញត្តិក្នុងច្បាប់ការងារ។"*

## ផលប៉ះពាល់លើកម្ពុជា

*ការអនុវត្តមិនស្មើភាព មកលើកម្មករនិយោជិតបរទេស ប៉ះពាល់ជាអវិជ្ជមានទៅលើសមត្ថភាពប្រកួតប្រជែង និងភាពទាក់ទាញរបស់ប្រទេសកម្ពុជានៅក្នុងការជ្រើសរើសអ្នកឯកទេស និងវិនិយោគបរទេស ហើយអាចមានភាពមិនស៊ីសង្វាក់ទៅនឹងការប្តេជ្ញាចិត្តជាអន្តរជាតិរបស់ប្រទេសកម្ពុជា។ នៅពេលការអនុវត្តមិនស្មើភាពត្រូវបានបង្ហាញតាមរយៈការកំណត់ឱ្យអនុវត្តលក្ខណៈប្រតិសកម្មនូវប្រាក់បំណាច់អតីតភាពការងារ នោះភាពជឿជាក់ និងរូបភាពរបស់ប្រទេសកម្ពុជា ក្នុងនាមជាគោលដៅវិនិយោគដែលយកចិត្តទុកដាក់ចំពោះធុរកិច្ច និងគ្មានការរើសអើងនឹងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យកែសម្រួលឡើងវិញ នូវសារាចរណែនាំលេខ ០០៣ សហវ ដើម្បីដកចេញនូវលក្ខខណ្ឌសញ្ជាតិខ្មែរ ដើម្បីធានាឱ្យមានការអនុវត្តពន្ធដោយស្មើភាព នៃប្រាក់បំណាច់អតីតភាពការងារ ។

*យើងខ្ញុំសូមគោរពផ្តល់ជូនអនុសាសន៍ឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មេត្តាធ្វើការកែសម្រួលសេចក្តីណែនាំលេខ០០៣ សហវ ស្តីពីការលើកលែងពន្ធលើប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ និងប្រាក់បំណាច់អតីតភាពការងារចាប់ពីឆ្នាំ២០១៩តទៅមុខ និងសេវារកការងារឱ្យធ្វើ បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករ ឬកម្មសិក្សាការីទៅធ្វើការនៅបរទេស ដើម្បីដកចេញ នូវលក្ខខណ្ឌសញ្ជាតិខ្មែរដើម្បីឱ្យអាចលើកលែងពន្ធប្រាក់ទូទាត់សម្រាប់សញ្ជាតិបរទេស។ ការដកចេញនេះនឹងធានាឱ្យមានការអនុវត្តដោយស្មើភាព និងគ្មានការរើសអើងសម្រាប់កម្មករនិយោជិតតាមកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ស្របទៅតាមសេចក្តីប្រកាសរបស់សម្តេចនាយករដ្ឋមន្ត្រីនៅក្នុងវេទិកាពរដ្ឋាភិបាល-ផ្នែកឯកជន និងការអនុវត្តពន្ធពីមុនៗទៅលើប្រាក់បំណាច់បញ្ចប់កិច្ចសន្យាដែលត្រូវជំនួសដោយប្រាក់បំណាច់អតីតភាពការងារ។*

២១

# ការលើកទឹកចិត្តសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

ធ្វើបច្ចុប្បន្នភាព

---

### អនុសាសន៍ឆ្នាំ ២០១៧

សូមស្នើឱ្យធ្វើការពិចារណាកែសម្រួលការលើកទឹកចិត្តសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់ប្រទេសកម្ពុជា ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណេញដើម្បីផ្តល់ឧត្តមភាពប្រកួតប្រជែងផ្នែកពន្ធឱ្យកាន់តែល្អប្រសើរថែមទៀតដល់វិនិយោគិន។

### ការឆ្លើយតបផ្នែកគោលនយោបាយ

*តាមរយៈការឆ្លើយឆ្លងកន្លងមកជាមួយនឹងសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា អគ្គនាយកដ្ឋានពន្ធដារបានសង្កត់ធ្ងន់ថា "យន្តការដកយកវិញ" លើកាតលាភដូចមានចែងនៅក្នុងមាត្រា ២៣ នៃច្បាប់ស្តីពីសារពើពន្ធ មានគោលដៅជំរុញលើកទឹកចិត្តឱ្យគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) យកផលចំណូលដែលខ្លួនទទួលបានទៅធ្វើការវិនិយោគបន្ថែមទៀតលើមុខជំនួញនានានៅក្នុងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកំពុងរៀបចំធ្វើបច្ចុប្បន្នភាពច្បាប់ស្តីពីការវិនិយោគដើម្បីឆ្លុះបញ្ចាំងកាន់តែច្បាស់លាស់អំពីមហិច្ឆតាកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ហើយបានប្តេជ្ញាពិនិត្យបញ្ចប់ច្បាប់ថ្មីនេះនៅត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០១៩។ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា កំពុងទន្ទឹងរង់ចាំច្បាប់បច្ចុប្បន្នភាពថ្មី ជាពិសេសពាក់ព័ន្ធនឹងការកែសម្រួលការលើកទឹកចិត្តដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ដើម្បីផ្តល់ឧត្តមភាពប្រកួតប្រជែងផ្នែកពន្ធឱ្យកាន់តែល្អប្រសើរដល់វិនិយោគិន។ ក្រៅពីនេះ ដូចដែលបានស្នើឡើងនៅក្នុងជំពូកស្តីពីកិច្ចការពារការវិនិយោគ យើងក៏បានស្នើឱ្យធ្វើការពិចារណាមាត្រា ២៣ ឡើងវិញដើម្បីឱ្យស្របទៅនឹងច្បាប់ស្តីពីការវិនិយោគថ្មីផងដែរ។*

---

**ពិពណ៌នាបញ្ហា**

*ច្បាប់ស្តីពីការវិនិយោគរបស់ប្រទេសកម្ពុជា (ឆ្នាំ១៩៩៤) ព្រមទាំងអនុក្រឹត្យ និងវិសោធនកម្មច្បាប់ស្តីពីការអនុវត្តជាបន្តបន្ទាប់អាចឱ្យក្រុមហ៊ុនអនុវត្តតាមដើម្បីឱ្យគម្រោងវិនិយោគរបស់ខ្លួនមានការទទួលស្គាល់ថាជា "គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" (QIP) ដែលផ្តល់នូវការលើកទឹកចិត្តជាច្រើន ដូចជា ការអនុគ្រោះពន្ធ និងនីតិវិធីរដ្ឋបាលឆាប់រហ័សជាដើម។ ការលើកទឹកចិត្តនេះមានទាំងការលើកលែងពីកាតព្វកិច្ចពន្ធអប្បបរមា ១% លើផលរបរប្រចាំឆ្នាំរបស់ខ្លួន ដែលគ្រប់ក្រុមហ៊ុនធុរកិច្ចទាំងអស់នៅក្នុងប្រទេសកម្ពុជាពីមុនត្រូវបង់ ប្រសិនបើចំនួនទឹកប្រាក់នោះមានចំនួនលើសពីចំនួនប្រាក់ពន្ធលើប្រាក់ចំណេញដែលត្រូវបង់សម្រាប់ឆ្នាំសារពើពន្ធនោះ ឬប្រសិនបើមុខជំនួញមានការខាតបង់។*

*នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៦៣៨ ស្តីពីលក្ខណៈវិនិច្ឆ័យនៃបញ្ជីគណនេយ្យមិនត្រឹមត្រូវ និងនីតិវិធីបង់ពន្ធអប្បបរមា។ ប្រកាសនេះបានពង្រីកការលើកលែងការអនុវត្តកាតព្វកិច្ចបង់ពន្ធអប្បបរមា ១% ទៅដល់គ្រប់ក្រុមហ៊ុនធុរកិច្ចទាំងអស់ដែលអនុវត្តតាមលក្ខខណ្ឌផ្តល់របាយការណ៍ដែលបានកំណត់ និងដែលបានដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរនៅអគ្គនាយកដ្ឋានពន្ធដារ (អពដ)។ ការផ្សព្វផ្សាយប្រកាសលេខ ៦៣៨ ត្រូវបានធ្វើឡើងបន្ទាប់ពីវិសោធនកម្មមាត្រា ២៤ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧*

*ដែលបានដាក់ពន្ធអប្បបរមា ១% ជាការពិន័យសម្រាប់ក្រុមហ៊ុនធុរកិច្ចដែលមិនបានរក្សាបញ្ជីគណនេយ្យបានត្រឹមត្រូវ។*

*ប្រកាសលេខ ៦៣៨ កំណត់បញ្ជីគណនេយ្យមិនត្រឹមត្រូវថាជាសហគ្រាសដែលមិនបានចេញវិក្កយបត្រដោយស្របតាមច្បាប់ស្តីពីសារពើពន្ធ មានការឆ្វេសប្រហែសធ្ងន់ធ្ងរ ឬដែលត្រូវបានរកឃើញថា បានចូលរួមនៅក្នុងការគេចពន្ធ។ ជាងនេះទៅទៀត សហគ្រាស ដែលមានផលរបរប្រចាំឆ្នាំលើសពី ២០០០ លានរៀល (៥០០០០០ ដុល្លារអាមេរិក) ទ្រព្យសកម្ម ៣០០០ លានរៀល (៧៥០០០០ ដុល្លារអាមេរិក) ឬបុគ្គលិកលើសពី ១០០ នាក់ ត្រូវផ្តល់របាយការណ៍សវនកម្មពីសវនករឯករាជ្យ។*

*ដើម្បីទទួលបានការលើកលែងពន្ធអប្បបរមានេះ អ្នកជាប់ពន្ធត្រូវដាក់បញ្ជីគណនេយ្យរបស់ខ្លួន ជូនគណៈកម្មាធិការដែលបានបង្កើតដោយអពជ ធ្វើការត្រួតពិនិត្យ ហើយគណៈកម្មាធិការនេះនឹងធ្វើការវាយតម្លៃលើកំណត់ត្រាដោយធៀបទៅនឹងលក្ខណៈវិនិច្ឆ័យខាងលើនៅរៀងរាល់ពីរឆ្នាំម្តង។ នៅពេលទទួលបានការជូនដំណឹងអំពីលទ្ធផលរបស់គណៈកម្មាធិការត្រួតពិនិត្យ អ្នកជាប់ពន្ធអាចធ្វើសំណើឱ្យ អពជ ធ្វើការពិនិត្យមើលលទ្ធផលវាយតម្លៃរបស់គណៈកម្មាធិការបាន ប្រសិនបើអ្នកជាប់ពន្ធនោះមិនយល់ស្របទៅនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការនេះ។*

*នៅមុនពេលចេញសេចក្តីប្រកាសនេះ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) គឺ ជាសហគ្រាសតែមួយគត់ដែលមានសិទ្ធិទទួលបានតែការលើកលែងពន្ធអប្បបរមា។ ទោះជាយ៉ាងនេះក្តី សិទ្ធិនេះលែងអនុវត្តជាស្វ័យប្រវត្តិទៀតហើយ ហើយនៅពេលនេះ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ចាំបាច់ត្រូវតែបំពេញនីតិវិធីដាក់ពាក្យស្នើសុំដូចគ្នាទៅនឹងអង្គភាពផ្សេងទៀតដែរ ហើយចាំបាច់ត្រូវមានការអនុម័តពី អពជ។*

*កត្តានេះបង្កឱ្យមានភាពមិនច្បាស់លាស់ដោយសារតែក្រុមហ៊ុនគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ត្រូវបានកំណត់ឱ្យអនុវត្តស្តង់ដារគណនេយ្យខ្ពស់ជាងក្រុមហ៊ុនធុរកិច្ចផ្សេងៗទៀតរួចជាស្រេចទៅហើយ និងត្រូវរក្សាបញ្ជីហិរញ្ញវត្ថុយ៉ាងម៉ត់ចត់ដែលត្រូវបានធ្វើសវនកម្មជារៀងរាល់ឆ្នាំដោយសវនករឯករាជ្យដើម្បីរក្សាតំណែងជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) និងទទួលការលើកទឹកចិត្ត។ ស្រដៀងគ្នានេះដែរ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (កអក) គួរដើរតួជា "ការិយាល័យច្រកចេញចូលតែមួយ" សម្រាប់វិនិយោគិនដោយស្នើសុំរាល់ការអនុញ្ញាត និងសិទ្ធិតាងនាមឱ្យគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ដើម្បីជួយសម្រួលដល់ដំណើរការ និងលើកទឹកចិត្តឱ្យធ្វើការវិនិយោគបន្ថែមទៀត ទោះបីជាដំណើរការនេះហាក់ដូចជាលែងមានភាពត្រឹមត្រូវក៏ដោយក្តី។ ជាលទ្ធផល ការចេញប្រកាសលេខ ៦៣៨ បានបង្កើតឱ្យមានបន្ទុករដ្ឋបាលមិនចាំបាច់ថ្មីសម្រាប់ក្រុមហ៊ុនគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ដែលត្រូវបានពិនិត្យយ៉ាងម៉ត់ចត់រួចទៅហើយពាក់ព័ន្ធនឹងការអនុវត្តទៅតាមនីតិវិធីហិរញ្ញវត្ថុ។*

### ផលប៉ះពាល់លើកម្ពុជា

*ភាពមិនច្បាស់លាស់នេះអាចបង្កើតឱ្យមានហានិភ័យផ្នែកបទប្បញ្ញត្តិសម្រាប់ក្រុមហ៊ុន ដោយសារតែក្រុមហ៊ុនទាំងនេះមិនអាចដឹងច្បាស់ថាតើក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានឹងបន្តធ្វើជាអាជ្ញាធរនាំមុខសម្រាប់ដំណើរការអនុម័តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) និងថាតើការលើកទឹកចិត្តដែលបានអនុវត្តនឹងនៅតែបន្តដែរឬទេនាពេលអនាគត។ កត្តានេះនឹងបណ្តាលឱ្យមានកម្រិតវិនិយោគទាបជាងមុនពីសំណាក់ក្រុមហ៊ុនដែលចាប់អារម្មណ៍នៅក្នុងការបង្កើតគម្រោងដែលមានផលប្រយោជន៍ជាតិសំខាន់ៗក្នុងប្រទេសកម្ពុជា។ ស្រដៀងគ្នានេះដែរ នៅក្នុងករណីដែលពន្ធអប្បបរមាត្រូវបានអនុវត្ត (ទឹកប្រាក់លើសពីចំនួនពន្ធលើប្រាក់ចំណេញ ឬប្រសិនបើមុខជំនួញមានការខាតបង់) នោះនឹងធ្វើឱ្យចំណាយធុរកិច្ចមានការកើនឡើងខ្លាំងសម្រាប់ក្រុមហ៊ុន QIP ដោយសារគម្រោងធំៗដែលមានទំហំចាំបាច់សម្រាប់ ទទួលបានការអនុម័តជា QIP តែងតែត្រូវចំណាយពេលយូរដើម្បីទទួលបានប្រាក់ចំណេញ។ បច្ចុប្បន្ននេះ មានភាពមិនច្បាស់លាស់ថាតើពន្ធនេះអាចអនុវត្តយ៉ាងដូចម្តេចចំពោះ QIP ដោយសារតែក្រុមហ៊ុនទាំងនេះមានជម្រើសក្នុងការជ្រើសរើសការរួចពន្ធលើប្រាក់ចំណេញ ឬការរំលស់ពិសេសជាការលើកទឹកចិត្តមួយទៀតដើម្បីលើកទឹកចិត្តដល់ការវិនិយោគ។*

*ដោយសារតែប្រទេសកម្ពុជាកំពុងធ្វើអន្តរកាលឆ្ពោះទៅក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប ហើយឧត្តមភាពប្រកួតប្រជែងដែលផ្តល់ជូនតាមរយៈការលើកលែងពន្ធពីទីផ្សារធំៗ ដូចជា ទីផ្សារអឺរ៉ុប និងសហរដ្ឋអាមេរិកចាប់ផ្តើមមានការថមថយមិនដូចមុន ប្រទេសកម្ពុជាចាំបាច់ត្រូវតែធានាថាខ្លួននៅមានសមត្ថភាពប្រកួតប្រជែងជាមួយនឹងបណ្តាប្រទេសនៅក្នុងតំបន់អាស៊ាន និងតំបន់ផ្សេងៗទៀតដើម្បីធ្វើការទាក់ទាញវិនិយោគបរទេសកាន់តែល្អប្រសើរថែមទៀត។*

### អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យធ្វើការពិចារណាដាក់ឱ្យអនុវត្តឡើងវិញនូវការលើកលែងពន្ធអប្បបរមាដោយស្វ័យប្រវត្តិសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងរយៈពេលលើកលែងពន្ធរបស់ខ្លួន។

*សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ទទួលស្គាល់ថាសេចក្តីសម្រេចក្នុងការលើកលែងក្រុមហ៊ុនធុរកិច្ចពីការបង់ពន្ធអប្បរមាមានការប៉ះពាល់ទៅដល់ប្រាក់ចំណូលរបស់ អពដ ហើយយើងសូមស្វាគមន៍ចំពោះសេចក្តីសម្រេចនេះថាជាគំនិតផ្តួចផ្តើមផ្តល់រង្វាន់លើកទឹកចិត្តដល់ក្រុមហ៊ុនធុរកិច្ចដែលបំពេញកាតព្វកិច្ចពន្ធបានត្រឹមត្រូវ និងលើកទឹកចិត្តដល់ក្រុមហ៊ុនផ្សេងទៀតឱ្យរក្សាបញ្ជីគណនេយ្យបានត្រឹមត្រូវ ដោយសារនេះគឺជាជំហ៊ានដ៏សំខាន់មួយទៀតនៅក្នុងការរៀបចំជាផ្លូវការ នូវប្រព័ន្ធសារពើពន្ធរបស់ប្រទេស*

កម្ពុជា។ ដោយពិចារណាទៅលើចំណុចនេះ ការចេញប្រកាសលេខ ៦៣៨ បានបង្កើតឱ្យមានភាពមិនច្បាស់លាស់ដោយជៀសមិនផុតចំពោះក្រុមហ៊ុនដែលខិតខំបង្កើត QIP ហើយបានដកចេញនូវការលើកទឹកចិត្តដែលធ្លាប់តែត្រូវបានអនុវត្តដោយស្វ័យប្រវត្តិកាលពីពេលមុន។ ដូច្នេះ យើងសូមខ្ញុំសូមគោរពផ្តល់ជូនអនុសាសន៍ដោយស្នើឱ្យរាជរដ្ឋាភិបាលធ្វើការពិចារណាដាក់ឱ្យអនុវត្តឡើងវិញនូវការលើកលែងដោយស្វ័យប្រវត្តិពីការបង់ពន្ធអប្បបរមាសម្រាប់ QIP នៅក្នុងរយៈពេលលើកលែងពន្ធ។

ជាងនេះទៅទៀត ដើម្បីឱ្យ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាចដើរតួជា "ការិយាល័យច្រកចេញចូលតែមួយ" យ៉ាងពិតប្រាកដបានសម្រាប់គម្រោងវិនិយោគបរទេសធំៗ វិនិយោគិនត្រូវការ ការធានាមួយថាដំណើរការអនុម័តនឹងនៅតែស្ថិតក្រោមសិទ្ធិអំណាចរបស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយពុំចាំបាច់មានការកំណត់លក្ខខណ្ឌបន្ថែមពីសំណាក់ក្រសួងផ្សេងៗទៀតដោយមិនមានការណែនាំជាមុនឡើយ។

# វិស័យគយ ការដឹកជញ្ជូន និងភ័ស្តុភារ

នៅក្នុងបរិបទដែលមានការគំរាមកំហែងខាងក្រៅមកលើស្ថានភាពនៃកិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មរបស់កម្ពុជា រាជរដ្ឋាភិបាលបានប្រកាសអនុវត្តកម្មវិធីកំណែទម្រង់រចនាសម្ព័ន្ធនៅកាលពីខែមករា ឆ្នាំ២០១៩ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការសម្រួលពាណិជ្ជកម្ម និងបង្កើនសមត្ថភាពប្រកួតប្រជែងក្នុងការនាំចេញរបស់កម្ពុជា។ កំណែទម្រង់ទាំងនេះត្រូវបានបញ្ជាក់នៅក្នុង វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (G-PSF) ដែលបានប្រព្រឹត្តទៅនៅខែមីនា ឆ្នាំ២០១៩ ដោយមានសម្តេចនាយករដ្ឋមន្ត្រីជាប្រធាន និងមានគោលបំណងកាត់បន្ថយថ្លៃចំណាយនៃការធ្វើធុរកិច្ចដើម្បីធ្វើការប៉ះប៉ូវជាមួយនឹងការអនុវត្តការយកពន្ធនាំចេញឡើងវិញនេះ។ស្របគ្នានេះដែរ វិស័យឯកជនក៏បានសម្តែងការស្វាគមន៍យ៉ាង ពេញទំហឹងចំពោះវិធានការនេះដែរ ហើយប្រសិនបើវិធានការនេះអនុវត្តបានប្រកបភាពជោគជ័យ នោះនឹងអាចដោះស្រាយបញ្ហាជាច្រើនដែលបានលើកឡើងដោយគណៈកម្មាធិការដឹកជញ្ជូន និងភ័ស្តុភាររបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា នៅផ្នែកខាងដើមនៃនៅក្នុងសៀវភៅ ស របស់យើងនេះ។ដោយស្របតាមអនុសាសន៍លើកមុនរបស់យើង រាជរដ្ឋាភិបាលបានរំលាយចោលនូវទីភ្នាក់ងារកម្ពុជានាវាចរ (កាំសាប) ដែលជាស្ថាប័នរដ្ឋមានសិទ្ធិផ្តាច់មុខលើសេវាទីភ្នាក់ងារដឹកជញ្ជូនផ្នែកនាវាចរ ដែលបានចូលជាធរមាន ចាប់ពីថ្ងៃទី២៨ ខែ កុម្ភៈ ឆ្នាំ២០១៩ កន្លងទៅនេះ។ ការរំលាយចោលកាំសាបនេះនឹងជំរុញឱ្យមានការប្រកួតប្រជែងកាន់តែប្រសើរឡើងក្នុងវិស័យភ័ស្តុភារ ដោយបានដកចេញនូវបន្ទុកមិនចាំបាច់ដែលនាំឱ្យមានការកែលម្អលើគុណភាពសេវាកម្ម និងតម្លៃជាប្រាក់។ បន្ថែមពីនេះទៅទៀត អគ្គនាយកដ្ឋានត្រួតពិនិត្យទំនិញ នីហរណ៍-អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្មកម្ពុជា ត្រូវបានដកភារកិច្ចចេញពីប៉ុស្តិ៍ត្រួតពិនិត្យតាមព្រំដែនកំពង់ផែសមុទ្រ តំបន់សេដ្ឋកិច្ចពិសេសទាំងអស់ និងតំបន់ត្រួតពិនិត្យផ្សេងទៀត។ ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ នឹងក្លាយជាស្ថាប័នតែ

មួយគត់ដែលទទួលបានការអនុញ្ញាតឱ្យធ្វើការត្រួតពិនិត្យទំនិញនៅច្រកចូលមកកាន់ប្រទេសកម្ពុជា។ សេចក្ដីសម្រេចនេះនឹងជួយក្រុមហ៊ុនធុរកិច្ច កាត់បន្ថយការចំណាយជាច្រើន ដោយសារការតែថ្លៃសេវាលើការត្រួតពិនិត្យនេះប្រមូលបានជិត ៣០ លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗ។ នៅពេលរួមបញ្ចូលជាមួយវិធានការកំណែទម្រង់ដែលបានលើកឡើងខាងដើមនេះដើម្បីលុបបំបាត់ថ្លៃសេវាគ្រប់គ្រងការនាំចេញ និងលក្ខខណ្ឌតម្រូវសុំវិញ្ញាបនបត្រដើមកំណើតទំនិញសម្រាប់ប្រទេសមួយចំនួន ក្រសួងពាណិជ្ជកម្ម ប៉ាន់ស្មានថា មានការបាត់បង់ចំណូលប្រចាំឆ្នាំរបស់ខ្លួនប្រមាណជា៦០លានដុល្លារអាមេរិក។

អនុសាសន៍របស់យើងអំពីថ្លៃសេវាផ្លូវការសម្រាប់នីតិវិធីគយដែលធ្វើនៅក្រៅម៉ោងការងារធម្មតា និងក្រៅកន្លែងធ្វើការ ត្រូវបានដោះស្រាយស្របគ្នាទៅនឹងប្រកាសលេខ ១៦០៨ ដែលសមាជិកយើងធ្លាប់បានពិភាក្សាក្នុងកិច្ចប្រជុំពិគ្រោះយោបល់កន្លងមក និងបានដាក់អនុវត្តនៅថ្ងៃទី០១ ខែមេសា ឆ្នាំ ២០១៩។

នីតិវិធីគយថ្មីនេះត្រូវបានដាក់ឱ្យអនុវត្តទន្ទឹមនឹងការប្រកាសឱ្យកាត់បន្ថយថ្លៃសេវាត្រួតពិនិត្យកុងតឺន័រចំនួន ៥០% ដែលតម្រូវដោយគយ បន្ទាប់ពីមានសេចក្ដីណែនាំចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយបន្ថែមទៀតនូវបន្ទុកហិរញ្ញវត្ថុនៃការនាំចូល និងនាំចេញរបស់ក្រុមហ៊ុនធុរកិច្ច។ សំខាន់ជាងនេះទៅទៀត ក៏មានសេចក្ដីប្រកាសមួយត្រូវបានធ្វើឡើងដោយបានលើកឡើងថាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានឹងដាក់ឱ្យប្រើប្រាស់បង្កាន់ដៃតាមប្រព័ន្ធអ៊ីនធឺណិតសម្រាប់សេវាកម្មទាំងនេះ ដែលនឹងធ្វើឱ្យកាន់តែមានតម្លាភាពបន្ថែមទៀតអំពីថ្លៃចំណាយដែលពាក់ព័ន្ធជាមួយនីតិវិធីទាំងនេះ។ ទោះបីជាមិនទាន់មានការបញ្ជាក់អំពីកាលបរិច្ឆេទដាក់ឱ្យដំណើរការជាផ្លូវការក្ដី សេចក្ដីប្រកាសនេះបានទទួលការកោតសរសើរយ៉ាងខ្លាំង ដោយសារតែ កង្វះការចេញវិក្កយបត្រផ្លូវការត្រូវបានលើកឡើងជាទៀងទាត់ថាជាកត្ដាកង្វល់ដ៏សំខាន់ បំផុតមួយសម្រាប់ក្រុមហ៊ុនអន្តរជាតិ និងដែលបង្ខំឱ្យក្រុមហ៊ុនទាំងនោះប្រើសេវាជើងសារ ដើម្បីកាត់បន្ថយហានិភ័យផ្លូវច្បាប់ ដែលបង្កើនថ្លៃចំណាយលើការធ្វើធុរកិច្ចរបស់ខ្លួន។

ទន្ទឹមនឹងការអនុវត្តទៅមុខនូវកម្មវិធីកំណែទម្រង់ដ៏សំខាន់ទាំងនេះ លទ្ធផលនេះនឹងត្រូវការពេលវេលាសមស្របមួយដើម្បីអាចសម្រេចបានប្រកបដោយ ប្រសិទ្ធភាពយ៉ាងពេញលេញ។ អាស្រ័យហេតុនេះ ដោយសារតែកិច្ចការនេះបានបន្តសម្រេចបាននូវវឌ្ឍនភាពល្អ សម្រាប់វិស័យគយ ការដឹកជញ្ជូន និងភ័ស្តុភារនៅឆ្នាំនេះ យើងខ្ញុំមានតែអនុសាសន៍ចំនួនបីប៉ុណ្ណោះដើម្បីបង្ហាញអំពីបញ្ហានៅសេសសល់ ដែលមិនទាន់បានដោះស្រាយតាមរបៀបវារៈកំណែទម្រង់នៅឡើយ។ អនុសាសន៍ទីមួយ ដើម្បីបង្កើនប្រសិទ្ធផលនៃដំណើរការការងារគយឱ្យកាន់តែល្អប្រសើរថែមមួយកម្រិតទៀត យើងខ្ញុំសូមស្នើដល់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបន្តកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យនីតិវិធីបញ្ចេញទំនិញពីគយកាន់តែមានភាពសាមញ្ញដោយប្រើគោលការណ៍ណែនាំសម្រាប់ការបញ្ចេញទំនិញពីគយរហ័សភ្លាមៗ របស់អង្គការគយពិភពលោក។

ឧត្តមានុវត្តន៍អន្តរជាតិនេះ មានស្តង់ដារនីយកម្ម និងបញ្ញាបនីតិវិធី ដោយចាត់ថ្នាក់ប្រភេទទំនិញដឹកជញ្ជូនដោយផ្អែកលើកម្រិតនៃហានិភ័យ និងអាចឱ្យមានការបញ្ចេញទំនិញពីគយទាន់ពេលវេលានៅក្នុងករណីដែលប្រតិបត្តិករបានផ្តល់ព័ត៌មានគយចាំបាច់មុនពេលទំនិញមកដល់។

អនុសាសន៍ទីពីរ យើងបានរក្សាទុកអនុសាសន៍របស់យើងអំពីភាពចាំបាច់នៅក្នុងការផ្តល់អាទិភាពលើការពង្រីកកម្មវិធីទំនើបកម្មគយតាមរយៈការអនុវត្តប្រព័ន្ធទូទាត់តាមប្រព័ន្ធអ៊ីនធឺណិតមានសុវត្ថិភាពនិងពង្រីកសមត្ថភាពដំណើរការឯកសារតាមប្រព័ន្ធអេឡិចត្រូនិកដើម្បីអាចឆ្លើយតបទៅនឹងកំណើនពាណិជ្ជកម្មកាន់តែមានប្រសិទ្ធភាព។ ដោយសារតែអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានបង្ហាញនូវគោលបំណងរបស់ខ្លួនក្នុងការចេញបង្កាន់ដៃតាមប្រព័ន្ធអ៊ីនធឺណិតសម្រាប់សេវាគយ យើងសង្ឃឹមថាគំនិតផ្តួចផ្តើមនេះនឹងដាក់ឱ្យអនុវត្តស្របពេលដាក់ឱ្យអនុវត្តប្រព័ន្ធសម្រួលការទូទាត់តាមប្រព័ន្ធអ៊ីន

ជីណិតដែរ ដោយសារតែការធ្វើបែបនេះនឹងជួយបង្កើនគណនេយ្យភាព និងកាត់បន្ថយហានិភ័យនៃការអនុវត្តមិនមានតម្លាភាព។ អនុសាសន៍ចុងក្រោយរបស់យើង គឺស្វែងរកដំណោះស្រាយសម្រាប់ក្ដីកង្វល់កំពុងបន្តកើតមានរបស់វិស័យឯកជន ពាក់ព័ន្ធនឹងការលើកបញ្ហាដែលទាក់ទងជាមួយមន្ត្រីគយ ឬការស្នើសុំឱ្យមានការពិនិត្យមើលឡើងវិញលើការសម្រេចរបស់មន្ត្រីគយ។ ដោយទទួលស្គាល់ថាការអនុវត្តបច្ចុប្បន្ន អាចមានភាពសមស្របសម្រាប់តម្រូវការសេដ្ឋកិច្ចកន្លងមក ប៉ុន្តែដោយសារតែចំនួនធុរកិច្ចដែលធ្វើការងារជាមួយនឹងផ្នែកគយបានកើនឡើងយ៉ាងច្រើន ដូចជា ការនាំចេញ និងការនាំចូល ដូច្នេះក្រុមហ៊ុនធុរកិច្ចត្រូវការវិធីសាស្ត្រលើកបញ្ហាដែលមានប្រសិទ្ធភាពខ្ពស់។

ជាការពិតណាស់ យើងទទួលបានការលើកទឹកចិត្តខ្ពស់ពីកម្មវិធីកំណែទម្រង់រចនាសម្ព័ន្ធជាវិជ្ជមាន និងបុរេសកម្មរបស់រាជរដ្ឋាភិបាលកន្លងមកដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងផ្នែកពាណិជ្ជកម្មរបស់កម្ពុជាឱ្យកាន់តែប្រសើរឡើង ហើយយើងក៏ទន្ទឹងរង់ចាំកិច្ចប្រជុំពិភាក្សាបែបស្ថាបនាកាន់តែច្រើនថែមទៀតតាមរយៈកិច្ចសហការជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធនានា ដើម្បីស្វែងរកដំណោះស្រាយសម្រាប់បញ្ហាដែលយើងបានលើកឡើង។

២២

# ការសម្រួលនីតិវិធីបញ្ចេញទំនិញពីគយ

ថ្មី

**ពិពណ៌នាបញ្ហា**

*សន្ទុះពាណិជ្ជកម្មអន្តរជាតិកើនឡើង និងការធ្វើសមាហរណកម្មរបស់ប្រទេសកម្ពុជាចូលទៅក្នុងខ្សែ សង្វាក់ផ្គត់ផ្គង់ពិភពលោកបានក្លាយជាកត្តាជំរុញមូលដ្ឋានក្នុងការរក្សាការពង្រីកសេដ្ឋកិច្ចរបស់កម្ពុជាដែលអាចជំរុញកំណើនសេដ្ឋកិច្ចដល់ ៧,៣% នៅឆ្នាំ២០១៨ ។ ទោះបីយ៉ាងណាក៏ដោយ កត្តានេះបានបង្កើនកំណើនតម្រូវការពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ដែលធ្វើឱ្យមានកំណើនតម្រូវការធនធានរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដោយសារតែប្រទេសនេះចាំបាច់ត្រូវមាននីតិវិធីគយស្មុគស្មាញដើម្បីជួយសម្រួលដំណើរការផ្ទេរទំនិញចេញចូលមកក្នុង និងទៅក្រៅប្រទេស។ ស្របពេលគ្នានេះដែរ វិស័យឯកជនដែលមានអនុលោមភាពតាមនីតិវិធីគយ យល់ឃើញថាភាពស្មុគស្មាញ និងការពន្យារពេលឆ្លើយតបនេះអាចក្លាយជាឧបសគ្គនាំឱ្យមានប៉ះពាល់ដល់កំណើនសមត្ថភាពប្រកួតប្រជែងរបស់ប្រទេសកម្ពុជានៅថ្ងៃអនាគតជាក់ជាមិនខាន។*

*បច្ចុប្បន្ន អគ្គនាយកដ្ឋានគយ និងរដ្ឋាករ មិនអាចធ្វើការបែងចែកភាពខុសគ្នានៃប្រភេទទំនិញ តម្លៃ ទំហំខុសគ្នា ឬសេវាដឹកជញ្ជូនឆាប់រហ័សសម្រាប់ការដឹកជញ្ជូនអន្តរជាតិក្រៅពីការដឹកជញ្ជូនទំនិញ មានតម្លៃប្រកាសក្រោម ៥០ ដុល្លារអាមេរិក បន្ទាប់ពីបានអនុវត្តដោគជ័យនូវរបបទំនិញតម្លៃទាបនៅឆ្នាំ២០១៨។ នេះមានន័យថា កម្រិតឯកសារ និងការត្រួតពិនិត្យល្អិតល្អន់ដែលចាំបាច់សម្រាប់ អគ្គអនាយកដ្ឋានគយក្នុងការរៀបចំដំណើរការបំពេញបែបបទបញ្ចេញទំនិញ និងការបញ្ចេញទំនិញ គឺសុទ្ធតែដូចគ្នាចំពោះទំនិញគ្រប់ប្រភេទទម្ងន់ និងដែលមានតម្លៃលើសពី ៥០ ដុល្លារអាមេរិក ឧ. សំណុំឯកសារ ៣ ច្បាប់សម្រាប់អញ្ញាតប័ណ្ណដឹកជញ្ជូនផ្លូវអាកាស* (master air way bill) *អញ្ញាតប័ណ្ណ ឃ្លាំងដឹកជញ្ជូនផ្លូវអាកាស* (house airway bill) *វិក្កយបត្រ និងបញ្ជីវេចខ្ចប់ វិញ្ញាបនប្រត្រចុះបញ្ជី ពាណិជ្ជកម្ម វិញ្ញាបនបត្រអាករលើតម្លៃបន្ថែម* (VAT) *និងលិខិតអនុញ្ញាត។*

*ដំណើរការនេះបង្កើតឱ្យមានឧបសគ្គរាំងដល់ការដឹកជញ្ជូនទំនិញប្រកបដោយប្រសិទ្ធភាព ដោយ សារតែទំនិញក្នុងបរិមាណច្រើន និងមានតម្លៃខ្ពស់ ត្រូវការធនធានច្រើនដើម្បីធ្វើការត្រួតពិនិត្យ និង ដំណើរការទំនិញរូបវន្ត ដោយសារតែអាចមានទំនិញដែលបានប្រកាសប្រតិវេទន៍គយមិន ត្រឹមត្រូវ ឬមានបង្កប់ទំនិញខុសច្បាប់នៅខាងក្នុងនោះ។ ទោះបីជាទំនិញមានបរិមាណតិចតួច និងមានតម្លៃទាបជាងនេះត្រូវបានរំពឹងថាគួរតែមានការយកចិត្តទុកដាក់ដូចគ្នានេះដែរពីផ្នែកគយ ទោះបីជាបានដឹងថា ហានិភ័យរបស់ទំនិញទាំងនេះមានកម្រិតទាបខ្លាំងជាងក៏ដោយ។ ការអនុវត្តបែបនេះបង្កឱ្យមានបញ្ហាខ្លាំងសម្រាប់ទំនិញដែលផ្ញើតាមក្រុមហ៊ុនបញ្ជូនទំនិញឆាប់រហ័ស ឬតាមការដឹកជញ្ជូនតាមផ្លូវអាកាស ដោយសារការពុំមានការបែងចែកសេវាសម្រាប់ទំនិញទាំងនោះនោះទេ ដែលជារឿយៗ ឱ្យមានការពន្យារពេលបញ្ចេញទំនិញពីគយ ពីព្រោះការបញ្ចេញទំនិញនោះមិនអាចពន្លឿនដំណើរការបាន ហើយក្រុមហ៊ុនក៏ត្រូវដាក់ឯកសារដោយត្រូវរង់ចាំរយៈពេលវែងដូចគ្នាទៅនឹងទម្រង់ដឹកទំនិញផ្សេងទៀតដែរ។*

ប្រសិនបើក្រុមហ៊ុនដឹកជញ្ជូនទទួលបានការអនុញ្ញាតឱ្យផ្តល់ទិន្នន័យចាំបាច់ និងជូនដំណឹងដល់គយ ជាមុនអំពីការមកដល់របស់ទំនិញ គយនឹងអាចកំណត់ប្រភេទទំនិញដែលត្រូវការនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយគ្រប់ជ្រុងជ្រោយដោយផ្អែកលើការប៉ាន់ស្មានកម្រិតហានិភ័យរបស់ទំនិញដូចជា មុខទំនិញ ឬប្រទេសនៃប្រភពដើមជាដើម។ ដំណើរការបែបនេះ អាចឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករៀបចំដំណើរការនិងបញ្ចេញទំនិញមួយចំនួនភ្លាមៗនៅពេលទំនិញទាំងនោះមកដល់ ហើយទន្ទឹមនឹងនោះបានផ្តោតធនធានរបស់ខ្លួនទៅលើទំនិញដែលមានហានិភ័យខ្ពស់ជំនួសវិញ ដោយអនុញ្ញាតឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករ រៀបចំដំណើរការ និងបញ្ចេញទំនិញទាំងអស់កាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល។ សំខាន់ជាងនេះទៅទៀត តាមរយៈប្រព័ន្ធនេះ  អគ្គនាយកដ្ឋានគយ និងរដ្ឋាករ អាចបន្តធ្វើការត្រួតពិនិត្យទំនិញដែលខ្លួនគិតថាមានភាពចាំបាច់ ដូចមុនដដែល ប៉ុន្តែភាពចាំបាច់ និងពេលវេលាត្រូវការសម្រាប់ធ្វើការត្រួតពិនិត្យនឹងអាចកាត់បន្ថយ បានច្រើន។

## ផលប៉ះពាល់លើកម្ពុជា

ផលវិបាកកើតចេញពីការពន្យារពេលក្នុងការបំពេញបែបបទបញ្ចេញទំនិញពីគយ និងការបញ្ចេញ ទំនិញ បានប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចកម្ពុជាទាំងមូល។ ប្រសិនបើក្រុមហ៊ុនទ្រទ្រង់ផ្នែកភស្តុភារ(ឡូជីស្ទិក)មិនអាច ដឹកជញ្ជូនទំនិញតាមកាលវិភាគបញ្ជូនទំនិញដ៏មមាញឹករបស់ខ្លួនបានដោយសារតែដំណើរការការបំពេញ បែបបទបញ្ចេញទំនិញពីគយដែលអប្រសិទ្ធភាពនេះ នឹងបង្កើតឱ្យមានផលប៉ះពាល់មិនអាចព្យាករណ៍ ដឹងមុន និងកាត់បន្ថយសមត្ថភាពរបស់ក្រុមហ៊ុនផលិត និងក្រុមហ៊ុនផ្គត់ផ្គង់ក្នុងការរៀបចំផែនការ គ្រប់គ្រង និងបង្កើនប្រសិទ្ធភាពខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួន ដោយធ្វើឱ្យក្រុមហ៊ុនទាំងនោះមាន ថ្លៃចំណាយលើការផលិតកម្មកាន់តែខ្ពស់ថែមទៀត។ បច្ចុប្បន្ន ដោយសារតែក្រុមហ៊ុនធុរកិច្ចជាច្រើន បានចូលរួមនៅក្នុងបណ្តាញផលិតកម្មក្នុងតំបន់ ផលប៉ះពាល់ជាបន្តបន្ទាប់កើតចេញពីការពន្យារពេលបញ្ចេញទំនិញពីគយជាប្រចាំបែបនេះ អាចធ្វើឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរយ៉ាងខ្លាំងទៅលើសមត្ថភាព ប្រកួតប្រជែង និងឱកាសរបស់កម្ពុជាក្នុងការបង្កើនកិត្យានុភាពរបស់ខ្លួននៅក្នុងខ្សែសង្វាក់គុណតម្លៃ។

កំណើនពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (e-commerce) គឺជាកត្តាលើកទឹកចិត្តរឹងដ៏មាំមួយសម្រាប់កម្ពុជាក្នុងការធ្វើបច្ចុប្បន្នភាពដំណើរការគយរបស់ខ្លួន ដោយសារតែប្រព័ន្ធស្មុគស្មាញនាពេលបច្ចុប្បន្ននេះអាចបង្កជាឧបសគ្គដល់សកម្មភាពធុរកិច្ច ដោយសារតែបញ្ហាប្រឈមដែលទាក់ទងជាមួយនឹងការគ្រប់គ្រង ដូចជា កំណើនបរិមាណពាណិជ្ជកម្មយ៉ាងគំហុក។ ដោយសារតែពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអាចភ្ជាប់ក្រុមហ៊ុនធុរកិច្ចដោយផ្ទាល់ជាមួយអ្នកប្រើប្រាស់ នោះទំនិញតិចតួច និងមានតម្លៃទាបដែលផ្ញើញឹកញាប់តាមក្រុមហ៊ុនបញ្ជូនទំនិញឆាប់រហ័សនឹងមានការកើនឡើងខ្ពស់ ហើយ អាចបង្កើនបន្ទុកការងារច្រើនដល់អគ្គនាយកដ្ឋានគយ និងរដ្ឋាករជាពិសេស ដោយសារតែចំណេះដឹងរបស់អ្នកទិញ និងអ្នកលក់ជាច្រើនអំពីលក្ខខណ្ឌតម្រូវនាំចេញ និងនាំចូលនៅមានកម្រិតនៅឡើយ។ ស្រដៀងគ្នានេះដែរ ដោយសារតែកម្ពុជាមិនបានចាត់ចែងការដឹកជញ្ជូនទំនិញឆាប់រហ័សដាច់ដោយឡែកពីសេវាផ្សេងទៀត ទំនិញដែលគួរតែបញ្ចេញឱ្យបានឆាប់រហ័ស បែរជាត្រូវពន្យារពេលវែងទៅវិញ ដែលធ្វើឱ្យប៉ះពាល់ដល់ការពេញចិត្តរបស់អតិថិជន និងធ្វើឱ្យខូចកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនដែលប្រកប អាជីវកម្មលើប្រព័ន្ធអ៊ីនធឺណិត។

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យផ្តល់អាទិភាពលើការអនុម័តដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំសម្រាប់ការបញ្ចេញទំនិញពីគយរហ័សភ្លាមៗរបស់អង្គការគយពិភពលោកដើម្បីសម្រួលនីតិវិធីបំពេញបែបបទបញ្ចេញទំនិញ ពីគយឱ្យមានភាពសាមញ្ញ។

*យើងខ្ញុំសូមគោរពផ្តល់ជូនអនុសាសន៍ដោយស្នើឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករផ្តល់អាទិភាព លើការអនុម័តដាក់ឱ្យប្រើប្រាស់នីតិវិធីបញ្ចេញទំនិញពីគយឱ្យមានភាពសាមញ្ញដើម្បីអនុញ្ញាតឱ្យមានការបញ្ចេញទំនិញមួយចំនួនបានរហ័សភ្លាមៗ ដោយសារតែដំណើរការនេះគឺស្របតាមកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការធ្វើឱ្យប្រសើរឡើង នូវការសម្រួលពាណិជ្ជកម្ម និងលុបបំបាត់ចេញនូវនីតិវិធីចេញដែលមិនចាំបាច់មួយ ចំនួន។*

*ដោយសារតែកម្ពុជាបានអនុម័តដាក់ឱ្យប្រើប្រាស់នីតិវិធីគយបែបសាមញ្ញរួចទៅហើយសម្រាប់ទំនិញមាន តម្លៃក្រោម ៥០ ដុល្លារអាមេរិករយៈតាមប្រព័ន្ធទំនិញតម្លៃទាប យើងស្នើសុំឱ្យពង្រីកដំណើរការនេះដោយយកនីតិវិធីមានលក្ខណៈសាមញ្ញនោះផ្អែកលើគោលការណ៍ណែនាំសម្រាប់ការបញ្ចេញទំនិញពីគយរហ័សភ្លាមៗរបស់អង្គការគយពិភពលោក ។ គោលការណ៍ណែនាំទាំងនេះមានគោលបំណងសម្រួល និងធ្វើស្តង់ដារនីយកម្ម ដល់នីតិវិធីគយ តាមរយៈការកំណត់ប្រភេទទំនិញតាមកម្រិតហានិភ័យ និងបែងចែកការបញ្ចេញទំនិញពីដំណើរការបញ្ចេញទំនិញដែលប្រើពេលច្រើន នៅក្នុងករណីដែល ប្រតិបត្តិករឡជីស្ទិកផ្តល់ព័ត៌មានចាំបាច់មុនពេលទំនិញមកដល់។ ប្រភេទទាំងបួននេះរួមមានៈ*

*១. លិខិតឆ្លើយឆ្លង និងឯកសារ ទំនិញដែលមិនមានតម្លៃពាណិជ្ជកម្ម និងមិនជាប់ពន្ធ។*

*២. ទំនិញតម្លៃទាបដែលមិនប្រមូលពន្ធ និងអាករ (ទំនិញតម្លៃទាប) – បានអនុវត្តរួចហើយនៅកម្ពុជា ដោយអនុញ្ញាតឱ្យមានការបញ្ចេញទំនិញរហ័សភ្លាមៗក្រោយពីដាក់សេចក្តីប្រកាសគយមានលក្ខណៈសាមញ្ញរួច។*

*៣. ទំនិញតម្លៃទាបជាប់ពន្ធ – ទំនិញដែលមិនលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានការ លើកលែងពន្ធ ប៉ុន្តែនៅក្រោមកម្រិតអតិបរមាដែលបានកំណត់ថាមិនតម្រូវឱ្យបំពេញប្រតិវេទន៍គយពេញលេញឡើយ។ មានគោលណងសម្រេចឱ្យបានការបញ្ចេញទំនិញក្នុងរយៈពេល ១ ម៉ោង បន្ទាប់ពីទំនិញមកដល់។*

*៤. ទំនិញតម្លៃខ្ពស់ – ទំនិញដែលមិនស្ថិតក្រោមប្រភេទផ្សេងទៀត ដូច្នេះត្រូវអនុវត្តនីតិវិធីបំពេញ បែបបទបញ្ចេញទំនិញពីគយ និងការបញ្ចេញទំនិញធម្មតា។ មានគោលណងសម្រេចឱ្យបានការបញ្ចេញទំនិញក្នុងរយៈពេល ៣ ម៉ោង បន្ទាប់ពីទំនិញមកដល់។*

*វិធានការបន្ថែមដែលយើងខ្ញុំសូមគោរពស្នើសុំឱ្យលើកកម្ពស់សមត្ថភាពរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករនៅ ក្នុងការពន្លឿនដំណើរការការបំពេញបែបបទបញ្ចេញ ទំនិញពីគយ និងការបញ្ចេញទំនិញដើម្បីបំពេញ តាមគោលដៅនៃការបញ្ចេញទំនិញពីគយរហ័សភ្លាមៗរួមមាន៖*

- *សម្រួលការបង់ពន្ធគយ និងតម្លៃសេវារៀបចំតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់ទំនិញតម្លៃទាបជាប់ពន្ធ និងទំនិញតម្លៃខ្ពស់ និងចេញរបាយការណ៍ប្រចាំថ្ងៃតាមប្រព័ន្ធអេឡិចត្រូនិកជូនប្រតិបត្តិករឡូជីស្ទិកដើម្បីអាចធ្វើការបង់ពន្ធគយមុនទំនិញមកដល់ៗ*

- *ពង្រីកម៉ោងធ្វើការរបស់មន្ត្រីគយដើម្បីគ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធភាពលើកាលវិភាគទំនិញដឹកជញ្ជូនតាមផ្លូវអាកាសមកដល់មុនពេល និងយឺតជាងកាលកំណត់ៗ*

- *ផ្តល់អាទិភាពលើការបង្កើតអង្គភាពដោះស្រាយរហ័សដើម្បីអាចចាត់ចែងទំនិញជាក្រុម និងបញ្ជ្រាបដំណើរការសម្រាប់ទំនិញឆាប់រហ័សទាំងអស់ៗ*

- *ធានាថាតម្លៃសេវាសម្រាប់ដំណើរការអាករ និងពន្ធគយ និងតម្លៃសេវាការងារនៅក្រៅម៉ោង ធ្វើការនឹងគិតតាមតម្លៃសេវាសាធារណៈរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដែលបាន អនុម័តនៅពេលថ្មីៗនេះដូចមានចែងនៅក្នុងប្រកាសលេខ ១៦០៨ៗ*

*គំនិតផ្តួចផ្តើមទាំងនេះនឹងអាចឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាអាចប្រើប្រាស់ធនធានរបស់ខ្លួនកាន់តែមានប្រសិទ្ធផល ហើយសំខាន់ជាងនេះទៅទៀត គឺអាចអនុវត្តបានដោយមិនចាំបាច់ ប៉ះពាល់ដល់សន្តិសុខតាមព្រំដែន ឬការប្រមូល ចំណូលនោះឡើយៗ ទោះបីជាយើងទទួលស្គាល់ថា ការកែសម្រួលដំណើរការស្នូលដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករ បំពេញភារកិច្ចរបស់ខ្លួនគឺ ជាកិច្ចការដ៏លំបាកមួយក៏ដោយ ប៉ុន្តែអត្ថប្រយោជន៍នៃការសម្រួលពាណិជ្ជកម្ម និងសមត្ថភាពប្រកួតប្រជែងរបស់ប្រទេសកម្ពុជា តាមរយៈការសម្រួលនីតិវិធីគយគឺមិនអាចមើលរំលង ឡើយៗ*

២៣

# ការធ្វើទំនើបកម្មគយ

ធ្វើបច្ចុប្បន្នភាព

---

**អនុសាសន៍ឆ្នាំ ២០១៧**

សូមផ្តល់អាទិភាពដល់ការប្រើប្រព័ន្ធបង់ប្រាក់តាមប្រព័ន្ធអ៊ីនធឺណិតមានសុវត្ថិភាព និងការពង្រីកសមត្ថភាពប្រព័ន្ធឯកសារតាមប្រព័ន្ធអ៊ីនធឺណិតរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*រាជរដ្ឋាភិបាលកម្ពុជាកំពុងបន្តអនុវត្តយ៉ាងសកម្មនូវគម្រោងប្រព័ន្ធបញ្ជរតែមួយជាតិកម្ពុជា ដែលនឹងបង្កើតច្រកចេញចូលតែមួយសម្រាប់ដោះស្រាយបញ្ហាផ្លូវច្បាប់ដែលមានពាក់ព័ន្ធជាមួយការនាំចូល ការនាំចេញ និងការឆ្លងកាត់ទាំងអស់ និងធ្វើស្តង់ដារនីយកម្មលក្ខខណ្ឌតម្រូវសម្រាប់ព័ត៌មាន។ ដំណាក់កាលទី ២ នៃគម្រោងនេះត្រូវបានដាក់ឱ្យដំណើរការនៅខែមីនា ឆ្នាំ២០១៨ និងបានដាក់បញ្ចូលអាជ្ញាធរកម្ពុជាប្រាំពីរស្ថាប័នទៅក្នុងកម្មវិធីសម្របសម្រួលពាណិជ្ជកម្មតាមប្រព័ន្ធអ៊ីនធឺណិតរួមមួយ ដែលដាក់ឱ្យអនុវត្តសាកល្បងចាប់ពីថ្ងៃទី២៥ ខែមីនា ដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩។ រាជរដ្ឋាភិបាលកម្ពុជាមានបំណងដាក់ឱ្យដំណើរការផ្លូវការនូវគម្រោងប្រព័ន្ធបញ្ជរតែមួយជាតិនេះនៅដើមខែមិថុនា ឆ្នាំ២០១៩ ខាងមុខនេះ។*

*ការបង្កើតប្រព័ន្ធបញ្ជរតែមួយជាតិនេះ ស្របតាមការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន ដែលនឹងបង្កើតបញ្ជរតែមួយអាស៊ានដើម្បីអាចឱ្យមានការផ្លាស់ប្តូរទិន្នន័យគយតាមប្រព័ន្ធអេឡិចត្រូនិករវាងក្រសួងស្ថាប័នរដ្ឋាភិបាលសមាជិកអាស៊ានទាំងអស់ ដែលទទួលបន្ទុកផ្នែកពាណិជ្ជកម្ម។ ប្រព័ន្ធនេះនឹងបញ្ជ្រាប និងធ្វើឌីជីថលនីយកម្មដំណើរការនាំចេញ និងការរៀបចំឯកសារតាមប្រព័ន្ធឌីជីថលរួមមាន ការបំពេញបែបបទបញ្ចេញទំនិញពីគយ អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតទូទាំងតំបន់ដើម្បីកាត់បន្ថយហានិភ័យឆ្លងកាត់ព្រំដែន ដោយបង្កើនប្រសិទ្ធផលការដោះដូរពាណិជ្ជកម្ម និងកាត់បន្ថយថ្លៃចំណាយសម្រាប់ការធ្វើធុរកិច្ចឱ្យនៅត្រឹមកម្រិតអប្បបរមា។*

---

**ពិពណ៌នាបញ្ហា**

*សមាជិករបស់យើងសូមស្វាគមន៍ចំពោះការខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដែលបានធ្វើទំនើបកម្មនីតិវិធីគយ និងបានបន្តដាក់ឱ្យប្រើប្រាស់ដំណើរការប្រព័ន្ធដំណើរការ ស្វ័យប្រវត្តិទំនើប ដែលជួយគាំទ្រដល់ប្រព័ន្ធដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតមានស្រាប់ ដូចបានបង្ហាញតាមរយៈការអនុវត្តដំណាក់កាលទី ២ នៃគម្រោងប្រព័ន្ធបញ្ជរតែមួយជាតិ។ នីតិវិធីគយត្រូវបានគេការយល់ឃើញជាទូទៅថា មានភាពកាន់តែងាយស្រួលជាងមុន តាមរយៈគំនិតផ្តួចផ្តើមស្វ័យប្រវត្តិកម្មនាពេលថ្មីៗនេះ ដូចជាការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធដំណើរការតាមប្រព័ន្ធអ៊ីនធឺណិត សម្រាប់ឱ្យអ្នកនាំចូលស្នើសុំវិញ្ញាបនបត្រដើមកំណើតទំនិញជាដើម។*

*ដោយសារតែអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ទទួលស្គាល់នៅក្នុងយុទ្ធសាស្ត្រ និងកម្មវិធីការងារកំណែទម្រង់ និង ទំនើបកម្មរបស់ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ (ឆ្នាំ២០១៤-២០១៨) ទើបមានឱកាសសម្រេចបាននូវការចំណេញពេលវេលា និងថ្លៃ*

ចំណាយបន្ថែមជាច្រើនតាមរយៈការពង្រីកការប្រើប្រាស់ប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក។ សមត្ថភាព មានស្រាប់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ក្នុងការទទួលបាន នឹងទទួលយកឯកសារតាមប្រព័ន្ធអេឡិចត្រូនិកនៅមានកម្រិត ហើយក្នុងករណីជាច្រើន នៅតែត្រូវការឱ្យមានអ្នកតំណាងរបស់ម្ចាស់ទំនិញបង្ហាញខ្លួននៅមជ្ឈមណ្ឌលប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (អាស៊ីគូដា) ដើម្បីឆ្លើយសំណួររបស់មន្ត្រីគយ ឬផ្តល់ឯកសារបន្ថែមទៀត។ ករណីនេះនៅមានកើតឡើងសម្រាប់ការដឹកជញ្ជូនជាច្រើនប្រភេទ៖

- នៅក្នុងវិស័យដឹកជញ្ជូន នីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ តម្រូវឱ្យផ្តល់ឯកសារអំពីទំនិញនៅក្នុងកុងតឺន័រនីមួយៗ។ ក្រុមហ៊ុនដឹកជញ្ជូនត្រូវបានតម្រូវឱ្យដាក់បញ្ចូលគ្នានូវឯកសារដែលទទួលបានពីអតិថិជននីមួយៗ ហើយត្រូវផ្តល់ទាំងឯកសារជាក្រដាស (ដោយផ្ទាល់) និងឯកសារជាទម្រង់អេឡិចត្រូនិក (បញ្ចូលដោយដៃ) ដល់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ។ លេខនាវាដែលមាននៅក្នុងឯកសារ បានដឹងរួចហើយនៅពេលមន្ត្រីគយត្រួតពិនិត្យទំនិញនៅកណ្តាគារគយ ក្នុងន័យនេះប្រសិនបើមានប្រព័ន្ធចាំបាច់ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ គួរតែអាចទាញឯកសារទាំងនោះតាមប្រព័ន្ធអាស៊ីគូដា។ អាស្រ័យដូចនេះ ក្រុមហ៊ុនដឹកជញ្ជូនក៏លែងចាំបាច់បញ្ចូលឯកសារដោយដៃ ដែលជានីតិវិធីបន្ទុកផ្នែករដ្ឋបាលជានិច្ចគ្នាច្រើនតង់ទៀតឡើយ។

- ចំពោះទំនិញដឹកតាមផ្លូវអាកាស អគ្គនាយកដ្ឋានគយ និរដ្ឋាករ តម្រូវឱ្យក្រុមហ៊ុនដឹកជញ្ជូនផ្តល់ឯកសារអនុញ្ញាតបញ្ចេញទំនិញចាំបាច់ជាក្រដាស ហើយមិនមានប្រព័ន្ធសម្រាប់សុំអញ្ញាតប័ណ្ណដឹកជញ្ជូនផ្លូវអាកាសជាទម្រង់អេឡិចត្រូនិកឡើយ ដែលបានក្លាយជារឿងធម្មតាសម្រាប់អាជ្ញាធរគយកាន់តែច្រើនឡើងនៅទូទាំងពិភពលោក និងមានការគាំទ្រពីក្រុមហ៊ុនអាកាសចរណ៍មួយចំនួនដែលកំពុងប្រតិបត្តិការនៅកម្ពុជា។ ឧបសម្ព័ន្ធ ឃ នៃសំណៅឯកសារកែសម្រួលអំពីការអនុវត្តដែលបានផ្តល់អនុសាសន៍លេខ ១៦៧០ (RP១៦៧០) របស់សមាគមដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ រៀបរាប់អំពីរបៀបដែលអញ្ញាតប័ណ្ណដឹកជញ្ជូនផ្លូវអាកាសជាទម្រង់អេឡិចត្រូនិក អាចជួយធ្វើឱ្យការទំនាក់ទំនងមានលក្ខណៈសាមញ្ញរវាងក្រុមហ៊ុនបញ្ជូនទំនិញ និងក្រុមហ៊ុនដឹកទំនិញ ហើយសូម្បីតែនៅក្នុងចំណោមប្រទេសហត្ថលេខីនៃអនុសញ្ញាក្រុង Warsaw (រួមទាំងប្រទេសកម្ពុជាផងដែរ) ដែលតម្រូវការឯកសារជាក្រដាស។

ជាទូទៅ ប្រសិនបើឯកសារបន្ថែម ដូចជាការកែសម្រួលលើបញ្ជីមេ ត្រូវបានតម្រូវជាចាំបាច់ឱ្យដាក់ជូនអគ្គនាយកដ្ឋានគយ និងរដ្ឋាករ នោះការផ្ញើឯកសារទាំងនេះតាមប្រព័ន្ធអេឡិចត្រូនិកគឺលឿនជាងការបញ្ជូនឯកសារដោយផ្ទាល់ដៃ។

លើសពីនេះទៅទៀត ក្នុងករណីដែលថ្លៃសេវាគយដល់ពេលត្រូវបង់ បច្ចុប្បន្ននេះ មិនទាន់មានប្រព័ន្ធណាមួយដែលអាចធ្វើការបង់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកបាននៅឡើយនោះទេ។ ជាថ្មីម្តងទៀត ប្រព័ន្ធបង់ប្រាក់តាមប្រព័ន្ធអ៊ីនធឺណិត មានសុវត្ថិភាព នឹងជួយកាត់បន្ថយពេលវេលាដោយមិនចាំបាច់ឱ្យតំណាងក្រុមហ៊ុនបង្ហាញខ្លួនដោយផ្ទាល់ឡើយ ហើយប្រព័ន្ធនេះថែមទាំងអាចផ្តល់ឯកសារកំណត់ត្រាតាមដានយ៉ាងត្រឹមត្រូវសម្រាប់សវនកម្មដល់ប្រតិបត្តិករភ័ស្តុភារ (ឡូជីស្ទិក) ទៀតផង។

**ផលប៉ះពាល់លើកម្ពុជា**

*សារៈសំខាន់នៃតម្លាភាព និងតម្រូវការឱ្យបង្ហាញកំណត់ត្រាមានការបញ្ជាក់ សម្រាប់បញ្ហាគយបានកើនឡើងគួរឱ្យកត់សម្គាល់ ដោយសារក្រុមហ៊ុនពហុជាតិ កំពុងសម្របសម្រួល និងធ្វើស្តង់ដារនីយកម្មការអនុវត្តការគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុននៅក្នុងពិភពលោកដើម្បីធានាដល់ប្រតិបត្តិការរបស់ខ្លួននៅគ្រប់ដែនយុត្តាធិការទាំងអស់ដោយ ស្របតាមទំនួលខុសត្រូវចំពោះប្រទេស នីងចំពោះក្រុមហ៊ុនខ្លួនឯង។ អាស្រ័យហេតុនេះ ប្រសិនបើមិនមានប្រព័ន្ធមានប្រសិទ្ធភាពក្នុងការសម្រួលដល់ការផ្លាស់ប្តូរឯកសារ និងការបង់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកទេ នោះសមត្ថភាពប្រកួតប្រជែង និងការទាក់ទាញការវិនិយោគរបស់កម្ពុជា អាចនឹងធ្លាក់ចុះ ដោយសារតែក្រុមហ៊ុនធុរកិច្ចសកលមិនអាចបន្តទទួលយកហានិភ័យនិយ័តកម្មដែលកើតចេញពីការអនុវត្តមិនមានតម្លាភាពបានទៀតឡើយ។*

*នៅពេលដែលទំហំពាណិជ្ជកម្មអន្តរជាតិមានការកើនឡើងដោយសារតែទំហំសេដ្ឋ-កិច្ចកម្ពុជាមានការរីកធំខ្លាំងឡើង នោះកង្វះប្រព័ន្ធស្វ័យប្រវត្តិកម្ម នៅក្នុងដំណើរការ និងនីតិវិធីគយនឹងបន្តបង្អាក់ដល់សមត្ថភាពរបស់នាយកដ្ឋានគយក្នុងការឆ្លើយតប និងការគ្រប់គ្រងកំណើននេះជាក់ជាមិនខាន។*

*ស្រដៀងគ្នានេះដែរ ការបន្តអនុវត្តនីតិវិធីប្រើក្រដាសឯកសារនៅតែជាបន្ទុកសម្រាប់ទាំងវិស័យឯកជន និងអគ្គនាយកដ្ឋានគយ ដោយសារតែនីតិវិធីនេះនឹងកាត់បន្ថយប្រសិទ្ធផលការងារ និងមានហានិភ័យក្នុងការបាត់ឯកសារ ឬការមានកំហុសឆ្គងច្រើនគួរឱ្យកត់សម្គាល់។*

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យផ្តល់អាទិភាពប្រើប្រព័ន្ធបង់ប្រាក់តាមប្រព័ន្ធអ៊ីនធឺណិត មានសុវត្ថិភាព និង ការពង្រីកសមត្ថភាពប្រព័ន្ធឯកសារតាមប្រព័ន្ធអ៊ីនធឺណិតដើម្បីសម្រួលនីតិវិធីគយឱ្យកាន់តែមានប្រសិទ្ធភាព។

*អគ្គនាយកដ្ឋានគយ និងរដ្ឋាករ មានកម្មវិធីកំណែទម្រង់ ដែលបានរៀបចំឡើងដើម្បីប្រែក្លាយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ឱ្យក្លាយទៅជារដ្ឋបាលគយកាន់តែទំនើបតាមរយៈការអនុវត្តឧត្តមានុវត្តន៍ស្របតាមស្តង់ដារអន្តរជាតិ។ គំនិតផ្តួចផ្តើមនេះបានដាក់បញ្ចូលកម្មវិធីកំណែទម្រង់ជាច្រើនទៅជាផ្នែកនៃគម្រោងទូលំទូលាយរយៈពេលវែង។ នៅក្នុងការអនុវត្តកម្មវិធីកំណែទម្រង់នេះ ចាំបាច់ត្រូវកំណត់អាទិភាពការងារដើម្បីងាយស្រួលរកាជនីធនធានមានកំណត់ដល់គម្រោងដែលផ្តល់អត្ថប្រយោជន៍ច្រើនបំផុត។ យើងខ្ញុំសូមផ្តល់ជូនអនុសាសន៍ដោយស្នើឱ្យរាជរដ្ឋាភិបាលផ្តល់អាទិភាពលើការអនុម័តឱ្យប្រើប្រាស់ប្រព័ន្ធបង់ប្រាក់តាមប្រព័ន្ធអ៊ីនធឺណិតមាន*

*សុវត្ថិភាព និងលើកទឹកចិត្តអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ឱ្យធ្វើការពិចារណាលើមតិយោបល់របស់យើងខ្ញុំអំពីដំណើរការឯកសារសម្រាប់ការដឹកជញ្ជូនទំនិញតាមផ្លូវសមុទ្រ និងផ្លូវអាកាស នៅពេលអគ្គនាយកដ្ឋានបន្តពង្រឹងសមត្ថភាពរៀបចំឯកសារតាមប្រព័ន្ធអ៊ីនធឺណិតនាពេលបន្តបន្ទាប់ខាងមុខ។*

២៤

# នីតិវិធីសម្រាប់លើកបញ្ហា

**ធ្វើបច្ចុប្បន្នភាព**

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើឱ្យបង្កើតដំណើរការច្បាស់លាស់និងមានលក្ខណៈជាប្រព័ន្ធដែលវិស័យឯកជនអាចលើកបញ្ហា និងស្នើសុំឱ្យមានការពិនិត្យមើលឡើងវិញលើសេចក្តីសម្រេចរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*នៅខែវិច្ឆិកា ឆ្នាំ២០១៨ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា បានរៀបចំកម្មពិធីពិសា «អាហារថ្ងៃត្រង់» ជាមួយនឹងឯកឧត្តម បណ្ឌិត គុណ ញឹម ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដែលកម្មវិធីនេះបានផ្តល់ឱកាសពិសេសឱ្យអ្នកចូលរួមលើកឡើងដោយផ្ទាល់អំពីកម្មវិធីកំណែទម្រង់ និងទំនើបកម្មគយរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ។ នៅក្នុងកម្មពិធីនេះ មានការលើកសំណួរមួយជូនឯកឧត្តមអគ្គនាយកអំពីដំណើរការលើកបញ្ហាដែលមានទាក់ទងជាមួយបញ្ហាគយ។ ជាការឆ្លើយតប ឯកឧត្តម បានបញ្ជាក់ជាថ្មីអំពីដំណើរការក្នុងច្បាប់ស្តីពីគយ ដែលចែងថា ប្រសិនបើបុគ្គលណាម្នាក់មិនពេញចិត្តចំពោះការសម្រេចនូវចំណាត់ថ្នាក់តាមតារាង ដើមកំណើត ឬតម្លៃគិតពន្ធគយ បុគ្គលនោះអាចជំទាស់ទៅនឹងការសម្រេចនេះជាលាយលក្ខណ៍អក្សរទៅកាន់អគ្គនាយកនៅក្នុងរយៈពេល ៣០ ថ្ងៃគិតចាប់ពីពេលទទួលបានការជូនដំណឹងពីអគ្គនាយកដ្ឋានគយ។*

*សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ឯកឧត្តម បណ្ឌិត គុណ ញឹម អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដែលបានចូលរួមជាមួយនឹងវិស័យឯកជន។ យើងខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការធ្វើទំនើបកម្មដំណើរការគយនៅក្នុងប្រទេសកម្ពុជាផងដែរ។ ទោះបីយ៉ាងណាក៏ដោយ សមាជិករបស់យើងជឿជាក់ថាដំណើរការលើកបញ្ហានាពេលបច្ចុប្បន្ននេះ មិនទាន់ត្រូវបានដាក់ឱ្យអនុវត្តបានសមស្របទៅតាមកំណើនតម្រូវការសេដ្ឋកិច្ចនៅកម្ពុជានាពេលបច្ចុប្បន្ននេះឡើយ។ ជាពិសេស នៅពេលដែលសមត្ថភាពប្រកួតប្រជែងផ្នែកនាំចេញរបស់កម្ពុជាកំពុងរងសម្ពាធកាន់តែខ្លាំងឡើង និងកំពុងត្រូវការជាចាំបាច់នូវកំណែទម្រង់បន្ថែមទៀតដើម្បីកែលម្អឱ្យកាន់តែប្រសើរឡើង។*

**ពិពណ៌នាបញ្ហា**

*អគ្គនាយកដ្ឋានគយ និងរដ្ឋាករ មានអង្គភាពទំនាក់ទំនងសាធារណៈដែលជាទូទៅសកម្មខ្លាំង និងមានការឆ្លើយតបទាន់ពេលវេលា។ យើងខ្ញុំសូមវាយតម្លៃខ្ពស់ដែលកន្លងមកអគ្គនាយកដ្ឋានគយបានខិតខំប្រឹងប្រែងជួយដោះស្រាយបញ្ហាជាក់លាក់ជាច្រើនដែលសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាបានលើកឡើង។ ប៉ុន្តែទន្ទឹមនឹងនេះ សមាជិករបស់យើងខ្ញុំក៏បានលើកឡើងអំពីក្តីកង្វល់ចំពោះនីតិវិធីមានស្រាប់ក្នុងការលើកបញ្ហាដែលមានទាក់ទងជាមួយមន្ត្រីគយ ឬស្នើសុំឱ្យធ្វើការពិនិត្យមើលឡើងវិញលើសេចក្តីសម្រេចដែលបានធ្វើឡើងដោយអគ្គនាយកដ្ឋានគយ។*

*មាត្រា ២៤ ក្នុងជំពូក ៣ នៃច្បាប់ស្តីពីគយ ដែលប្រកាសឱ្យប្រើប្រាស់នៅឆ្នាំ២០០៧ បានចែងថាប្រសិនបើបុគ្គលណាម្នាក់មិនពេញចិត្តចំពោះការសម្រេចនូវចំណាត់ថ្នាក់តាមតារាង ដើមកំណើត ឬតម្លៃគិតពន្ធគយ បុគ្គលនោះអាចជំទាស់ទៅនឹងការសម្រេចនេះជាលាយលក្ខណ៍អក្សរទៅកាន់អគ្គនាយកនៅក្នុងរយៈពេល ៣០*

ថ្ងៃគិតចាប់ពីពេលទទួលបានការជូនដំណឹងពីអគ្គនាយកដ្ឋានគយ។បន្ទាប់ពីនោះ អគ្គនាយក ត្រូវធ្វើសេចក្តីសម្រេចលើការជំទាស់នោះនៅក្នុងរយៈពេល ៦០ ថ្ងៃ បើមិនដូច្នោះទេ ការជំទាស់នឹងត្រូវចាត់ទុកថា បានយល់ព្រម។ ប្រសិនបើអគ្គនាយកបានធ្វើការម្រេចរួចហើយ ក៏បុគ្គលនោះនៅតែអាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការតារាងពន្ធគយ ជំទាស់ទៅនឹងការសម្រេចរបស់អគ្គនាយកបានក្រោយពីនោះ ការតវ៉ាជំទាស់នានាត្រូវធ្វើឡើងទៅតុលាការនៅក្នុងរយៈពេល ៣០ ថ្ងៃគិតចាប់ពីពេលចេញសេចក្តីសម្រេចរបស់គណៈកម្មាធិការនេះ។

ទោះបីជាដំណើរការនេះអាចមានភាពសមស្របសម្រាប់តម្រូវការសេដ្ឋកិច្ចកម្ពុជាកាលពីមុនមក ប៉ុន្តែ ដោយសារតែកម្រិតពាណិជ្ជកម្មកម្ពុជាបានកើនឡើងយ៉ាងឆាប់រហ័ស ហើយចំនួនក្រុមហ៊ុនធុរកិច្ចមានចំនួនច្រើនជាងមុនខ្លាំងដែរនោះ ដំណើរការនាពេលបច្ចុប្បន្ននេះហាក់ដូចជាលែងមានប្រសិទ្ធផលក្នុងការគ្រប់គ្រងសំណើសុំនិងការពិនិត្យមើលឡើងវិញដែលមានចំនួនកើនឡើង និងញឹកញាប់ខ្លាំងបានដូចពេលមុនឡើយ។ អាស្រ័យហេតុនេះ ក្រុមហ៊ុនធុរកិច្ច ជាពិសេស សហគ្រាសធុនតូចនិងមធ្យម ត្រូវការវិធីសាស្រ្តដែលមានប្រសិទ្ធភាព និងប្រសិទ្ធផលជាងមុនដើម្បីលើកបញ្ហាដែលខ្លួនបានជួបប្រទះ នៅពេលធ្វើការងារជាមួយនឹងមន្រ្តីគយ និងស្នើសុំឱ្យមានការពិនិត្យមើលឡើងវិញលើសេចក្តីសម្រេចណាមួយដែលបានធ្វើឡើង។

## ផលប៉ះពាល់លើកម្ពុជា

ដំណើរការសម្រាប់ការលើកបញ្ហាដែលបានជួបប្រទះជាមួយមន្រ្តីគយមិនទាន់ត្រូវបានអនុវត្តក្នុងកម្រិតមួយដែលអាចបំពេញតាមតម្រូវការរបស់សកម្មភាពសេដ្ឋកិច្ចបច្ចុប្បន្នរបស់កម្ពុជាបាននោះទេ ដែលជាហេតុធ្វើឱ្យក្រុមហ៊ុនធុរកិច្ចមានអារម្មណ៍ថាធុរកិច្ចរបស់ខ្លួនគ្មានសន្តិសុខ ដោយហេតុថាក្រុមហ៊ុនធុរកិច្ចទាំងនោះយល់ឃើញថា សិទ្ធិរបស់ខ្លួនក្នុងការតវ៉ាលើការសម្រេចរបស់មន្រ្តីគយនៅមានកម្រិតនៅឡើយ។ ការកែលម្អស្ថានភាពនេះឱ្យមានដំណើរការល្អប្រសើរឡើងវិញ អាចបង្កើនទំនុកចិត្តរបស់វិនិយោគិនបច្ចុប្បន្ន និងអនាគតនៅក្នុងប្រទេសកម្ពុជា ព្រមទាំងអាចជួយធានាការអនុវត្តប្រកបដោយដោយយុត្តិធម៌ និងសង្គតភាពនូវ ច្បាប់ និងបទប្បញ្ញត្តិនានារបស់កម្ពុជាចំពោះគ្រប់ក្រុមហ៊ុនធុរកិច្ច និងគ្រប់កាលៈទេសៈទាំងអស់។

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ធ្វើបច្ចុប្បន្នភាពនីតិវិធីដែលវិស័យឯកជនអាចលើកបញ្ហា និងស្នើឱ្យពិនិត្យមើលឡើងវិញ លើសេចក្តីសម្រេចរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ។

យើងខ្ញុំសូមគោរពស្នើសុំឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ធ្វើបច្ចុប្បន្នភាពនីតិវិធីដែលធុរកិច្ចអាចលើកបញ្ហា និងស្នើឱ្យមានការពិនិត្យមើលឡើងវិញជាលក្ខណៈប្រព័ន្ធទៅលើសេចក្តីម្រេចរបស់មន្រ្តីគយ។ នីតិវិធីនេះនឹងអំណោយផលដល់គន្លងកំណើនសេដ្ឋកិច្ចកម្ពុជា និងភាពស្មុគស្មាញនៃសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួនដើម្បីធានា នូវការគ្រប់គ្រងកំណើនបរិមាណស្នើសុំយ៉ាងមានប្រសិទ្ធភាព និងប្រសិទ្ធផល។ លើសពីនេះទៅទៀត អគ្គនាយកដ្ឋានគយ និងរដ្ឋាករ គួរតែធ្វើការផ្សព្វផ្សាយនីតិវិធីនេះឱ្យបានទូលំទូលាយដល់មន្រ្តីគយ និងវិស័យឯកជនដើម្បីលើកកម្ពស់ការយល់ដឹងអំពីដំណើរការនេះ និងបង្កើនទំនុកចិត្តពីសំណាក់វិនិយោគិន។

# វិស័យយានយន្ត

សកម្មភាពតស៊ូមតិរបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាពាក់ព័ន្ធនឹងវិស័យយានយន្ត បានផ្តោតលើការគាំទ្រគំនិតផ្តួចផ្តើមរបស់សហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា (CAIF)។ កិច្ចសហការនេះបានជួយឱ្យសហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជាអាចក្លាយជាសំឡេងដ៏សំខាន់សម្រាប់ការពង្រីកបណ្តាញក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ពីរោងចក្រយានយន្តនៅកម្ពុជា ដោយសារតែសហព័ន្ធខិតខំលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ និងលើកទឹកចិត្តឱ្យមានបរិយាកាសប្រកួតប្រជែងស្មើភាពសម្រាប់គ្រប់ក្រុមហ៊ុនធុរកិច្ចទាំងអស់នៅក្នុងវិស័យនេះ។ សហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា បានចូលរួមបុរេសកម្មជាមួយនឹងរាជរដ្ឋាភិបាល ដោយសារតែសហព័ន្ធកំពុងធ្វើការងារឆ្ពោះទៅរកដំណោះស្រាយបញ្ហាដែលនឹងមានផលប៉ះពាល់មកលើក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ ជាពិសេស ការអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសម្រាប់ផលិតផលយានយន្តចំនួន ១៩ របស់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប (UNECE) ដូចមានចែងនៅក្នុងប្រកាសលេខ ១៥០។

ក្រោយពីមានកិច្ចប្រជុំពិភាក្សាជាច្រើនលើកដែលរៀបចំឡើងដំបូងដោយសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ហើយបន្ទាប់មកកិច្ចប្រជុំទាំងនេះត្រូវបានបន្តរៀបចំឡើងដោយសហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា យើងមានសេចក្តីសោមនស្សសូមរាយការណ៍ជូនថា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលស្គាល់អំពីកង្វល់តវ៉ារបស់វិស័យឯកជនដោយបានចេញប្រកាសលេខ ៩៩ ដើម្បីពន្យារពេលអនុវត្តប្រកាសលេខ ១៥០ ដែលបានពន្យារពេលរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។ ប្រកាសលេខ ៩៩ ដែលចេញនៅខែមីនា ឆ្នាំ២០១៩ក៏បានបង្កើនលក្ខខណ្ឌតម្រូវក្នុងការអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសម្រាប់ផលិតផលយានយន្តចំនួន ១៩ របស់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប (UNECE) ចំពោះក្រុមហ៊ុនធុរកិច្ចដែលចូលរួមក្នុងផលិតកម្ម ការបំលែង ការនាំចូល និងការលក់ផលិតផលយានយន្តនៅត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២០។ ទោះបីជាសេចក្តីលម្អិតអំពីកម្មវិធីអនុវត្តនឹងត្រូវកំណត់ជាចំដោយឡែកក្តី ក៏ប្រកាសលេខ ៩៩ ទទួលបានការស្វាគមន៍យ៉ាងទូលំទូលាយផងដែរ ដោយសារតែប្រកាសនេះផ្តល់សញ្ញាដល់វិស័យនេះថា

បទប្បញ្ញត្តិរបស់ សហគមន៍សេដ្ឋកិច្ចអឺរ៉ុប (UNECE) អាចនឹងអនុវត្តសម្រាប់គ្រប់យានយន្តទាំងអស់ដែលនាំចូលមកក្នុងប្រទេសកម្ពុជា។ ដោយទទួលស្គាល់ថាកំណែទម្រង់នេះនឹងចំណាយពេលវេលា និងធនធានច្រើនដើម្បីសម្រេចបានជោគជ័យ ប្រកាសលេខ ៩៩ ពិតជាបានលើកទឹកចិត្តដល់ក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ដូចមានលើកឡើងនៅក្នុងសៀវភៅ ស លើកមុនរបស់យើងហើយថា បរិយាកាសធុរកិច្ចនៅក្នុងប្រទេសកម្ពុជាមានស្ថានការណ៍កាន់តែលំបាកខ្លាំងឡើងសម្រាប់ក្រុមហ៊ុនធុរកិច្ចក្នុងវិស័យនេះរក្សាសមត្ថភាពប្រកួតប្រជែងរបស់ខ្លួននៅលើទីផ្សារ។ ជាការពិតណាស់ បញ្ហាប្រឈមផ្នែកនិយ័តកម្មដែលមានមិនចេះឈប់ឈរសម្រាប់វិស័យនេះគឺជាកាតាលីករនៃការដកខ្លួនចេញនាពេលថ្មីៗនេះរបស់ក្រុមហ៊ុនចែកចាយយានយន្តអឺរ៉ុបដ៏ល្បីល្បាញ និងមានបទពិសោធន៍ច្រើនចេញពីទីផ្សារកម្ពុជា។

ដោយធ្វើការពិចារណាលើការវិវត្តនេះ អនុសាសន៍នៅឆ្នាំនេះ យើងសូមស្នើបំពេញបន្ថែមទៀតទៅលើការយល់ដឹងដែលមាននៅក្នុងសៀវភៅ ស លើកមុនរបស់យើង រួមទាំង មតិយោបល់ជាច្រើនក្នុងការបង្កើនគុណភាព និងសុវត្ថិភាពវិស័យយានយន្ត ព្រមទាំងការលើកកម្ពស់ភាពប្រកួតប្រជែង និងភាពទាក់ទាញរបស់វិស័យនេះ នៅក្នុងទស្សនវិស័យវិនិយោគផងដែរ។ អនុសាសន៍ទីមួយរបស់យើងសូមស្នើឱ្យមានការប្តេជ្ញាចិត្តផ្លូវការដែលប្រការចែង នៅក្នុងប្រកាសលេខ ៩៩ តម្រូវឱ្យធុរកិច្ចយានយន្តទាំងអស់ត្រូវអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសម្រាប់ផលិតផលយានយន្តចំនួន ១៩បទប្បញ្ញត្តិរបស់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប (UNECE) នឹងត្រូវរក្សាទុក និងអនុវត្តជាសកលជាជាងគ្រាន់តែអនុវត្តលើយានយន្តថ្មីដែលក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់បាននាំចូលនោះ។ ការណ៍នេះនឹងធានាថាក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់នឹង មិនជាប់បន្ទុកដោយមិនស្មើភាពគ្នាតាមរយៈការដាក់ឱ្យប្រើប្រាស់ស្តង់ដារតឹងរ៉ឹងជាងមុន ហើយនឹងមិនបង្កើតឱ្យមានប្រព័ន្ធនិយ័តកម្មពីរដាច់ដោយឡែកពីគ្នាសម្រាប់វិស័យដូចគ្នា។ សំខាន់ជាងនេះទៅទៀត បទប្បញ្ញត្តិទាំងនោះនឹងមានផលប៉ះពាល់យ៉ាង ច្រើនដល់ការលើកកម្ពស់សុវត្ថិភាព ប្រសិនបើ

អនុវត្តបទប្បញ្ញត្តិទាំងអស់នោះលើគ្រប់យានយន្តទាំងអស់។ អាស្រ័យហេតុនេះ យើងខ្ញុំសូមផ្តល់ជូនអនុសាសន៍ថាប្រកាសលេខ ១៥០ គួរតែអនុវត្តចំពោះគ្រប់យានយន្តទាំងអស់ដែលនាំចូលមកកម្ពុជា ហើយចំពោះក្រុមហ៊ុនចែកចាយដែលមិនអាចអនុវត្តតាមប្រកាសនេះ នឹងត្រូវហាមឃាត់មិនឱ្យនាំចូលយានយន្តទៀតឡើយ គិតចាប់ពីថ្ងៃប្រកាសលេខ ១៥០ នេះបានចូលជាធរមាន។

អនុសាសន៍បន្ទាប់របស់យើងគឺសូមស្នើឱ្យពង្រីក ប្រធានបទនៃការពង្រឹងកិច្ចការពារអ្នកប្រើប្រាស់តាមរយៈការសម្របសម្រួលការដាក់ឱ្យប្រើប្រាស់នូវដំណើរការប្រមូលទិញផលិតផលមកវិញសម្រាប់គ្រប់យានយន្តទាំងអស់។ យើងសូមទទួលស្គាល់ថាក្រសួងសាធារណការ និងដឹកជញ្ជូនបានអនុវត្តគំនិតផ្តួចផ្តើមយ៉ាងសំខាន់ៗជាច្រើនរួចមកហើយ ដើម្បីដោះស្រាយបញ្ហាសុវត្ថិភាពយានយន្ត ជាពិសេសបំផុតនោះគឺតាមរយៈការកែលម្អ និងការបង្កើនការត្រួតពិនិត្យយានយន្ត។ ទោះបីយ៉ាងនេះក្តី យើងសង្កេតឃើញថា កម្ពុជានៅមានកង្វះខាតមធ្យោបាយមានសុវត្ថិភាពសម្រាប់ពាងចក្រផលិតរថយន្តក្នុងការជូនដំណឹងដល់ម្ចាស់រថយន្តប្រសិនបើមានបញ្ហាទាក់ទងជាមួយនឹង សុវត្ថិភាពកើតឡើងលើរថយន្តដែលពួកគេបានទិញប្រើប្រាស់។ ទោះបីជាយានយន្តយ៉ាងច្រើនសន្ធឹកសន្ធាប់នៅកម្ពុជាត្រូវបាននាំចូលដោយក្រុមហ៊ុនមិនមានសិទ្ធិស្របច្បាប់ក្តី ក៏ក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ត្រូវទទួល ខុសត្រូវចំពោះការអនុវត្តវិធានការសេវា ដែលកែសម្រួលបញ្ហាសុវត្ថិភាព ទោះបីជាក្រុមហ៊ុនចែកចាយទាំងនោះមិនអាចបំពេញការងារទាំងនោះបាន ដោយសារតែមិនបានដឹងច្បាស់ថាតើមានយានយន្តអ្វីខ្លះនៅក្នុងប្រទេសនេះក៏ដោយ។

អនុសាសន៍ចុងក្រោយរបស់យើងគឺសូមបង្ហាញជូនរាជរដ្ឋាភិបាលអំពីរបៀបធ្វើសនិទានកម្មគោលនយោបាយសារពើពន្ធលើយានយន្តដើម្បីប្រមូលចំណូលឱ្យបានកាន់តែច្រើនលើរយៈពេលប្រើប្រាស់ទាំងមូលរបស់យានយន្តថ្មី រួមទាំងអត្ថប្រយោជន៍បន្ថែមនៃការលើកទឹកចិត្តឱ្យសាធារណជន ទិញយានយន្តមានសុវត្ថិភាពនិងមិនប៉ះពាល់ដល់បរិស្ថានផងដែរ។ គោលនយោបាយសារពើពន្ធដែលមាន

ស្រាប់លើយានយន្តនៅកម្ពុជា លើកទឹកចិត្តយ៉ាងខ្លាំងដល់ការទិញយានយន្តប្រើរួចជាជាងយានយន្តថ្មី ដោយសារតែពន្ធគយសរុបសម្រាប់ការនាំចូលយានយន្តដឹកអ្នកដំណើរថ្មីពីក្រៅតំបន់អាស៊ានអាចកើនដល់ ១៥១% នៃតម្លៃយានយន្ត ដែលធ្វើឱ្យតម្លៃយានយន្តហួសពីលទ្ធភាពទិញសម្រាប់ប្រជាជនកម្ពុជាជាច្រើន។ ផ្ទុយទៅវិញប្រសិនបើធ្វើការកែសម្រួលប្រព័ន្ធសារពើពន្ធរបស់កម្ពុជាដោយដំឡើងពន្ធលើយានយន្តប្រើប្រាស់រួច ឬហាមឃាត់ការនាំចូលរថយន្តប្រើប្រាស់រួចទាំងស្រុងវិញនោះ អ្នកប្រើប្រាស់នឹងងាកមកប្រើប្រាស់យានយន្តថ្មីជំនួសវិញ ហើយទន្ទឹមនឹងនោះក៏បានរឹតបន្តឹងមិនឱ្យមានយានយន្តចាស់ៗ មិនមានសុវត្ថិភាព និងដែលប៉ះពាល់ដល់បរិស្ថានច្រើននៅកម្ពុជា។

នៅក្នុងជំពូកនេះចាប់ពីដើមរហូតដល់ចប់ យើងសូមជម្រាបជូនថា សមាជិករបស់យើងដែលជាតំណាងបណ្តាញក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់កំពុងមានការរីកចម្រើននេះ បានវិនិយោគយ៉ាងច្រើនសន្ធឹកសន្ធាប់រួចទៅហើយទៅលើទីតាំងរោងចក្ររបស់ខ្លួន និងមានឆន្ទៈវិនិយោគខ្ពស់ជាងព្រមទាំងមានបំណងបន្តការប្តេជ្ញាចិត្តរបស់ខ្លួននៅក្នុងការអភិវឌ្ឍវិស័យយានយន្តតាមរយៈការបង្កើនការវិនិយោគបន្ថែមទៀតនៅកម្ពុជា។ ទោះបីយ៉ាងណាក៏ដោយកត្តានេះអាចកើតឡើយបាន លុះត្រាតែក្រុមហ៊ុនទាំងនោះអាចបង្ហាញប្រាប់ក្រុមហ៊ុនមេរបស់ខ្លួនថាវិស័យយានយន្តនៅកម្ពុជាអាចមានប្រាក់ចំណេញច្រើនសម្រាប់ក្រុមហ៊ុន ហើយការអនុវត្តក្របខ័ណ្ឌច្បាប់គឺមានភាពយុត្តិធម៌និងមានសង្គតិភាពសម្រាប់ក្រុមហ៊ុនទាំងអស់។

# ២៥

# ការអនុវត្តស្តង់ដារសុវត្ថិភាពរបស់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប (UNECE)

ធ្វើបច្ចុប្បន្នភាព

---

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើឱ្យអនុវត្តវិធានការនិយ័តកម្មនានាដើម្បីទប់ស្កាត់ការនាំចូលរថយន្តដែលមិនសមស្របសម្រាប់បរិស្ថានកម្ពុជា។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានចេញប្រកាសលេខ ៩៩ ដើម្បីពន្យារពេលការអនុវត្តប្រកាសលេខ ១៥០ ស្តីពីបទប្បញ្ញត្តិបច្ចេកទេសសម្រាប់ផលិតផលយានយន្តចំនួន ១៩ របស់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប (UNECE) សម្រាប់ផលិតផលយានយន្តចាប់ពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។ សំខាន់ជាងនេះទៅទៀត ប្រកាសនេះបានពង្រីកលក្ខខណ្ឌតម្រូវក្នុងការអនុវត្តតាមប្រកាសលេខ ១៥០ ចំពោះក្រុមហ៊ុនធុរកិច្ចដែលចូលរួមក្នុងផលិតកម្ម ការកែច្នៃ ការនាំចូល និងការលក់ផលិតផលយានយន្តដោយបានលើកឡើងថាគ្រប់ក្រុមហ៊ុនធុរកិច្ចទាំងអស់ត្រូវចាប់ផ្តើមអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសម្រាប់ផលិតផលយានយន្តចំនួន ១៩ របស់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប (UNECE) ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០។*

---

**ពិពណ៌នាបញ្ហា**

*សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា និងសហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា (CAIF) បានសាទរចំពោះការចេញប្រកាសប្រកាសលេខ ១៥០ នៅខែមិថុនា ឆ្នាំ២០១៦ ដោយវិទ្យាស្ថានស្តង់ដារកម្ពុជា នៅក្រោមចំណុះរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដែលជាវិធានការវិជ្ជមានក្នុងការលើកកម្ពស់សុវត្ថិភាពយានយន្តនៅតាមដងផ្លូវ ព្រមទាំងកិច្ចការពារអ្នកប្រើប្រាស់ផងដែរ។ ដំបូងឡើយ ក្រុមហ៊ុនមានសិទ្ធិចែកចាយយានយន្តស្របច្បាប់ទទួលបានដំណឹងថា ប្រកាសលេខ ១៥០ នឹងអនុវត្តតែចំពោះយានយន្តថ្មីប៉ុណ្ណោះដែលនាំចូលមកប្រទេសកម្ពុជា ចំណែកយានយន្តប្រើរួចដែលនាំចូលនឹងត្រូវលើកលែងការអនុវត្តវិធាននេះ។ ដោយសារតែយានយន្តថ្មីសរុបមានចំនួនប្រមាណជាតិចជាង ១០% នៃចំនួនយានយន្តនាំចូលសរុប កត្តានេះនឹងបង្កើតបរិយាកាសប្រកួតប្រជែងមិនស្មើភាពគ្នាសម្រាប់យានយន្តថ្មី បង្កើនថ្លៃចំណាយក្នុងការធ្វើធុរកិច្ចសម្រាប់ក្រុមហ៊ុននាំចូលយានយន្តថ្មី និងបាត់បង់ឱកាសក្នុងការលើកកម្ពស់គុណភាពយានយន្តនៅលើដងផ្លូវកម្ពុជាដោយសារតែការអនុវត្តដោយផ្នែក។*

*ជាសំណាងល្អ ក្រោយពីមានការចូលរួមច្រើនជាមួយរាជរដ្ឋាភិបាល ពិសេសពីសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ហើយបន្ទាប់មក បន្តដោយសហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានចេញប្រកាសលេខ ៩៩ នៅខែមីនា ឆ្នាំ២០១៩ ដើម្បីពន្យារពេលការអនុវត្តប្រកាសលេខ ១៥០ រហូតដល់*

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។ ប្រកាសនេះក៏ចែងថាធុរកិច្ចដែលចូលរួមក្នុងផលិតកម្មការកែច្នៃ ការនាំចូល និងការលក់ផលិតផលយានយន្ត ត្រូវអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសម្រាប់ផលិតផលយានយន្តចំនួន ១៩ របស់ សហគមន៍សេដ្ឋកិច្ចអឺរ៉ុប (UNECE)។ ទោះបីជាកម្មវិធីអនុវត្តសំរាប់បង្ហាញពីអនុលោមភាពនឹងកំណត់ដោយសេចក្តីប្រកាសដាច់ដោយឡែកក៏ដោយ ក៏ប្រកាសលេខ ៩៩ ទទួលបានស្វាគមន៍យ៉ាងទូលំទូលាយពីវិស័យនេះ ដោយសារតែប្រកាសនេះបានបង្ហាញថាបទប្បញ្ញត្តិរបស់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប (UNECE) នឹងត្រូវអនុវត្តជាសកលសម្រាប់គ្រប់យានយន្តទាំងអស់ដែលនាំចូលមកកាន់ប្រទេសកម្ពុជា។

ទោះបីយ៉ាងណា ដោយសារតែការនាំចូលយានយន្តថ្មីដោយអ្នកលក់ក្នុងទីផ្សារលួចលាក់ និងទីផ្សារប្រផេះ ក៏មិនត្រូវបានរឹតបន្តឹងផងដែរនោះ នៅតែមានភាពមិនទាន់ច្បាស់នៅឡើយថាស្តង់ដារទាំងនេះអាចអនុវត្តបានប្រកបដោយសង្គតិភាពចំពោះយានយន្តនាំចូលទាំងអស់ដើម្បីកុំឱ្យមានឧបសគ្គតែចំពោះក្រុមហ៊ុនមានសិទ្ធិចែកចាយយានយន្តស្របច្បាប់។ ស្របគ្នានេះដែរ មិនមានការព្រមព្រៀងលើការកំណត់និយមន័យណាមួយថាតើយានយន្តថ្មីមានន័យដូចម្តេចនៅពេលត្រូវបានលក់ដោយអ្នកចែកចាយដែលមិនមានសិទ្ធិស្របច្បាប់ ដោយសារតែអគ្គនាយកដ្ឋានគយ និង រដ្ឋាករយល់ឃើញថាទាំងរថយន្តស៊េរីឆ្នាំបច្ចុប្បន្ន និងស៊េរីឆ្នាំបន្ទាប់គឺជាយានយន្តថ្មីសម្រាប់គោលបំណងគិតពន្ធ។

## ផលប៉ះពាល់លើកម្ពុជា

ទោះបីគោលបំណងល្អនៃការអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសម្រាប់ផលិតផលយានយន្តចំនួន ១៩ របស់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប (UNECE) គឺដើម្បី "ធ្វើឱ្យផលិតផលយានយន្តមានសុវត្ថិភាព និងបង្ការភាពមហន្តរាយដែលប៉ះពាល់ មនុស្ស បរិស្ថាន និងសង្គម" ក៏ដោយ ក៏បទប្បញ្ញត្តិទាំងនោះនឹងមានផលប៉ះពាល់ជាក់ស្តែងតិចតួចប៉ុណ្ណោះ ប្រសិនបើបទប្បញ្ញត្តិនេះអនុវត្តដោយផ្តេកចំពោះតែយានយន្តថ្មីដែលបាននាំចូលដោយក្រុមហ៊ុនចែកចាយមានសិទ្ធិស្របច្បាប់ ដោយសារតែយានយន្តទាំងនេះមានចំនួនមិនដល់ ១០% ផងនៃយានយន្តសរុបដែលបើកបរនៅលើដងផ្លូវកម្ពុជា។ ជាគោលការណ៍ ការអនុវត្តបែបនេះនឹងបង្កើតឱ្យមានប្រព័ន្ធនិយ័តកម្មដាច់ដោយឡែកពីគ្នាពីរសម្រាប់វិស័យតែមួយ ហើយនឹងបង្កើតបន្ទុកមិនស្មើភាពគ្នាចំពោះក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ដែលបានវិនិយោគច្រើនសន្ធឹកសន្ធាប់លើការបង្កើតទីតាំងក្រុមហ៊ុនរបស់ខ្លួននៅកម្ពុជារួចទៅហើយ។ ដោយសារតែកម្ពុជាមិនមានការរឹតបន្តឹងការនាំចូលយានយន្តមានតែប្រទេសសមាជិកអាស៊ាន ប៉ុណ្ណោះដែលអនុញ្ញាតឱ្យនាំចូលយានយន្តប្រើរួចដោយមិនមានការកម្រិតអ្វីទាំងអស់ដែលនេះ មានន័យថា បញ្ហាប្រឈមនៅក្នុងការអនុវត្តបទប្បញ្ញត្តិទាំងនេះសម្រាប់ការនាំចូលយានយន្តទាំងអស់គឺមានលក្ខណៈពិសេសសម្រាប់តែកម្ពុជា។

ប្រសិនបើបទប្បញ្ញត្តិទាំងនេះអនុវត្តបានឯកសណ្ឋានភាពបាន ១០០% លើគ្រប់យានយន្តទាំងអស់ដែលនាំចូលក្រោយកាលបរិច្ឆេទអនុវត្តនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ នោះបទប្បញ្ញត្តិទាំងនោះនឹងកាន់តែមានប្រសិទ្ធភាពខ្លាំងឡើង ក្នុងការទប់ស្កាត់មិនឱ្យមានយានយន្តដែលមិនសមស្របសម្រាប់បរិស្ថានរបស់កម្ពុជា

*ហើយធានាថាមានតែយានយន្តមានសុវត្ថិភាព និងអាចទុកចិត្តបានប៉ុណ្ណោះដែលដាក់លក់នៅលើទីផ្សារកម្ពុជា។ ការរឹងបន្តឹងឱ្យនាំចូលតែយានយន្តដែលអនុវត្តតាមស្តង់ដារអន្តរជាតិ នឹងនាំឱ្យយានយន្តនៅលើដងផ្លូវកម្ពុជាកាន់តែល្អប្រសើរ និងមានសុវត្ថិភាពខ្ពស់ជាងមុន ព្រមទាំងចូលរួមចំណែកសម្រេចគោលបំណងរបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកកម្ពុជា ដើម្បីកាត់បន្ថយចំនួនអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ឱ្យបាន ៥០% នៅត្រឹមឆ្នាំ២០២០។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យធានាថាប្រកាសលេខ ១៥០ នឹងត្រូវអនុវត្តជាសកលសម្រាប់គ្រប់យានយន្តទាំងអស់ដែលនាំចូលមកកាន់ប្រទេសកម្ពុជាដោយស្របតាមប្រកាសលេខ ៩៩។

*ដើម្បីសម្រេចបាននូវអត្ថប្រយោជន៍ទាំងនេះ យើងខ្ញុំសូមគោរពស្នើឱ្យរាជរដ្ឋាភិបាលធានាថាវិញ្ញាបនបត្រយានយន្ត និងស្តង់ដារសុវត្ថិភាពដែលមានចែងនៅក្នុងប្រកាសលេខ ១៥០ នឹងត្រូវអនុវត្តសម្រាប់គ្រប់យានយន្តទាំងអស់ ទាំងយានយន្តថ្មី និងប្រើរួច ដើម្បីធានានូវបរិយាកាសប្រកួតប្រជែងសម្រាប់ក្រុមហ៊ុនចែកចាយយានយន្តទាំងអស់ដោយស្របតាមប្រកាសលេខ ៩៩។ លើសពីនេះ ទៅទៀត យើងខ្ញុំសូមគោរពផ្តល់ជូននូវអនុសាសន៍ឱ្យមានការហាមឃាត់ការនាំចូលយានយន្តដែលមិនអាចបង្ហាញ អនុវត្តតាមស្តង់ដារអនុវត្ត ចាប់ពីថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០១៩ តទៅ ដោយសារតែកត្តានេះនឹងជួយទប់ស្កាត់យ៉ាងមានប្រសិទ្ធភាពនូវការនាំចូលយានយន្តដែលរងការខូចខាតដោយទឹកជំនន់ យានយន្តដែលត្រូវបានលួច យានយន្តដែលលែងអាចធានារ៉ាប់រងបាន និងដែលមានលក្ខខណ្ឌគ្រោះថ្នាក់ផ្សេងទៀត ដែលនាំឱ្យមានរថយន្តមិនមានសុវត្ថិភាពធ្វើចរាចរណ៍នៅលើដងផ្លូវ។ តាមរយៈការអនុវត្តអនុសាសន៍ទាំងនេះក្នុងពេលតែមួយ រាជរដ្ឋាភិបាលនឹងលើកកម្ពស់ភាពប្រកួតប្រជែង និងការទាក់ទាញវិស័យយានយន្តនៅកម្ពុជាបានច្រើនក្នុងន័យទស្សនៈវិនិយោគ ហើយទន្ទឹមនឹងនោះ ក៏លើកកម្ពស់គុណភាព និងសុវត្ថិភាពយានយន្តនៅលើដងផ្លូវកម្ពុជាផងដែរ។*

២៦

# អនុញ្ញាតឱ្យក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់អនុវត្តវិធានសេវាកម្ម និងការប្រមូលយានយន្តត្រឡប់មកវិញ

ធ្វើបច្ចុប្បន្នភាព

---

## អនុសាសន៍ឆ្នាំ ២០១៧

សូមស្នើឱ្យនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកធ្វើការជូនដំណឹងដល់ក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់អំពីព័ត៌មានទំនាក់ទំនងសម្រាប់ការចុះបញ្ជីយានយន្តថ្មី ឬការផ្ទេរសិទ្ធិយានយន្តប្រើរួចក្នុងមួយត្រីមាសម្តងដើម្បីជួយសម្រួលដល់ការប្រមូលផលិតផលមកវិញ។

## ការឆ្លើយតបផ្នែកគោលនយោបាយ

*ក្រសួងសាធារណការ និងដឹកជញ្ជូនបានអនុវត្តគំនិតផ្តួចផ្តើមជាច្រើនក្នុងការដោះស្រាយបញ្ហាលើការប្រើប្រាស់យានយន្តមិនមានសុវត្ថិភាពនៅកម្ពុជា។ គំនិតផ្តួចផ្តើមទាំងនេះ រួមមាន ការពង្រីកការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តចល័តដល់គ្រប់ខេត្តទាំងអស់ ការដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មតាមប្រព័ន្ធអ៊ីនធឺណិតសម្រាប់ការចុះបញ្ជីការត្រួតពិនិត្យយានយន្ត និងការសហការយ៉ាងទូលំទូលាយជាមួយនឹងទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ដើម្បីលើកកម្ពស់ស្តង់ដារត្រួតពិនិត្យយានយន្ត។ កម្មវិធីទំនើបកម្ម និងកែលម្អនេះទទួលបានការកោតសរសើរ និងបង្ហាញអំពីបំណងរបស់រាជរដ្ឋាភិបាលក្នុងការបង្កើនស្តង់ដារយានយន្តនៅលើដងផ្លូវកម្ពុជា។ ទោះបីយ៉ាងណាក៏ដោយ ដោយសារតែក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ត្រូវទំនួលខុសត្រូវទាំងស្រុងក៏ការអនុវត្តការប្រមូលផលិតផលមកវិញក្នុងហេតុផលសុវត្ថិភាពដែលជាកាតព្វកិច្ចរបស់ក្រុមហ៊ុនផលិត ទើបក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ទាំងនោះត្រូវការមធ្យោបាយមានប្រសិទ្ធភាពក្នុងការជូនដំណឹងដល់ម្ចាស់យានយន្ត ក្នុងករណីមានបញ្ហាទាក់ទងជាមួយសុវត្ថិភាពកើតឡើង។*

---

## ពិពណ៌នាបញ្ហា

*ក្រុមហ៊ុនផលិតយានយន្តលំដាប់ពិភពលោកនីមួយៗ សុទ្ធតែមានកម្មវិធីតាមដានគុណភាពផលិតផលយ៉ាងតឹងរ៉ឹង រួមមាន ការតាមដានបញ្ហាទាក់ទងនឹងសុវត្ថិភាពក្រោយពេលផលិត និងក្រោយពេលលក់។ នេះគឺជាការអនុវត្តទូទៅសម្រាប់ក្រុមហ៊ុនផលិតក្នុងការចេញសេចក្តីប្រកាស "ប្រមូល ផលិតផលមកវិញ" ដែលមានន័យថាជាសេចក្តីប្រកាសអំពីបញ្ហាទាក់ទងនឹងសុវត្ថិភាព ដែលកិច្ចការនេះត្រូវកំណត់អត្តសញ្ញាណយានយន្តដែលមានបញ្ហា និងជូនដំណឹងដល់អ្នកប្រើប្រាស់ឱ្យយកយានយន្តត្រឡប់មកកាន់យានដ្ឋានរបស់ក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ដើម្បីធ្វើការជួសជុល។ ជាធម្មតាក្រុមហ៊ុននាំចូល និងក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ជាអ្នកទទួលខុសត្រូវក្នុងការជូនដំណឹងដល់អតិថិជន។ សម្រាប់ការអនុវត្តជាស្តង់ដារ ក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ ត្រូវធ្វើការត្រួតពិនិត្យយានយន្តនីមួយៗ ដែលគេយកមកយានដ្ឋានរបស់ខ្លួនដើម្បីបញ្ជាក់ឱ្យបានច្បាស់ថាតើចាំបាច់មានវិធានការផ្តល់សេវាបន្ទាន់ណាមួយ ឬត្រូវធ្វើភ្លាមៗដែរឬទេ។ រីឯថ្លៃសេវាជួសជុល ថ្លៃកម្លាំងពលកម្ម និងគ្រឿងបន្លាស់ ជាទូទៅគឺជាបន្ទុករ៉ាប់រងរបស់ក្រុមហ៊ុនផលិត ពោលគឺមិនមែនជាបន្ទុករបស់ម្ចាស់យានយន្តឡើយ។*

*ប៉ុន្តែ ដោយសារតែយានយន្តមួយចំនួនធំទាំងថ្មី និងប្រើរួចដែលនាំចូលដោយអ្នកមិនមានសិទ្ធិចែកចាយស្របច្បាប់ ដូច្នេះ ក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ មិនអាចដឹងថាមានយានយន្តអ្វីខ្លះដែលកំពុងមាននៅក្នុងប្រទេសកម្ពុជាឡើយ ដែលជាហេតុមិនអាចផ្តល់ការជូនដំណឹងឱ្យបានទាន់ពេលវេលាដល់អ្នកប្រើប្រាស់បានក្នុងករណីដែលយានយន្តម៉ាកណាមួយជាយានយន្តដែលក្រុមហ៊ុនផលិតបានប្រកាសអនុវត្តវិធានសេវាកម្ម និងការប្រមូលត្រឡប់មកវិញ។*

**ផលប៉ះពាល់លើកម្ពុជា**

*ការខកខានមិនបានចាត់វិធានការផ្តល់សេវាកម្ម មានន័យថា យានយន្តមានបញ្ហាអាចនៅតែបន្តធ្វើចរាចរនៅលើដងផ្លូវ ហើយជាបញ្ហាមួយដែលផ្តល់ផលប៉ះពាល់ធ្ងន់ធ្ងរដល់សុវត្ថិភាពរបស់អ្នកប្រើប្រាស់។ ប្រសិនបើពុំមានមធ្យោបាយជូនដំណឹងដល់ម្ចាស់យានយន្តអំពីការប្រមូលត្រឡប់មកវិញទេនោះ អ្នកប្រើប្រាស់អាចមិនដឹងថាយានយន្តរបស់ខ្លួនមានបញ្ហា និងអាចមិនមានសុវត្ថិភាពឡើង។ ផ្តើមចេញពីទស្សនវិស័យធុរកិច្ចក្រុមហ៊ុនផលិត និងក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ដែលបានវិនិយោគក្នុងទីផ្សារកម្ពុជានឹងធានានូវការលើកស្ទួយកេរ្តិ៍ឈ្មោះ និងទំនួលខុសត្រូវរបស់ម៉ាក និងផលិតផលរបស់ខ្លួន ដោយសារតែដំណើរការប្រមូលផលិតផលត្រលប់មកវិញមានប្រសិទ្ធភាពនឹងអាចឱ្យខ្លួនដោះស្រាយបញ្ហាដែលផលិតផលរបស់ខ្លួនអាចមានបានឆាប់រហ័ស។*

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកផ្តល់លេខអត្តសញ្ញាណយានយន្តនៃយានយន្តដែលបានចុះបញ្ជីដល់ក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ក្នុងមួយត្រីមាសម្តងដើម្បីឱ្យក្រុមហ៊ុន អាចធ្វើការជូនដំណឹងដល់នាយកដ្ឋាន ក្នុងករណីដែលមានការប្រមូលផលិតផលត្រលប់មកវិញ។

*យើងខ្ញុំទទួលស្គាល់ថា អាចមានការព្រួយបារម្ភពីបញ្ហាឯកជនភាពពាក់ព័ន្ធនឹងការចែករំលែកព័ត៌មានរបស់ម្ចាស់យានយន្ត ស្រដៀងគ្នានេះដែរ នាយកដ្ឋានដឹកជញ្ជូនផ្លូវគោកក្រោមចំណុះរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន អាចមិនមានបំណងផ្តល់ព័ត៌មានរសើបនេះដល់ក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ ក្នុងករណីដែលក្រុមហ៊ុនចែកចាយទាំងនោះមិនទទួលខុសត្រូវចំពោះការលក់របស់ខ្លួនទេនោះ។ ដូច្នេះ យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យនាយកដ្ឋានផ្តល់លេខអត្តសញ្ញាណយានយន្ត (VIN) នៃយានយន្តដែលបានចុះបញ្ជីក្នុងមួយត្រីមាសម្តង ដោយសារតែលេខអត្តសញ្ញាណយានយន្តគឺជាព័ត៌មានមិនបញ្ចេញអត្តសញ្ញាណ ហើយជាលេខអត្តសញ្ញាណពិសេសខុសប្លែកគ្នាដែលរោងចក្រផលិតយានយន្តអាចប្រើដើម្បីកំណត់អត្តសញ្ញាណយានយន្តនីមួយៗ។ ក្រោយពីទទួលព័ត៌មាននេះ ក្រុមហ៊ុនមានសិទ្ធិចែកចាយស្រប*

ច្បាប់អាចជូនដំណឹងដល់នាយកដ្ឋានក្នុងករណីដែលយានយន្តណាមួយត្រូវតម្រូវឱ្យប្រមូលត្រឡប់មកវិញ ហើយនឹងអាចឱ្យនាយកដ្ឋានធ្វើការទាក់ទងម្ចាស់យានយន្តដែលបានចុះបញ្ជីនោះ ឱ្យយកយានយន្តរបស់ខ្លួនទៅកាន់ក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ដើម្បីធ្វើការជួសជុល។ ទោះបីជាការធ្វើបែបនេះនឹងធ្វើឱ្យនាយកដ្ឋានមានបន្ទុកការងារច្រើនថែមទៀតក្តី ប៉ុន្តែនេះគឺនេះជាដំណើរការដើម្បីធានាសុវត្ថិភាព និងគុណភាពរបស់យានយន្តដែលកំពុងប្រើនៅកម្ពុជា ហើយទន្ទឹមនឹងនោះ ក៏គោរពឯកជនភាពរបស់ម្ចាស់យានយន្តបានផងដែរ។

២៧

# ការធ្វើវិចារណកម្មគោលនយោបាយសារពើពន្ធ

ធ្វើបច្ចុប្បន្នភាព

**ពិពណ៌នាបញ្ហា** បច្ចុប្បន្ន វិស័យយានយន្តនៅកម្ពុជា បែងចែកការនាំចូលយានយន្តជាបីប្រភេទ៖

១. យានយន្តថ្មីដែលនាំចូលដោយក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់៖ យានយន្តទាំងនេះត្រូវបាននាំចូលដោយប្រើវិក្កយបត្រពីរោងចក្រផលិត។ គិតចាប់ពីថ្ងៃ១៥ ខែមិថុនា ឆ្នាំ២០១៩ តទៅ យានយន្តទាំងនេះនឹងត្រូវអនុវត្តតាមស្តង់ដាររបស់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប (UNECE) ដែលប្រកាសឱ្យប្រើប្រាស់ដោយវិទ្យាស្ថានស្តង់ដារ ក្រោមចំណុះរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

២. យានយន្តថ្មីដែលនាំចូលដោយក្រុមហ៊ុនមិនមានសិទ្ធិស្របច្បាប់ ហៅម្យ៉ាងទៀតថា "ការនាំចូលលួចលាក់"៖ យានយន្តទាំងនេះត្រូវបានទិញពីក្រុមហ៊ុនចែកចាយនៅក្រៅប្រទេសកម្ពុជា ហើយតម្លៃដែលបានប្រកាស ជាធម្មតាផ្អែកលើតារាងតម្លៃបានវាយតម្លៃដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករបានរក្សាអនុវត្ត។ ដោយបានផលិតសម្រាប់ផ្គត់ផ្គង់ទីផ្សារប្រទេសផ្សេង យានយន្តទាំងនេះអាចមិនបំពេញតាមស្តង់ដារដែលបានប្រកាសដោយវិទ្យាស្ថានស្តង់ដារឡើយ ហើយអាចមិនសមស្របសម្រាប់អាកាសធាតុ ប្រេងឥន្ធនៈ និងស្ថានភាពផ្លូវនៅកម្ពុជាឡើយ។

៣.យានយន្តប្រើរួច៖ យានយន្តទាំងនេះត្រូវបានទិញនៅក្រៅប្រទេស ហើយនាំចូលមកកម្ពុជា ប៉ុន្តែតម្លៃយានយន្តទាំងនោះត្រូវវាយតម្លៃតាមតារាងតម្លៃរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ។ គេមិនអាចធានាពីស្ថានភាពយានយន្តទាំងនេះបាននោះទេ។ ក្រុមហ៊ុនមានសិទ្ធិចែកចាយស្របច្បាប់ជាទូទៅបានមើលឃើញថាយានយន្តប្រើប្រាស់រួចទាំងនោះ ជាយានយន្តធ្លាប់ទទួលរងគ្រោះថ្នាក់ចរាចរណ៍ ខូចខាតច្រើន ឬជារថយន្តដែលត្រូវបានលួច។ យានយន្ត ប្រើប្រេងម៉ាស៊ូតនាំចូលដែលត្រូវបានរចនាឡើងដើម្បីប្រើប្រេងម៉ាស៊ូតដែលមិនមានលក់នៅក្នុងកម្ពុជាមានប្រើប្រាស់ជាទូទៅនៅកម្ពុជា ហើយយានយន្តទាំងនេះមានបញ្ហាគ្រឿងម៉ាស៊ីន និងប្រព័ន្ធភ្លើងជាញឹកញាប់។ អ្នកប្រើប្រាស់ មិនទទួលបានការធានាចំពោះសុវត្ថិភាព ឬការជឿជាក់ទៅលើយានយន្តទាំងនោះទេ ។យើងលំបាកក្នុងការកំណត់ថាតើយានយន្តទាំងនោះបានបំពេញតាមស្តង់ដារសុវត្ថិភាពរបស់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប (UNECE) ដែលត្រូវបានអនុវត្តនៅកម្ពុជាដែរឬយ៉ាងណា។

អគ្គនាយកដ្ឋានគយ និងរដ្ឋាករបានអនុវត្តពន្ធគយ និងអាករលើយានយន្តនាំចូលទាំងអស់ដោយប្រើវិក្កយបត្រពីរោងចក្រសម្រាប់យានយន្តប្រភេទទី ១ ខាងលើ ឬតម្លៃដែលបានកំណត់សម្រាប់យានយន្តប្រភេទ ២ និងប្រភេទ ៣ ខាងលើ។ តាមរយៈការប៉ាន់ស្មានចំនួនសរុប យានយន្តប្រើរួចប្រភេទទីបីនេះមានចំនួនយ៉ាងច្រើនលើសលុប ដែលមានប្រមាណជាង ៦០.០០០ គ្រឿងដែលត្រូវបាននាំចូលបន្ថែមមកចរាចរនៅលើដងផ្លូវកម្ពុជាជារៀងរាល់ឆ្នាំ។ ផ្ទុយទៅវិញ យានយន្តថ្មីដែលនាំចូលមកកម្ពុជាមានចំនួនត្រឹមតែចន្លោះចាប់ពី ១០-១៥% ប៉ុណ្ណោះ។

ជាទូទៅមានការលំបាកខ្លាំងក្នុងការប៉ាន់ស្មានឱ្យបានត្រឹមត្រូវលើតម្លៃយានយន្តដែលប្រើរួច ដែលបន្ថែមពីលើការព្រួយបារម្ភផ្នែកសុវត្ថិភាពដែលកើតមានពីការនាំចូលយានយន្តមិនមានសុវត្ថិភាព ហើយជាមូលហេតុដែលទីផ្សារជាច្រើនបានហាមឃាត់ការនាំចូលរថយន្តដែលប្រើរួចនេះផងដែរ។ យោងតាមប្រព័ន្ធថ្មី នេះដោយសារតែតម្លៃពន្ធគយនាំចូលខ្ពស់ បានធ្វើឱ្យកម្ពុជាក្លាយជាទីផ្សារដែលលក់រាយយានយន្តថ្មីក្នុងតម្លៃខ្ពស់បំផុតនៅក្នុងតំបន់អាស៊ាន ទោះបីជាប្រទេសដែលមានផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ទាបបំផុតនៅក្នុងមនុស្សម្នាក់នៅក្នុងតំបន់។ បើសរុបអំពីការគិតពន្ធទាំងអស់ តម្លៃសម្រាប់ការនាំចូលយានយន្តដឹកអ្នកដំណើរថ្មីពីក្រៅប្រទេសអាស៊ានមកកាន់កម្ពុជាអាចកើនដល់ ១៥១% នៃតម្លៃយានយន្តឯណោះ។

គួរឱ្យសោកស្តាយ ស្ថានភាពនេះបានលើកទឹកចិត្តឱ្យមានការនាំចូលយានយន្តដែលប្រើរួចជាងយានយន្តថ្មី ទោះបីយានយន្តថ្មីអាចរកចំណូលពន្ធបានច្រើនខ្លាំងជាងយានយន្តដែលប្រើរួចក៏ដោយ។ សម្រាប់យានយន្តថ្មី ដោយសារតែគោលដៅទីមួយបន្ទាប់ពីបានផលិតរួចគឺប្រទេសកម្ពុជា រាជរដ្ឋាភិបាល នឹងប្រមូលចំណូលពន្ធពេញមួយអាយុកាលទាំងមូលរបស់យានយន្ត។ ការប្រមូលពន្ធចាប់ផ្តើមនៅពេលយានយន្តនោះត្រូវបានលក់ ហើយនាំចូលដោយក្រុមហ៊ុនចែកចាយ និងបន្តពេញរយៈពេលប្រើប្រាស់នៅលើផ្លូវ ពេលចាក់ប្រេងឥន្ធនៈ ជួសជុល និងពន្ធផ្លូវប្រចាំឆ្នាំរហូតដល់ប្រើលែងកើតនៅពេលរុះរើយកគ្រឿងលក់។ តាមការប្រៀបធៀប យានយន្តប្រើរួចបានបំពេញដំណាក់កាលនៃវដ្តនេះអស់ភាគច្រើនទៅហើយនៅប្រទេសផ្សេងទៀត និងបានខិតជិតដល់ ឬហួសអាយុកាលប្រើប្រាស់ ដែលធ្វើឱ្យយានយន្តទាំងនោះនឹងត្រូវបោះចោលលែងប្រើមិនយូរប៉ុន្មានទៀតនោះទេ។ ការរៀបរាប់នេះបង្ហាញអំពីមូលហេតុដែលអ្នកលក់ស្វែងរកប្រភព និងលក់យានយន្តទាំងនោះក្នុងតម្លៃមួយទាបខ្លាំង ដោយសារតែកម្ពុជាគឺជាទីផ្សារមួយក្នុងចំណោមទីផ្សារនៅសល់មួយចំនួនដែលយានយន្តទាំងនោះត្រូវបានគេបញ្ចេញចោល។

ផ្ទុយទៅវិញ គោលនយោបាយសារពើពន្ធបច្ចុប្បន្នរបស់កម្ពុជាបានលើកទឹកចិត្តយ៉ាងមានប្រសិទ្ធភាពឱ្យទិញយានយន្តប្រើរួចជាងយានយន្តថ្មី។ កត្តានេះបាននាំឱ្យយានយន្តជាច្រើននៅលើដងផ្លូវប្រទេសកម្ពុជាមិនសមស្រប និងមានហានិភ័យធ្ងន់ធ្ងរដល់សុវត្ថិភាព ដោយយានយន្តទាំងអស់នោះធ្លាប់មានគ្រោះថ្នាក់ពីមុនរួចហើយនៅក្នុងប្រទេសដើមរបស់វា ហើយយានយន្តចាស់ៗទាំងនោះក៏មិនមានលក្ខណៈបច្ចេកទេសទំនើបគ្រប់គ្រាន់ដែលអាចជួយកាត់បន្ថយផលប៉ះពាល់ដែលយានយន្តអាចមានចំពោះបរិស្ថានឡើយ។

## វដ្តជីវិតគិតពន្ធរបស់យានយន្ត




*ជាប្រការចាំបាច់ដែលត្រូវទទួលស្គាល់ថាយានយន្តប្រើរួច នឹងបន្តដើរតួនាទីយ៉ាងសំខាន់នៅក្នុងទីផ្សារយានយន្តកម្ពុជា ហើយទីផ្សារយានយន្តមួយទឹក ក៏មិនអាចសាបសូន្យបានឡើយ។ ជាការពិតណាស់ យានយន្តប្រើរួច ជាទូទៅអាចលក់ដាច់ខ្លាំងជាងយានយន្តថ្មី។ ប៉ុន្តែយានយន្តថ្មីទាំងអស់នោះនឹងចូលក្នុងទីផ្សារក្នុងនាមជាយានយន្តថ្មីសិន ហើយក្រោយមក ទើបត្រូវបានអ្នកទិញលក់ចេញវិញ ហើយនឹងត្រូវគេទិញប្រើម្តងទៀតជាយានយន្តប្រើរួច ប៉ុន្តែករណីនេះយើងអាចធានាបានថាយានយន្តប្រើរួចទាំងនេះគឺបានផលិតឡើងយ៉ាង សមស្របសម្រាប់ស្ថានភាពប្រទេសគោលដៅ។*

*វិស័យយានយន្តកម្ពុជាទទួលស្គាល់ថា រាជរដ្ឋាភិបាលមានតម្រូវការជាច្រើន ដែលបានពាក់ព័ន្ធនឹងគោលនយោបាយយានយន្តរបស់ខ្លួន ដែលរួមមាន ការបង្កើនចំណូលពន្ធ ហើយទន្ទឹមនឹងនោះត្រូវធានាថាពលរដ្ឋរបស់ខ្លួនអាចទិញយានយន្តមានតម្លៃសមរម្យច្រើនជម្រើស។ គួរឱ្យសោកស្តាយ ការបន្តប្រើតារាងវាយតម្លៃរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករក្នុងការប៉ាន់ស្មានលើតម្លៃយានយន្តប្រើរួច បានធ្វើឱ្យប៉ះពាល់ដល់ចំណូលពន្ធបន្ថែមរបស់រាជរដ្ឋាភិបាល។ យើងជឿជាក់ថាតាមរយៈការហាមឃាត់ការនាំចូលយានយន្តប្រើរួច រាជរដ្ឋាភិបាលនឹងអាចកាត់បន្ថយបន្ទុកពន្ធ និងអាករជារួមលើយានយន្ត ហើយទន្ទឹមនឹងនោះក៏ធានាបានថាអ្នកប្រើប្រាស់នៅតែអាចមានលទ្ធភាពទិញយានយន្តក្នុងតម្លៃសមរម្យបានដដែល។*

## ផលប៉ះពាល់លើកម្ពុជា

គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មរបស់រាជរដ្ឋាភិបាល ទទួលស្គាល់ថាប្រព័ន្ធសារពើពន្ធដារល្អផ្តល់អត្ថប្រយោជន៍ជាច្រើន ដោយបានបង្ហាញនូវការប្តេជ្ញាចិត្តក្នុងការ "ពិនិត្យមើលឡើងវិញទៅលើប្រព័ន្ធសារពើពន្ធ និងប្រព័ន្ធគយ តាមរយៈការផ្លាស់ប្តូរវាទៅជាឧបករណ៍មួយដែលមិនត្រឹមតែសម្រាប់ការប្រមូលចំណូលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីជំរុញឱ្យមានការអភិវឌ្ឍឧស្សាហកម្មកាន់តែល្អប្រសើរឡើងទៀតផង"។

គោលការណ៍ដូចគ្នានេះ អនុវត្តនៅក្នុងទីផ្សារអ្នកប្រើប្រាស់ដូចជាយានយន្តជាដើម។ យើងជឿជាក់ថាការហាមឃាត់ទាំងស្រុងលើការនាំចូលយានយន្តប្រើរួច ឬការយកពន្ធខ្ពស់ខ្លាំងលើការនាំចូលយានយន្តប្រើរួច នឹងអាចផ្លាស់ប្តូរតម្រូវការរបស់អ្នកប្រើប្រាស់ឱ្យងាកមកប្រើយានយន្តថ្មីជំនួសវិញ ដូច្នេះនឹងអាចដកយានយន្តចាស់មិនមានសុវត្ថិភាព និងដែលប៉ះពាល់ដល់បរិស្ថាននៅលើដងផ្លូវចេញអស់មិនខានព្រមទាំងជំរុញឱ្យវិស័យយានយន្តរកប្រាក់ចំណូលបានកាន់តែច្រើនបន្ថែមទៀតសម្រាប់ប្រទេសកម្ពុជាទៀតផង។

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើ ឱ្យធ្វើវិចារណកម្មលើគោលនយោបាយសារពើពន្ធសម្រាប់យានយន្តដើម្បីលើកទឹកចិត្តឱ្យមានការប្រើយានយន្តកាន់តែសមស្រប និងមិនប៉ះពាល់ដល់បរិស្ថានកម្ពុជា។

ដើម្បីសម្រេចគោលបំណងក្នុងការជំរុញឱ្យមានអនុលោមភាពពន្ធកាន់តែល្អប្រសើរ បង្កើនចំណូលពន្ធកាន់តែច្រើន និងមានយានយន្តមានសុវត្ថិភាពនៅលើដងផ្លូវកម្ពុជា យើងខ្ញុំសូមគោរពផ្តល់ជូននូវអនុសាសន៍ សម្រាប់អនុវត្តដំណាលគ្នានូវវិធានការដូចខាងក្រោម៖

ក. អនុវត្តបំរាមហាមឃាត់ទាំងស្រុងលើការនាំចូលយានយន្តប្រើរួច។

ខ. ស្វែងរកវិធីសាស្ត្រកាត់បន្ថយពន្ធដាររួម និងអាករលើការនាំចូលដើម្បីធានាថាអ្នកប្រើប្រាស់នៅតែមានលទ្ធភាពទិញយានយន្តក្នុងតម្លៃសមរម្យ។

ការដាក់ឱ្យអនុវត្តវិធានការទាំងពីរនេះ នឹងលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ពីផលប៉ះពាល់នៃយានយន្តដែល សមស្របសម្រាប់បរិស្ថានកម្ពុជា ហើយទន្ទឹមនឹងនោះក៏ជំរុញឱ្យមានការទិញយានយន្តថ្មីជាង និងមានសុវត្ថិភាពខ្ពស់ជាងមុន ដែលរាជរដ្ឋាភិបាលកម្ពុជានឹងអាចប្រមូលចំណូលពន្ធកាន់តែច្រើនថែមទៀត។

# វិស័យធុរកិច្ចកសិកម្ម

គណៈកម្មាធិការធុរកិច្ចកសិកម្មរបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៨ ក្រោយពីសមាជិករបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា បានបង្ហាញចំណាប់អារម្មណ៍យ៉ាងខ្លាំងពាក់ព័ន្ធនឹងវិស័យកែច្នៃចំណីអាហារ និងកសិកម្ម។ ដោយមានករណីដូចគ្នាទៅនឹងគណៈកម្មាធិការតាមវិស័យផ្សេងៗទៀតរបស់យើង គណៈកម្មាធិការធុរកិច្ចកសិកម្មផ្តល់ជាវេទិកាដ៏មានតម្លៃដល់សមាជិកដើម្បីពិភាក្សា និងកំណត់បញ្ហាដែលប៉ះពាល់ដល់ធុរកិច្ចរបស់ខ្លួន ហើយសំខាន់ជាងនេះទៅទៀត គឺដើម្បីស្នើសុំដំណោះស្រាយជាក់ស្តែង និងប្រកបដោយការស្ថាបនាដល់រាជរដ្ឋាភិបាល។ ដំណើរការនៃកិច្ចសហការដែលបានសម្របសម្រួលតាមរយៈវេទិកានេះ បានបង្កើតឱ្យមានជំពូកវិស័យធុរកិច្ចកសិកម្មថ្មីរបស់យើង និងពង្រីកកិច្ចខិតខំប្រឹងប្រែងរបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាក្នុងការលើកកម្ពស់កិច្ចពិភាក្សារវាងរាជរដ្ឋាភិបាល និងវិស័យឯកជន ព្រមទាំងដើម្បីចែករំលែកឧត្តមានុវត្តអន្តរជាតិនៅក្នុងវិស័យជាច្រើនផ្សេងទៀតផងដែរ។

យើងខ្ញុំមានសេចក្តីសោមនស្ស សូមរាយការណ៍ថា ចាប់តាំងពីពេលបង្កើតឡើងមក គណៈកម្មាធិការធុរកិច្ចកសិកម្មសម្រេចបាននូវការចូលរួមប្រកបដោយផ្លែផ្កាជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ នៅក្នុងកិច្ចប្រជុំណែនាំគណៈកម្មាធិការរបស់យើង ក្រសួងនេះបានស្វាគមន៍ចំពោះកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយនឹងវិស័យឯកជនដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងនៃវិស័យកសិកម្មរបស់កម្ពុជា។ គណៈកម្មាធិការនេះក៏បានរៀបចំកម្មវិធីពាក់ព័ន្ធនឹងវិស័យរបស់ខ្លួនជាលើកដំបូងជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខែកុម្ភៈ ឆ្នាំ២០១៩ ផងដែរ ដោយបានអញ្ជើញឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើជាអធិបតីក្នុងកម្មវិធី អាហារថ្ងៃត្រង់ ដែលក្នុងឱកាសនោះឯកឧត្តមរដ្ឋមន្ត្រីបានចែករំលែកនូវចក្ខុវិស័យរបស់ឯកឧត្តមចំពោះក្រសួង និងគោលនយោបាយនាថ្ងៃខាងមុខរបស់ក្រសួង។ ភាពជោគជ័យនៃកម្មវិធីនេះបានបង្ហាញអំពីបំណងរបស់វិស័យនេះក្នុងការចូលរួមយ៉ាងសកម្មជាមួយនឹងរាជរដ្ឋាភិបាល ដែលសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជានឹងខិតខំធ្វើការសម្របសម្រួលលើកិច្ចសហការមួយនេះ។

តម្រូវការនៃការតស៊ូមតិប្រកបដោយប្រសិទ្ធភាព សម្រាប់វិស័យធុរកិច្ចកសិកម្មនេះ ត្រូវបានបញ្ជាក់នៅក្នុងខែឧសភា ឆ្នាំ២០១៨ ជាមួយនឹងការហាមឃាត់ដោយមិនបានរំពឹងជាមុន លើការនាំចូលផលិតផលការពារដំណាំបន្ទាប់ពីមានបញ្ហាពុលទឹកយ៉ាងធ្ងន់ធ្ងរនោះ។ ដោយមានការគាំទ្រពីគណៈកម្មាធិការនេះ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាអាចលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់ដ៏គ្រោះថ្នាក់ដែលការហាមឃាត់នេះអាចនឹងមាន មកលើវិស័យកសិកម្ម ហើយថាការបន្តការហាមឃាត់នេះនឹងជំរុញកំណើនប្រើប្រាស់ផលិតផលក្លែងក្លាយ និងផលិតផលនាំចូលខុសច្បាប់កាន់តែច្រើនឡើងជាក់ជាមិនខាន។ បន្ទាប់ពីបានធ្វើការស៊ើបអង្កេតទៅលើការពុលនោះ ក្រសួងបានដកការហាមឃាត់ចេញវិញ និងប្តេជ្ញាពង្រឹងកិច្ចខិតខំប្រឹងប្រែងបន្តទៀតជាមួយអាជ្ញាធរពាក់ព័ន្ធដើម្បីប្រយុទ្ធប្រឆាំងនឹងការនាំចូលផលិតផលក្លែងក្លាយ។

សម្រាប់ជំពូកបើកនេះ សមាជិករបស់យើងបានកំណត់បញ្ហាអាទិភាពចំនួនប្រាំដែលយើងបានស្នើជាអនុសាសន៍អនុវត្តជាក់ស្តែងដើម្បីដោះស្រាយបញ្ហាទាំងនោះ។

អនុសាសន៍ទីមួយមានគោលបំណងឆ្លុះបញ្ចាំងនូវភាពមានកម្រិតដែលមានស្រាប់នៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ដែលត្រូវបានអនុម័តនៅឆ្នាំ២០១៦។ ចំណុចគួរឱ្យកត់សម្គាល់បំផុតនោះគឺ ច្បាប់នេះបានចែងយ៉ាងច្បាស់អំពីការហាមឃាត់ការប្រើប្រាស់សារធាតុដែលបង្កគ្រោះថ្នាក់ដល់មនុស្ស និងសត្វ ប៉ុន្តែដោយសារតែពុំទាន់មានការកំណត់សារធាតុជាក់លាក់ណាមួយនោះ ច្បាប់នេះនៅតែបើកចំហឱ្យមានការបកស្រាយផ្សេងៗគ្នា។ ជាផលវិបាកចំណុចនេះ បាននាំឱ្យមានការប្រើប្រាស់សារធាតុមិនមានសុវត្ថិភាពក្នុងផលិតកម្មចំណីអាហារ ជាពិសេស សារធាតុបេតាអាហ្គូនីស (beta agonists) នឹងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ។

អនុសាសន៍ទីពីររបស់យើងគឺលើកឡើងអំពីក្តីកង្វល់ជាមួយនឹងផលប៉ះពាល់អវិជ្ជមាននៃវត្តមានផលិតផលកសិកម្មនាំចូលខុសច្បាប់ដែលកំពុងមានការប្រកួតប្រជែង និងការវិនិយោគនៅក្នុងវិស័យនេះ។ ក្រុមហ៊ុនចែកចាយស្របច្បាប់នូវផលិតផលកសិកម្មត្រូវគោរពតាមលក្ខខណ្ឌតម្រូវអនុលោមភាពតឹង

រុងមុនពេលអនុញ្ញាតឱ្យលក់ផលិតផល ជូនអតិថិជនរួមមានការសុំអាជ្ញាប័ណ្ណសម្រាប់ធ្វើពាណិជ្ជកម្ម ការរៀបចំឃ្លាំង និងការនាំចូលផលិតទាំង នោះ ដែលលក្ខខណ្ឌតម្រូវនីមួយៗត្រូវចំណាយប្រាក់យ៉ាងច្រើនៗ ដោយសារតែក្រុមហ៊ុនចែកចាយខុសច្បាប់គេចវេសពីដំណើរការអនុលោមភាពនេះទាំងស្រុង ទើបក្រុមហ៊ុនចែកចាយខុសច្បាប់ទាំងនោះអាចលក់ផលិតផលដែលអាចបង្កគ្រោះថ្នាក់ ដែលមិនសមស្របសម្រាប់ទីផ្សារកម្ពុជា ក្នុងតម្លៃទាបខ្លាំងជាងតម្លៃរបស់ដៃគូប្រកួតប្រជែងដែលអនុលោមតាមច្បាប់ កត្តានេះធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ប្រាក់ចំណេញរបស់ដៃគូប្រកួតប្រជែងស្របច្បាប់ និងប៉ះពាល់ដល់ការទាក់ទាញរបស់វិស័យនេះ។

វិស័យកសិកម្មគឺនិយោជកដ៏ធំមួយ និងជាកត្តាជំរុញដល់សេដ្ឋកិច្ចកម្ពុជា ព្រមទាំងមានលក្ខខណ្ឌតម្រូវការងារល្អ និងអត្ថប្រយោជន៍ដែលមានចែងក្នុងច្បាប់ស្តីពីការងារ ដែលវិស័យផ្សេងទៀតមិនត្រូវការអនុវត្តតាម ឬផ្តល់ឱ្យ។ អនុសាសន៍បន្ទាប់របស់យើងមានគោលបំណងសង្កត់ធ្ងន់ថា លក្ខខណ្ឌបន្ថែមទាំងនេះគួរតែត្រូវបានពិចារណាដោយរាជរដ្ឋាភិបាល នៅពេលដែលរាជរដ្ឋាភិបាលអនុវត្តកម្មវិធីកំណែទម្រង់ការងារថ្មី ដូចជាការអនុម័តប្រាក់ឈ្នួលអប្បបរមាស្តង់ដារជាដើម។ ដោយមានការទទួលស្គាល់ថាកម្មវិធីកំណែទម្រង់ការងារនេះទទួលបានការស្វាគមន៍យ៉ាងខ្លាំង ហើយយើងខ្ញុំសូមចែករំលែកថាគួរស្វែងរកឱ្យមានតុល្យភាពដែលផ្តល់កត្តាគាំទ្រលើអត្ថប្រយោជន៍បន្ថែមទាំងនេះ។

ភាពប្រកួតប្រជែងក្នុងវិស័យនាំចេញផលិតផលកសិកម្មរបស់កម្ពុជាបានក្លាយជាចំណុចផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត បន្ទាប់ពីគណៈកម្មការអឺរ៉ុបបានសម្រេចអនុវត្តវិធានការការពារលើការនាំចេញអង្ករកម្ពុជាទៅកាន់សហភាពអឺរ៉ុប។ អាស្រ័យហេតុនេះ យើងខ្ញុំសូមបង្ហាញជូនអំពីតម្រូវការសម្រាប់កម្ពុជា នៅក្នុងការធ្វើពិពិធកម្មផលិតកម្មស្រូវ តាមរយៈការដាំស្រូវប្រភេទខុសៗគ្នា និងស្នើឱ្យទទួលយកស្រូវកូនកាត់ជាផ្លូវការ និងដាំគ្រាប់ពូជនោះ ដើម្បីកាត់បន្ថយការគំរាមកំហែងស្រដៀងគ្នានេះផងដែរ។

ជាចុងក្រោយ អនុសាសន៍ចុងក្រោយរបស់យើងគឺមានគោលបំណងធ្វើការបញ្ជាក់អំពីលក្ខខណ្ឌតម្រូវរបស់ក្រសួងបរិស្ថាន ដែល

កំណត់ថាក្រុមហ៊ុនធុរកិច្ចកសិកម្មត្រូវតែធ្វើតេស្តគុណភាពទឹកតាមរយៈកន្លែងពិសោធន៍ផ្ទាល់របស់ក្រសួង។ ទោះបីសមាជិករបស់យើងទទួលស្គាល់ពីតម្រូវការចាំបាច់ក្នុងការវិភាគហេតុប៉ះពាល់បរិស្ថានជាទៀងទាត់ក្តី ក៏យើងខ្ញុំសូមបង្ហាញថាការកំណត់ឱ្យត្រូវតែប្រើមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថានបែបនេះបានកម្រិតដល់សមត្ថភាពប្រកួតប្រជែង និងកាត់បន្ថយភាពមិនលម្អៀងនៃលទ្ធផលធ្វើតេស្ត។

យើងនឹងទន្ទឹមរង់ចាំឱកាសចូលរួមក្នុងកិច្ចប្រជុំពិភាក្សាប្រកបដោយផ្លែផ្កាជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការឆ្លើយតបទៅនឹងអនុសាសន៍ទាំងនេះ ដោយសារតែយើងមានគោលដៅរួមនៅក្នុងការលើកកម្ពស់សមត្ថភាពប្រកួតប្រជែង នៃវិស័យកសិកម្មរបស់ប្រទេសកម្ពុជា។

២៨

# សារធាតុហាមឃាត់នៅក្នុងផលិតកម្មសត្វ

ថ្មី

**ពិពណ៌នាបញ្ហា**

*រាជរដ្ឋាភិបាលបានអនុម័តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វនៅឆ្នាំ២០១៦ ដើម្បីធានាដល់ការគ្រប់គ្រងមានប្រសិទ្ធភាព និងការអភិវឌ្ឍការចិញ្ចឹមសត្វដោយធ្វើទំនើបកម្ម និងធ្វើបមាណីយកម្មនៃការអនុវត្តដោយស្របតាមបទប្បញ្ញត្តិអន្តរជាតិ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺធ្ងន់ៗ ស្រដៀងនេះដែរ ច្បាប់នេះមានគោលបំណងបន្ស៊ីស្តង់ដាររបស់សត្វរបស់កម្ពុជាជាមួយនឹងប្រទេសជិតខាងនៅក្នុងតំបន់របស់ខ្លួន ដើម្បីសម្រួលដល់កំណើនពាណិជ្ជកម្មឆ្លងកាត់ព្រំដែននៃផលិតផលសត្វ និងការធ្វើសមាហរណកម្មក្នុងតំបន់បន្ថែមទៀត។*

*ទោះបីជាច្បាប់នេះបានបង្ហាញអំពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដែលរាជរដ្ឋាភិបាលបានអនុវត្តដើម្បីលើកកម្ពស់សុខភាព និងសុវត្ថិភាពផលិតកម្មសត្វនៅកម្ពុជាក៏ដោយ ក៏ប៉ុន្តែច្បាប់នេះត្រូវបានគេយល់ឃើញថានៅមានកម្រិតនៅឡើយ ពាក់ព័ន្ធនឹងសេចក្តីលម្អិតអំពីការអនុវត្តនានាដែលច្បាប់នេះមិនបានអនុញ្ញាត ដែលអាចធ្វើឱ្យធុរកិច្ចមួយចំនួនគេចវេសពីការអនុវត្តតាមលក្ខខណ្ឌតម្រូវ។*

*ឧទាហរណ៍ មាត្រា ២៧ នៃជំពូក ២ នៅក្នុងច្បាប់នេះបានចែងអំពីការហាមឃាត់ការប្រើប្រាស់សារធាតុមានគ្រោះថ្នាក់ដល់សត្វ និងមនុស្ស ដែលបានកែច្នៃសេនេទិក និងសារធាតុជំរុញការលូតលាស់របស់សត្វខុសប្រក្រតីដោយមិនបានកំណត់អំពីប្រភេទជាក់លាក់នៃសារធាតុហាមឃាត់ទាំងនោះឡើយ។ ដោយមិនមានការបញ្ជាក់អំពីសមាសធាតុគ្រោះថ្នាក់ មាត្រានៅតែបើកចំហឱ្យមានការបកស្រាយ និងអនុញ្ញាតឱ្យធុរកិច្ចបន្តប្រើសារធាតុទាំងនោះក្នុងផលិតកម្មរបស់ខ្លួនដដែល។*

*ការធ្វើតេស្តឯករាជ្យបានរកឃើញវត្តមានរីកសាយភាយនៃការប្រើថ្នាំបេតាអាហ្គូនីស* (beta agonists) *ដូចជា សាល់ប៊ុយតាម៉ុល* (salbutamol) *និងរ៉េកតូប៉ាមីន* (ractopamine) *នៅក្នុងផលិតផលចំណីសត្វនានា និងលាយជាមួយនឹងចំណីសត្វជាមុនដោយក្រុមហ៊ុនធុរកិច្ច ដែលធ្វើអាជីវកម្មពាក់ព័ន្ធនឹងការចិញ្ចឹមសត្វនៅកម្ពុជាដើម្បីទទួលបានផលចំណេញនៅក្នុងការប្រកួតប្រជែងនៅលើទីផ្សារ។ ថ្នាំបេតាអាហ្គូនីស* (beta agonists) *ដូចជា រ៉េកតូប៉ាមីន* (ractopamine) *សាល់ប៊ុយតាម៉ុល* (salbutamol) *ក្លេនប៊ូលតេរ៉ូល* (clenbuterol) *និង ហ្វីណូតេរ៉ូល* (fenoterol) *ត្រូវបានគេប្រើយ៉ាងច្រើនលើសលុបនៅក្នុងការចិញ្ចឹមជ្រូកនៅកម្ពុជាដើម្បីកាត់បន្ថយបរិមាណខ្លាញ់របស់សត្វជ្រូក ដោយការជំរុញឱ្យមានការលូតលាស់ជាលិកាសាច់ដុំនៅក្នុងដំណាក់កាលឡើងជាត់មុនពេលយកទៅសម្លាប់យកសាច់លក់។ ការប្រើថ្នាំបេតា អាហ្គូនីស* (beta agonists) *អាចឱ្យអ្នកចិញ្ចឹមទទួលបានសាច់គ្មានខ្លាញ់ និងទម្ងន់ឡើងខ្ពស់ ដោយសារតែកំណើនស្រូបជាតិទឹករបស់សត្វចិញ្ចឹមនោះ។*

*ប្រទេសជាច្រើនរួមទាំងថៃ វៀតណាម ចិន រុស្ស៊ី និងសហភាពអឺរ៉ុបបានហាមឃាត់ការប្រើប្រាស់ថ្នាំបេតាអាហ្គូនីសនៅក្នុងការចិញ្ចឹមសត្វដោយសារវាមានផលប៉ះពាល់អវិជ្ជមានចំពោះសត្វ និងមនុស្សដែលបរិភោគផលិតផលសម្រេចនោះ ពីព្រោះកម្រិត*

*សមាសធាតុដែលអាចរស់រវើងបាននៅតែមាននៅក្នុងសាច់សត្វ។ ហានិភ័យសុខភាពដែលទាក់ទងនឹងការប្រើថ្នាំបេតា អាហ្គូនីស រួមមាន៖ បង្កើនហានិភ័យកើតជំងឺសរសៃឈាមបេះដូង ជំងឺឈឺក្បាល ជំងឺញាក់ញ័រខ្លួនប្រាណ ការខូចសាច់ដុំឆ្អឹង និងការធ្វើឱ្យសត្វងាប់ជាដើម។*

*ដោយសារតែច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វបានហាមឃាត់ការប្រើប្រាស់សារធាតុគ្រោះថ្នាក់ដែលជំរុញការលូតលាស់របស់សត្វរួចទៅហើយ នេះមានន័យថាថ្នាំបេតា អាហ្គូនីស ក៏ត្រូវបានហាមឃាត់មិនឱ្យប្រើប្រាស់នៅកម្ពុជាដែរ ដូច្នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គប្បីអនុវត្តច្បាប់នេះដោយកំណត់ច្បាស់លាស់អំពីសមាសធាតុហាមឃាត់ជាក់លាក់ដើម្បីលុបបំបាត់ទម្លាប់ប្រើប្រាស់សារធាតុគ្រោះថ្នាក់ទាំងអស់នេះទៀត។*

## ផលប៉ះពាល់លើកម្ពុជា

*ដោយសាតែតម្រូវការសាច់សត្វនៅតែបន្តកើនឡើង រាជរដ្ឋាភិបាលចាំបាច់គួរតែចាត់វិធានការឱ្យបានគ្រប់គ្រាន់ក្នុងការធានាថាការប្រើផលិតផលនៅអំឡុងពេលចិញ្ចឹមសត្វទាំងនោះគឺមានសុវត្ថិភាពដល់សុខុមាលភាពសត្វ ហើយថាផលិតផលចុងក្រោយមានលក្ខណៈសមស្របសម្រាប់មនុស្សបរិភោគ។ប្រសិនបើការប្រើសារធាតុគ្រោះថ្នាក់ទាំងនេះនៅបន្តមានដោយមិនមានការទប់ស្កាត់ ហើយហានិភ័យពាក់ព័ន្ធបានរីករាលដាលកាន់តែច្រើនឡើង នោះសត្វចិញ្ចឹមនៅកម្ពុជាអាចមានកេរ្តិ៍ឈ្មោះមិនល្អដោយជាប្រការគ្រោះថ្នាក់មួយចំពោះកំណើនវិស័យកសិកម្មនៅកម្ពុជា។ ឧទាហរណ៍នៃផលប៉ះពាល់ដោយសារតែ ការបន្តមានកេរ្តិ៍ឈ្មោះមិនល្អកាន់តែខ្លាំងឡើងនេះអាចមានដូចជា ដោយហេតុថាប្រទេសថៃ និងវៀតណាម បានហាមឃាត់ការប្រើប្រាស់ថ្នាំបេតា អាហ្គូនីស រួចហើយ ដូច្នេះប្រទេសទាំងពីរនេះមិនអនុញ្ញាតឱ្យមានការនាំចូលទំនិញណាដែលត្រូវបានគេរកឃើញមានផ្ទុកសារធាតុទាំងនេះឡើយ។ អាស្រ័យហេតុនេះ ទោះបីជាច្បាប់ស្តីពីសុខភាពសត្វ នឹងផលិតកម្មសត្វបង្កើតឡើងក្នុងគោលបំណងបន្សើស្តង់ដាររបស់កម្ពុជាជាមួយនឹងប្រទេសជិតខាងខ្លួនដើម្បីសម្រួលដល់ការធ្វើសមាហរណកម្មក្នុងតំបន់ និងពាណិជ្ជកម្មឆ្លងកាត់ព្រំដែនឱ្យកាន់តែល្អប្រសើរក៏ដោយ ប៉ុន្តែប្រសិនបើមិនមានការកំណត់សមាសធាតុសារធាតុហាមឃាត់ជាក់លាក់ទេនោះ ការប្រើប្រាស់សារធាតុទាំងនោះនឹងនៅតែបន្តមានដដែល ហើយអាចនឹងប៉ះពាល់ដល់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងនាមជាប្រទេសនាំចេញសាច់សត្វដ៏មានសក្តានុពល។*

*លើសពីនេះទៅទៀត ការកំណត់សមាសធាតុហាមឃាត់ជាក់លាក់ អាចជាយុទ្ធសាស្ត្រលើកកម្ពស់ការយល់ដឹងកាន់តែមានប្រសិទ្ធភាពរបស់ក្រសួង ដើម្បីឱ្យអ្នកចិញ្ចឹមសត្វទាំងអស់អាចមានព័ត៌មានកាន់តែច្បាស់អំពីសារធាតុដែលត្រូវប្រើលើសត្វរបស់ខ្លួន ពីព្រោះមានអ្នកចិញ្ចឹមសត្វទ្រង់ទ្រាយតូចជាច្រើនមិនមានការយល់ដឹងអំពីផលវិបាកដ៏គ្រោះថ្នាក់កើតឡើងចេញពីការបន្តប្រើសារធាតុទាំងនោះឡើយ។ ស្រដៀងគ្នានេះដែរ ការកំណត់ច្បាស់លាស់នូវសារធាតុហាមឃាត់ នឹងជំរុញឱ្យមានទីផ្សារប្រកួតប្រជែងកាន់តែល្អប្រសើរសម្រាប់អ្នកចិញ្ចឹមសត្វ ដោយសារតែតម្លៃក្នុងសត្វមួយក្បាលអាចប្រែប្រួលខ្លាំងតាមរយៈការប្រើថ្នាំបេតា អាហ្គូនីស ពីព្រោះកន្លង*

មកអ្នកចិញ្ចឹមសត្វដែលមិនប្រើសារធាតុទាំងនោះមានសមត្ថភាពប្រកួតប្រជែងតិចជាងអ្នកចិញ្ចឹមដែលប្រើថ្នាំបេតា អាហ្គូនីស និងទទួលបានប្រាក់ចំណេញតិចជាងនៅពេលលក់សត្វចិញ្ចឹមរបស់ខ្លួន។

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំណត់បញ្ជីសារធាតុហាមឃាត់ដែលមានចែងនៅក្នុងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងផ្តល់ការធានាថាបញ្ជីនោះមានដាក់បញ្ចូលឈ្មោះថ្នាំបេតា អាហ្គូនីស ផងដែរ។

ដើម្បីបន្សុីស្តង់ដារចិញ្ចឹមសត្វកម្ពុជាឱ្យស្របតាមស្តង់ដាររបស់បណ្តាប្រទេសជាច្រើនផ្សេងទៀត និងទីផ្សារនាំចេញសំខាន់ក្នុងតំបន់សំខាន់ៗ យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកំណត់បញ្ជីសារធាតុហាមឃាត់ដែលមានចែងនៅក្នុងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងផ្តល់ការធានាថាបញ្ជីនោះមានដាក់បញ្ចូលឈ្មោះពពួកថ្នាំបេតា អាហ្គូនីស ដូចជា រ៉េកតូប៉ាមីន (ractopamine) សាល់ប៊ុយតាម៉ុល (salbutamol) ក្លេនប៊ូលីតេរ៉ូល (clenbuterol) និងហ្វីណូតេរ៉ូល (fenoterol)។ តាមរយៈការធ្វើដូច្នេះ ក្រសួងនឹងបង្កើនសុវត្ថិភាព និងគុណភាពផលិតផលសត្វដែលមានលក់នៅលើទីផ្សារកម្ពុជា និងបង្កើតឱ្យមានទីផ្សារប្រកួតប្រជែងកាន់តែខ្លាំងឡើងសម្រាប់ធុរកិច្ចដែលអនុវត្តតាមច្បាប់។

ជាប្រការសំខាន់ដែលថាបន្ទាប់ពីមានការផ្សព្វផ្សាយនូវសារធាតុហាមឃាត់ជាក់លាក់ ទាំងនោះរួច គួរតែមានយុទ្ធនាការមានប្រសិទ្ធភាពដើម្បីលើកកម្ពស់ការយល់ ដឹងអំពីបញ្ហាទាំងនេះ ក្នុងគោលបំណងបញ្ចុះបញ្ចូលឱ្យក្រុមហ៊ុនធុរកិច្ចមិនប្រើសារធាតុហាមឃាត់ និងផ្តល់ព័ត៌មានដល់ពួកគេអំពីវិធីសាស្ត្រសុវត្ថិភាព ក្នុងការជំរុញកំណើនផលិតកម្មរបស់ខ្លួន។ ស្រដៀងនេះដែរ ក្រសួងគប្បីបង្កើនការត្រួតពិនិត្យឱ្យបានកាន់តែច្រើនលើកសិដ្ឋាន និងនៅលើទីផ្សារដើម្បីធានាថាអ្នកចិញ្ចឹម អនុវត្តតាមបទប្បញ្ញត្តិថ្មីនេះ។ សម្រាប់អ្នកចិញ្ចឹមដែលបន្តប្រើសារធាតុគ្រោះថ្នាក់ដូចបានរៀបរាប់ខាងលើ ក្រសួងគួរអនុវត្តវិធានពិន័យដូចមានចែងនៅក្នុងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីធានានូវប្រយោជន៍ស្មើភាពចំពោះអ្នកចិញ្ចឹមសត្វទាំងឡាយណាដែលអនុវត្តតាមបទប្បញ្ញត្តិនេះ។

២៩

# លទ្ធភាពនៃផលិតផលកសិកម្មមិនស្របច្បាប់

ថ្មី

**ពិពណ៌នាបញ្ហា**

*វិស័យកសិកម្មមានប្រសិទ្ធផល និងផលិតភាពគឺជាសសរស្តម្ភស្នូលនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍រួមរបស់រាជរដ្ឋាភិបាលសម្រាប់ប្រទេសកម្ពុជា ព្រមទាំងមានសារៈសំខាន់ខ្លាំងសម្រាប់សមត្ថភាពប្រកួតប្រជែងនាំចេញ និងសន្តិសុខស្បៀងរបស់ខ្លួនផងដែរ។ មូលដ្ឋានគ្រឹះសម្រាប់វិស័យកសិកម្មមានផលិតភាព គឺជាការប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព នូវសម្ភារកសិកម្មមានគុណភាពខ្ពស់ ដូចជា គ្រាប់ពូជ ជី និងថ្នាំសម្លាប់សត្វចង្រៃដែលអាចឱ្យកសិករបង្កើនទិន្នផលរបស់ខ្លួន និងប្រពលភាពក្នុងការប្រើប្រាស់ដីធ្លី។ ប៉ុន្តែដោយសារតែការវិនិយោគនៅមានកម្រិតនៅឡើយ និងវិបាំងបច្ចេកទេស ទើបកម្ពុជានៅមិនទាន់មានលទ្ធភាពផលិតផលិតផលសម្ភារកសិកម្មផ្ទាល់ខ្លួនបានច្រើនដើម្បីបំពេញតាមកំណើនតម្រូវការរបស់វិស័យនេះនៅឡើយនោះទេ។ ទោះបីជាកត្តានេះកំពុងមានការផ្លាស់ប្តូរនៅពេលមានកំណើនការវិនិយោគខ្ពស់ក៏ដោយ ក៏វិស័យកសិកម្មកម្ពុជានៅតែពឹងផ្អែកខ្លាំងទៅលើការនាំចូលផលិតផលសម្ភារកសិកម្មជាច្រើននៅឡើយ ជាពិសេស ការនាំចូលមកពីប្រទេសវៀតណាម និងថៃ។*

*ដោយសារតែសារៈសំខាន់នៃវិស័យនេះ និងដោយមានការទទួលស្គាល់ថាផលិតកម្មក្នុងស្រុកនៅមានកម្រិតនៅឡើយនោះ រាជរដ្ឋាភិបាលបានកំណត់តម្លៃតពន្ធគយសូន្យសម្រាប់ការនាំចូលផលិតផលសម្ភារកសិកម្មមកកាន់ប្រទេសកម្ពុជា។ ដើម្បីទទួលបានការលើកទឹកចិត្តនេះ និងធានានូវការអនុវត្តតាមច្បាប់ ក្រុមហ៊ុនធុរកិច្ចកសិកម្មនានាចាំបាច់ត្រូវចុះបញ្ជិកានៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្នើសុំអាជ្ញាប័ណ្ណធ្វើពាណិជ្ជកម្ម ការចែកចាយ និងការរក្សាទុកសម្ភារកសិកម្មនៅក្នុងប្រទេសកម្ពុជា។ បន្ថែមពីលើនេះទៅទៀត ផលិតផលនីមួយៗដែលក្រុមហ៊ុនធុរកិច្ចមានបំណងនាំចូលមកកាន់ប្រទេសកម្ពុជា ត្រូវចុះបញ្ជិកានៅក្រសួងដើម្បីបញ្ជាក់ពីសមាសធាតុ និងសុវត្ថិភាពរបស់ផលិតផលនោះ។ លុះត្រាតែបានបំពេញដំណើរការចុះបញ្ជីទាំងនេះចប់រួចរាល់ហើយ ទើបក្រុមហ៊ុនធុរកិច្ចអាចដាក់ពាក្យស្នើសុំ អាជ្ញាប័ណ្ណនាំចូល និងលិខិតអនុញ្ញាតដើម្បីនាំចូលផលិតផលទាំងនោះ។ ទោះបីជាដំណើរការអនុវត្តតាមច្បាប់នេះមានលក្ខណៈស្មុគស្មាញ និងមានការចំណាយពាក់ព័ន្ធច្រើនក្តី ក៏អត្ថប្រយោជន៍នៃការលើកលែងពន្ធនាំចូល និងសិទ្ធិចែកចាយផ្តាច់មុខលើផលិតផលនានាដែលខ្លួនបានចុះបញ្ជិកា អាចឱ្យក្រុមហ៊ុនធុរកិច្ចដែលអនុវត្តតាមច្បាប់ភាគច្រើនអាចបំពេញលក្ខខណ្ឌតម្រូវទាំងនេះបានយ៉ាងសមស្រប។*

*ទោះបីជាក្រសួងបានខិតខំប្រឹងប្រែងគ្រប់គ្រង និងត្រួតពិនិត្យការនាំចូលផលិតផលសម្ភារកសិកម្មចូលមកក្នុងប្រទេសកម្ពុជាក៏ដោយ ក៏មានការធ្វើពាណិជ្ជកម្មផលិតផលសម្ភារកសិកម្មក្រៅផ្លូវការក្នុងទំហំដ៏ធំគួរឱ្យកត់សម្គាល់ផងដែរ ដែលត្រូវបានលួចដឹកជញ្ជូនឆ្លងកាត់ព្រំដែនដោយខុសច្បាប់ចេញពីប្រទេសជិតខាងយ៉ាងទូលំទូលាយ ហើយត្រូវបានយកមកលក់ និងប្រើប្រាស់ដោយកសិករជាច្រើននៅទូទាំងប្រទេសកម្ពុជា។ ទោះបីជាប្រទេសទាំងនេះគឺជាប្រភពដែលមានផលិតផលចុះបញ្ជីជាច្រើនក៏ដោយ ប៉ុន្តែដោយសារតែរោងចក្រនៅទីនោះបានផលិតលើសពីតម្រូវការទីផ្សាររបស់ខ្លួន ទើបក្រុមហ៊ុនចែកចាយមិនបានចុះបញ្ជីកេងចំណេញពីផលិតផល*

*លើសពីតម្រូវការដែលមានថ្លៃចំណាយទាបនេះ ដោយបាននាំចូលលើសតម្រូវការមកលក់នៅកម្ពុជាក្នុងតម្លៃទាបជាងតម្លៃទីផ្សារនៅក្នុងស្រុក។ការទម្លាក់តម្លៃនេះ បានដាក់សម្ពាធមិនចាំបាច់លើក្រុមហ៊ុនធុរកិច្ចដែលអនុវត្តតាមច្បាប់ ដោយសារតែក្រុមហ៊ុនធុរកិច្ចទាំងនោះមិនអាចលក់តាមតម្លៃទាបតាមក្រុមហ៊ុនចែកចាយមិនបានចុះបញ្ជី ដែលបានចំណេញថ្លៃចំណាយពីការចុះបញ្ជី និងការស្នើសុំអាជ្ញាប័ណ្ណធ្វើពាណិជ្ជកម្ម និងអាជ្ញាប័ណ្ណនាំចូលផលិតផលរបស់ខ្លួនបាន។*

*ករណីខ្លះទៀត ទំនិញនាំចូលខុសច្បាប់ក៏អាចមានប្រភពមកពីរោងចក្រផលិតតែមួយដូចគ្នាទៅនឹងទំនិញស្របច្បាប់ដែរ ប៉ុន្តែទំនិញទាំងនោះមិនបាននាំចូលតាមប្រភពបណ្តាញចែកចាយស្របច្បាប់ឡើយ ពីព្រោះពុំមានប្រភពច្បាស់លាស់ដែលអាចបញ្ជាក់ថាផលិតផលទាំងនោះត្រូវគ្នាទៅនឹងអ្វីដែលអ្នកលក់មិនមានសិទ្ធិស្របច្បាប់បានអះអាងដែរឬទេ។ ជាលទ្ធផល ផលិតផលទាំងនេះជាទូទៅមិនមានអក្សរខ្មែរនៅលើកញ្ចប់ ឬស្លាកសញ្ញា ដើម្បីឱ្យកសិករកម្ពុជាអាចអនុវត្តតាមសេចក្តីណែនាំអំពីការប្រើប្រាស់បានឡើយ ដែលជាហេតុអាចនាំឱ្យកសិករប្រើផលិតផលទាំងនោះមិនបានត្រឹមត្រូវ ហើយអាចបង្កការខូចខាតដល់ដំណាំរបស់ពួកគាត់ និងបរិស្ថានកម្ពុជាបានទៀតផង។ ស្រដៀងគ្នានេះដែរ ដោយសារតែមិនមានការធានាគុណភាពពីរោងចក្រ ឬក្រុមហ៊ុនចែកចាយ កសិករមិនបានដឹងថាផលិតផលទាំងនោះគឺជាផលិតផលមិនមានគុណភាពតាមស្តង់ដារ ក្លែងក្លាយ ឬមានគ្រោះថ្នាក់ខ្លាំងជាងផលិតផលដែលមានលក់ស្របច្បាប់ដែរឬយ៉ាងណានោះទេ។ អាស្រ័យហេតុនេះ សម្ភារកសិកម្មដែលនាំចូលខុសច្បាប់មកកាន់ប្រទេសកម្ពុជាអាចមិនមានសុវត្ថិភាពខ្លាំងសម្រាប់កសិករ និងអ្នកប្រើប្រាស់ ហើយមានផលប៉ះពាល់អវិជ្ជមានដល់ចីរភាពបរិស្ថានរយៈពេលវែងផងដែរ។*

## ផលប៉ះពាល់លើកម្ពុជា

*ដោយហេតុថាការដែលរំពឹងថាកសិករភាគច្រើននឹងមានចំណេះដឹងបច្ចេកទេសក្នុងការកំណត់ថាតើផលិតផលសម្ភារកសិកម្មដែលពួកគាត់ទិញគឺជាផលិតផលបាននាំចូលស្របច្បាប់នោះគឺជារឿងមិនសមហេតុផលឡើយ ហើយនេះគឺជាទំនួលខុសត្រូវរបស់និយ័តករកម្ពុជាដែលត្រូវពង្រឹងការយល់ដឹងជុំវិញគ្រោះថ្នាក់នៃការប្រើប្រាស់ផលិតផលនាំចូលខុសច្បាប់និងការពង្រឹងការអនុវត្តតាមច្បាប់ឱ្យកាន់តែមានប្រសិទ្ធភាព។ ប្រសិនបើមិនមានការអនុវត្តច្បាប់ទូលំទូលាយទេនោះ ក្រុមហ៊ុនធុរកិច្ចកសិកម្មដែលបានអនុវត្តតាមច្បាប់ នឹងទទួលអត្ថប្រយោជន៍មិនស្មើភាពគ្នាឡើយ ដោយសារតែក្រុមហ៊ុនធុរកិច្ចស្របច្បាប់ទាំងនេះមិនអាចប្រកួតប្រជែងជាមួយផលិតផលខុសច្បាប់ដែលមានតម្លៃទាបឡើយ។ កត្តានេះបានធ្វើឱ្យប៉ះពាល់ដល់កំណើនវិស័យកសិកម្មកម្ពុជា និងសមត្ថភាពទាក់ទាញរបស់វិស័យកសិកម្មនេះដែលជាគោលដៅវិនិយោគ ដោយសារតែផលិតផលខុសច្បាប់ទាំងនោះបានបំផ្លាញកេរ្តិ៍ឈ្មោះម៉ាកផលិតផលយ៉ាងធ្ងន់ធ្ងរ ហើយក្រុមហ៊ុនធុរកិច្ចស្របច្បាប់ទាំងនោះអាចនឹង មិនមានបំណងបន្តដំណើរការ ឬបង្កើនការវិនិយោគរបស់ខ្លួនឡើយ ប្រសិនបើខ្លួនមិនអាចរកប្រាក់ចំណេញបានទេនោះ។ បន្ថែមពីលើនេះទៅទៀត ដោយសារតែក្រុមហ៊ុនចែកចាយផលិតផលនាំចូលខុសច្បាប់ទាំងនោះបានគេចវេសពីលក្ខខណ្ឌតម្រូវចុះបញ្ជី និងការស្នើសុំអាជ្ញាប័ណ្ណដែលកំណត់ដោយក្រសួងកសិកម្ម រាជរដ្ឋាភិបាលបានបាត់ចំណូលជាតិដ៏សំខាន់ និងបានបាត់សមត្ថភាពកត់ត្រាទិន្នន័យត្រឹមត្រូវសម្រាប់ការវិភាគកំណើនរបស់វិស័យនេះបានឡើយ។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ ស្នើស្នើឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអនុវត្តវិធានការអនុវត្តច្បាប់ឱ្យបានតឹងរ៉ឹង នៅពេលចុះត្រួតពិនិត្យនៅតាមចំណុចចែកចាយផលិតផលសម្ភារកសិកម្ម។

ក្រុមហ៊ុនធុរកិច្ចកសិកម្ម ត្រូវការឱ្យមានការធានាជាចាំបាច់ដោយចង់មើលឃើញរាជរដ្ឋាភិបាលចាត់វិធានការតឹងរ៉ឹង ប្រយុទ្ធប្រឆាំងនឹងលំហូរចូលនូវផលិតផលសម្ភារកសិកម្ម នាំចូលខុសច្បាប់មកកម្ពុជា អាស្រ័យហេតុនេះយើងខ្ញុំសូមគោរពស្នើឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តវិធានការអនុវត្តច្បាប់ឱ្យបានតឹងរ៉ឹងនៅពេលចុះត្រួតពិនិត្យលើអ្នកលក់រាយ និងទីតាំងចែកចាយ។ វិធានការនេះអាចដាក់ចេញអមជាមួយនឹងការអនុវត្តតាមវិធានពិន័យសម្រាប់អ្នកប្រព្រឹត្តិល្មើសដដែលៗ និងការរឹបអូសយកផលិតផលដែលមិនបានចុះបញ្ជីនៅក្រសួង។ យើងខ្ញុំក៏សូមស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងកិច្ចសហការអន្តរក្រសួងជាមួយនឹងអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ក៏ដូចជាការផ្ដល់ព័ត៌មានលម្អិតអំពីការចុះបញ្ជីផលិតផលទាំងនោះដល់ស្ថាប័ននេះ ពីព្រោះទាល់តែមានព័ត៌មានគ្រប់គ្រាន់ទើបស្ថាប័ននេះអាចផ្ទៀងផ្ទាត់បានថាតើផលិតនាំចូលណាខ្លះស្រប ឬមិនស្របច្បាប់។

សំខាន់ជាងនេះទៅទៀត យើងខ្ញុំសូមបញ្ជាក់ថាការអនុវត្តច្បាប់មិនគួរអនុវត្តចំពោះកសិករដែលប្រើប្រាស់ផលិតផលសម្ភារកសិកម្មខុសច្បាប់ដោយខ្លួនឯងឡើយ ដោយសារគាត់មិនបានដឹងផលិតផលទាំងនោះខុសច្បាប់ឡើយ ផ្ទុយមកវិញពួកគាត់គួរតែទទួលបានការអប់រំ អំពីគ្រោះថ្នាក់នៃផលិតផលទាំងនោះ និងរបៀបកំណត់អត្តសញ្ញាណផលិតផលខុសច្បាប់ដើម្បីឱ្យពួកគាត់អាចជៀសវាងមិនទិញផលិតផលទាំងនោះលើកក្រោយ។

៣០

# លក្ខខណ្ឌការងារពិសេសសម្រាប់វិស័យកសិកម្ម

ថ្មី

**ពិពណ៌នាបញ្ហា**

ច្បាប់ស្តីពីការងារបានចែងអំពីទំនាក់ទំនងរវាងនិយោជក និងនិយោជិត និងលក្ខខណ្ឌការងារដែលអនុវត្តចំពោះវិស័យឯកជនទាំងអស់ដែលចូលរួមក្នុងសេដ្ឋកិច្ចកម្ពុជា។ ដោយសារតែវិស័យកសិកម្មមានតម្រូវការពិសេសខុសពីវិស័យផ្សេងទៀត ក្រុមហ៊ុនធុរកិច្ចដែលមានកម្មករមានប្រាក់ឈ្នួលជាទៀងទាត់សម្រាប់ការដាំដុះដំណាំសម្រាប់ពាណិជ្ជកម្ម ត្រូវមានកាតព្វកិច្ចបន្ថែមដែលបានចែងដោយច្បាប់ដែលវិស័យឯកជនផ្សេងទៀតមិនត្រូវបានតម្រូវឱ្យអនុវត្តតាមឡើយ។

ជំពូក ៧ នៃច្បាប់ការងារបានចែងអំពីលក្ខខណ្ឌការងារដាក់លាក់ថាក្រុមហ៊ុនធុរកិច្ចកសិកម្មត្រូវផ្តល់ការគាំទ្រដល់កម្មករ និងគ្រួសាររបស់ពួកគាត់ដើម្បីធានាថាពួកគាត់គឺស្រួបច្បាប់ប៉ុ។ កាតព្វកិច្ចទាំងនេះរួមមាន កន្លែងស្នាក់នៅដោយឥតគិតថ្លៃ ប្រាក់ឧបត្ថម្ភសេវាទឹកភ្លើង ចំណីអាហារ ការថែទាំនៅពេលថ្ងៃ និងសំណង់សាលារៀនដែលគ្រប់គ្រងផ្ទាល់ខ្លួនឯងដោយក្រុមហ៊ុនធុរកិច្ចទាំងនោះ។ ទោះបីជាលក្ខខណ្ឌទាំងនេះពិតជាបានបន្ថែម ប្រតិបត្តិការចំណាយច្រើនចំពោះរបស់ធុរកិច្ចកសិកម្មក៏ដោយ ប៉ុន្តែមានក្រុមហ៊ុនធុរកិច្ចជាច្រើនបានទទួលស្គាល់ថាចំណាយនេះគឺជាផ្នែកមួយនៃចំណាយធ្វើធុរកិច្ចនៅក្នុងវិស័យកសិកម្មនៅកម្ពុជា ដោយសារតែចំការភាគច្រើនស្ថិតនៅក្នុងតំបន់ជនបទដាច់ស្រយាល ហើយថានេះគឺជាអត្ថប្រយោជន៍ និងកិច្ចការពារដែលក្រុមហ៊ុនផ្តល់ជូនកម្មកររបស់ខ្លួន។

ចំណុចសំខាន់សម្រាប់ករណីនេះគឺថាអត្ថប្រយោជន៍បន្ថែមទាំងនេះ ជារឿយៗ មិនត្រូវបានយកមកធ្វើការពិចារណាឡើយនៅពេលធ្វើការវាយតម្លៃប្រាក់ឈ្នួលជាក់ស្តែងដែលកម្មករក្នុងវិស័យនេះទទួលបាន។ ទោះបីជាប្រាក់ឈ្នួលសុទ្ធរបស់កម្មករក្នុងវិស័យនេះអាចមានចំនួនទាបជាងកម្មករនៅក្នុងវិស័យផ្សេងទៀត ដោយសារតែក្រុមហ៊ុនក្នុងវិស័យនេះមានបន្ទុកចំណាយចាំបាច់ប្រចាំថ្ងៃជាច្រើនផ្សេងទៀតរបស់កម្មករខ្លួនក្តី ប៉ុន្តែកម្មករនៅក្នុងវិស័យនេះគួរតែស្ថិតនៅក្នុងស្ថានភាពមួយដែលអាចសន្សំប្រាក់ឈ្នួលរបស់ខ្លួនបានច្រើនជាងកម្មករនៅក្នុងវិស័យផ្សេងទៀត ដែលត្រូវចំណាយប្រាក់ឈ្នួលរបស់ខ្លួនទៅលើការស្នាក់នៅ ចំណីអាហារ និងតម្រូវការជាច្រើនផ្សេងទៀត។

ចន្លោះប្រហោងកន្លែងនេះ កំពុងតែធ្វើឱ្យមានក្តីកង្វល់ខ្លាំងសម្រាប់ក្រុមហ៊ុនធុរកិច្ចក្នុងកសិកម្មដោយសារតែនាពេលថ្មីៗនេះមានការពិភាក្សាច្រើនជុំវិញលទ្ធភាពដាក់ឱ្យអនុម័តស្តង់ដារនៃប្រាក់ឈ្នួលអប្បបរមាសម្រាប់វិស័យច្រើនបន្ថែមទៀត ក្រៅពីវិស័យកាត់ដេរ វាយនភ័ណ្ឌ និងស្បែកជើង។ ទោះបីជានាពេលបច្ចុប្បន្នប្រាក់ឈ្នួលអប្បបរមាត្រូវបានអនុវត្តតែនៅក្នុងវិស័យផលិតកម្មទាំងនេះក៏ដោយ ប៉ុន្តែវាមានឥទ្ធិពលរួចទៅហើយទៅលើប្រាក់ឈ្នួលរបស់វិស័យផ្សេងទៀត ដោយសារតែកម្មករនិយោជិតជាច្រើនបានរំពឹងថានឹងទទួលបានប្រាក់ឈ្នួលដូចគ្នាទៅនឹងកម្មករនិយោជិតនៅក្នុងវិស័យកាត់ដេរ វាយនភ័ណ្ឌ និងស្បែកជើង ដែលជាហេតុធ្វើឱ្យក្រុមហ៊ុននៅក្នុងវិស័យនេះមានចំណាយកើនឡើងលើការប្រកួតប្រជែងរបស់ខ្លួន។

ក្រុមហ៊ុនធុរកិច្ចនៅក្នុងវិស័យកសិកម្ម ទទួលស្គាល់ថាកត្តានេះអាចនឹងបង្កជាបញ្ហាក្នុងការទាក់ទងជា មួយនឹងក្រុមកម្មករនិយោជិត ដោយសារតែពួកគាត់ចាំបាច់ត្រូវតែលើកកម្ពស់ការយល់ដឹងអំពីភាពខុសគ្នារវាងការទទួលបានប្រាក់ឈ្នួលសុទ្ធទាបជាងបន្តិច តែមានអត្ថប្រយោជន៍បន្ថែមជាច្រើនសម្រាប់កម្មករនិយោជិត បើធៀបទៅនឹងការទទួលបានប្រាក់ឈ្នួលសុទ្ធខ្ពស់ជាង តែទទួលបានអត្ថប្រយោជន៍បន្ថែមតិចតួចៗ ស្រដៀងគ្នានេះដែរ ក៏មានការចាំបាច់ក្នុងការលើកកម្ពស់ការយល់ដឹងអំពីចំណុចនេះសម្រាប់អ្នកធ្វើគោលនយោបាយផងដែរ ដើម្បីធានាថាកាតព្វកិច្ចពិសេសដែលមានសម្រាប់វិស័យកសិកម្ម និងអត្ថប្រយោជន៍បន្ថែមជាច្រើនដែលផ្តល់ឱ្យត្រូវបានយកមកធ្វើការពិចារណានៅពេលធ្វើការពិភាក្សាអំពីកំណែទម្រង់ការងារនាពេលអនាគត។

## ផលប៉ះពាល់លើកម្ពុជា

ទោះបីជាការអនុវត្តគំនិតផ្តួចផ្តើមជាច្រើនរបស់រាជរដ្ឋាភិបាលដើម្បីដាក់អនុវត្តកិច្ចការពារការងារជាផ្លូវការនេះ ទទួលបានការស្វាគមន៍យ៉ាងច្រើនពីសហគមន៍ធុរកិច្ចក៏ដោយ ប៉ុន្តែកំណែទម្រង់ទាំងនោះចាំបាច់ត្រូវរក្សាតុល្យភាពសមស្របរវាងតម្រូវការរបស់កម្មករ និងតម្រូវការរបស់ក្រុមហ៊ុនធុរកិច្ចដើម្បី ធានាថាកម្ពុជានៅតែអាចរក្សាសមត្ថភាពប្រកួតប្រជែងរបស់ខ្លួនបាន។ ប្រសិនបើថ្លៃចំណាយលើកម្លាំងពលកម្មនៅតែបន្តកើនឡើងដោយមិនមានផលិតភាពសមស្របទេនោះ កម្ពុជានឹងបាត់បង់ឧត្តមភាពប្រកួតប្រជែងរបស់ខ្លួន ដែលជាមូលដ្ឋានផលិតកម្មមានថ្លៃចំណាយទាបហើយអាចនឹងបង្ខំឱ្យក្រុមហ៊ុនធុរកិច្ចជាច្រើនប្តូរទៅកាន់ប្រទេសផ្សេងទៀត ហើយប្រសិនបើករណីនេះកើតឡើង នឹងធ្វើឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់កំណើនសេដ្ឋកិច្ចកម្ពុជានាពេលអនាគតជាក់ជាមិនខាន។

លើសពីនេះទៅទៀត ក្រុមហ៊ុនពាណិជ្ជកម្មមានការលំបាកខ្លាំងរួចហើយនៅក្នុងការប្រកួតប្រជែងនៅក្នុងទីផ្សារដែលមានការប្រកួតប្រជែងខ្ពស់ ដោយសារតែសហគ្រាសកសិកម្មតូចៗ និងវិស័យផ្សេងទៀតមិនត្រូវបានតម្រូវឱ្យផ្តល់អត្ថប្រយោជន៍បន្ថែមដូចមានរៀបរាប់លម្អិតខាងលើសនោះទេ និងអាចគេចផុតពីការចំណាយដ៏ច្រើនលើសលុបនេះ។ នៅពេលយកថ្លៃចំណាយទាំងនេះមកបូករួមបញ្ចូលជាមួយនឹង ការកំណែទម្រង់ការងារថ្មីៗនេះដូចជា បេឡាជាតិរបបសន្តិសុខសង្គម ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ និងកម្មវិធីប្រាក់សោធននាពេលខាងមុខ យើងកត់សម្គាល់ឃើញថាប្រសិទ្ធភាពថ្លៃចំណាយ និងកត្តាអំណោយផលផ្នែកសេដ្ឋកិច្ចសម្រាប់កិច្ចការពារសម្រាប់ផលិតកម្មកសិកម្មសម្រាប់ពាណិជ្ជកម្មនៅកម្ពុជា នឹងមានការធ្លាក់ចុះទាបជាងមុន នេះមិនទាន់រាប់បញ្ចូលផងនូវបន្ទុកបន្ថែមដែលអាចនឹងមាន ដោយសារតែប្រាក់ឈ្នួលអប្បបរមាស្តង់ដារនាពេលអនាគត។

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យផ្តល់ការធានាថារាជរដ្ឋាភិបាលនឹងធ្វើការពិចារណាលើអត្ថប្រយោជន៍បន្ថែម និងលក្ខខណ្ឌការងារដែលក្រុមហ៊ុនធុរកិច្ចកសិកម្មបានផ្តល់ជូនកន្លងមក នៅពេលអនុវត្តកម្មវិធីកំណែទម្រង់ការងារថ្មី។

*ទោះបីជាយើងខ្ញុំស្វាគមន៍ចំពោះការបង្កើតឱ្យអនុវត្តជាផ្លូវការនូវកិច្ចការពារការងាររបស់កម្ពុជា និងដោយទទួលស្គាល់នូវសេចក្តីត្រូវការជាចាំបាច់នូវប្រាក់ឈ្នួលដែលអាចរស់នៅបានសម្រាប់ប្រជាពលរដ្ឋកម្ពុជាក៏ដោយ ក៏សមាជិករបស់យើងខ្ញុំយល់ឃើញថាចំណុចដែលបានរៀបរាប់ខាងលើចាំបាច់ត្រូវតែអនុវត្តដោយរក្សាឱ្យបាននូវតុល្យភាពរវាងតម្រូវការរបស់ក្រុមហ៊ុនធុរកិច្ចកសិកម្ម និងតម្រូវការរបស់កម្មករនិយោជិត។ អាស្រ័យហេតុនេះ យើងខ្ញុំសូមគោរពស្នើឱ្យរាជរដ្ឋាភិបាលធ្វើការពិចារណាទៅលើអត្ថប្រយោជន៍បន្ថែម និងលក្ខខណ្ឌការងារដែលក្រុមហ៊ុនធុរកិច្ចបានផ្តល់រួចហើយ នៅពេលអនុវត្តកម្មវិធីកំណែទម្រង់ការងារថ្មីដើម្បីធានាថាវិស័យកសិកម្មកម្ពុជានៅតែមានសមត្ថភាពប្រកួតប្រជែងខ្ពស់ដូចមុនដដែល។*

៣១

# ស្រូវកូនកាត់

ថ្មី

**ពិពណ៌នាបញ្ហា**

*តាមរយៈកិច្ចខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល និងវិស័យកសិកម្មនៅក្នុងការពង្រីក និងធ្វើទំនើបកម្មផលិតកម្មស្រូវ កម្ពុជាបានក្លាយទៅជាប្រទេសនាំចេញមានសមត្ថភាពប្រកួតប្រជែងកាន់តែខ្ពស់ ដែលធ្វើការផ្គត់ផ្គង់ទៅកាន់ទីផ្សារក្នុងតំបន់ និងទីផ្សារអន្តរជាតិ។ ទោះបីជាមានការយកចិត្តទុកដាក់ខ្ពស់ទៅលើការនាំចេញប្រភេទអង្ករក្រអូបប្រណីត ដែលត្រូវការតម្លៃកាន់តែខ្ពស់ និងមានការទទួលស្គាល់ពីទីផ្សារអន្តរជាតិក៏ដោយ ប៉ុន្តែប្រភេទអង្ករធម្មតាជារឿយៗ មានការលំបាកក្នុងការប្រកួតប្រជែងជាមួយនឹងការនាំចេញរបស់ប្រទេសវៀតណាម។ ដោយហេតុថាទីផ្សារអង្កររបស់ពិភពលោកមានទំហំធំធេង និងមានចំណែកទីផ្សារខុសៗគ្នាជាច្រើននោះ ប្រទេសកម្ពុជាគួរខិតខំធ្វើពិពិធកម្មពូជស្រូវតាមរយៈការបង្កើនផលិតកម្មស្រូវធម្មតាដើម្បីធានាថាខ្លួននៅតែមានភាពប្រកួតប្រជែងខ្ពស់ និងអាចសម្រេចបានគោលដៅនាំចេញអង្កររបស់ខ្លួនដោយភាពជោគជ័យ។*

*មធ្យោបាយមានប្រសិទ្ធភាពនៅក្នុងការបង្កើនផលិតកម្មស្រូវប្រភេទផ្សេងៗនៅតាមបណ្តាប្រទេសដាំដុះស្រូវឈានមុខគេផ្សេងៗទៀត ជាពិសេសគឺប្រទេសចិន ហ្វីលីពីន វៀតណាម ឥណ្ឌា គឺធ្វើឡើងតាមរយៈការប្រើប្រាស់ពូជស្រូវកូនកាត់។ ពូជស្រូវកូនកាត់គឺជាប្រភេទពូជដែលបានបង្កាត់យ៉ាងសម្រិតសម្រាំងពីពូជស្រូវមេចំនួនពីរខុសគ្នាដើម្បីបង្កាត់ទៅជាពូជកូនកាត់នៃពូជទាំងពីរនោះ។ ដំណើរការនេះអាចផលិតបានជាពូជស្រូវដែលអាចមានទិន្នផលខ្ពស់ជាងពូជ ដែលបានបង្កាត់តាមវិធីសាស្ត្រចាស់ប្រហាក់ប្រហែលគ្នា រហូតដល់ទៅពី ១៥% ទៅ ៣០% ហើយក៏ជាប្រភេទពូជដែលធន់នឹងកង្វះខាតទឹក ជាតិប្រៃ សីតុណ្ហភាពខ្ពស់ និងសត្វល្អិតចង្រៃនានាផងដែរ។*

*ទោះជាយ៉ាងនេះក្តី ដំណើរការបង្កាត់ពូជខ្វែងនេះ បង្កើតបានទៅជាពូជស្រូវដែលមិនអាចទុកជាពូជសម្រាប់សាបព្រោះម្តងទៀតបានឡើយ ហើយដោយសារតែមានបញ្ហាប្រឈមផ្នែកបច្ចេកទេស ទើបដំណើរការនេះចាំបាច់ត្រូវតែមានការគ្រប់គ្រងដោយផលិតករគ្រាប់ពូជជាលក្ខណៈ ពាណិជ្ជកម្មទើបមានប្រសិទ្ធភាព។ម្យ៉ាងវិញទៀត ដោយហេតុតែពូជស្រូវកូនកាត់នេះមិនអាចយកទៅប្រើជាគ្រាប់ពូជសម្រាប់ប្រមូលផលលើកក្រោយបាន កសិករចាំបាច់ត្រូវតែទិញពូជស្រូវនេះថ្មីទៀតសម្រាប់ធ្វើជាពូជសាបព្រោះតាមរដូវកាលនីមួយៗ ហើយគ្រាប់ពូជទាំងនេះមានតម្លៃខ្ពស់ជាងប្រភេទពូជស្រូវធម្មតា។ ទោះបីជាប្រភេទពូជនេះផ្តល់នូវទិន្នផលខ្ពស់ក៏ដោយ ប៉ុន្តែ ក្នុងការសាបព្រោះគឺត្រូវការបរិមាណគ្រាប់ពូជតិចជាងប្រភេទស្រូវធម្មតាឆ្ងាយណាស់។ ដោយសារថ្លៃចំណាយខ្ពស់លើគ្រាប់ពូជ និងលក្ខខណ្ឌជី និងសត្វល្អិតចង្រៃបន្ថែមផ្សេងៗទៀត គេចាំបាច់ត្រូវតែធ្វើការវាយតម្លៃលើប្រសិទ្ធភាពថ្លៃចំណាយនៃប្រភេទស្រូវកូនកាត់នេះដើម្បីដឹងថាតើប្រភេទពូជស្រូវនេះមានលក្ខណៈសមស្របសម្រាប់កសិករមួយចំនួនដែរឬទេ។*

*បច្ចុប្បន្ន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមិនអនុញ្ញាតឱ្យក្រុមហ៊ុនកសិកម្មធ្វើការចុះបញ្ជីផលិតផលអង្ករកូនកាត់សម្រាប់ប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្ម*

ឡើយ ដែលបានរារាំងយ៉ាងមានប្រសិទ្ធភាពទៅលើការប្រើប្រាស់ប្រភេទពូជនេះជាផ្លូវការនៅក្នុងប្រទេសកម្ពុជា។ គោលជំហរ នេះអាចដោយសារតែមានការភាន់ច្រឡំជុំវិញការចាត់ថ្នាក់មិនត្រឹមត្រូវនូវប្រភេទដំណាំកូនកាត់ជា សារពាង្គកាយដែលបានធ្វើកំណែប្រែសេនេទិច (GMO)។ GMO មានលក្ខណៈខុសគ្នាទាំងស្រុងពីដំណាំកូនកាត់ដោយសារ GMO ត្រូវបានបង្កើតឡើងដោយការដាក់បញ្ចូលគ្នានូវសារធាតុសេនេទិច ពីសារពាង្គកាយដែលមានលក្ខណៈខុសគ្នាទាំងស្រុង ដែលមិនអាចកើតឡើងដោយធម្មជាតិបានឡើយ ចំណែកពូជកូនកាត់គឺស្ថិតក្នុងអំបូរតែមួយ ហើយសេនេទិចក៏មានលក្ខណៈដូចគ្នាដែរ ដូច្នេះពុំមានការព្រួយបារម្ភផ្នែកសុខភាព ឬការរឹតត្បិតទៅលើការនាំចេញផលិតផលសម្រេចនោះឡើយ។

ចំណុចនេះត្រូវបានបញ្ជាក់ឱ្យឃើញតាមរយៈអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលកាលពីពេលថ្មីៗនេះបានបង្កើតប្រភេទពោតកូនកាត់ផ្ទាល់ខ្លួនដែលមានឈ្មោះថា "BNT-5666" ដោយមានជំនួយពីកម្មវិធីកសិកម្មអន្តរជាតិកូរ៉េ (KOPIA)។ ប្រភេទពោតកូនកាត់នេះ បានបង្កើនទិន្នផលយ៉ាងច្រើន និងមានភាពធន់ខ្ពស់ទៅនឹងជំងឺ ហើយរំពឹងថានឹងផ្ដល់ជូនសម្រាប់កសិករប្រើប្រាស់នៅក្នុងឆ្នាំ2019 នេះ។ ស្រដៀងគ្នានេះដែរ អង្ករមានគុណភាពទាបជាច្រើនដែលបានដាក់លក់សម្រាប់បរិភោគក្នុងប្រទេសកម្ពុជា គឺជាប្រភេទអង្ករកូនកាត់ដែលបានដាំដុះនៅក្រៅផ្លូវការនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ រួចបន្ទាប់មកធ្វើការដឹកជញ្ជូនទៅកាន់ប្រទេសវៀតណាមដើម្បីធ្វើការកែច្នៃ រួចទើបនាំចេញត្រឡប់ទៅវិញ ដោយសារសមត្ថភាពកែច្នៃអង្ករបស់ប្រទេសកម្ពុជាផ្ដោតតែទៅលើប្រភេទអង្ករប្រណីតប៉ុណ្ណោះ។

អាស្រ័យហេតុនេះ ដោយហេតុថាអត្ថប្រយោជន៍នៃដំណាំកូនកាត់ត្រូវបានទទួលស្គាល់ដោយក្រសួងកសិកម្ម ហើយអង្ករកូនកាត់មានដាក់លក់យ៉ាងទូលំទូលាយរួចស្រេចទៅហើយ ដូច្នេះគួរតែអនុញ្ញាតឱ្យក្រុមហ៊ុនកសិកម្មធ្វើការចុះបញ្ជីប្រភេទស្រូវកូនកាត់សម្រាប់ប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជាដើម្បីឱ្យកសិករអាចធ្វើពិពិធកម្មផលិតកម្ម និងប្រមូលផល សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុកជាផ្លូវការ។

## ផលប៉ះពាល់លើកម្ពុជា

ការកាត់បន្ថយភាពក្រីក្រយ៉ាងមានប្រសិទ្ធភាពនៅតាមតំបន់ជនបទ នៅទូទាំងប្រទេសកម្ពុជា ដែលប្រទេសនេះសម្រេចបាន គឺមួយផ្នែកធំកើតចេញពីកំណើនតម្រូវការ និងប្រាក់ចំណូលពីការដាំដុះស្រូវ ដោយសារស្រូវគឺជាដំណាំ និងប្រភព ប្រាក់ចំណូលចម្បងរបស់ប្រជាជនកម្ពុជាចំនួន ៨៥%នៅតាមតំបន់ជនបទ។ ទោះបីយ៉ាងណាក៏ដោយ ដោយសារតែផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងភាពប្រកួតប្រជែងកាន់តែខ្លាំងនៅលើទីផ្សារពិភពលោក ប្រភពប្រាក់ចំណូលចម្បងនេះទទួលរងការគំរាមកំហែងគួរឱ្យព្រួយបារម្ភ។ ពូជស្រូវកូនកាត់ផ្ដល់ជូនកសិករ នូវដំណោះស្រាយលើបញ្ហាភាពធន់ទៅនឹងអាកាសធាតុ និងជាដំណោះស្រាយ ប្រកប ដោយចីរភាពនៅក្នុងការបង្កើនទិន្នផល និងពង្រីកផលិតភាព ដូច្នេះពូជស្រូវនេះ នឹងបង្កើនប្រាក់ចំណូលសម្រាប់កសិករ ព្រមទាំងរួមចំណែកពង្រឹងសន្តិសុខស្បៀង របស់ប្រទេសកម្ពុជាផងដែរ។ ស្រដៀងគ្នាទៅនឹងគំនិតផ្ដួចផ្ដើមអំពីពោតកូនកាត់ របស់អគ្គនាយកដ្ឋានកសិកម្មដែរ ប្រទេសកម្ពុជាក៏អាចអភិវឌ្ឍប្រភេទពូជ ស្រូវកូនកាត់ផ្ទាល់ខ្លួនដែលអាចលក់នៅ

*ក្នុងទីផ្សារផ្សេងៗទៀតបានដោយបង្កើតនូវកម្មសិទ្ធិបញ្ញា និងលំហូរប្រាក់ចំណូលបន្ថែមនៅពេលតម្រូវការពូជកូនកាត់មានការកើនឡើង។*

*ជាងនេះទៅទៀត ការបង្កើតគោលនយោបាយកាលពីពេលថ្មីៗនេះនៅក្នុងប្រទេសវៀតណាម ជាសញ្ញាបង្ហាញថា រដ្ឋាភិបាលវៀតណាមចង់ប្តូរការផលិតស្រូវពីប្រភេទពូជមានតម្លៃទាប ទិន្នផលខ្ពស់ ទៅជាផលិតផលដែលមានតម្លៃខ្ពស់ ដើម្បីឱ្យកសិករអាចបង្កើនកម្រិតប្រាក់ចំណូលរបស់ខ្លួន។ ទោះបីជាឥទ្ធិពលនេះត្រូវការពេលវេលាមួយចំនួន មុននឹងរីកសាយភាយមកដល់ប្រទេសកម្ពុជាក៏ដោយ ប៉ុន្តែ នេះគឺជាបញ្ហាប្រឈមចំពោះផលិតកម្មស្រូវប្រណីតដោយសារតែសមត្ថភាពឧស្សាហកម្មខ្ពស់របស់ប្រទេសវៀតណាម។ ដូច្នេះ នៅក្នុងការអនុវត្តជាក់ស្តែង ប្រភេទស្រូវកូនកាត់អាចផ្តល់នូវដំណោះស្រាយសម្រាប់កសិករកម្ពុជានៅក្នុងការធ្វើពិពិធកម្មផលិកម្មរបស់ខ្លួនដើម្បីធានាថាខ្លួននៅតែអាចមានលទ្ធភាពប្រកួតប្រជែងខ្ពស់នៅក្នុងប្រភេទស្រូវផ្សេងៗទៀត និងដើម្បីស្របទៅតាមគោលបំណងគោលនយោបាយអង្កររបស់ប្រទេសកម្ពុជា ដែលខិតខំបង្កើនការនាំចេញឱ្យក្លាយជាប្រទេសឈានមុខគេនៅក្នុងពិភពលោកផ្នែកពាណិជ្ជកម្មអង្ករ។*

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមពិចារណាផ្តល់ការអនុញ្ញាតឱ្យពូជស្រូវកូនកាត់អាចដាំដុះ និងចុះបញ្ជីដោយស្របច្បាប់នៅក្នុងប្រទេសកម្ពុជា។

*ទោះបីប្រភេទស្រូវកូនកាត់មានទាំងលក្ខណៈវិជ្ជមាន និងអវិជ្ជមាន ដែលធ្វើឱ្យស្រូវប្រភេទនេះមានលក្ខណៈសមស្របសម្រាប់ការអនុវត្តមួយចំនួនក៏ដោយ ប៉ុន្តែកសិករគួរទទួលបាននូវឱកាសប្រើប្រាស់ដំណាំច្នៃប្រឌិត និងទំនើបនេះដើម្បីបង្កើនផលិតកម្ម និងប្រាក់ចំណូលរបស់ខ្លួន។ អាស្រ័យហេតុនេះ យើងខ្ញុំសូមផ្តល់ជូនអនុសាសន៍ដោយការគោរពដោយស្នើឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មេត្តាពិចារណាអនុញ្ញាតឱ្យពូជស្រូវកូនកាត់នេះអាចចុះបញ្ជីដោយស្របច្បាប់ និងដាំដុះជាផ្លូវការក្នុងប្រទេសកម្ពុជាដោយក្តីអនុគ្រោះ។*

## ៣២

# លក្ខខណ្ឌកំណត់ឱ្យប្រើប្រាស់មន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន

ថ្មី

**ពិពណ៌នាបញ្ហា**

*បន្ទាប់ពីកើតមានហេតុការណ៍ធ្ងន់ធ្ងរជាច្រើន ពាក់ព័ន្ធនឹងការបំពុលប្រភពទឹកធម្មជាតិដែលសង្ស័យថាចេញមកពីសម្ភារកសិកម្ម ក្រសួងបរិស្ថានបានចាប់ផ្តើមតម្រូវឱ្យក្រុមហ៊ុនធុរកិច្ចដែលពាក់ព័ន្ធនឹងកសិកម្មបែបពាណិជ្ជកម្មត្រូវធ្វើតេស្តគុណភាពទឹកដើម្បីធានាថា រាល់សកម្មភាពរបស់ខ្លួន មិនបង្កឱ្យខូចខាតដល់បរិស្ថាន។ ទោះបីក្រោយមកមានការបញ្ជាក់ថា ហេតុការណ៍បំពុលទឹកទាំងនោះមិនបណ្តាលមកពីបញ្ហានៃប្រតិបត្តិការកសិកម្មនៅក្បែរនោះក៏ដោយ ក៏លក្ខខណ្ឌដែលកំណត់ឱ្យក្រុមហ៊ុនធុរកិច្ចធ្វើតេស្តគុណភាពទឹកប្រចាំឆមាសនៅតែអនុវត្តដដែល។*

*ក្រុមហ៊ុនធុរកិច្ចកសិកម្មបានឯកភាពថា ការធ្វើតេស្តបរិស្ថានជាទៀងទាត់គឺជាផ្នែកសំខាន់នៃប្រតិបត្តិការរបស់ខ្លួន ដោយសារប្រភពទឹកធម្មជាតិ ងាយនឹងរងគ្រោះថ្នាក់ដោយសារការបំពុលប្រសិនបើពុំមានការគ្រប់គ្រងឱ្យបានល្អទេ។ ប៉ុន្តែសមាជិកយើងបានបញ្ជាក់ថា ដើម្បីបំពេញកាតព្វកិច្ចនេះបាន ក្រុមហ៊ុនធុរកិច្ចត្រូវប្រើប្រាស់មន្ទីរពិសោធន៍ផ្ទាល់របស់ក្រសួងបរិស្ថាន។ ក្រសួងបានជូនដំណឹងដល់ក្រុមហ៊ុនធុរកិច្ចថា ការកំណត់បែបនេះគឺដោយសារតែខ្លួនមិនអាចធ្វើការបញ្ជាក់ចំពោះភាពអាចទុកចិត្តបាន និងសុក្រឹតភាពនៃមន្ទីរពិសោធន៍នៅក្រៅការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល។*

*ទោះបីជាបែបនេះក្តី ក៏សមាជិកយើងមានការព្រួយបារម្ភ ពាក់ព័ន្ធនឹងមន្ទីរពិសោធន៍របស់ក្រសួង ដោយសារសមាជិកទាំងនោះបានទទួលលទ្ធផលមិនត្រឹមត្រូវ និងមិនអាចជឿជាក់បាន ដែលភាគច្រើនគឺដោយសារតែធនធាន និងការអភិវឌ្ឍសមត្ថភាពរបស់មន្ទីរពិសោធន៍នៅមានកម្រិត។ ក្រុមហ៊ុនធុរកិច្ចភាគច្រើនបានប្រើមន្ទីរពិសោធន៍ឯកជនរបស់ភាគីទីបីដើម្បីធ្វើតេស្តលើការគ្រប់គ្រងគុណភាពទឹក និងការវិភាគហេតុប៉ះពាល់បរិស្ថាន ព្រមទាំងផ្អែកលើលទ្ធផលត្រឹមត្រូវ និងឥតលម្អៀងបានមកពីការធ្វើតេស្តទាំងនោះដើម្បីធ្វើការសម្រេចចិត្តវិនិយោគ និងពាណិជ្ជកម្មរបស់ខ្លួនផងដែរ។ ដូច្នេះ ការធ្វើតេស្តឯកជននឹងក្លាយជាយន្តការកាន់តែមានប្រសិទ្ធភាពដើម្បីធានាថា ប្រតិបត្តិការកសិកម្មបែបពាណិជ្ជកម្មមិនបង្កការខូចខាតដល់ប្រព័ន្ធបរិស្ថាន។*

**ផលប៉ះពាល់លើកម្ពុជា**

*លក្ខខណ្ឌកំណត់ឱ្យប្រើប្រាស់មន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន បានបន្ថែមការចំណាយ មិនចាំបាច់លើធុរកិច្ចកសិកម្ម ដោយសារក្រុមហ៊ុនធុរកិច្ច ត្រូវការសុក្រឹតភាពដែលមាន កម្រិតខ្ពស់ជាងមន្ទីរពិសោធន៍របស់ក្រសួងអាចផ្តល់ឱ្យបាន ដូច្នេះ ក្រុមហ៊ុនធុរកិច្ចចាំបាច់ត្រូវចំណាយលើការធ្វើតេស្តទ្វេដង។ ដូចគ្នានេះដែរ ការកំណត់ឱ្យក្រុមហ៊ុនធុរកិច្ចកសិកម្មទាំងអស់ត្រូវធ្វើតេស្តតាមរយៈក្រសួងអាចដាក់ បន្ទុកហួសកម្រិតលើធនធានរបស់ក្រុមហ៊ុន ធ្វើឱ្យថយចុះប្រសិទ្ធផលរបស់ខ្លួន និងធ្វើឱ្យមានភាពយឺតយ៉ាវដល់ការអនុវត្តតាមច្បាប់។ ប៉ុន្តែ ក្នុងករណីដែលក្រុមហ៊ុនធុរកិច្ចដែលត្រូវបានអនុញ្ញាតឱ្យប្រើមន្ទីរពិសោធន៍ឯកជន នោះបន្ទុកការងារ អាចរំលែកទៅដល់ផ្នែកជាច្រើនផ្សេងទៀតដើម្បីធានាការផ្តល់ សេវាទាន់ ពេលវេលា។ ប្រសិនបើកិច្ចការនេះនៅតែ*

*បន្តក្នុងលក្ខណៈផ្តាច់មុខ នោះនឹងធ្វើឱ្យកើនឡើងនូវការចំណាយក្នុងការធ្វើធុរកិច្ច និងបន្ទុករដ្ឋបាលសម្រាប់ក្រុមហ៊ុនអនុវត្តតាមច្បាប់ ហើយចុងក្រោយនឹងធ្វើឱ្យថយចុះនូវសមត្ថភាពប្រកួតប្រជែងនៃវិស័យកសិកម្មដែលកំពុងកើនឡើងរបស់កម្ពុជា។*

*ជាងនេះទៅទៀត ដោយសារគោលបំណងតែមួយគត់នៃមន្ទីរពិសោធន៍ឯករាជ្យគឺដើម្បីធ្វើតេស្តសម្រាប់ភាគីទីបី នោះសុចរិតភាពនៃមន្ទីរពិសោធន៍ទាំងនោះគឺផ្អែកលើសមត្ថភាពរបស់ខ្លួនក្នុងការផ្តល់លទ្ធផលអាចជឿជាក់បាន ត្រឹមត្រូវ និងឥតលម្អៀងដោយមិនស្ថិតក្រោមឥទ្ធិពល និងការគ្រប់គ្រងរបស់ភាគីពាក់ព័ន្ធឡើយ។ ស្របគ្នានេះដែរ មន្ទីរពិសោធន៍ទាំងនោះបានវិនិយោគធនធានយ៉ាងច្រើនទៅលើបរិក្ខារ និងបុគ្គលិករបស់ខ្លួនដើម្បីរក្សាបានភាពឥតលម្អៀង និងសុក្រឹតភាពរបស់ខ្លួនដើម្បីធានាថា អតិថិជនខ្លួននឹងបន្តប្រើមន្ទីរពិសោធន៍នេះសម្រាប់ធ្វើតេស្ត និងវិភាគដើម្បីជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចលើធុរកិច្ចរបស់ខ្លួន។*

✓ ស្នើសុំការបញ្ជាក់ថា តើក្រុមហ៊ុនធុរកិច្ចចាំបាច់ត្រូវប្រើមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថានដើម្បីធ្វើការធ្វើតេស្តគុណភាពទឹកដែរឬទេ។

**អនុសាសន៍ឆ្នាំ ២០១៩**

*ទោះបីសមាជិកយើងទទួលស្គាល់ពីសារសំខាន់នៃការវិភាគអំពីផលប៉ះពាល់បរិស្ថានដោយទៀងទាត់ដើម្បីធានាថា ធុរកិច្ចកសិកម្មមិនបណ្តាលឱ្យមានផលអវិជ្ជមានលើបរិស្ថានកម្ពុជាក៏ដោយ យើងគិតថា ការសំខាន់ដែលការវិភាគនេះត្រូវធ្វើឡើងនៅមន្ទីរពិសោធន៍ឯករាជ្យ ជាភាគីទីបីដែលអាចធានា ចំពោះសុក្រឹតភាព និងភាពឥតលម្អៀងនៃលទ្ធផលរបស់ខ្លួន។ ដូច្នេះ យើងខ្ញុំសូមគោរពស្នើ ឱ្យក្រសួងបរិស្ថានបញ្ជាក់ឱ្យបានច្បាស់ថា តើក្រុមហ៊ុនធុរកិច្ចកសិកម្មចាំបាច់ត្រូវប្រើប្រាស់មន្ទីរពិសោធន៍របស់ក្រសួងដើម្បីធ្វើតេស្តគុណភាពទឹកដែរឬទេ ហើយប្រសិនបើតម្រូវឱ្យប្រើ សូមពិចារណាអនុញ្ញាតឱ្យក្រុមហ៊ុនធុរកិច្ចទាំងនោះដាក់លទ្ធផលធ្វើតេស្តដែលទទួលបានពីមន្ទីរពិសោធន៍ឯករាជ្យដែលមានកេរ្តិ៍ឈ្មោះល្អក្នុងការធ្វើតេស្តគុណភាពទឹក។*

# វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

រាជរដ្ឋាភិបាលទទួលស្គាល់នូវតួនាទីដ៏សំខាន់របស់វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ដែលកំពុងមានការរីកចម្រើនខ្លាំងរបស់កម្ពុជានៅក្នុងការរួមចំណែកសម្រេចនូវ ផែនការរបស់ព្រះរាជាណាចក្រឆ្ពោះទៅធ្វើពិពិធកម្មសេដ្ឋកិច្ច ព្រមទាំងបានអនុវត្តកិច្ចប្រឹងប្រែងជាច្រើនដើម្បីពង្រឹងការចូលរួម និងការប្រាស្រ័យទាក់ទងរបស់វិស័យនេះ ជាមួយនឹងភាគី ពាក់ព័ន្ធដទៃទៀតនៅក្នុងវិស័យនេះ។ ភាពល្អប្រសើរឡើងនេះត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈវិធីសាស្ត្រពិគ្រោះយោបល់ដែលអនុវត្តដោយរាជរដ្ឋាភិបាល នៅក្នុងដំណើរការពីដើមដល់ចប់ក្នុងការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក ដែលគណៈកម្មាធិការបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា បានចូលរួមជាដៃគូសន្ទនា ដ៏សំខាន់ក្នុងនាមជាតំណាង មកពីវិស័យឯកជន។ សមាជិកគណៈកម្មាធិការបានផ្តល់មតិត្រឡប់យ៉ាងលម្អិតទៅលើសមាសធាតុនីមួយៗនៃច្បាប់ថ្មីនេះ ដើម្បីធ្វើការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័ត៌មានលម្អិតផ្នែកបច្ចេកទេស និងផ្តល់នូវអនុសាសន៍ដែលមានប្រយោជន៍សំដៅលើកកម្ពស់សុខដុមនីយកម្មថ្នាក់តំបន់ ព្រមទាំងធានាថា បទប្បញ្ញត្តិនានានឹងមិនបង្អាក់ដល់ការច្នៃប្រឌិតដើម្បីផលប្រយោជន៍របស់ប្រទេសកម្ពុជាឡើយ។ យើងជឿជាក់ថា រាជរដ្ឋាភិបាលចាត់ទុកមតិយោបល់ និងការណែនាំរបស់យើងថាមានលក្ខណៈស្ថាបនា ខណៈដែលខ្លួនរៀបចំបញ្ចប់ជាស្ថាពរនូវក្របខ័ណ្ឌច្បាប់ ដ៏សំខាន់បំផុតមួយនេះ។

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានផ្តល់ការគាំទ្រយ៉ាងទូលំទូលាយ ដល់អន្តរកម្មឌីជីថលដែលកំពុងត្រូវបានអនុវត្ត និងចូលរួមជាប្រចាំ ជាមួយនឹងវិស័យឯកជន ដើម្បីដោះស្រាយរបាំងទាំងឡាយណាដែលអាចរារាំងដល់ភាពជោគជ័យនា ពេលអនាគត នៃវិស័យសេដ្ឋកិច្ចឌីជីថលរបស់កម្ពុជា។ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាមានសំណាង ដែលបានចូលរួមចំណែកគាំទ្រដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ព្រមទាំងក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងការរៀបចំវេទិកាស្តីពីការចាប់ផ្តើមជំនួញបច្ចេកវិទ្យា និងសហគ្រាសធុនតូច និងមធ្យម (MSME) កាលពីខែឧសភា ឆ្នាំ២០១៨ កន្លងទៅ ដែល

នៅក្នុងវេទិកានេះ ក្រុមហ៊ុននានាបានពិភាក្សាអំពីកាលានុវត្តភាព និងភាពប្រឈម នៃការចាប់យកបច្ចេកវិទ្យាថ្មីៗ។

ជុំវិញវឌ្ឍនភាពបន្ថែមទៀតសម្រាប់ជំពូកនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានផ្តល់ការឆ្លើយតប ជាលាយលក្ខណ៍អក្សរចំពោះអនុសាសន៍មុនៗរបស់យើង និងបានគូសបញ្ជាក់អំពីកិច្ចប្រជុំពិគ្រោះយោបល់យ៉ាងទូលំទូលាយជាសាធារណៈ ដែលបានជួយជំរុញ ការរៀបចំតាក់តែងក្របខណ្ឌគតិយុត្តិថ្មីៗរបស់វិស័យនេះ ដោយក្នុងនោះ រាប់បញ្ចូលទាំងមូលនិធិសម្រាប់ការអនុវត្តកាតព្វកិច្ចសេវាកម្មសាកល និងមូលនិធិ សម្រាប់ការកសាងសមត្ថភាពការស្រាវជ្រាវ និងការអភិវឌ្ឍផងដែរ។ ចាប់តាំងពីពេលបង្កើតមូលនិធិសម្រាប់ការអនុវត្តកាតព្វកិច្ចសេវាកម្មសាកល និងមូលនិធិសម្រាប់ការកសាងសមត្ថភាពការស្រាវជ្រាវ និងការអភិវឌ្ឍ កាលពីខែកក្កដា ឆ្នាំ២០១៧ មក ក្រុមហ៊ុនទូរគមនាគមន៍បានចូលរួមផ្តល់វិភាគទានថវិកាជាង ១៣,៥ លានដុល្លារអាមេរិក ដើម្បីពង្រីកសេវាកម្ម និងគាំទ្រការអភិវឌ្ឍកម្លាំងពលកម្មបច្ចេកទេស។ អនុលោមភាពកម្រិតនេះ ឆ្លុះបញ្ចាំងនូវភាពជោគជ័យដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននៅក្នុងការដោះស្រាយបញ្ហាកង្វល់របស់វិស័យឯកជន។ សមាសធាតុអំណោយផល មួយនៃសេចក្តីព្រាងគោលការណ៍ណែនាំសម្រាប់ការអនុវត្តនេះ គឺយន្តការសម្រាប់ការសងវិញដែលផ្តល់លទ្ធភាពឱ្យក្រុមហ៊ុននានាអាចដកយកមកវិញនូវចំណែកវិភាគទានមូលនិធិរបស់ខ្លួន នៅពេលអនុវត្តគម្រោងនានាដោយស្របតាមគោលដៅរបស់មូលនិធិនេះ ដែលព្យាយាមកាត់បន្ថយបញ្ហាគម្លាតឌីជីថលនាពេលបច្ចុប្បន្ន។

អនុសាសន៍ថ្មីៗរបស់យើង សម្រាប់ការបោះពុម្ពផ្សាយលើកនេះ គឺខិតខំធ្វើការបំពេញបន្ថែមទៅលើវឌ្ឍនភាពវិជ្ជមានផ្នែកនិយ័តកម្មនេះ ដោយស្នើឡើងឱ្យមានការអនុម័តច្បាប់ថ្មីដែលសំខាន់សម្រាប់វិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានប្រកបដោយវិបុលភាព ភាពប្រកួតប្រជែង និងមាននវានុវត្តន៍។ ជាបឋម យើងលើកឡើងអំពីភាពចាំបាច់ដែលប្រទេសកម្ពុជាគប្បីផ្តល់អាទិភាពទៅលើការអនុម័តច្បាប់ស្តីពីការការពារទិន្នន័យ និងឯកជនភាព

ដោយហេតុថា បច្ចុប្បន្ននេះ នៅពុំទាន់មានក្របខណ្ឌគតិយុត្តិណាមួយ ដែលគ្រប់គ្រងលើរបៀបប្រើប្រាស់ ការគ្រប់គ្រង ឬការរក្សាទុកទិន្នន័យឡើយ។ ច្បាប់ទាំងនេះគឺសំខាន់ចាំបាច់ខ្លាំងណាស់ ដើម្បីធានាថាប្រជាពលរដ្ឋ និងក្រុមហ៊ុនទាំងអស់ នឹងទទួលបាន កិច្ចការពារគ្រប់គ្រាន់ពីការប្រើប្រាស់មិនត្រឹមត្រូវ ហើយច្បាប់ទាំងនេះក៏ក្លាយជាឧបករណ៍ដ៏សំខាន់ផងដែរ ក្នុងការលើកកម្ពស់ការយល់ដឹងជុំវិញរបៀបប្រើប្រាស់ទិន្នន័យ ជាពិសេស ការប្រើប្រាស់ដោយភាគីទីបីតែម្តង។

អនុសាសន៍ថ្មីបន្ទាប់មកទៀតរបស់យើង គឺផ្តោតសំខាន់លើការលើកទឹកចិត្តឱ្យមានជម្រើស សម្រាប់អ្នកប្រើប្រាស់ និងការប្រកួតប្រជែងដោយយុត្តិធម៌ ដោយស្នើឱ្យមានការអនុវត្តប្រព័ន្ធប្តូរប្រតិបត្តិករលេខទូរសព្ទចល័ត (mobile phone number portability) និងគោលនយោបាយបើកចំហបណ្តាញប្រ៊ដប៊ែន (broadband open access policy) ផងដែរ។ តាមរយៈការផ្តល់ឱ្យអតិថិជននូវលទ្ធភាពផ្លាស់ប្តូរប្រតិបត្តិករទូរគមនាគមន៍របស់ខ្លួនដោយងាយស្រួល តាមការស្នើសុំនេះ ក្រុមហ៊ុននានានឹងត្រូវជំរុញឱ្យធ្វើនវានុវត្តន៍ថ្មីៗបន្ថែមទៀត ដើម្បីធានាថាអាចរក្សាអតិថិជនរបស់ខ្លួនបាន ដែលនឹងនាំឱ្យមានការកែលម្អគុណភាពសេវាកម្មកាន់តែល្អប្រសើរថែមមួយកម្រិតទៀត តម្លៃកាន់តែមានភាពប្រកួតប្រជែង និងវិស័យបច្ចេកវិទ្យាកាន់តែរឹងមាំ និងកាន់តែមានភាពប្រកួតប្រជែងខ្លាំងថែមទៀត។

អនុសាសន៍ថ្មីចុងក្រោយរបស់យើង គឺដើម្បីដោះស្រាយបញ្ហាគម្លាតជំនាញដ៏ធំធេង ដែលកំពុងមាននៅក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដោយលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាលជំរុញការចូលរួម កាន់តែខ្លាំងក្លាថែមទៀតពីសំណាក់អ្នកផ្តល់ការបណ្តុះបណ្តាល និងវិស័យឯកជនដើម្បីធ្វើឱ្យខ្លឹមសារ និងគុណវុឌ្ឍិនៃការបណ្តុះបណ្តាលកាន់តែល្អប្រសើរឡើងថែមទៀត។ ទោះបីជាយើងទទួលស្គាល់ថាបញ្ហាគម្លាតជំនាញនេះគឺកើតមានជាទូទៅ និងជាធម្មតានៅក្នុងវិស័យជាច្រើននៃសេដ្ឋកិច្ច ដោយសារតែល្បឿននៃការរីកចម្រើនផ្នែកបច្ចេកវិទ្យាមិនសូវលឿនក៏ដោយ ប៉ុន្តែយើងខ្ញុំសូមបញ្ជាក់ជូនថាផលវិបាកនៃបញ្ហាគម្លាតជំនាញនេះ

អាចបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់សមត្ថភាពប្រកួតប្រជែងរបស់វិស័យបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍នៅក្នុងប្រទេសកម្ពុជា។

ជាចុងក្រោយ យើងសូមរក្សាទុកនូវអនុសាសន៍ចំនួនពីរ ដែលបានផ្តល់ជូននៅក្នុង ច្បាប់បោះពុម្ពផ្សាយលើកមុន ដែលផ្តោតសំខាន់ទៅលើការកាត់បន្ថយបន្ទុកហិរញ្ញវត្ថុ ដែលកើតចេញពីការផ្លាស់ប្តូរក្របខណ្ឌនិយ័តកម្មថ្មី ដោយសារតែវិស័យទូរគមនាគមន៍ បានកំពុងចូលរួមចំណែកផ្តល់វិភាគទានមួយចំណែកធំនៃចំណូលរបស់ខ្លួនទៅក្នុងថវិកាជាតិ របស់រាជរដ្ឋាភិបាលកម្ពុជារួចស្រាប់ទៅហើយ។អាស្រ័យហេតុនេះ យើងសូមខ្ញុំសូមសង្កត់ធ្ងន់ជាថ្មីម្តងទៀតថា កំណែទម្រង់ត្រូវតែព្យាយាមស្វែងរកតុល្យភាពត្រឹមត្រូវរវាងការបង្កើតចំណូលសាធារណៈ និងការធានាលទ្ធភាពចំណេញផ្នែកសេដ្ឋកិច្ចរបស់វិស័យនេះសម្រាប់ទាំងវិនិយោគិនដែលមានស្រាប់ និងវិនិយោគិននាពេលអនាគត។

៣៣

# ការផ្តល់អាទិភាពដល់ការអនុម័តច្បាប់ស្តីពីការការពារទិន្នន័យ និងឯកជនភាព

ថ្មី

**ពិពណ៌នាបញ្ហា**

*អន្តរកម្មឌីជីថលដែលកំពុងកើតមានឡើងនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន បានបង្កើនសារៈសំខាន់កាន់តែខ្លាំងឡើងទៅលើទិន្នន័យឯកជន និងរបៀបរក្សាទុក គ្រប់គ្រង និងប្រើប្រាស់ទិន្នន័យទាំងនោះ ជាពិសេស ពីសំណាក់ភាគីទីបី។ ទោះបីជារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់សិទ្ធិឯកជន និងការរក្សាការសម្ងាត់នៃការប្រាស្រ័យទាក់ទងគ្នារបស់ពលរដ្ឋគ្រប់រូបក្តី ប៉ុន្តែក្នុងពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជានៅពុំទាន់មានក្របខណ្ឌគតិយុត្តិគ្រប់ជ្រុងជ្រោយដើម្បីរឹតត្បិត និងគ្រប់គ្រងការប្រើប្រាស់ទិន្នន័យឯកជន និងធានានូវកិច្ចការពារប្រឆាំងនឹងការប្រើប្រាស់ដោយមិនមានការអនុញ្ញាត ឬដោយខុសច្បាប់។*

*ដោយសារតែទិន្នន័យមានការជាប់ទាក់ទងគ្នាយ៉ាងសំខាន់ ទៅនឹងឌីជីថលូបនីយកម្មសេដ្ឋកិច្ច ទើបក្រុមហ៊ុនធុរកិច្ចនានាពឹងផ្អែកលើគុណតម្លៃរបស់ទិន្នន័យដើម្បីផ្តល់សេវាកម្ម និងទំនិញ ជំរុញនវានុវត្តន៍ និងគាំទ្រសេចក្តីសម្រេចចិត្តវិនិយោគ របស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលបានបង្ហាញឱ្យឃើញដោយ កំណើននៃចំនួនករណីចោរកម្មទិន្នន័យធំៗនៅលើពិភពលោក ករណីរំលោភ និងប្រើប្រាស់ទិន្នន័យមិនត្រឹមត្រូវកន្លងមក ជាការសំខាន់ណាស់សម្រាប់កម្ពុជា ក៏ដូចជាបណ្តាប្រទេសដទៃទៀតទាំងអស់ ក្នុងការគ្រប់គ្រង និងការពារទិន្នន័យឱ្យមានសុវត្ថិភាព បើមិនដូច្នេះទេ បញ្ហានេះនឹង ផ្តល់ផលវិបាកដែលអាចបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរទៅលើកេរ្តិ៍ឈ្មោះ និងកិច្ចប្រតិបត្តិការជាក់ជាមិនខាន។*

*ខណៈពេលដែលបណ្តាក្រុមហ៊ុនធុរកិច្ចជាច្រើននៅក្នុងប្រទេសកម្ពុជាទទួលស្គាល់រួចហើយនូវភាពចាំបាច់នៃកិច្ចការពារទិន្នន័យ និងភាពឯកជន ហើយថែមទាំងបានអនុវត្តយុទ្ធសាស្ត្រសម្រាលផលប៉ះពាល់ខ្លះៗរួចទៅហើយក្តី ប៉ុន្តែអាចជាការយល់ខុសប្រសិនបើមានការសន្មតថាក្រុមហ៊ុនទាំងអស់នោះនឹងធ្វើការវិនិយោគពេលវេលា និងធនធានចាំបាច់របស់ខ្លួន ទៅលើកិច្ចការពារទិន្នន័យ ដែលពុំមានច្បាប់ច្បាស់លាស់ក្នុងការគ្រប់គ្រងទិន្នន័យអេឡិចត្រូនិកផងនោះ។*

**ផលប៉ះពាល់លើកម្ពុជា**

*បច្ចេកវិទ្យាថ្មីៗ គឺជាសមាសធាតុរួមចំណែកដ៏សំខាន់នៅក្នុងកិច្ចអភិវឌ្ឍន៍ជាតិរបស់ប្រទេសកម្ពុជា។ ប៉ុន្តែប្រសិនបើមិនមានក្របខណ្ឌគតិយុត្តិរឹងមាំដែលគ្រប់គ្រងទៅលើការប្រើប្រាស់ និងការរក្សាទុកប្រកបដោយទំនួលខុសត្រូវនូវទិន្នន័យដែលបង្កើតចេញពីបច្ចេកវិទ្យាថ្មីៗ ក៏ដូចជាការប្រើប្រាស់ និងការរក្សាទុកដោយភាគីទីបីទេនោះ គេអាចនឹងមើលរំលងនូវសារៈសំខាន់នៃសន្តិសុខទិន្នន័យ ហើយបុគ្គលម្នាក់ៗ ក្រុមហ៊ុន ឬរាជរដ្ឋាភិបាល អាចនឹងត្រូវប្រឈមទៅនឹងការគំរាមកំហែង និងអស្ថិរភាពយ៉ាងធ្ងន់ធ្ងរ ហើយបញ្ហានេះមិនត្រឹមតែធ្វើឱ្យខូចខាតកេរ្តិ៍ឈ្មោះដោយសារតែការប្រើប្រាស់ទិន្នន័យមិនត្រឹមត្រូវប៉ុណ្ណោះនោះទេ ប៉ុន្តែរួមទាំងផលវិបាកនៃការបាត់បង់ទិន្នន័យដោយសារតែការដាច់ចរន្តអគ្គិសនី ឬគ្រោះមហន្តរាយធម្មជាតិ ថែមទៀតផង ។*

លំហូរទិន្នន័យដែលអាចជួយឱ្យសេដ្ឋកិច្ចឌីជីថលរីកលូតលាស់បានគឺពឹងផ្អែកទៅលើទំនុកចិត្ត ពីព្រោះអ្នកដែលផ្តល់ទិន្នន័យឯកជន ត្រូវតែមានការជឿទុកចិត្តថាអង្គភាពដែលប្រើប្រាស់ឬរក្សាទុកទិន្នន័យរបស់ខ្លួន នឹងធ្វើសកម្មភាពដោយសុចរិតភាព។ ប្រសិនបើទំនុកចិត្តនេះត្រូវបានរំលោភបំពាន ការជឿទុកចិត្តទៅលើអង្គភាពនោះនឹងទទួលរងផលប៉ះពាល់ ហើយអ្នកផ្សេងទៀត ក៏នឹងលែងជឿជាក់ថាព័ត៌មានរបស់ខ្លួននឹងមានសុវត្ថិភាពទៀតដែរ។ នេះគឺជាកង្វល់ដ៏ធំមួយសម្រាប់ក្រុមហ៊ុនទាំងឡាយដែលពាក់ព័ន្ធទៅនៅក្នុងការប្រើប្រាស់ និងការគ្រប់គ្រងទិន្នន័យឯកជន ដូចជាព័ត៌មានទំនាក់ទំនង ឬព័ត៌មានហិរញ្ញវត្ថុ ពីព្រោះពួកគេនឹងលែងមានភាពប្រកួតប្រជែងយ៉ាងឆាប់រហ័ស។ ប្រសិនបើប្រទេសកម្ពុជាជាប់ឈ្មោះថាជាប្រទេសដែលមិនអាចគ្រប់គ្រងទិន្នន័យបានត្រឹមត្រូវ ដោយសារតែពុំមានបទប្បញ្ញត្តិគ្រប់គ្រាន់ នោះការវិនិយោគក្នុងវិស័យបច្ចេកវិទ្យា ដែលកំពុងមានការរីកចម្រើនខ្លាំងនេះ នឹងត្រូវធ្លាក់ចុះទៅវិញយ៉ាងឆាប់រហ័សផងដែរ។

ជាងនេះទៅទៀត ដោយសារតែមានការបារម្ភកើនឡើងជុំវិញរបៀបប្រើប្រាស់ទិន្នន័យ ប្រទេសមួយចំនួនកំពុងធ្វើការរឹតត្បិតលើលំហូរទិន្នន័យ ទៅកាន់ប្រទេសទាំងឡាយណា ដែលមានច្បាប់ការពារទិន្នន័យ និងភាពឯកជនធូររលុងដើម្បី ធានាថាក្រុមហ៊ុននានាមិនអាចគេចវេះពីច្បាប់ក្នុងស្រុករបស់ខ្លួនបានឡើយ។ ស្រដៀងគ្នានឹងករណីទិន្នន័យផងដែរច្បាប់ដែលគ្រប់គ្រងការប្រើប្រាស់ទិន្នន័យលែងកំណត់ដោយដែនយុត្តាធិការទៀតហើយ និងបច្ចុប្បន្នច្បាប់នេះកំពុងត្រូវបានអនុវត្តន៍ឆ្លងដែនដីទៀតផង ដូចដែលបង្ហាញឱ្យឃើញដោយបទប្បញ្ញត្តិ ស្តីពីការការពារទិន្នន័យទូទៅ (GDPR) របស់សហភាពអឺរ៉ុប។ បទប្បញ្ញត្តិនេះអនុវត្តកាតព្វកិច្ចតឹងរ៉ឹងទៅលើក្រុមហ៊ុនទាំងឡាយណា ដែលដំណើរការទិន្នន័យរបស់ពលរដ្ឋអឺរ៉ុប បើមិនដូច្នេះទេនឹងត្រូវប្រឈមនឹងវិធានការទណ្ឌកម្មធ្ងន់ធ្ងរសម្រាប់ការមិនអនុលោមតាម ទោះបីទីតាំងរូបវន្តរបស់ក្រុមហ៊ុនស្ថិតនៅទីណាក៏ដោយ។ អាស្រ័យហេតុនេះ ប្រសិនបើមិនមានក្របខណ្ឌគតិយុត្តិ ប្រកបដោយប្រសិទ្ធភាព ដែលអាចរក្សាវឌ្ឍនភាពប្រហាក់ប្រហែលទៅនឹងទីផ្សារដែលអាចប្រៀបធៀបគ្នាបាននោះទេ សមត្ថភាពប្រកួតប្រជែងរបស់វិស័យឌីជីថលនៅក្នុងប្រទេសកម្ពុជាអាចនឹងធ្លាក់ចុះ ដែលនឹងធ្វើឱ្យកាន់តែលំបាកក្នុងការទាក់ទាញវិនិយោគទុនថែមទៀត។

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យផ្តល់អាទិភាពដល់ការអនុម័តច្បាប់ ស្តីពីការការពារទិន្នន័យ និងឯកជនភាព នៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីមានដំណើរការពិគ្រោះយោបល់រវាងវិស័យសាធារណៈ និងវិស័យឯកជន ប្រកបដោយប្រសិទ្ធភាពរួចហើយនោះ។

*ទោះបីជាយើងខ្ញុំទទួលស្គាល់ថាការវិវត្តរបស់បច្ចេកវិទ្យា ជាទូទៅមានការរីកចម្រើនលឿនជាងការវិវត្តនៃក្របខណ្ឌគតិយុត្តិដែលគ្រប់គ្រងវិស័យនេះក្តី យើងខ្ញុំសូមគោរពផ្តល់ជូននូវអនុស្សាសន៍ថា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ គួរផ្តល់អាទិភាពដល់ការអនុម័តច្បាប់ស្តីពីការការពារទិន្នន័យ និងភាពឯកជនដើម្បីធានានូវការប្រើប្រាស់ និងការគ្រប់គ្រងទិន្នន័យប្រកបដោយទំនួលខុសត្រូវ។ ជាការសំខាន់ដែលថាបទប្បញ្ញត្តិនៃច្បាប់នេះចាំបាច់ត្រូវរៀបចំតាក់តែងឡើងដោយផ្តោតលើការគ្រប់គ្រងហានិភ័យ ឱ្យស្ថិតនៅត្រឹមកម្រិតមួយ ដែលអាចទទួលយកបាន និងរក្សាតុល្យភាពរវាងផលប្រយោជន៍សេដ្ឋកិច្ច និងផលប្រយោជន៍សង្គមដែលអាចនាំមកដោយនវានុវត្តន៍ឌីជីថល រួមជាមួយនឹងការធានាការការពារពីផលប៉ះពាល់អវិជ្ជមាននៃការប្រើប្រាស់ទិន្នន័យមិនត្រឹមត្រូវផងដែរ។*

*ការអនុម័តច្បាប់នេះ ក៏នឹងពង្រឹងកិច្ចប្រឹងប្រែងរបស់កម្ពុជាក្នុងការធ្វើសមាហរណកម្មជាបន្តទៀតទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ពីព្រោះមានការផ្តោតសំខាន់ជាក់លាក់ ដើម្បីធ្វើសុខដុមនីយកម្មច្បាប់ស្តីពីការការពារទិន្នន័យ និងការប្តេជ្ញាជំរុញការបង្កើនកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន* (ICT) *ដូចដែលមានបង្ហាញនៅក្នុងផែនការមេស្តីពីការតភ្ជាប់អាស៊ាន និងក្របខណ្ឌអាស៊ានស្តីពីការការពារទិន្នន័យផ្ទាល់ខ្លួន។ ដោយពិចារណាលើចំណុចនេះ គណៈកម្មាធិការបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន របស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជានឹង ស្វាគមន៍ចំពោះការផ្តល់ឱកាសចូលរួមចំណែក នៅក្នុងការរៀបចំតាក់តែងច្បាប់នេះ ជាលក្ខណៈសហប្រតិបត្តិការ និងការគាំទ្រ ដែលមានលក្ខណៈស្រដៀងគ្នានឹងដំណើរការពិគ្រោះយោបល់ដែលរាជរដ្ឋាភិបាលបានអនុវត្តសម្រាប់ការធ្វើសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាដើម។*

៣៤

# ការធានាឱ្យមានជម្រើសសម្រាប់អតិថិជន និងការប្រើប្រាស់ដោយបើកចំហ

ថ្មី

**ពិពណ៌នាបញ្ហា**

*ខណៈដែលសេដ្ឋកិច្ចឌីជីថលកាន់តែរីកលូតលាស់ជាបន្តបន្ទាប់ ហើយការប្រើប្រាស់សេវាកម្មទូរគមនាគមន៍បានក្លាយជាតម្រូវការដ៏ចាំបាច់ ជាការសំខាន់ណាស់ដែលត្រូវមានកិច្ចការពារគ្រប់គ្រាន់ទៅដល់អតិថិជនដើម្បីធានាថាពួកគាត់មានសេរីភាពក្នុងការជ្រើសរើស សេវាកម្មដែលស្របនឹងសេចក្តីត្រូវការផ្ទាល់ខ្លួន។ ស្រដៀងគ្នានេះដែរ ខណៈដែលប្រភេទ នៃសេវាកម្មក៏រីកកាន់តែច្រើនខ្លាំងឡើង រាជរដ្ឋាភិបាលចាំបាច់ត្រូវចាត់វិធានការដើម្បីទាញប្រយោជន៍ពីកំណើននៃវិស័យនេះ តាមរយៈការបង្កើតគោលនយោបាយ និងបទប្បញ្ញត្តិប្រកបដោយប្រសិទ្ធភាពដែលសំដៅដល់ការលើកកម្ពស់នវានុវត្តន៍ និងលើកទឹកចិត្តដល់ការប្រកួតប្រជែងដោយស្មើភាពរវាងអ្នកផ្តល់សេវានានា។*

*ប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ប្រសិនបើអតិថិជនណាម្នាក់មិនសប្បាយចិត្តនឹងគុណភាពសេវាកម្ម ពីអ្នកផ្តល់សេវាកម្មទូរសព្ទចល័តរបស់គាត់ និងសម្រេចចិត្តប្តូរទៅប្រើសេវាកម្មរបស់អ្នកផ្តល់សេវាកម្មថ្មីមួយទៀត អតិថិជននោះតម្រូវឱ្យបោះបង់លេខទូរសព្ទរបស់គាត់ចោល និងត្រូវប្រើលេខថ្មីមួយទៀត ដែលប្រការនេះនាំឱ្យកើនការចំណាយក្នុងការផ្លាស់ប្តូរអ្នកផ្គត់ផ្គង់សេវាកម្ម នឹងមានភាពលំបាកក្នុងការជូនដំណឹងដល់អ្នកដទៃអំពីការផ្លាស់ប្តូរ លេខទំនាក់ទំនងរបស់ខ្លួន។ ដោយពុំមានលទ្ធភាពផ្ទេរលេខទូរសព្ទទៅកាន់អ្នកផ្តល់សេវាកម្មផ្សេងទៀត អ្នកផ្តល់សេវាកម្មខ្លះអាចធ្វើការទិញអាជ្ញាប័ណ្ណ សម្រាប់លេខទូរសព្ទជាច្រើនលំដាប់ ក្នុងនោះរាប់ទាំងលេខដែលគេចង់ប្រើ និងលេខសំណាងជាដើម ក្នុងតម្លៃមួយដែលទាប បន្ទាប់ពីបានច្របាច់ចូលគ្នានូវក្រុមហ៊ុនផ្តល់សេវាកម្មមួយចំនួន ដែលនាំឱ្យមានការប្រកួតប្រជែងមិនយុត្តិធម៌ប្រឆាំងនឹងអ្នកផ្តល់សេវាកម្ម ដែលកំពុងប្រតិបត្តិការស្រាប់ផ្សេងទៀត។*

*ដើម្បីដោះស្រាយបញ្ហាទាំងនេះ បណ្តាប្រទេសជាច្រើនបានអនុម័តបទប្បញ្ញត្តិចាំបាច់ពាក់ព័ន្ធនឹងប្រព័ន្ធប្តូរប្រតិបត្តិករ លេខទូរសព្ទចល័ត* (mobile number portability) *ដែល អនុញ្ញាតឱ្យអតិថិជនអាចរក្សាលេខទូរសព្ទចាស់របស់ខ្លួនបានដដែលនៅពេលប្តូរទៅប្រើសេវាកម្មរបស់អ្នកផ្តល់សេវាកម្មថ្មីមួយផ្សេងទៀត ដែលបានជួយកាត់បន្ថយការ ចំណាយរបស់អ្នកប្រើប្រាស់ ហើយទន្ទឹមនឹងនោះក៏បង្កើនការប្រកួតប្រជែង និងការពេញចិត្តរបស់អតិថិជនបានផងដែរ។ នៅក្នុងតំបន់អាស៊ានមានប្រទេសមួយចំនួនដូចជា ប្រទេសសិង្ហបុរី ម៉ាឡេស៊ី និងថៃ បានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធប្តូរប្រតិបត្តិករលេខទូរសព្ទចល័តដោយឥតគិតថ្លៃ និងការប្តូរនេះ អាចធ្វើឡើងចប់សព្វគ្រប់ក្នុងរយៈពេលតិចជាង ៣ ថ្ងៃ ហើយអ្នកផ្តល់សេវាកម្មនៅក្នុងប្រទេសវៀតណាម ក៏បានចាប់ផ្តើមដាក់ឱ្យប្រើប្រាស់ ប្រព័ន្ធប្តូរប្រតិបត្តិករលេខទូរសព្ទចល័តនេះផងដែរ កាលពីខែវិច្ឆិកា ឆ្នាំ២០១៨ មក។ ស្រដៀងគ្នានេះដែរ ប្រទេសជាសមាជិកអាស៊ានទាំងអស់ទទួលបានការលើកទឹកចិត្តឱ្យអនុវត្ត ប្រព័ន្ធប្តូរប្រតិបត្តិករលេខទូរសព្ទចល័តនេះ នៅពេលការដាក់បញ្ចូលប្រការនេះនៅក្នុងសេចក្តីប្រកាស*

*នៅទីក្រុងសៀមរាបនាកិច្ចប្រជុំរដ្ឋមន្ត្រីទូរគមនាគមន៍ និង ព័ត៌មានវិទ្យាអាស៊ាន ដែលបានប្រព្រឹត្តទៅកាលពីខែធ្នូ ឆ្នាំ២០១៧។*

*ការធានានូវភាពប្រកួតប្រជែង និងជម្រើសសម្រាប់អតិថិជន គឺមានសារៈសំខាន់ស្មើគ្នា ប្រសិនបើយើងនិយាយអំពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់លំហូរនៃសារគមនាគមន៍។ ខណៈដែលតំណភ្ជាប់អ៊ីនធឺណិតបានក្លាយជាការប្រើប្រាស់ដ៏ចាំបាច់បំផុត ជាតម្រូវការចាំបាច់ដែលសេវាកម្មប្រើប្រាស់បណ្តាញហេដ្ឋារចនាសម្ព័ន្ធនេះត្រូវបានផ្តល់ឱ្យក្នុងលក្ខខណ្ឌយុត្តិធម៌ និងសមហេតុផល ពីព្រោះហេដ្ឋារចនាសម្ព័ន្ធដើរតួនាទីចម្បងនៅក្នុងការរៀបចំសណ្ឋាននៃការប្រកួតប្រជែងក្នុងវិស័យនេះ។ ទោះបីជាអ្នកប្រើប្រាស់ជាច្រើននៅក្នុងប្រទេសកម្ពុជា អាចនឹងពេញចិត្តជាមួយនឹងអ៊ីនធឺណិតទូរសព្ទចល័តរបស់ខ្លួន និងអាចមិនមានភាពចាំបាច់ក្នុងការតភ្ជាប់ជាមួយនឹងបណ្តាញអ៊ីនធឺណិតជារូបវន្តក្តី ប៉ុន្តែជារឿយៗ ក្រុមហ៊ុននានាមានតម្រូវការជាចាំបាច់នូវសមត្ថភាពបញ្ជូនទិន្នន័យ (bandwidth) ធំៗ និងចាំបាច់ត្រូវការតភ្ជាប់ជាមួយនឹងបណ្តាញអ៊ីនធឺណិត ដែលមានល្បឿនលឿន ខ្លាំងជាងល្បឿនដែលសេវាអ៊ីនធឺណិតទូរសព្ទចល័តអាចផ្តល់បាន។*

*នៅក្នុងប្រទេសកម្ពុជា នៅពេលមានអគារថ្មីមួយបានសាងសង់រួច អ្នកផ្តល់សេវាកម្មទូរគមនាគមន៍នឹងធ្វើកិច្ចព្រមព្រៀងជាមួយម្ចាស់អគារនោះដើម្បីតភ្ជាប់អគារនោះទៅនឹងបណ្តាញប្រ៊ដប៊ែន ដែលនឹងផ្តល់សេវាអ៊ីនធឺណិតផ្តាច់មុខដល់អតិថិជនទាំង អស់ដែលស្នាក់នៅក្នុងអគារនោះ។ ប្រការនេះផ្តល់ឱ្យអ្នកផ្តល់សេវាកម្មនូវសិទ្ធិផ្តាច់មុខទៅលើអ្នកជួលអគារ និងធ្វើឱ្យអតិថិជនមានជម្រើសតិចតួច ប្រសិនបើពួកគាត់មិនសប្បាយចិត្តជាមួយនឹងគុណភាពនៃសេវារបស់អ៊ីនធឺណិតនោះ ហើយប្រសិនបើប្រការនេះកើតឡើង នៅក្នុងអគារការិយាល័យវិញ បញ្ហានេះអាចនឹងប៉ះពាល់ធ្ងន់ធ្ងរដល់សកម្មភាពពាណិជ្ជកម្មទៀតផង។*

*ដោយសារតែមានការលើកទឹកចិត្តតិចតួច ដល់អ្នកផ្តល់សេវាកម្មក្នុងការផ្តល់សិទ្ធិប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួនទៅដល់ដៃគូប្រកួតប្រជែង ទើបវិស័យនេះតម្រូវឱ្យរាជរដ្ឋាភិបាល អនុវត្តនូវគោលនយោបាយបើកចំហ ការប្រើប្រាស់ប្រ៊ដប៊ែនប្រកបដោយប្រសិទ្ធភាព ដើម្បីអនុញ្ញាតដល់ការប្រើប្រាស់រួមគ្នាដោយស្មើភាពនូវហេដ្ឋារចនាសម្ព័ន្ធនៃបណ្តាញ។ ការអនុវត្តគោលនយោបាយបើកចំហការប្រើប្រាស់បែបនេះ នឹងអនុវត្តតាមគំរូដែលបានកំណត់ដោយមូលនិធិកាតព្វកិច្ចសកលទូរគមនាគមន៍របស់រាជរដ្ឋាភិបាល ដែលមានគោលបំណងលើកទឹកចិត្តវិស័យឯកជនឱ្យពង្រីកហេដ្ឋារចនាសម្ព័ន្ធបណ្តាញទៅដល់តំបន់នានា ដែលមិនសូវមានអំណោយផលផ្នែកសេដ្ឋកិច្ច ប៉ុន្តែ ផ្តល់ផលប្រយោជន៍យ៉ាងច្រើនសន្ធឹកសន្ធាប់ ដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ទាំងនោះ។*

## ផលប៉ះពាល់លើកម្ពុជា

ដូចគ្នាទៅនឹងបណ្តាប្រទេសជាច្រើនទៀតដែរ ច្បាប់ស្តីពីទូរគមនាគមន៍របស់ប្រទេសកម្ពុជាបានផ្តោតសំខាន់ខ្លាំងទៅលើការគ្រប់គ្រងការបង្កើតបណ្តាញ និងការផ្តល់អាជ្ញាប័ណ្ណដល់អ្នកផ្តល់សេវាកម្ម។ ប៉ុន្តែខណៈដែលវិស័យនេះបន្តអភិវឌ្ឍច្រើនឡើង ហើយមានតួអង្គកាន់តែច្រើនចូលរួមនៅក្នុងទីផ្សារ ជាការសំខាន់ចាំបាច់ដែលត្រូវមានគោលនយោបាយ ឱ្យស្របទៅតាមស្ថានភាពនោះដែរ ដើម្បីលើកទឹកចិត្តដល់ការប្រកួតប្រជែងប្រកបដោយយុត្តិធម៌ និងរក្សាការពារឱ្យអតិថិជននៅតែមានជម្រើសច្រើនសម្រាប់ជ្រើសរើស។ កំណើននៃការប្រកួតប្រជែងដែលកើតចេញពីគោលនយោបាយ ដែលយកចិត្តទុកដាក់លើអតិថិជនប្រកបដោយប្រសិទ្ធភាព ជួយជំរុញវិស័យឯកជនឱ្យកាន់តែមាននវានុវត្តន៍ និងបង្កើនគុណភាពសេវាកម្មឱ្យកាន់តែល្អប្រសើរ ហើយតម្លៃក៏កាន់តែមានភាពប្រកួតប្រជែងខ្ពស់ថែមទៀត។ ប្រសិនបើក្រុមហ៊ុនមិនធ្វើដូច្នេះទេ ក្រុមហ៊ុនទាំងនោះនឹងប្រឈមមុខជាមួយនឹងការបាត់បង់អតិថិជនទៅកាន់ដៃគូប្រកួតប្រជែងរបស់ខ្លួន ដែលបានធ្វើល្អប្រសើរជាង ដោយហេតុថា អតិថិជនកាន់តែមានឥទ្ធិពលនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ទិញសេវាកម្មដោយផ្អែកទៅលើព័ត៌មានគ្រប់ជ្រុងជ្រោយ។

គោលបំណងនៃការអនុវត្តគោលនយោបាយគាំទ្រការប្រកួតប្រជែង ដូចជា ប្រព័ន្ធប្តូរប្រតិបត្តិករលេខទូរសព្ទចល័ត (mobile phone number portability) និងការបើកចំហការប្រើប្រាស់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធប្រ៊ដប៊ែនគឺដើម្បីលើកកម្ពស់ការយល់ដឹង របស់អតិថិជនអំពីសេវាកម្មទូរគមនាគមន៍នៅកម្ពុជា ដែលធ្វើឱ្យអតិថិជនយល់ដឹងអំពីជម្រើសនានា និងធ្វើឱ្យដំណើរការផ្លាស់ប្តូរអ្នកផ្តល់សេវាកម្មកាន់តែមានភាពសាមញ្ញនិងងាយស្រួលខ្លាំងឡើង។ ប្រការនេះ នឹងលើកទឹកចិត្តឱ្យមានការវិនិយោគកាន់តែច្រើនថែមទៀត នៅក្នុងវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន នៅក្នុងប្រទេសកម្ពុជា ដែលនេះនឹងនឹងជំរុញទីផ្សារឱ្យកាន់តែរឹងមាំ និងមានភាពប្រកួតប្រជែងកាន់តែខ្លាំងក្លា ព្រមទាំងបង្កើនគុណភាពហេដ្ឋារចនាសម្ព័ន្ធបណ្តាញកាន់តែប្រសើរជាងមុនថែមទៀត។

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យធ្វើការពិចារណាអនុវត្តគោលនយោបាយបើកចំហ ឱ្យមានប្រព័ន្ធប្តូរប្រតិបត្តិករលេខទូរសព្ទចល័ត (mobile phone number portability) និងបណ្តាញប្រ៊ដប៊ែន (broadband) ដើម្បីផ្តល់ជាជម្រើសកាន់តែច្រើនដល់អតិថិជន និងការប្រកួតប្រជែងកាន់តែយុត្តិធម៌នៅក្នុងវិស័យទូរគមនាគមន៍ក្នុងប្រទេសកម្ពុជា។

*យើងខ្ញុំសូមគោរពផ្តល់ជូននូវអនុសាសន៍ថា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ គប្បីថាត់វិធានការអនុវត្តគោលនយោបាយបើកចំហឱ្យមានប្រព័ន្ធប្តូរប្រតិបត្តិករលេខទូរសព្ទចល័ត* (mobile phone number portability) *និងបណ្តាញប្រ៊ីដប៊ែន ដើម្បីលើកទឹកចិត្ត ឱ្យមានជម្រើសកាន់តែច្រើនដល់អតិថិជន និងការប្រកួតប្រជែងកាន់តែយុត្តិធម៌ថែមទៀតនៅក្នុងវិស័យទូរគមនាគមន៍នៅក្នុងប្រទេសកម្ពុជា។ សម្រាប់ប្រព័ន្ធប្តូរប្រតិបត្តិករលេខទូរសព្ទចល័តនេះ យើងខ្ញុំសូមស្នើឱ្យមានការធ្វើសុខដុមនីយកម្មច្បាប់ ជាមួយនឹងច្បាប់នានា ដែលកំពុងត្រូវបានអនុវត្តដោយប្រទេសសមាជិកអាស៊ានផ្សេងទៀត ដូចដែលបានលើកទឹកចិត្តដោយសេចក្តីប្រកាសទីក្រុងសៀមរាបរបស់កិច្ចប្រជុំរដ្ឋមន្ត្រីទូរគមនាគមន៍ និងព័ត៌មានវិទ្យា អាស៊ាន ឆ្នាំ២០១៧ កន្លងទៅនេះ។*

*ដោយទទួលស្គាល់ថាការអនុវត្តគោលនយោបាយបើកចំហការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញ គឺជាដំណើរការមួយដែលត្រូវប្រើពេលវេលាច្រើន និងមានលក្ខណៈបច្ចេកទេសខ្ពស់ យើងសូមស្នើថាក្រសួងគួរស្វែងរកការអនុវត្តដែលប្រសើរបំផុត និងរៀបចំឱ្យមានកិច្ចប្រជុំពិគ្រោះយោបល់រវាងវិស័យរដ្ឋ និងវិស័យឯកជន ដើម្បីធានាថាគោលនយោបាយនេះនឹងមានប្រសិទ្ធភាពក្នុងការធានាតុល្យភាពរវាងតម្រូវការរបស់អតិថិជន ប្រតិបត្តិករ និងម្ចាស់ ព្រមទាំងដើម្បីលើកទឹកចិត្តដល់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយភាពយុត្តិធម៌ផងដែរ។*

៣៥

# ដោះស្រាយបញ្ហាគម្លាតជំនាញបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន ( ICT )

ថ្មី

**ពិពណ៌នាបញ្ហា**

រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តយ៉ាងច្បាស់លាស់ ដើម្បីលើកកម្ពស់បទដ្ឋាននៃការអប់រំនៅទូទាំងប្រទេស ដូចដែលបានបង្ហាញឱ្យឃើញតាមរយៈនិន្នាការជាបន្តបន្ទាប់នៃវិស័យអប់រំដែលទទួលបានការវិភាជន៍ថវិកាជាតិខ្ពស់បំផុត គឺ ៧៣៧ លានដុល្លារអាមេរិក ដែលគ្រោងសម្រាប់ឆ្នាំ២០១៩ បន្ទាប់ពីការបង្កើនថវិកាចំនួន ២៤% ពីលើថវិកាឆ្នាំ២០១៨។ ខណៈដែលវិស័យឯកជនទទួលស្គាល់ និងស្វាគមន៍នូវភាពល្អប្រសើរឡើងនេះ និយោជកមកពីគ្រប់មជ្ឈដ្ឋាន នៅតែបន្តរាយការណ៍អំពីបញ្ហាប្រឈមនៅក្នុងការស្វែងរកបេក្ខជនដែលមានសមត្ថភាពដើម្បីជ្រើសរើសធ្វើជាបុគ្គលិក ដោយសារតែបញ្ហាគម្លាតជំនាញដ៏គួរឱ្យកត់សម្គាល់នេះ ដែលកើតមាននៅចន្លោះការអប់រំដែលបានផ្តល់ឱ្យ និងជំនាញដែលវិស័យនានា ត្រូវការចាំបាច់។ សម្រាប់វិស័យបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន ដែលកំពុងអភិវឌ្ឍន៍យ៉ាងលឿនរហ័សវិញ បញ្ហាគម្លាតជំនាញ រឹតតែមានប្រេវ៉ាឡង់ខ្ពស់ខ្លាំងថែមទៀត។

ដោយសារតែកំណើនតម្រូវការសម្រាប់សេវាកម្មវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) នៅក្នុងប្រទេសកម្ពុជា គ្រឹះស្ថានបណ្តុះបណ្តាលមួយចំនួនធំត្រូវបានបង្កើតឡើង រួមជាមួយនឹងសាកលវិទ្យាល័យដែលមានស្រាប់ ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលផ្តោតលើវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ជាច្រើនសម្បុរបែប។ ប៉ុន្តែ ជាអកុសល ដោយសារតែវិស័យនេះនៅខ្វះនូវក្របខ័ណ្ឌគុណវុឌ្ឍិដែលមានការទទួលស្គាល់ ទើបគុណភាពនៃវគ្គបណ្តុះបណ្តាលដែលបានផ្តល់នៅក្នុងប្រទេសកម្ពុជា មានភាពខុសៗគ្នាគួរឱ្យកត់សម្គាល់ ហើយការសិក្សាភាគច្រើនអាចនឹងបានផ្តល់ជូនតាមរបៀបហួសសម័យ និងមានភាពពាក់ព័ន្ធតិចតួចទៅនឹងវិស័យការងារពេលបច្ចុប្បន្ននេះ។ ខណៈដែលប្រជាជនកម្ពុជាជាច្រើនកំពុងមានការយល់ដឹងកាន់តែច្រើនឡើងអំពីបច្ចេកវិទ្យា ដោយសារតែកំណើននៃការប្រើប្រាស់ឧបករណ៍ចល័ត ប៉ុន្តែអក្ខរកម្មកុំព្យូទ័រនៅតែកម្រិតទាបនៅឡើយ ដែលនាំឱ្យនិស្សិតជាច្រើនដែលបានបញ្ចប់ការសិក្សានៅមិនទាន់អាចត្រៀមលក្ខណៈគ្រប់គ្រាន់សម្រាប់ទីផ្សារការងារ ហើយគុណវុឌ្ឍិរបស់ពួកគេមានគុណតម្លៃតិចតួច ទាំងសម្រាប់ទីផ្សារការងារនៅក្នុងប្រទេសកម្ពុជា និងនៅលើឆាកអន្តរជាតិ។

ទោះបីជាសាកលវិទ្យាល័យនៅក្នុងស្រុក និងវិស័យឯកជន បានចាប់ផ្តើមធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នាដើម្បីកាត់បន្ថយបញ្ហាគម្លាតនេះក្តី កិច្ចការនេះបានផ្តោតសំខាន់ច្រើនទៅលើការស្វែងរកកម្មសិក្សាឱ្យនិស្សិត ជាជាងការឱ្យក្រុមហ៊ុនបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន (ICT) ចូលរួមនៅក្នុងការរៀបចំតាក់តែងកម្មវិធីសិក្សា។ ជាលទ្ធផល ដោយសារតែកម្មវិធីសិក្សាកម្រនឹងគិតគូរដល់តម្រូវការការងារជាក់ស្តែងរបស់ វិស័យនេះ ហើយនិស្សិតមានសមត្ថភាពក្រោមបន្ទាត់នៃការរំពឹងទុកពីការងារវិជ្ជាជីវៈ ដូច្នេះ ក្រុមហ៊ុននានាចាំបាច់ត្រូវធ្វើការបណ្តុះបណ្តាលជំនាញនេះជាថ្មីឡើងវិញដល់និស្សិតបញ្ចប់ការសិក្សាថ្មីៗជាច្រើនដែលខ្លួនជ្រើសរើសឱ្យចូលបម្រើការងារ។

*ក្រុមហ៊ុនបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន* (ICT) *ភាគច្រើនទទួលស្គាល់ថា និស្សិតដែលទើបតែបញ្ចប់ការសិក្សាថ្មីៗ ចាំបាច់ត្រូវតែទទួលការបណ្តុះបណ្តាលក្នុងពេលកំពុងបំពេញការងារ ដោយសារតែបទពិសោធន៍បច្ចេកទេសរបស់ពួកគេនៅមានកម្រិតនៅឡើយ ប៉ុន្តែមានក្រុមហ៊ុនជាច្រើនយល់ឃើញថា ពួកគេត្រូវបង្ខំចិត្តបង្រៀនជំនាញកម្រិតមូលដ្ឋានឡើងវិញ ដូចជា លេខនព្វន្តជាមូលដ្ឋាន ដែលគួរតែរៀនចប់តាំងពីឆ្នាំសិក្សាដំបូងៗមកម៉្លេះ។ ក្រុមហ៊ុនត្រូវបានតម្រូវឱ្យវិនិយោគពេលវេលា និងធនធានយ៉ាងច្រើនទៅលើនិស្សិតដែលទើបបញ្ចប់ការសិក្សាម្នាក់ៗ ហើយជារឿយៗក្រុមហ៊ុនពិបាកនឹងទទួលបានផលមកវិញខ្លាំងណាស់ ដោយសារតែអត្រាបុគ្គលិកឈប់ពីការងារមានកម្រិតខ្ពស់ ព្រោះតែបន្ទាប់ពីបានចូលធ្វើការងារមិនយូរប៉ុន្មានផងបុគ្គលិកក៏សម្រេចចិត្តចាកចេញពីការងារចាស់ទៅរកការងារថ្មីមួយទៀតដើម្បីស្វែងរកប្រាក់ខែដែលខ្ពស់ជាង។*

## ផលប៉ះពាល់លើកម្ពុជា

*ខណៈដែលកំណើននៃការប្រើប្រាស់ឧបករណ៍ចល័ត ពីសំណាក់ប្រជាជនកម្ពុជាបង្កើតជាឱកាសដ៏ធំមួយ សម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន* (ICT) *ក្នុងការផ្តល់ដំណោះស្រាយផ្តោតលើបច្ចេកវិទ្យាដែលមាននវានុវត្តភាពពិតមែន កង្វះដ៏ច្រើននូវជំនាញបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មានក្នុងស្រុក បានកាត់បន្ថយលទ្ធភាពរបស់ប្រទេសកម្ពុជា ក្នុងការរក្សាខ្លួនឱ្យមានភាពប្រកួតប្រជែងនៅក្នុងវិស័យដែលតែងតែវិវឌ្ឍឥតឈប់ឈរនេះទៅវិញ។ ដើម្បីបំពេញតម្រូវការនេះ ក្រុមហ៊ុននានាបានបង្ខំចិត្តវិនិយោគធនធានដ៏ច្រើនទៅលើការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពនិស្សិតទើបបញ្ចប់ការសិក្សា ឬចំណាយធនធានកាន់តែច្រើនថែមទៀតទៅលើការថែរក្សា និងការជ្រើសរើសបុគ្គលិកជាតិ និងអន្តរជាតិដែល មានបទពិសោធន៍ដើម្បីបំពេញនូវកង្វះខាតនេះ។ បញ្ហានេះបណ្តាលឱ្យការចំណាយទៅលើថ្លៃពលកម្មកើនឡើង និងមានអតុល្យភាពជាមួយនឹងដៃគូប្រកួតប្រជែងនៅក្នុងតំបន់ ដោយសារតែបេក្ខជនមានបទពិសោធន៍ពិតប្រាកដ គឺមានចំនួនតិចតួច កំណើននៃចំណាយទាំងនេះ បានធ្វើឱ្យប៉ះពាល់ទៅដល់លទ្ធភាពរបស់វិស័យបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន នៅក្នុងប្រទេសកម្ពុជា ក្នុងការរក្សាសមត្ថភាពប្រកួតប្រជែងផ្នែកហិរញ្ញវត្ថុ ដែលនេះជាកត្តាដ៏សំខាន់បំផុត ពីព្រោះគម្រោង បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន ជាច្រើន គឺលែងពឹងផ្អែកលើទីតាំងភូមិសាស្ត្រដូចមុនទៀតហើយ។*

*ឧបសគ្គផ្នែកហិរញ្ញវត្ថុបន្ថែមនេះ បានធ្វើឱ្យមានផលប៉ះពាល់មួយកម្រិតថែមទៀតទៅលើក្រុមហ៊ុនបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន ដែលទើបតែនឹងចាប់ផ្តើម ហើយកំពុងស្ថិតក្នុងស្ថានភាពផុយស្រួយស្រាប់ ក្រុមហ៊ុននេះជារឿយៗ ត្រូវបានគេចាត់ទុកថាជាសរសៃឈាមនៃវិស័យ បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន ដែលមានភាពប្រកួតប្រជែងខ្ពស់។ ក្រុមហ៊ុនចាប់ផ្តើមថ្មីត្រូវការបុគ្គលិកដែលអាចធ្វើការដោយឯករាជ្យដែលត្រូវការការបណ្តុះបណ្តាលតិចតួចបំផុត និងដែលអស់ការចំណាយទាប ពីព្រោះការរួមចំណែករបស់ពួកគេត្រូវបានផ្តល់រង្វាន់តបស្នងវិញ តាមរយៈបទពិសោធន៍វិជ្ជាជីវៈដែលមានគុណតម្លៃខ្ពស់។ ដូច្នេះ ដោយសារតែធនធានរបស់ពួកគេនៅមានកម្រិតនៅក្នុងអំឡុងពេលនៃដំណាក់កាលលូតលាស់ដំបូង ក្រុមហ៊ុនបង្កើតថ្មីថ្មោងពុំមានសមត្ថភាពគាំទ្រដល់កម្រិតនៃការបណ្តុះបណ្តាល ដែលនិស្សិតកម្ពុជាជាច្រើនកំពុងត្រូវការនោះឡើយ។ កង្វះនូវបេក្ខភាពដែលមានទេពកោសល្យ និងមានប្រសិទ្ធភាពថ្លៃចំណាយនេះ បានរឹតត្បិតលទ្ធភាពរបស់ក្រុមហ៊ុនចាប់ផ្តើមថ្មីថ្មោង*

*ក្នុងការលួតលាស់ និងអាចអនុញ្ញាតឱ្យក្រុមហ៊ុនបរទេសអាចបង្កើតឈរជើងរឹងមាំនៅក្នុងទីផ្សារកម្ពុជា នៅមុនពេលដែលក្រុមហ៊ុនក្នុងស្រុកអាចធ្វើបានទៅទៀត។*

✓ សូមស្នើឱ្យលើកកម្ពស់ការចូលរួមកាន់តែច្រើនថែមទៀត ពីសំណាក់អ្នកផ្តល់សេវាបណ្តុះបណ្តាល និងវិស័យឯកជន ដើម្បីកែលម្អវគ្គបណ្តុះបណ្តាលបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងការទទួលស្គាល់ ដើម្បីដោះស្រាយបញ្ហាគម្លាតជំនាញក្នុងវិស័យនេះ។

**អនុសាសន៍ឆ្នាំ ២០១៩**

*ដោយទទួលស្គាល់នូវកិច្ចប្រឹងប្រែង ដែលក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានអនុវត្តកន្លងមក ដើម្បីលើកកម្ពស់បទដ្ឋាននៃការអប់រំ យើងខ្ញុំសូមផ្តល់ជូនអនុសាសន៍ ដោយស្នើឱ្យរាជរដ្ឋាភិបាល ខិតខំជំរុញការចូលរួមឱ្យបានច្រើនថែមទៀតពីសំណាក់អ្នកផ្តល់សេវាបណ្តុះបណ្តាល និងវិស័យឯកជន ដើម្បីកែលម្អបទដ្ឋាននៃការបណ្តុះបណ្តាលបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន និងបទដ្ឋានទទួលស្គាល់។ ការធ្វើដូច្នេះ នឹងស្របទៅនឹងគោលដៅរបស់មូលនិធិសម្រាប់ការកសាងសមត្ថភាពការស្រាវជ្រាវ និងការអភិវឌ្ឍ ដែលទើបបាននឹងបង្កើតថ្មីក្នុងគោលបំណងលើកទឹកចិត្តដល់ការអភិវឌ្ឍធនធានមនុស្សតាមរយៈការគាំទ្ររបស់វិស័យឯកជន។*

*ទោះបីជាយើងខ្ញុំទទួលស្គាល់ថា ការរៀបចំបង្កើតឱ្យមានក្របខ័ណ្ឌអប់រំដែលមានការទទួលស្គាល់មួយសម្រាប់វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន គឺជាកិច្ចការដែលត្រូវការពេលវេលាយូរក៏ដោយ យើងខ្ញុំសូមសំណូមថាអ្នកផ្តល់សេវាបណ្តុះបណ្តាលគួរតែសហការឱ្យបានជិតស្និទ្ធជាមួយនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដើម្បីរៀបចំតាក់តែវគ្គបណ្តុះបណ្តាលរបស់ខ្លួន ពីព្រោះថាក្រុមហ៊ុនយល់ដឹងច្បាស់អំពីតម្រូវការបច្ចុប្បន្ន និងនាពេលអនាគតរបស់វិស័យនេះ។ វិស័យឯកជនអាចផ្តល់ការគាំទ្រដល់គ្រឹះស្ថានបណ្តុះបណ្តាល ដើម្បីបង្កើតនូវកម្មវិធីសិក្សាមួយដែលផ្តោតលើតម្រូវការជាក់ស្តែង ដោយពិនិត្យឡើងវិញទៅលើខ្លឹមសារនៃការបណ្តុះបណ្តាល វិធីសាស្ត្របង្រៀន និងការប្រឡង។ បន្ទាប់ពីនេះ គ្រឹះស្ថានបណ្តុះបណ្តាលច្រើនថែមទៀត គួរតែខិតខំផ្តល់នូវវិញ្ញាបនបត្របច្ចេកទេស ដូចជា Cisco, Microsoft និង Oracle ពីព្រោះកម្មវិធីវិជ្ជាជីវៈដែលមានការទទួលស្គាល់ជាអន្តរជាតិទាំងនេះ ត្រូវបានរៀបចំបង្កើតឡើងសម្រាប់ការប្រើប្រាស់ជាក់លាក់ និងសម្រាប់ការអភិវឌ្ឍអាជីពវិជ្ជាជីវៈ។*

*យើងខ្ញុំសង្ឃឹមថា ការជំរុញឱ្យមានកិច្ចសម្របសម្រួលកាន់តែជិតស្និទ្ធថែមទៀតនេះ នឹងទទួលបានភាពជោគជ័យ ដូចដែលការចូលរួមកាន់តែច្រើនឡើង របស់វិស័យ រដ្ឋ និងឯកជន ជាមួយនឹងក្រសួងបានបង្ហាញឱ្យឃើញដូច្នេះដែរ ហើយភាពជោគជ័យនេះនឹងផ្តល់នូវភាគលាភនៅក្នុងរយៈពេលវែងតាមរយៈការលើកកម្ពស់ផលិតភាព និងឧត្តមភាពប្រកួតប្រជែងនៃកម្លាំងពលកម្មជំនាញបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរបស់កម្ពុជា ដោយស្របទៅនឹងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើពិពិធកម្មសេដ្ឋកិច្ចទាំងមូល។*

៣៦

# ការធានាស្ថិរភាពនិយ័តកម្មដើម្បីទ្រទ្រង់ដល់ការវិនិយោគនៅក្នុងវិស័យទូរគមនាគមន៍

**ធ្វើបច្ចុប្បន្នភាព**

---

**អនុសាសន៍ឆ្នាំ ២០១៧**

សូមធ្វើការពិគ្រោះយោបល់ខ្លឹមសារស៊ីជម្រៅជាមួយវិស័យឯកជនជាមុនសិន មុននឹងអនុវត្តដំណើរការចេញអាជ្ញាប័ណ្ណទូរគមនាគមន៍សារជាថ្មីឡើងវិញ។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*នៅក្នុងលិខិតដែលបានផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា កាលពីខែតុលា ឆ្នាំ២០១៨ ក្រសួងប្រៃសណីយ៍និងទូរគមនាគន៍ បានរៀបរាប់យ៉ាងលម្អិតអំពីទិដ្ឋភាពជាច្រើន ដែលវិស័យឯកជនបានចូលរួម នៅក្នុងការបង្កើតច្បាប់ថ្មីស្តីពីទូរគមនាគមន៍។ ក្រសួងក៏បានលើកឡើងជាថ្មីម្តងទៀត ថាខ្លួនមានគោលបំណងបន្តរៀបចំកិច្ចប្រជុំពិគ្រោះយោបល់អំពីការកែប្រែច្បាប់នានាក្នុងពេលអនាគត ក្នុងនោះរួមទាំងដំណើរការនៃការផ្តល់អាជ្ញាប័ណ្ណជាថ្មីផងដែរ និងបានសម្តែងការស្វាគមន៍ចំពោះគ្រប់មតិត្រឡប់ ធាតុចូល ព្រមទាំងការព្រួយបារម្ភនានា ដែលវិស័យឯកជនអាចនឹងមានទៀតផង។*

---

**ពិពណ៌នាបញ្ហា**

*រាជរដ្ឋាភិបាល បានអនុម័តច្បាប់ថ្មីស្តីពីទូរគមនាគមន៍ កាលពីខែធ្នូ ឆ្នាំ២០១៥ ដែលក្នុងនោះ បានដាក់បញ្ញត្តិលើលក្ខខណ្ឌតម្រូវឱ្យក្រុមហ៊ុនធុរកិច្ចទាំងអស់នៅក្នុងវិស័យទូរគមនាគមន៍ ដាក់ពាក្យឡើងវិញដើម្បីស្នើសុំអាជ្ញាប័ណ្ណប្រតិបត្តិការអាជីវកម្ម។ សេចក្តីព្រាងប្រកាសបានលើកឡើងអំពីដំណើរការដាក់ពាក្យឡើងវិញ និងតម្លៃសេវា ត្រូវបានផ្សព្វផ្សាយកាលពីដើមឆ្នាំ២០១៧ និងត្រូវបានរំពឹងទុកថានឹងត្រូវបានអនុម័តក្នុងអំឡុងឆ្នាំ២០១៧ ប៉ុន្តែការអនុម័តនេះ ត្រូវបានពន្យារពេល ដោយរង់ចាំកិច្ចពិគ្រោះយោបល់បន្ថែមទៀត។ ច្បាប់ថ្មីនេះក៏បានចែងផងដែរអំពីការដំឡើងតម្លៃសេវាពាក់ព័ន្ធនឹងនិយ័តកម្ម និងសារពើពន្ធផ្សេងៗ ដូចជា តម្លៃសេវាកំណត់លេខដែលបានកែប្រែថ្មី ការផ្លាស់ប្តូរការបែងចែកចំណូល និងលក្ខខណ្ឌតម្រូវឱ្យធ្វើវិភាគទានចូលមូលនិធិសម្រាប់កាតព្វកិច្ចសេវាសាកល និងមូលនិធិសម្រាប់ការកសាងសមត្ថភាពការស្រាវជ្រាវ និងការអភិវឌ្ឍ ដែលកំពុងប៉ះពាល់ដល់សមត្ថភាពប្រកួតប្រជែងរបស់វិស័យនេះ។*

**ផលប៉ះពាល់លើកម្ពុជា**

*ទោះបីជាតម្លៃលក់រាយ នូវសេវាទូរសព្ទចល័តនៅកម្ពុជាស្ថិតក្នុងកម្រិតទាបជាងគេបំផុតមួយនៅលើពិភពលោកហើយក្តី ប៉ុន្តែការប្រើប្រាស់ទិន្នន័យដោយទូរសព្ទចល័ត (mobile data) កំពុងមានការកើនឡើងគួរឱ្យកត់សម្គាល់ ដែលនាំឱ្យប្រតិបត្តិករសេវាទូរសព្ទចល័ត ត្រូវតែធ្វើការវិនិយោគយ៉ាងច្រើន ទៅលើហេដ្ឋារចនាសម្ព័ន្ធបណ្តាញ និងបច្ចេកវិទ្យាទំនើប ដែលមានវដ្តជីវិតខ្លីៗ។ ដូច្នេះហើយ ដើម្បីទាក់ទាញការវិនិយោគបន្តនៅក្នុងវិស័យទូរគមនាគមន៍ និងក្នុងប្រទេសកម្ពុជា ជារួម ជារឿងសំខាន់ណាស់ ដែលរាជរដ្ឋាភិបាលត្រូវផ្តល់ឱ្យវិនិយោគិននូវការលើកទឹកចិត្តជំរុញបន្តការវិនិយោគ។*

នៅក្នុងយុគសម័យ ៥G ខាងមុខនេះ ដែលជាធាតុដ៏សំខាន់មួយនៃសេដ្ឋកិច្ចឌីជីថល ព្រមទាំងឧស្សាហកម្ម ៤.០ ការវិនិយោគច្រើននឹងត្រូវការជាចាំបាច់ពាក់ព័ន្ធទៅនឹងឧបករណ៍ វិសាលគម និងហេដ្ឋារចនាសម្ព័ន្ធនៅកម្រិតផ្សេងៗទៀត។ នៅក្នុងទីផ្សារក្នុងប្រទេសដទៃទៀត រដ្ឋាភិបាលនានាកំពុងវាយតម្លៃឡើងវិញទៅលើពន្ធដាក់លាក់តាមវិស័យ ទន្ទឹមគ្នានឹងការផ្ដល់ការលើកទឹកចិត្តដល់ប្រតិបត្តិករដែលមានសមត្ថកម្ម និងអនុលោមភាពខ្ពស់ ដើម្បីឱ្យអនុវត្តការពង្រីកហេដ្ឋារចនាសម្ព័ន្ធ។ ឧទាហរណ៍ គណៈកម្មការប្រព័ន្ធផ្សព្វផ្សាយ និងទូរគមនាគមន៍ជាតិរបស់ប្រទេសថៃកំពុងមានផែនការផ្ដល់ឱ្យប្រតិបត្តិករនូវកម្ចីដែលមានអត្រាការប្រាក់ទាប ដោយប្រើថវិកាមូលនិធិសម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍរបស់ខ្លួនហើយទន្ទឹមនឹងនោះក៏ បានផ្ដល់នូវលក្ខខណ្ឌមានភាពបត់បែនខ្ពស់សម្រាប់ការដេញថ្លៃវិសាលគមនាពេលខាងមុខដើម្បីលើកទឹកចិត្ត និងគាំទ្រដល់ការវិនិយោគទាក់ទងនឹងបណ្ដាញ ៥G ផងដែរ។

វិស័យទូរគមនាគមន៍របស់ប្រទេសកម្ពុជា បាននិងកំពុងអភិវឌ្ឍក្នុងល្បឿនមួយគួរជាទីពេញចិត្ត ប៉ុន្តែ វិធានការបន្ថែមដើម្បីទាញយកចំណូលពីវិស័យនេះ អាចនឹងប៉ះពាល់អវិជ្ជមានទៅលើអ្នកពាក់ព័ន្ធ។

វិស័យនេះទទួលស្គាល់តួនាទីរបស់ខ្លួននៅក្នុងការរួមចំណែករកចំណូលសម្រាប់ចំណូលថវិកាជាតិរបស់រដ្ឋាភិបាល ប៉ុន្តែដើម្បីឱ្យវិស័យនេះកាន់តែមាននិរន្តរភាព កំណែទម្រង់បន្ថែមគួរតែធ្វើឱ្យមានតុល្យភាពគ្នាជាមួយនឹងកំណើនរបស់វិស័យនេះ និងភាពចាំបាច់សម្រាប់ការវិនិយោគបន្ថែម ជាពិសេស ដោយសារតែយុទ្ធសាស្ត្រកំណត់តម្លៃត្រូវបានរារាំងដោយតម្រូវការទីផ្សារ។

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យមានការបន្តរៀបចំឱ្យមានការចូលរួមនៅក្នុងការពិគ្រោះយោបល់ស៊ីជម្រៅជាមួយនឹងវិស័យឯកជនជាមុនសិន មុននឹងអនុម័តដំណើរការបន្តអាជ្ញាប័ណ្ណផ្នែកទូរគមនាគមន៍សាជាថ្មីឡើងវិញ ព្រមទាំងពិនិត្យរកឱកាស ផ្ដល់ការលើកទឹកចិត្តដល់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ផងដែរ។

យើងខ្ញុំសូមគោរពផ្ដល់ជូនអនុសាសន៍ ដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងអង្គភាពនិយ័តករទូរគមនាគមន៍កម្ពុជា ឱ្យបន្តចូលរួមនៅក្នុងការពិគ្រោះយោបល់ស៊ីជម្រៅ ជាមួយវិស័យឯកជនជាមុនសិន មុននឹងអនុម័តដំណើរការបន្តអាជ្ញាប័ណ្ណផ្នែកទូរគមនាគមន៍សាជាថ្មីឡើងវិញ។ បន្ថែមពីលើនេះទៅទៀត រាជរដ្ឋាភិបាលគួរតែពិនិត្យរកមើលឱកាសក្នុងការទ្រទ្រង់ និងលើកទឹកចិត្តដល់ការវិនិយោគច្រើនថែមទៀត ដើម្បីពង្រីក និងពន្លឿនល្បឿននៃការអភិវឌ្ឍន៍លើហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ តាមរយៈការផ្ដល់ការលើកទឹកចិត្ត និងលក្ខខណ្ឌកិច្ចសន្យាដែលមានភាពអនុគ្រោះ។

ជាងនេះទៅទៀត យើងខ្ញុំសូមលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាលប្រកាន់យកនូវគោលការណ៍ "មិនកាន់តែពិបាក" (no worse off) នៅក្នុងដំណាក់កាលរៀបចំ និងសម្រេចចុងក្រោយនូវប្រកាសថ្មីនានានៅពេលខាងមុខ[1] - លក្ខខណ្ឌថ្មីគួរតែគោរពលក្ខខណ្ឌនានាដែលបានព្រមព្រៀងគ្នារួចមកហើយជាមួយនឹងវិនិយោគិនដែលមានស្រាប់ និងមិនគួរបន្ថែមបន្ទុកនិយ័តភាព និងការចំណាយផ្សេងៗទៅលើវិនិយោគិនទាំងនោះឡើយ។ ប្រសិនបើពន្ធ និងការចំណាយផ្នែកនិយ័តកម្ម នឹងត្រូវដំឡើងបន្ថែមទៀតនោះ កត្តានេះនឹងធ្វើឱ្យសេវាទូរគមនាគមន៍កាន់តែមានតម្លៃថ្លៃហួសពីសមត្ថភាពជាវបានរបស់អតិថិជន និងអាចមានផលប៉ះពាល់អវិជ្ជមានមកលើនិរន្តរភាពរបស់វិស័យនេះជាក់ជាមិនខាន។

៣៧

# ការផ្តល់ជូនវិសាលគម

ធ្វើបច្ចុប្បន្នភាព

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើឱ្យរៀបចំបង្កើត និងដាក់ឱ្យអនុវត្តនូវដំណើរការពិនិត្យមើល និងជ្រើសរើសអ្នកដេញថ្លៃវិសាលគមនាពេលអនាគត ។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*ដូចដែលបានតម្រូវដោយច្បាប់ស្តីពីទូរគមនាគមន៍ រាជរដ្ឋាភិបាលកំពុងរៀបចំធ្វើសេចក្តីព្រាងអនុក្រឹត្យថ្មីមួយ ស្តីពីការរៀបចំផែនការ ការផ្តល់ជូន ការកំណត់ និងការតាមដានហ្វ្រេកង់វិសាលគម ហើយយើងរំពឹងថា អនុក្រឹត្យនេះនឹងផ្តល់លទ្ធភាពដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អាចផ្តល់ជូនវិសាលគមតាមរយៈដំណើរការដេញថ្លៃ។*

**ពិពណ៌នាបញ្ហា**

*រាជរដ្ឋាភិបាលរក្សាសិទ្ធិ នៅក្នុងការផ្តល់ជូន និងកំណត់ការប្រើប្រាស់ហ្វ្រេកង់វិសាលគមគ្មានខ្សែ ទៅឱ្យក្រុមហ៊ុនទូរគមនាគមន៍នានា។ បច្ចុប្បន្ននេះមានក្រុមហ៊ុនវិស័យឯកជនជាច្រើនដែលកំពុងកាន់កាប់លើវិសាលគមនៅកម្ពុជា ប៉ុន្តែក្រុមហ៊ុនខ្លះកាន់កាប់វិសាលគមផ្តាច់មុខ ប៉ុន្តែមិនផ្តល់សេវាអ្វីឡើយ។ វិសាលគមគ្មានខ្សែគឺជាធនធានធម្មជាតិដ៏កម្រមួយ ហើយក្នុងនោះមានតែមួយចម្រៀកតូចប៉ុណ្ណោះដែលមានសមត្ថភាពសមល្មមសម្រាប់បញ្ជូនរលកសញ្ញាទូរគមនាគមន៍។ ដូច្នេះប្រព័ន្ធផ្តល់ជូនវិសាលគមមួយ ដែលមិនធានានូវការប្រើប្រាស់ប្លុកបដោយប្រសិទ្ធភាព នឹងបង្កជាឧបសគ្គដល់ការអភិវឌ្ឍសេវាកម្មទូរគមនាគមន៍នៅកម្ពុជា។ ច្បាប់ថ្មីស្តីពីទូរគមនាគមន៍ បានតម្រូវឱ្យមានអនុក្រឹត្យថ្មីមួយ ដែលត្រូវគ្របដណ្តប់លើការធ្វើផែនការ ការផ្តល់ជូន ការកំណត់ និងការតាមដានវិសាលគម ។*

*យើងខ្ញុំទទួលបានព័ត៌មានថា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កំពុងរៀបសេចក្តីព្រាងអនុក្រឹត្យថ្មីនេះ ហើយរំពឹងទុកថា នឹងដាក់ចេញឱ្យអនុវត្តនូវប្រព័ន្ធដេញថ្លៃមួយ ដើម្បីគ្រប់គ្រងទៅលើការផ្តល់ជូនវិសាលគម។ នេះគឺខុសពីដំណើរការដាក់ឱ្យដេញថ្លៃបែបប្រកួតប្រជែង ពីព្រោះការដាក់ឱ្យដេញថ្លៃផ្តល់ជូនវិសាលគមដោយផ្អែកលើតម្លៃខ្ពស់បំផុតដែលបានផ្តល់ដោយអ្នកដេញថ្លៃចាប់អារម្មណ៍ ខណៈដែលជាមួយអ្នកឈ្នះការដេញថ្លៃនេះ ការផ្តល់ជូនវិសាលគមគឺផ្អែកទៅតាមផែនការអាជីវកម្មដែលបានដាក់ជូន រួចហើយត្រូវបានវាយតម្លៃដោយធៀបទៅនឹងលក្ខណៈវិនិច្ឆ័យដាក់លាក់។ ការដាក់ឱ្យដេញថ្លៃវិសាលគម គឺជាវិធីសាស្ត្រផ្តល់ជូនដែលគេប្រើជាទូទៅនៅក្នុងប្រទេសដទៃទៀត ប៉ុន្តែការដាក់ឱ្យដេញថ្លៃនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងសមហេតុផល ដើម្បីជៀសវាងការបំប៉ោងតម្លៃដោយអ្នកដេញថ្លៃទុកលក់បន្តយកចំណេញ ដែលគ្មានសមត្ថភាពហិរញ្ញវត្ថុដើម្បីបង់ថ្លៃវិសាលគមដែលខ្លួនដេញបាននោះ ឬក៏គ្មានសមត្ថភាពផ្តល់សេវាដែលប្រើប្រាស់វិសាលគមនោះដែរ។*

## ផលប៉ះពាល់លើកម្ពុជា

*វិស័យទូរគមនាគមន៍នៅកម្ពុជា នឹងទទួលបានផលប្រយោជន៍ជាច្រើន នៅពេលមានការធានាពីរាជរដ្ឋាភិបាល ដើម្បីធានាថាវិសាលគមនឹងត្រូវផ្តល់ជូនអ្នកផ្តល់សេវាដែលនឹងប្រើប្រាស់វិសាលគមនោះយ៉ាងពិតប្រាកដ ពីព្រោះក្រុមហ៊ុនផ្តល់សេវាទាំងនេះហើយ ដែលចូលរួមចំណែកបង់ពន្ធជូនរដ្ឋ បង្កើតការងារ និងបង្កើនការតភ្ជាប់បណ្តាញទូរគមនាគមន៍។ ផ្ទុយទៅវិញ ការដាក់វិសាលគមយកទៅស្តុកទុកដោយគ្មានផ្តល់សេវាអ្វីទាល់តែសោះ នឹងធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជា បាត់បង់ឱកាសក្នុងការសម្រេចបាននូវគោលបំណងអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួន។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យមានការដេញថ្លៃវិសាលគមនាពេលអនាគត អនុវត្តសម្រាប់តែការផ្តល់ជូនវិសាលគមថ្មីប៉ុណ្ណោះ និងត្រូវធានាថាមានការត្រួតពិនិត្យត្រឹមត្រូវលើអ្នកដេញថ្លៃ។

*ប្រសិនបើរាជរដ្ឋាភិបាលអនុវត្តតាមសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងការដាក់ចេញនូវការដេញថ្លៃវិសាលគម យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យយន្តការនេះប្រើសម្រាប់តែការផ្តល់ជូនវិសាលគមថ្មីប៉ុណ្ណោះ ដូចជាសម្រាប់ ៧០០MHz ជាជាងការអនុវត្តសម្រាប់ការបន្ត ឬការផ្តល់ជូនជាថ្មីឡើងវិញនូវសម្បទានដែលមានស្រាប់ ដែលធ្លាប់មានដំណើរការដាក់ដេញថ្លៃបែបប្រកួតប្រជែងគ្រប់គ្រាន់រួចទៅហើយ។ ប្រការនេះរាប់បញ្ចូលទាំងការកំណត់លក្ខខណ្ឌតម្រូវឱ្យអ្នកដេញថ្លៃត្រូវតែឆ្លងកាត់នីតិវិធីមុនការដេញថ្លៃ នៅមុនចូលរួមការដេញថ្លៃ ដើម្បីធានាថាតម្លៃនៃវិសាលគមនឹងមិនត្រូវបានបំប៉ោងកែ្លងក្លាយដោយអ្នកដេញថ្លៃទាំងនោះ។ ការពិនិត្យជម្រុះនៅមុនការដេញថ្លៃ គួរតែតម្រូវឱ្យក្រុមហ៊ុននានាបង្ហាញអំពីបំណងពិតប្រាកដក្នុងការផ្តល់សេវានៅលើវិសាលគមដែលពួកគេនឹងដេញថ្លៃយក ឧទាហរណ៍ ដោយតម្រូវឱ្យក្រុមហ៊ុនទាំងនោះផ្តល់នូវផែនការផ្តល់សេវាកម្ម និងការបង្ហាញអំពីសមត្ថភាពហិរញ្ញវត្ថុនៅមុនពេលផ្តល់ការអនុញ្ញាតឱ្យចូលរួមនៅក្នុងដំណើរការដេញថ្លៃ។*

*លើសពីនេះទៅទៀត ជាផ្នែកមួយនៃការសម្រេចចុងក្រោយទៅលើអនុក្រឹត្យស្តីពីការដេញថ្លៃវិសាលគម យើងខ្ញុំសូមជូនជាអនុសាសន៍ថាការផ្តល់វិសាលគមដល់អ្នកកាន់អាជ្ញាប័ណ្ណបច្ចុប្បន្ន គួរត្រូវបានរក្សាទុកនៅដដែល (លើកលែងតែអ្នកដែលមិនប្រើប្រាស់វិសាលគមនោះទាល់តែសោះ) ហើយស្របពេលគ្នានោះដែរ គួរពិចារណាដាក់ចេញនូវកាតព្វកិច្ចផែនការប្រតិបត្តិការអប្បបរមា ឬរបៀបគ្រប់គ្រងផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះ ដើម្បីទប់ស្កាត់កុំឱ្យអ្នកដេញថ្លៃដែលមិនប្រាកដប្រជាចូលរួមនៅក្នុងការដេញថ្លៃ។ ជាងនេះទៅទៀត វិសាលគមច្រើនថែមទៀតគួរតែបញ្ចេញទៅឱ្យសេវាទូរសព្ទចល័ត ដើម្បីគាំទ្រដល់របៀបវារៈជំរុញបរិយាបន្នឌីជីថលរបស់ប្រទេសកម្ពុជាឱ្យកាន់តែល្អប្រសើរ។*

# វិស័យធុរកិច្ចបៃតង

គណៈកម្មាធិការធុរកិច្ចបៃតងរបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាគឺជាគណៈកម្មាធិការមួយក្នុងចំណោមគណៈកម្មាធិការសកម្មបំផុតដែលបានបង្ហាញចំណាប់អារម្មណ៍របស់វិស័យឯកជនយ៉ាងខ្លាំងចំពោះការរួមបញ្ចូលការអនុវត្តឱ្យកាន់តែមានទំនួលខុសត្រូវចំពោះសង្គម និងបរិស្ថាននៅក្នុងប្រតិបត្តិការធុរកិច្ចរបស់ខ្លួន។ គណៈកម្មាធិការនេះបានដឹកនាំកម្មវិធីជាច្រើនកាលពីឆ្នាំមុន ដោយបានរៀបចំកម្មវិធី អាហារពេលព្រឹកអំពីប្រធានបទគួរឱ្យចាប់អារម្មណ៍មួយចំនួន ដូចជា ការវិនិយោគដែលមានផលប៉ះពាល់ ការកាត់បន្ថយប្លាស្ទីក គម្រោងសាងសង់ផ្ទះមានតម្លៃសមរម្យ និងចក្ខុវិស័យនាពេលអនាគតអំពីថាមពលជាដើម។ កម្មវិធីនីមួយៗបានផ្តល់ជាវេទិកាប្រកបដោយការស្វាគមន៍ដល់អ្នកចូលរួមដែលមកពីរាជរដ្ឋាភិបាល សង្គមស៊ីវិល និងសហគមន៍ធុរកិច្ច ក្នុងការផ្លាស់ប្តូរយុទ្ធសាស្ត្រដោះស្រាយបញ្ហាប្រឈមនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅកម្ពុជា។

ដើម្បីពង្រឹងការលើកកម្ពស់ការយល់ដឹងតាមរយៈកម្មវិធីអាហារពេលព្រឹក សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា បានចាប់ផ្តើមកម្មវិធីប្រកួតប្រជែង និងផ្តល់រង្វាន់ចំពោះក្រុមហ៊ុនណាដែលមានទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម (CSR) លើគ្រប់វិស័យជាលើកដំបូងនៅកម្ពុជាដើម្បីទទួលស្គាល់ និងលើកទឹកចិត្តដល់ការអនុវត្តទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម របស់ក្រុមហ៊ុនដែលជាសមាជិក។ កម្មវិធីដ៏គួរឱ្យចាប់អារម្មណ៍នេះនឹងអាចឱ្យក្រុមហ៊ុនចូលរួមបង្ហាញអំពីកម្មវិធី CSR របស់ខ្លួនដើម្បីឱ្យគណៈកម្មការធ្វើការវាយតម្លៃលើហេតុប៉ះពាល់ វិធីសាស្ត្រ និងភាពច្នៃប្រឌិត ដែលមានគោលបំណងផ្តល់ជូននូវភាពដែលអាចមើលឃើញយ៉ាងទូលំទូលាយដល់ទស្សនៈទានរបស់ CSR នៅកម្ពុជា។

ពាក់ព័ន្ធនឹងការបង្កើតការតស៊ូមតិ គណៈកម្មាធិការធុរកិច្ចបៃតងរបស់យើង បានបង្កើនទំនាក់ទំនងជាមួយនឹងរាជរដ្ឋាភិបាល ជាពិសេស តាមរយៈកម្មវិធីអាហារថ្ងៃត្រង់ជាមួយឯកឧត្តមបណ្ឌិត សាយ សំអាល់

រដ្ឋមន្ត្រីក្រសួងបរិស្ថាន នៅខែមករា ឆ្នាំ ២០១៨។ អ្នកចូលរួមក្នុងកម្មវិធីនេះ បានទទួលនូវការយល់ដឹងដោយផ្ទាល់អំពីកម្មវិធីកំណែទម្រង់នាពេលអនាគតរបស់ក្រសួង និងគំនិតផ្តួចផ្តើមកសាងសមត្ថភាពនានាដែលកំពុងដំណើរការដើម្បីប្រែក្លាយនិងធ្វើទំនើបកម្មក្រសួងនេះ។ ក្រសួងក៏បានបន្តបើកកិច្ចពិភាក្សាពិគ្រោះយោបល់ជាសាធារណៈអំពីសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិរបស់កម្ពុជាដែលនឹងត្រូវអនុម័តនាពេលខាងមុខ ហើយសមាជិករបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា បានបង្ហាញអំពីឱកាសបន្តបន្ទាប់ ក្នុងការផ្តល់មតិត្រឡប់ ដាក់ស្តែងលើសេចក្តីព្រាងក្រមនោះ ដែលបច្ចុប្បន្នកំពុងស្ថិតនៅក្រោមការកែសម្រួលនៅដំណាក់កាលទី ១១។ ដោយសារតែមានការលើកឡើងអំពីកង្វល់ជាច្រើននៅក្នុងសៀវភៅ ស មុនៗរបស់យើង ដែលទាក់ទងជាមួយនឹងផ្នែកដែលនឹងត្រូវដោះស្រាយដោយក្រមថ្មីនេះ យើងក៏បានដាក់បញ្ចូលអនុសាសន៍ថ្មី អំពីការកំណត់អាទិភាពបញ្ចប់ក្រមនេះដើម្បីធ្វើការបញ្ជាក់ឱ្យកាន់តែច្បាស់អំពីទំនួលខុសត្រូវបរិស្ថានរបស់ វិនិយោគិន។

អាជ្ញាធរអគ្គិសនីកម្ពុជា បានចាត់វិធានការចាំបាច់ក្នុងការបង្កើតជាផ្លូវការនូវបរិយាកាសនិយ័តកម្មសម្រាប់ថាមពលកកើតឡើងវិញ នៅខែមករា ឆ្នាំ២០១៨ ដោយមានការបង្កើតនូវបទប្បញ្ញត្តិស្តីអំពីបណ្តាញប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ ដែលតភ្ជាប់ជាមួយនឹងប្រព័ន្ធបណ្តាញអគ្គិសនីជាតិ។ បន្ទាប់ពីដាក់ចេញនូវបទប្បញ្ញត្តិនេះ អាជ្ញាធរអគ្គិសនីកម្ពុជា បានអញ្ជើញគណៈកម្មាធិការធុរកិច្ចបៃតងរបស់យើងឱ្យផ្តល់នូវធាតុចូលបច្ចេកទេសចំពោះរចនាសម្ព័ន្ធតារាងតម្លៃថ្មី ដែលបានដាក់ឱ្យប្រើប្រាស់ជាមួយនឹងបទប្បញ្ញត្តិ។ ទោះជាយ៉ាងណាក៏ដោយ នៅតែមានក្តីកង្វល់ដែលបានលើកឡើងជាមួយនឹងអត្រាតម្លៃដែលបានកំណត់សម្រាប់តារាងតម្លៃទាំងនេះ ដោយសារតែក្រុមហ៊ុនធុរកិច្ចជាច្រើនបានគិតថាតម្លៃអគ្គិសនីនៅក្នុងតារាងនេះគឺខ្ពស់ខ្លាំងពេក ដែលនឹងធ្វើឱ្យប៉ះពាល់ដល់ស្ថានភាពសេដ្ឋកិច្ចសម្រាប់ការដំឡើងបន្ទះសូឡាទាញយកថាមពលព្រះអាទិត្យនៅលើដំបូល។ អាស្រ័យហេតុនេះ យើងខ្ញុំបានធ្វើបច្ចុប្បន្នភាពអនុសាសន៍អំពីការគាំទ្រដល់ការប្រកួតប្រជែងលើថាមពលពន្លឺព្រះអាទិត្យ ដោយស្នើថា គម្រោងកម្មវិធី

លើកទឹកចិត្តដែលមាននៅក្នុងសេចក្តីព្រាងថ្មីនៃក្រុមបរិស្ថាន និងធនធានធម្មជាតិ សូមរក្សាទុកឱ្យនៅដដែលក្នុងកំណែប្រែសេចក្តីព្រាងស្ថាពរ។លើសពីនេះទៀត យើងខ្ញុំក៏បានរក្សាទុកអនុសាសន៍អំពីការលើកទឹកចិត្តឱ្យដកចេញនូវលក្ខខណ្ឌតម្រូវសញ្ជាតិខ្មែរសម្រាប់ការប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយសារតែលក្ខខណ្ឌនេះរឹតត្បិតដល់ការប្រកួតប្រជែង ហើយមិនស្របតាមការប្តេជ្ញាចិត្តអន្តរជាតិរបស់កម្ពុជាទៀតផង។

ការទទួលស្គាល់សំណង់អគារប្រកបដោយនិរន្តរភាពនៅកម្ពុជា គឺជាមានដំណើរការដូចគ្នានេះដែរ ដែលបានធ្វើការពិភាក្សានៅក្នុងក្រសួងបរិស្ថានដើម្បីបង្កើតកម្រងគោលការណ៍ណែនាំស្តីពីអគារបៃតងដោយក្រុមការងារបច្ចេកទេសទើបបង្កើតថ្មីអំពីទីក្រុងនិរន្តរភាព។នេះជាការលើកទឹកចិត្តពិតប្រាកដណាស់ ដោយសារតែមានការចាប់អារម្មណ៍ចំពោះការបង្កើតក្រុមប្រឹក្សាអគារបៃតងកម្ពុជានៅក្រោមក្រសួងបរិស្ថាន។ ប៉ុន្តែ យើងខ្ញុំសូមផ្តល់អនុសាសន៍ថា អង្គភាពនេះគួរតែបង្កើតឡើងដោយឯករាជ្យមិនស្ថិតនៅក្រោមរាជរដ្ឋាភិបាល ដូចដែលបានតម្រូវឱ្យមានដោយក្រុមប្រឹក្សាអគារបៃតងពិភពលោកដើម្បីអាចមានសិទ្ធិចូលទៅកាន់បណ្តាញគាំទ្រជាសកលនិងឧត្តមានុភាពជាអន្តរជាតិ។

អនុសាសន៍នៅសល់របស់យើងខ្ញុំគឺសូមស្នើឱ្យធ្វើការពង្រឹង និងចូលរួមចំណែកបន្ថែមនៅក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើអន្តរកាលរបស់កម្ពុជាទៅជាប្រទេសសេដ្ឋកិច្ចបៃតងដែលទំនួលខុសត្រូវបរិស្ថាន និងសង្គមរបស់កម្ពុជានៅក្នុងការបន្តជំរុញកំណើនសេដ្ឋកិច្ចរបស់ខ្លួននឹងមិនធ្វើឱ្យប៉ះពាល់ឡើយ។ ដើម្បីសម្រួលដំណើរការនេះ យើងបានធ្វើបច្ចុប្បន្នភាពអនុសាសន៍ស្តីអំពីការបង្កើតកម្មវិធីស្លាកសញ្ញាបរិស្ថានជាតិសម្រាប់ទំនិញ និងជំរុញឱ្យមានការអនុវត្តការគ្រប់គ្រងសំណល់ប្រកបដោយនិរន្តរភាព នៅក្នុងវិស័យឯកជន។ អនុសាសន៍ចុងក្រោយរបស់យើងសង្កត់ធ្ងន់ទៅលើតម្រូវការចំពោះការគាំទ្រហិរញ្ញវត្ថុកាន់តែប្រសើរសម្រាប់សហគ្រាស ធុនតូច និងមធ្យម (SMEs) ដើម្បីធ្វើការវិនិយោគលើការអភិវឌ្ឍកាបូនកម្រិតទាប ដោយសារតែវិស័យសហគ្រាសធុនតូច និងមធ្យមមានគោលជំហរល្អក្នុងការដឹកនាំការប្រែក្លាយទៅជាសេដ្ឋកិច្ចបៃតង។

៣៨

# ការបញ្ចប់ក្រមបរិស្ថាន និងធនធានធម្មជាតិកម្ពុជា

ថ្មី

**ពិពណ៌នាបញ្ហា**

*រាជរដ្ឋាភិបាលទទួលស្គាល់អំពីតម្រូវការរឹងមាំ ក្នុងការពិនិត្យកែសម្រួលក្របខ័ណ្ឌច្បាប់បរិស្ថានរបស់កម្ពុជា ដោយសារតែច្បាប់ត្រូវអនុវត្តន៍ដែលគ្រប់គ្រងលើកិច្ចការពារបរិស្ថាន និងការប្រើប្រាស់ធនធានធម្មជាតិ នៅមិនទាន់បានធ្វើបច្ចុប្បន្នភាពនៅឡើយនោះទេ ចាប់តាំងពីពេលច្បាប់នេះត្រូវបានប្រកាសឱ្យប្រើប្រាស់នៅឆ្នាំ១៩៩៦មក។ ជាលទ្ធផល ក្រសួងបរិស្ថានបានប្ដេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ក្នុងការធ្វើសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិកម្ពុជាថ្មីចាប់តាំងពីឆ្នាំ២០១៥ រួមជាមួយនឹងសេចក្តីព្រាងក្រមនាបច្ចុប្បន្នកំពុងស្ថិតនៅក្នុងដំណើរការកែសម្រួលដំណាក់កាលទី១១។*

*នៅក្នុងដំណើរការបង្កើតយ៉ាងទូលំទូលាយនេះ ក្រសួងបានចូលរួមយ៉ាងសកម្មជាមួយនឹងភាគីពាក់ព័ន្ធតាមរយៈក្រុមការងារសង្គមស៊ីវិល និងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិមួយចំនួនជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល សហគមន៍មូលដ្ឋាន ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនដើម្បីប្រមូលធាតុចូល និងមតិត្រឡប់ដោយផ្ទាល់។ សិក្ខាសាលាថ្នាក់ជាតិនាពេលថ្មីបំផុតនេះត្រូវបានរៀបចំនៅខែមីនា ឆ្នាំ២០១៨ ហើយមតិត្រឡប់ទទួលបានពីសិក្ខាសាលាទាំងនេះត្រូវបានដាក់បន្ទូលជូនរាជរដ្ឋាភិបាលតាមរយៈក្រុមហ៊ុនច្បាប់ដែលចូលរួមក្នុងការរៀបចំសេចក្តីព្រាងក្រមនោះ។*

*គោលបំណងរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំសេចក្តីព្រាងក្រមថ្មីនេះគឺដើម្បីបង្កើតមូលដ្ឋានច្បាប់ពេញលេញសម្រាប់ដោះស្រាយគ្រប់បញ្ហាទាំងអស់ដែលពាក់ព័ន្ធ ដោយមិនកំណត់ចំពោះតែបរិស្ថាន និងធនធានធម្មជាតិនោះទេ។ ក្រមនេះត្រូវបានរំពឹងថា នឹងគ្របដណ្តប់លើផ្នែកជាច្រើន រួមមាន ការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិដោយមានកិច្ចសហការ ការគ្រប់គ្រងការបំពុល និងសំណល់ កិច្ចការពារជីវចម្រុះ កិច្ចការពារសម្បត្តិបេតិកភណ្ឌវប្បធម៌ និងការផ្តល់នីតិវិធីដោះស្រាយវិវាទជាដើម។ លើសពីនេះទៅទៀត ក្រមនេះត្រូវបានប្រកាសនៅខែវិច្ឆិកា ឆ្នាំ២០១៨ ថា សេចក្តីព្រាងក្រមនេះ នឹងត្រូវធ្វើវិសោធនកម្មម្តងទៀតដើម្បីដាក់បញ្ចូលបញ្ញត្តិជាក់លាក់ដែលគ្របដណ្តប់លើច្បាប់ចាស់ ស្តីពីព្រៃឈើ ជលផល និងតំបន់ការពារដែលនឹងតម្រូវឱ្យមានកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈបន្ថែមទៀត និងកិច្ចសហការរវាងក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានផងដែរ។*

*វិធីសាស្ត្រពិគ្រោះយោបល់បរិយាបន្ននេះ ដែលបានរៀបចំឡើងដោយរាជរដ្ឋាភិបាល បានទទួលការស្វាគមន៍យ៉ាងច្រើនគួរឱ្យកត់សម្គាល់ ហើយយើងទទួលស្គាល់ថាភាពស្មុគស្មាញនៃការបង្កើតច្បាប់ដ៏ មានសារៈសំខាន់ និងមានលក្ខណៈគ្រប់ជ្រុងជ្រោយនេះបាននាំឱ្យមានការយឺតយ៉ាវមិនអាចសម្រេច បានតាមពេលវេលាកំណត់ ប៉ុន្តែវិស័យឯកជនក៏មានក្តីកង្វល់ផងដែរ ថាការពន្យារពេលយូរបង្កើតក្រមនេះអាចមានផលប៉ះពាល់អវិជ្ជមានខ្លាំងដល់ការវិនិយោគនៅកម្ពុជា។*

## ផលប៉ះពាល់លើកម្ពុជា

ដោយសារតែក្រមបរិស្ថាន និងធនធានធម្មជាតិធ្វើបច្ចុប្បន្នភាពថ្មីដែលនឹងបញ្ចប់ក្នុងពេលឆាប់ៗនេះគឺជាច្បាប់ដ៏សំខាន់ ហើយត្រូវបានរំពឹងថានឹងត្រូវដាក់បញ្ចូលគ្រប់ផ្នែកទាំងអស់ដែលមានទាក់ទងជា មួយនឹងបរិស្ថានធម្មជាតិនៅកម្ពុជា ភាពមិនច្បាស់លាស់ដែលបណ្តាលមកពីការពន្យារពេលជាបន្តបន្ទាប់ អាចនឹងប៉ះពាល់ដល់ការសម្រេចចិត្តរបស់វិនិយោគិន។ កង្វះភាពច្បាស់លាស់ទៅលើអ្វីដែលរាជរដ្ឋាភិបាលរំពឹងទុក និងតម្រូវពីវិស័យឯកជន អាចធ្វើឱ្យក្រុមហ៊ុនធុរកិច្ចមិនដឹងអំពីអ្វីដែលគួរចាត់វិធានការដើម្បីអនុលោមឱ្យបានពេញលេញនូវក្រមនេះ។ កត្តានេះបង្កើតឱ្យមានហានិភ័យផ្លូវច្បាប់ និងនិយ័តកម្មបន្ថែមទៀត សម្រាប់វិនិយោគិនបច្ចុប្បន្ន និងអនាគត ដែលនឹងដាក់បញ្ចូលនៅក្នុងការគណនារបស់ខ្លួននៅពេលធ្វើការពិចារណាកម្ពុជាជាគោលដៅវិនិយោគ បើធៀបទៅនឹងបណ្តាប្រទេសផ្សេងទៀត។

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យកំណត់អាទិភាពរៀបចំបញ្ចប់ក្រមបរិស្ថាន និងធនធានធម្មជាតិកម្ពុជា។

មានអនុសាសន៍ជាច្រើនដែលយើងខ្ញុំបានផ្តល់ជូននៅក្នុងសំណៅបោះពុម្ពផ្សាយសៀវភៅ ស លើកមុនរបស់យើង មានទាក់ទងជាមួយនឹងផ្នែកមួយចំនួនដែលយើងរំពឹងថានឹងមានគ្រប់ដណ្តប់ក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិកម្ពុជាថ្មីនេះ។ អាស្រ័យហេតុនេះ ដើម្បីធ្វើឱ្យមានភាពច្បាស់លាស់ផ្នែកនិយ័តកម្មដោយភាពជោគជ័យដែលត្រូវការជាចាំបាច់ដើម្បីសម្រួលដោះស្រាយជម្លោះក្តីកង្វល់ដែល ពាក់ព័ន្ធនឹងទំនួលខុសត្រូវបរិស្ថានរបស់វិនិយោគិន យើងខ្ញុំសូមគោរពផ្តល់ជូននូវអនុសាសន៍ ស្នើឱ្យរាជរដ្ឋាភិបាលផ្តល់អាទិភាពរៀបចំបញ្ចប់ក្រមបរិស្ថាន និងធនធានធម្មជាតិកម្ពុជា។

៣៩

# ការគាំទ្រភាពប្រកួតប្រជែងរបស់វិស័យថាមពលពន្លឺព្រះអាទិត្យ

ធ្វើបច្ចុប្បន្នភាព

---

**អនុសាសន៍ឆ្នាំ ២០១៧**

សូមអនុវត្តវិធានការលើកទឹកចិត្តផ្នែកសារពើពន្ធ និងពិចារណាធ្វើការសាកល្បងយន្តការទូទាត់ថាមពលអគ្គិសនីពន្លឺព្រះអាទិត្យនៅសល់ ( net metering ) ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍វិស័យថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជា។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់អំពីភាពទាក់ទាញនៃថាមពលពន្លឺព្រះអាទិត្យ ហើយកាលពីខែមករា ឆ្នាំ ២០១៨ បានអនុម័តបទប្បញ្ញត្តិពាក់ព័ន្ធនឹងថាមពលពន្លឺព្រះអាទិត្យលើកដំបូងរបស់ខ្លួនតាមរយៈអាជ្ញាធរអគ្គិសនីកម្ពុជា ដែលបានលើកឡើងអំពីក្របខ័ណ្ឌនិយ័តកម្មសម្រាប់ការតភ្ជាប់ប្រភពបង្កើតថាមពលពន្លឺព្រះអាទិត្យ (PV) ជាមួយនឹងខ្សែបណ្តាញអគ្គិសនីជាតិ។ យោងតាមបទប្បញ្ញត្តិនេះ បច្ចុប្បន្ន អ្នកប្រើប្រាស់ម្នាក់ៗអាចដំឡើងប្រព័ន្ធសូឡា ដោយមិនមានការរឹតត្បិតណាមួយឡើយដរាបណាប្រព័ន្ធនោះមិនតម្រូវឱ្យមានការតភ្ជាប់ជាមួយនឹងខ្សែបណ្តាញអគ្គិសនីជាតិ។ មានតែអ្នកប្រើប្រាស់ថាមពលធំ (កម្លាំងតង់ស្យុងលើសពី ៣៨០ វ៉ុលរហូតដល់ ២២.០០០ វ៉ុល) និងធំជាងនេះ (កម្លាំងតង់ស្យុងចាប់ពី ២២.០០០ វ៉ុលឡើងទៅ) ប៉ុណ្ណោះ ដែលអាចស្នើសុំការអនុញ្ញាតដើម្បីតភ្ជាប់ប្រព័ន្ធសូឡារបស់ខ្លួនជាមួយនឹងខ្សែបណ្តាញអគ្គិសនីជាតិដែលនឹងត្រូវគិតថ្លៃតាមតារាងតម្លៃ លក្ខណៈបច្ចេកទេស និងលក្ខខណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ។*

*បទប្បញ្ញត្តិថ្មីទាំងនេះ ទទួលបានការស្វាគមន៍យ៉ាងទូលំទូលាយពីវិស័យនេះ ហើយក៏ត្រូវបានរំពឹងថា នឹងក្លាយជាកត្តាជំរុញដ៏ធំក្នុងការពង្រីកការវិនិយោគទៅលើការអភិវឌ្ឍថាមពលពន្លឺព្រះអាទិត្យ ជាលក្ខណៈទ្រង់ទ្រាយធំនៅទូទាំងប្រទេសកម្ពុជា។ ជាការពិតណាស់ ទោះបីនេះជាការសន្យា និងបានបញ្ជាក់ច្បាស់លាស់ដែលមានភាពចាំបាច់ខ្លាំង ចំពោះវិស័យថាមពលកកើតឡើងវិញក៏ដោយ ក៏សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា បន្តស្នើសុំឱ្យរាជរដ្ឋាភិបាលអនុវត្ត វិធានការលើកទឹកចិត្តសម្រាប់ការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យដោយការដំឡើងបន្ទះសូឡានៅលើដំបូល ដើម្បីលើកទឹកចិត្តឱ្យមានការប្រើប្រាស់យ៉ាងទូលំទូលាយនូវផលិតកម្មថាមពលកកើតឡើងវិញនៅក្នុងប្រទេសកម្ពុជា។*

---

**ពិពណ៌នាបញ្ហា**

*ថាមពលពន្លឺព្រះអាទិត្យ គឺជាប្រភពថាមពលមួយដែលបំពេញបន្ថែម ដល់ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់ប្រភពថាមពលដែលអាចជឿទុកចិត្តបានដល់ប្រជាពលរដ្ឋរបស់ខ្លួនប្រើប្រាស់ ការលើកកម្ពស់ការអភិវឌ្ឍថាមពលប្រកបដោយចីរភាព និងការផ្លាស់ប្តូរអន្តរកាលទៅជាប្រទេសមានឯករាជ្យភាពផ្នែកថាមពលនាពេលអនាគត។ ផ្ទៃដីរបស់ប្រទេសកម្ពុជាមានកាំរស្មីពន្លឺព្រះអាទិត្យក្នុង កម្រិតមួយខ្ពស់ ដែលជាមធ្យមមានពន្លឺព្រះអាទិត្យប្រមាណ ៦ ម៉ោងពេញក្នុងមួយថ្ងៃ ដែលនេះគឺជាកត្តាអំណោយផលល្អសម្រាប់ប្រែក្លាយថាមពលពន្លឺព្រះអាទិត្យទៅជាដំណោះស្រាយបច្ចេកទេសវិទ្យា និងពាណិជ្ជកម្មដើម្បីបំពេញតម្រូវការមួយភាគធំក្នុងប្រទេសនេះ។ ថាមពលពន្លឺព្រះអាទិត្យក៏អាចជួយរាជរដ្ឋាភិបាលឱ្យសម្រេចបាននូវគោលដៅក្នុងការកាត់បន្ថយការបំភាយឧស្ម័នកាបូនិក ($CO_2$) ផងដែរ ហើយការប្តេជ្ញាចិត្ត ក្នុងការសម្រេចនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពយ៉ាងទូលំទូលាយ។*

គម្រោងអភិវឌ្ឍន៍ថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជានាពេលបច្ចុប្បន្នកំពុងមានតម្រូវការយ៉ាងខ្លាំង ជាពិសេស កសិដ្ឋានពន្លឺព្រះអាទិត្យខ្នាតតូច បន្ទាប់ពីការអនុវត្តសាកល្បងបានជោគជ័យនៃកសិដ្ឋានពន្លឺព្រះអាទិត្យខ្នាតធំដំបូងរបស់កម្ពុជានៅទីក្រុងបាវិតនៅក្នុងឆ្នាំ២០១៧។ គម្រោងនេះត្រូវបានពង្រីងបន្ថែម ដោយការអនុម័តបទប្បញ្ញត្តិស្តីពីលក្ខខណ្ឌទូទៅសម្រាប់ការតភ្ជាប់ប្រភពផ្តល់ថាមពលពន្លឺព្រះអាទិត្យ PV ជាមួយនឹងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីរបស់ខ្សែបណ្តាញជាតិពីអាជ្ញាធរអគ្គិសនីកម្ពុជា (EAC) នៅខែមករា ឆ្នាំ២០១៨។ លក្ខខណ្ឌទាំងនេះមានអំណោយផលដល់ប្រយោជន៍របស់វិនិយោគិន និងដៃគូអភិវឌ្ឍន៍ពហុភាគីមានកំណើនខ្លាំង ហើយបច្ចុប្បន្ននេះមានគម្រោងពន្លឺព្រះអាទិត្យខ្នាតតូចដែលរឹងមាំនៅក្នុងដំណាក់កាលនៃការរៀបចំផែនការ និងការបង្កើតនៅក្នុងខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង និងរាជធានីភ្នំពេញ។

បច្ចុប្បន្ន រាជរដ្ឋាភិបាលកំពុងផ្តល់ការគាំទ្រដល់គម្រោងទាំងនេះមួយចំនួន ដោយសារតែរាជរដ្ឋាភិបាលបានទទួលស្គាល់ថា ភាពទាក់ទាញនៃវិស័យថាមពលពន្លឺព្រះអាទិត្យគឺជាមធ្យោបាយដើម្បីធ្វើពិពិធកម្មធនធានផលិតថាមពលរបស់ប្រទេសកម្ពុជា និងជួយកាត់បន្ថយថ្លៃចំណាយលើការផលិតអគ្គិសនី និងការកាត់បន្ថយដានកាបូនរបស់កម្ពុជា។ ទោះបីដំណើរការនេះទទួលបានការស្វាគមន៍ក្នុងកម្រិតមួយយ៉ាងល្អប្រសើរ និងបង្ហាញពីសមិទ្ធលទ្ធភាពសេដ្ឋកិច្ចនៃគម្រោងពន្លឺព្រះអាទិត្យខ្នាតតូចនៅកម្ពុជាក៏ដោយ ក៏ការគាំទ្រដល់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ នៅលើដំបូលក្នុងវិស័យពាណិជ្ជកម្ម និងសំណង់អគារស្នាក់នៅមានកម្រិតខ្លាំងនៅឡើយ។

តម្រូវការថាមពលរបស់កម្ពុជា ត្រូវបានព្យាករណ៍ថានឹងបន្តកើនឡើងគួរឱ្យកត់សម្គាល់ ហើយទោះបីជាកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយតម្លៃអគ្គិសនីរបស់រាជរដ្ឋាភិបាលទទួលបានការកោតសរសើរច្រើនក៏ដោយ ក៏ថ្លៃចំណាយខ្ពស់លើអគ្គិសនីជារឿយៗ ត្រូវបានវិស័យឯកជនចាត់ទុកថាជាឧបសគ្គដ៏ធំមួយចំពោះការបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។ ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូល គឺជាដំណោះស្រាយដ៏សំខាន់ដើម្បីធានាការផ្គត់ផ្គង់អគ្គិសនីមានស្ថិរភាព និងជួយកាត់បន្ថយថ្លៃចំណាយរបស់ក្រុមហ៊ុនធុរកិច្ច ដោយសារតែប្រព័ន្ធនោះពិតជាមានភាពស័ក្តិសមខ្លាំងណាស់សម្រាប់តម្រូវការថាមពលរបស់វិស័យពាណិជ្ជកម្ម និងឧស្សាហកម្ម ដូចជា ផលិតកម្មនៅក្នុងវិស័យកាត់ដេរ ដែលជារឿយៗ ម៉ោងដែលវិស័យទាំងនេះត្រូវការប្រើអគ្គិសនីខ្ពស់ខ្លាំងគឺស្របពេលនឹងម៉ោងដែលមានពន្លឺព្រះអាទិត្យច្រើនផងដែរ។

ទោះជាយ៉ាងណាក៏ដោយ ដោយសារតែការវិនិយោគនៅក្នុងវិស័យនេះចាំបាច់ត្រូវតែចំណាយខ្ពស់ខ្លាំងសមហេតុផលនៅពេលចាប់ផ្តើមដំបូងទៅលើប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យនេះ ទើបក្រុមហ៊ុនធុរកិច្ចធ្វើការពិចារណាថាខ្លួនអាចវិនិយោគលើវិស័យនេះទៅបាន លុះត្រាតែខ្លួនអាចរំពឹងថានឹងទទួលបានផលចំណេញពីការវិនិយោគនោះក្នុងរយៈពេលមួយមានកំណត់តែប៉ុណ្ណោះ។ បន្ថែមពីនេះទៅទៀត ដោយសារតែប្រភពថាមពលពន្លឺព្រះអាទិត្យមិនទាន់អាចជំនួសប្រភពថាមពលបែបបុរាណបានទាំងស្រុងនៅឡើយ ដែលនៅតែត្រូវការជាចាំបាច់ដើម្បីផ្តល់ថាមពលបន្ទុកគោលដោយសារតែកត្តាលក្ខខណ្ឌអាកាសធាតុដែលមិនអាចព្យាករណ៍ទុកបាន ទើបក្រុមហ៊ុនធុរកិច្ចដែលមានបំណងប្រើថាមពលពន្លឺព្រះអាទិត្យនៅតែត្រូវការតភ្ជាប់ជាមួយខ្សែបណ្តាញជាតិដដែល។

*ទោះបីជាបច្ចុប្បន្ន ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យខ្នាតធំ អាចតភ្ជាប់ជាមួយបណ្តាញជាតិ ដោយស្របតាមបទប្បញ្ញត្តិរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក៏ដោយ ក៏ការដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យអាចប្រើសម្រាប់តែការផ្គត់ផ្គង់ឱ្យខ្លួនឯងតែប៉ុណ្ណោះ ហើយអគ្គិសនីដែលបានផលិតពីប្រព័ន្ធពន្លឺព្រះអាទិត្យដែលលើសតម្រូវការ មិនអាចផ្តល់ឱ្យខ្សែបណ្តាញជាតិឡើយ។ ដោយសារតែខ្សែបណ្តាញជាតិ មិនទទួលបានផលពីការផ្គត់ផ្គង់លើសតម្រូវការនេះ អាជ្ញាធរអគ្គិសនីកម្ពុជា បានកំណត់តារាងតម្លៃពិសេសរួមមាន ការគិតតម្លៃលើការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ និងបរិមាណសម្រាប់ប្រព័ន្ធដែលតភ្ជាប់ជាមួយខ្សែបណ្តាញជាតិ។ ការធ្វើបែបនេះគឺដើម្បីធានាថាការវិនិយោគមានស្រាប់របស់រាជរដ្ឋាភិបាលទៅលើរោងចក្រដើរដោយថាមពលវារីអគ្គិសនី និងធ្យូងថ្មនឹងមិនលើសតម្រូវការ ប្រសិនបើអ្នកប្រើប្រាស់ថាមពលច្រើននឹងប្តូរទៅប្រើថាមពលពន្លឺព្រះអាទិត្យនោះ។*

*យើងទទួលស្គាល់ថា រាជរដ្ឋាភិបាលមានភាពចាំបាច់ក្នុងការរក្សាតុល្យភាពចំណុចអាទិភាពរបស់ខ្លួនក្នុងការស្វែងរកដំណោះស្រាយថាមពលដែលមានចំណាយទាបបំផុត ហើយទន្ទឹមនឹងនោះក៏ត្រូវការពារទ្រព្យសម្បត្តិដែលមានស្រាប់ផងដែរ។ ទោះបីយ៉ាងណាក៏ដោយ បទប្បញ្ញត្តិថ្មីទាំងនេះបានគិតពន្ធយ៉ាងមានប្រសិទ្ធភាពលើការប្រើថាមពលពន្លឺព្រះអាទិត្យ និងមិនបានផ្តល់យន្តការឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា សម្រាប់ប្រើប្រាស់អគ្គិសនីថាមពលពន្លឺព្រះអាទិត្យ ដែលលើសនេះជាប្រយោជន៍ ឬផ្តល់ការប៉ះប៉ូវសងដល់ម្ចាស់ប្រព័ន្ធសម្រាប់ការប្រើនេះឡើយ។ ដូច្នេះ កត្តាសន្សំសំចៃផ្នែកសេដ្ឋកិច្ច នៃការប្រើថាមពលពន្លឺព្រះអាទិត្យលើដំបូល សម្រាប់ការប្រើប្រាស់នៅក្នុងវិស័យពាណិជ្ជកម្ម និងឧស្សាហកម្ម ត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់ ពីព្រោះ ក្រុមហ៊ុនធុរកិច្ចនឹងមានការលំបាកខ្លាំងក្នុងទទួលបានផលរបរពីការវិនិយោគរបស់ខ្លួននៅក្នុងរយៈពេលសមស្របណាមួយជាក់ជាមិនខាន។*

## ផលប៉ះពាល់លើកម្ពុជា

*យើងសូមគូសបញ្ជាក់ថាថាមពលពន្លឺព្រះអាទិត្យគឺជាប្រភពថាមពលជួយបំពេញបន្ថែម ពោលគឺមិនមែនជាប្រភពថាមពលដែលមានភាពប្រកួតប្រជែងដោយផ្ទាល់ជាមួយនឹងប្រភពថាមពលផ្សេងទៀតដែលកម្ពុជាកំពុងធ្វើការវិនិយោគនោះទេ។ ជាការពិតណាស់ ថាមពលពន្លឺព្រះអាទិត្យដែលមានតួនាទីយ៉ាងធំធេងនៅក្នុងចំណោមប្រភពថាមពលចម្រុះរបស់ប្រទេសកម្ពុជា នឹងផ្តល់ឧត្តមប្រយោជន៍យ៉ាងច្រើនដល់ហេដ្ឋារចនាសម្ព័ន្ធថាមពលរបស់ប្រទេសកម្ពុជា៖*

- *កម្ពុជានៅតែមានការពឹងផ្អែកខ្លាំងនៅឡើយទៅលើការនាំចូលអគ្គិសនីពីប្រទេសជិតខាង ដើម្បីបំពេញតម្រូវការរបស់ខ្លួន។ ការកើនឡើងសមាមាត្រ នៃការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យក្នុងប្រទេសកម្ពុជា នឹងជួយកាត់បន្ថយតម្រូវការនាំចូលអគ្គិសនីពីក្រៅប្រទេស។*

- *នៅក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ គេសង្កេតឃើញមានការវិនិយោគខ្លាំងទៅលើគម្រោងវារីអគ្គិសនី ខ្នាតធំជាច្រើន ក្នុងប្រទេសកម្ពុជា។ គម្រោងទាំងនេះមានផលិតភាពតិចណាស់ក្នុងរដូវក្តៅរដូវប្រាំង ស្របពេលដែល ប្រភពថាមពលពន្លឺព្រះអាទិត្យកំពុងមានផលិតភាពខ្ពស់បំផុត។*

- *ប្រភពថាមពលពន្លឺព្រះអាទិត្យ មានផលិតភាពខ្ពស់នៅពេលថ្ងៃ ដែលចំពេលដែលអគ្គិសនីតាមខ្សែបណ្ដាញជាតិកំពុងមានតម្រូវការខ្ពស់ខ្លាំង។ កត្តានេះបាន ធ្វើឱ្យការផលិតអគ្គិសនីនៅពេលថ្ងៃក៏មានតម្លៃខ្ពស់ដែរ ហេតុដូច្នេះ ប្រភពថាមពលពន្លឺព្រះអាទិត្យនឹងក្លាយជាជម្រើសជំនួសគួរឱ្យទាក់ទាញមួយក្នុងការកាត់បន្ថយតម្រូវការបន្ទុកម៉ាស៊ីនខ្ពស់ដើម្បីផលិតអគ្គិសនីសម្រាប់បំពេញសេចក្ដីត្រូវការនេះ។*

*ដើម្បីឱ្យគម្រោងផលិតប្រភពថាមពលកកើតឡើងវិញ ដ៏សំខាន់នេះមានភាពជោគជ័យនៅក្នុងប្រទេសកម្ពុជា វិស័យនេះក៏ចាំបាច់ត្រូវមានចីរភាពផ្នែកសេដ្ឋកិច្ចផងដែរ។ ការណ៍នេះអាចសម្រេចបានតាមរយៈគោលនយោបាយគាំទ្ររបស់រដ្ឋាភិបាលចំពោះថាមពលពន្លឺព្រះអាទិត្យ សម្រាប់ទាំងផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់។ យើងខ្ញុំជឿជាក់ថារាជរដ្ឋាភិបាលនឹងទទួលបានគុណប្រយោជន៍ក្នុងការធ្វើការងារជាមួយនឹងវិស័យឯកជនដើម្បីបង្កើតឱ្យមានបរិយាកាសប្រកួតប្រជែងដោយយុត្តិធម៌រវាងដំណោះស្រាយប្រភពថាមពលពន្លឺព្រះអាទិត្យ និងប្រភពថាមពលផ្សេងទៀត។ ដំណើរការនេះ នឹងជួយគាំទ្រដល់ការអភិវឌ្ឍថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជា ដែលជាផ្នែកមួយនៃគម្រោងទូលំទូលាយ ក្នុងការធានានូវប្រភពថាមពលចម្រុះសមស្រប ដើម្បីផ្ដល់បំពេញកំណើនតម្រូវការ របស់ប្រទេសកម្ពុជា និងបង្កើតឱ្យមានប្រភពថាមពលដែលអាចជឿទុកចិត្តបានសម្រាប់ប្រជាជននៅទូទាំងប្រទេស។*

✓ សូមស្នើឱ្យផ្ដល់ការធានាថា ការលើកទឹកចិត្តដល់ការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ ដែលមាននៅក្នុងសេចក្ដីព្រាងលើកទី១១ នៃក្រុមបរិស្ថាន និងធនធានធម្មជាតិកម្ពុជា នៅតែរក្សាទុក នៅក្នុងសេចក្ដីព្រាងស្ថាពរ។

**អនុសាសន៍ឆ្នាំ ២០១៩**

*យើងខ្ញុំសូមគោរពផ្ដល់ជូននូវអនុសាសន៍ ដោយស្នើឱ្យរាជរដ្ឋាភិបាលផ្ដល់ការធានាថានៅការអនុម័តចុងក្រោយនៃក្រុមបរិស្ថាន និងធនធានធម្មជាតិកម្ពុជា នឹងរក្សាទុកបញ្ញត្តិលើកទឹកចិត្តឱ្យប្រើថាមពលពន្លឺព្រះអាទិត្យរួមទាំងលក្ខខណ្ឌតម្រូវក្នុងការបង្កើតបទប្បញ្ញត្តិលើយន្តការទូទាត់ថាមពលអគ្គិសនីពន្លឺព្រះអាទិត្យនៅសល់ ការកាត់បន្ថយពន្ធលើប្រាក់ចំណេញ និងការសាកល្បងមួយឆ្នាំសម្រាប់កម្មវិធីផ្ទេរថាមពលចូលខ្សែបណ្ដាញជាតិ* (feed-in-tariff scheme)។ *ការធ្វើបែបនេះនឹងជួយដោះស្រាយបញ្ហាលទ្ធភាពទិញប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យនៅលើដំបូល ហើយនឹងជួយដល់វិស័យថាមពលពន្លឺព្រះអាទិត្យឱ្យមានការប្រកួតប្រជែងបែបសេដ្ឋកិច្ចចំពោះទម្រង់ផលិតកម្មថាមពលមិនមានចីរភាព។*

តាមរយៈការអនុវត្តគោលនយោបាយគាំទ្រការប្រកួតប្រជែងរបស់ថាមពលពន្លឺព្រះអាទិត្យ រាជរដ្ឋាភិបាលនឹងពង្រឹងបន្ថែមទៀតទៅលើការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការអនុវត្តផែនការសកម្មភាពអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការផ្នែកថាមពល (APAEC) ឆ្នាំ២០១៦-២០២៥ ដែលបានកំណត់គោលដៅសម្រេចឱ្យបាន ២៣% នៃការប្រើប្រាស់ថាមពលកកើតឡើងវិញ ក្នុងចំណោមប្រភពថាមពលចម្រុះបឋមឱ្យបាននៅត្រឹមឆ្នាំ២០២៥។ ស្រដៀងគ្នានេះដែរ ការលើកទឹកចិត្តទាំងនេះ បន្សុីការអនុវត្តរបស់កម្ពុជាឱ្យស្របជាមួយនឹងសមាជិកអាស៊ានផ្សេងទៀតដែរ ដូចជា ប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន និងថៃ ដែលប្រទេសទាំងអស់នេះបានដាក់ឱ្យប្រើប្រាស់កម្មវិធីផ្ទេរថាមពលចូលខ្សែបណ្តាញជាតិ និងបានក្លាយជាប្រទេសកំពូលសម្រាប់ការវិនិយោគលើការដំឡើងប្រព័ន្ធថាមពលកកើតឡើងវិញ។

៤០

# ការប្រកួតប្រជែងមានកម្រិតនៅក្នុងចំណោមក្រុមហ៊ុនប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**រក្សាទុកដដែល**

---

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើសុំឱ្យផ្ដល់ការធានា នឹងមិនមានការដាក់បញ្ចូលលក្ខខណ្ឌតម្រូវសញ្ជាតិសម្រាប់ក្រុមហ៊ុនប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅក្នុងសេចក្ដីព្រាងស្ថាពររបស់ក្រមបរិស្ថាន និងធនធានធម្មជាតិកម្ពុជា ឬនៅក្នុងលិខិតូបករណ៍នានាដែលនឹងចេញក្រោយក្រមនេះ ហើយសូមស្នើឱ្យធ្វើការពិចារណាលើពាក្យសុំការទទួលស្គាល់ផ្លូវការដោយផ្អែកលើសមត្ថភាពជាក់ស្ដែងរបស់ក្រុមហ៊ុនដែលបានដាក់ពាក្យស្នើសុំ។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*នៅខែមករា ឆ្នាំ២០១៨ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាបានរៀបចំពិធីពិសារអាហារថ្ងៃត្រង់កម្រិតខ្ពស់ជាមួយនឹងឯកឧត្តម បណ្ឌិត សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដែលនាពិធីនេះអ្នកចូលរួមបានទទួលទស្សនៈជុំដំបូងទៅលើគោលនយោបាយ និងរបៀបវារៈអំពីកំណែទម្រង់របស់ឯកឧត្តមរដ្ឋមន្ត្រីសម្រាប់វិស័យបរិស្ថាននៅកម្ពុជាដែលនឹងអនុម័តនាពេលខាងមុខៗ នៅក្នុងពិធីនោះ អ្នកចូលរួមក៏បានលើកសំណួរមួយទៅកាន់ឯកឧត្តមរដ្ឋមន្ត្រីអំពីដំណើរការដាក់ពាក្យសុំការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) និងថាតើមានគោលនយោបាយដើម្បីបង្កើនចំនួនក្រុមហ៊ុនដែលអាចផ្ដល់សេវាប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានបន្ថែមទៀតដែរឬទេ។*

*ជាការឆ្លើយតប ឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់ថា ក្រសួងចង់ឱ្យមានក្រុមហ៊ុនច្រើនផ្ដល់សេវាទាំងនេះ ទោះបីជាដំណើរការផ្ដល់អាជ្ញាប័ណ្ណសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានលក្ខណៈហ្មត់ចត់ និងតម្រូវឱ្យមានការត្រួតពិនិត្យឡើងវិញដើម្បីធានាថាក្រុមហ៊ុនទាំងនោះអាចបន្តផ្ដល់សេវាចាំបាច់ទាំងនេះបានត្រឹមត្រូវទៀតឬយ៉ាងណាក៏ដោយ។ ជាលទ្ធផលនៃការត្រួតពិនិត្យឡើងវិញទាំងនេះ ក្រសួងកំពុងរៀបចំដំណើរការដែលអាចលុបចោលអាជ្ញាប័ណ្ណមានស្រាប់មួយចំនួនដោយ សារតែក្រុមហ៊ុនទាំងនោះត្រូវបានរកឃើញថាមិនបានបំពេញទំនួលខុសត្រូវរបស់ខ្លួនបានត្រឹមត្រូវឡើយ។ ចំណែកឯលក្ខខណ្ឌតម្រូវសញ្ជាតិកម្ពុជាវិញ ឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់ថា ក្នុងរយៈពេលវែង អាចមានការសម្រួលលើការរឹតបន្តឹងនេះ ដោយសារតែការប្ដេជ្ញាចិត្តរបស់កម្ពុជា ទៅលើអង្គការពាណិជ្ជកម្មពិភពលោក ប៉ុន្តែនៅដំណាក់កាលនេះ មិនមានផែនការធ្វើដូច្នេះនៅឡើយនោះទេ។ ផ្ទុយទៅវិញ ឯកឧត្តមរដ្ឋមន្ត្រី បានផ្ដល់យោបល់ឱ្យក្រុមហ៊ុនបរទេស ដែលមានបំណងផ្ដល់សេវាប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា គួរបង្កើតភាពជាដៃគូជាមួយនឹងក្រុមហ៊ុនកម្ពុជា។*

*សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា បានស្វាគមន៍ចំពោះការឆ្លើយតបដោយផ្ទាល់ពីឯកឧត្តមរដ្ឋមន្ត្រីអំពីបញ្ហានេះ ហើយជាថ្មីម្ដងទៀត សូមថ្លែងអំណរគុណដល់ក្រសួងបរិស្ថានដែលចូលរួមគាំទ្រកន្លងមក។ ទោះបីយ៉ាងណាក៏ដោយ យើងខ្ញុំនឹងបន្តលើកទឹកចិត្តឱ្យរដ្ឋាភិបាលកម្ពុជាធ្វើការពិចារណាដកលក្ខខណ្ឌតម្រូវសញ្ជាតិចេញពីក្រមបរិស្ថាន និងធនធានធម្មជាតិកម្ពុជា។*

---

## ពិពណ៌នាបញ្ហា

*សេចក្តីព្រាងថ្មីនៃក្រមបរិស្ថាន និងធនធានធម្មជាតិកម្ពុជាបន្តរក្សាបញ្ញត្តិដែលបានចែងថាពាល់គម្រោងអភិវឌ្ឍន៍ថ្មីទាំងអស់ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន* (EIA) *តាមរយៈក្រុមហ៊ុនដែលមានការទទួលស្គាល់ដែលត្រូវតែមានសញ្ជាតិខ្មែរ។ ទោះបីជាសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាបានយល់ដឹងអំពីករណីលើកលែងមានកម្រិតខ្លះចំពោះករណីនេះ ដែលក្រុមហ៊ុនបរទេសអាចបង្កើតភាពជាដៃគូជាមួយនឹងក្រុមហ៊ុនកម្ពុជាដើម្បីស្នើសុំអាជ្ញាប័ណ្ណផ្តល់សេវាប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានក៏ដោយ ប៉ុន្តែជម្រើសធ្វើបែបនេះមិនមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយឡើយ ហើយក្រុមហ៊ុនបរទេសជាច្រើននៅតែមិនត្រូវបានរាប់បញ្ចូល។*

*យោងតាមការប្តេជ្ញាចិត្តរបស់កម្ពុជា នៅក្នុងអនុវត្តតាមគោលការណ៍ណែនាំរបស់អង្គការពាណិជ្ជកម្មពិភពលោក* (WTO) *ប្រទេសកម្ពុជាបានអនុញ្ញាតឱ្យក្រុមហ៊ុនសេវាប្រឹក្សាបរិស្ថានបរទេស ផ្តល់សេវាប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ទាំងតាមរយៈការផ្តល់សេវាឆ្លងប្រទេស និងការបង្កើតក្រុមហ៊ុនក្នុងស្រុក* (CPC 9409)*។ ឯកសារនេះ មិនមានការរឹតត្បិត ឬលក្ខខណ្ឌតម្រូវបទប្បញ្ញត្តិបន្ថែមណាមួយសម្រាប់ការផ្តល់សេវាវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជាឡើយ។ លើសពីនេះទៅទៀត "មាត្រាអំពីសញ្ជាតិ" នឹងធ្វើឱ្យមានការរឹតត្បិតលើការប្រកួតប្រជែង រវាងក្រុមហ៊ុនប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាននានាតាមរយៈការរឹតត្បិតការចូលក្នុងទីផ្សារ។ ការប្រកួតប្រជែងមានកម្រិតនេះនឹងធ្វើឱ្យតម្លៃសេវាកើតឡើង និងមិនមានការលើកទឹកចិត្តឱ្យមានការពង្រឹងគុណភាពសេវាឡើយ។*

## ផលប៉ះពាល់លើកម្ពុជា

*ដោយយោងតាមការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការអនុវត្តគោលការណ៍ណែនាំរបស់អង្គការពាណិជ្ជកម្មពិភពលោក មាត្រាដែលរឹតត្បិតដោយអនុញ្ញាតឱ្យតែក្រុមហ៊ុនដែលមានសញ្ជាតិខ្មែរផ្តល់សេវាប្រឹក្សាវាយតម្លៃបរិស្ថាន ប្រសិនបើត្រូវអនុម័តជាច្បាប់មែននោះ នឹងធ្វើឱ្យក្រុមហ៊ុនមានចម្ងល់ខ្លាំងចំពោះការគោរពតាមការប្តេជ្ញាចិត្តជាអន្តរជាតិរបស់កម្ពុជាជាក់ជាមិនខាន។ ចុងក្រោយ បញ្ហានេះអាចធ្វើឱ្យប៉ះពាល់កេរ្តិ៍ឈ្មោះរបស់កម្ពុជាក្នុងនាមជាដៃគូពាណិជ្ជកម្មអន្តរជាតិ និងអាចជាកត្តាមិនលើកទឹកចិត្តដល់ការធ្វើពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជាទៀតផង។*

*លើសពីនេះទៅទៀត បញ្ហានេះអាចបង្កើតឱ្យមានថ្លៃចំណាយបន្ថែម និងបន្ទុករដ្ឋបាលសម្រាប់វិនិយោគិន ព្រមទាំងមានផលប៉ះពាល់អវិជ្ជមាន ដល់សមត្ថភាពប្រកួតប្រជែង និងភាពទាក់ទាញរបស់កម្ពុជាក្នុងនាមជាប្រទេសគោលដៅសម្រាប់ការវិនិយោគផងដែរ។ សមាជិកជាច្រើនរបស់យើងខ្ញុំត្រូវការជាចាំបាច់នូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលផ្តល់សេវាដោយក្រុមហ៊ុនប្រឹក្សាបរទេស ដែលជាលក្ខខណ្ឌកំណត់ដោយនីតិវិធីត្រួតពិនិត្យផ្ទៃក្នុងផ្ទាល់របស់ខ្លួន។ សម្រាប់ក្រុមហ៊ុនទាំងនេះ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានស្របច្បាប់ដោយក្រុមហ៊ុនប្រឹក្សាមានការទទួលស្គាល់នៅកម្ពុជា គឺជាបន្ទុកចំណាយបន្ថែម ហើយគុណតម្លៃបន្ថែមមានតិចតួច។ ផ្ទុយទៅវិញ ការដកចេញនូវមាត្រាអំពីសញ្ជាតិចេញនឹងមានផលវិជ្ជមានដល់ទីផ្សារសេវាប្រឹក្សា ដោយសារតែក្រុមហ៊ុននានាចាំបាច់ត្រូវតែកម្ពស់គុណភាពសេវារបស់ខ្លួន និងកំណត់តម្លៃសេវា មានលក្ខណៈប្រកួតប្រជែងខ្ពស់ បើមិនដូច្នោះទេ អាចប្រឈមនឹងហានិភ័យបាត់បង់អតិថិជន ទៅក្រុមហ៊ុនប្រកួតប្រជែងដែលមានគុណភាពសេវាល្អប្រសើរជាងជាក់ជាមិនខាន។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យផ្តល់ការធានាថា លក្ខខណ្ឌតម្រូវសញ្ជាតិ សម្រាប់ក្រុមហ៊ុនប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នឹងមិនដាក់បញ្ចូលនៅក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិកម្ពុជាស្ថាពរឡើយ។

*យើងខ្ញុំសូមគោរពផ្តល់ជូនអនុសាសន៍ ដោយស្នើឱ្យរាជរដ្ឋាភិបាលផ្តល់ការធានាថា លក្ខខណ្ឌតម្រូវសញ្ជាតិសម្រាប់ក្រុមហ៊ុនប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានមិនដាក់បញ្ចូលនៅក្នុងសំណៅក្រមបរិស្ថាន និងធនធានធម្មជាតិកម្ពុជាស្ថាពរឡើយ ដូចដែលបានផ្ញើនៅក្នុងសេចក្តីព្រាងមុនៗ (សេចក្តីព្រាងទី ៦ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៦ និងសេចក្តីព្រាងទី៧ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦)។ បន្ថែមពីនេះទៅទៀត យើងខ្ញុំសូមស្នើឱ្យធ្វើការពិចារណា លើការដាក់ពាក្យសុំទទួលស្គាល់ការប្រឹក្សាវាយតម្លៃ ហេតុប៉ះពាល់បរិស្ថានដោយផ្អែកលើសមត្ថភាពរបស់ក្រុមហ៊ុនដាក់ពាក្យសុំ ដោយសារតែកត្តានេះ នឹងលើកទឹកចិត្តឱ្យមានការដាក់ពាក្យសុំកាន់តែច្រើនពីសំណាក់ក្រុមហ៊ុនប្រឹក្សា និងធានាបាននូវភាពប្រកួតប្រជែងដោយស្មើភាពនៅក្នុងចំណោមក្រុមហ៊ុនផ្តល់សេវាទាំងអស់។*

## ៤១

# ការបង្កើតក្រុមប្រឹក្សាអគារបៃតងឯករាជ្យ

ធ្វើបច្ចុប្បន្នភាព

---

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើឱ្យពិនិត្យមើលអំពីលទ្ធភាពនៃការបង្កើតក្រុមប្រឹក្សាអគារបៃតងកម្ពុជា។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*គណៈកម្មាធិការធុរកិច្ចបៃតងនៃសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា បានចូលរួមយ៉ាងសកម្មជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាដើម្បីស្នើសុំឱ្យមានការបង្កើតក្រុមប្រឹក្សា អគារបៃតងកម្ពុជា។ អង្គភាពឯករាជ្យមួយនេះមានគោលបំណងត្រួតពិនិត្យលើការបង្កើតនិងការអនុវត្តបទដ្ឋាន និងត្រួតពិនិត្យលើក្របខណ្ឌវិញ្ញាបនបត្របញ្ជាក់ ដែលនឹងអាចឱ្យវិស័យសំណង់អគារបៃតងបង្ហាញអនុលោមភាពតាមការអនុវត្តអគារបៃតង។*

*បន្ទាប់ពីបានធ្វើការពិភាក្សាប្រកបដោយផ្លែផ្កា ជាមួយនឹងក្រសួងបរិស្ថាន និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់រួចមក សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាទទួលបានព័ត៌មានថា ក្រុមការងារបច្ចេកទេសផ្នែកទីក្រុងនិរន្តរភាព ត្រូវបានក្រសួងបរិស្ថានកៀរគរដើម្បីរៀបចំកិច្ចប្រជុំពិភាក្សាពាក់ព័ន្ធនឹងការបង្កើតគោលការណ៍ណែនាំស្តីពីអគារបៃតង។ ដោយសារតែគោលបំណងនៃការផ្តួចផ្តើមនេះមានលក្ខណៈស្របគ្នាជាមួយនឹងគោលបំណងរបស់ក្រុមប្រឹក្សា អគារបៃតង សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ទទួលបានការណែនាំឱ្យរៀបចំសិក្ខាសាលាដើម្បីឱ្យភាគីពាក់ព័ន្ធទាំងអស់ ពីវិស័យរដ្ឋ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ចូលរួមពិភាក្សាអំពីការបង្កើតក្រុមប្រឹក្សាអគារបៃតងកម្ពុជា។*

---

**ពិពណ៌នាបញ្ហា**

*បច្ចុប្បន្ននេះ វិស័យសំណង់នៅក្នុងប្រទេសកម្ពុជាកំពុងមានកំណើនយ៉ាងខ្លាំង ហើយអាចរំពឹងទុកថា ការវិនិយោគនេះនឹងមានកាន់តែច្រើនឡើងបន្ថែមទៀតនៅក្នុងវិស័យសំណង់ នៅទសវត្សរ៍ខាងមុខនេះ។ ដោយសារតែកត្តានេះ រាជរដ្ឋាភិបាលចាំបាច់គួរកំណត់ទិសដៅគោលនយោបាយដែលលើកទឹកចិត្តឱ្យមានការអនុវត្តល្អផ្នែកស្ថាបត្យកម្ម និងសំណង់ដើម្បីធានាដល់និរន្តភាពរយៈពេលវែងនៅក្នុងវិស័យសំណង់ និងតំបន់ទីក្រុងនៅក្នុងប្រទេសកម្ពុជា។ជាការពិតណាស់ដែលថាវិស័យនគរូបនីយកម្មនៅក្នុងប្រទេសកម្ពុជានៅមានកម្រិតទាបខ្លាំង បើធៀបទៅនឹងបណ្តាប្រទេសសមាជិកអាស៊ានផ្សេងទៀត ដែលបានផ្តល់ឱកាសជាច្រើនក្នុងការបញ្ចៀសពីបញ្ហានគរូបនីយកម្ម ដែលបានកើតមាននៅក្នុងបណ្តាប្រទេសផ្សេងទៀត ដើម្បីដើរតួនាទីជាអ្នកនាំមុខ និងក្លាយជាប្រទេសគំរូដ៏ល្អនៅក្នុងតំបន់អាស៊ាន និងសហគមន៍អន្តរជាតិ ក្នុងនាមជាប្រទេសដែលមានដំណោះស្រាយអគារប្រកបដោយនិរន្តរភាព។*

*កម្ពុជានៅតែជាប្រទេសសមាជិកអាស៊ានចុងក្រោយគេ ដែលនៅពុំទាន់មានគោលការណ៍ណែនាំ និង បទប្បញ្ញត្តិផ្លូវការស្តីពី អគារ ប្រកបដោយនិរន្តរភាព ហើយចន្លោះប្រហោងផ្នែកច្បាប់នេះនឹងផ្តល់ឱកាសឱ្យមានផលប៉ះពាល់បរិស្ថានបែបអវិជ្ជមានលើកំណើនទីក្រុងយ៉ាងឆាប់រហ័ស។ រាជរដ្ឋាភិបាល ទទួលស្គាល់នូវបញ្ហាប្រឈមនេះ*

ហើយបានចាត់វិធានការដោះស្រាយក្តីកង្វល់ទាំងនេះ តាមរយៈការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាបន្តបន្ទាប់ ស្តីពីបច្ចុប្បន្នភាពនៃក្រុមបរិស្ថាន និងធនធានធម្មជាតិព្រមទាំងបានកៀរគរក្រុមការងារបច្ចេកទេស នៅក្នុងក្រសួងបរិស្ថាន ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលកើតមានឡើងទាំងនេះ រួមទាំងក្រុមការងារបច្ចេកទេសផ្នែកទីក្រុងនិរន្តរភាពផងដែរ។ កត្តានេះ ច្បាស់ណាស់គឺជាការលើកទឹកចិត្តដោយសារ តែមានកិច្ចប្រជុំពិភាក្សាជាច្រើន កំពុងរៀបចំពាក់ព័ន្ធនឹងការបង្កើតគោលការណ៍ណែនាំស្តីពី អគារបៃតង និងមានការបង្ហាញចំណាប់អារម្មណ៍ក្នុងការសហការជាមួយនឹង គណៈកម្មាធិការធុរកិច្ចបៃតងនៃសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ដើម្បីបង្កើតក្រុមប្រឹក្សា អគារបៃតងកម្ពុជា (CGBC) ក្រោមការដឹកនាំរបស់ក្រសួងបរិស្ថាន ។

ទោះបីយ៉ាងណាក៏ដោយ ដោយសារតែអង្គភាពនេះនឹងទទួលខុសត្រូវ លើការបង្កើតក្របខណ្ឌទទួលស្គាល់ សម្រាប់សំណង់អគារប្រកបដោយនិរន្តរភាព និងដើរតួនាទីជាអាជ្ញាធរបែបវិទ្យាសាស្ត្រដើម្បីកំណត់ចំណាត់ថ្នាក់ដោយមិនលម្អៀង និងផ្តល់រង្វាន់ដល់ អគារដោយផ្អែកលើលិខិតបញ្ជាក់សំណង់អគារប្រកបដោយនិរន្តរភាពក្តី ក៏អង្គភាពមួយនេះចាំបាច់ត្រូវបង្កើតឡើងដោយឯករាជ្យដាច់ដោយ ឡែកពីរាជរដ្ឋាភិបាល។ស្រដៀងគ្នានេះដែរ ក្រុមប្រឹក្សាអគារបៃតងនេះចាំបាច់ត្រូវរៀបចំឡើងតាមលក្ខខណ្ឌតម្រូវជាអង្គភាពឯករាជ្យ មិនរកប្រាក់ចំណេញ ដើម្បីអាចក្លាយជាសមាជិកនៃក្រុមប្រឹក្សាអគារបៃតងពិភពលោក (WGBC) ដោយធានាឱ្យបាននូវអនុលោមតាមការអនុវត្តល្អជាអន្តរជាតិប្រកបដោយប្រសិទ្ធភាព។

## ផលប៉ះពាល់លើកម្ពុជា

ឯករាជ្យភាពនៃក្រុមប្រឹក្សា អគារបៃតងកម្ពុជា នឹងធានានូវវិធីសាស្ត្របរិយាបន្នមួយក្នុងការលើកកម្ពស់ឱ្យមានសំណង់អគារប្រកបដោយនិរន្តភាពតាមរយៈការពិចារណាលើធាតុចូលរបស់ភាគីពាក់ព័ន្ធយ៉ាងទូលំទូលាយដែលចាំបាច់ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរទីផ្សារវិស័យសំណង់អគារកាន់តែល្អប្រសើរថែមទៀត។ លើសពីនេះទៀតកម្រិតនៃភាពឯករាជ្យនេះនឹងបង្ហាញអំពីធម្មានុរូបកាន់រឹងមាំនៃអង្គភាពមួយនេះពីព្រោះកត្តានេះនឹងធ្វើឱ្យអង្គភាពនេះមិនមានឱកាសកើតទំនាស់ផលប្រយោជន៍ឬការលម្អៀងនៅពេលចាត់ចំណាត់ថ្នាក់ និងផ្តល់រង្វាន់ដល់សំណង់អគារ។ កត្តានេះនឹងផ្តល់ផលប៉ះពាល់វិជ្ជមាន ដល់បរិយាកាសវិនិយោគនៅក្នុងវិស័យអចលនទ្រព្យ ដោយសារតែវិនិយោគិននឹងទទួលបានការធានាដោយប្រព័ន្ធទទួលស្គាល់ដែលមានឯករាជ្យភាពនេះ។ សំខាន់ជាងនេះទៅទៀត ប្រសិនបើរចនាសម្ព័ន្ធអភិបាលកិច្ចរបស់អង្គភាពនេះមិនឯករាជ្យទេនោះ អង្គភាពនេះនឹងមិនអាចទទួលបានការគាំទ្រជាសកលពីក្រុមប្រឹក្សា អគារបៃតងពិភពលោកឡើយដែលមានអង្គភាពអន្តរជាតិប្រមាណជា ៧០ ជាសមាជិក។ អង្គភាពសមាជិកអន្តរជាតិនេះជួយពង្រឹងដល់ការបង្កើតក្រុមប្រឹក្សា អគារបៃតងថ្មីៗ ដោយធ្វើជាបណ្តាញផ្ទេរចំណេះដឹងដ៏មានតម្លៃ និងដោយផ្តល់ការគាំទ្រដល់ការបង្កើតផែនការធុរកិច្ច អភិបាលកិច្ច និងទីផ្សារ។ កម្រិតនៃការគាំទ្រនេះគឺពិតជាមានតម្លៃថ្លៃខ្លាំងណាស់ ជាពិសេស នៅក្នុងដំណាក់កាលចាប់ផ្តើមដំបូងរបស់អង្គភាពនេះតែម្តង ដោយសារតែការទទួលបាន កិច្ចគាំទ្រពីភាគីពាក់ព័ន្ធគ្រប់គ្រាន់ គឺជាកត្តាជោគជ័យរបស់អង្គភាព។ ស្រដៀងគ្នានេះដែរ ប្រការដែលសំខាន់នោះគឺថា ក្រុមប្រឹក្សា អគារបៃតងកម្ពុជា ទទួលបានសមាជិកភាពក្នុង

*ក្រុមប្រឹក្សា អគារបៃតងពិភពលោក ដើម្បីអាចចូលរួមក្នុងគម្រោងសកល និងភាពជាដៃគូ ដែលនឹងធានាថា អង្គភាពនេះនឹងក្លាយជាអាជ្ញាធរដ៏សំខាន់មួយដែលទទួលបន្ទុកលើសំណង់អគារប្រកបដោយនិរន្តរភាពនៅកម្ពុជា។*

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យធ្វើការពិចារណាគាំទ្រដល់ការបង្កើតក្រុមប្រឹក្សាអគារបៃតងកម្ពុជា ដើម្បីអាចក្លាយជាសមាជិកភាពរបស់ក្រុមប្រឹក្សាអគារបៃតងពិភពលោក។

*សេចក្តីសម្រេចរបស់ក្រសួងបរិស្ថាន ក្នុងការបង្កើតក្រុមការងារបច្ចេកទេសផ្នែកទីក្រុងនិរន្តរភាពទទួលបានការស្វាគមន៍យ៉ាងខ្លាំង ដោយសារតែនេះគឺជាការបង្ហាញថា រាជរដ្ឋាភិបាលមានបំណង លើកកម្ពស់ឱ្យមានសំណង់អគារប្រកបដោយនិរន្តភាព និងមានការទទួលខុសត្រូវ។ ដោយបានឃើញចំណាប់អារម្មណ៍ ពីក្រសួង និងភាគីពាក់ព័ន្ធ ក្នុងការបង្កើតក្រុមប្រឹក្សា អគារបៃតង អាស្រ័យហេតុនេះ យើងខ្ញុំសូមគោរពផ្តល់ជូននូវអនុសាសន៍ដែលស្នើឱ្យ រាជរដ្ឋាភិបាលធ្វើការពិចារណាផ្តល់ការគាំទ្រដល់ការរៀបចំរចនាសម្ព័ន្ធអង្គភាពនេះជាស្ថាប័ន ឯករាជ្យ និងមិនរកប្រាក់ចំណេញ។*

*កត្តានេះនឹងធានាថាអង្គភាពកម្ពុជាមួយនេះនឹងអាចទទួលបាន សិទ្ធិចូលរួមជាមួយនឹងបណ្តាញក្រុមប្រឹក្សាសំណង់អគារបៃតងពិភពលោក និងទទួលបានអត្ថប្រយោជន៍ដូចដែលបានជម្រាបជូនខាងលើ ដោយហេតុថារចនាសម្ព័ន្ធអភិបាលកិច្ចនេះគឺជាលក្ខខណ្ឌតម្រូវមួយ ដើម្បីក្លាយជាសមាជិកភាពរបស់ក្រុមប្រឹក្សា អគារបៃតងពិភពលោក។*

៤២

# ការបង្កើតស្លាកសញ្ញាបរិស្ថាន

ធ្វើបច្ចុប្បន្នភាព

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើឱ្យបង្កើតក្រុមការងារបច្ចេកទេសរវាងស្ថាប័នសាធារណៈ និងផ្នែកឯកជន ដែលផ្តោតលើស្លាកសញ្ញាផលិតផលថាមពលប្រកបដោយប្រសិទ្ធផល។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*នៅក្នុងឆ្នាំ២០១៨ រដ្ឋាភិបាលចិនបានផ្តល់ការគាំទ្រការកសាងសមត្ថភាពដល់ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅក្នុងការបង្កើតស្លាកសញ្ញាអេកូ និងការបង្កើតកម្មវិធីដាក់ស្លាកសញ្ញាបរិស្ថានជាតិនៅកម្ពុជា។ គម្រោងនេះដឹកនាំដោយមជ្ឈមណ្ឌលបញ្ជាក់រួមបរិស្ថានចិន (CEC) និងប្រើប្រាស់បទពិសោធន៍របស់ខ្លួនក្នុងការបង្កើតស្លាកសញ្ញាបរិស្ថានចិន និងការអនុវត្តល្អជាអន្តរជាតិ។ គម្រោងនេះបានបង្កើតរបាយការណ៍ជាតិកម្ពុជាស្តីពីការដាក់ស្លាកសញ្ញាអេកូ ដែលរៀបចំឡើងរួមគ្នាហើយមជ្ឈមណ្ឌល CEC បានផ្តល់ការគាំទ្របច្ចេកទេស និងការបណ្តុះបណ្តាលដល់មន្ត្រីចំនួន ២៥ រូប របស់ក្រសួងបរិស្ថាន ដែលបច្ចុប្បន្នមានភារកិច្ច ក្នុងការបង្កើតកម្មវិធីដាក់ស្លាកសញ្ញាបរិស្ថាននៅកម្ពុជា។ ទោះបីជារបាយការណ៍នេះមិនទាន់បានផ្សព្វផ្សាយជាសាធារណៈក្តី សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា សូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះគំនិតផ្តួចផ្តើមរួមបែបបុរេសកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលចិន ដោយសារតែនេះ គឺជាការបង្ហាញនូវសារៈសំខាន់ នឹងតម្រូវការកាន់តែខ្លាំងឡើង សម្រាប់ការដាក់ ស្លាកសញ្ញាបរិស្ថាននៅកម្ពុជាពីដៃគូអភិវឌ្ឍន៍ជាច្រើន។ យើងសូមលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាលបន្តសកម្មភាពបង្កើតកម្មវិធីដាក់ស្លាកសញ្ញាបរិស្ថានរបស់ខ្លួនតទៅទៀត ហើយអាចនឹងចាប់យកឱកាសគាំទ្រដល់ការងារនេះតាមរយៈការសម្រួលឱ្យមានការចូលរួមពីសំណាក់វិស័យឯកជនផងដែរ។*

### ពិពណ៌នាបញ្ហា

*បច្ចុប្បន្ននេះ ពុំទាន់មានលក្ខខណ្ឌតម្រូវឱ្យផលិតផលដែលកំពុងធ្វើការផ្សព្វផ្សាយទីផ្សារ និងលក់នៅក្នុងប្រទេសកម្ពុជា ត្រូវតែមានស្លាកសញ្ញា ដែលបញ្ជាក់អំពីប្រសិទ្ធផលថាមពល ឬហេតុប៉ះពាល់បរិស្ថាននៅឡើយនោះទេ។ ប៉ុន្តែក្រុមហ៊ុនមួយចំនួនបានស្ម័គ្រចិត្តបង្ហាញព័ត៌មានអំពីកម្រិតប្រសិទ្ធផលថាមពល នៃផលិតផលរបស់ខ្លួនដោយផ្អែកលើក្របខ័ណ្ឌដែលប្រើប្រាស់ នៅក្នុងបណ្តាប្រទេសផ្សេងទៀត ទោះបីជាមានផលិតផលជាច្រើនដែលកំពុងដាក់លក់នៅក្នុងទីផ្សារកម្ពុជាមិនមានបង្ហាញនូវព័ត៌មានទាំងក្តី។ ជាលទ្ធផល អ្នកប្រើប្រាស់មានការលំបាក ក្នុងការបែងចែកភាពខុសគ្នារវាងផលិតផលដែលបានផលិតដោយបានគិតគូរដល់ផលប៉ះពាល់បរិស្ថាន និងផលិតផលដែលមិនមាន ឬមាន ថាមពលប្រកបដោយប្រសិទ្ធផលតិចជាង។ ផលិតផលដែលបានគិតគូរដល់បរិស្ថាន ជារឿយៗ បានប្រើបច្ចេកវិទ្យាទំនើប ឬមានដំណើរការផលិតកម្មចាំបាច់ច្រើនជាង ដែលធ្វើឱ្យតម្លៃលក់ជូនអ្នកប្រើប្រាស់ខ្ពស់ជាងផលិតផលដែលមិនគិតគូរដល់បរិស្ថាន។ ប្រសិនបើផលិតផលណាមួយដែលអតិថិជនចង់ទិញមិនមានព័ត៌មានគ្រប់គ្រាន់អំពីផលប៉ះពាល់បរិស្ថានទេនោះ អ្នកប្រើប្រាស់អាចនឹងមិនបានដឹងអំពីមូលហេតុ ដែលធ្វើឱ្យផលិតផលដែលមិនប៉ះពាល់ដល់បរិស្ថានមានតម្លៃខ្ពស់ជាងផលិតផលប្រកួតប្រជែងដែលប៉ះពាល់ខ្លាំងដល់បរិស្ថាន*

*ឡើយ។ អ្នកប្រើប្រាស់ក៏អាចមិនបានដឹងអំពីការសន្សំសំចៃដែលខ្លួននឹងទទួលបាននៅពេលទិញផលិតផល ថាមពលប្រកបដោយប្រសិទ្ធផល ដែលស៊ីភ្លើងតិចជាងផលិតផលផ្សេងទៀតដែលស៊ីភ្លើងច្រើន។ ក្តីកង្វល់នេះ ក៏កើតមានឡើងស្រដៀងគ្នានៅក្នុងវិស័យពាណិជ្ជកម្ម និងឧស្សាហកម្មផងដែរ ដែលមិនមានលក្ខខណ្ឌតម្រូវឱ្យប្រាប់ដល់អ្នកទិញនូវព័ត៌មានអំពីប្រសិទ្ធផល ឬផលប៉ះពាល់បរិស្ថានរបស់ផលិតផលនីមួយៗ ដូចជា គ្រឿងចក្រធុនធ្ងន់ ឬឧបករណ៍សាងសង់ជាដើម។*

## ផលប៉ះពាល់លើកម្ពុជា

*តាមរយៈការបង្កើតកម្មវិធីកាក់ស្លាកសញ្ញាអេកូ រាជរដ្ឋាភិបាល នឹងដើរតួជាកត្តាជំរុញមួយ នៅពីក្រោយកំណើនសេដ្ឋកិច្ចបៃតងនៅក្នុងប្រទេសកម្ពុជា តាមរយៈការគាំទ្រកិច្ចខិតខំប្រឹងប្រែងបញ្ជ្រាបគោលការណ៍នៃការអនុវត្តបរិស្ថានល្អ និងការបង្កើនទម្រង់នៃការប្រើប្រាស់ និងផលិតកម្មប្រកបដោយចីរភាព។ ប៉ុន្តែ ប្រសិនបើគ្មានកម្មវិធីជំរុញការអនុវត្ត និងការផ្តល់ព័ត៌មានដែលរួមចំណែកដល់ការសម្រេចចិត្តក្នុងការទិញផលិតផលដោយផ្អែកលើហេតុប៉ះពាល់បរិស្ថាននៃផលិតផលទាំងនេះនោះទេ អាកប្បកិរិយារបស់អ្នកប្រើប្រាស់ទំនងជាមិនអាចផ្លាស់ប្តូរ លឿនដូចគ្នាទៅនឹងបណ្តាប្រទេសផ្សេងទៀតដែលមានការដាក់ស្លាកសញ្ញាអេកូបាននោះឡើយ។ ដូច្នេះ ការគាំទ្រឱ្យមានផលិតផលបៃតង និងប្រកបដោយនិរន្តរភាព នឹងស្ថិតនៅក្រោមឥទ្ធិពលទីផ្សារដាក់ជាមិនខាន ដែលមានភាពពិបាក ក្នុងការប្រកួតប្រជែងដោយសារតែកំណើនថ្លៃចំណាយផលិតរបស់ខ្លួន។ កត្តានេះអាចនឹងប៉ះពាល់ដល់សមត្ថភាពប្រកួតប្រជែងនាពេលអនាគត របស់រោងចក្រផលិត និងក្រុមហ៊ុនផ្គត់ផ្គង់នៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងតំបន់អាស៊ាន ដែលសារៈសំខាន់នៃការអនុវត្តផលិតកម្ម និងលទ្ធកម្មបៃតង កំពុងតែមានកំណើនយ៉ាងខ្លាំង។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យផ្តល់អាទិភាពបង្កើតកម្មវិធីជាតិដាក់ស្លាកសញ្ញាបរិស្ថាននៅកម្ពុជា។

*រាជរដ្ឋាភិបាលបានទទួលស្គាល់រួចហើយពីសារៈសំខាន់នៃការដាក់ស្លាកសញ្ញាអេកូ ដូចបានបង្ហាញតាមគម្រោងកសាងសមត្ថភាពរបស់ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយចីរភាពជាមួយនឹងរាជរដ្ឋាភិបាលចិន។ ដូច្នេះ យើងខ្ញុំសូមគោរពផ្តល់ជូនអនុសាសន៍ឱ្យរាជរដ្ឋាភិបាលផ្តល់អាទិភាពលើការបង្កើតកម្មវិធីដាក់ស្លាកសញ្ញាបរិស្ថាននៅកម្ពុជានាពេលបច្ចុប្បន្ន ដើម្បីជួយផ្តល់ព័ត៌មានកាន់តែច្រើនសម្រាប់ការសម្រេចចិត្តទិញរបស់អតិថិជននូវទំនិញមិនប៉ះពាល់ដល់បរិស្ថាន និងដែលមានប្រសិទ្ធផលថាមពលខ្ពស់។ ដើម្បីកសាងការគាំទ្រឱ្យបានទូលំទូលាយនៅ*

ក្នុងរាជរដ្ឋាភិបាល យើងខ្ញុំក៏សូមលើកទឹកចិត្តក្រសួងបរិស្ថានពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់អន្តរក្រសួងជាមួយនឹងក្រសួងឧស្សាហកម្ម និងសិប្បកម្មនៅក្នុងពេលបង្កើតកម្មវិធីនេះ។

បន្ទាប់ពីមានការអនុវត្តដោយភាពជោគជ័យ និងការពង្រីកផលិតផលមានដាក់ស្លាកសញ្ញាមានព័ត៌មានទូលំទូលាយ រាជរដ្ឋាភិបាលអាចចាប់ផ្តើមបង្កើតគោលនយោបាយលទ្ធកម្មសាធារណៈបៃតង ដែលផ្តល់អាទិភាពលើការទិញផលិតផល និងសេវាកម្មដែលចូលរួមចំណែកចំពោះសេដ្ឋកិច្ចបៃតងតាមរយៈការប្រើប្រាស់ និងផលិតកម្មប្រកបដោយចីរភាព។ កត្តានេះនឹងអាចឱ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើជាគំរូ និងគាំទ្រដល់វិស័យឯកជន ដោយពិចារណាទៅលើផលប៉ះពាល់បរិស្ថាន និងការបង្កើនចំណែកទីផ្សារនៃផលិតផលបៃតង ហើយទន្ទឹមនឹងនោះ ក៏បន្ស៊ីការអនុវត្តលទ្ធកម្មសាធារណៈរបស់កម្ពុជាជាមួយនឹងស្តង់ដារអនុវត្តរបស់បណ្តារដ្ឋជាសមាជិកអាស៊ានផ្សេងទៀតផងដែរ។

៤៣

# ការផ្តល់ហិរញ្ញប្បទានសម្រាប់សេដ្ឋកិច្ចបៃតង

ធ្វើបច្ចុប្បន្នភាព

## ពិពណ៌នាបញ្ហា

*តម្លៃខ្ពស់នៃអគ្គិសនី ត្រូវបានគេមើលឃើញថា ជាឧបសគ្គចម្បងក្នុងការលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ជាពិសេស ចំពោះឱកាសបង្កើនសង្វាក់តម្លៃផលិតកម្ម សម្រាប់ដំណើរការអតិផលថាមពលកាន់តែច្រើនថែមទៀត។ ទោះបីរាជរដ្ឋាភិបាលខិតខំប្រឹងប្រែង ក្នុងការដោះស្រាយបញ្ហានេះគួរឱ្យកោតសរសើរ ដែលរួមមានកញ្ចប់ប្រាក់ឧបត្ថម្ភចំនួន ៥០ លានដុល្លារអាមេរិកកាលពីពេលថ្មីៗនេះដើម្បីកាត់បន្ថយតម្លៃអគ្គិសនីយ៉ាងណាក្តី ក៏វិធានការនេះនឹងអាចជាការសម្រាលបណ្តោះអាសន្នតែប៉ុណ្ណោះ ដោយសារចាំបាច់ ត្រូវមានការវិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធ នៃផលិតកម្មថាមពល និងការកែលម្អប្រសិទ្ធភាពដើម្បីឱ្យ ស្របទៅតាមការរីកចម្រើននៃប្រទេសកម្ពុជា។ ដូចគ្នានេះដែរ ប្រទេសកម្ពុជាងាយនឹងរងផលប៉ះពាល់ខ្ពស់ពីការគំរាមកំហែងនៃបញ្ហាបម្រែបម្រួលអាកាសធាតុ ដោយវិស័យសេដ្ឋកិច្ចជាច្រើនមិនបានត្រៀមខ្លួនក្នុងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាពទៅលើផលប៉ះពាល់ដោយសារកំណើនគ្រោះមហន្តរាយធម្មជាតិដែលបានកើតឡើងជារៀងរាល់ឆ្នាំនោះឡើយ។*

*ជាការលើកទឹកចិត្ត ការវិនិយោគលើការផលិតថាមពលកកើតឡើងវិញកំពុងមានការកើនឡើងច្រើននៅក្នុងប្រទេសកម្ពុជា ដោយសារវិនិយោគិនទទួលស្គាល់ពីតម្លៃនៃការវិនិយោគនេះ នៅក្នុងការកាត់បន្ថយថ្លៃអគ្គិសនី និងការសាយភាយឧស្ម័នជា ពិសេស ថាមពលពន្លឺព្រះអាទិត្យ ដែលមានតម្លៃប្រហាក់ប្រហែលទៅនឹងប្រភពថាមពលផ្សេងៗទៀត នៅក្នុងបណ្តាប្រទេសជាច្រើន។ ប៉ុន្តែ ការវិនិយោគទាំងនេះបានផ្តោតច្រើនទៅលើគម្រោងធំៗ ទោះបីបណ្តាញផ្គត់ផ្គង់អគ្គិសនីកម្ពុជានៅមិនទាន់មានលក្ខណៈរួម ដោយបណ្តាញអគ្គិសនីថ្នាក់ជាតិដែលអាចផ្គត់ផ្គង់ទៅដល់គ្រួសារប្រមាណ ៧១.៥ ។ ទោះបីរាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តក្នុងការពង្រីកវិសាលភាពខ្សែបណ្តាញជាតិ និងមានបំណងតភ្ជាប់ខ្សែបណ្តាញជាតិឱ្យបានគ្រប់ ២៤ខេត្តនៅត្រឹមឆ្នាំ២០២០យ៉ាងណាក្តី ក៏ផែនការទាំងនេះជួបប្រទះនូវបញ្ហាប្រឈមកាន់តែខ្លាំង ដោយសារប្រជាជនចំនួន ៧៩% រស់នៅតាមតំបន់ជនបទ1។*

*ស្ថានភាពនេះផ្តល់នូវឱកាសល្អសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម (SME) ក្នុងការដឹកនាំជំរុញសេដ្ឋកិច្ចមានកាបូនទាបទាំងក្នុងការកែលម្អទាំងថាមពលកកើតឡើងវិញ និងប្រសិទ្ធផលថាមពល។ ឧទាហរណ៍ នៅក្នុងតំបន់ជនបទដែលមិនបានតភ្ជាប់ជាមួយខ្សែបណ្តាញជាតិ សហគ្រាសផលិតអគ្គិសនីជនបទឯកជន (REEs) ផលិតនូវថាមពលអគ្គិសនីដោយប្រើប្រាស់ម៉ាស៊ីនភ្លើងម៉ាស៊ូតកម្រិតទាប និងមានតម្លៃថ្លៃតាមរយៈខ្សែបណ្តាញតូចៗ។ គំរូវិមជ្ឈការនេះអាចដើរតួយ៉ាងសំខាន់ក្នុងការធ្វើអន្តរកាលតំបន់ជនបទទៅរកការប្រើប្រាស់ថាមពលកកើតឡើងវិញដោយផ្លាស់ប្តូរម៉ាស៊ីនភ្លើងម៉ាស៊ូតមានស្រាប់ទាំងនេះទៅជាការប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យវិញ ដែលគ្រប់គ្រងដោយសហគ្រាសខ្នាតតូច និងមធ្យម។ ដូចគ្នានេះដែរ ដោយសារគ្រួសារពលរដ្ឋកម្ពុជា និងក្រុមហ៊ុនធុរកិច្ចជាច្រើនពឹងផ្អែកលើឧបករណ៍ប្រើប្រាស់ និងបច្ចេកវិទ្យាចាស់ៗ មិនមានប្រសិទ្ធផល ទើបវិធានការលើកកម្ពស់*

ប្រសិទ្ធផលនៃការប្រើប្រាស់អគ្គិសនីពីឧបករណ៍ និងបច្ចេកវិទ្យាទាំងនោះនឹងជួយបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ ផលិតភាព និងហេតុប៉ះពាល់បរិស្ថាន។

ក្រៅពីឱកាសទាំងនេះ សហគ្រាសខ្នាតតូច និងមធ្យមជាច្រើននៅកម្ពុជា ជួបឧបសគ្គក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីអនុវត្ត ឬពង្រីកការអភិវឌ្ឍន៍កាបូនទាប ដែលឧបសគ្គចម្បងគឺ លទ្ធភាពក្នុងការទទួលបានហិរញ្ញវត្ថុនៅមានកម្រិតនៅឡើយ។ ទោះបីប្រទេសកម្ពុជាមានវិស័យមីក្រូហិរញ្ញវត្ថុល្អប្រសើរ និងមានលក្ខណៈប្រកួតប្រជែងយ៉ាងណាក្តី ក៏មូលធនដែលស្ថាប័នទាំងនោះមាន ជាទូទៅ នៅមានកម្រិតទាបជាងតម្រូវការរបស់សហគ្រាសខ្នាតតូច និងមធ្យមដើម្បីអនុវត្តគម្រោងទាំងនោះនៅឡើយ។ ដូចគ្នានេះដែរ ដើមទុនដែលមានសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមដែលទទួលបានពីគ្រឹះស្ថានហិរញ្ញវត្ថុធម្មតាមានត្រឹមតែផ្នែកនៃសមត្ថភាពផ្តល់កម្ចីពីគ្រឹះស្ថានទាំងនោះប៉ុណ្ណោះ ហើយជាទូទៅ មានតែចំពោះធុរកិច្ចដែលមានដំណើរការល្អប៉ុណ្ណោះ។ ស្ថានភាពនេះអាចបណ្តាលមកពីកត្តាជាច្រើនដែលមានទាំងលើផ្នែកផ្គត់ផ្គង់ និងទាំងតម្រូវការ ដោយរួមទាំងលក្ខខណ្ឌតម្រូវឱ្យមានទ្រព្យបញ្ចាំដែលមិនសមស្របតាមបរិបទ ផលរបរមិនអាចទទួលយកបាន និងរយៈពេលសងតឹងរ៉ឹង ប៉ុន្តែសហគ្រាសខ្នាតតូច និងមធ្យម ជារឿយៗ អាចមានចំណេះដឹងបច្ចេកទេស ឬបទពិសោធន៍ផ្នែកពាណិជ្ជកម្ម នៅមានកម្រិតនៅឡើយ ជាពិសេស ពាក់ព័ន្ធនឹងការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ។

ជាចុងក្រោយ លក្ខខណ្ឌទាំងនេះបង្អាក់ដល់កំណើនដែលមិនត្រឹមតែចំពោះសេដ្ឋកិច្ចមានកាបូនទាបប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការពង្រីកសកម្មភាពទាំងអស់របស់សហគ្រាសខ្នាតតូច និងមធ្យមផងដែរ។ ជាបច្ច័យល្អដែលរាជរដ្ឋាភិបាលបានស្វែងរកដំណោះស្រាយបញ្ហាប្រឈមទាំងនេះតាមរយៈការបង្កើតធនាគារសហគ្រាសខ្នាតតូច និងមធ្យមថ្មី ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានមូលនិធិសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមក្នុងស្រុកដែលនឹងចាប់ផ្តើមដាក់ដំណើរការនៅឆ្នាំ២០១៩ នេះហើយ។ ធនាគារសហគ្រាសខ្នាតតូច និងមធ្យមដែលគាំទ្រដោយរដ្ឋាភិបាលនេះ នឹងមានដើមទុនបឋម ១០០ លានដុល្លារអាមេរិក ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបញ្ជាក់ថា មូលនិធិទាំងនេះបានបែងចែកសម្រាប់គម្រោងរួចរាល់ហើយ។ ក្រសួងក៏បានបញ្ជាក់ផងដែរថា ធនាគារថ្មីនេះនឹងផ្តោតអាទិភាពទៅលើការគាំទ្រដល់ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យមនៅក្នុងវិស័យសំខាន់ចំនួនបួន – ធុរកិច្ចកសិកម្ម ផលិតកម្ម ទេសចរណ៍ និងក្រុមហ៊ុនអភិវឌ្ឍប្រព័ន្ធឌីជីថល ហើយផ្តោតជាពិសេសលើទីផ្សារនាំចេញគោលដៅទាំងនោះ។

ទោះបីជាគម្រោងនេះទំនងជាទទួលបានជោគជ័យ និងបន្តកិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលក្នុងការឆ្លើយតបចំពោះតម្រូវការសម្រាប់ការគាំទ្រហិរញ្ញវត្ថុកាន់តែប្រសើរចំពោះសហគ្រាសខ្នាតតូច និងមធ្យមយ៉ាងណាក្តី ក៏គម្រោងនេះអាចផ្តល់ឱកាសដើម្បីលើកទឹកចិត្តដល់ការវិនិយោគក្នុងការអភិវឌ្ឍន៍កាបូនទាប និងកំណើនបៃតងរបស់សហគ្រាសខ្នាតតូច និងមធ្យមផងដែរ។ ការប្រើប្រាស់មូលនិធិសាធារណៈចំពោះទម្រង់នៃការវិនិយោគទាំងនេះ រួមជាមួយវិស័យអាទិភាព ដែលបានរៀបរាប់នឹងមានប្រសិទ្ធភាពខ្ពស់ក្នុងការជំរុញឱ្យមានអន្តរកាលទៅរកសេដ្ឋកិច្ចមានកាបូនទាប ហើយនឹងបង្ហាញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ចំពោះអនាគតដែលប្រកបដោយចីរភាពនៃប្រទេសកម្ពុជាផងដែរ។

**ផលប៉ះពាល់លើកម្ពុជា**

*ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់នៅក្នុងចំណោមប្រទេសទាំងដប់ដែលងាយរងគ្រោះបំផុតពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលភាគច្រើន ដោយសារកម្ពុជាមានលទ្ធភាពតិចតួចក្នុងការសម្របតាមបម្រែបម្រួលបរិកាសនេះ ។ ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុកំពុងបង្កផលវិបាកធ្ងន់ធ្ងររួចទៅហើយសម្រាប់វិស័យកសិកម្ម និងសហគមន៍ជនបទនៅកម្ពុជា ដោយសារប្រទេសទាំងនោះខិតខំកាត់បន្ថយផលប៉ះពាល់ គ្រោះមហន្តរាយធម្មជាតិជារៀងរាល់ឆ្នាំ។ ទន្ទឹមនឹងនេះ ចាំបាច់ត្រូវមានវិធានការសម្របខ្លួនដើម្បីលើកកម្ពស់ភាពស៊ាំរបស់ប្រទេសកម្ពុជាចំពោះផលប៉ះពាល់ធ្ងន់ធ្ងរនៃបម្រែបម្រួលអាកាសធាតុ។*

*យ៉ាងណាមិញ ការលើកកម្ពស់ប្រសិទ្ធផលថាមពល និងការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានរបស់ សហគ្រាសខ្នាតតូច និងមធ្យមទំនងមិនមែនជាកង្វល់ចម្បងរបស់សហគ្រាសខ្នាតតូច និងមធ្យមភាគច្រើនឡើយ ដោយសារសហគ្រាសទាំងនោះជារឿយៗ មិនបានដឹងអំពីសារសំខាន់ និងផលប្រយោជន៍នៃការវិនិយោគទៅលើបច្ចេកវិទ្យាបៃតងចំពោះប្រតិបត្តិការរបស់ខ្លួនឡើយ។ ដោយសារហិរញ្ញប្បទានពីស្ថាប័នវិស័យឯកជនមានកម្រិត ឬមិនមានតែម្តង លើកលែងមានការចាត់វិធានការពីរាជរដ្ឋាភិបាលដើម្បីលើកទឹកចិត្តដល់ការវិនិយោគលើការអភិវឌ្ឍន៍កាបូនទាបទើបសហគ្រាសខ្នាតតូច និងមធ្យមនឹងត្រូវផាត់ចេញពីការនាំមុខក្នុងកំណើនសេដ្ឋកិច្ចបៃតង។*

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមពិចារណាពង្រីកអាទិភាព របស់ធនាគារសហគ្រាសខ្នាតតូច និងមធ្យមថ្មី ដើម្បីដាក់បញ្ចូលការវិនិយោគ លើការអភិវឌ្ឍន៍កាបូនទាបរបស់សហគ្រាសខ្នាតតូច និងមធ្យម។

*យើងខ្ញុំសូមគោរពផ្តល់ជូននូវអនុសាសន៍ដល់រាជរដ្ឋាភិបាល ឱ្យពិចារណាក្នុងការពង្រីកអាទិភាពរបស់ធនាគារសហគ្រាសខ្នាតតូច និងមធ្យមថ្មីដើម្បីដាក់បញ្ចូលការវិនិយោគលើការអភិវឌ្ឍន៍កាបូនទាបរបស់សហគ្រាសខ្នាតតូច និងមធ្យមស្របតាមវិស័យសំខាន់ចំនួនបួន៖ ធុរកិច្ចកសិកម្ម ផលិតកម្ម ទេសចរណ៍ និងក្រុមហ៊ុនអភិវឌ្ឍប្រព័ន្ធឌីជីថល។ វិធីសាស្ត្រនេះនឹងលើកកម្ពស់លទ្ធភាពទទួលបានឧបករណ៍ហិរញ្ញវត្ថុរយៈពេលវែង និងការប្រាក់ទាបសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមដែលបានទទួលស្គាល់រួចហើយពីអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនៃការអភិវឌ្ឍន៍កាបូនទាប ប៉ុន្តែក៏នឹងធ្វើឱ្យជ្រួតជ្រាបអំពីកិច្ចដំណើរការសេដ្ឋកិច្ចបៃតងទំនើបនៅកម្ពុជាផងដែរ។ ជាងនេះទៅទៀត កត្តានេះនឹងមានអំណោយផលល្អ ចំពោះគោលបំណងរបស់រាជរដ្ឋាភិបាលក្នុងការបង្កើនការចូលរួមពីវិស័យឯកជននៅក្នុងការកាត់បន្ថយ និងការសម្របខ្លួនរបស់ប្រទេសកម្ពុជាទៅនឹងបម្រែបម្រួលអាកាសធាតុ។*

## ៤៤

# ការលើកកម្ពស់ការគ្រប់គ្រងសំណល់ប្រកបដោយនិរន្តរភាព

ធ្វើបច្ចុប្បន្នភាព

**ពិពណ៌នាបញ្ហា**

*ដោយសារប្រទេសកម្ពុជាមានសកម្មភាពពង្រីកទីក្រុង និងអភិវឌ្ឍសេដ្ឋកិច្ច អ្នកប្រើប្រាស់កាន់តែធំ ទីក្រុងនានារបស់កម្ពុជា នឹងមានសំណល់រឹងកាន់តែច្រើនៗ សំណល់ប្រចាំខែ នៅកន្លែងចាក់សម្រាមទីក្រុងភ្នំពេញបានកើនឡើងលើសពីពីរដងទៅទៀតនៅក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ដែលមានសំណល់រឹងប្រមាណជា ១ លានតោនជារៀងរាល់ឆ្នាំ ។ កត្តានេះនាំមកនូវបញ្ហាប្រឈមកាន់តែធំសម្រាប់ អាជ្ញាធរនៅទីក្រុង និងក្រុមហ៊ុនគ្រប់គ្រងសំណល់ ដោយសារអាជ្ញាធរ និងក្រុមហ៊ុនគ្រប់គ្រងសំណល់ត្រូវខិតខំគ្រប់គ្រងឱ្យបាននូវសម្រាមដែលកើនឡើងដ៏ច្រើនលើសលុបនេះៗ*

*ជាបច្ច័យល្អ រដ្ឋបាលរាជធានីភ្នំពេញ (PPCA) បានចូលរួមស្តាបនាជាមួយភាគីពាក់ព័ន្ធជាច្រើន ដើម្បីកែលម្អការឆ្លើយតបចំពោះសំណល់នៅទីក្រុង និងតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមជាមួយដៃគូអភិវឌ្ឍន៍នានា បានពិនិត្យបញ្ចប់ជាស្ថាពរនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់រាជធានីភ្នំពេញឆ្នាំ២០១៨-២០៣៥ ដើម្បីដាក់ឱ្យអនុម័តនៅដើមឆ្នាំ២០១៩ នេះៗ ឯកសារគ្រប់ជ្រុងជ្រោយនេះ គឺផ្អែកតាមវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ សម្រាប់ការគ្រប់គ្រងសំណល់ ហើយនឹងធ្វើជាយុទ្ធសាស្ត្របង្ហាញផ្លូវសម្រាប់រដ្ឋបាលរាជធានីភ្នំពេញក្នុងការសម្រេចបានការកែលម្អជាប្រព័ន្ធដែលចាំបាច់នៅក្នុងកាត់បន្ថយបរិមាណកាកសំណល់នៅក្នុងទីក្រុង និងដើម្បីពង្រឹងការប្រមូល និងបញ្ចេញចោលសំណល់ទាំងនោះៗ ដោយសារស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រងសំណល់នៅក្នុងរាជធានីភ្នំពេញ នេះគឺជាកិច្ចការលំបាកមួយ ដែលនឹងតម្រូវឱ្យមានការសម្របសម្រួលកម្រិតខ្ពស់ និងធនធានច្រើនដើម្បីសម្រេចបាននៅក្នុងរយៈពេល ១៦ ឆ្នាំទៀតៗ*

*វិធានការបន្ទាន់បំផុតដែលយុទ្ធសាស្ត្រនេះបានកំណត់គឺ ភាពចាំបាច់ក្នុងការកំណត់ថាតើ សំណល់កើតឡើងដោយរបៀបណា និងត្រូវបានប្រមូលចេញពីប្រភពដោយរបៀបណា ដូចជា សំណល់តាមផ្ទះ សាលារៀន ភោជនីយដ្ឋាន សណ្ឋាគារ និងគ្រឹះស្ថានផ្សេងទៀតៗ សំខាន់ជាងនេះ គឺការផ្តោតទៅលើអ្នកបង្កើតសំណល់ ដើម្បីចាប់ផ្តើមញែកទម្រង់នៃកាកសំណល់ខុសៗគ្នាដើម្បីអាចឱ្យក្រុមហ៊ុនគ្រប់គ្រងសំណល់ ប្រមូល និងធ្វើប្រព្រឹត្តិកម្មសំណល់ឱ្យកាន់តែមានប្រសិទ្ធផល និងប្រសិទ្ធភាពថ្លៃចំណាយៗ*

*ជាជំហានដំបូង ការញែកសំណល់សរីរាង្គចេញពីសំណល់អសរីរាង្គ អាចបង្កើនតម្លៃសំណល់យ៉ាងខ្លាំង ដោយសារនេះគឺជាដំណើរការស្មុគស្មាញ និងចំណាយខ្ពស់ក្រោយពីសំណល់លាយឡំជាមួយគ្នាៗ ប្រសិនបើការញែកសំណល់ត្រូវធ្វើឡើងនៅប្រភពបញ្ចេញកាកសំណល់ គេអាចធ្វើជីសរីរាង្គចេញពី សំណល់សរីរាង្គដើម្បីបង្កើតទំនិញកសិកម្មសំខាន់ ចំណែកសំណល់អសរីរាង្គគេអាចបំលែងសម្រាប់*

*ការប្រើប្រាស់ឡើងវិញ។ ទោះបីយ៉ាងណា កម្ពុជាមិនដែលធ្វើការញែកសំណល់ផ្លូវការណាមួយទេ ផ្ទុយទៅវិញ ប្រជាជនពឹងផ្អែកលើបណ្តាញពុំមានលក្ខណៈប្រព័ន្ធនៃអ្នកប្រមូលសំណល់ក្រៅផ្លូវការដើម្បីបែងចែកកាលសំណល់ដែលអាចយកលក់បាននៅប្រភពបញ្ចេញសំណល់ និងនៅទីតាំងចាក់សំរាម។ ដូច្នេះ ការដាក់ឱ្យប្រើប្រាស់លក្ខខណ្ឌតម្រូវតឹងរ៉ឹងលើប្រជាជនឱ្យញែកសំណល់របស់ខ្លួននឹងអាចមិនមានប្រសិទ្ធភាពឡើយ លុះត្រាតែមានការផ្លាស់ប្តូរទៅលើផ្នត់គំនិត និងឥរិយាបថរបស់សាធារណជនលើបញ្ហាកាកសំណល់។*

*ការពិត អនុក្រឹតលេខ ១១៣ ស្តីពីការគ្រប់គ្រងសម្រាម សំណល់រឹងនៅទីប្រជុំជនត្រូវបានអនុម័តនៅឆ្នាំ២០១៥ ដែលបានផ្ទេរវិមជ្ឈការរដ្ឋបាលគ្រប់គ្រងកាកសំណល់ទៅឱ្យអាជ្ញាធរមូលដ្ឋាននៅរាជធានីភ្នំពេញ បានចែងថា កាកសំណល់ត្រូវញែក វេចខ្ចប់ ទុកដាក់ និងបោះចោលឱ្យបានត្រឹមត្រូវ។ គួរឱ្យសោកស្តាយ ការអនុវត្តអនុក្រឹតនេះនៅមានកម្រិត ហើយអាជ្ញាធរមូលដ្ឋាន ក្រុមហ៊ុនធុរកិច្ច និងប្រជាពលរដ្ឋមិនបានយល់ដឹងពេញលេញពីទំនួលខុសត្រូវរបស់ខ្លួនឡើយ។*

*ក្នុងនាមជាអ្នកបញ្ចេញសំណល់ច្រើនជាងគេ វិស័យឯកជនដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់ស្ថានភាពគ្រប់គ្រងកាកសំណល់នៅកម្ពុជា ហើយត្រូវបានគេមើលឃើញថាជាដៃគូយុទ្ធសាស្ត្រក្នុងការកសាងការយល់ដឹងជុំវិញអត្ថប្រយោជន៍នៃការកាត់បន្ថយកាកសំណល់ និងការញែកកាកសំណល់។ តាមរយៈវិធីជាច្រើន វិស័យឯកជនទាញយកផលប្រយោជន៍ច្រើនបំផុតពីប្រព័ន្ធគ្រប់គ្រងកាកសំណល់ដែលមានការរៀបចំត្រឹមត្រូវ ពីការលក់សម្ភារកែច្នៃឡើងវិញក្នុងតម្លៃថោក កាសធុរកិច្ចថ្មីក្នុងការកែច្នៃឡើងវិញ និងដើម្បីលើកកម្ពស់មុខមាត់ចំពោះមុខសាធារណៈជនតាមរយៈការបង្ហាញពីទំនួលខុសត្រូវផ្នែកបរិស្ថាន។ ក្រុមហ៊ុនធុរកិច្ចគប្បី ធ្វើប្រក្រតីកម្មការញែកកាកសំណល់ និងវិធីសាស្ត្រគ្រប់គ្រងកាកសំណល់ប្រកបដោយចីរភាព។*

*ទោះបីយ៉ាងណា ក្រុមហ៊ុនម៉ៅការគ្រប់គ្រងកាកសំណល់នៅរាជធានីភ្នំពេញបច្ចុប្បន្នមិនមានសមត្ថភាពប្រមូល ឬធ្វើប្រព្រឹត្តិកម្មកាកសំណល់ដែលមានទម្រង់ខុសៗគ្នាបានឡើយ ដែលធ្វើឱ្យការញែកសំណល់កាន់តែមានការលំបាកថែមទៀត។ ជាលទ្ធផល ក្រុមហ៊ុនធុរកិច្ចទទួលខុសត្រូវជាច្រើននៅប្រទេសកម្ពុជាដែលមានបំណងគ្រប់គ្រងកាកសំណល់របស់ខ្លួនតាមវិធីសាស្ត្រប្រកបដោយចីរភាព អាចមិនទទួលបាន ការលើកទឹកចិត្តឱ្យអនុវត្តកិច្ចការនេះ ដោយសារកាកសំណល់របស់ខ្លួន នឹងត្រូវលាយឡំគ្នានៅពេលប្រមូលទោះបីខ្លួនអនុវត្តយុទ្ធសាស្ត្រផ្ទៃក្នុងយ៉ាងដូចម្តេចក៏ដោយ។*

*ជាជាងការពន្យារពេលសកម្មភាពរហូតដល់បញ្ហានេះមានការកែលម្អ រដ្ឋាភិបាលអាចពង្រឹងការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការដោះស្រាយបញ្ហាសំណល់ចេះតែកើនឡើងនេះដោយចាត់វិធានការដើម្បីទទួលស្គាល់ លើកទឹកចិត្ត និងជំរុញ តួអង្គដែលបានអនុវត្តការផ្តួចផ្តើមនេះរួចហើយដើម្បីកាត់បន្ថយ និងញែកសំណល់។ តាមរយៈការអនុវត្តវិធីសាស្ត្រកាន់តែមានលក្ខណៈប្រព័ន្ធរាជរដ្ឋាភិបាល និង វិស័យឯកជននឹងធ្វើការសម្រួលដល់កិច្ចខិតខំប្រឹងប្រែងរបស់វិស័យក្រៅផ្លូវការដើម្បីប្រមូល និងកែច្នៃសំណល់អាចប្រើប្រាស់បានឡើងវិញ ព្រមទាំងផ្តល់ការគាំទ្រដល់សេវាខ្នាតតូច ដែលនឹងនាំឱ្យមានសេវាធ្វើកំប៉ុស្ត៍ និងកែច្នៃឡើងវិញដំណើរការដោយផ្នែកឯកជនកាន់តែមានចំនួនច្រើនឡើងផងដែរ។*

## ផលប៉ះពាល់លើកម្ពុជា

*ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ និងកំណើនការគាំទ្រសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព បានបង្ខំវិនិយោគិនឱ្យយកចិត្តទុកដាក់កាន់តែខ្លាំង ទៅលើការអនុវត្តផ្នែកបរិស្ថាន នៃការវិនិយោគរបស់ខ្លួន។ ជាការពិត ការធ្វើសមាហរណកម្មបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ទៅក្នុងការសម្រេចចិត្ត វិនិយោគបានកើនឡើងគួរឱ្យកត់សម្គាល់ ដោយសារវិនិយោគិនដែលមានទំនួលខុសត្រូវទទួលស្គាល់ពីការចូលរួមគ្រប់ជ្រុងជ្រោយរបស់ខ្លួនទៅលើ ការវិនិយោគប្រកបដោយចីរភាព។*

*ចំពោះការគ្រប់គ្រងកាកសំណល់ វិនិយោគិន និងពហុជាតិសាសន៍កំពុងផ្ដល់អាទិភាពលើកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយការបង្កើតសំណល់ កែច្នៃសម្ភារឡើងវិញ និងផលិតថាមពលចេញពីកាកសំណល់ ព្រមទាំងប្រព្រឹត្តិកម្មសំណល់មិនអាចប្រើបានប្រកបដោយនិរន្តរភាព ដោយសារផលវិបាកផ្នែកសេដ្ឋកិច្ច និងមុខមាត់ប្រសិនបើមិនបានអនុវត្តតាមការកំណត់នេះ។ ប្រសិនបើប្រព័ន្ធគ្រប់គ្រងកាកសំណល់របស់កម្ពុជាមិនអាចឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះកំណើនសំណល់យ៉ាងឆាប់រហ័សទេនោះ ស្ថានភាពនេះអាចនឹងប៉ះពាល់ដល់លទ្ធភាពរបស់ប្រទេសកម្ពុជាក្នុងការទាក់ទាញវិនិយោគថ្មីៗ និងការប្រកួតប្រជែងជាមួយបណ្ដាប្រទេសដែលមានការគ្រប់គ្រងកាកសំណល់ប្រកបដោយចីរភាព។*

*ជាងនេះទៅទៀត ការលើកកម្ពស់ និងការបង្កើតការអនុវត្តល្អក្នុងការគ្រប់គ្រងកាកសំណល់ប្រកបដោយចីរភាព នឹងមិនត្រឹមតែជាការប្ដេជ្ញាចិត្តជាអន្តរជាតិ និងថ្នាក់តំបន់របស់កម្ពុជាក្នុងការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានប៉ុណ្ណោះទេ ប៉ុន្តែ សំខាន់ជាងនេះក៏បានជួយកាត់បន្ថយហានិភ័យចំពោះសុខភាពសាធារណៈពាក់ព័ន្ធដែលមានមកជាមួយនឹងទម្រង់នៃប្រព្រឹត្តិកម្មកាលសំណល់ ដែលគ្មានចីរភាពផងដែរ។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ បង្កើតលិខិតូបករណ៍សារពើពន្ធ និងមិនមែនសារពើពន្ធដើម្បីទទួលស្គាល់ ជំរុញ និងលើកទឹកចិត្តដល់គំនិតផ្ដួចផ្ដើមរបស់វិស័យឯកជនក្នុងការកាត់បន្ថយ ញែក និងកែច្នៃសំណល់ឡើងវិញ។

*ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងជាប្រចាំ ដើម្បីធ្វើទំនើបកម្មវិស័យគ្រប់គ្រងសំណល់ទីក្រុងនៅប្រទេសកម្ពុជា យើងខ្ញុំសូមជូនអនុសាសន៍ដល់រាជរដ្ឋាភិបាលឱ្យបង្កើតលិខិតូបករណ៍សារពើពន្ធ និងមិនមែនសារពើពន្ធ ដើម្បីទទួលស្គាល់ ជំរុញ និងលើកទឹកចិត្ត ដល់គំនិតផ្ដួចផ្ដើមរបស់វិស័យឯកជនលើផ្នែលដែលកាត់បន្ថយ ញែក និងកែច្នៃសំណល់ឡើងវិញ៖*

- *លើកទឹកចិត្តវិស័យឯកជនឱ្យអនុវត្តការគ្រប់គ្រងផ្ទៃក្នុងនូវសំណល់រឹង និងគោលនយោបាយដែលនឹងជួយសម្រួលដល់ការប្រមូលសំណល់ បង្កើតភាពដៃគូជាមួយក្រុមហ៊ុនកែច្នៃសំណល់ឡើងវិញ កាត់បន្ថយសំណល់ និងបួរការប្រើសំណល់ផ្លាស្ទិកដែលប្រើតែម្តងរួចបោះចោល (ថង់ផ្លាស្ទិក ការវេចខ្ចប់ការប្រើលើសចំនួន ដបប្រើតែម្តងរួចបោះចោល កំណ្តាធ្វើពីជ័រ ទុយោបឺត)។*
- *តាមការស្ម័គ្រចិត្ត ផ្តល់ឱកាសដល់ក្រុមហ៊ុនធុរកិច្ច ផ្តល់ព័ត៌មានពីការអនុវត្តការគ្រប់គ្រងកាកសំណល់បានល្អរបស់ខ្លួន ដើម្បីទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ។*
- *លើកកម្ពស់ និងលើកទឹកចិត្តឱ្យធ្វើការកែច្នៃឡើងវិញ និងប្រើវត្ថុធម្មជាតិសម្រាប់ការវេចខ្ចប់ ព្រមទាំងបង្កើនការចូលទីផ្សារសម្រាប់ក្រុមហ៊ុនផ្គត់ផ្គង់ការវេចខ្ចប់កែច្នៃឡើងវិញតាមរយៈការលើកទឹកចិត្តផ្នែកសារពើពន្ធ និងពន្ធគយ។*
- *លើកកម្ពស់ និងលើកទឹកចិត្តឱ្យមានការបង្កើតទីតាំងកែច្នៃសំណល់ឡើងវិញនៅក្នុងទីក្រុងធំៗនៅ ក្នុងប្រទេសកម្ពុជា។*
- *បន្តមិនលើកទឹកចិត្តឱ្យប្រើថង់ផ្លាស្ទិកនៅតាមផ្សារទំនើបនិងដាក់ឱ្យអនុវត្តបទប្បញ្ញត្តិតឹង រ៉ឹងជុំវិញការប្រើប្រាស់ និងការបោះចោលសំណល់ផ្លាស្ទិកដោយគ្មានការទទួលខុសត្រូវ។*
- *ផ្សព្វផ្សាយគោលការណ៍ណែនាំបរិស្ថានអំពីការគ្រប់គ្រងកាកសំណល់រឹងនៅព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ១១៣ ស្តីពីការគ្រប់គ្រងសម្រាមសំណល់រឹងនៅទីប្រជុំជនឱ្យបានទូលំទូលាយ ព្រមទាំងបន្តដាក់ចេញនូវចាត់វិធានការអនុវត្តច្បាប់។*
- *កៀរគរធនធានដើម្បីបើកយុទ្ធនាការអប់រំ និងលើកកម្ពស់ការយល់ដឹងដល់ប្រជាជនអំពី អត្ថប្រយោជន៍ពីការញែកកាកសំណល់ និងទំនួលខុសត្រូវរបស់ពួកគាត់ក្នុងនាមជាអ្នកបង្កើតសំណល់។*

# វិស័យសុខាភិបាល

ម៉ាកផលិតផលថែទាំសុខភាពរបស់សហភាពអឺរ៉ុបបន្តទទួលបានការទទួលស្គាល់យ៉ាងខ្លាំងនៅកម្ពុជា ហើយដើរតួយ៉ាងសំខាន់ ក្នុងការលើកកម្ពស់ស្តង់ដារខ្ពស់លើការគ្រប់គ្រងគុណភាពដែលធានានូវសុវត្ថិភាពដល់អ្នកជំងឺ។ យើងខ្ញុំមានក្តីសោមនស្ស សូមជម្រាបជូនថា ការចូលរួមរបស់យើងខ្ញុំជាមួយនឹងក្រសួងសុខាភិបាលកាន់តែមានភាពប្រសើរឡើងចាប់តាំងពីការដាក់ឱ្យប្រើប្រាស់ នូវសៀវភៅស លើកទីមួយមកម៉្លេះ។ គណៈកម្មាធិការសុខាភិបាលរបស់យើងខ្ញុំ មានឱកាសពិភាក្សាអំពីអនុសាសន៍មុនៗជាមួយនឹងនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង និងមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ដែលយើងខ្ញុំសូមសម្តែងនូវអំណរគុណចំពោះក្រសួងសុខាភិបាលសម្រាប់ការសម្របសម្រួលនេះ។ ស្រដៀងគ្នានេះដែរ គណៈកម្មាធិការនេះបានបន្តសហការយ៉ាងជិតស្និទ្ធជាមួយនឹងគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយនៃកម្ពុជា ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងនឹងផលិតផលឱសថក្លែងក្លាយ និងខុសច្បាប់ដែលយើងខ្ញុំកំពុងតែរៀបចំអនុស្សរណៈនៃការយោគយល់ដើម្បីបង្កើតកិច្ចសហការនេះជាផ្លូវការ។

ការចូលរួមប្រកបដោយការស្ថាបនានេះ គឺ ជាការកិច្ចគាំទ្រមួយក្នុងការស្វែងរកដំណោះស្រាយសម្រាប់បញ្ហាប្រឈមមួយចំនួន ដែលក្រុមហ៊ុនមានអនុលោមភាពនៅក្នុងវិស័យសុខាភិបាលបានជួបប្រទះកន្លងមក។ចំពោះការវិវឌ្ឍន៍នាពេលថ្មីៗក្រសួងសុខាភិបាលបានបញ្ជាក់ជូនថា ក្រសួងកំពុងរៀបចំកម្មវិធីតាមប្រព័ន្ធអនឡាញ ដើម្បីគ្រប់គ្រងការចុះបញ្ជិកា និងការនាំចូលផលិតផលឱសថតាមប្រព័ន្ធអេឡិចត្រូនិកដោយមានការគាំទ្រផ្នែកបច្ចេកទេសពីអង្គការសុខភាពពិភពលោក (WHO)។ ខណៈពេលដែលខ្ញុំទទួលស្គាល់ថា គម្រោងនេះត្រូវការចំណាយរយៈ ពេលយូរ និងធនធានជាច្រើន ដើម្បីអនុវត្តក្តី ក៏យើងខ្ញុំសូមសាទរចំពោះគម្រោងនេះ និងសូមលើកទឹកចិត្តឱ្យក្រសួងផ្តល់អាទិភាពលើការអភិវឌ្ឍសមត្ថភាពដែលជាកត្តាដ៏សំខាន់មួយដើម្បីបង្កើនប្រសិទ្ធផល និងតម្លាភាពដំណើរការទាំងនេះឱ្យកាន់តែប្រសើរថែមទៀត។

ក្រសួងក៏បានបញ្ចប់សេចក្តីព្រាងគោលការណ៍ណែនាំ ពាក់ព័ន្ធនឹងបែបបទការផ្លាស់ប្តូរលើផលិតផលឱសថក្រោយការចុះបញ្ជិកាដែលត្រូវបានរៀបចំដោយអនុលោមតាមគោលការណ៍ណែនាំអាស៊ានស្តីពី

ការផ្លាស់ប្តូរផលិតផលឱសថ។ យើងខ្ញុំទន្ទឹងរង់ចាំមើលបទប្បញ្ញត្តិថ្មីទាំងនេះ ហើយជឿជាក់ថា ប្រកាសបច្ចុប្បន្នសម្រាប់ការដាក់ពាក្យសុំផ្លាស់ប្តូរ ផលិតផលឱសថ នឹងត្រូវរក្សាទុកឱ្យមានដដែលរួមទាំង ទំហំកញ្ចប់ និងការផ្លាស់ប្តូរការផលិត ដោយសារចំណុចទាំងនេះអាចឱ្យក្រុមហ៊ុនឱសថកែលម្អ និងធ្វើបច្ចុប្បន្នភាពផលិតផលរបស់ខ្លួនបានប្រកបដោយប្រសិទ្ធភាព នៅពេលចាំបាច់។ នៅពេលគោលការណ៍ណែនាំនេះទទួលបានការអនុម័ត ក្រសួងសុខាភិបាលនឹងចេញប្រកាសរួមមួយជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីបែបបទការផ្លាស់ប្តូរលើផលិតផលឱសថ ដែលរួមបញ្ចូលទាំងរចនាសម្ព័ន្ធតម្លៃសេវាសម្រាប់ការផ្លាស់ប្តូរលើផលិតផលឱសថក្រោយចុះបញ្ជិកា ដែលគ្រោងនឹងអនុវត្តនៅក្នុងឆ្នាំ២០១៩ នេះ។ យើងខ្ញុំសង្ឃឹមថាតម្លៃនៃការស្នើសុំការផ្លាស់ប្តូរលើផលិតផលឱសថក្រោយពេលចុះបញ្ជិកានេះ នឹងមិនមានការកើនឡើងនោះទេ ដូចដែលបាន ប្រាស្រ័យទាក់ទងគ្នានៅក្នុងកិច្ចប្រជុំក្រុមការងារ នាវេទិកាពជរដ្ឋាភិបាល-ផ្នែកឯកជន កាលពីខែកុម្ភៈ ឆ្នាំ២០១៩ កន្លងទៅនេះ។ សមាជិករបស់យើងខ្ញុំសូមវាយតម្លៃខ្ពស់លើវិធីសាស្រ្តសមស្របដែលក្រសួងសុខាភិបាលបានអនុវត្តក្នុងការទទួលយកការផ្លាស់ប្តូរលើផលិតផលឱសថជាក់លាក់មួយចំនួននៅក្នុងរយៈពេលសាកល្បងនេះដើម្បីធានាដល់ការផ្គត់ផ្គង់ឱសថសម្រាប់អ្នកជំងឺ។

ស្រដៀងគ្នានេះដែរ ក្រសួងសុខាភិបាលបានធ្វើបច្ចុប្បន្នភាព បញ្ជីឈ្មោះឱសថលក់ដោយមិនចាំបាច់មានវេជ្ជបញ្ជា (OTC) នៅឆ្នាំ២០១៧ និងបានជូនដំណឹងដល់សមាជិករបស់យើងខ្ញុំថា ក្រសួងមានបំណងបញ្ចប់ការធ្វើបច្ចុប្បន្នភាពផ្សេងៗទៀតទៅលើបញ្ជីនេះនៅឆ្នាំ២០១៩ ដើម្បីធានាថាបញ្ជីនេះបន្តបង្ហាញអំពីការផ្លាស់ប្តូរតម្រូវការសុខាភិបាលរបស់ប្រជាពលរដ្ឋ។ យោងតាមតម្រូវការនេះ យើងខ្ញុំបានដាក់បញ្ចូលអនុសាសន៍ថ្មីដោយស្នើសុំឱ្យមានការបញ្ជាក់ឱ្យបានច្បាស់អំពីដំណើរការ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្លាស់ប្តូរឱសថមានវេជ្ជបញ្ជាទៅជាឱសថមិនចាំបាច់វេជ្ជបញ្ជា និងសូមស្នើឱ្យអនុវត្តដំណើរការទាំងនេះស្របតាមការអនុវត្តរបស់អាស៊ាន។

ទោះបីជាការវិវឌ្ឍន៍ទាំងនេះបង្ហាញ អំពីការកែលម្អនាពេលខាងមុខ សម្រាប់វិស័យសុខាភិបាលក៏ដោយ ក៏បញ្ហាជា ច្រើនដែលប៉ះពាល់ទៅដល់ក្រុមហ៊ុនធុរកិច្ចសុខា

ភិបាលនៅកម្ពុជា នៅតែបន្តកើតឡើង ដោយសារតែក្រសួងសុខាភិបាល និង ច្បាប់កម្ពុជា មិនទាន់បានចាត់ទុកការចែកចាយឱសថមិនមានសិទ្ធិអនុញ្ញាត ជាអំពើខុសច្បាប់។ នេះជាបញ្ហាដែលសមាជិករបស់យើងខ្ញុំយល់ឃើញថា ច្បាប់នាពេលបច្ចុប្បន្នមិនទាន់អាចធានានូវសុវត្ថិភាព ឬគុណភាពផលិតផលឱសថទាំង នោះបាននៅឡើយ ដូច្នេះហើយ ផលិតផលទាំងនោះបានបង្កការគំរាមកំហែងដល់សុវត្ថិភាពអ្នកជំងឺ។ ជាលទ្ធផល គណៈកម្មាធិការសុខាភិបាលរបស់សភាពាណិជ្ជកម្មអឺរ៉ុប បានបន្តស្នើសុំឱ្យក្រសួងចាត់វិធានការយ៉ាងតឹងរ៉ឹង ដើម្បីកាត់បន្ថយការដាក់លក់ផលិតផលឱសថដែលមិនគោរពតាមច្បាប់ និងលក្ខ-ខណ្ឌតម្រូវធ្វើតេស្តដូចដែលបានកំណត់ដោយក្រសួងសុខាភិបាល។

អនុសាសន៍ដែលយើងខ្ញុំសូមរក្សាទុក គឺការប្តេជ្ញាចិត្តដ៏មុតមាំ ក្នុងការបង្កើតស្តង់ដារខ្ពស់នៃការថែទាំ និងសុវត្ថិភាពអ្នកជំងឺដោយជំរុញឱ្យមាននូវលទ្ធភាព នៃជម្រើសព្យាបាលសុខភាព ក្នុងតម្លៃសមរម្យតាមរយៈទីផ្សារកាន់តែមានភាពប្រកួតប្រជែង។ យើងខ្ញុំសូមស្នើឱ្យពង្រីកបញ្ជីដីវផលិតផលដែលបានទទួលយកឱ្យកាន់តែទូលំទូលាយ ដាង បញ្ជីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមុន (Pre-Qualified List) របស់អង្គការសុខភាពពិភពលោក ដើម្បីឆ្លុះបញ្ចាំងឱ្យកាន់តែច្បាស់អំពីតម្រូវការរបស់កម្ពុជា រួមជាមួយការធ្វើឱ្យសាមញ្ញ នូវបញ្ជិកាឧបករណ៍បរិក្ខារពេទ្យ ដើម្បីអាចចុះបញ្ជិឧបករណ៍ជាច្រើន បានដែលស្ថិតនៅក្រុមថ្នាក់តែមួយ និងអនុលោមភាពប្រភេទនៃការចុះបញ្ជី តាមគោលការណ៍ណែនាំរបស់អាស៊ាន។ លើសពីនេះទៅទៀតយើងខ្ញុំមាន គោលបំណងបញ្ជាក់ឱ្យបានច្បាស់ អំពីភាពមិនច្បាស់លាស់ដែលមាន នៅក្នុងនិយ័តកម្មពាក់ព័ន្ធនឹងសកម្មភាពផ្សព្វផ្សាយលក់ផលិតផលឱសថការស្នើសុំឱ្យដាក់ប្រើប្រាស់ឡើងវិញនូវដំណើរការសុំអាជ្ញាប័ណ្ណនាំចូលបន្ទាន់ (ពិសេស) និងលើកទឹកចិត្តក្រសួងឱ្យរៀបចំកិច្ចប្រជុំគណៈកម្មការបញ្ជិកា និងបន្តសុពលភាពឱ្យបានកាន់តែញឹកញាប់ថែមទៀត។

៤៥

# ពង្រីកវិសាលភាពបញ្ជីជីវផលិតផលដែលបានឯកភាពសម្រាប់ការនាំចូល

ថ្មី

**ពិពណ៌នាបញ្ហា**

*កម្ពុជាបានទទួលភាពជោគជ័យគួរឱ្យកត់សម្គាល់ ក្នុងការលើកកម្ពស់ស្តង់ដារសុខាភិបាល និងការទទួលបានសេវាសុខាភិបាលនៅទូទាំងប្រទេស។ សមាសធាតុដ៏សំខាន់ដែលសម្រេចបានភាពជោគជ័យ ក្នុងការអនុវត្តយុទ្ធសាស្ត្រសុខាភិបាលនៅក្នុងប្រទេសកម្ពុជាគឺកម្មវិធីចាក់ថ្នាំបង្ការមានប្រសិទ្ធភាពដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក* (WHO) *ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺដែលអាចបង្ការបានដោយការចាក់ថ្នាំបង្ការ ដូចជា ជំងឺខ្វិន ជំងឺកញ្ជ្រិល ជំងឺស្អូច និងជំងឺផ្សេងទៀត។*

*ដោយសារតែក្តីកង្វល់អំពីបញ្ហាសុវត្ថិភាពមានកាន់តែច្រើនឡើង និងភាពស្មុគស្មាញនៃផលិតកម្ម និងការធ្វើតេស្ត ការនាំចូលវ៉ាក់សាំង និងជីវផលិតផល ផ្សេងទៀតមកកាន់ប្រទេសកម្ពុជាមានលក្ខណៈតឹងរ៉ឹងជាងផលិតផលថែទាំសុខភាពផ្សេងទៀត។ កង្វល់ទាំងនេះបាននាំឱ្យក្រសួងសុខាភិបាលអនុវត្តការរឹតបន្តឹងកាន់តែម៉ឺងម៉ាត់នាពេល ថ្មីៗនេះលើក្រុមហ៊ុនឱសថដែលនាំចូលជីវផលិតផលនានា។ ក្រសួងសុខាភិបាល បានបញ្ជាក់ថាក្រសួងនឹងផ្តល់ជូនតែអាជ្ញាប័ណ្ណនាំចូលសម្រាប់ផលិតផលណាដែលមាននៅក្នុងបញ្ជីវ៉ាក់សាំងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមុន* (Prequalified Vaccines List) *របស់អង្គការសុខភាពពិភពលោកប៉ុណ្ណោះ ដែលនឹងកាត់បន្ថយយ៉ាងច្រើនលើការដាក់លក់ជីវផលិតផលជាច្រើនទៀតនៅក្នុងប្រទេសកម្ពុជា។*

*អង្គការសុខភាពពិភពលោក បានបង្កើតបញ្ជីវ៉ាក់សាំងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមុន* (Prequalified Vaccines List) *ដែលជាសេវាសម្រាប់ទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ* (UN) *ដែលទិញវ៉ាក់សាំងដើម្បីកំណត់កម្រិតលទ្ធភាពអាចទទួលយកវ៉ាក់សាំងចេញពីប្រភពខុសៗគ្នា និងឆ្លុះបញ្ចាំងអំពីផលិតផលទាំងនោះដែលតម្រូវដោយអ្នកជេញថ្លៃនីមួយៗ និងដែលត្រូវដាក់ស្នើសុំការវាយតម្លៃ។ អង្គការសុខភាពពិភពលោកបានបញ្ជាក់ថា ខ្លួនមិនមានគោលបំណងយកផលិតផលនេះធ្វើជាបញ្ជីផលិតផលទូលំទូលាយដែលប្រើប្រាស់ក្នុងការព្យាបាលជំងឺនោះឡើយ ហើយថា ប្រសិនបើផលិតផលណាមួយមិនត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីនេះនោះទេ មិនមានន័យថាផលិតផលនោះមិនអនុវត្តតាមស្តង់ដារផលិតផលឡើយ ក្នុងករណីបានដាក់ស្នើសុំការវាយតម្លៃហើយនោះ ។ ដូចគ្នានេះដែរ ប្រសិនបើផលិតផលណាមួយដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីនេះ មិនមានន័យថាផលិតផលនោះ ឬរោងចក្រផលិតនោះ* (manufacturer) *ដែលមានការអនុម័តទទួលស្គាល់ពីអង្គការសុខភាពពិភពលោកឡើយ ដោយសារតែនេះគឺជាទំនួលខុសត្រូវរបស់អាជ្ញាធរជាតិនៃប្រទេសនាំចេញវ៉ាក់សាំងទាំងនោះ ហើយមិនមានការធានាថា ផលិតផលទាំងនោះនឹងបន្តបំពេញតាមស្តង់ដាររបស់អង្គការសុខភាពពិភពលោកឡើយ។*

សំខាន់ជាងនេះទៅទៀត បញ្ជីឱសថមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមុន (Prequalified List) របស់អង្គការសុខភាពពិភពលោក ក៏ពឹងផ្អែកលើការវាយតម្លៃផ្នែកវិទ្យាសាស្ត្រ និងការត្រួតពិនិត្យដែលធ្វើឡើងដោយរដ្ឋបាលឱសថ និងចំណីអាហារសហរដ្ឋអាមេរិក (USFDA) និងទីភ្នាក់ងារឱសថអឺរ៉ុប (EMA) ជាមូលដ្ឋានសម្រាប់ការរៀបចំបញ្ជីឱសថមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមុននេះ (Prequalified List)។ ដូច្នេះ ប្រសិនបើផលិតផលដែលតម្រូវដោយទីភ្នាក់ងារអង្គការសហប្រជាជាតិបានទទួលការវាយតម្លៃពីអាជ្ញាធរណាមួយទាំងនេះរួចហើយ អង្គការសុខភាពពិភពលោកមិនទាមទារឱ្យមានការវាយតម្លៃផ្ទាល់របស់ខ្លួនឡើយ មុនពេលចុះបញ្ជី ដោយសារអង្គការសុខភាពពិភពលោកទទួលស្គាល់ថា USFDA និង EMA មានសមត្ថភាព និងលទ្ធភាពបញ្ជាក់ពីសុវត្ថិភាព និងប្រសិទ្ធភាពនៃផលិតផលនោះ។

## ផលប៉ះពាល់លើកម្ពុជា

ខណៈដែលយើងខ្ញុំទទួលស្គាល់ថា ក្រសួងបានអនុវត្តការរឹងបន្តឹងបន្ថែមនេះ ដើម្បីធានាថាជីវផលិតផលដែលមានដាក់លក់នៅលើទីផ្សារ គឺមានសុវត្ថិភាព និងប្រសិទ្ធភាពដូចមានកំណត់ដោយអង្គការសុខភាពពិភពលោក ដោយសារតែបញ្ជីនេះនៅមានកម្រិត និងមានតម្រូវការខុសគ្នាៗ និងភាពចាំបាច់ដែលផលិតផលទាំងអស់ត្រូវចុះបញ្ជីមុនពេលដែលអាចនាំចូលផលិតផលទាំងនោះ ធ្វើឱ្យអ្នកជំងឺពិបាកនឹងទទួលបាននូវការព្យាបាល។ ដោយសារតែការដាក់បញ្ចូលការព្យាបាលថ្មី ពឹងផ្អែកទាំងស្រុងទៅលើតម្រូវការរបស់ទីភ្នាក់ងារអង្គការសហប្រជាជាតិ ដែលពឹងផ្អែកទៅលើបញ្ជីអង្គការសុខភាពពិភពលោកជាគោល នឹងមិនមានសង្គតិភាពតាមតម្រូវការថែទាំសុខភាពជាក់លាក់ និងស្ថានភាពកំពុងមានការផ្លាស់ប្តូរនៅក្នុងប្រទេសកម្ពុជាឡើយ ហើយអាចហួសកាលបរិច្ឆេទយ៉ាងឆាប់រហ័សដោយសារតែការអភិវឌ្ឍផ្នែកវិទ្យា-សាស្ត្រមានល្បឿនលឿន។ ជាលទ្ធផល ប្រសិនបើមានវិធីព្យាបាលថ្មីណាមួយនៅក្នុងទីផ្សារ នោះនឹងមានការរំពឹងទុកថានឹងត្រូវការពេលវេលាមួយចំនួនមុននឹងវិធីសាស្ត្រព្យាបាលនោះមាននៅក្នុងបញ្ជីនេះដោយសារតែដំណើរការរដ្ឋបាលពាក់ព័ន្ធមានភាពស្មុគស្មាញច្រើន ដែលអាចឱ្យពលរដ្ឋកម្ពុជាមិនអាចទទួលបានការព្យាបាលជួយសង្គ្រោះជីវិតតាមវិធីសាស្ត្រថ្មីនេះទាន់ពេលវេលា។

ការរឹតត្បិតមិនឱ្យមានការព្យាបាលថ្មី ដោយប្រើផលិតផលដែលមាននៅក្នុងបញ្ជីរបស់អង្គការសុខភាពពិភពលោកបែបនេះ ក៏នឹងមានផលប៉ះពាល់អវិជ្ជមានចំពោះការចំណាយលើជីវផលិតផលកម្ពុជាផងដែរ ដោយសារតែការកម្រិតកំណត់ទៅលើការប្រកួតប្រជែង។ ការព្យាបាលតាមរបៀបផ្សេងៗ ដែលបានបង្ហាញថាមានសុវត្ថិភាព និងប្រសិទ្ធភាព មិនអាចប្រកួតប្រជែងដណ្តើមយកចំណែកទីផ្សារបានឡើយ ដែលធ្វើឱ្យក្រុមហ៊ុនចែកចាយនៅតែលក់ផលិតផល ដែលមានឈ្មោះនៅក្នុងបញ្ជីក្នុងតម្លៃខ្ពស់ដដែល។ ស្រដៀងគ្នានេះដែរ ដោយសារតែបញ្ជីរបស់អង្គការសុខភាពពិភពលោកបញ្ជាក់ពីកម្រិតដូសចាំបាច់ ដូច្នេះមានតែផលិតផលកំណែប្រែថ្មី ដែលត្រូវនឹងកម្រិតដូសជាក់លាក់នេះប៉ុណ្ណោះនឹងទទួលបានការអនុម័តឱ្យនាំចូលដែលចំណុចនេះនឹងកាត់បន្ថយលទ្ធភាពសម្រាប់មន្ទីរពេទ្យ និងគ្លីនិកក្នុងការទទួលបានតម្លៃប្រកួតប្រជែង និងចំណាយក្នុងការទិញឱសថក្នុងបរិមាណច្រើន។

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យក្រសួងសុខាភិបាលពង្រីកការទទួលយកជីវផលិតផលដាក់ក្នុងផលិតផលដែលអនុម័តដោយរដ្ឋបាលឱសថ និងចំណីអាហារសហរដ្ឋអាមេរិក និង/ឬទីភ្នាក់ងារឱសថអឺរ៉ុប។

*យើងខ្ញុំសូមគោរពស្នើឱ្យក្រសួងសុខាភិបាល ពង្រីកការទទួលយកជីវផលិតផលដាក់ក្នុងផលិតផលដែលអនុម័តសម្រាប់ការនាំចូល ដើម្បីអនុញ្ញាតឱ្យមានការដាក់បញ្ចូលផលិតផលដែលបានទទួលការអនុម័តរួចហើយពី* USFDA *និង/ឬ* EMA។ *ដោយសារតែអង្គការសុខភាពពិភពលោក ដែលមិនមែនជាអង្គភាពនិយ័តកម្មបានយកការវាយតម្លៃរបស់* USFDA *និង* EMA *ជាមូលដ្ឋានសម្រាប់ការអនុម័តបញ្ជីរបស់ខ្លួន ទើបបានជាក្រសួងចាំបាច់ធ្វើការត្រួតពិនិត្យនិយ័តកម្មក្នុងកម្រិតមួយខ្ពស់ដើម្បីធានាថាមានតែផលិតផលមានសុវត្ថិភាព និងប្រសិទ្ធភាពប៉ុណ្ណោះនឹងនាំចូលមកកាន់ប្រទេសកម្ពុជា ហើយទន្ទឹមនឹងនោះក៏បង្កើនការទទួលបានការព្យាបាលថ្មីសម្រាប់អ្នកជំងឺ និងមន្ទីរពេទ្យក៏អាចទាញយកអត្ថប្រយោជន៍ពីយុទ្ធសាស្ត្រសន្សំការចំណាយនេះផងដែរ។*

៤៦

# ការផ្ទេរឱសថមានវេជ្ជបញ្ជាទៅជាឱសថមិនចាំបាច់មានវេជ្ជបញ្ជា

ថ្មី

### ពិពណ៌នាបញ្ហា

*ការប្រើប្រាស់ឱសថដោយខ្លួនឯង ដោយការទិញឱសថមិនចាំបាច់មានវេជ្ជបញ្ជា គឺជាទម្រង់ទូទៅបំផុតនៃការថែទាំវេជ្ជសាស្ត្រនៅទូទាំងពិភពលោក។ ឱសថមិនចាំបាច់មានវេជ្ជបញ្ជា (OTC) អាចឱ្យអ្នកប្រើប្រាស់ទទួលអត្ថប្រយោជន៍ពីជម្រើសព្យាបាលងាយៗជាច្រើនដោយការចំណាយតិច និងដោយមិនចាំបាច់ធ្វើការពិគ្រោះជំងឺជាមួយនឹងគ្រូពេទ្យជំនាញថែទាំសុខភាព។ ដូច្នេះ និន្នាការនេះបានកើនឡើងជាពិសេសនៅក្នុងទីផ្សារអភិវឌ្ឍន៍ដើម្បីបង្កើនលទ្ធភាពទទួលការព្យាបាលថ្មី ដោយធ្វើឱ្យផលិតផលឱសថកាន់តែច្រើនមានដាក់លក់ដោយមិនចាំបាច់មានវេជ្ជបញ្ជា ជាជាងការតម្រូវឱ្យអ្នកជំងឺត្រូវតែមានវេជ្ជបញ្ជា។*

*ការចាត់ចំណាត់ថ្នាក់ជាថ្មីនៃឱសថមានវេជ្ជបញ្ជា ឱ្យទៅជាឱសថមិនចាំបាច់មានវេជ្ជបញ្ជានេះ មិនមែនជារឿងកើតឡើងថ្មីឡើយដោយសារតែបច្ចុប្បន្ននេះ មានការព្យាបាលទូទៅជាច្រើនបានប្រើថ្នាំ ដូចជាប៉ារ៉ាសេតាម៉ុល ថ្នាំ* ibuprofen *និង* antihistamines *ដែលថ្នាំទាំងអស់នេះត្រូវការវេជ្ជបញ្ជាតែម្តងប៉ុណ្ណោះ។ ការចាត់ចំណាត់ថ្នាក់ជាថ្មីធ្វើឡើងនៅពេលដែលអាជ្ញាធរសុខាភិបាល និងក្រុមហ៊ុនឱសថមានការជឿជាក់ថាហានិភ័យដែលអាចកើតមានលើការទទួលបានថ្នាំយ៉ាងទូលំទូលាយនេះមានកម្រិតតិចតួចជាងអត្ថប្រយោជន៍ដែលអ្នកជំងឺនឹងទទួលបាន និងក្រោយមានកំណត់ត្រាតាមដានពីរោគវិនិច្ឆ័យមានសុវត្ថិភាព ការព្យាបាល និងការគ្រប់គ្រងដោយមិនចាំបាច់ត្រូវការការត្រួតពិនិត្យពីវេជ្ជបណ្ឌិត។*

*នៅក្នុងប្រទេសកម្ពុជា មានភាពមិនច្បាស់លាស់មួយចំនួនជុំវិញដំណើរការ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធដើម្បីផ្ទេរឱសថមានវេជ្ជបញ្ជាទៅជាឱសថមិនចាំបាច់មានវេជ្ជបញ្ជា។ ដូច្នេះ វិស័យថែទាំសុខភាពជាច្រើន និងពលរដ្ឋកម្ពុជា នឹងទទួលបានអត្ថប្រយោជន៍ពីដំណើរការបង្កើតផ្លូវការដែលមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់ និងមានសង្គតិភាពសម្រាប់ក្រុមហ៊ុនថែទាំសុខភាពអនុវត្តតាមក្នុងការផ្ទេរផលិតផលមានវេជ្ជបញ្ជាទៅជាផលិតផលមិនចាំបាច់មានវេជ្ជបញ្ជា។*

### ផលប៉ះពាល់លើកម្ពុជា

*អវត្តមាននៃការកំណត់នីតិវិធីច្បាស់លាស់ សម្រាប់ក្រុមហ៊ុនថែទាំសុខភាពក្នុងការផ្ទេរឱសថមានវេជ្ជបញ្ជាទៅជាឱសថមិនចាំបាច់មានវេជ្ជបញ្ជាប្រកបដោយសុវត្ថិភាព បានធ្វើឱ្យអ្នកជំងឺត្រូវចំណាយពេល និងប្រាក់បន្ថែមទៀតលើការពិគ្រោះជំងឺជាមួយនឹងគ្រូពេទ្យជំនាញថែទាំសុខភាព ជាជាងការប្រើការព្យាបាលក្នុងតម្លៃសមរម្យ ដោយប្រើឱសថមិនចាំបាច់មានវេជ្ជបញ្ជាសម្រាប់លក្ខខណ្ឌជាក់លាក់មួយចំនួន ទៅតាមភាពងាយស្រួលផ្ទាល់ខ្លួនរបស់អ្នកជំងឺ។ ស្រដៀងគ្នានេះដែរ ប្រសិនបើអ្នកជំងឺមិនអាចព្យាបាលរោគសញ្ញានៃជំងឺតូចតាចរបស់ខ្លួនបានទេ ករណីនេះនឹងបង្កើនសំពាធយ៉ាងធាប់រហ័សទៅលើប្រព័ន្ធសុខាភិបាលរបស់កម្ពុជា ហើយអ្នកជំងឺដែលមានស្ថានភាពធ្ងន់ធ្ងរពិតប្រាកដមិនអាចទទួលបានសេវា នឹងគ្រូពេទ្យជំនាញ ដោយសារតែធនធានទាំងនោះបានប្រើដោយមិនសមស្របទៅលើបញ្ហាថែទាំសុខភាពមួយចំនួនដែលអ្នកជំងឺអាចធ្វើការថែទាំដោយខ្លួនឯង។*

*ប្រសិនបើវិធីសាស្ត្រព្យាបាលជាច្រើនដោយឱសថ មិនចាំបាច់មានវេជ្ជបញ្ជា មិនអាចវិវត្តឱ្យទាន់នឹងតម្រូវការផ្លាស់ប្តូរថែទាំសុខភាពរបស់កម្ពុជានាពេលនេះទេ ការប្រើប្រាស់មិនស្របច្បាប់នៃឱសថមានវេជ្ជបញ្ជាអាចនឹងកើនឡើង ដោយសារតែអ្នកជំងឺមានជម្រើសតិចតួច និងត្រូវបន្តប្រើផលិតផលឱសថទាំងនេះនៅពេលពួកគាត់ធ្លាក់ខ្លួនឈឺ។ គ្រោះថ្នាក់ដែលទាក់ទងជាមួយឱសថមានវេជ្ជបញ្ជាកើនឡើងយ៉ាងខ្លាំង នៅពេលប្រើខុសច្បាប់ ដោយសារតែជាញឹកញាប់ អ្នកជំងឺមិនបានដឹងអំពីប្រតិកម្មដែលអាចមាន ឬផលប៉ះពាល់គ្រោះថ្នាក់ចំពោះការប្រើឱសថទាំងនោះ។ តាមការប្រៀបធៀប អ្នកជំងឺស្គាល់ឱសថមិនចាំបាច់មានវេជ្ជបញ្ជាមានគ្រោះថ្នាក់តិច ហើយមានប្រសិទ្ធភាពសម្រាប់ស្ថានភាពជំងឺជាក់លាក់មួយចំនួន ដោយសារតែកម្រិតថ្នាំ(ដូស)មានសុវត្ថិភាពជាង និងការបិទផ្លាក់សញ្ញាព័ត៌មាន និងការវេចខ្ចប់កាន់តែទូលំទូលាយដែលផ្តល់ការណែនាំអំពីការប្រើប្រាស់លម្អិតលើរោគសញ្ញាដែលអាចព្យាបាលបាន និងផលប៉ះពាល់ដែលអាចមាន។*

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យបន្ធូរលក្ខណៈវិនិច្ឆ័យស្របច្បាប់ និងដំណើរការពាក់ព័ន្ធនឹងការចាត់ចំណាត់ថ្នាក់ផលិតផលឱសថមានវេជ្ជបញ្ជា ទៅជាផលិតផលឱសថមិនចាំបាច់មានវេជ្ជបញ្ជានៅក្នុងប្រទេសកម្ពុជាដោយស្របតាមការអនុវត្តរបស់អាស៊ាន។

*សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា សូមស្នើឱ្យក្រសួងសុខាភិបាលកំណត់លក្ខណៈវិនិច្ឆ័យ និងដំណើរការឱ្យបានច្បាស់លាស់ សម្រាប់ក្រុមហ៊ុនថែទាំសុខភាពអនុវត្តតាម នៅពេលចាត់ចំណាត់ថ្នាក់ឡើងវិញ នូវផលិតផលឱសថមានវេជ្ជបញ្ជាសម្រាប់ការប្រើប្រាស់ជាផលិតផលមិនចាំបាច់មានវេជ្ជបញ្ជានៅក្នុងប្រទេសកម្ពុជា។ ការធ្វើដូច្នេះ ក្រសួង នឹងអាចឱ្យប្រជាពលរដ្ឋទទួលយកទំនួលខុសត្រូវ កាន់តែល្អច្រើនប្រកបដោយសុវត្ថិភាពក្នុងការគ្រប់គ្រងការថែទាំសុខភាពផ្ទាល់ខ្លួន ដែលការណ៍នេះអាចនាំមកនូវអត្ថប្រយោជន៍សេដ្ឋកិច្ច និងសុខភាពសាធារណៈជាច្រើននៅពេលមានកំណើនស្វ័យព្យាបាល។ ទោះបីជាយ៉ាងណាក៏ដោយ ជាប្រការសំខាន់ដែលត្រូវមានការគ្រប់គ្រងតឹងរ៉ឹងដើម្បីធានាថាមានតែការព្យាបាលដែលសមស្របសម្រាប់ការប្រើឱសថដោយខ្លួនឯងប៉ុណ្ណោះនឹងត្រូវចាត់ចំណាត់ថ្នាក់ជាថ្មី។*

*ដោយទទួលស្គាល់ថាលក្ខណៈវិនិច្ឆ័យសម្រាប់ការចាត់ចំណាត់ជាថ្មីនេះ នឹងផ្អែកលើលក្ខខណ្ឌតម្រូវរបស់ក្រសួងសុខាភិបាល យើងខ្ញុំសូមផ្តល់ជូននូវអនុសាសន៍ថាដំណើរការនេះ គួរតែផ្អែកលើភស្តុតាង និងផ្អែកលើទិន្នន័យឥតលម្អៀង របស់វិស័យថែទាំសុខភាព ដើម្បីបង្ហាញអំពីភាពសមស្របនៃផលិតផលឱសថរបស់ក្រុមហ៊ុនដែលក្រសួងសុខាភិបាលនឹងត្រូវធ្វើការត្រួតពិនិត្យឡើងវិញដោយផ្អែកលើគោលការណ៍ សុវត្ថិភាព និងប្រសិទ្ធភាព។*

៤៧

# ការទប់ស្កាត់ការនាំចូលផលិតផលឱសថមិនបានចុះបញ្ជិកា

ធ្វើបច្ចុប្បន្នភាព

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើឱ្យអនុវត្តវិធានការបន្ថែមដើម្បីទប់ស្កាត់ការនាំចូលដោយលួចលាក់នូវផលិតផលឱសថ។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*តាមរយៈលិខិតផ្ញើជូនសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែសីហា ឆ្នាំ២០១៨ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង បានបញ្ជាក់ជាថ្មីអំពីគោលជំហររបស់ក្រសួងសុខាភិបាល លើភាពស្របច្បាប់នៃផលិតផលឱសថនាំចូលលួចលាក់មកកាន់ប្រទេសកម្ពុជា។ ដោយសារតែបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលមិនអនុញ្ញាតឱ្យក្រុមហ៊ុនឱសថទទួលសិទ្ធិផ្តាច់មុខក្នុងការនាំចូលផលិតផលឱសថមកកាន់ប្រទេសកម្ពុជាឡើយ ដូច្នេះ ក្រសួងយល់ឃើញថា PARALLEL IMPORTS គឺជាការនាំចូលស្របច្បាប់។*

*នាយកដ្ឋាននេះបានបញ្ជាក់ទៀតថាក្នុងករណីដែលក្រសួងបានចេញអាជ្ញាប័ណ្ណឱ្យ ពីព្រោះដោយសារតែផលិតនោះបានទទួលសិទ្ធិស្របច្បាប់ឱ្យចូលក្នុងទីផ្សារនេះរួចហើយសម្រាប់ការចែកចាយ នឹងត្រូវបានអនុញ្ញាតឱ្យនាំចូលមកកាន់ប្រទេសកម្ពុជាដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ។ នាយកដ្ឋានបានអះអាងថា នេះមានន័យថាផលិតផលទាំងនោះត្រូវបានវេចខ្ចប់បានសមស្រប នឹងបានបង់ពន្ធ ដែលក្រសួងបានចុះត្រួតពិនិត្យផ្ទៀងផ្ទាត់តាមរយៈការធ្វើអធិការកិច្ចជាទៀងទាត់ទៅលើឱសថស្ថាននានា។*

*សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាបន្តបញ្ជាក់ថាកង្វល់ចម្បងអំពីបញ្ហានេះនៅតែមានដដែល ដោយហេតុផលធានានូវការនាំចូលតែផលិតផលឱសថដែលមានគុណភាពខ្ពស់ ហើយសំខាន់ជាងនេះទៅទៀតនោះគឺផលិតផលឱសថមានសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋកម្ពុជា។ សមាជិករបស់យើងយល់ឃើញថា ដោយយោងតាមក្របខ័ណ្ឌបច្ចុប្បន្ន បញ្ហានេះមិនអាចមានការធានាបានឡើយប្រសិនបើមិនមានវិធានការតឹងរ៉ឹងទេនោះ។ ស្របជាមួយគ្នានេះដែរ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាបន្តស្នើសុំឱ្យមានការអនុវត្តវិធានការបន្ថែមដើម្បីរឹតបន្តឹងការនាំចូលផលិតផលឱសថដោយមិនបានចុះបញ្ជិកាមកកាន់ប្រទេសកម្ពុជាដើម្បីធានានូវសុវត្ថិភាពសម្រាប់អ្នកជំងឺ។*

**ពិពណ៌នាបញ្ហា**

*កម្ពុជាមាននីតិវិធីតឹងរ៉ឹងសម្រាប់ការចុះបញ្ជិកាផលិតផលឱសថដែលត្រូវមានការបញ្ជាក់លក្ខណៈបច្ចេកទេសលម្អិតទាំងនៅលើផលិតផល និងការវេចខ្ចប់ដើម្បីធានានូវសុវត្ថិភាព ប្រសិទ្ធភាព និងគុណភាពរបស់ផលិតផល។ យោងតាមច្បាប់ មានតែផលិតផលដែលអាចបំពេញតាមយថាប្រភេទផ្នែកបច្ចេកទេស ដែលបានចុះបញ្ជិកានៅក្រសួងសុខាភិបាលប៉ុណ្ណោះ ដែលអាចនាំចូលមកកាន់ប្រទេសកម្ពុជាបាន។ ទោះបីជាមានការចែងដោយច្បាប់បែបនេះក្តី មានក្រុមហ៊ុនចែកចាយឱសថមួយចំនួនដែលបញ្ចៀសការបំពេញតាមលក្ខខណ្ឌតម្រូវទាំងនេះ ដោយបាននាំចូលផលិតផលទាំងនោះដោយបន្លំលេខបញ្ជិការបស់ក្រុមហ៊ុនចែកចាយមានសិទ្ធិស្របច្បាប់ ឬផលិតផលដែលបញ្ចៀសការចុះបញ្ជិកា និងធ្វើតេស្តទាំងស្រុង។ ដោយសារតែផលិតផលទាំងនេះមិនបានទទួលការអនុញ្ញាតឱ្យនាំចូលពីក្រសួង ដូច្នេះផលិតផលទាំងនោះគួរតែត្រូវបានចាត់ទុកជាខុសច្បាប់ប្រសិន បើមានលក់នៅក្នុងប្រទេសកម្ពុជា។*

*ទោះបីជានៅក្នុងករណីខ្លះ ផលិតផលមិនបានចុះបញ្ជិកាទាំងនេះអាចមានប្រភពចេញពីក្រុមហ៊ុនផលិត ដែលមានសិទ្ធិអនុញ្ញាត និងអាចបំពេញតាមយថាប្រភេទបច្ចេកទេសផលិតផលក្តី ក៏ផលិតផលទាំងនោះអាចផ្តល់ហានិភ័យដល់សុខភាពនៅពេលដឹកជញ្ជូនដោយក្រុមហ៊ុនក្រៅផ្លូវការចូលមកកម្ពុជា។ ក្រុមហ៊ុនឱសថពហុជាតិគិតគូរដល់លក្ខខណ្ឌអាកាសធាតុនៅពេលរៀបចំរចនាបទវេចខ្ចប់ផលិតផលទាំងនោះ និងកែសម្រួលការវេចខ្ចប់ផលិតផលជាទៀងទាត់សម្រាប់ប្រទេសជាក់លាក់ដើម្បីធ្វើការការពារបន្ថែមទៀត។ កម្ពុជាមានអាកាសធាតុត្រូពិក ហើយឱសថស្ថានជាច្រើននៅក្នុងប្រទេសកម្ពុជាមិនមានយន្តការគ្រប់គ្រងអាកាសធាតុដែលតម្រូវឱ្យមានការវេចខ្ចប់សមស្របដើម្បីការពារកុំឱ្យផលិតផលឱសថទាំងនោះខូចដោយសារតែកម្តៅសីតុណ្ហភាព។ ផ្ទុយទៅវិញ ផលិតផលដែលនាំពីអឺរ៉ុបនឹងមានការវេចខ្ចប់សមស្របសម្រាប់បរិយាកាសនៅអឺរ៉ុបដែលអាចមិនទាន់គ្រប់គ្រាន់ និងមិនសមស្របសម្រាប់បរិកាសនៅក្នុងប្រទេសកម្ពុជា។ ដើម្បីធានាថាផលិតផលទាំងនោះត្រូវបានដឹកជញ្ជូន និងរក្សាស្តុកទុកតាមលក្ខខណ្ឌត្រឹមត្រូវ រោងចក្រផលិតបានតម្រូវឱ្យក្រុមហ៊ុនចែកចាយរបស់ខ្លួនធ្វើការត្រួតពិនិត្យឱ្យបានហ្មត់ចត់ និងមានដំណើរការជ្រើសរើសត្រឹមត្រូវ។ ក្រុមហ៊ុនចែកចាយដែលដឹកផលិតផលដោយមិនមានការចាត់តាំងពីក្រុមហ៊ុនផលិត នឹងមិនធ្វើការត្រួតពិនិត្យបែបនោះទេ ហើយមិនអាចធានាថាផលិតផលនឹងមានសុវត្ថិភាពឡើយនៅពេលផលិតផលទាំងនោះធ្លាក់ដល់ដៃរបស់អ្នកជំងឺ។*

*ទិដ្ឋភាពសំខាន់ផ្សេងទៀតនៃសុវត្ថិភាពឱសថគឺជាប្រតិកម្មរំខានរបស់ឱសថ (ហ្វាម៉ាកូវីជីឡង់) ដែលក្រុមហ៊ុនផលិតនឹងត្រូវបានជូនដំណឹងក្នុងករណីដែលមានបញ្ហាណាមួយដែលផលប៉ះពាល់ដោយសារតែឱសថដែលកំពុងលក់នៅលើទីផ្សារ។ ប្រតិកម្មរំខានរបស់ឱសថ (ហ្វាម៉ាកូវីជីឡង់) នេះ គឺជាផលអវិជ្ជមានដែលកើតឡើងដោយសារតែការប្រើឱសថរបស់អ្នកជំងឺ ហើយក្រុមហ៊ុនចែកចាយត្រូវប្រាប់ដល់រោងចក្រផលិតដើម្បីចាត់វិធានការប្រុងប្រយ័ត្នជាមុនក្នុងការធានាសុវត្ថិភាពដល់អ្នកជំងឺ។ ទោះបីយ៉ាងណាក៏ដោយ ដោយសារតែក្រុមហ៊ុនចែកចាយផលិតផលមិនបានចុះបញ្ជិកាមិនទទួលបានការចាត់តាំងពីក្រុមហ៊ុនផលិត ក្រុមហ៊ុនទាំងនោះមិនអាចជូនដំណឹងដល់រោងចក្រអំពីបញ្ហាប៉ះពាល់ទាំងនោះបានឡើយ ហេតុដូច្នេះ គ្រោះថ្នាក់ដែលកើតចេញពីឱសថទាំងនោះនឹងនៅតែបន្តមាននៅពេលចែកចាយ ដោយសារតែមិនមានការគ្រប់គ្រងដើម្បីធានាសុវត្ថិភាពសម្រាប់អ្នកជំងឺ។*

*គណៈកម្មាធិការសុខាភិបាលនៃសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា បានគាំទ្រយ៉ាងខ្លាំងក្លាទៅលើការព្យាបាលក្នុងតម្លៃសមរម្យ ដែលអ្នកជំងឺអាចមានលទ្ធភាពទទួលបាន។ ដំណោះស្រាយដើម្បីមានឱសថក្នុងតម្លៃសមរម្យនៅកម្ពុជា គឺបង្កើនបរិយាកាសប្រកួតប្រជែងតាមរយៈការផ្តល់ជម្រើសព្យាបាលខុសៗគ្នាពីរោងចក្រផលិតជាច្រើន ដែលមានការកំណត់តម្លៃផ្សេងៗគ្នា។ ផ្ទុយមកវិញ ផលិតផលមិនបានចុះបញ្ជិកាមិនមែនជាដំណោះស្រាយយូរអង្វែងសម្រាប់បញ្ហាតម្លៃសមរម្យឡើយ ដោយសារតែផលិតផលទាំងនោះអាចចូលទីផ្សារក្នុងតម្លៃទាប ពីព្រោះផលិតផលទាំងនោះមិនបានធ្វើតេស្តនៅមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល និងដំណើរការត្រួតពិនិត្យលើប្រតិកម្មរំខានរបស់ឱសថ (ហ្វាម៉ាកូវីជីឡង់) របស់រោងចក្រផលិតឡើយ។*

*ទោះបីជាយើងខ្ញុំទទួលស្គាល់ថា បទប្បញ្ញត្តិដែលមានស្រាប់របស់កម្ពុជា មិនអនុញ្ញាតឱ្យក្រុមហ៊ុនចែកចាយនូវសិទ្ធិចែកចាយផលិតផលឱសថផ្ដាច់មុខក៏ដោយ ប៉ុន្តែយើងខ្ញុំយល់ដឹងថា បទប្បញ្ញត្តិទាំងនេះក៏មិនអនុញ្ញាតឱ្យមានការនាំចូលផលិតផលដែលខុសពីផលិតផលឱសថ ដែលបានចុះបញ្ជិកាផងដែរ។ ក្រុមហ៊ុនចែកចាយផលិតផលឱសថត្រូវដាក់ពាក្យសុំធ្វើការផ្លាស់ប្តូរនៅពេលមានការកែសម្រួលទៅលើផលិតផលឱសថដែលបានចុះបញ្ជិការួចដើម្បីធានានូវភាពត្រឹមត្រូវនៃព័ត៌មានលម្អិតដែលបានចុះបញ្ជិកា និងធានាថាផលិតផលដែលស្នើសុំផ្លាស់ប្ដូរនោះគឺមានសុវត្ថិភាព។ការស្វែងរកនៅមានកម្រិតនូវផលិតផលមិនបានចុះបញ្ជីកាដែលបានហូរចូលមកក្នុងទីផ្សារកម្ពុជា បានបង្កើតឱ្យមានភាពងាយរងគ្រោះដល់ខ្សែសង្វាក់ចែកចាយស្របច្បាប់។ អាស្រ័យហេតុនេះ អត្រានាំចូលផលិតផលឱសថក្លែងក្លាយនិងអន់គុណភាពមកកម្ពុជា គឺមានកម្រិតខ្ពស់ខ្លាំងគួរឱ្យព្រួយបារម្ភ ហើយទំនុកចិត្តលើគុណភាពភាពឱសថក៏នឹងថយចុះផងដែរ ដោយសារតែមិនមានប្រព័ន្ធត្រួតពិនិត្យដើម្បីបញ្ជាក់ថាសមាសធាតុផ្សំសកម្មត្រូវនឹងអ្វីដែលអ្នកលក់អះអាង។*

## ផលប៉ះពាល់លើកម្ពុជា

*ក្ដីកង្វល់ចម្បងរបស់យើងខ្ញុំលើបញ្ហានេះ គឺជាសុវត្ថិភាពអ្នកជំងឺជាជាងផលប៉ះពាល់មកលើប្រាក់ចំណូលរបស់ក្រុមហ៊ុនចែកចាយមានសិទ្ធិស្របច្បាប់។ ផលិតផលឱសថមិនបានចុះបញ្ជិកាមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ចំពោះសុខភាពរបស់ប្រជាជនកម្ពុជាដោយសារតែមិនមានមធ្យោបាយធានាគុណភាពផលិតផលទាំងអស់នោះ។ អ្នកប្រើប្រាស់ទូទៅ មិនមានចំណេះដឹងបច្ចេកទេសក្នុងការកំណត់ដឹងថាតើផលិតផលឱសថណាខ្លះដែលខូចគុណភាព ឬខូចគុណភាពដោយសារតែការដឹកជញ្ជូនឬការវេចខ្ចប់មិនសមស្រប ដូច្នេះ ទំនួលខុសត្រូវទាំងអស់នេះត្រូវធ្លាក់មកលើនិយ័តករដែលត្រូវផ្ដល់ការធានាគុណភាពតាមរយៈការគ្រប់គ្រងការនាំចូលទាំងអស់ឱ្យមានមានប្រសិទ្ធភាព។*

*ក្នុងករណីដែលផលិតផលមិនបានចុះបញ្ជិកា ត្រូវបានចាត់ទុកថាជាផលិតផលស្របច្បាប់ ក្រុមហ៊ុនផលិតកម្មអាចនឹងបានចុះបញ្ជិកាលើការលក់រួចរាល់ហើយនៅក្នុងប្រទេសផ្សេងទៀត ដូច្នេះមិនគួរមានបញ្ហាខាតបង់ផ្នែកហិរញ្ញវត្ថុដោយសារតែការនាំចូលមិនបានចុះបញ្ជិកាស្របច្បាប់ឡើយ។ ទោះបីយ៉ាងណាក៏ដោយនៅក្នុងរយៈពេលវែង វត្តមានផលិតផលមិនបានចុះបញ្ជិកាកាន់តែច្រើន នៅក្នុងទីផ្សារនឹងបង្អាក់ដល់ការវិនិយោគ ពីសំណាក់ក្រុមហ៊ុនឱសថពហុជាតិ មកលើសេដ្ឋកិច្ចក្នុងស្រុក។ ប្រសិនបើ ក្រុមហ៊ុនបុត្រសម្ព័ន្ធនៅកម្ពុជា មិនអាចសម្រេចបានលទ្ធផលហិរញ្ញវត្ថុ ល្អប្រសើរដោយសារតែបញ្ហាគ្រប់គ្រងលើការនាំចូលមានភាពធូររលុងនោះក្រុមហ៊ុនទាំងនេះមិនអាចទទួលបានជំនួយថវិកាពីម្ចាស់ជំនួយសម្រាប់សកម្មភាពនានា ដូចជា ការអប់រំ និងការបណ្ដុះបណ្ដាលសម្រាប់អ្នកជំងឺ និងគ្រូពេទ្យជំនាញថែទាំសុខភាពឡើយ។*

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យផ្ដល់អាទិភាពលើការបង្កើតកិច្ចសម្របសម្រួលអន្តរក្រសួងរវាងក្រសួងសុខាភិបាល និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដើម្បីអនុវត្តវិធានការបន្ថែមទៀត ក្នុងការទប់ស្កាត់ការនាំចូលផលិតផលឱសថ ដែលមិនបានចុះបញ្ជិកា និងមិនបានធ្វើតេស្តមកកាន់ទីផ្សារកម្ពុជា។

*យើងខ្ញុំសូមលើកទឹកចិត្តឱ្យក្រសួងសុខាភិបាល បង្កើតកិច្ចសហការជិតស្និទ្ធជាមួយអគ្គនាយកដ្ឋានគយ និងរដ្ឋាករដើម្បីចាត់វិធានការបុរេសកម្ម ក្នុងការកំណត់ និងទប់ស្កាត់ការនាំចូលផលិតផលឱសថមិនបានចុះបញ្ជិកាមកកាន់ប្រទេសកម្ពុជា និងជូនដំណឹងដល់ក្រុមហ៊ុនចែកចាយផ្ដាច់មុខដែលចែកចាយផលិតផលឱសថចុះបញ្ជិកាត្រឹមត្រូវស្របច្បាប់ អំពីករណីឱសថមិនបានចុះបញ្ជិកានេះ ឱ្យបានដឹងផងដែរ។ វិធានការដែលនឹងសម្របសម្រួលកិច្ចសហការនេះរួមមាន៖*

- *ធានាថាក្រសួងសុខាភិបាលនឹងចេញអាជ្ញាប័ណ្ណនាំចូល សម្រាប់ផលិតផលឱសថនៅក្នុងតែករណី ផលិតផលទាំងនោះ ស្របគ្នាជាមួយនឹង យថាប្រភេទបច្ចេកទេសបានចុះបញ្ជិកា និងហាមមិនឱ្យនាំចូលដោយបុគ្គល ឬក្រុមហ៊ុនដែលនឹងរំលោភលើសិទ្ធិរបស់ក្រុមហ៊ុនចែកចាយដែលបានចុះបញ្ជិកា។ ដើម្បីអនុវត្តគោលការណ៍នេះប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យមានកម្មវិធីតាមប្រព័ន្ធអេឡិចត្រូនិកអន្តរក្រសួងដើម្បីចែករំលែកព័ត៌មាន និងឯកសារជាធរមាននានា។*

- *ផ្ដល់សិទ្ធិអនុញ្ញាតងាយស្រួល ក្នុងការចូលមើលព័ត៌មានអំពីយថាប្រភេទបច្ចេកទេសចុះបញ្ជិកា ផលិតផលឱសថដល់មន្ត្រីគយ រួមមានដូចជា ព័ត៌មានអំពីការវេចខ្ចប់និងលក្ខណៈសម្គាល់រូបភាព (ARTWORK) ដើម្បីឱ្យមន្ត្រីគយមានភាពងាយស្រួលក្នុងការត្រួតពិនិត្យរកភាពខុសគ្នារវាងយថាប្រភេទបច្ចេកទេសរបស់ផលិតផលឱសថដែលបានចុះបញ្ជិកា និងទំនិញផ្សេងៗទៀតដែលកំពុងនាំចូលមកកម្ពុជា។*

- *ចុះត្រួតពិនិត្យឱ្យបានទៀងទាត់តាមឱសថស្ថាន និងលក្ខខណ្ឌស្តុកទុកផលិតផលឱសថទាំងនោះតាមរយៈអាជ្ញាធរមានសមត្ថកិច្ច និងមានសិទ្ធិអនុញ្ញាត ព្រមទាំងធ្វើការរឹបអូសផលិតផលដែលមិនត្រូវគ្នាជាមួយនឹងយថាប្រភេទបច្ចេកទេសដែលបានចុះបញ្ជិកាដើម្បីជំរុញឱ្យឱសថស្ថាននានាកាន់តែបង្កើនការប្រុងប្រយ័ត្នកាន់តែខ្លាំងឡើងចំពោះប្រភពផ្គត់ផ្គង់ផលិតផលឱសថរបស់ខ្លួន។*

៤៨

# ការប្រាស្រ័យទាក់ទងគ្នារវាងវិស័យសាធារណៈ និងឯកជន

**ធ្វើបច្ចុប្បន្នភាព**

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើឱ្យបង្កើតវេទិកាវិស័យរដ្ឋ និងឯកជនជាផ្លូវការសម្រាប់វិស័យសុខាភិបាល ធ្វើការផ្សព្វផ្សាយព័ត៌មានផ្លូវច្បាប់ដែលមានពាក់ព័ន្ធនឹងវិស័យសុខាភិបាលឱ្យកាន់តែល្អប្រសើរ និងទូលំទូលាយថែមទៀត និងស្នើឱ្យធ្វើការពិចារណាបង្កើតវេទិកាសន្ទនារវាងវិស័យរដ្ឋអន្តរក្រសួង និងឯកជនដោយផ្តោតជាសំខាន់លើការនាំចូលលួចលាក់នូវផលិតផលឱសថ។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*តាមរយៈលិខិតផ្ញើមកសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែសីហា ឆ្នាំ២០១៨ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង បានឆ្លើយតបចំពោះសំណើរបស់យើងខ្ញុំឱ្យបង្កើតវេទិកាវិស័យសាធារណៈ និងឯកជនជាផ្លូវការសម្រាប់វិស័យសុខាភិបាល និងបានណែនាំថា ក្រុមហ៊ុនគួរដាក់លិខិតផ្លូវការមកថ្នាក់ដឹកនាំក្រសួងសុខាភិបាល ដោយសារតែនាយកដ្ឋានមិនមានសិទ្ធិសម្រេចក្នុងការបង្កើតយន្តការនេះទេ។ ជាបច្ច័យល្អ នៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (G-PSF) ដែលដឹកនាំដោយសម្តេចនាយករដ្ឋមន្ត្រីកាលពីខែមីនា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានប្រកាសអំពីការពង្រីកក្រុមការងារនៃវេទិកាពជរដ្ឋាភិបាល-ផ្នែកឯកជន ដោយបានដាក់បញ្ចូលក្រុមការងារវិស័យសុខាភិបាល វិស័យអប់រំ និងវិស័យសំណង់។ នាយកដ្ឋាននេះក៏បានបញ្ជាក់ផងដែរថា បច្ចុប្បន្ននេះ ក្រសួងកំពុងរៀបចំបង្កើតកម្មវិធីការចុះបញ្ជិកាឱសថតាមប្រព័ន្ធអនឡាញ (E-Registration និង E-importation) ដើម្បីគ្រប់គ្រងបញ្ជិកាផលិតផលឱសថ និងការនាំចូលផលិតផលទាំងនេះតាមរយៈប្រព័ន្ធអេឡិចត្រូនិក ដោយមានការឧបត្ថម្ភ និងគាំទ្រពីអង្គការសុខភាពពិភពលោក។*

**ពិពណ៌នាបញ្ហា**

*មាននិន្នាការកើនឡើង នៅក្នុងក្រសួងមួយចំនួននៅកម្ពុជា ក្នុងការធ្វើទំនើបកម្មដំណើរការ និងប្រព័ន្ធគ្រប់គ្រងរបស់ខ្លួនដោយផ្តល់សេវាកម្មតាមប្រព័ន្ធឌីជីថលដោយការបង្កើតកម្មវិធីអនឡាញ ដូចមានបង្ហាញដោយ ប្រព័ន្ធគ្រប់គ្រងមជ្ឈការ កម្មករបរទេសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងការចុះបញ្ជី ពាណិជ្ជកម្មតាមប្រព័ន្ធអនឡាញរបស់ក្រសួងពាណិជ្ជកម្ម។ ការអនុវត្តប្រកបដោយប្រសិទ្ធភាព នៃកម្មវិធីតាមប្រព័ន្ធអនឡាញនេះបានលើកកម្ពស់ប្រសិទ្ធផលច្រើន និង កាត់បន្ថយតម្រូវការធនធានរបស់រាជរដ្ឋាភិបាល ហើយក៏បង្កើនគុណភាពសេវាកម្មតាមរយៈការធ្វើស្វ័យប្រវត្តិកម្មផងដែរ។*

*នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង បានបញ្ជាក់មកសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ក្នុងកិច្ចប្រជុំនៅខែកក្កដា ឆ្នាំ២០១៨ និងតាមរយៈលិខិតឆ្លើយតបមកថា ក្រសួងកំពុងរៀបចំបង្កើតកម្មវិធីតាមប្រព័ន្ធអ៊ីនធឺណិតផ្ទាល់ ដើម្បីគ្រប់គ្រងលើដំណើរការចុះបញ្ជិកា និងការនាំចូលផលិតផលវេជ្ជសាស្ត្រមកកាន់ប្រទេសកម្ពុជា ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក ដែលហៅថាប្រព័ន្ធចុះបញ្ជិកាតាមអនឡាញ* (E-Registration) *និងប្រព័ន្ធនាំចូលតាមអនឡាញ* (E-Importation)*។ វិស័យឯកជនដែលមានអនុលោមភាព សូមស្វាគមន៍យ៉ាងកក់ក្តៅ*

*ចំពោះការវិវត្តនេះ ដោយសារយើងខ្ញុំរំពឹងទុកថា កម្មវិធីអនឡាញនេះនឹងជួយសម្រួលដល់ដំណើរការនិយ័តកម្មជាច្រើនផ្សេងទៀត។*

*បច្ចុប្បន្ននេះ ក្រុមហ៊ុនថែទាំសុខភាពដែលរង់ចាំការចុះបញ្ជិកាថ្មី ឬការបន្តសុពលភាពបញ្ជិកា មិនទទួលបានអត្ថប្រយោជន៍ពីកម្មវិធីណាមួយឡើយដើម្បីធ្វើការតាមដានវឌ្ឍនភាពនៃការដាក់ពាក្យសុំរបស់ខ្លួន នេះមានន័យថា ទោះបីជាក្រសួងមានគោលបំណងដំណើរការចុះបញ្ជិកាក្នុងរយៈពេល ៦ខែ ក្តី ប៉ុន្តែជាក់ស្តែងដំណើរការនេះអាចចំណាយពេលយូរជាងនេះ ដោយសារតែបញ្ហារៀបចំឯកសារ។ បញ្ហានេះផ្តល់ផលប៉ះពាល់អវិជ្ជមានដល់ដំណើរការរបស់ក្រុមហ៊ុនថែទាំសុខភាពជាច្រើន ដោយសារតែការពន្យារពេលយូរចំពោះដំណើរការចុះបញ្ជិកាបានបង្អាក់លទ្ធភាពរបស់ក្រុមហ៊ុនទាំងនោះក្នុងការនាំចូល ឬចែកចាយផលិតផលនៅក្នុងប្រទេសកម្ពុជា។*

*ដោយទទួលស្គាល់ថា ការបង្កើតកម្មវិធីតាមប្រព័ន្ធអនឡាញ ជាគម្រោងដ៏សំខាន់សម្រាប់ក្រសួងដែលតម្រូវឱ្យមានធនធានច្រើនដើម្បីបង្កើត និងអនុវត្តប្រកបដោយភាពជោគជ័យតាមគោលបំណងនោះ យើងខ្ញុំយល់ឃើញថា ក្រសួងសុខាភិបាលចាំបាច់គួរផ្តល់អាទិភាពលើការបង្កើតគម្រោងអនឡាញដើម្បីធានាថាគម្រោងនេះនឹងមិនមានដំណើរការយឺតជាងការគ្រោងទុក។*

**ផលប៉ះពាល់លើកម្ពុជា**

*ការអនុវត្តទាន់ពេលវេលា នៃកម្មវិធីតាមប្រព័ន្ធអនឡាញ នឹងបង្ហាញពីការប្តេជ្ញាចិត្តរបស់ក្រសួងសុខាភិបាលក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មី ដើម្បីជំរុញការចូលរួមជាមួយវិស័យឯកជន។ ប្រសិនបើគ្មានប្រព័ន្ធទំនើបបែបនេះទេ រូបវន្តបុគ្គល និងក្រុមហ៊ុនធុរកិច្ចអាចទទួលបានព័ត៌មានពីរាជរដ្ឋាភិបាល និងសេវានានាបានលុះត្រាតែមកកាន់ស្ថាប័នដោយផ្ទាល់នៅក្នុងម៉ោងធ្វើការដែលធ្វើឱ្យមានការពន្យារពេលយូរ និងអាចផ្តល់ផលអវិជ្ជមានដល់ដំណើរការអនុវត្ត និងប្រសិទ្ធភាពរបស់ក្រសួង។ ជាលទ្ធផល បញ្ហានេះអាចកាត់បន្ថយគុណភាពក្នុងការផ្តល់សេវា ដោយសារតែបញ្ហាធនធានមានកម្រិត ក្នុងការគ្រប់គ្រងលើកំណើនសំណើសុំសេវា ដែលអាចនឹងប៉ះពាល់ដល់ការយល់ឃើញលើសេវាសាធារណៈនៅកម្ពុជារបស់វិស័យឯកជន។*

*មូលហេតុសំខាន់ ដែលធ្វើឱ្យមានការពន្យារពេលនិយ័តកម្មយូរ នៅក្នុងវិស័យសុខាភិបាលនេះក៏អាចរួមចំណែកពីបញ្ហាអសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការតាមដានការគ្រប់គ្រង ឬការឆ្លើយតបចំពោះបញ្ហាដែលបានកើតឡើងនៅពេលខ្លួនដាក់ពាក្យស្នើសុំផងដែរ។ ប្រសិនបើបញ្ហានេះនៅតែបន្តកើតមាន កត្តានេះអាចនឹងរារាំងដល់ការវិនិយោគបន្ថែមទៀត និងបន្ថយគុណភាពសេវាសុខាភិបាលនៅកម្ពុជា ដោយសារតែអ្នកជំងឺ និងគ្រូពេទ្យជំនាញថែទាំសុខភាព នឹងត្រូវជួបឧបសគ្គក្នុងការប្រើប្រាស់វិធីសាស្ត្រព្យាបាលថ្មី និងទំនើប ពីព្រោះក្រុមហ៊ុនមិនអាចយកការព្យាបាលទាំងនោះធ្វើទីផ្សារមានប្រសិទ្ធភាពនោះទេ។*

- ✓ សូមស្នើឱ្យផ្តល់អាទិភាពលើការអនុវត្តប្រព័ន្ធចុះបញ្ជិកាតាមអនឡាញ (E-Registration) និងប្រព័ន្ធនាំចូលតាមអនឡាញ (E-Importation) របស់ក្រសួងសុខាភិបាល និងឱ្យវិស័យឯកជនចូលរួមនៅក្នុងដំណើរការនៃការបង្កើតកម្មវិធីទាំងនេះ។

## អនុសាសន៍ឆ្នាំ ២០១៩

*ការបញ្ជាក់របស់ក្រសួងសុខាភិបាល ដែលថាខ្លួនកំពុងរៀបចំបង្កើតប្រព័ន្ធចុះបញ្ជិកាតាមអនឡាញ* (E-Registration) *និង* (E-Importation) *ទទួលបានការស្វាគមន៍យ៉ាង កក់ក្តៅពីវិស័យឯកជនដែលមានអនុលោមភាព។ យើងខ្ញុំសង្ឃឹមថា ដំណើរការនេះនឹងជំរុញឱ្យមានតម្លាភាព សុក្រឹតភាព និងការផ្សព្វផ្សាយព័ត៌មានរវាងរាជរដ្ឋាភិបាល និងក្រុមហ៊ុនធុរកិច្ចកាន់តែល្អប្រសើរ ដោយសារតែការធ្វើស្វ័យប្រវត្តិកម្មសេវាទាំងនេះនឹងលុបបំបាត់នូវភាពមិនច្បាស់លាស់លើបញ្ហានិយ័តកម្ម និងកាត់បន្ថយឱកាសសម្រាប់ការអនុវត្តមិនមានតម្លាភាព។ អាស្រ័យហេតុនេះ យើងខ្ញុំសូមលើកទឹកចិត្តដល់ក្រសួងសុខាភិបាល មេត្តាផ្តល់អាទិភាពលើការអនុវត្តកម្មវិធីតាមប្រព័ន្ធអនឡាញនេះដើម្បីកុំឱ្យមានការពន្យារពេលយូរទៀត។*

*ខណៈពេលដែលយើងខ្ញុំ ទទួលស្គាល់សមិទ្ធផលសម្រេចបានរបស់ក្រសួងកន្លងមក យើងខ្ញុំសូមផ្តល់ជូនអនុសាសន៍ឱ្យក្រសួងធ្វើការពិគ្រោះយោបល់ជាមួយនឹងវិស័យឯកជននៅដំណាក់កាលបង្កើត និងធ្វើតេស្តកម្មវិធីតាមប្រព័ន្ធអនឡាញទាំងនោះ ដើម្បីពិចារណាលើកង្វល់របស់ក្រុមហ៊ុនឯកជន។ ការណ៍នេះនឹងធានាដល់ការផ្តល់ប្រព័ន្ធមានប្រសិទ្ធភាពដែលបំពេញតាមតម្រូវការរបស់រាជរដ្ឋាភិបាល និងគ្រូពេទ្យជំនាញថែទាំសុខភាពក្នុងការបំពេញតាមតម្រូវការរបស់អ្នកជំងឺ។*

*គណៈកម្មាធិការសុខាភិបាលនៃសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ត្រៀមខ្លួនរួចជាស្រេចដើម្បីផ្តល់ការគាំទ្រដល់ក្រសួង នៅពេលក្រសួងអនុវត្តគម្រោងសំខាន់នេះ ហើយនឹងសូមស្វាគមន៍ឱកាសធ្វើតេស្ត និងផ្តល់មតិត្រឡប់ចំពោះកម្មវិធីនេះដោយយោងតាមស្ថានភាពប្រើប្រាស់ជាក់ស្តែង។*

៤៩

# ការចុះបញ្ជិកាឧបករណ៍បរិក្ខារពេទ្យជាក្រុម

ថ្មី

**ពិពណ៌នាបញ្ហា**

*ដូចបានរៀបរាប់លម្អិតពីមុនរួចហើយ នីតិវិធីជុំវិញការចុះបញ្ជិកាផលិតផលវេជ្ជសាស្ត្រ អាចត្រូវធ្វើការត្រួតពិនិត្យឡើងវិញ ដើម្បីកាត់បន្ថយបញ្ហារាំងស្ទះ ផ្នែករដ្ឋបាលដែលកំពុងប៉ះពាល់ដល់វិស័យសុខាភិបាលនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ ជាពិសេស បញ្ហានេះកើតឡើងចំពោះក្រុមហ៊ុនចែកចាយឧបករណ៍បរិក្ខារពេទ្យ ដែលតម្រូវឱ្យចុះបញ្ជិកាលើការផ្លាស់ប្តូរផលិតផលផ្សេងៗ និងសមាសធាតុផលិតផលដូចគ្នា ឱ្យទៅជាការចុះបញ្ជិកាដាច់ដោយឡែកពីគ្នា។ បញ្ហានេះបង្កឱ្យមានការបង្កើន ចំណាយច្រើនទៅលើការនាំយកឧបករណ៍ថ្មីៗចូលមកទីផ្សារ និងធនធានជាច្រើនដែលត្រូវប្រើដើម្បីដាក់ពាក្យសុំចុះបញ្ជិកានេះ។*

*ឧទាហរណ៍ នៅពេលក្រុមហ៊ុនចែកចាយមួយ ចុះបញ្ជិកាឧបករណ៍ប្រើប្រាស់មួយ ដូចជា ឧបករណ៍ផ្សាំក្នុងខ្លួនមនុស្ស* (implant) *ដែលតម្រូវមានទំហំច្រើនជម្រើស ដើម្បីបំពេញតាមតម្រូវការ របស់អ្នកជំងឺម្នាក់ៗ ប៉ុន្តែម៉ានមុខផ្ការដូចគ្នាដដែល ពេលខ្លះ ក្រសួងសុខាភិបាលតម្រូវឱ្យមានការផ្លាស់ប្តូរឧបករណ៍នីមួយៗ ត្រូវចុះបញ្ជិកាដាច់ដោយឡែកពីគ្នា។ នេះគឺជាក្តីកង្វល់ខ្លាំងសម្រាប់ក្រុមហ៊ុនចែកចាយ ឧបករណ៍បរិក្ខារសង្គ្រោះជីវិត ដូចជា បំពង់សិកបញ្ចូលក្នុងសរសៃឈាមបេះដូង* (cardiovascular implants) *ជាដើម ដោយសារតែផលិតផលដែលមានរាងតូចៗទាំងនេះ តែងតែមានទំហំជាច្រើនប្រភេទ ទោះបីជាចំណាយលើការចុះបញ្ជិកា អាចមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើអត្ថិភាពរបស់ផលិតផលទាំងនោះក៏ដោយ។ ស្រដៀងគ្នានេះដែរ សារធាតុធ្វើតេស្តច្រើនមុខ* (reagents) *ដែលជាសារធាតុត្រូវប្រើរួមជាមួយប្រព័ន្ធផ្សេងទៀតដើម្បីបង្កឱ្យមានប្រតិកម្មគីមី ត្រូវការការផ្លាស់ប្តូររាប់រយសម្រាប់មុខងារជាក់លាក់ ទោះបីយ៉ាងសារធាតុទាំងនោះនៅតែតម្រូវឱ្យចុះបញ្ជិកាដាច់ដោយឡែកពីឧបករណ៍ដែលត្រូវប្រើជាមួយសារធាតុនោះ។*

*បច្ចុប្បន្ននេះ អាចមិនមានសង្គតិភាពនៅក្នុងនីតិវិធីរដ្ឋបាលសម្រាប់ការចុះបញ្ជិកាសារធាតុធ្វើតេស្តច្រើនមុខទាំងនេះ។ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខាពេទ្យ និងគ្រឿងសំអាង បានបញ្ជាក់ថា ការចុះបញ្ជិកាសារធាតុធ្វើតេស្តច្រើនមុខត្រូវបានអនុញ្ញាតនៅពេលចុះបញ្ជិកាដំណាលគ្នាជាមួយឧបករណ៍ដែលប្រើជាមួយសារធាតុទាំងនោះ។ ទោះបីជាយ៉ាងណាក៏ដោយ សមាជិករបស់យើងខ្ញុំបានបញ្ជាក់ជូនថា ការអនុវត្តជាក់ស្តែងនៅតែមិនអាចធ្វើទៅបានជារឿយៗនោះទេ ហើយសមាជិកទាំងនោះត្រូវបន្តចុះបញ្ជិសារធាតុធ្វើតេស្តនីមួយៗដាច់ដោយឡែកពីគ្នា និងបង់ថ្លៃឈ្នួលច្រើនលើការចុះបញ្ជិកានោះ។*

*ជាឧទាហរណ៍ថ្នាក់តំបន់ ដើម្បីបំពេញទៅតាមចំណាត់ថ្នាក់ប្រភេទចម្រុះ នៃឧបករណ៍បរិក្ខារពេទ្យដែលមានលក់នៅក្នុងប្រទេសសិង្ហបុរី ក្រុមហ៊ុនចែកចាយអាចចាត់ចំណាត់ថ្នាក់ឧបករណ៍ជាក់លាក់ជាក្រុមនៅក្រោមពាក្យស្នើសុំចុះបញ្ជិកាផលិតផលតែមួយ ដើម្បីសម្រួលដំណើរការរដ្ឋបាលឱ្យមានភាពសាមញ្ញផងដែរ។ ដើម្បីចុះបញ្ជិការួម*

*ទៅលើឧបករណ៍នៅក្រុមតែមួយ ផលិតផលត្រូវមានគោលបំណងប្រើរួម ស្ថិតនៅក្នុងចំណាត់ថ្នាក់គ្រោះថ្នាក់ដូចគ្នា និងការផ្លាស់ប្តូរស្ថិតក្នុងទំហំដែលបានកំណត់។ គោលការណ៍ណែនាំមានស្រាប់ជាមុនស្តីពីការចុះបញ្ជីកាឧបករណ៍បរិក្ខារពេទ្យជាក្រុមនេះ អាចមានលក្ខណៈសមស្របសម្រាប់ប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា។*

## ផលប៉ះពាល់លើកម្ពុជា

*ការចម្លងប្រព័ន្ធរបស់សិង្ហបុរី សម្រាប់ការចុះបញ្ជិកាជាក្រុមចំពោះឧបករណ៍បរិក្ខារពេទ្យ ដែលអនុញ្ញាតឱ្យក្រុមហ៊ុនចែកចាយចុះបញ្ជីកា លើការផ្លាស់ប្តូរផលិតផលរបស់ខ្លួននៅក្នុងក្រុមតែមួយ ឬប្រភេទតែមួយនឹងកាត់បន្ថយការរាំងស្ទះផ្នែករដ្ឋបាលបានច្រើនដែលមាននៅក្នុងវិស័យសុខាភិបាលកម្ពុជា។ធនធានដែលតម្រូវដោយក្រសួងសុខាភិបាល និងវិស័យឯកជនដើម្បីដំណើរការចុះបញ្ជិកាផលិតផលនឹងមានការថយចុះខ្លាំង និងមិនប៉ះពាល់លើសុវត្ថិភាព ដោយសារផលិតផលនៅតែមានអនុលោមភាពនិងការចុះបញ្ជិកាបានត្រឹមត្រូវ។*

*ដំណើរបន្តការអនុវត្តដែលមិនអាចដឹងទុកមុន អំពីលក្ខខណ្ឌតម្រូវចុះបញ្ជិកាបរិក្ខារពេទ្យ នឹងចូលរួមចំណែកចំពោះការប្រកួតប្រជែងមិនស្មើភាពគ្នា ដោយសារតែការចុះបញ្ជីកាម្តងអាចចំណាយប្រមាណជា ១០០ ដុល្លារអាមេរិក ដូចនេះចំណាយលើការចុះបញ្ជិកាផ្លាស់ប្តូរសារធាតុធ្វើតេស្តច្រើនមុខ ដាច់ដោយឡែកពីគ្នាជាជាងការចុះបញ្ជិកាជាក្រុម ធ្វើឱ្យមានការចំណាយច្រើនដល់ក្រុមហ៊ុនចែកចាយ។ ការចំណាយថ្លៃកើនឡើង និងចំណាយពេលយូរនៃអនុលោមភាពនេះ អាចរារាំងមិនឱ្យមានការបង្កើតថ្មី និងជម្រើស ដោយសារតែចំណុចនេះអាចបង្អាក់ដល់ក្រុមហ៊ុនផ្គត់ផ្គង់ក្នុងការនាំយកឧបករណ៍បរិក្ខារថ្មីៗមកកាន់ប្រទេសកម្ពុជា។*

*ផលប៉ះពាល់កើតចេញពីបញ្ហានេះ មានជាច្រើនមកលើអ្នកជំងឺ និងគុណភាពនៃការថែទាំ ដោយសារតែអ្នកជំងឺនឹងមិនអាចទទួលបានអត្ថប្រយោជន៍ពីការព្យាបាលសង្គ្រោះជីវិតបែបទំនើប ចំណែកឯគ្រូពេទ្យជំនាញថែទាំសុខភាពក៏មានអាចតាមទាន់បច្ចេកវិទ្យាដែលមានការវិវត្តយ៉ាងឆាប់រហ័សនៅក្នុងវិស័យមួយនេះផងដែរ។*

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យធ្វើការពិចារណាចេញបទប្បញ្ញត្តិ ដែលនឹងអនុញ្ញាតឱ្យមានការចុះបញ្ជិការួមសម្រាប់ឧបករណ៍បរិក្ខារពេទ្យដែលស្ថិតនៅក្នុងក្រុម និងប្រភេទតែមួយ។

*ដើម្បីសម្រាលបន្ទុករដ្ឋបាល របស់ក្រសួងសុខាភិបាល និងក្រុមហ៊ុនចែកចាយឧបករណ៍បរិក្ខារពេទ្យ យើងខ្ញុំសូមផ្តល់ជូនអនុសាសន៍ឱ្យក្រសួងធ្វើការពិចារណា ចេញបទប្បញ្ញត្តិដែលនឹងអនុញ្ញាតឱ្យមានការចុះបញ្ជិការួម សម្រាប់ឧបករណ៍បរិក្ខារពេទ្យដែលស្ថិតនៅក្នុងក្រុម និងប្រភេទតែមួយ នៅពេលដាក់ពាក្យស្នើសុំដំណាលគ្នា។ បន្ថែមពីនេះទៅទៀត ដើម្បីប៉ះប៉ូវដល់ចំណូលដែលអាចថយចុះ ដោយសារតែដំបូងអាចមានការចុះបញ្ជិកាផលិតផលតិច ក្រសួងអាចគិតថ្លៃសេវាដែលកើនឡើងសម្រាប់ការចុះបញ្ជិកាឧបករណ៍បរិក្ខារពេទ្យ ដែលតម្រូវឱ្យមានការផ្លាស់ប្តូរច្រើន ឬសមាសធាតុពាក់ព័ន្ធច្រើនផ្សេងទៀត។*

៥០

# ចំណាត់ថ្នាក់ឧបករណ៍បរិក្ខារពេទ្យសម្រាប់ការចុះបញ្ជិកា

ធ្វើបច្ចុប្បន្នភាព

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើឱ្យក្រសួងសុខាភិបាលកំណត់ឱ្យបានច្បាស់ នូវបញ្ជីចំណាត់ថ្នាក់ផលិតផលសម្រាប់ឧបករណ៍បរិក្ខារពេទ្យដោយមានព័ត៌មានលម្អិតអំពីនីតិវិធី និងឯកសារដែលចាំបាច់សម្រាប់ផលិតផលនីមួយៗ និងបោះពុម្ពផ្សាយនីតិវិធីផ្លូវការសម្រាប់ការចុះបញ្ជិកាសារធាតុធ្វើតេស្ត។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*តាមរយៈលិខិតផ្ញើមកកាន់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាកាលពីខែសីហា ឆ្នាំ២០១៨ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខាពេទ្យ និងគ្រឿងសំអាង បានបញ្ជាក់ថាប្រកាសមានស្រាប់លេខ ១២៥៨ ដែលគ្រប់គ្រងលើដំណើរការចុះបញ្ជិកាសម្រាប់សម្ភារឧបករណ៍បរិក្ខារពេទ្យនៅក្នុងប្រទេសកម្ពុជា បានតម្រូវឱ្យមានការចុះបញ្ជិកាផលិតផលទាំងនេះដាច់ដោយឡែកពីគ្នា ហើយមិនអនុញ្ញាតឱ្យដាក់ផលិតផលទាំងនោះជាក្រុម និងចុះបញ្ជិកានៅក្រោមប្រភេទតែមួយឡើយ។ នាយកដ្ឋាននេះក៏បានបញ្ជាក់ផងដែរថាក្រសួងសុខាភិបាលអាចធ្វើការពិចារណាដាក់ចេញនូវប្រកាសស្តីពីការចុះបញ្ជិកាជាក្រុមសម្រាប់ឧបករណ៍បរិក្ខារពេទ្យដើម្បីកាត់បន្ថយថ្លៃឈ្នួលសេវា ដែលតម្រូវ និងបន្ទុកនានារបស់ក្រុមហ៊ុនដែលកំពុងប្រតិបត្តិការនៅកម្ពុជា ហើយសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាសូមស្វាគមន៍ចំពោះឱកាសក្នុងការផ្តល់ការគាំទ្រដល់ដំណើរការនេះ។*

*នាយកដ្ឋានក៏បានបញ្ជាក់ផងដែរថា ក្រសួងអនុញ្ញាតឱ្យមានការចុះបញ្ជិកាសារធាតុធ្វើតេស្តរួមគ្នាជាមួយនឹងឧបករណ៍បរិក្ខារពេទ្យ ប្រសិនបើក្រុមហ៊ុនដាក់ពាក្យសុំចុះបញ្ជិកាក្នុងពេលដំណាលគ្នា និងទទួលបានលេខចុះបញ្ជិកាដូចគ្នា។ ទោះបីយ៉ាងនេះក្តី សមាជិករបស់យើងខ្ញុំបានបញ្ជាក់ជូនថា ពេលខ្លះ ដំណើរការនេះមិនមានសង្គតិភាពនៅក្នុងការអនុវត្តជាក់ស្តែងនាពេលបច្ចុប្បន្ននោះទេ ដោយហេតុថា សមាជិករបស់យើងខ្ញុំនៅតែតម្រូវឱ្យចុះបញ្ជិកាសារធាតុធ្វើតេស្តដាច់ដោយឡែកពីគ្នា ទោះបីជាបញ្ហានេះអាចបណ្តាលមកពីមន្ត្រីជួរមុខដែលមិនបានដឹងអំពីការកែសម្រួលដំណើរការថ្មីៗនេះក៏ដោយ។*

**ពិពណ៌នាបញ្ហា**

*នីតិវិធី និងឯកសារដែលត្រូវការជាចាំបាច់ដើម្បីចុះបញ្ជិកាឧបករណ៍បរិក្ខារពេទ្យនៅក្នុងប្រទេសកម្ពុជាគឺអាស្រ័យទៅលើការចាត់ចំណាត់ថ្នាក់ផលិតផលរបស់ក្រសួងសុខាភិបាល។ បច្ចុប្បន្ន ក្រុមហ៊ុនចែកចាយឧបករណ៍បរិក្ខារពេទ្យមួយចំនួន បានយល់ដឹងអំពីភាពខ្វះខាតនៃបទប្បញ្ញត្តិពាក់ព័ន្ធនឹងការចុះបញ្ជិកាឧបករណ៍បរិក្ខារពេទ្យ។ គោលការណ៍ណែនាំដែលបានចែងទាំងនោះ ហាក់បីដូចជាផ្អែកទៅលើប្រព័ន្ធនិយតកម្មចម្រុះរបស់បណ្តាប្រទេសជាច្រើន។ គោលការណ៍ណែនាំមួយចំនួន អាចជាន់គ្នាជាមួយនឹងគោលការណ៍ណែនាំមួយផ្សេងទៀត ហើយបង្កើតឱ្យមានភាពមិនច្បាស់លាស់ទៅលើលក្ខខណ្ឌតម្រូវនៃនីតិវិធី និងឯកសារដែលបានតម្រូវសម្រាប់ការចុះបញ្ជិកាផលិតផលឧបករណ៍បរិក្ខារពេទ្យទាំងនោះ។*

*ភាពមិនច្បាស់លាស់នេះ បង្ខំឱ្យក្រុមហ៊ុនចែកចាយឧបករណ៍បរិក្ខារពេទ្យ ធ្វើការវិនិច្ឆ័យផ្ទាល់ខ្លួនលើឧបករណ៍ដែលខ្លួនគិតថាគួរចុះបញ្ជិកា ដោយផ្អែកលើព័ត៌មានពីការស្រាវជ្រាវមកពីប្រភពនានា រាប់បញ្ចូលទាំងការសម្រេចចិត្តថា តើឧបករណ៍បរិក្ខារណាខ្លះដែលតម្រូវឱ្យចុះបញ្ជិកានៅក្នុងប្រទេសផ្សេងទៀត និងដែលត្រូវធ្វើការទាក់ទងមកកាន់អគ្គនាយកដ្ឋានគយ និងរដ្ឋាករដើម្បីសុំការបញ្ជាក់បន្ថែមលើចំណុចជាច្រើនទៀត។ បច្ចុប្បន្ននេះ សមាជិករបស់យើងខ្ញុំបានបញ្ជាក់ជូនថា ពួកគាត់ប្រាកដតែចំពោះឧបករណ៍បរិក្ខារ ដែលទាក់ទងជាមួយសារធាតុគីមីប៉ុណ្ណោះ ឧទាហរណ៍ សារធាតុសម្រាប់ការធ្វើតេស្ត និងឧបករណ៍បរិក្ខារពេទ្យផ្សេងទៀតដូចជា ឧបករណ៍សម្រាប់ភ្ជាប់ បណ្តុះ ឬផ្សាំក្នុងខ្លួនមនុស្ស* (implants) *ដែលបានតម្រូវឱ្យមានការចុះបញ្ជិកា ហើយពេលខ្លះនៅតែមិនទាន់ដឹងច្បាស់លាស់ថាតើត្រូវចុះបញ្ជិកាឧបករណ៍បរិក្ខារប្រភេទផ្សេងទៀតមុនពេលធ្វើការនាំចូលដែរ ឬយ៉ាងណានោះទេ។*

*នៅឆ្នាំ២០១៥ ប្រទេសកម្ពុជា ជាមួយនឹងប្រទេសសមាជិកអាស៊ានទាំងអស់ផ្សេងទៀត បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនាំស្តីពីឧបករណ៍បរិក្ខារពេទ្យអាស៊ាន* (AMDD) *ដើម្បីធ្វើសុខដុមនីយកម្មបទប្បញ្ញត្តិឧបករណ៍បរិក្ខារពេទ្យនៅក្នុងតំបន់ទាំងមូល និងបានបញ្ច្រៀបបដំណើរការនេះសម្រាប់ក្រុមហ៊ុនក្នុងការចូលទីផ្សាររបស់ខ្លួន ដោយកាត់បន្ថយរបាំងផ្នែកបច្ចេកទេស និងនិយ័តកម្ម។ សមាសធាតុសំខាន់នៃកិច្ចព្រមព្រៀងនេះគឺទម្រង់ឯកសារគំរូស្នើសុំរួមរបស់អាស៊ាន* (ASEAN Common Submission Dossier Template) *ដែលក្រុមហ៊ុនផលិតទាំងនោះអាចប្រើប្រាស់ដើម្បីដាក់ឯកសារបច្ចេកទេសរួមទៅកាន់អាជ្ញាធរនីមួយៗដើម្បីកាត់បន្ថយការចំណាយ និងលើកកម្ពស់ប្រសិទ្ធផលនិយ័តកម្ម។ នេះតម្រូវឱ្យប្រទេសសមាជិកអាស៊ាន បង្កើត និងអនុវត្តគោលការណ៍ណែនាំរួម និងកំណត់ស្តង់ដារលក្ខណៈវិនិច្ឆ័យសម្រាប់ការចំណាត់ថ្នាក់ឧបករណ៍នៃកិច្ចព្រមព្រៀង* AMDD *ដើម្បីសម្រួលដល់ការធ្វើសមាហរណកម្មទីផ្សារតែមួយសម្រាប់ផលិតឧបករណ៍បរិក្ខារពេទ្យ។*

*ខណៈដែលកិច្ចព្រមព្រៀងនេះត្រូវបានរំពឹងទុកថានឹងចូលជាធរមានចាប់ពីឆ្នាំ២០២០ខាងមុខនេះ ប្រទេសកម្ពុជានៅតែត្រូវសម្របនីតិវិធីអនុលោមភាពផ្ទៃក្នុងជាមួយនឹងគោលការណ៍ណែនាំដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង* AMDD *ដែលអាចជាមូលហេតុធ្វើឱ្យមានភាពមិនច្បាស់លាស់ជាបន្តបន្ទាប់សម្រាប់ក្រុមហ៊ុនចែកចាយផលិតផលឧបករណ៍បរិក្ខារពេទ្យដែលកំពុងប្រតិបត្តិការនៅកម្ពុជា។*

## ផលប៉ះពាល់លើកម្ពុជា

*ភាពមិនច្បាស់លាស់នៃចំណាត់ថ្នាក់ឧបករណ៍បរិក្ខារពេទ្យ បានចូលរួមចំណែកដល់បញ្ហាពន្យារពេល ដែលយើងបានលើកឡើងខាងលើ នៅក្នុងដំណើរការចុះបញ្ជិកាឧបករណ៍បរិក្ខារពេទ្យនៅក្នុងប្រទេសកម្ពុជា ដោយសារតែក្រុមហ៊ុនធុរកិច្ច នៅក្នុងវិស័យនេះមិនអាចដឹងច្បាស់ថាតើលក្ខខណ្ឌតម្រូវណាខ្លះដែលក្រសួង កំណត់សម្រាប់ផលិតផលជាក់លាក់ណាមួយនោះទេ។ ភាពមិនច្បាស់លាស់នេះអាចធ្វើឱ្យប្រព័ន្ធនិយ័តកម្មមិនមានប្រសិទ្ធផលក្នុងការឆ្លើយតបទៅនឹងកំណើនតម្រូវការនៅក្នុង វិស័យនេះបានឡើយ ដោយសារតែបញ្ហាបន្ទុកការងាររដ្ឋបាលមានកាន់តែច្រើនឡើងចំពោះក្រសួង និងវិស័យឯកជនដែលមានអនុលោមភាព។ សំខាន់ជាងនេះទៅទៀត*

បញ្ហានេះក៏អាចបង្កើនឱកាសដល់ឧបករណ៍បរិក្ខារពេទ្យដែលមានហានិភ័យកំរិតខ្ពស់ចូលមកកាន់ប្រទេសកម្ពុជាដោយមិនស្របច្បាប់ ក្នុងទម្រង់ជាឧបករណ៍មានហានិភ័យកំរិតទាបដែលការគ្រប់គ្រងនិយ័តកម្មមានកម្រិតតិចតួច និងអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពអ្នកជំងឺ និងគុណភាពសេវាព្យាបាលរបស់គ្រូពេទ្យជំនាញថែទាំសុខភាព។

លក្ខខណ្ឌតម្រូវចុះបញ្ជិកាអសង្គតិភាពនេះ ក៏បានចូលរួមចំណែកធ្វើឱ្យមានការប្រកួតប្រជែងមិនស្មើភាពគ្នាផងដែរ ដោយធ្វើឱ្យក្រុមហ៊ុនត្រូវចំណាយខ្ពស់លើការចុះបញ្ជិកា និងអាចបន្ថបង្អាក់មិនឱ្យក្រុមហ៊ុនផ្គត់ផ្គង់នាំយកឧបករណ៍សម្ភារបែបកាន់តែច្រើននៅកម្ពុជា ដែលអាចនឹងបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានដល់អ្នកជំងឺ ប្រសិទ្ធផល ការស្រាវជ្រាវ និងនវានុវត្តន៍ នៅក្នុងប្រព័ន្ធថែទាំសុខភាពទៀតផង។ ប្រសិនបើប្រទេសកម្ពុជា និងប្រទេសសមាជិកអាស៊ានទាំងអស់អនុវត្តកិច្ចព្រមព្រៀង AMDD ប្រកបដោយភាពជោគជ័យ កត្តានេះអាចនឹងជំរុញឱ្យវិស័យបរិក្ខារពេទ្យនៅទូទាំងតំបន់អាស៊ីអាគ្នេយ៍មានការរីកចម្រើនខ្ពស់។

✓ សូមស្នើឱ្យសម្របប្រភេទចំណាត់ថ្នាក់និងគោលការណ៍ណែនាំស្ដីពីការចុះបញ្ជិកាឧបករណ៍បរិក្ខារពេទ្យ ឱ្យស្របជាមួយនឹងចំណាត់ថ្នាក់ និងគោលការណ៍ណែនាំដែលមានចែងក្នុងកិច្ចព្រមព្រៀងស្ដីពីឧបករណ៍បរិក្ខារពេទ្យអាស៊ាន ( ASEAN Medical Device Directive ) ។

**អនុសាសន៍ឆ្នាំ ២០១៩**

យើងខ្ញុំសូមគោរពស្នើឱ្យក្រសួងសុខាភិបាលសម្រួបគោលការណ៍ណែនាំស្ដីពីការចុះបញ្ជិកាឧបករណ៍បរិក្ខារពេទ្យ និងប្រភេទឧបករណ៍បរិក្ខារពេទ្យដែលចាំបាច់សម្រាប់ស្នើសុំការអនុញ្ញាតការនាំចូលតាមប្រភេទជាមួយនឹងគោលការណ៍ណែនាំដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងស្ដីពីឧបករណ៍បរិក្ខារពេទ្យអាស៊ាន (AMDD) ។ ដោយសារតែកិច្ចព្រមព្រៀងនេះត្រូវបានគេរំពឹងទុកថានឹងចូលជាធរមាននៅឆ្នាំ២០២០ ការធ្វើបែបនេះនឹងអាចជួយក្រសួងក្នុងការត្រៀមលក្ខណៈបានល្អសម្រាប់ការធ្វើសុខដុម-នីយកម្មបទប្បញ្ញត្តិ និងគាំទ្របន្ថែមដល់ផែនការធ្វើសមាហរណកម្មរបស់កម្ពុជាចូលទៅក្នុងទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយរបស់អាស៊ាន។

មាត្រា ៤ នៃកិច្ចព្រមព្រៀងស្ដីពីឧបករណ៍បរិក្ខារពេទ្យអាស៊ាន (AMDD) បានកំណត់ការចាត់ចំណាត់ថ្នាក់ឧបករណ៍បរិក្ខារពេទ្យជាបួនចំណាត់ថ្នាក់ដោយផ្អែកលើកំរិតហានិភ័យដូចខាងក្រោម៖

- *ចំណាត់ថ្នាក់ ក៖ កំរិតហានិភ័យទាប – ដូចជាបង់រុំរបួស ស្រោមដៃវះកាត់ និងបំពង់ IV។*
- *ចំណាត់ថ្នាក់ ខ៖ កំរិតហានិភ័យពីទាបទៅមធ្យម– ដូចជាបង្គោលធ្មេញសិប្បនិម្មិត កែវភ្នែកសិប្បនិម្មិត (contact lenses) និងឧបករណ៍ពិនិត្យផ្ទៃពោះ។*
- *ចំណាត់ថ្នាក់ គ៖ កំរិតហានិភ័យពីមធ្យមទៅខ្ពស់– ដូចជា ថង់ឈាម សូលុយស្យុង សម្រាប់សម្អាតកែវភ្នែកសិប្បនិម្មិត (contact lenses) និងកញ្ចប់ធ្វើតេស្តសេន។*
- *ចំណាត់ថ្នាក់ ឃ៖ កំរិតហានិភ័យខ្ពស់ – ដូចជា ឧបរកណ៍បរិក្ខារពេទ្យដែលមានឱសថខាងក្នុងបេះដូងសិប្បនិម្មិត និងកញ្ចប់ធ្វើតេស្តរកមេរោគអេដស៍។*

*ប្រសិនបើក្រសួងអនុញ្ញាតជាផ្លូវការ ឱ្យក្រុមហ៊ុនចែកចាយឧបរកណ៍បរិក្ខារពេទ្យ អនុវត្តតាមចំណាត់ថ្នាក់ទាំងនេះ នៅពេលដំណើរការស្នើសុំការអនុញ្ញាតនាំចូលនោះ បញ្ហាពាក់ព័ន្ធនឹងភាពមិនច្បាស់លាស់ នឹងលែងមានទៀតហើយសម្រាប់ក្រុមហ៊ុនចែកចាយឧបករណ៍បរិក្ខារពេទ្យនៅកម្ពុជា ព្រមទាំងនឹងជួយគាំទ្រឱ្យក្រុមហ៊ុនទាំងនេះនាំចូលកាន់ប្រទេសកម្ពុជានូវឧបករណ៍បរិក្ខារព្យាបាលច្នៃប្រឌិតថ្មីៗកាន់តែច្រើនថែមទៀត។*

៥១

# ដំណើរការសុំការអនុញ្ញាតសម្រាប់ការផ្សព្វផ្សាយ លក់ផលិតផលឱសថ

ថ្មី

**ពិពណ៌នាបញ្ហា**

*ការផ្សព្វផ្សាយលក់ផលិតផលថែទាំសុខភាពក្នុងប្រទេសកម្ពុជា ត្រូវបានគ្រប់គ្រងយ៉ាងតឹងរ៉ឹងដោយក្រសួងសុខាភិបាលដើម្បីធានានូវភាពស្របច្បាប់នៃសេចក្តីអះអាងខ្លឹមសារ និងទិដ្ឋភាព នៃសកម្មភាពទាំងនោះ និងដើម្បីកាត់បន្ថយហានិភ័យដែលអាចកើតឡើងចំពោះសុវត្ថិភាពអ្នកជំងឺ។ បទប្បញ្ញត្តិទាំងនេះ តម្រូវឱ្យក្រុមហ៊ុនថែទាំសុខភាពស្នើសុំការអនុញ្ញាតជាមុនពីក្រសួង សម្រាប់សម្ភារ និងកម្មវិធីដែលក្រុមហ៊ុនចង់ប្រើប្រាស់ដើម្បីផ្សព្វផ្សាយលក់ផលិតផលរបស់ខ្លួនមុនពេលផ្តល់ផ្តល់ទៅដល់សាធារណជន អ្នកជំនាញផ្នែកថែទាំសុខភាព និងភាគីពាក់ព័ន្ធក្នុងវិស័យ។*

*ទោះបីជាបទដ្ឋាននេះត្រូវបានអនុវត្តនៅក្នុងប្រទេសជាច្រើនក៏ដោយ ប៉ុន្តែសមាជិករបស់យើងខ្ញុំ មានភាពមិនច្បាស់លាស់ជុំវិញដំណើរការអនុម័ត នៅក្នុងប្រទេសកម្ពុជាដោយសារតែមានការផ្លាស់ប្តូរថ្មីៗនៅក្នុងការអនុវត្តរបស់ក្រសួងដែលមិនទាន់បានរៀបចំជាផ្លូវការ ទោះបីមានការអនុវត្តសម្រាប់ករណីមួយចំនួនរួចទៅហើយក្តី។ សមាជិករបស់យើងខ្ញុំ សូមជម្រាបឱ្យដឹងថាសម្រាប់សម្ភារផ្សព្វផ្សាយលក់មានម៉ាកសញ្ញាដែលជាទូទៅត្រូវបានផ្តល់ទៅឱ្យអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ដូចជាសៀវភៅបញ្ជីកត់ត្រាផ្នែកមន្ទីរពិសោធន៍ដែលពីមុនមិនបានឆ្លងកាត់ការត្រួតពិនិត្យទាំងនេះ នៅពេលនេះក្រុមហ៊ុនត្រូវបានតម្រូវឱ្យស្នើសុំការអនុញ្ញាតិជាមុនសិន។ ដូចគ្នានេះដែរ សម្រាប់សម្ភារផ្សេងៗទៀត ដូចជាសម្ភារទាក់ទាញចំណាប់អារម្មណ៍ មានការលំបាកខ្លាំងចំពោះក្រុមហ៊ុនផលិតក្នុងការទទួលបានសំណាកទោលជាក់ស្តែងដោយសារបញ្ហាកំហិតនៅក្នុងការផលិត ហើយនៅក្នុងការអនុវត្តជាក់ស្តែង កត្តានេះអាចរារាំងក្រុមហ៊ុនមិនឱ្យស្នើសុំការអនុម័តចំពោះសម្ភារផ្សព្វផ្សាយរបស់ខ្លួន។*

*ភាពមិនច្បាស់លាស់ដែលកើតឡើង ដោយសារភាពខុសគ្នាពីដំណើរការមុនៗ ក៏បន្តរហូតដល់ដំណើរការស្នើសុំការអនុញ្ញាត ដែលចាំបាច់សម្រាប់ក្រុមហ៊ុននៅក្នុងការរៀបចំ ឬចូលរួមនៅក្នុងកម្មវិធី ឬកិច្ចប្រជុំពាក់ព័ន្ធនឹងការផ្សព្វផ្សាយលក់ផលិតផលឱសថ ជាមួយនឹងអ្នកជំនាញផ្នែកថែទាំសុខភាព។ កាលពីមុន តំណាងក្រុមហ៊ុនត្រូវបានអនុញ្ញាតឱ្យចូលរួមនៅក្នុងកិច្ចប្រជុំរួមជាមួយសមាគមវេជ្ជសាស្ត្រប្រសិនបើសមាគមបានទទួលការអនុញ្ញាត ទោះបីនៅក្នុងករណីមួយចំនួន ក្រសួងតម្រូវឱ្យទាំងសមាគម និងក្រុមហ៊ុននីមួយៗដែលចូលរួម ត្រូវស្នើសុំការអនុញ្ញាតដាច់ដោយឡែកពីគ្នាក្តី។ ស្រដៀងគ្នានេះដែរ ការអនុញ្ញាតដែលបានទទួលសម្រាប់កម្មវិធីវេជ្ជសាស្ត្រពីមុនមានសុពលភាពរយៈពេលមួយខែ ដែលអាចឱ្យក្រុមហ៊ុនបត់បែននៅក្នុងការផ្លាស់ប្តូរផែនការ ដោយសមហេតុផល ប៉ុន្តែនៅពេលនេះក្រសួងតម្រូវឱ្យរៀបចំកម្មវិធីនៅកាលបរិច្ឆេទជាក់លាក់ ដែលបានស្នើសុំការអនុញ្ញាត។ កត្តានេះបានធ្វើឱ្យក្រុមហ៊ុនពុំអាចមានលទ្ធភាពអញ្ជើញអ្នកជំនាញថែទាំសុខភាព ដែលមានជំនាញផ្តល់សារវេជ្ជសាស្ត្រមានសារប្រយោជន៍ ដោយសារនៅពេលនេះត្រូវស្នើសុំការអនុញ្ញាត ទើបធ្វើឱ្យមានភាពយឺតយ៉ាវក្នុងការទាក់ទងទៅអ្នកជំនាញដ៏មមាញឹកទាំងនេះសម្រាប់កាលបរិច្ឆេទជាក់លាក់។*

*បញ្ហាពាក់ព័ន្ធនឹងដំណើរការសុំការអនុញ្ញាតនេះ មានច្រើនបែបសម្រាប់កម្មវិធីផ្សព្វផ្សាយផ្សេងៗដែលរៀបចំឡើងនៅក្រៅទីក្រុងភ្នំពេញ ជាពិសេស នៅខេត្តបាត់ដំបង សៀមរាប និងកំពង់ចាម ដោយសារក្រុមហ៊ុនត្រូវស្នើសុំការអនុញ្ញាតពីក្រសួង ព្រមទាំងពីមន្ទីរសុខាភិបាលខេត្ត ដែលបង្កឱ្យមានបន្ទុកផ្នែករដ្ឋបាលមិនចាំបាច់បន្ថែមទៀត។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងដែលបានខិតខំប្រឹងប្រែងទប់ស្កាត់ការស្នើសុំការអនុញ្ញាតជាន់គ្នាពីអាជ្ញាធរមូលដ្ឋាន ប៉ុន្តែសមាជិករបស់យើងខ្ញុំបានលើកឡើងថាបញ្ហានេះនៅតែបន្តកើតមាននៅឡើយ។*

*ក្រុមហ៊ុនថែទាំសុខភាព គាំទ្រចំពោះការតម្រូវឱ្យមានក្របខណ្ឌនិយតកម្មសមស្របសម្រាប់វិស័យថែទាំសុខភាពដើម្បីធានាថា ក្រុមហ៊ុនពុំមានសកម្មភាពមិនសមរម្យ ឬធ្វើសេចក្តីអះអាងមិនត្រឹមត្រូវ នៅក្នុងឯកសារផ្សព្វផ្សាយលក់ផលិតផលរបស់ខ្លួន ដែលអាចបង្កគ្រោះថ្នាក់ទៅដល់សាធារណជនឡើយ។ ដូច្នេះ វិស័យសុខាភិបាលតម្រូវឱ្យបទប្បញ្ញត្តិទាំងនេះមានភាពច្បាស់លាស់ មានសង្គតិភាព និងអមដោយការណែនាំជាផ្លូវការដែលអាចឱ្យក្រុមហ៊ុនអាចដឹងថាតើសម្ភារផ្សព្វផ្សាយលក់ផលិតផលណាដែលអាចទទួលយកបាន និងមិនទទួលយកបានមុននឹងដាក់ជូនក្រសួងសុខាភិបាល។*

## ផលប៉ះពាល់លើកម្ពុជា

*ដូចគ្នាទៅនឹងវិស័យឯកជនផ្សេងៗទៀតដែរ ក្រុមហ៊ុនថែទាំសុខភាព ប្រើប្រាស់ យុទ្ធសាស្ត្រផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពដើម្បីបង្ហាញអំពីលក្ខណៈពិសេសនៃ ផលិតផល និងរក្សាគោលជំហររបស់ខ្លួន នៅក្នុងទីផ្សារ ជាមួយនឹងដៃគូប្រកួតប្រជែង។ កត្តានេះជួយជំរុញឱ្យវិស័យថែទាំសុខភាពដែលមានភាពប្រកួតប្រជែងខ្ពស់លើកទឹកចិត្តឱ្យមានការវិនិយោគកាន់តែច្រើន ពីក្រុមហ៊ុនពហុជាតិ ដែលនាំមកនូវស្តង់ដារគុណភាពថែទាំសុខភាពកាន់តែខ្ពស់។ កម្មវិធី និងឯកសារផ្សព្វផ្សាយលក់ផលិតផលក៏ត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនឱសថផងដែរដើម្បីផ្សព្វផ្សាយព័ត៌មានវេជ្ជសាស្ត្រផ្អែកលើភស្តុតាងសំខាន់ៗទៅដល់អ្នកជំនាញផ្នែកវេជ្ជសាស្ត្រអំពីផលិតផល ព្រមទាំងព័ត៌មានវេជ្ជសាស្ត្រមិនមែនជាការផ្សព្វផ្សាយ ដូចជាបច្ចុប្បន្នភាពព័ត៌មានវិទ្យាសាស្ត្រអំពីគោលការណ៍ណែនាំអន្តរជាតិ និងភស្តុតាងវេជ្ជសាស្ត្រថ្មីៗ។ គោលបំណងនៃការផ្សព្វផ្សាយនេះ គឺដើម្បីគាំទ្រទៅដល់អ្នកជំនាញផ្នែកថែទាំសុខភាពក្នុងការជ្រើសរើសការព្យាបាលល្អបំផុតសម្រាប់អ្នកជំងឺរបស់ខ្លួនទៅតាមផលិតផលដែលមានលក់នៅតាមទីផ្សារ។*

*ទោះបីយ៉ាងណា កង្វះគោលការណ៍ណែនាំច្បាស់លាស់ អំពីប្រភេទនៃការផ្សព្វផ្សាយដែលបានអនុញ្ញាត និងអំពីពេលវេលាដែលក្រុមហ៊ុនត្រូវស្នើសុំការអនុញ្ញាតនោះ បានធ្វើឱ្យបរិយាកាសនិយតកម្មមិនមានភាពច្បាស់លាស់ ដែលធ្វើឱ្យក្រុមហ៊ុនកាន់តែមានការលំបាក ក្នុងការធ្វើអាជីវកម្មក្នុងកម្ពុជា និងប៉ះពាល់ជាអវិជ្ជមានដល់វិនិយោគិនដែលមានបំណងចង់វិនិយោគនៅកម្ពុជានាពេលខាងមុខផងដែរ។ ដំណើរការនិយតកម្មប្រកបដោយភាពស្មុគស្មាញ ដែលកាត់បន្ថយសមត្ថភាពប្រកួតប្រជែងចុងក្រោយនឹងធ្វើឱ្យប៉ះពាល់ទៅដល់លទ្ធភាពរបស់អ្នកជំងឺ នៅក្នុងការទទួលបានការព្យាបាលសង្គ្រោះជីវិតបែបទំនើប ដោយសារក្រុមហ៊ុនថែទាំសុខភាពទំនងជានឹង មិននាំយកវិធីព្យាបាលទាំងនេះមកកាន់ទីផ្សារថ្មីឡើយប្រសិនបើមិនមានការរំពឹងទុកថានឹងទទួលបានប្រាក់ចំណូលពីការវិនិយោគរបស់ខ្លួនទេនោះ។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យមានការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីគោលការណ៍ណែនាំដែលក្រុមហ៊ុនថែទាំសុខភាពត្រូវអនុវត្តតាមដើម្បីស្នើសុំការអនុញ្ញាតពីក្រសួងសុខាភិបាលសម្រាប់សកម្មភាពផ្សព្វផ្សាយផលិតផល។

*យើងខ្ញុំសូមគោរពស្នើឱ្យក្រសួងសុខាភិបាល ធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីគោលការណ៍ណែនាំ ដែលក្រុមហ៊ុនថែទាំសុខភាពត្រូវអនុវត្តតាម ដើម្បីធានាថា សកម្មភាពផ្សព្វផ្សាយផលិតផលរបស់ខ្លួន អនុលោមទៅតាមលក្ខខណ្ឌតម្រូវរបស់ក្រសួង។ គោលការណ៍ណែនាំទាំងនេះ គួរតែពន្យល់លម្អិតថា តើពេលណាដែលក្រុមហ៊ុនចាំបាច់ត្រូវស្នើសុំការអនុញ្ញាតសម្រាប់សកម្មភាពមួយចំនួន និងពេលណាដែលមិនចាំបាច់ស្នើសុំ ទំហំនៃឯកសារ (ចំនួនទំព័រ) ពេលវេលាដំណើរការប៉ាន់ស្មាន ព្រមទាំងឯកសារអមនិងឯកសារដែលចាំបាច់សម្រាប់ដាក់ស្នើសុំការអនុញ្ញាត។ យើងខ្ញុំសូមជំរុញឱ្យក្រសួងត្រឡប់ទៅកំណត់សុពលភាពរយៈពេលដប់ថ្ងៃដូចមុនសម្រាប់ការអនុញ្ញាតដែលបានផ្តល់ជូន ដោយសាររយៈពេលនេះអាចឱ្យក្រុមហ៊ុនមានភាពបត់បែនក្នុងការរៀបចំនិងចូលរួមនៅក្នុងកម្មវិធីផ្សព្វផ្សាយផលិតផល។*

*ពាក់ព័ន្ធនឹងសម្ភារទាក់ទាញចំណាប់អារម្មណ៍ទីផ្សារ* (gimmicks) *យើងសូមស្នើឱ្យក្រសួងធ្វើការពិចារណាអនុវត្តតាមនីតិវិធីបច្ចុប្បន្នដែលតម្រូវឱ្យមានតែរូបភាព* (art work) *សម្រាប់ដាក់ជូន ដោយសាររូបភាពនេះបង្ហាញអំពីរាល់ព័ត៌មាន និងសារចាំបាច់ដែលក្រសួងតម្រូវឱ្យមានសម្រាប់ការត្រួតពិនិត្យ។*

*ដោយសារផលិតផលនៅតែត្រូវបានអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយទោះបីអាជ្ញាប័ណ្ណចុះបញ្ជិកាផលិតផលទាំងនេះហួសសុពលភាពទៅហើយក្តី យើងខ្ញុំសូមគោរពស្នើឱ្យក្រសួងអនុញ្ញាតឱ្យបន្តធ្វើការចុះបញ្ជិកាកម្មវិធីផ្សព្វផ្សាយ ដោយសារអាជ្ញាប័ណ្ណនេះតម្រូវឱ្យមានសម្រាប់តែការនាំចូលផលិតផលប៉ុណ្ណោះ គឺមិនមែនសម្រាប់ការផ្សព្វផ្សាយទេ។*

*ដើម្បីធានាថាដំណើរការសុំការអនុញ្ញាតផ្សព្វផ្សាយផលិតផល ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព យើងខ្ញុំក៏សូមផ្តល់អនុសាសន៍ឱ្យក្រសួងបញ្ជាក់ឡើងវិញអំពីដំណើរការផ្សព្វផ្សាយពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវរបស់ខ្លួន ទៅដល់គ្រប់មន្ទីរសុខាភិបាលខេត្តដើម្បីធានាថា បទប្បញ្ញត្តិនេះត្រូវបានអនុវត្តដូចៗគ្នានៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងពុំមានការស្នើសុំការអនុញ្ញាតជាន់គ្នា។*

# ៥២

# អាជ្ញាប័ណ្ណនាំចូលបន្ទាន់

ធ្វើបច្ចុប្បន្នភាព

---

**អនុសាសន៍ឆ្នាំ ២០១៧**

ណែនាំអំពីដំណើរការស្នើសុំអាជ្ញាប័ណ្ណពិសេសសម្រាប់ផលិតផលដែលបានចុះបញ្ជិកាជាបន្តបន្ទាប់ ឬដែលកំពុងឆ្លងកាត់ដំណើរការសុំបន្តសុពលភាពឡើងវិញ។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ទទួលស្គាល់ចំពោះកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្មនាពេលកន្លងមករបស់ក្រសួងសុខាភិបាលក្នុងការគាំទ្រដល់បណ្តាក្រុមហ៊ុននានាស្នើសុំអាជ្ញាប័ណ្ណនាំចូលផលិតផលវេជ្ជសាស្ត្រក្នុងករណីផលិតផលទាំងនោះជួបប្រទះបញ្ហាពន្យារពេលនៅក្នុងដំណើរការសុំបន្តសុពលភាពបញ្ជិកាឡើងវិញរបស់ក្រុមហ៊ុនទាំងនោះ។ គួរឱ្យសោកស្តាយ នៅក្នុងលិខិតចុះខែសីហា ឆ្នាំ២០១៨ របស់នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខាពេទ្យ និងគ្រឿងសំអាង ដែលបានជូនដំណឹងមកសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាថា ក្រសួងនឹងបញ្ឈប់ការអនុញ្ញាតលើសំណើសុំអាជ្ញាប័ណ្ណនាំចូលបន្ទាន់ៗទៀតហើយ។ នាយកដ្ឋានក៏បានបញ្ជាក់បន្ថែមផងដែរថា ចាប់ពីពេលនេះតទៅ គ្រប់ផលិតផលវេជ្ជសាស្ត្រទាំងអស់នឹងលែងទទួលបានការអនុញ្ញាតឱ្យមានការនាំចូលមកកម្ពុជាទៀតហើយ ប្រសិនបើផលិតផលទាំងនោះមិនទទួលបានអាជ្ញាប័ណ្ណចុះបញ្ជិកាមានសុពលភាពជាមុនទេនោះ បើទោះបីជាផលិតផលកំពុងរង់ចាំសុំបន្តសុពលភាពអាជ្ញាប័ណ្ណឡើងវិញក៏ដោយ។ នាយកដ្ឋានបានបញ្ជាក់ថា ក្រសួងនឹងផ្តល់វិញ្ញាបនប័ត្របន្តសុពលភាពបញ្ជិកាឡើងវិញក្នុងរយៈពេល ៦ ខែ ហើយ ក្រសួងកំពុងដំណើរការរៀបចំបង្កើតកម្មវិធីថ្មីសម្រាប់ការចុះបញ្ជិកាឱសថតាមប្រព័ន្ធអនឡាញ (E-Registrations) និង ការរៀបចំឯកសារនាំចូលតាមប្រព័ន្ធអេឡិចត្រូនិច (E-Importation) ដែលនឹងសម្រួលដល់ដំណើរការនេះឱ្យកាន់តែមានភាពងាយស្រួល។*

*ស្របពេលដែលសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ទទួលស្គាល់ថា ក្រសួងអាចនឹងចាត់វិធានការយ៉ាងតឹងរ៉ឹងនេះ ដើម្បីជានាកម្រិតប្រកួតប្រជែងសម្រាប់ក្រុមហ៊ុនទាំងអស់ យើងខ្ញុំយល់ឃើញថាការសម្រេចចាត់វិធានការបែបនេះបានរឹតត្បិតឱកាសក្នុងការផ្តល់សេវាគាំទ្រមួយចំនួនដែលជួយសម្រួលដល់ដំណើរការធ្វើធុរកិច្ចនៅកម្ពុជានៅក្នុងស្ថានភាពបែបនេះ។ លើសពីនេះទៀត សេចក្តីសម្រេចនេះនឹងជះឥទ្ធិពលដល់អ្នកជំងឺដែលមករកសេវាព្យាបាលវេជ្ជសាស្ត្រ ប្រសិនបើមានការពន្យារពេលក្នុងការផ្តល់អាជ្ញាប័ណ្ណនាំចូលឱសថសំខាន់ៗទាំងនោះ។ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាសូមលើកទឹកចិត្តដល់ក្រសួង ឱ្យបញ្ជាក់ជាថ្មីម្តងទៀតអំពីដំណើរការដើម្បីទទួលបានអាជ្ញាប័ណ្ណនាំចូលបន្ទាន់សម្រាប់ផលិតផលថែទាំសុខភាពដែលកំពុងរង់ចាំការបន្តសុពលភាពបញ្ជិកា ឬចុះបញ្ជិកា ស្របគ្នានេះយើងខ្ញុំក៏សូមលើកទឹកចិត្តឱ្យអនុវត្តដំណើរការដាក់ពាក្យសុំផ្លូវការដែលមានគោលការណ៍ណែនាំច្បាស់លាស់បង្ហាញអំពីលក្ខខណ្ឌតម្រូវនៃការទទួលបានអាជ្ញាប័ណ្ណនេះ។*

---

**ពិពណ៌នាបញ្ហា**

*ផលិតផលវេជ្ជសាស្ត្រដែលកំពុងឆ្លងកាត់ដំណើរការសុំបន្តសុពលភាពបញ្ជិកាមិនមែនមានសិទ្ធ ទទួលបានអាជ្ញាប័ណ្ណនាំចូលដោយស្វ័យប្រវត្តិបានឡើយ។ យោងតាមនីតិវិធីទូទៅ ដើម្បីទទួលបានអាជ្ញាប័ណ្ណនាំចូលពីក្រសួងសុខាភិបាល ដែលដំណើរការនេះត្រូវចំណាយពេលរហូតដល់ ៦ ខែនោះ គឺតម្រូវឱ្យមានវិញ្ញាបនប័ត្រចុះបញ្ជិកាផលិតផលជាមុនសិន។ សមាជិករបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាបានបញ្ជាក់ជូនថា កាលវិភាគកំណត់នេះ គឺមានលក្ខណៈយុត្តិធម៌ ហើយជាទូទៅមានសុក្រឹតភាពក្រោយពីបានដាក់ឯកសារចាំបាច់ទាំងអស់រួចរាល់ហើយ ទោះបីស្ថិតក្នុងស្ថានភាពដែលមានបញ្ហាពាក់ព័ន្ធនឹងការដាក់ពាក្យសុំរបស់ខ្លួនក្តី ក៏សមាជិកបាន*

ដឹងអំពីភាពខ្វះចន្លោះនៃការប្រាស្រ័យទាក់ទងច្បាស់លាស់ជាមួយក្រសួងដែលនឹងប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការអនុម័តលើការផ្តល់អាជ្ញាប័ណ្ណនោះ។

ដោយសារក្រុមហ៊ុនមិនអាចតាមដានឱ្យបានគ្រប់ជ្រុងជ្រោយ លើការដាក់ពាក្យសុំរបស់ខ្លួនបាន ក្រុមហ៊ុនមិនដឹងអំពីបញ្ហានានាដែលអាចនឹងកើតមានឡើងពាក់ព័ន្ធនឹងការដាក់ពាក្យសុំរបស់ខ្លួនឡើយ ហើយជារឿយៗត្រូវចំណាយពេលខ្លះៗ មុនពេលក្រសួងទាក់ទងមកក្រុមហ៊ុនដើម្បីដោះស្រាយបញ្ហាទាំងនោះ។ បញ្ហាទាំងនេះបានបង្កឱ្យមានការពន្យារពេលលើនីតិវិធីនាំចូល ពីព្រោះក្រសួងមិនអាចដំណើរការពាក្យសុំបានទេ លុះត្រាតែ ឯកសារទាំងអស់បានរៀបចំតាមលំដាប់លំដោយរួចរាល់។ នៅពេលក្រុមហ៊ុនទទួលបានការជូនដំណឹង និងបានដោះស្រាយបញ្ហានានាហើយ ពេលវេលាកំណត់នៃដំណើរការសុំបន្តសុពលភាពរយៈពេល ៦ ខែ នឹងត្រូវចាប់ផ្តើមម្តងទៀត ដែលនេះនឹងបង្កឱ្យមានការពន្យារពេលច្រើនថែមទៀតដល់ដំណើរការសុំបន្តសុពលភាព ហើយក្រុមហ៊ុនត្រូវបានហាមឃាត់មិនឱ្យធ្វើការនាំចូលផលិតផលរបស់ខ្លួនឡើយក្នុងរយៈពេលអន្តរកាលនេះ។

កាលពីមុន ក្រសួងបានប្រឹងប្រែងជួយរកដំណោះស្រាយចំពោះបញ្ហាទាំងនេះ ដោយបានព្រមព្រៀងពិចារណា ផ្តល់សំណើសុំអាជ្ញាប័ណ្ណនាំចូលបន្ទាន់តាមករណីនីមួយៗ នៅពេលមានការដាក់ពាក្យស្នើសុំ។ បើទោះបីយើងខ្ញុំកោតសរសើរអំពីកិច្ចខិតខំប្រឹងប្រែងទាំងនេះយ៉ាងណាក៏ដោយ ក៏បច្ចុប្បន្ន ក្រសួងបានបញ្ជាក់ថា ក្រសួងនឹងពិចារណាបញ្ឈប់ការផ្តល់សំណើសុំបែបនេះទៀតហើយ ដែលជាហេតុបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ក្រុមហ៊ុនទាំងអស់នៅក្នុងវិស័យសុខាភិបាល។ ដូច្នេះ វិស័យនេះត្រូវការជាចាំបាច់នូវបណ្តាញសមស្របមួយ ដើម្បីឱ្យក្រុមហ៊ុនដាក់ពាក្យសុំអាជ្ញាប័ណ្ណនាំចូលបន្ទាន់ សម្រាប់ផលិតផលវេជ្ជសាស្ត្រ ក្នុងករណីមានការពន្យារពេលណាមួយកើតឡើងហួសពីការគ្រប់គ្រងរបស់ក្រុមហ៊ុន ហើយយន្តការនេះនឹងទទួលបានអត្ថប្រយោជន៍ជាច្រើនពីដំណើរការដែលមានលក្ខណៈផ្លូវការ។

## ផលប៉ះពាល់លើកម្ពុជា

ការពន្យារពេលចុះបញ្ជិកា និងបន្តសុពលភាពបញ្ជិកាផលិតផល អាចរារាំងដល់ការនាំចូលឱសថ និងឧបករណ៍សង្គ្រោះជីវិតចូលមកក្នុងប្រទេសកម្ពុជា។ ចំណុចនេះនឹងធ្វើឱ្យគុណភាព និងសុវត្ថិភាពនៃការថែទាំសុខភាពដែលមានសម្រាប់ពលរដ្ឋកម្ពុជាកាន់តែធ្លាក់ចុះ ដោយសារហេតុផលចំនួនពីរ៖ ទីមួយ ការពន្យារពេលនេះនឹងហាមឃាត់មិនឱ្យផលិតផលទទួលបានអត្ថប្រយោជន៍ ពីការស្រាវជ្រាវ និងការអភិវឌ្ឍទំនើបនិងថ្មីចុងក្រោយបំផុតចូលមកក្នុងប្រទេសកម្ពុជា។ ទីពីរ ការពន្យារពេលនេះនឹងបង្កើតឱ្យមានតម្រូវការផលិតផលមិនបានចុះបញ្ជិកា និងផលិតផលក្លែងក្លាយដោយសារឱសថស្ថាន ដែលមិនមានអនុលោមភាពនឹងទិញផលិតផលទាំងនេះ ដើម្បី រក្សាឱ្យមាននៅក្នុងស្តុករបស់ខ្លួន ព្រោះឱសថស្ថានទាំងនេះព្យាយាមគេចវេះពីដំណើរការចុះបញ្ជិកាទាំងស្រុង។ ការរារាំងផ្នែកនិយ័តកម្មដូចជាបញ្ហានេះក៏បង្កឱ្យមានបន្ទុកប្រតិបត្តិការជាច្រើនសម្រាប់ក្រុមហ៊ុនថែទាំសុខភាពដែលនឹងកាត់បន្ថយកម្រិតវិនិយោគរបស់ខ្លួន និងបន្ថយការស្នើសុំសម្រាប់វិស័យនេះផងដែរ។

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមបញ្ជាក់ជាថ្មីអំពីបណ្តាញ (CHANNEL) ណាមួយសម្រាប់ឱ្យក្រុមហ៊ុនដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណនាំចូលបន្ទាន់សម្រាប់ផលិតផលដែលកំពុងរង់ចាំការសុំបន្តសុពលភាព ឬការចុះបញ្ជិកាតាមរយៈការអនុវត្តដំណើរការដាក់ពាក្យសុំផ្លូវការដែលមានគោលការណ៍ណែនាំច្បាស់លាស់បង្ហាញអំពីលក្ខខណ្ឌតម្រូវនៃការទទួលបានអាជ្ញាប័ណ្ណនេះ។

*ក្រសួងសុខាភិបាលនឹងអនុវត្តផែនការទំនើបកម្ម ដោយសារបច្ចុប្បន្ននេះ ក្រសួងបានរៀបចំឱ្យមានការអនុវត្តកម្មវិធីការចុះបញ្ជិកាផលិតផលឱសថតាមប្រព័ន្ធអនឡាញ* (e-Registration *និង* e-Importation) *ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក។ យើងខ្ញុំរំពឹងថា កម្មវិធីនេះនឹងនាំមកនូវប្រសិទ្ធផលកាន់តែប្រសើរសម្រាប់ដំណើរការចុះបញ្ជិកា និងនាំចូលផលិតផល ដែលអាចអនុញ្ញាតឱ្យក្រុមហ៊ុនដាក់បញ្ចូលឯកសារចាំបាច់នានាដើម្បីចុះបញ្ជិកា និងតាមដានពាក្យសុំរបស់ខ្លួន។*

*ទោះបីជាយ៉ាងណា ក្នុងអំឡុងពេលរង់ចាំការដាក់ឱ្យប្រើប្រាស់កម្មវិធីតាមប្រព័ន្ធអនឡាញនេះ បញ្ហាប្រាស្រ័យទាក់ទងគ្នានៅតែបន្តកើតមានឡើង ដូច្នេះក្រុមហ៊ុនត្រូវការវិធីសាស្ត្រមួយក្នុងការដាក់ពាក្យសុំអាជ្ញាប័ណ្ណនាំចូលបន្ទាន់ ដើម្បីធានាថាអ្នកជំងឺទទួលបានការព្យាបាលប្រកដបដោយប្រសិទ្ធភាព នៅពេលដែលមានការពន្យារពេលណាមួយចំពោះដំណើរការដាក់ពាក្យសុំនោះដោយសារកត្តានានាក្រៅដែនគ្រប់គ្រងរបស់ក្រុមហ៊ុន។*

*បន្ទាប់ពីសមាជិកយើងខ្ញុំបានទទួលស្គាល់ និងឯកភាពជាមួយនឹងពេលវេលាកំណត់រយៈពេល ៦ ខែ ដើម្បីដំណើរការបន្តសុពលភាព ដែលបញ្ជាក់ពីក្រសួង យើងខ្ញុំសង្ឃឹមថា ក្រសួងគួរពិចារណាលើការចេញអាជ្ញាប័ណ្ណនាំចូលបន្ទាន់ ក្នុងករណីដែលដំណើរការដាក់ពាក្យសុំបន្តសុពលភាពត្រូវចំណាយពេលលើសពី ៦ ខែ។ ដើម្បីធានាដំណើរការពាក្យសុំនេះ យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យក្រសួងបោះពុម្ពផ្សាយគោលការណ៍ណែនាំ ដោយកម្រិតសេណារីយ៉ូថាតើ ផលិតណាមួយអាចមានសិទ្ធិសមស្របក្នុងការទទួលបានអាជ្ញាប័ណ្ណបន្ទាន់ ដូចជាតម្រូវការឱសថសំខាន់ៗ ក្នុងការជួយសង្គ្រោះអ្នកជំងឺជាដើម។*

៥៣

# ការកំណត់កាលវិភាគនៃកិច្ចប្រជុំរបស់គណៈកម្មការបញ្ជិកា និងបន្តសុពលភាព

ធ្វើបច្ចុប្បន្នភាព

---

**អនុសាសន៍ឆ្នាំ ២០១៧**

សូមក្រសួងសុខាភិបាលមេត្តាផ្សព្វផ្សាយអំពីកាលវិភាគច្បាស់លាស់នៃកិច្ចប្រជុំរបស់គណៈកម្មការបញ្ជិកា និងបន្តសុពលភាពនៅលើគេហទំព័ររបស់ក្រសួង។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*នៅក្នុងលិខិតកាលពីខែសីហា ឆ្នាំ២០១៨ របស់ក្រសួងសុខាភិបាល ដែលបានផ្ញើជូនសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខាពេទ្យ និងគ្រឿងសំអាង បានបញ្ជាក់ថា ក្រសួងសុខាភិបាលមិនអាចផ្សព្វផ្សាយកាលវិភាគជាក់លាក់មួយអំពីកិច្ចប្រជុំរបស់គណៈកម្មការបញ្ជិកា និងបន្តសុពលភាពជាមុនបាននោះទេ ពីព្រោះកិច្ចប្រជុំទាំងនេះគឺអាស្រ័យទៅលើកាលវិភាគរបស់អ្នកចូលរួម។ នាយកដ្ឋានគ្រាន់តែអាចបញ្ជាក់បានថា នាយកដ្ឋានមានបំណងរៀបចំកិច្ចប្រជុំគណៈកម្មការនេះក្នុងចន្លោះពី ៥ ទៅ ៦ លើកក្នុងមួយឆ្នាំ។*

---

**ពិពណ៌នាបញ្ហា**

*សេចក្តីសម្រេចលើការចុះបញ្ជិកា និងបន្តសុពលភាពបញ្ជិកាផលិតផលវេជ្ជសាស្ត្រ ត្រូវធ្វើឡើងនៅក្នុងកិច្ចប្រជុំគណៈកម្មការរបស់ក្រសួងសុខាភិបាល។ គណៈកម្មការបញ្ជិកានេះ ទទួលយកឯកសារពាក់ព័ន្ធចាំបាច់ទាំងអស់របស់ក្រុមហ៊ុនដាក់ស្នើសុំជាមុន ដើម្បីធ្វើការត្រួតពិនិត្យមុនពេលធ្វើការសម្រេច ថាតើត្រូវឯកភាពលើពាក្យសុំផលិតផលនោះឬយ៉ាងណា។ ដោយសារកិច្ចប្រជុំទាំងនោះមានភាពចាំបាច់សម្រាប់ដំណើរការអនុម័តលើផលិតផលវេជ្ជសាស្ត្រទាំងអស់នៅកម្ពុជា កិច្ចប្រជុំទាំងនេះក៏មានសារៈសំខាន់បំផុត ចំពោះដំណើរការការងារក្នុងវិស័យសុខាភិបាលផងដែរ។ ស្របពេលដែលនាយកដ្ឋានបានបញ្ជាក់ថា គណៈកម្មការមានបំណងរៀបចំកិច្ចប្រជុំចន្លោះពី ៥ ទៅ ៦ លើកក្នុងមួយឆ្នាំ វិស័យឯកជនដែលមានអនុលោមតាមជឿជាក់ថា ប្រសិនបើគណៈកម្មការនេះអាចរៀបចំកិច្ចប្រជុំនេះ ឱ្យបានកាន់តែញឹកញាប់ នោះប្រព័ន្ធសុខាភិបាលនៅកម្ពុជាអាចឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកជំងឺកាន់តែមានប្រសិទ្ធភាព ដោយសារតែដំណើរការពាក្យស្នើសុំផលិតផលកាន់តែមានប្រសិទ្ធផលជាមុន។*

**ផលប៉ះពាល់លើកម្ពុជា**

*ដំណើរការចុះបញ្ជិកា និងបន្តសុពលភាពផលិតផលមានរយៈយូរ ធ្វើឱ្យមានការលំបាកកាន់តែច្រើនថែមទៀត សម្រាប់ក្រុមហ៊ុនថែរក្សាសុខភាពក្នុងការធ្វើធុរកិច្ចរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ហើយផ្ដល់ផលប៉ះពាល់អវិជ្ជមាន ដល់ទស្សនៈយល់ឃើញរបស់វិនិយោគិនអនាគត ចំពោះទីផ្សារកម្ពុជាផងដែរ។ សំខាន់ជាងនេះទៅទៀត ការពន្យារពេលចុះបញ្ជិកា និងបន្តសុពលភាពផលិតផលអាចរារាំងដល់ការនាំចូលឱសថ និងឧបករណ៍សង្គ្រោះជីវិតសំខាន់ៗមកក្នុងប្រទេសកម្ពុជាទៀតផង។ ប្រសិនបើគណៈកម្មការបញ្ជិកា និងបន្តសុពលភាពរបស់ក្រសួង អាចប្ដេជ្ញាចិត្តរៀបចំកិច្ចប្រជុំឱ្យបានកាន់តែញឹកញាប់លើសពី ៦ លើកក្នុងមួយឆ្នាំ នោះនឹងអាចធ្វើឱ្យក្រុមហ៊ុនថែរក្សាសុខភាពទាំងអស់ កាន់តែមានភាពងាយស្រួល ក្នុងការសម្របសម្រួលដល់ដំណើរការដាក់ពាក្យស្នើសុំរបស់ខ្លួន និងកាត់បន្ថយការពន្យារពេលចុះបញ្ជិកា និងបន្តសុពលភាពផលិតផលដែលអាចកើតមាន។*

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យគណៈកម្មការបញ្ជិកា និងបន្តសុពលភាពរបស់ក្រសួងសុខាភិបាល រៀបចំកិច្ចប្រជុំឱ្យបានយ៉ាងតិចណាស់ម្ដងក្នុងមួយខែ ដោយយោងតាមកាលវិភាគជាក់លាក់ដែលបានផ្សព្វផ្សាយ។

*ទោះបីសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ដឹងអំពីការលំបាកពាក់ព័ន្ធជាមួយនឹងការសម្របសម្រួលរបស់សមាជិកគណៈកម្មការជាច្រើនក៏ដោយ យើងខ្ញុំក៏សូមលើកទឹកចិត្តឱ្យក្រសួងសុខាភិបាល រៀបចំកិច្ចប្រជុំគណៈកម្មការបញ្ជិកា និងបន្តសុពលភាពឱ្យបានកាន់តែញឹកញាប់លើសពី ៦ លើកក្នុងមួយឆ្នាំ។ ទោះបីជាយើងខ្ញុំដឹងថាការសម្រេចនេះ គឺផ្អែកលើកាលវិភាគរបស់សមាជិកគណៈកម្មការយ៉ាងណាក្ដីក៏យើងខ្ញុំយល់ឃើញថា កិច្ចប្រជុំនេះនឹងផ្ដល់ផលប្រយោជន៍ច្រើនបំផុត ប្រសិនបើក្រសួងអាចរៀបចំកិច្ចប្រជុំនេះ យ៉ាងតិចណាស់ម្ដងក្នុងមួយខែ ដើម្បីផ្ដល់ឱកាសកាន់តែប្រសើរក្នុងការដំណើរការពាក្យស្នើសុំចុះបញ្ជិកា និងបន្តសុពលភាព។ យើងក៏ជឿជាក់ផងដែរថា ប្រសិនបើកាលវិភាគត្រូវបានកំណត់ និងផ្សព្វផ្សាយសម្រាប់ឆ្នាំខាងមុខ នោះសមាជិកគណៈកម្មការអាចលៃលកកាលវិភាគរបស់ខ្លួនទៅតាម កាលវិភាគកិច្ចប្រជុំទាំងនោះ ដោយសារកិច្ចប្រជុំមានសារៈសំខាន់បំផុតសម្រាប់អ្នកជំងឺនៅក្នុងប្រទេសកម្ពុជា។ ដោយអនុវត្តបែបនេះ ក្រសួងនឹងគាំទ្រដល់វិស័យនេះដើម្បីនាំមកនូវការព្យាបាល និងការសង្គ្រោះជីវិត បែបទំនើបថ្មីៗមកកាន់ប្រទេសកម្ពុជា ដើម្បីឱ្យការព្យាបាលជំងឺនៅកម្ពុជាកាន់តែមានប្រសិទ្ធផលថែមមួយកម្រិតទៀត ហើយក៏នឹងលើកកម្ពស់ប្រព័ន្ធសុខាភិបាលទាំងមូល ក៏ដូចជាគុណភាពថៃទាំអ្នកជំងឺផងដែរ។*

# វិស័យអចលនទ្រព្យ និងសំណង់

វិស័យអចលនទ្រព្យ និងសំណង់នៅកម្ពុជា នៅតែជាកត្តាជំរុញកំណើនដ៏សំខាន់ មួយ ហើយកំពុងសម្រេចបាននូវការលូតលាស់យ៉ាងខ្លាំងរយៈពេលយូរមកហើយ ដោយសារតែកត្តាលំហូរចូលដ៏ច្រើនសន្ធឹកសន្ធាប់នៃការវិនិយោគផ្ទាល់ពីបរទេសនិងកំណើនតម្រូវការក្នុងស្រុក។ជាការសំខាន់ណាស់ដែលវិស័យនេះត្រូវមានក្របខ័ណ្ឌនិយ័តកម្មគ្រប់គ្រាន់ និងអាចវិវឌ្ឍស្របទៅនឹងកំណើននេះ ដើម្បីធានាថាទីផ្សារត្រូវបានការពារគ្រប់គ្រាន់ពីភាពងាយរងគ្រោះដែលនឹងអាចកើតមានឡើង។ ជាការលើកទឹកចិត្ត រាជរដ្ឋាភិបាលទទួលស្គាល់នូវចំណុចនេះនិងបានស្វាគមន៍ការចូលរួម និងកិច្ចសហប្រតិបត្តិការរបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា តាមរយៈក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ដើម្បីផ្ដល់ជំនួយបច្ចេកទេសលើផ្នែកជាច្រើន។

បើគិតពីវឌ្ឍនភាពបែបស្ថាបនា ចាប់តាំងពីការបោះពុម្ពផ្សាយលើកមុនមក យើងខ្ញុំមានសេចក្ដីសោមនស្ស សូមរាយការណ៍ជូនឱ្យបានជ្រាបថា រាជរដ្ឋាភិបាលបានអនុវត្តកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្ម ដើម្បីលើកកម្ពស់បទដ្ឋានសុវត្ថិភាពសម្រាប់កម្មករ និងសំណង់អគារ។ កាលពីខែកក្កដាឆ្នាំ២០១៨ កន្លងទៅ រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោង (PAB) ដើម្បីជំរុញ និងត្រួតពិនិត្យបទដ្ឋានសុវត្ថិភាព និងសុខភាពនៅកន្លែងការងារនៅតាមទីតាំងការដ្ឋានសំណង់ ដែលរួមមានសមាសភាពតំណាងមកពីរាជរដ្ឋាភិបាល វិស័យឯកជន សហជីព និងអង្គការមិនមែនរដ្ឋាភិបាល។ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា មានសេចក្ដីរីករាយក្នុងការធ្វើជាតំណាងរបស់វិស័យឯកជន នៅក្នុងក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោងនេះ តាមរយៈគណៈកម្មាធិការអចលនទ្រព្យ និងសំណង់ នៃសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ដោយហេតុថា ការងារនេះគាំទ្រដល់ការប្ដេជ្ញាចិត្តរបស់យើង ក្នុងការលើកកម្ពស់ស្តង់ដារនៅកម្ពុជា។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យថ្មីមួយដើម្បីលើកកម្ពស់បទប្បញ្ញត្តិសុវត្ថិភាពអគ្គិភ័យសម្រាប់អគារពាណិជ្ជកម្ម និងអគារប្រើប្រាស់ក្នុងគោលបំណងចម្រុះ ដោយចែងថាអគារទាំងអស់នេះ

ត្រូវតែមានប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ។ ប៉ុន្តែ សេចក្ដីលម្អិតច្រើនជាងនេះថែមទៀត នៅតែត្រូវការចាំបាច់អំពីថាតើយថាប្រភេទ និងបទដ្ឋានអ្វីខ្លះ ដែលម្ចាស់អគារត្រូវបានតម្រូវឱ្យអនុវត្ត ដើម្បីអនុលោមតាមរបបអធិការកិច្ចដែលទើបបានបង្កើតឡើងថ្មីនេះ។

ជំពូកស្ដីពីវិស័យអចលនទ្រព្យ និងសំណង់ គឺជាជំពូកធំជាងគេបំផុតនៅក្នុងសៀវភៅ ស ប្រចាំឆ្នាំនេះ ដែលបង្ហាញនូវបំណងប្រាថ្នារបស់វិស័យឯកជន ដែលចង់ឃើញការពង្រឹងបរិយាកាសនិយ័តកម្មនៅក្នុងប្រទេសកម្ពុជា។ អនុសាសន៍ខាងក្រោមនេះ ផ្ដើឡើងក្នុងគោលបំណងចង់ឱ្យមានទំនាក់ទំនងគ្នាទៅវិញទៅមក និងឱ្យអនុវត្តព្រមៗគ្នា ដើម្បីបង្កើតជាក្របខ័ណ្ឌមួយដែលពេញលេញ និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ។អាស្រ័យហេតុនេះ យើងបានដាក់បញ្ចូលរួមគ្នា នូវអនុសាសន៍ថ្មី អនុសាសន៍ដែលបានធ្វើបច្ចុប្បន្នភាព និងអនុសាសន៍ចាស់ៗកន្លងមកសម្រាប់ផ្នែកទាំងបួនរួមមាន៖ ការអភិវឌ្ឍវិស័យសុរិយោដី និងអចលនទ្រព្យ ការគ្រប់គ្រងដែនដី និងនគរូបនីយកម្ម ការធ្វើទំនើបកម្មបទប្បញ្ញត្តិស្ដីពីអចលនទ្រព្យលំនៅដ្ឋាន និងវិស័យសំណង់។

ចំពោះផ្នែកអភិវឌ្ឍន៍វិស័យសុរិយោដី និងអចលនទ្រព្យ អនុសាសន៍ថ្មីរបស់យើងមានគោលបំណងស្នើឱ្យមានការកាត់បន្ថយហានិភ័យដែលទាក់ទងនឹងការរចនាប្លង់វិស្វកម្ម និងការងារផ្សេងៗទៀត ដែលធ្វើឡើងដោយអ្នកពិគ្រោះយោបល់វិស័យសំណង់ ដោយតម្រូវឱ្យអ្នកទាំងនេះត្រូវការធានារ៉ាប់រងលើភារៈទទួលខុសត្រូវស៊ីវិល ដែលនេះជាការអនុវត្តទូទៅនៅក្នុងទីផ្សារប្រទេសជាច្រើនផ្សេងទៀត។ យើងក៏បានធ្វើបច្ចុប្បន្នភាពអនុសាសន៍ចំនួនពីរ ដើម្បីធ្វើឱ្យបទប្បញ្ញត្តិបែបនេះ ស្របទៅនឹងឧត្ដមានុវត្តន៍ - ភាពចាំបាច់ក្នុងការធ្វើបទដ្ឋានកម្ម(ស្ដង់ដារ) ទៅលើរង្វាស់សម្រាប់វិស័យអចលនទ្រព្យនិងក្នុងការបង្កើនការគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ការអភិវឌ្ឍលំនៅដ្ឋានដើម្បីផ្ដល់ការការពារក្នុងករណីដែលគម្រោងមួយទទួលបរាជ័យផងដែរ។

ខណៈដែលយើងបន្តផ្តល់ជំនួយផ្នែកបច្ចេកទេស និងផ្នែកច្បាប់ដល់រាជរដ្ឋាភិបាលលើការងារគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរ យើងបានធ្វើបច្ចុប្បន្នភាព អនុសាសន៍ស្នូលរបស់យើងសម្រាប់ផ្នែកគ្រប់គ្រងដីធ្លីនិងនគរូបនីយកម្ម ដើម្បីផ្តល់អាទិភាពទៅលើក្របខ័ណ្ឌច្បាប់សម្រាប់ការអភិវឌ្ឍទាំងនេះ និងលើកទឹកចិត្តដល់ការអនុវត្តគម្រោងគំរូដើម្បីសាកល្បងភាពជាដៃគូរាជរដ្ឋាភិបាល និងវិស័យឯកជន នៅក្នុងតំបន់ឆ្នេរនៃប្រទេសកម្ពុជា។

យើងបានដាក់បន្ថែមនូវផ្នែកថ្មីមួយស្តីពីការធ្វើទំនើបកម្មបទប្បញ្ញត្តិស្តីពីអចលនទ្រព្យលំនៅដ្ឋាន ដោយសារយើងជឿជាក់ថា ផ្នែកនេះនឹងជំរុញឱ្យទីផ្សារអចលនទ្រព្យលំនៅដ្ឋានរីកលូតលាស់កាន់តែមាននិរន្តរភាពថែមទៀត ហើយក៏នឹងបង្កើនកិច្ចការពារ ផ្នែកច្បាប់សម្រាប់ប្រជាជនដែលមានកម្មសិទ្ធិលំនៅដ្ឋាននៅក្នុងប្រទេសកម្ពុជាផងដែរ។ អនុសាសន៍ទាំងនេះផ្តោតលើការធ្វើឱ្យទៅជាផ្លូវការ និងការធ្វើសុខដុមនីយកម្មនូវការអនុវត្តដែលមានស្រាប់នៅគ្រប់ទម្រង់ផ្សេងៗគ្នានៃអចលនទ្រព្យលំនៅដ្ឋាន ទន្ទឹមគ្នាជាមួយនឹងការស្នើឱ្យមានការរៀបចំ និងដាក់ឱ្យអនុវត្តនូវបទដ្ឋានសម្រាប់ការគ្រប់គ្រងវិស័យអលចនទ្រព្យលំនៅដ្ឋានដែលជាវិស័យថ្មី។ លើសពីនេះទៅទៀត យើងសូមលើកទឹកចិត្តដល់រាជរដ្ឋាភិបាល ឱ្យបន្តកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការធ្វើទំនើបកម្មប្រព័ន្ធ និងនីតិវិធីនានា ដោយផ្តោតអាទិភាពទៅលើការធ្វើឌីជីថលនីយកម្មនូវដំណើរការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ តាមរយៈការបង្កើតកម្មវិធីអនឡាញ។

ជាចុងក្រោយ សម្រាប់វិស័យសំណង់ យើងខ្ញុំសូមស្នើផ្តល់ការគាំទ្រ និងពង្រឹងគំនិតផ្តួចផ្តើមនានារបស់រាជរដ្ឋាភិបាល ក្នុងការបញ្ចប់នូវច្បាប់ ស្តីពីការសាងសង់របស់ប្រទេសកម្ពុជា ដោយដាក់បញ្ចូលបទប្បញ្ញត្តិសាងសង់ (Building Code) និងបញ្ជាក់នូវសារៈសំខាន់នៃការបន្តការរៀបចំតាក់តែងស្តង់ដារសុខភាព និងសុវត្ថិភាពការងារ នៅតាមការដ្ឋានសំណង់។អនុសាសន៍ថ្មីនិងចុងក្រោយរបស់យើង បង្ហាញអំពីភាពចាំបាច់ សម្រាប់ការធ្វើតេស្តការធានារ៉ាប់រង គុណភាពជាកាតព្វកិច្ចសម្រាប់សម្ភារសាងសង់គ្រោងអគារនៅមុនពេលដាក់លក់ ដើម្បីធានាថាផលិតផលទាំងនោះត្រូវបានផលិតឡើងដោយស្របតាមស្តង់ដារដែលបានព្រមព្រៀងគ្នា ខណៈដែលវិស័យនេះកំពុងរង់ចាំការអនុម័តច្បាប់ស្តីពីការសាងសង់ដូចដែលបានលើកឡើងខាងលើ ។

៥៤

# ការធានារ៉ាប់រងលើភារៈទទួលខុសត្រូវស៊ីវិល

ថ្មី

**ពិពណ៌នាបញ្ហា**

ខណៈដែលមានសកម្មភាពសាងសង់ដ៏ច្រើនសន្ធឹកសន្ធាប់ ដែលកំពុងកើតមាននៅទូទាំងប្រទេសកម្ពុជា ក្រុមហ៊ុននានាដែលប្រតិបត្តិការនៅក្នុងវិស័យនេះ ត្រូវតែដឹងអំពីរបៀបដែលពួកគេអាចគ្រប់គ្រង និងកាត់បន្ថយហានិភ័យ ទាំងនៅក្នុងអំឡុងពេល និងនៅក្រោយពេលនៃការសាងសង់គម្រោងៗ នៅក្នុងប្រទេសកម្ពុជា ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន គឺជាលក្ខខណ្ឌតម្រូវកំណត់ដោយច្បាប់នៅមុនពេលគម្រោង សាងសង់ណាមួយអាចចាប់ផ្ដើមដំណើរការ ដូចដែលបានបញ្ជាក់នៅក្នុងច្បាប់ស្ដីពីការធានារ៉ាប់រង និងអនុក្រឹត្យដែលពាក់ព័ន្ធៗ នេះគឺដោយសារតែសកម្មភាពសំណង់មានលក្ខណៈហានិភ័យខ្ពស់ ចំនួនដើមទុន និងអ្នកពាក់ព័ន្ធដែលចូលរួមច្រើន និងភាពចាំបាច់ដើម្បីការពារភាគីទីបីប្រឆាំងនឹងការខូចខាតណាមួយដែលមិនអាច ដឹងមុនៗ ប្រសិនបើគម្រោងណាមួយមិនមានការធានារ៉ាប់រងគ្រប់គ្រាន់ទេនោះ ម្ចាស់គម្រោង និងអ្នកផ្សេងទៀតដែលពាក់ព័ន្ធអាចនឹងត្រូវសងការខូចខាតដែលនឹងប៉ះពាល់ធ្ងន់ធ្ងរទៅលើលទ្ធភាពសំរេច ថវិកា និងរយៈពេលបញ្ចប់គម្រោង ហើយក្នុងករណីខ្លះ អាចនឹងបណ្ដាលឱ្យគម្រោងត្រូវដួលរលំតែម្ដងៗ

ខណៈដែលម្ចាស់គម្រោងត្រូវបានតម្រូវឱ្យមានការធានារ៉ាប់រង ដើម្បីជំនះភាពមិនច្បាស់លាស់ដែលពាក់ព័ន្ធនឹងការសាងសង់ ជាក់ស្ដែងរបស់គម្រោងមួយនៅកម្ពុជាសព្វថ្ងៃ នៅមិនទាន់មានការតម្រូវចំពោះអ្នកពិគ្រោះយោបល់ជំនាញដែលទទួលខុសត្រូវលើការរចនាប្លង់ វិស្វកម្ម វាស់វែង និងការងារធំៗផ្សេងទៀត ដែលជាកត្តាដ៏សំខាន់ចំពោះភាពជោគជ័យរបស់គម្រោង មានធានារ៉ាប់រងនៅឡើយទេៗ អ្នកពិគ្រោះយោបល់ទាំងនេះ ជាធម្មតា មិនស្ថិតនៅក្រោមការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានទូទៅទេ ដែលជារឿយៗ និយមន័យនៃការធានារ៉ាប់រងភារៈនេះ ទូទៅគឺមានលក្ខណៈតូចចង្អៀត ហើយអ្នកពិគ្រោះយោបល់ទាំងនេះ ត្រូវបានតម្រូវឱ្យមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវស៊ីវិលផ្ទាល់ខ្លួន ដើម្បីធានាពួកគេពីហានិភ័យនានាអាចដែលអាចកើតមានក្នុងអំឡុងពេលអនុវត្តការងារវិជ្ជាជីវៈរបស់ខ្លួនៗ

ដោយសារតែគេពឹងផ្អែកទៅលើការបណ្ដុះបណ្ដាល ចំណេះដឹង និងជំនាញរបស់អ្នកពិគ្រោះយោបល់ ការធានារ៉ាប់រងគឺសំដៅរ៉ាប់រងទៅលើការខាតបង់ផ្នែកសេដ្ឋកិច្ច ដូចជា ថ្លៃសាងសង់កើនឡើង ការខាតបង់ប្រាក់ចំណេញ ឬការខាតបង់ការប្រើប្រាស់ ដោយសារតែការធ្វេសប្រហែសឬកំហុសផ្សេងទៀតរបស់អ្នកពិគ្រោះយោបល់ នៅក្នុងអំឡុងពេលបំពេញការងាររបស់ពួកគេឡើយៗ ស្រដៀងគ្នានេះដែរ ក្នុងករណីមានរបួសស្នាម ឬការខូចខាតលើទ្រព្យសម្បត្តិណាមួយដែលកើតចេញពីទង្វើខុសឆ្គង ខណៈដែលអ្នកពិគ្រោះយោបល់កំពុងបំពេញការងារវិជ្ជាជីវៈរបស់ខ្លួន ទាំងនេះនឹងត្រូវគ្របដណ្ដប់ដោយផែនការធានារ៉ាប់រងលើភារៈទទួលខុសត្រូវស៊ីវិលដាច់ដោយឡែកៗ ទំហំនៃការគ្របដណ្ដប់នៃការធានារ៉ាប់រង គឺអាស្រ័យទៅតាមការងារ ឬសេវារបស់អ្នកពិគ្រោះយោបល់ដែលបានផ្ដល់ ប៉ុន្តែទំហំនៃការគ្របដណ្ដប់ត្រូវតែគ្រប់គ្រាន់ដើម្បីរ៉ាប់

*រងទៅលើការចូលរួមរបស់ពួកគេនៅក្នុងគម្រោង និងកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេពីការប្ដឹងទាមទារសំណងពីភាគីទីបីណាមួយ។*

*នៅក្នុងតំបន់អាស៊ាន ប្រទេសវៀតណាម និងសិង្ហបុរីបានអនុម័តបទប្បញ្ញត្តិ ដែលតម្រូវឱ្យអ្នកពិគ្រោះយោបល់សំណង់ត្រូវតែមានធានារ៉ាប់រងលើភារៈទទួលខុសត្រូវស៊ីវិលជាកាតព្វកិច្ច ចំណែកឯនៅក្នុងទីផ្សារដទៃទៀត ម្ចាស់គម្រោង និងសមាគមវិស័យនេះជារឿយៗអាចតម្រូវឱ្យមានការធានារ៉ាប់រងជាលក្ខខណ្ឌនៃការជួញថ្លៃ ឬសមាជិកភាព។ ដោយសារតែការអនុវត្តជាទូទៅបែបនេះ ក្រុមហ៊ុនសំណង់ជាច្រើនដែលកំពុងធ្វើប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា តម្រូវឱ្យអ្នកពិគ្រោះយោបល់ដែលខ្លួនធ្វើការជាមួយ ត្រូវមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវស៊ីវិលក្នុងកម្រិតអប្បបរមា ដើម្បីធានាថាពួកគេនឹងមិនត្រូវបង្ខំឱ្យទទួលខុសត្រូវចំពោះការធ្វេសប្រហែសរបស់អ្នកពិគ្រោះយោបល់នោះឡើយ។*

*ខណៈដែលការអនុវត្តបែបនេះ អាចមានសម្រាប់ក្រុមហ៊ុនល្បីៗជាច្រើនដោយសារតែនេះមិនមែនជាលក្ខខណ្ឌតម្រូវផ្លូវច្បាប់ ហើយម្យ៉ាងវិញទៀត សមាគមវិជ្ជាជីវៈក៏មិនអាចពង្រឹងការអនុវត្តលក្ខខ័ណ្ឌតម្រូវស្ដីពីការធានារ៉ាប់រងនេះទៅលើសមាជិកខ្លួនឯងបាន អ្នកពិគ្រោះយោបល់ជាច្រើននៅតែបន្តប្រតិបត្តិការដោយគ្មានការការពារបែបនេះដដែល។*

## ផលប៉ះពាល់លើកម្ពុជា

*ខណៈដែលវិស័យសំណង់របស់កម្ពុជានៅតែបន្តការលូតលាស់គួរឱ្យកត់សម្គាល់ ការទាក់ទាញវិនិយោគធំៗ និងការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធដែលមានចំនួនកាន់តែច្រើនឡើង ការធ្វេសប្រហែស និងឧប្បត្តិហេតុផ្សេងៗ ក៏ត្រូវបានគេសន្មតថានឹងកើនឡើងខ្ពស់ទៅដែរ។ ស្រដៀងគ្នានេះ ដោយសារតែប្រព័ន្ធច្បាប់នៅកម្ពុជាបន្តពង្រឹងជាបន្តបន្ទាប់ផងដែរនោះ លទ្ធភាពនៃការកើតមានបណ្ដឹងវិវាទប្រឆាំងនឹងអ្នកទាំងឡាយដែលប្រព្រឹត្តនូវការធ្វេសប្រហែស ក៏នឹងកើនឡើងដែរ ដែលអាចនឹងនាំឱ្យអ្នកប្រកបការងារក្នុងវិស័យនេះប្រឈមនឹងភារៈទទួលខុសត្រូវនានា។*

*ការតម្រូវឱ្យអ្នកពិគ្រោះយោបល់សំណង់ មានការធានារ៉ាប់រងភារៈទទួលខុសត្រូវស៊ីវិលក្នុងកម្រិតសមស្របមួយ នឹងកាត់បន្ថយការគំរាមកំហែងពីភាពក្ស័យធនពីព្រោះទាំងរូបវន្តបុគ្គល និងក្រុមហ៊ុន កម្រនឹងមានធនធានគ្រប់គ្រាន់ដើម្បីរ៉ាប់រងថ្លៃចំណាយលើបណ្ដឹងវិវាទដើម្បីតតាំងនឹងការទាមទារ ឬសងជាការប៉ះប៉ូវណាស់។ ដូច្នេះហើយ ការមានធានារ៉ាប់រងសមស្របនឹងការពារចំណូលនាពេលអនាគតរបស់អ្នកពិគ្រោះយោបល់សំណង់ និងភាពយូរអង្វែងរបស់ក្រុមហ៊ុនធុរកិច្ចរបស់ពួកគេ ទន្ទឹមគ្នានោះការធានារ៉ាប់រងនឹងផ្ដល់ការការពារដល់ជនទាំងឡាយដែលរងផលប៉ះពាល់ដោយសារការធ្វេសប្រហែសផងដែរ។*

*លើសពីនេះទៅទៀត ការតម្រូវឱ្យអ្នកពិគ្រោះយោបល់ទិញធានារ៉ាប់រង នឹងក្លាយជាអាជ្ញាប័ណ្ណដើម្បីធ្វើឱ្យក្រុមហ៊ុនធុរកិច្ចនៅក្នុងវិស័យសំណង់ និងបង្ខំឱ្យមានអនុលោមភាពកាន់តែប្រសើរឡើង ចំពោះបទប្បញ្ញត្តិផ្សេងទៀតទាំងអស់ ដែលអនុម័តដោយរាជរដ្ឋាភិបាល។ នេះគឺដោយសារតែមានដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវមានភាពតឹងរ៉ឹងខ្លាំងនៅពេលធ្វើការវាយតម្លៃហានិភ័យ ពីព្រោះក្រុមហ៊ុនទាំង*

*នេះនឹងមិនផ្តល់ការធានារ៉ាប់រងចំពោះក្រុមហ៊ុនទាំងឡាយណាដែលមិនគោរពច្បាប់ ឬដែលមិនមានស្ថានភាពហិរញ្ញវត្ថុល្អនោះទេ ដោយសារតែពួកគេយល់ឃើញថាអាចប្រឈមនឹងហានិភ័យខ្ពស់ពេក។ ដូចគ្នានេះដែរ ម្ចាស់គម្រោងទំនងជានឹងមិនធ្វើការជាមួយនឹងអ្នកពិគ្រោះយោបល់ណា ដែលមិនមានបណ្ណធានារ៉ាប់រងត្រឹមត្រូវនោះទេ ពីព្រោះពួកគេអាចនឹងត្រូវបង្ខំឱ្យទទួលខុសត្រូវ ដែលជាផលវិបាកពីការធ្វេសប្រហែសរបស់អ្នកពិគ្រោះយោបល់។*

*ការពង្រឹងការអនុវត្តការធានារ៉ាប់រង ភារៈទទួលខុសត្រូវស៊ីវិលជាកាតព្វកិច្ចនេះ ក៏អាច នឹងផ្តល់នូវផលប្រយោជន៍បន្ថែមដល់សេដ្ឋកិច្ចកម្ពុជាផងដែរ ពីព្រោះអ្នកពិគ្រោះយោបល់ដែលមិនទាន់ទិញធានារ៉ាប់រងអន្តរជាតិ នឹងត្រូវបង្ខំទិញធានារ៉ាប់រងក្នុងស្រុក ឬចំពោះអ្នកទាំងឡាយ ដែលមិនអាចទិញបណ្ណធានារ៉ាប់រងក្នុងស្រុកបាន គឺចាំបាច់ត្រូវតែចាប់ដៃគូជាមួយនឹងក្រុមហ៊ុនក្នុងស្រុក ដែលនឹងរ៉ាប់រងនូវទំនួលខុសត្រូវនេះ។ ប្រការនេះ នឹងនាំឱ្យមានការផ្ទេរចំណេះដឹងកាន់តែប្រសើរឡើង ដល់ក្រុមហ៊ុនកម្ពុជា និងពង្រឹងភាពជាដៃគូកាន់តែរឹងមាំជាមួយនឹងអ្នកជំនាញបរទេសផងដែរ។*

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យធ្វើការពិចារណា លើការកំណត់ជាលក្ខខណ្ឌតម្រូវឱ្យអ្នកពិគ្រោះយោបល់ទាំងអស់ ដែលចូលរួមក្នុងគម្រោងសាងសង់នៅក្នុងប្រទេសកម្ពុជា ត្រូវតែមានធានារ៉ាប់រងទំនួលខុសត្រូវស៊ីវិលជាកាតព្វកិច្ច។

*យើងខ្ញុំសូមគោរពផ្តល់ជូននូវអនុសាសន៍ដល់ រាជរដ្ឋាភិបាលគប្បីធ្វើការពិចារណាលើការតម្រូវឱ្យអ្នកពិគ្រោះយោបល់ទាំងអស់ដែលប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាដែលចូលរួមនៅក្នុងការងារធំដុំនៃគម្រោងសំណង់ ត្រូវតែមានការធានារ៉ាប់រងភារៈទទួលខុសត្រូវស៊ីវិលជាកាតព្វកិច្ច។ ការធ្វើបែបនេះនឹងធានាកិច្ចការពារគ្រប់គ្រាន់ដល់ភាគីទីបីពីផលវិបាកដែលកើតចេញពីការធ្វេសប្រហែស របស់អ្នកពិគ្រោះយោបល់ដែលបំពេញការងារវិជ្ជាជីវៈរបស់ខ្លួន ទន្ទឹមគ្នានឹងនោះក៏អាចការពារធុរកិច្ចរបស់អ្នកពិគ្រោះយោបល់មិនឱ្យក្ស័យធន និងកេរ្តិ៍ឈ្មោះរបស់វិស័យសំណង់ផងដែរ។*

*លក្ខខណ្ឌតម្រូវនេះ ក៏អាចបូករួមបញ្ចូលគ្នាជាមួយនឹងការជំរុញឱ្យអ្នកពិគ្រោះយោបល់ក្នុងស្រុក ឱ្យចូលរួមនៅក្នុងសមាគមវិជ្ជាជីវៈរបស់ខ្លួន ដូចជា គណៈវិស្វករកម្ពុជា និងគណៈស្ថាបត្យករកម្ពុជាជាដើម។ ការធ្វើបែបនេះ ក៏នឹងគាំទ្រដល់ការរីកចម្រើន របស់សមាគមទាំងនេះឱ្យក្លាយជាសំឡេងរួមតំណាងឱ្យវិជ្ជាជីវៈរបស់ខ្លួន និងលើកកម្ពស់បទដ្ឋាន និងជំនាញនៅក្នុងវិស័យ ដោយជំរុញឱ្យមានការអភិវឌ្ឍវិជ្ជាជីវៈជាប់រហូតទៀតផង។*

៥៥

# ការវាស់វែងដែលមានស្តង់ដារ

រក្សាទុកដដែល

## ពិពណ៌នាបញ្ហា

នាពេលបច្ចុប្បន្ន ប្រទេសកម្ពុជានៅពុំទាន់មានរបៀបជាស្តង់ដារនៃការពណ៌នាអំពីការវាស់វែងសំណង់អគារនៅឡើយទេ ហើយក៏គ្មានការបញ្ជាក់អំពីថាតើប្រភេទរង្វាស់ ឬការវាស់វែងមួយណា ដែលត្រូវអនុវត្តចំពោះប្រភេទនៃការប្រើប្រាស់អចលនទ្រព្យនីមួយៗដែរ។ បញ្ហានេះបានឈានទៅដល់ស្ថានភាពមួយដែលអ្នកជំនាញវិជ្ជាជីវៈក្នុងវិស័យអចលនទ្រព្យ អាចប្រើប្រាស់បច្ចេកទេសខុសៗគ្នាដែលធ្វើឱ្យមានភាពស្រពិចស្រពិលដល់និយមន័យនៃអ្វីដែលជាតំបន់ដែលបានវាស់វែង។ ឧទាហរណ៍ តួអង្គអចលនទ្រព្យខ្លះ ប្រើប្រាស់ផ្ទៃក្រឡាសរុបនៅពេលពណ៌នាអំពីផ្ទៃក្រឡារបស់អចលនទ្រព្យ ប៉ុន្តែក្នុងករណីខ្លះទៀត ផ្ទៃក្រឡានេះអាចគិតរួមបញ្ចូលទាំងផ្ទៃនានា ដូចជា ជណ្តើរយោង ទីធ្លាល័ហទុកសម្រាប់ប្រឡោះជណ្តើរ និងយ៉ខាងក្រៅ ខណៈដែលភាគីមួយផ្សេងទៀត អាចប្រើពាក្យ "ផ្ទៃក្រឡាសរុប" ដូចគ្នា ប៉ុន្តែ មិនគិតរាប់បញ្ចូលទាំងអ្វីៗដែលបានរៀបរាប់មុននេះទេ។ ភាពខុសគ្នានៃនិយមន័យនេះបានធ្វើឱ្យការប្រៀបធៀបអចលនទ្រព្យពីរផ្សេងគ្នាត្រូវចំណាយពេលវេលាច្រើន និងមានភាពច្របូកច្របល់ ដែលបានបង្កើតជាបញ្ហានានាសម្រាប់គ្រប់ភាគីទាំងអស់នៅក្នុងវិស័យនេះ ជាពិសេស អ្នកវាយតម្លៃ ភ្នាក់ងារ អ្នកកាន់កាប់ និងអ្នកវិនិយោគ។ ការស្រាវជ្រាវបង្ហាញថាផ្ទៃក្រឡាកម្រាលនៃអចលនទ្រព្យមួយអាចខុសគ្នាដល់ទៅ ២៤% ដោយអាស្រ័យទៅតាមវិធីសាស្ត្រវាស់វែងដែលគេប្រើប្រាស់ ហើយសូម្បីតែការខុសគ្នាតែបន្តិចក៏អាចមានផលប៉ះពាល់ធំដុំទៅលើការវាយតម្លៃអចលនទ្រព្យបានដែរ។

នៅក្នុងប្រទេសជាច្រើន ស្ថាប័ននិយ័តកម្ម គឺជាអ្នកដាក់ចេញនូវនិយមន័យកម្រងនៃការវាស់វែង និងចែងអំពីវិធីសាស្ត្រ ដែលសមស្របសម្រាប់ការពណ៌នាអំពីប្រភេទអចលនទ្រព្យនីមួយៗ។ ស្តង់ដារវាស់វែងអចលនទ្រព្យ កំពុងត្រូវបានធ្វើឱ្យកាន់តែមានស្តង់ដារប្រសើរឡើងនៅកម្រិតពិភពលោក ដើម្បីអនុញ្ញាតឱ្យភ្នាក់ងារ អ្នកវិនិយោគ និងអ្នកអភិវឌ្ឍន៍ អាចធាប់ និងងាយស្រួលយល់អំពីមូលដ្ឋានសម្រាប់ការវាស់វែង និងដើម្បីអាចធ្វើការប្រៀបធៀបត្រឹមត្រូវជាមួយនឹងអចលនទ្រព្យនៅក្នុងប្រទេសដទៃទៀត ។

## ផលប៉ះពាល់លើកម្ពុជា

កង្វះនូវបច្ចេកទេសវាស់វែងដែលមានស្តង់ដារ នាំឱ្យមានកង្វះប្រសិទ្ធផលនៅក្នុងទីផ្សារ ហើយក្នុងករណីអាក្រក់បំផុតនោះ អាចនឹងទុកចន្លោះប្រហោងឱ្យមានការរំលោភបំពាននៅក្នុងវិស័យនេះទៀតផង។ ទីបំផុតទៅ គឺអ្នកប្រើប្រាស់នឹងក្លាយជាអ្នកខាតបង់ពីភាពមិនច្បាស់លាស់នេះ ហើយម្យ៉ាងវិញទៀត បញ្ហានេះជំរុញឱ្យអ្នកទិញ និងអ្នកជួលបាត់បង់ជំនឿចិត្ត ដោយសារតែបទពិសោធន៍មិនល្អទាំងអស់នេះ។ បញ្ហានេះអាចបង្កើតជាការលំបាកចំពោះទីផ្សារអចលនទ្រព្យ និងបរិយាកាសវិនិយោគរបស់ប្រទេសកម្ពុជាទាំងមូល។ ខណៈដែលការវិនិយោគលើអចលនទ្រព្យឆ្លងដែនមានកាន់តែកើនឡើង ការមានវិធីសាស្ត្រវាស់វែងជាស្តង់ដារដែលគេទទួលស្គាល់ទូលំទូលាយ នឹងអាចជួយកាត់បន្ថយឧបសគ្គចំពោះការចូលមកក្នុងទីផ្សារ និងបង្កើនទំនុកចិត្តកាន់តែខ្លាំងបន្ថែមទៀត។

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យមានការដាក់ចេញនូវស្តង់ដារជាសកលសម្រាប់ការវាស់វែងនៅក្នុងវិស័យអចលនទ្រព្យ។

*ការដាក់ចេញនូវគោលការណ៍វាស់វែង នឹងជួយលើកកម្ពស់វិធីសាស្ត្រវាស់វែងដែលមានស្តង់ដារត្រឹមត្រូវ នៅទូទាំងប្រទេសកម្ពុជា ដែលនឹងពង្រឹងតម្លាភាព និងអនុញ្ញាតឱ្យអ្នកជំនាញវិជ្ជាជីវៈអចលនទ្រព្យអាចមានទំនុកចិត្តកាន់តែខ្លាំងឡើងនៅក្នុងការផ្តល់ការណែនាំ និងនៅក្នុងទីផ្សារអចលទ្រព្យ។ អាស្រ័យហេតុនេះ យើងខ្ញុំសូមគោរពផ្តល់ជូននូវអនុសាសន៍ដល់រាជរដ្ឋាភិបាល សូមធ្វើឱ្យវិធីសាស្ត្រវាស់វែងអចលនទ្រព្យមានស្តង់ដារ ដោយកំណត់ច្បាស់លាស់អំពីថាតើជាតុផ្សំណាខ្លះនៃអចលនទ្រព្យ ដែលត្រូវរាប់បញ្ចូល និងថាតើជាតុផ្សំណាខ្លះដែលត្រូវដកចេញពីផ្ទៃក្រឡាសរុបដើម្បីកាត់បន្ថយភាពមិនច្បាស់លាស់ដែលកំពុងមាន។*

*ពិតណាស់ថា រាជរដ្ឋាភិបាល គឺជាអ្នកសម្រេចចិត្តទៅលើនិយមន័យនៃការវាស់វែងបែបណាដែលសមស្របបំផុតសម្រាប់ប្រទេសកម្ពុជា ប៉ុន្តែយើងខ្ញុំសូមជូនជាយោបល់ដល់រាជរដ្ឋាភិបាល សូមពិចារណាយកលំនាំតាមវិធីសាស្ត្រ ដែលដាក់ចេញដោយសម្ព័ន្ធស្តង់ដារវាស់វែងអចលនទ្រព្យអន្តរជាតិ* (IPMSC)។ *សម្ព័ន្ធ* IPMSC *បានក្លាយជាមាគ៌ាដែលពេញនិយម សម្រាប់ការបង្កើតស្តង់ដារនូវការវាស់វែងជាសាកល និងត្រូវបានអនុម័តដោយអង្គការវិជ្ជាជីវៈ និងអង្គការមិនស្វែងរកប្រាក់ចំណេញអន្តរជាតិជាង ៧០ ក្នុងនោះរួមទាំង សមាគមអចលនទ្រព្យអាស៊ី ប៉ាស៊ីហ្វិក* (Asia Pacific Real Estate Association) *វិទ្យាស្ថានអ្នកវាយតម្លៃ និងភ្នាក់ងារអលចនទ្រព្យចិន* (China Institute of Real Estate Appraisers and Agents) *និង វិទ្យាស្ថាន* Royal Institute of Chartered Surveyors។ *សមាជិក* IPMSC *ធ្វើការរួមគ្នាដើម្បីអភិវឌ្ឍ និងអនុម័តនូវស្តង់ដារវាស់វែងអចលនទ្រព្យរួមគ្នាតែមួយ ក្នុងគោលបំណងជំរុញឱ្យមានភាពស៊ីសង្វាក់គ្នា និងភាពជឿជាក់នៅក្នុងវិស័យអចលនទ្រព្យនៅទូទាំងពិភពលោក។*

៥៦

# ការគ្រប់គ្រងហិរញ្ញវត្ថុក្នុងអំឡុងពេលនៃការអភិវឌ្ឍគម្រោង

**ធ្វើបច្ចុប្បន្នភាព**

**ពិពណ៌នាបញ្ហា**

*ដើម្បីកាត់បន្ថយហានិភ័យហិរញ្ញវត្ថុ នៅក្នុងវិស័យអចលនទ្រព្យ និងសំណង់ ប្រទេសជាច្រើន បានដាក់ចេញនូវលក្ខខណ្ឌតម្រូវស្តីពីដើមទុនអប្បបរមា ដែលត្រូវតែបំពេញឱ្យបាន មុនពេលទទួលបានលិខិតអនុញ្ញាតសាងសង់សម្រាប់គម្រោងមួយៗ។ អ្នកអភិវឌ្ឍត្រូវតែអាចបង្ហាញឱ្យឃើញថា ខ្លួនពិតជាមានដើមទុនស្មើនឹង ភាគរយជាក់លាក់ណាមួយនៃតម្លៃរបស់គម្រោងប្រាកដមែន។*

*ប្រកាសលេខ ៩៦៥ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍន៍លំនៅដ្ឋាន ដែលចេញកាលពីថ្ងៃទី២៤ខែសីហា ឆ្នាំ២០១៦ មានគោលបំណងដោះស្រាយក្តីកង្វល់នេះ ដោយបានកំណត់នូវលក្ខខណ្ឌតម្រូវដើមទុនអប្បបរមា សម្រាប់គម្រោងសាងសង់លំនៅដ្ឋានដែលមានតម្លៃជាទឹកប្រាក់ចំនួន ២ ពាន់លានរៀល (ស្មើនឹងប្រហែល ៥០០.០០០ ដុល្លារអាមេរិក)។ ដូចគ្នានេះដែរ ប្រសិនបើអ្នកអភិវឌ្ឍមានបំណងលក់សំណង់លំនៅដ្ឋានដើម្បីប្រមូលមូលនិធិ ខណៈដែលសំណង់នោះកំពុងដំណើរការសាងសង់ ពួកគេត្រូវតែមានប្រាក់ធានានៅក្នុងធនាគារ ស្មើនឹង ២% នៃដើមទុនវិនិយោគសរុប ឬដោយបង់តាមដំណាក់កាល។ ខណៈពេលដែលសេចក្តីសម្រេចនេះបានទទួលបានការស្វាគមន៍សមាជិករបស់យើងយល់ឃើញគិតថាលក្ខខណ្ឌតម្រូវនេះមិនទាន់គ្រប់គ្រាន់ដើម្បីអាចចាត់ទុកជាសំណាញ់សុវត្ថិភាពគ្រប់គ្រាន់សម្រាប់អតិថិជន និងសម្រាប់ទីផ្សារទាំងមូលឡើយ ក្នុងករណីដែលគម្រោងណាមួយដួលរលំ។*

*ជាការប្រៀបធៀបនៅថ្នាក់តំបន់ អ្នកអភិវឌ្ឍនៅក្នុងប្រទេសម៉ាឡេស៊ីត្រូវបានរឹតត្បិតលើការប្រើប្រាស់មូលនិធិរបស់អ្នកទិញ ដោយសារតែអ្នកអភិវឌ្ឍ អាចទទួលប្រាក់កក់បឋមតែ ១០% ប៉ុណ្ណោះ នៅមុនពេលដែលការសាងសង់ចាប់ផ្តើម ហើយក្រោយមកទៀត ការបង់ប្រាក់ត្រូវធ្វើឡើងជាដំណាក់ៗ ដោយយោងទៅតាមដំណាក់កាលនៃការងារសាងសង់ ដែលបានធ្វើរួចរាល់ ដោយមានអត្រាចន្លោះ ចាប់ពី ៥% ដល់ ១៥% នៃតម្លៃទិញសរុប។ មូលនិធិទាំងនេះ ត្រូវដាក់តម្កល់នៅក្នុងគណនីអភិវឌ្ឍន៍លំនៅដ្ឋានមួយ ដែលគ្រប់គ្រងដោយក្រសួងអភិវឌ្ឍន៍លំនៅដ្ឋាន របស់ម៉ាឡេស៊ី ហើយអាចប្រើប្រាស់បាន លុះត្រាតែវឌ្ឍនភាពនៃការសាងសង់ ត្រូវបានបញ្ជាក់ដោយស្ថាបត្យករដែលទទួលខុសត្រូវលើគម្រោង ដែលនេះគឺជាការធានាការប្រើប្រាស់មូលនិធិត្រឹមត្រូវផង និងការការពារអតិថិជនផង ក្នុងករណីគម្រោងត្រូវបរាជ័យ។ បញ្ញត្តិបែបនេះ បង្កើនថ្លៃចំណាយ ពេលចាប់ផ្តើមគម្រោងមួយ ប៉ុន្តែជួយទប់ស្កាត់អ្នកអភិវឌ្ឍមិនឱ្យចាប់ផ្តើមគម្រោងនានា ដែលពឹងផ្អែកហិរញ្ញវត្ថុទៅលើមូលនិធិប្រមូលមុនពេលលក់ ដែលជារឿយៗ គម្រោងបែបនេះមានហានិភ័យខ្ពស់នៃការអសមត្ថភាពសាងសង់នៅមុនពេលគម្រោងបញ្ចប់ជាស្ថាពរ។*

## ផលប៉ះពាល់លើកម្ពុជា

*អ្នកអភិវឌ្ឍដែលអនុវត្តគម្រោងនានា ដោយគ្មានដើមទុនចាប់ផ្តើមគ្រប់គ្រាន់ គឺជាហានិភ័យដ៏ធំមួយចំពោះទីផ្សារអចលនទ្រព្យរបស់កម្ពុជា និងសេដ្ឋកិច្ចជាតិទាំងមូល។ ប្រសិនបើគម្រោងណាមួយដួលរលំផ្នែកហិរញ្ញវត្ថុនៅមុនពេលសាងសង់រួចរាល់ នោះអាចនឹងប៉ះពាល់ដល់ជំនឿទុកចិត្ត ទៅលើទីផ្សារអចលនទ្រព្យ និងមានផលប៉ះពាល់បន្ទាប់បន្សំជាច្រើនផ្សេងទៀត ដូចជា ការលក់នៅមុនការបញ្ចប់គម្រោងផ្សេងទៀតនឹងធ្លាក់ចុះ ឬអតិថិជនដកប្រាក់កក់វិញ ជាដើម។ ប្រសិនបើករណីបែបនេះកើតមានមែននោះ អាចនឹងបង្ក "ឥទ្ធិពលដូមីណូ" ទៅលើវិស័យអចលនទ្រព្យរបស់កម្ពុជា និងអាចបណ្តាលឱ្យដួលរលំទីផ្សារទាំងមូលទៀតផង។*

*អាស្រ័យហេតុនេះ សម្រាប់ជាប្រយោជន៍ដល់ទាំងរាជរដ្ឋាភិបាល និងទាំងភាគីពាក់ព័ន្ធទាំងអស់ គប្បីមានការដាក់ឱ្យអនុវត្តនូវវិធានការគ្រប់គ្រងហិរញ្ញវត្ថុរឹងមាំដើម្បីត្រួតពិនិត្យគម្រោងអភិវឌ្ឍន៍លំនៅដ្ឋានដើម្បីផ្តល់ការការពារសមស្រប និងធានានូវកំណើនប្រកបដោយនិរន្តរភាពនៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។*

## អនុសាសន៍ឆ្នាំ ២០១៩

- ✓ សូមស្នើឱ្យធ្វើការពិចារណាបង្កើនការគ្រប់គ្រងហិរញ្ញវត្ថុ ដែលបង្កើតឡើងសម្រាប់គម្រោងអភិវឌ្ឍន៍លំនៅដ្ឋាន ដោយស្របតាមការអនុវត្តរបស់បណ្តាប្រទេសសមាជិកអាស៊ានផ្សេងទៀត ដើម្បីផ្តល់នូវកិច្ចការពារគ្រប់គ្រាន់ដល់អតិថិជន នៅក្នុងករណីដែលគម្រោងដួលរលំ។

*ដោយទទួលស្គាល់ថា រាជរដ្ឋាភិបាលបានជ្រាបរួចហើយអំពីហានិភ័យជុំវិញអ្នកអភិវឌ្ឍ ដែលអនុវត្តគម្រោងសាងសង់ដោយគ្មានដើមទុនគ្រប់គ្រាន់នៅក្នុងប្រទេសកម្ពុជា សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា សូមផ្តល់ជូនជាអនុសាសន៍ថា គួរបង្កើនលក្ខខណ្ឌតម្រូវដើមទុនអប្បបរមា ដើម្បីឱ្យស្របតាមការអនុវត្តនៅក្នុងបណ្តាប្រទេសសមាជិកអាស៊ាន ដែលជាប្រទេសជិតខាងរបស់កម្ពុជា។ ការបង្កើនដើមទុនអប្បបរមាដែលតម្រូវឱ្យមានសម្រាប់អភិវឌ្ឍគម្រោងលំនៅដ្ឋាន ទៅដល់តម្លៃមួយដែលផ្តល់តុល្យភាពសមស្របរវាងការការពារអតិថិជនតាមរយៈការត្រួតពិនិត្យផ្នែកច្បាប់បន្ថែម និងដោយស្របតាមគោលបំណងគោលនយោបាយរដ្ឋាភិបាល ក្នុងការអនុគ្រោះដល់វិនិយោគទុនដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍកាន់តែលឿនថែមទៀត។*

*យើងខ្ញុំសូមគោរពផ្តល់ជូននូវអនុសាសន៍ គប្បីរៀបចំឱ្យមានវិស័យឯកជនចូលរួមនៅក្នុងកិច្ចពិគ្រោះយោបល់ដើម្បីប្រមូលទិន្នន័យ និងព័ត៌មានពាក់ព័ន្ធដើម្បីកំណត់នូវកម្រិតគំរូសមស្របបំផុតមួយ។ កម្ពុជា ពិតជាអាចបន្តលើកទឹកចិត្តដល់លំហូរវិនិយោគទុន និងធ្វើឱ្យប្រសើរឡើងនូវភាពងាយស្រួលនៃបរិយាកាសធុរកិច្ច ហើយទន្ទឹមគ្នានោះដែរ ក៏បង្កើនការគ្រប់គ្រងផ្នែកច្បាប់ ដើម្បីធានានូវនិរន្តរភាពរបស់ទីផ្សារអចលនទ្រព្យផងដែរ។*

៥៧

# ការសម្របសម្រួលការវិនិយោគរដ្ឋ និងឯកជន នៅក្នុងការអភិវឌ្ឍតំបន់ឆ្នេរ

រក្សាទុកដដែល

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើឱ្យធ្វើការពិចារណា អនុញ្ញាតឱ្យមាន "គម្រោងគំរូ" ដើម្បីបង្ហាញដល់វិនិយោគិនអនាគត ថាការអភិវឌ្ឍតំបន់ឆ្នេរស្របតាមបទដ្ឋានអន្តរជាតិ គឺលទ្ធភាពអាចធ្វើទៅបាននៅក្នុងប្រទេសកម្ពុជា។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*គណៈកម្មាធិការអចលនទ្រព្យ និងសំណង់របស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ខិតខំប្រឹងប្រែងសហការជាមួយនឹងរាជរដ្ឋាភិបាល ដើម្បីរៀបចំសេចក្តីព្រាងក្របខ័ណ្ឌនិយ័តកម្មសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងតំបន់ឆ្នេរ តាមរយៈការសម្របសម្រួលជាតុចូលផ្លូវច្បាប់ និងការគាំទ្រផ្នែកបច្ចេកទេសពីអ្នកជំនាញបរទេស។ ទោះបីជាការចូលរួមនេះពិតជាមានសារៈប្រយោជន៍ខ្លាំងក្នុងការកំណត់អាទិភាពសម្រាប់ច្បាប់ថ្មី រួមមាន ការអនុម័តឯកសារច្បាប់ថ្មី ដូចជាបញ្ញត្តិស្តីពីការបែងចែកតំបន់ និងការលើកកម្ពស់ភាពជាដៃគូរវាងវិស័យរដ្ឋ និងវិស័យឯកជនក៏ដោយ ក៏បទប្បញ្ញត្តិថ្មីនេះមានវឌ្ឍនភាពតិចតួចប៉ុណ្ណោះចាប់តាំងពីពេលនោះរហូតមកដល់ពេលនេះ។*

*ខណៈដែលបណ្តាខេត្តនៅក្នុងតំបន់ឆ្នេរនៅកម្ពុជា កំពុងបន្តទាក់ទាញការវិនិយោគយ៉ាងច្រើនសន្ធឹកសន្ធាប់ ហើយការអភិវឌ្ឍនៅក្នុងតំបន់ទាំងនេះ កំពុងចំណាប់អារម្មណ៍កាន់តែខ្លាំងឡើង ការអនុម័តច្បាប់ថ្មីស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍតំបន់ឆ្នេរពិតជាសំខាន់ចាំបាច់ខ្លាំងណាស់ ហើយគួរតែផ្តល់អាទិភាព។*

**ពិពណ៌នាបញ្ហា**

*រាជរដ្ឋាភិបាលទទួលស្គាល់នូវផលប្រយោជន៍សង្គម និងសេដ្ឋកិច្ច ដែលអាចសម្រេចបានតាមរយៈគម្រោងអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព នៅក្នុងបណ្តាខេត្តតាមបណ្តោយឆ្នេរទាំងបួន គឺខេត្តកែប ខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកោះកុង ប៉ុន្តែដើម្បីប្រែក្លាយកាលានុវត្តភាពទាំងនេះ ទៅជាការពិតបាន ចាំបាច់ត្រូវតែមានស្ថាប័នគាំទ្រផ្នែកច្បាប់ និងបទប្បញ្ញត្តិ ដែលទាក់ទងនឹងការអភិវឌ្ឍតំបន់ឆ្នេរ។*

*បច្ចុប្បន្ន ក្របខ័ណ្ឌច្បាប់សម្រាប់គម្រោងអភិវឌ្ឍន៍ គឺផ្អែកតាមអនុក្រឹត្យលេខ ៨៦ ស្តីពីការផ្តល់លិខិតអនុញ្ញាតសាងសង់ ដែលបានចេញចាប់តាំងពីឆ្នាំ១៩៩៧ ដែលពណ៌នាអំពីប្រភេទនៃគម្រោងសាងសង់ ដែលតម្រូវឱ្យមាន លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអាជ្ញាធរខេត្ត ឬក្រុង។ អនុក្រឹត្យនេះក៏ផ្តល់ការណែនាំអំពីព័ត៌មាន ដែលត្រូវផ្តល់នៅពេលដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ផងដែរ។ អនុក្រឹត្យនេះដាក់ចេញឱ្យអនុវត្តនៅពេលដែលប្រទេសកម្ពុជានៅមានកម្រិតអភិវឌ្ឍន៍សេដ្ឋកិច្ចទាបនៅឡើយ ហើយពុំមានទិដ្ឋភាពជាក់លាក់អំពីប្រភេទនៃសំណង់ ឬគម្រោងហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំៗ ដែលបច្ចុប្បន្នអ្នកអភិវឌ្ឍ និងវិនិយោគិនកំពុងចាប់អារម្មណ៍កាន់តែខ្លាំងឡើយ។ ដូច្នេះច្បាប់គួរតែមានការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនាពេលបច្ចុប្បន្ន។*

*ការវិនិយោគរដ្ឋ និងឯកជន អាចសម្របសម្រួលឱ្យបានល្អប្រសើរជាងនេះថែមទៀត ដើម្បីធានានូវផលប្រយោជន៍របស់ភាគីទាំងសងខាង និងការអភិវឌ្ឍតំបន់បែងចែកនានាឱ្យកាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀត។ ប្រការនេះនឹងតម្រូវឱ្យរាជរដ្ឋាភិបាលប្រកាន់យកតួនាទីដឹកនាំច្រើនជាងនេះ តាមរយៈការកំណត់ "ផែនការមេ" នៃប្រភេទគម្រោងនានា ដែលខ្លួនចង់ឃើញឱ្យមានការអភិវឌ្ឍ និងថាតើហេដ្ឋារចនាសម្ព័ន្ធអ្វីខ្លះដែលត្រូវកសាង ដើម្បីគាំទ្រដល់គម្រោងទាំងនេះ។ បន្ទាប់មកទៀត គួរតែបង្កើតនិងដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធលើកទឹកចិត្តដល់វិស័យឯកជនក្នុងការអនុវត្តផែនការមេនេះ ដោយផ្តល់រង្វាន់ដល់វិនិយោគិននៅក្នុងគម្រោងឯកជននានាក្នុងទម្រង់ជាសម្បទានពន្ធ និងផលប្រយោជន៍ដទៃទៀត ជាថ្នូរនឹងការចូលរួមរបស់ពួកគេនៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ នៅក្នុងតំបន់ដែលបានបែងចែក។*

*ដើម្បីសម្រេចនូវចំណុចរៀបរាប់ខាងលើនេះ ចាំបាច់គឺត្រូវមានវេទិកាមួយដែលកាន់តែមានប្រសិទ្ធភាពថែមទៀត សម្រាប់ឱ្យអ្នកអភិវឌ្ឍអាចស្វែងយល់អំពីអាទិភាពអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ព្រមទាំងឯកសារច្បាប់នានា ដើម្បីគ្រប់គ្រងលើដំណើរការដេញថ្លៃ និងកំណត់ខ្លឹមសារ និង លក្ខខណ្ឌនៃភាពជាដៃគូរវាងរដ្ឋាភិបាល និងវិស័យឯកជន។ ក្របខ័ណ្ឌបែបនេះ នឹងផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាល ក្នុងការត្រួតពិនិត្យទៅលើគម្រោងអភិវឌ្ឍន៍នានា និងសមត្ថភាពក្នុងការធានាថាដៃគូវិស័យឯកជនអនុវត្តតាមការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ហើយទន្ទឹមនឹងនេះ ក៏ផ្តល់នូវការធានាគ្រប់គ្រាន់ដល់វិនិយោគិន ដើម្បីធានាសន្តិសុខសម្រាប់វិនិយោគរបស់ពួកគេផងដែរ។ កង្វះក្របខ័ណ្ឌច្បាប់បានបង្ហាញឱ្យឃើញថា ជាការបន្ទុចបង្អាក់ដល់អ្នកអភិវឌ្ឍ ក្នុងការពិចារណាគម្រោងអភិវឌ្ឍន៍ធំៗនៅក្នុងប្រទេសកម្ពុជា។*

*តាមរយៈគណៈកម្មាធិការអចលនទ្រព្យ និងសំណង់របស់ខ្លួន និងដោយផ្អែកទៅតាមលក្ខខណ្ឌនៃអនុស្សរណៈយោគយល់ជាមួយនឹងក្រសួង សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា បានផ្តល់ធាតុចូលផ្នែកច្បាប់ និងបច្ចេកទេស ដល់ គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ នៅក្នុងការរៀបចំតាក់តែងក្របខ័ណ្ឌច្បាប់ សម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរ។ ក្របខ័ណ្ឌនេះ គឺមានគោលបំណងសម្របសម្រួលដល់ការអភិវឌ្ឍ និងការផ្តល់សេវាកម្មនានា ដល់ "តំបន់អភិវឌ្ឍន៍" ដែលបានបែងចែក ដែលដើរតួនាទីជាឧបករណ៍មួយសម្រាប់ការធ្វើផែនការវិស័យរដ្ឋឱ្យស្របទៅនឹងការអនុវត្តរបស់វិស័យឯកជន។ ជាងនេះទៅទៀត ក្របខ័ណ្ឌនេះត្រូវបានបង្កើតឡើងដោយស្របទៅតាមកម្រងអនុសាសន៍ ដែលបង្កើតឡើងនៅក្នុងអំឡុងពេលនៃសន្និសីទវិស័យរដ្ឋ-ឯកជនអន្តរជាតិ ស្តីពី "ការអភិវឌ្ឍតំបន់ឆ្នេររបស់កម្ពុជា" ដែលបានប្រព្រឹត្តទៅកាលពីខែធ្នូ ឆ្នាំ២០១៦ នៅក្នុងខេត្តព្រះសីហនុ។ យើងខ្ញុំសូមស្វាគមន៍ការទទួលស្គាល់របស់រាជរដ្ឋាភិបាលចំពោះសារៈសំខាន់នៃគម្រោងនេះ និងវិធីសាស្រ្តតម្រង់ទិសសម្រាប់គោលបំណងជាក់លាក់នៃការរៀបចំតាក់តែងមូលដ្ឋានគ្រឹះច្បាប់បែបនេះឡើង។*

## ផលប៉ះពាល់លើកម្ពុជា

អ្នកអភិវឌ្ឍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ មើលឃើញភាពមិនច្បាស់លាស់នៅក្នុងក្របខ័ណ្ឌច្បាប់បច្ចុប្បន្ន សម្រាប់គម្រោងអភិវឌ្ឍន៍នានា នៅក្នុងប្រទេសកម្ពុជា ។ ឧទាហរណ៍ គម្រោងអភិវឌ្ឍន៍មួយដែលសាងសង់នៅលើដីដែលកាន់កាប់ដោយរដ្ឋ ក្នុងរូបភាពជាការជួលរយៈពេលវែង ពុំមានការធានាពិតប្រាកដទៅលើដីនោះទេ ហើយគេក៏មិនច្បាស់ទាំងស្រុង ថាតើអ្នកណាជាម្ចាស់នៃគម្រោងនោះ។ បញ្ហានេះកាត់បន្ថយសក្តានុពលនៃការហូរចូលនៃវិនិយោគផ្ទាល់ពីបរទេសបន្ថែមទៀតសម្រាប់ការអភិវឌ្ឍ និងហេដ្ឋារចនាសម្ព័ន្ធតំបន់ឆ្នេររបស់កម្ពុជា ដោយសារតែធនាគារយល់ឃើញថា វាមានហានិភ័យផ្នែកច្បាប់ និងបទប្បញ្ញត្តិ ហើយពួកគេមិនចង់ផ្តល់ហិរញ្ញប្បទានដល់អ្នកអភិវឌ្ឍឡើយ។ នៅពេលដែលវិនិយោគិនមិនអាចទទួលបានហិរញ្ញប្បទានពីប្រភពធនាគារទាំងនេះបានទេនោះ វានឹងកាន់តែពិបាកថែមទៀតក្នុងការស្វែងរកដៃគូវិស័យឯកជនដែលសមស្រប ដើម្បីឱ្យចូលរួមនៅក្នុងការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធ។

ការបង្កើតច្បាប់ដើម្បីសម្របសម្រួល ដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតំបន់ឆ្នេរ ព្រមទាំងការបង្កើតនូវភាពជាដៃគូរវាងរដ្ឋាភិបាល និងឯកជននៅក្នុងគម្រោងបែបនេះ នឹងផ្តល់ផលប្រយោជន៍ដ៏ច្រើនដល់សេដ្ឋកិច្ចជាតិ ពោលគឺមិនមែនមានត្រឹមតែតំបន់ទាំងនេះនឹងទទួលបានកម្រិតវិនិយោគកាន់តែខ្ពស់ប៉ុណ្ណោះនោះទេ ប៉ុន្តែការធានានូវការសម្របសម្រួលគម្រោងអភិវឌ្ឍន៍បានល្អ ក៏នឹងបង្កើនផលប្រយោជន៍ជាអតិបរមាដល់តំបន់ទាំងនេះផងដែរ។

លើសពីនេះទៅទៀត វិធីសាស្ត្រដែលមានការសម្របសម្រួលកាន់តែប្រសើរថែមទៀតសម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរ នឹងជួយលើកកម្ពស់ដល់វិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចរបស់កម្ពុជា ក្នុងន័យជាគុណភាព ពិពិធកម្ម និងសមត្ថភាព។ ប្រការនេះនឹងជួយបង្កើតតំបន់ទេសចរណ៍ថ្មីៗថែមទៀត (សព្វថ្ងៃ កោះនៅតាមឆ្នេរមានមិនច្រើនប៉ុន្មាននោះទេ ដែលទទួលបានការអភិវឌ្ឍខ្លាំងក្លានោះ) ជំរុញកំណើនតួលេខទេសចរណ៍ជាតិ និងលើកទឹកចិត្តដល់ការស្នាក់នៅរយៈពេលយូរក្នុងប្រទេសកម្ពុជា លើសពីការគ្រាន់តែស្នាក់នៅខេត្តសៀមរាប។ ការមានលទ្ធភាពផ្តល់ជម្រើសបដិសណ្ឋារកិច្ចដែលមានគុណភាពខ្ពស់ ក៏ជាឱកាសទាក់ទាញភ្ញៀវទេសចរច្រើនថែមទៀត និងបង្កើននូវការចំណាយជាមធ្យមនៅក្នុងទេសចរម្នាក់ៗផងដែរ។

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យផ្ដល់អាទិភាពដល់ការអនុម័តក្របខ័ណ្ឌច្បាប់ថ្មី សម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងតំបន់ឆ្នេរ និងសូមស្នើឱ្យធ្វើការពិចារណាអនុញ្ញាតឱ្យមាន "គម្រោងគំរូ" ដើម្បីបង្ហាញដល់វិនិយោគិនថា ការអភិវឌ្ឍតំបន់ឆ្នេរទៅតាមស្តង់ដារអន្តរជាតិ គឺជាលទ្ធភាពមួយដែលអាចធ្វើបាននៅក្នុងប្រទេសកម្ពុជា។

*យើងខ្ញុំសូមគោរពផ្ដល់ជូននូវអនុសាសន៍ដល់រាជរដ្ឋាភិបាល គួរផ្ដល់អាទិភាពដល់ការអនុម័តក្របខ័ណ្ឌច្បាប់ថ្មីសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងតំបន់ឆ្នេរ ដើម្បីផ្ដល់ភាពច្បាស់លាស់ផ្នែកច្បាប់ដែលមានភាពចាំបាច់សម្រាប់វិនិយោគិន។ ជាងនេះទៅទៀត យើងខ្ញុំសូមសង្កត់ធ្ងន់ជាថ្មីម្តងទៀតអំពីផលប្រយោជន៍នៃការអនុវត្ត "គម្រោងគំរូ" នៅក្នុងតំបន់ដែលអភិវឌ្ឍស្របតាមការអនុវត្តល្អបំផុតអន្តរជាតិ។ កម្មវិធីសាកល្បងនេះនឹងបង្ហាញឱ្យឃើញថា កម្ពុជាអាចស្មើ និងត្រូតពិនិត្យការអនុវត្តគម្រោងដែលស្របតាមស្តង់ដារអន្តរជាតិ ហើយនឹងបង្កើតឱកាសដើម្បីបង្ហាញដល់វិនិយោគិនអនាគតថាការអភិវឌ្ឍតំបន់ឆ្នេរស្របតាមស្តង់ដារអន្តរជាតិ គឺជាលទ្ធភាពដែលអាចធ្វើបានយ៉ាងពិតប្រាកដនៅក្នុងប្រទេសកម្ពុជា។ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាមានបំណងផ្ដល់ការគាំទ្រ ដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាបន្តទៀត ហើយក៏នឹងមានក្ដីសោមនស្សក្នុងការជួយដល់ការរៀបចំនូវដំណើរការដេញថ្លៃ សម្រាប់ "គម្រោងគំរូ" ដោយកំណត់នូវលទ្ធផលរំពឹងចង់បាននានាដែលដៃគូវិស័យឯកជនត្រូវតែបំពេញឱ្យបានដើម្បីអាចមានសិទ្ធិទទួលបានការលើកទឹកចិត្ត ដូចជា សម្បទានពន្ធ ជាដើម។*

៥៨

# ការធ្វើសុខដុមនីយកម្មបទប្បញ្ញត្តិសម្រាប់អគារលំនៅដ្ឋាន

ថ្មី

**ពិពណ៌នាបញ្ហា**

*ការប្រកាសដាក់ឱ្យប្រើអនុក្រឹត្យលេខ ១២៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់អគារសហកម្មសិទ្ធិឆ្នាំ២០០៩ បានបង្កើតជាក្របខ័ណ្ឌគតិយុត្តិសម្រាប់ការកាន់កាប់ សិទ្ធិ និងកាតព្វកិច្ចនៃចំណែកឯកជននៅក្នុងអគារសហកម្មសិទ្ធិ។ ច្បាប់នេះគឺជាពេលវេលាកំណត់អំពីទីផ្សារអចលនទ្រព្យកម្ពុជា ខណៈដែលប្រទេសនេះបានដាក់ឱ្យអនុវត្តនូវប្រភេទកម្មសិទ្ធិលំនៅដ្ឋានថ្មី និងបានជួយសម្រួលដល់លំហូរចូលនូវវិនិយោគទុនបរទេស បន្ទាប់ពីការអនុម័តច្បាប់ស្តីពីការផ្តល់សិទ្ធិលើកម្មសិទ្ធិចំណែកឯកជន នៃអគារសហកម្មសិទ្ធិដល់ជនបរទេសកាលពីឆ្នាំ២០១០។*

*ទោះបីជាច្បាប់ទាំងនេះត្រូវបានស្វាគមន៍ និងមានផលវិជ្ជមានដ៏ច្រើនទៅលើវិស័យអចលនទ្រព្យ សមាជិករបស់យើងយល់ឃើញថានៅមានភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងការបកស្រាយអនុក្រឹត្យលេខ ១២៦ សម្រាប់អលចនទ្រព្យលំនៅដ្ឋាន ដូចជាអាផាតមិន* (Apartments) *ដែលបានសាងសង់នៅមុនឆ្នាំ២០១០។*

*អគារអាផាតមិន គឺជាចលករដ៏សំខាន់នៃទីផ្សារអចលនទ្រព្យលំនៅដ្ឋាននៅក្នុងរាជធានីភ្នំពេញ នៅមុនឆ្នាំ២០១០ និងបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការផ្តល់ដំណោះស្រាយលំនៅដ្ឋានដែលមានតម្លៃសមរម្យ ដល់អ្នករស់នៅទីក្រុងដើម្បីគ្រប់គ្រងកំណើនប្រជាជន។ ដូច្នេះហើយទើបរាជធានីភ្នំពេញ មានអចលនទ្រព្យដ៏ច្រើនសន្ធឹក ដែលមានចរិតលក្ខណៈត្រូវនឹងនិយមន័យនៃពាក្យថាអគារសហកម្មសិទ្ធិដូចដែលបានកំណត់ដោយអនុក្រឹត្យលេខ ១២៦ ៖ "អគារ ឬសំណង់ ដែលមានសហកម្មសិទ្ធិករច្រើននាក់រស់នៅ។ អគារសហកម្មសិទ្ធិមានផ្នែកខ្លះ ដែលជាកម្មសិទ្ធិផ្តាច់មុខរបស់សហកម្មសិទ្ធិករម្នាក់ៗ ដែលហៅថា "ចំណែកឯកជន" និងផ្នែកផ្សេងទៀតដែលប្រើប្រាស់រួមគ្នាដោយសហកម្មសិទ្ធិករ ហៅថា "កន្លែងប្រើប្រាស់រួម"។ ប៉ុន្តែ អគារប្រភេទនេះជាច្រើន ត្រូវបានសាងសង់ឡើងនៅមុនពេលនៃការដាក់ឱ្យប្រើប្រព័ន្ធបណ្ណកម្មសិទ្ធិដីធ្លីបច្ចុប្បន្ន ដោយនាំឱ្យអចលនទ្រព្យទាំងនេះ ស្ថិតក្នុងនៅភាពមិនច្បាស់លាស់ផ្នែកច្បាប់ ពីព្រោះកម្មសិទ្ធិនៃអគារទាំងនេះកាន់កាប់ដោយប្លង់ទន់ ដែលទទួលស្គាល់ត្រឹមតែកម្រិតរដ្ឋអំណាចថ្នាក់មូលដ្ឋានប៉ុណ្ណោះ។*

*ទោះបីជាអនុក្រឹត្យលេខ ១២៦ មានភាពបត់បែន និងពិតជាមានចែងនូវបទប្បញ្ញត្តិអន្តរកាលដែលស្ថិតក្រោមជំពូកទី ៥ ដើម្បីបំលែងអគារមួយដែលត្រូវបានសាងសង់ឡើងនៅមុនពេលនៃការប្រកាសឱ្យប្រើអនុក្រឹត្យនេះទៅជាអគារសហកម្មសិទ្ធិក្តី គិតមកទល់បច្ចុប្បន្ននេះ សមាជិករបស់យើងពុំបានដឹងអំពីអគារណាមួយដែលត្រូវបានបំលែងដូច្នេះនៅឡើយទេ។*

## ផលប៉ះពាល់លើកម្ពុជា

កត្តារួមផ្សំគ្នានៃកង្វះការថែទាំ និងការអភិរក្សគ្រប់គ្រាន់ និងភាពមិនច្បាស់លាស់ផ្នែកនិយ័តកម្មជុំវិញនឹងកម្មសិទ្ធិឯកជនទៅលើអាផាតមិន បានបណ្តាលឱ្យអគារលំនៅដ្ឋានជាច្រើននៅក្នុងរាជធានីភ្នំពេញ ធ្លាក់ទៅក្នុងស្ថានភាពទ្រុឌទ្រោម ហើយបច្ចុប្បន្នអគារទាំងនេះត្រូវការការជួសជុលកែលម្អឡើងវិញ ដើម្បីអាចឱ្យប្រជាជនរស់នៅបន្តទៀតបាន។ ប៉ុន្តែ ដោយសារតែអចលនទ្រព្យទាំងនេះមិនត្រូវបានទទួលស្គាល់ជាចំណែកឯកជននៅក្នុងអគារសហកម្មសិទ្ធិ អលចនទ្រព្យទាំងនេះមិនមានបទបញ្ញាផ្ទៃក្នុងដែលអគារខុនដូត្រូវការជាចាំបាច់ដើម្បីគ្រប់គ្រងសិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់អចលនទ្រព្យ។ ប្រសិនបើមិនមានកិច្ចព្រមព្រៀងបែបនេះទេ ការគ្រប់គ្រង និងការថែទាំរួមគ្នានូវកន្លែងប្រើប្រាស់រួម ដូចជា ផ្លូវដើរ រចនាសម្ព័ន្ធ និងរបស់របរប្រើប្រាស់ផ្សេងៗ មិនត្រូវបានគេយកចិត្តទុកនោះទេ ហើយក៏គ្មានលក្ខខណ្ឌតម្រូវឱ្យម្ចាស់អលចនទ្រព្យរ៉ាប់រងថ្លៃចំណាយទៅលើការថែទាំទាំងនោះឡើយ។

ខណៈដែលកម្មសិទ្ធិឯកជននៃ អាផាតមិន ទាំងនេះនៅតែមិនមានភាពច្បាស់លាស់ និងមិនត្រូវបានទទួលស្គាល់នៅកម្រិតថ្នាក់ជាតិ វិនិយោគិនជាច្រើនយល់ឃើញថា អលចនទ្រព្យទាំងនេះអាចមានហានិភ័យខ្ពស់ ពីព្រោះពួកគេអាចនឹងមិនបានចំណេញមកវិញពីការវិនិយោគរបស់ខ្លួន ឬដោយសារតែអចលនទ្រព្យដែលនៅជាប់និងកន្លែងប្រើប្រាស់រួម ទំនងជានឹងមិនមានអ្នកថែទាំ។ ជាលទ្ធផល ដោយសារតែមានអាផាតមិនចាស់ៗជាច្រើននៅពាសពេញរាជធានីភ្នំពេញដែលទាមទារនូវការថែទាំជិតដល់ និងកម្រិតនៃការវិនិយោគច្រើន។ អ្វីដែលអាចនឹងកើតឡើងនោះគឺថាអគារស្ថាបត្យកម្មនិមិត្តរូបទាំងនេះ នឹងកាន់តែចាស់ទ្រុឌទ្រោមរហូតដល់ក្លាយជាគ្រោះថ្នាក់ដ៏ធំដល់អ្នករស់នៅទីក្រុងទៀតផង។

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យមានការបញ្ជាក់ច្បាស់លាស់ អំពីដំណើរការបំលែងអគារស្នាក់នៅដែលបានសាងសង់ឡើងនៅមុនពេលចេញអនុក្រឹត្យលេខ ១២៦ ទៅជាចំណែកឯកជននៅក្នុងអគារ សហកម្មសិទ្ធិ និងបញ្ជាក់អំពីវិធីសាស្ត្រដែលម្ចាស់អចលនទ្រព្យអាចស្នើសុំប័ណ្ណកម្មសិទ្ធិរួមថ្មី រៀងៗខ្លួន។

ទោះបីជាយើងខ្ញុំទទួលស្គាល់ថា អនុក្រឹត្យលេខ ១២៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់អគារសហកម្មសិទ្ធិ ពិតជាមានចែងអំពីបទប្បញ្ញត្តិអន្តរកាលនៅក្រោមជំពូកទី៥ ក្តី យើងខ្ញុំពុំបានដឹងអំពីអគារស្នាក់នៅ ដែលមានស្រាប់ណាមួយ ដែលត្រូវបានទទួលស្គាល់ និងចុះបញ្ជីដោយភាពជោគជ័យ ក្នុងនាមជាអគារសហកម្មសិទ្ធិ ដែលមានចំណែកឯកជនកាន់កាប់ដោយប័ណ្ណសហកម្មសិទ្ធិនៅឡើយទេ។ ដូច្នេះ យើងខ្ញុំសូមគោរពផ្តល់ជូនជាអនុសាសន៍ថារាជរដ្ឋាភិបាលគួរតែបញ្ជាក់ឱ្យបានច្បាស់លាស់អំពីដំណើរការដែលម្ចាស់អចលនទ្រព្យ អាចអនុវត្តដើម្បីបំលែងអចលនទ្រព្យរបស់ខ្លួនទៅជាចំណែក

ឯកជននៅក្នុងអគារសហកម្មសិទ្ធិ និងគូសបញ្ជាក់នូវវិធីដែលម្ចាស់អចលនទ្រព្យអាចស្នើសុំប័ណ្ណកម្មសិទ្ធិរួមថ្មី ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់កម្មសិទ្ធិ (strata title)។

ជាងនេះទៅទៀត អនុសាសន៍នេះនឹងជួយដល់ការធ្វើសុខដុមនីយកម្ម ដំណើរការសម្រាប់អគារស្នាក់នៅ ដែលមានស្រាប់ ជាមួយនឹងអនុក្រឹត្យលេខ ១២៦ ដែលមានចែងថា៖ "នីតិវិធីសម្រាប់ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវតែសាមញ្ញ ងាយស្រួលយល់ មានតម្លាភាព និងគោរពគោលការណ៍វិមជ្ឈការ វិសហមជ្ឈការ និងអភិបាលកិច្ចល្អ"។

៥៩

# បទប្បញ្ញត្តិដែលអនុញ្ញាតឱ្យមានកម្មសិទ្ធិឯកជន សម្រាប់ទីធ្លាចំណតយានយន្ត

ថ្មី

**ពិពណ៌នាបញ្ហា**

*អនុក្រឹត្យលេខ ១២៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់អគារសហកម្មសិទ្ធិ ដែលអនុម័តកាលពីខែសីហា ឆ្នាំ២០០៩ និងច្បាប់ស្តីពីការផ្តល់កម្មសិទ្ធិដល់ជនបរទេសលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដែលដាក់ឱ្យអនុវត្តកាលពីខែឧសភា ឆ្នាំ២០១០ ទទួលបានការសាទរថាជាវឌ្ឍនភាពដ៏សំខាន់សម្រាប់វិស័យអចលនទ្រព្យកម្ពុជា ពីព្រោះអនុក្រឹត្យនេះបានបង្កើតនូវក្របខ័ណ្ឌគតិយុត្តិសម្រាប់អគារសហកម្មសិទ្ធិ និងបានបើកចំហទីផ្សារអចលនទ្រព្យដល់វិនិយោគិនបរទេស។*

*បទប្បញ្ញត្តិទាំងនេះ គឺជាចលករជំរុញកំណើនដ៏លឿន សម្រាប់ការអភិវឌ្ឍខុនដូនៅទូទាំងរាជធានីភ្នំពេញ ដោយការបង្កើតពិពិធកម្មទីផ្សារសម្រាប់អ្នកទិញអចលនទ្រព្យជាតិ និងអន្តរជាតិ។*

*អនុក្រឹត្យលេខ ១២៦ នេះកំណត់អំពីជាតុផ្សំនៃអគារសហកម្មសិទ្ធិដែលស្ថិតក្រោមកម្មសិទ្ធិឯកជនផ្តាច់មុខរបស់សហកម្មសិទ្ធិករម្នាក់ៗ ព្រមទាំងជាតុផ្សំដែលស្ថិតក្រោមការប្រើប្រាស់រួមផងដែរ។ កន្លែងប្រើប្រាស់រួមទាំងនេះគឺសម្រាប់ជាផលប្រយោជន៍ដល់សហកម្មសិទ្ធិករទាំងអស់ និងស្ថិតក្រោមការគ្រប់គ្រង និងកម្មសិទ្ធិរួម។ ផ្នែកទី ២ ប្រការ ៣ នៃអនុក្រឹត្យនេះ កំណត់និយមន័យនៃកន្លែងដែលស្ថិតក្រោមកម្មសិទ្ធិរួម ដែលរួមបញ្ចូលទាំង ដី ទីធ្លា ផ្លូវចេញ-ចូល ជញ្ជាំងអឌ្ឍសិទ្ធិ និងជាតុផ្សំនៃកន្លែងប្រើប្រាស់រួមដទៃទៀត។ ជាការកត់សម្គាល់ ទីធ្លាចំណតយានយន្តក៏ត្រូវបានរាប់បញ្ចូលជាកន្លែងប្រើប្រាស់រួមដែរ ដែលមានន័យថា អ្នកអភិវឌ្ឍមិនអាច បែងចែកទីធ្លាចំណែតឯកជនទៅឱ្យម្ចាស់អចលនទ្រព្យបានទេ។*

*នេះជាចំណុចដែលមិនប្រក្រតី ពីព្រោះថា ជាទូទៅ នៅក្នុងការអភិវឌ្ឍខុនដូនៅទូទាំងពិភពលោក នៅពេលដែលអតិថិជនទិញចំណែកឯកជនណាមួយ ទីធ្លាចំណតយានយន្តដែលបែងចែកសម្រាប់ចំណែកមួយនោះ ត្រូវបានដាក់បញ្ចូលនៅក្នុងកិច្ចសន្យាលក់សម្រាប់ការប្រើប្រាស់ផ្តាច់មុខរបស់អតិថិជននោះ។ ការធ្វើដូច្នេះគឺដើម្បីធានាថាអ្នកកាន់កាប់អាចចតយានយន្តរបស់ខ្លួន នៅក្នុងទីធ្លានៃខុនដូរបស់ខ្លួនបាន បើមិនដូច្នេះទេ កន្លែងចតនឹងត្រូវពេញ ដែលនាំឱ្យសហកម្មសិទ្ធិករខាតបង់ប្រយោជន៍នៅក្នុងអចលនទ្រព្យផ្ទាល់ខ្លួនរបស់ខ្លួនឯង។ ខណៈដែលសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាដឹងថាអ្នកអភិវឌ្ឍជាច្រើនកំពុងផ្តល់ទីធ្លាចំណតយានយន្តឯកជនសម្រាប់ការជួល ឬការលក់ដោយសារតែកំណើនតម្រូវការនៃការទិញអចលនទ្រព្យនៅពេលបច្ចុប្បន្ន អនុក្រឹត្យលេខ ១២៦ ពុំមានចែងអំពីយន្តការដែលអនុញ្ញាតឱ្យការអនុវត្តបែបនេះត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់នោះទេ ដែលនាំឱ្យម្ចាស់អចលនទ្រព្យអាចនឹងទទួលនូវផលវិបាកដែលអាចកើតឡើង។*

## ផលប៉ះពាល់លើកម្ពុជា

*ប្រព័ន្ធប្រើប្រាស់រួមគ្នាសម្រាប់ការចតយានយន្តនាពេលបច្ចុប្បន្ននៅក្នុងអគារខុនដូ បង្កើតជាចន្លោះប្រហោងដែលអាចនាំឱ្យមានការប្រើប្រាស់ខុសពីសំណាក់សហកម្មសិទ្ធិករ ដែលអាចនឹងឆ្លៀតកេងយកប្រយោជន៍ពីចេតនាល្អនៃការប្រើប្រាស់រួម និងអាចនាំឱ្យកើតមាននូវការមិនពេញចិត្តរបស់សហកម្មសិទ្ធិករដទៃទៀត ហើយអាចបង្កើតឱ្យមានបរិយាកាសអវិភាពមួយសម្រាប់អ្នកកាន់កាប់គ្រប់រូប។ ប្រសិនបើអ្នកអភិវឌ្ឍនៅតែមិនអាចផ្តល់ទីធ្លាចំណតយានយន្តឯកជនជាផ្នែកនៃការលក់ខុនដូរបស់ខ្លួនទៀតនោះ កត្តានេះអាចនឹងប៉ះពាល់ដល់ទីផ្សារអចលនទ្រព្យដែលកំពុងរីកលូតលាស់របស់កម្ពុជា ដោយបង្អាក់ទឹកចិត្តអ្នកទិញឱ្យរារែកក្នុងការទិញ។ បញ្ហានេះគេឃើញមាននៅក្នុងរាជធានីភ្នំពេញ ដែលប្រជាជនកំពុងជួបការលំបាករួចជាស្រេចទាក់ទងនឹងការកកស្ទះចរាចរណ៍ ដែលគេរំពឹងថានឹងកាន់តែមានស្ថានភាពធ្ងន់ធ្ងរជាងនេះថែមទៀតនៅពេលដែលចំនួនប្រជាជន និងជីវភាពនៅក្នុងរាជធានីភ្នំពេញកាន់តែរីកលូតលាស់ខ្លាំងជាងនេះជាបន្តទៀត។*

*ការបង្កើតយន្តការមួយ ដើម្បីអនុញ្ញាតឱ្យមានកម្មសិទ្ធិឯកជនសម្រាប់ទីធ្លាចំណតយានយន្ត ក៏អាចបង្កើតនូវទីផ្សារថ្មីមួយដែលអាចទិញដូរបានផងដែរសម្រាប់ទីធ្លាចំណតយានយន្ត ពីព្រោះថាអ្នកកាន់កាប់ខុនដូរដែលមិនប្រើប្រាស់ទីធ្លារបស់ខ្លួនអាចលក់ ឬជួលទីធ្លាមិនប្រើនេះទៅឱ្យអ្នកដទៃបាន។ ទីធ្លាចំណតយានយន្តនេះ ក៏កំពុងក្លាយជាទីផ្សារកាន់តែរីកធំ និងកាន់តែមានតម្លៃផងដែរនៅក្នុងបណ្តាប្រទេសជាច្រើន ដែលទីធ្លាចំណតនៅកណ្តាលទីក្រុងកាន់តែខ្សត់ទៅៗ ហើយវាអាចជាមធ្យោបាយមានប្រសិទ្ធភាពមួយក្នុងការជួយកាត់បន្ថយការកកស្ទះចរាចរណ៍ថែមទៀតផង។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យអនុម័តបទប្បញ្ញត្តិ ដែលអនុញ្ញាតឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ ចាត់ចែងទីធ្លាចំណតយានយន្តនៅក្នុងបរិវេណខុនដូ ជាចំណែកឯកជន និងអនុញ្ញាតឱ្យមានការចេញប័ណ្ណសម្គាល់កម្មសិទ្ធិឯកជនសម្រាប់ចំណតយានយន្ត។

*តាមរយៈការធ្វើវិសោធនកម្ម ទៅលើអនុក្រឹត្យលេខ ១២៦ ដើម្បីអនុញ្ញាតឱ្យអ្នកអភិវឌ្ឍន៍ចាត់ចែងទីធ្លាចំណតយានយន្ត នៅក្នុងអគារសហកម្មសិទ្ធិជាចំណែកឯកជន រាជរដ្ឋាភិបាលនឹងជួយតម្រង់ទិសទីផ្សារខុនដូរបស់កម្ពុជាឱ្យស្របទៅនឹងទីផ្សារនៅបណ្តាប្រទេសជាច្រើនទៀតនៅជុំវិញពិភពលោក ហើយម្យ៉ាងទៀត ការធ្វើដូច្នេះ ក៏នឹងបង្កើនការពេញចិត្តរបស់អ្នកទិញអចលនទ្រព្យថ្មីផងដែរ។ ការអនុម័តបទប្បញ្ញត្តិថ្មីសម្រាប់ទីធ្លាចំណតយានយន្តនឹងអនុញ្ញាតឱ្យក្រុមហ៊ុនអភិវឌ្ឍន៍អាចចេញវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិឯកជន និងអាចធ្វើការបែងចែកទីធ្លាចំណតដោយស្មើៗគ្នាទៅដល់អ្នកកាន់កាប់អចលនទ្រព្យទាំងអស់ដើម្បីឱ្យពួកគាត់អាចប្រើប្រាស់តាមក្តីប្រាថ្នារបស់ខ្លួនបាន។*

*សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជានឹងមានភាពរីករាយក្នុងការជួយដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅក្នុងការរៀបចំតាក់តែង និងអនុម័តបទប្បញ្ញត្តិថ្មីៗទាំងនេះដើម្បីផ្តល់លទ្ធភាពដល់ការបង្កើតនូវប្រព័ន្ធមួយសម្រាប់ការចេញវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសម្រាប់ទីធ្លាចំណតយានយន្តឯកជន ដូចដែលបានគូសបញ្ជាក់នៅក្នុងសេចក្តីស្នើអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួង។*

៦០

# ស្តង់ដារនៃការគ្រប់គ្រងអចលនទ្រព្យ

ថ្មី

**ពិពណ៌នាបញ្ហា**

*ចាប់តាំងពីពេលដែលទីផ្សារអចលនទ្រព្យរបស់កម្ពុជា បានបើកចំហដោយអនុញ្ញាតដល់វិនិយោគទុនបរទេសបន្ទាប់ពីពេលចេញសេចក្តីប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស (ច្បាប់ស្តីពីកម្មសិទ្ធិបរទេស) ឆ្នាំ២០១០ មកការអភិវឌ្ឍខុនដូបានកើនឡើងយ៉ាងគំហុកនៅទូទាំងប្រទេសកម្ពុជា ជាពិសេស នៅក្នុងរាជធានីភ្នំពេញ។ ខុនដូផ្តល់ឱកាសវិនិយោគយ៉ាងទាក់ទាញដល់អ្នកទិញជាជនជាតិបរទេសដោយសារតែតម្លៃនៅទាប និងទីតាំងស្ថិតនៅចំកណ្តាលទីក្រុង ដែលផ្តល់លទ្ធភាពដល់ម្ចាស់ខុនដូអាចចូលរួមចំណែក និងទាញយកផលប្រយោជន៍ជាច្រើនពីកំណើនសេដ្ឋកិច្ចដ៏លឿនរហ័សរបស់កម្ពុជា។*

*ដោយសារតែទំហំទូទៅនៃការអភិវឌ្ឍសំណង់ខុនដូ និងលក្ខណៈរួមគ្នានៃអគារ និងបរិក្ខារប្រើប្រាស់ អគារខុនដូត្រូវការការថែទាំ និងការគ្រប់គ្រងកម្រិតខ្ពស់ដើម្បីធានានូវស្ថានភាពមិនធាប់ចាស់ទ្រុឌទ្រោមរបស់អគារ។ ជារៀយៗ អចលនទ្រព្យប្រភេទនេះ ត្រូវការការគ្រប់គ្រងប្រកបដោយវិជ្ជាជីវៈនូវចំណែក និងសមាសភាគដែលជាកម្មសិទ្ធិរួមដើម្បីអាចរក្សាសោភ័ណភាព សុវត្ថិភាព និងដំណើរការបាន ដោយធានាថា ការថែទាំមានភាពពេញលេញ បុគ្គលិកមានការគ្រប់គ្រង និងកម្រៃសេវានានាត្រូវបានប្រមូលបានត្រឹមត្រូវ។ កម្រៃសេវាទាំងនេះ អាចរួមមានដូចជា ប្រាក់ធនានុគ្រោះ ឬថ្លៃសេវាថែទាំ ដែលទុកសម្រាប់ចំណាយទៅលើការបោសសម្អាត សន្តិសុខ អ្នកបច្ចេកទេសជួសជុល និងនៅក្នុងទីផ្សារភាគច្រើនបំផុត ដែលម្ចាស់ខុនដូត្រូវបានតម្រូវឱ្យចូលរួមបង់វិភាគទានដល់មូលនិធិរក្សាទុកដោយឡែកសម្រាប់ការថែទាំអគាររយៈពេលវែង។*

*អនុក្រឹត្យលេខ ១២៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់អគារសហកម្មសិទ្ធិ ដែលចេញកាលពីឆ្នាំ២០០៩ បានត្រួសត្រាយផ្លូវឱ្យមានច្បាប់ស្តីពីកម្មសិទ្ធិរបស់ជនបរទេស ដោយផ្តល់ការណែនាំដំបូងស្តីពីការគ្រប់គ្រងអគារប្រើប្រាស់រួម ដែលតម្រូវឱ្យអគារបែបនេះត្រូវអនុវត្តបទបញ្ជាផ្ទៃក្នុង និងបង្កើតនូវគណៈកម្មាធិការប្រតិបត្តិ ដើម្បីមើលការខុសត្រូវលើបញ្ហាអចលនទ្រព្យ។ ទោះបីជាអនុក្រឹត្យលេខ ១២៦ កំណត់អំពីនីតិវិធីសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត និងទំនួលខុសត្រូវនៃការចំណាយសម្រាប់ការថែទាំអគារក្តី ប៉ុន្តែអនុក្រឹត្យនេះមិនបានបញ្ជាក់ច្បាស់លាស់អំពីបញ្ហាមួយចំនួនឡើយ ក្នុងនោះរាប់បញ្ចូលទាំង ធានារ៉ាប់រងអគារ លក្ខខណ្ឌតម្រូវឱ្យមានមូលនិធិរក្សាទុកដោយឡែក ឬការគ្រប់គ្រងអគារពីសំណាក់ភាគីទីបីជាដើម។*

*ចាប់តាំងពីខែមិថុនា ឆ្នាំ២០១៧ សេវាកម្មគ្រប់គ្រងអចលនវត្ថុត្រូវបានគ្រប់គ្រងដោយប្រកាសលេខ ៦៣៦ ស្តីពីការគ្រប់គ្រងអាជីវកម្មផ្តល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ។*

*បទប្បញ្ញត្តិនេះ តម្រូវឱ្យអ្នកជំនាញវិជ្ជាជីវៈគ្រប់គ្រងអចលនវត្ថុស្នើសុំអាជ្ញាប័ណ្ណ ដាក់លាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីអាចមានសិទ្ធិប្រតិបត្តិការសេវាកម្ម ដោយស្របច្បាប់។ ប៉ុន្តែបទប្បញ្ញត្តិនេះមិនមានចែងអំពីលក្ខខណ្ឌតម្រូវដាក់លាក់ ឬព័ត៌មានលម្អិតពាក់ព័ន្ធនឹងតួនាទី និងកាតព្វកិច្ចដែលអ្នកគ្រប់គ្រងអចលនទ្រព្យ ត្រូវតែផ្តល់ជូនអតិថិជនរបស់ខ្លួនឡើយ។ ដូច្នេះបទប្បញ្ញត្តិមានស្រាប់របស់កម្ពុជា សម្រាប់វិស័យគ្រប់គ្រងអចលនវត្ថុនៅមានវិសាលភាពមានកម្រិតនៅឡើយ និងមិន ទាន់បានផ្តល់ក្របខណ្ឌផ្លូវច្បាប់រឹងមាំនៅឡើយនោះទេ។*

*ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្នមានក្រុមហ៊ុនជាច្រើនកំពុងផ្តល់សេវាគ្រប់គ្រង អចលនទ្រព្យស្រាប់ទៅហើយ នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែដោយសារតែពុំទាន់មាន បទប្បញ្ញត្តិ ឬបទដ្ឋាននីតិវិធីប្រតិបត្តិការ ដើម្បីកំណត់ច្បាស់លាស់ អំពីលក្ខខណ្ឌតម្រូវ ហានិភ័យគឺមានខ្ពស់ចំពោះទាំងម្ចាស់អចលនទ្រព្យ និងទាំងអ្នកគ្រប់គ្រងអចលនទ្រព្យ ផងដែរ។ ដោយសារតែវិស័យនេះថ្មីនៅឡើយសម្រាប់ប្រទេសកម្ពុជា ម្ចាស់អចលនទ្រព្យ អាចនឹងមិនដឹងអំពីថ្លៃចំណាយ ឬសេវានានា ដែលគួរតែដាក់បញ្ចូលនៅក្នុងកិច្ចព្រម ព្រៀងសេវាកម្មគ្រប់គ្រងអចលនទ្រព្យនោះទេ។ ស្រដៀងគ្នានេះដែរ វិធានការ ច្បាប់ ក៏មានតិចតួចដែរសម្រាប់ក្រុមហ៊ុនគ្រប់គ្រងអចលនទ្រព្យអនុវត្ត ក្នុងករណីដែល ម្ចាស់អចលនទ្រព្យលែងបង់ថ្លៃថែទាំ ឬលែងបង់វិភាគទានសម្រាប់មូលនិធិរក្សាទុក ដោយឡែក ដែលនឹងប៉ះពាល់ដល់ម្ចាស់អចលនទ្រព្យដទៃទៀតទាំងអស់។ ការប្រើ ប្រាស់មូលនិធិអចលនទ្រព្យឱ្យបានសមស្រប ក៏ជាបញ្ហាធំផ្សេងទៀតដែលត្រូវធ្វើ ការគ្រប់គ្រងផងដែរ ពីព្រោះថាចំនួនប្រាក់ដែលប្រមូលបានពីអ្នករស់នៅនឹងកើន ខ្លាំងដើម្បីរ៉ាប់រងការចំណាយទៅលើការថែទាំ និងសេវាកម្មនានា។*

*ប្រសិនបើយើងធ្វើការប្រៀបធៀបទៅនឹងប្រទេសម៉ាឡេស៊ី ជាប្រទេសដែលវិនិយោគ បរទេសទៅលើទីផ្សារខុនដូក៏មានការរីកលូតលាស់ខ្លាំងដែរ និងមានប្រជាជនមួយភាគ ធំដែលកំពុងរស់នៅក្នុងអចលនទ្រព្យសហកម្មសិទ្ធិដែរនោះ រដ្ឋាភិបាលម៉ាឡេស៊ីបាន និងកំពុងអនុវត្តបទប្បញ្ញត្តិសម្រាប់វិស័យគ្រប់គ្រងអចលនទ្រព្យក្នុងរយៈពេលពីរ ទសវត្សរ៍ចុងក្រោយនេះ។ ថ្មីៗនេះ រដ្ឋាភិបាលម៉ាឡេស៊ីបានដាក់ចេញនូវបទដ្ឋាន គ្រប់គ្រងអចលនទ្រព្យ និងតម្រូវឱ្យអ្នកប្រកបវិជ្ជាជីវៈគ្រប់គ្រងអចលនទ្រព្យទាំង អស់ ធ្វើការចុះបញ្ជីជាមួយក្រុមប្រឹក្សាអ្នកវាយតម្លៃអចលនទ្រព្យ ភ្នាក់ងារអចលនទ្រព្យ និងអ្នកគ្រប់គ្រងអចលនទ្រព្យ ដោយមានកំណត់អំពីការដាក់ទណ្ឌកម្ម ក្នុងករណី ដែលមិនអនុវត្តតាម។*

*ចំណាត់ការនេះ ធ្វើឡើងដើម្បីឆ្លើយតបទៅនឹងទិន្នន័យស្ទង់មតិរបស់រដ្ឋាភិបាល ដែលបានបង្ហាញដែលថា ភាគច្រើននៃអគារអាផាតមិន និងខុនដូនៅទូទាំងប្រទេស នេះនៅមានភាពខ្វះខាតយ៉ាងខ្លាំងនូវការគ្រប់គ្រងសមស្រប ដោយសារតែម្ចាស់ អចលនទ្រព្យមិនព្រមបង់ថ្លៃថែទាំ អ្នកគ្រប់គ្រងអចលនទ្រព្យដែលមិនមានបទ ពិសោធន៍ និងការអនុវត្តបទប្បញ្ញត្តិដែលមានស្រាប់នៅមានចន្លោះប្រហោងជាច្រើន។*

## ផលប៉ះពាល់លើកម្ពុជា

ការបណ្ដោយឱ្យវិស័យគ្រប់គ្រងអចលនទ្រព្យ នៅតែគ្មានបទប្បញ្ញត្តិគ្រប់គ្រងបែប
នេះ អាចនឹងបង្កហានិភ័យអវិជ្ជមានដែលមិនចាំបាច់ទៅដល់ទីផ្សារអចលនទ្រព្យ
នៅកម្ពុជា ហើយក៏អាចមានផលពលប៉ះពាល់ទៅលើទឹកចិត្តរបស់វិនិយោគិនទាំង
បច្ចុប្បន្ន និងទាំងអនាគត។ ខណៈដែលវិនិយោគិនមួយចំនួនអាចនឹងមានក្ដីបារម្ភ
តិចតួចចំពោះលទ្ធភាពចំណេញរយៈពេលវែងរបស់អគារខុនដូ ប្រសិនបើពួកគេ
មានបំណងកាន់កាប់អចលនទ្រព្យមួយត្រឹមតែមួយរយៈពេលខ្លីសម្រាប់ទុកលក់
វិញ ដើម្បីបានប្រាក់ចំណេញ ប្រសិនបើអចលនទ្រព្យសហកម្មសិទ្ធិនេះ មិនមានការ
ថែរក្សាឱ្យបានសមស្របទេនោះ វាអាចនឹងធ្លាក់ទៅក្នុងភាពអស់សង្ឃឹម។ ដូច្នេះ ប្រសិន
បើម្ចាស់អចលនទ្រព្យធ្វេសប្រហែសក្នុងការបង់ថ្លៃថែទាំ វានឹងមានផលប៉ះពាល់
អវិជ្ជមានទៅលើតម្លៃរបស់ម្ចាស់អចលនទ្រព្យដទៃទៀត ព្រមទាំងការយល់ឃើញ
ជាទូទៅពីសំណាក់វិនិយោគិនទៅលើទីផ្សារអចលនទ្រព្យ។

កង្វះការគ្រប់គ្រងសមស្រប អាចបង្កឱ្យមានប៉ះពាល់ធ្ងន់ធ្ងរទៅលើការប្រើប្រាស់អចលន
ទ្រព្យរបស់អ្នករស់នៅ តម្លៃលក់បន្តរបស់អចលនទ្រព្យ និងប្រាក់ចំណេញពីការជួល
ពីព្រោះថាអ្នកទិញ ឬអ្នកជួល នឹងជ្រើសរើសអចលនទ្រព្យផ្សេងទៀតដែលមានការ
គ្រប់គ្រងប្រកបដោយប្រសិទ្ធភាពជាងនេះ។ ដូចដែលមានទឡ្ហីករណ៍បង្ហាញនៅក្នុង
ទីផ្សារដទៃទៀតនៅទូទាំងពិភពលោក អចលនទ្រព្យដែលមិនមានការគ្រប់គ្រងល្អ
ជានិច្ចកាល គឺបណ្ដាលឱ្យធ្លាប់ចាស់ទ្រុឌទ្រោម ឬខូចខាត ទៅលើទាំងកន្លែងប្រើប្រាស់រួម
និងទាំងយូនីតខុនដូដាច់ដោយឡែកនីមួយៗ ហើយនៅទីបំផុតទៅ វានឹងបង្កើនការ
ចំណាយចំពោះម្ចាស់ទាំងអស់ និងបង្កជាការព្រួយបារម្ភអំពីសុវត្ថិភាព ផងដែរ ។

សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ដឹងអំពីក្រុមហ៊ុនមួយចំនួន ដែលមានបទពិសោធន៍
នៅក្នុងវិស័យគ្រប់គ្រងអចលនទ្រព្យនៅក្នុងទីផ្សារផ្សេងទៀត ប៉ុន្តែបានផ្អាកការចូលរួម
នៅក្នុងវិស័យនេះវិញ ដោយសារតែកម្ពុជានៅខ្វះបទប្បញ្ញត្តិ និងការការពារគ្រប់គ្រាន់។
ដើម្បីបន្តទាក់ទាញវិនិយោគិនច្រើនថែមទៀត ដែលចាប់អារម្មណ៍លើការវិនិយោគ
រយៈពេលវែងនៅក្នុងទីផ្សារអចលនទ្រព្យនៅក្នុងវិស័យនេះ កម្ពុជាចាំបាច់ត្រូវតែមាន
ស្ថិរភាពផ្នែកច្បាប់ និងបទប្បញ្ញត្តិ និងភាពអាចព្យាករណ៍បានកម្រិតខ្ពស់។ ការធ្វើ
បទប្បញ្ញត្តិសម្រាប់វិស័យគ្រប់គ្រងអចលនទ្រព្យនៅកម្ពុជាផ្ដល់ឱកាសដល់រាជរដ្ឋា-
ភិបាលក្នុងការជំរុញលើកទឹកចិត្តដល់វិស័យនេះឱ្យផ្ដល់នូវសេវាដែលមានគុណភាព
កាន់តែខ្ពស់ជាងមុន កិច្ចការពារកាន់តែរឹងមាំជាងមុន និងបង្កើនការបង្កើតការងារ
និងចំណូលពន្ធ ។

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើឱ្យធ្វើការពិចារណាអនុម័តក្របខ័ណ្ឌនិយ័តកម្ម ដើម្បីគ្រប់គ្រងលើវិស័យគ្រប់គ្រងអចលនទ្រព្យនៅកម្ពុជា និងស្នើឱ្យពិគ្រោះយោបល់ជាមួយនឹងវិស័យឯកជនដើម្បីបង្កើតជាសំណុំឯកសារបទដ្ឋាននីតិវិធីប្រតិបត្តិ។

*ដោយទទួលស្គាល់ថា ទីផ្សារអចលនទ្រព្យសហកម្មសិទ្ធិនៅកម្ពុជាជាទីផ្សារមួយថ្មីនៅឡើយ និងបែបប្រពៃណី ការគ្រប់គ្រងអចលនទ្រព្យ គឺជាកិច្ចការគ្រួសារ យើងខ្ញុំជឿជាក់ថា ការតាក់តែងក្របខ័ណ្ឌច្បាប់មួយដែលគាំទ្រដល់វិស័យគ្រប់គ្រងអចលនទ្រព្យ នឹងផ្តល់ផលប្រយោជន៍ច្រើនដល់ម្ចាស់លំនៅដ្ឋានក្នុងស្រុកគ្រប់រូប។ ការតាក់តែងបទដ្ឋាននីតិវិធីប្រតិបត្តិជាក់លាក់ សម្រាប់អ្នកប្រកបវិជ្ជាជីវៈផ្នែកគ្រប់គ្រង អចលនទ្រព្យ គឺជាជំហានចាំបាច់មួយនៅក្នុងការបង្កើតបទដ្ឋានសេវាកម្មដែលអាចទទួលយកបាន និងបង្កើតជាមូលដ្ឋានសម្រាប់ឧត្តមានុវត្តន៍នៅក្នុងវិស័យនេះ។ បទដ្ឋានបែបនេះ ក៏អាចប្រើប្រាស់ផងដែរដើម្បីវាស់កម្រិតនៃការផ្តល់សេវាសម្រាប់ទីផ្សារដោយវាស់វែងថាតើសេវាមួយត្រូវបានផ្តល់សមស្របដែរ ឬទេ ហើយនៅទីបំផុតវានឹងជួយលើកកម្ពស់គុណភាពរបស់វិស័យនេះទាំងមូល។*

*យើងខ្ញុំសូមសំណូមពរ ឱ្យមានការតាក់តែងបទដ្ឋាននីតិវិធីប្រតិបត្តិដោយផ្អែកលើឧត្តមានុវត្តន៍អន្តរជាតិ ប៉ុន្តែទន្ទឹមគ្នានេះដែរ យើងក៏សូមលើកទឹកចិត្តដោយសេចក្តីគោរពឱ្យមានការចូលរួមពិគ្រោះយោបល់ជាមួយនឹងវិស័យឯកជនដើម្បីកំណត់ថាអ្វីដែលនឹងសមស្របបំផុតសម្រាប់ការអនុវត្តស្របទៅតាមបរិបទរបស់កម្ពុជា។ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា សូមស្វាគមន៍នូវឱកាសផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាលនៅក្នុងការតាក់តែងក្របខ័ណ្ឌច្បាប់ ដើម្បីគ្រប់គ្រងទៅលើវិស័យគ្រប់គ្រងអចលនទ្រព្យនៅកម្ពុជាដូចដែលបានស្នើនៅក្នុងអនុស្សរណៈនៃការយោគយល់គ្នារបស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាជាមួយនឹងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។*

៦១

# ដំណើរការនៃការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ

ថ្មី

**ពិពណ៌នាបញ្ហា**

*ដោយសារតែអតីតកាលដ៏ច្របូកច្របល់របស់កម្ពុជា ច្បាប់ និងបទប្បញ្ញត្តិដែលគ្រប់គ្រងទៅលើកម្មសិទ្ធិឯកជន លើអចលនទ្រព្យមានភាពស្មុគស្មាញ និងពិបាកក្នុងការបកស្រាយ ចាប់តាំងពីពេលដែលកម្មសិទ្ធិឯកជនត្រូវបានទទួលស្គាល់ជាបឋមតាមរយៈច្បាប់ភូមិបាលនៅក្នុងឆ្នាំ១៩៩២ មកម្ល៉េះ។ នៅក្រោយការធ្វើបច្ចុប្បន្នភាពច្បាប់ភូមិបាលនាឆ្នាំ២០០១ ម្ចាស់អចលនទ្រព្យអាចចុះបញ្ជីអចលនទ្រព្យរបស់ខ្លួនដើម្បីឱ្យរាជរដ្ឋាភិបាលទទួលស្គាល់នៅកម្រិតថ្នាក់ជាតិ ដោយទទួលបានវិញ្ញាបនប័ត្រសម្គាល់កម្មសិទ្ធិ ដែលជាទូទៅហៅថា ប្លង់រឹង។ ប្លង់រឹងនេះចេញដោយការិយាល័យសុរិយោដីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ហើយជាទម្រង់នៃកម្មសិទ្ធិអចលនទ្រព្យដែលមានសន្តិសុខបំផុត ពីព្រោះនេះជាឯកសារតែមួយគត់ ដែលត្រូវការដើម្បីបញ្ជាក់ពីភាពជាម្ចាស់កម្មសិទ្ធិ។ ប្លង់រឹង គឺខុសពីប្លង់ទន់ ដែលភាពជាម្ចាស់កម្មសិទ្ធិត្រូវបានទទួលស្គាល់ត្រឹមតែថ្នាក់រដ្ឋបាលមូលដ្ឋានប៉ុណ្ណោះ និងអាចមានការជំទាស់តវ៉ាពីភាគីទីបី ប៉ុន្តែដោយសារតែអចលនទ្រព្យជាច្រើននៅមិនទាន់បានផ្ទេរទៅជាប្លង់រឹងនៅឡើយ ទើបប្លង់ទន់នៅតែជាទម្រង់ទូទៅមួយនៃកម្មសិទ្ធិនៅក្នុងប្រទេសកម្ពុជា។*

*ដោយសារតែកម្មសិទ្ធិប្លង់ទន់មិនត្រូវបានទទួលស្គាល់ពេញលេញដោយច្បាប់ ទើបមានភាពងាយស្រួលជាង ក្នុងការធ្វើដំណើរការផ្ទេរកម្មសិទ្ធិអចលនទ្រព្យទៅឱ្យម្ចាស់ថ្មី ពីព្រោះមានដំណើរការផ្នែករដ្ឋបាលពាក់ព័ន្ធតិចជាង ការចំណាយអស់តិចជាង ហើយហានិភ័យ និងកាតព្វកិច្ចដែលទាក់ទងនឹងអចលនទ្រព្យ ត្រូវផ្ទេរទាំងស្រុងទៅឱ្យម្ចាស់ថ្មី។ ប្រសិនបើយើងធៀបជាមួយនឹងប្លង់រឹង ដើម្បីផ្ទេរកម្មសិទ្ធិអចលនទ្រព្យមួយដែលមានប្លង់រឹង គូភាគីពាក់ព័ន្ធនៅក្នុងការទិញចាំបាច់ត្រូវចុះកិច្ចសន្យាមួយដែលលម្អិតអំពីលក្ខខណ្ឌនៃការលក់ បង្ហាញភស្តុតាងពីអត្តសញ្ញាណរបស់ខ្លួន បង់ពន្ធ និងត្រូវឆ្លងកាត់ដំណើរការនីតិវិធីតាមរយៈការិយាល័យសុរិយោដីដើម្បីសម្របសម្រួលការផ្ទេរ។*

*ទោះបីជានីតិវិធីកាត់ឈ្មោះនេះ មានលក្ខណៈប្រហាក់ប្រហែលគ្នាជាទូទៅនៅក្នុងប្រទេសភាគច្រើនបំផុតក៏ដោយ ប៉ុន្តែនៅកម្ពុជាមានការណែនាំតិចតួចប៉ុណ្ណោះដែលផ្សព្វផ្សាយដោយរាជរដ្ឋាភិបាល ដើម្បីជួយគាំទ្រដល់ម្ចាស់កម្មសិទ្ធិ និងអ្នកទិញឱ្យយល់ដឹងអំពីអ្វីខ្លះដែលពាក់ព័ន្ធនៅក្នុងដំណើរការផ្ទេរ ឬកាត់ឈ្មោះ រយៈពេលរំពឹងទុកសម្រាប់ការរត់ការផ្ទេរ ឬថ្លៃសេវាដែលត្រូវបង់នានា។ ដូច្នេះហើយ ភាពមិនច្បាស់លាស់នេះបង្កឱ្យមនុស្សជាច្រើនប្រើប្រាស់ភ្នាក់ងារឱ្យធ្វើជាអន្តរការីដើម្បីជួយសម្រួលដល់ដំណើរការផ្ទេរកម្មសិទ្ធិជាមួយការិយាល័យសុរិយោដី។ ភ្នាក់ងារទាំងនេះ ពុំមានអាជ្ញាប័ណ្ណនោះទេ ហើយការប្រើប្រាស់សេវារបស់ពួកគេនាំឱ្យកើនការចំណាយដែលគ្មានភាពចាំបាច់ទៅលើការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ និងរយៈពេលរត់ការ ហើយទន្ទឹមនឹងនេះក៏បង្កើតហានិភ័យច្រើនផងដែរ ដោយហេតុថាភ្នាក់ងារអាចបោកប្រាស់យកលុយហើយ មិនបានជួយសម្រួលដល់ការរត់ការផ្ទេរ*

*នេះទៀតផង ហើយករណីបែបនេះ បើកើតឡើង ហើយគ្មានការកត់ត្រា ឬបង្កាន់ដៃបង់ប្រាក់ជាភស្តុតាងនៃសេវាកម្មបែបនេះ គឺពិបាកក្នុងការចាត់វិធានការច្បាប់។ ជាលទ្ធផល ប្រសិនបើភ្នាក់ងារណាម្នាក់បានបំពេញការផ្តល់សេវារបស់ខ្លួន ការផ្ទេរកម្មសិទ្ធិអចលនទ្រព្យអាចចំណាយពេលចន្លោះចាប់ពី ២ ទៅ ៣ខែ ដើម្បីពិនិត្យ និងសម្រេចដោយការិយាល័យសុរិយោដី ដែលនាំឱ្យពេលវេលាដែលត្រូវការដើម្បីទិញអចលនទ្រព្យដែលមានការទទួលស្គាល់ផ្លូវច្បាប់ពេញលេញនៅក្នុងប្រទេសកម្ពុជាកាន់តែវែងឆ្ងាយថែមទៀត។*

**ផលប៉ះពាល់លើកម្ពុជា**

*សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាទទួលស្គាល់ថា ភាគីខ្លះអាចនឹងចង់ជួលសេវាភ្នាក់ងារ ដើម្បីកុំឱ្យស្មុគស្មាញដល់ពួកគេក្នុងការចូលរួម និងថាដំណើរការរដ្ឋបាលនៅថ្នាក់ជាតិអាចចំណាយពេលវេលាច្រើន ជាពិសេស ដោយសារតែការផ្ទេរកម្មសិទ្ធិពាក់ព័ន្ធមិនត្រឹមតែការិយាល័យសុរិយោដីតែមួយនោះទេ ប៉ុន្តែក៏ពាក់ព័ន្ធផងដែរជាមួយក្រសួងមហាផ្ទៃ និងអគ្គនាយកដ្ឋានពន្ធដារ នៅដំណាក់កាលខុសៗគ្នានៃដំណើរការ។ ទោះបីជាកម្មសិទ្ធិលើអចលនទ្រព្យ គឺជាសិទ្ធិមួយ ដែលផ្តល់ដល់ប្រជាជនកម្ពុជាគ្រប់រូបក្តី ប្រសិនបើមិនមែនការណែនាំផ្លូវការពីរាជរដ្ឋាភិបាល ដែលលម្អិតព័ត៌មានអំពីរបៀបរបបនៃការផ្ទេរកម្មសិទ្ធិអចលនទ្រព្យទេនោះ ម្ចាស់អចលនទ្រព្យនិងអ្នកទិញនៅតែពុំបានដឹងព័ត៌មានគ្រប់ជ្រុងជ្រោយ ហើយនឹងនៅតែបង្ខំចិត្តប្រើសេវាភ្នាក់ងារដែលគ្មានអាជ្ញាប័ណ្ណដើម្បីឱ្យជួយសម្រួលដល់ការរត់ការការផ្ទេរកម្មសិទ្ធិរបស់ខ្លួនដដែល។ ក្នុងករណីដែលភ្នាក់ងារម្នាក់យកលុយហើយ ប៉ុន្តែមិនបានបំពេញសេវាកម្មរបស់ខ្លួនទេ បញ្ហានេះនឹងបង្កនូវភាពតានតឹងចិត្ត និងការមិនពេញចិត្តដល់អ្នកទាំងឡាយដែលពាក់ព័ន្ធ ថែមទាំអាចជះផលប៉ះពាល់មិនល្អដល់ទឹកចិត្តរបស់អ្នកវិនិយោគ ប្រសិនបើនៅតែគ្មានការត្រួតពិនិត្យទៀតនោះ។*

*កង្វះនូវការណែនាំ ដែលបញ្ជាក់ច្បាស់អំពីពេលវេលា និងថ្លៃចំណាយពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិ បានរឹតត្បិតលទ្ធភាពរបស់វិនិយោគិន និងអ្នកអភិវឌ្ឍក្នុងការធ្វើផែនការ ផ្តល់ហិរញ្ញប្បទាន ឬអនុវត្តគម្រោងសំណង់ឱ្យមានប្រសិទ្ធភាព និងឱ្យបានត្រឹមត្រូវ ពីព្រោះពួកគេត្រូវការភាពច្បាស់លាស់ និងការយល់ដឹងកម្រិតខ្ពស់អំពីហានិភ័យ ដែលអាចប៉ះពាល់លើវិនិយោគទុនរបស់ពួកគេ។ ស្រដៀងគ្នានេះដែរ ដោយសារតែមិនមានការផ្សព្វផ្សាយអំពីថ្លៃចំណាយផ្លូវការនេះ រាជរដ្ឋាភិបាលបាត់បង់ឱកាសក្នុងការប្រមូលចំណូលឱ្យមានប្រសិទ្ធផល ពីព្រោះថ្លៃចំណាយលើការផ្ទេរកម្មសិទ្ធិ ត្រូវបានប្រមូលដោយភ្នាក់ងារដែលគិតបន្ថែមថ្លៃសេវារបស់ខ្លួន ដែលនាំឱ្យថ្លៃចំណាយសរុបលើសេវាផ្ទេរកម្មសិទ្ធិកាន់តែកើនឡើងខ្ពស់ថែមទៀត។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យផ្តល់អាទិភាព ដល់ការបង្កើតឌីជីថលនីយកម្ម នៃដំណើរការផ្ទេរកម្មសិទ្ធិអចលនទ្រព្យតាមរយៈការដាក់ឱ្យដំណើរការកម្មវិធីតាមប្រព័ន្ធអនឡាញ។

ដើម្បីធានាថា ដំណើរការនៃការផ្ទេរកម្មសិទ្ធិលើអចលនទ្រព្យមានភាពស្របច្បាប់ ស៊ីសង្វាក់គ្នា និងមានតម្លាភាព យើងខ្ញុំសូមស្នើឱ្យរាជរដ្ឋាភិបាលចាត់វិធានការនានា ដើម្បីផ្តល់អាទិភាពទៅលើការធ្វើឌីជីថលនីយកម្ម នូវដំណើរការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ តាមរយៈការដាក់ឱ្យដំណើរការកម្មវិធីតាមប្រព័ន្ធអនឡាញ។ កម្មវិធីតាមប្រព័ន្ធអនឡាញនេះនឹងអនុញ្ញាតឱ្យភាគីពាក់ព័ន្ធនៅក្នុងការផ្ទេរកម្មសិទ្ធិអាចចូលមើល និងប្រើប្រាស់ព័ត៌មានចាំបាច់ទាំងអស់នៅលើអ៊ីនធឺណិត រួចហើយដាក់ពាក្យស្នើសុំ និងតាមដានពាក្យស្នើសុំរបស់ខ្លួនទៅកាន់ការិយាល័យសុរិយោដី តាមប្រព័ន្ធអេឡិចត្រូនិក ដែលអាចឱ្យការិយាល័យនេះដើរតួនាទីជា "ច្រកចេញចូលតែមួយ" យ៉ាងពិតប្រាកដ សម្រាប់ការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ។

តាមរយៈការដាក់ឱ្យដំណើរការកម្មវិធីផ្ទេរកម្មសិទ្ធិអចលនទ្រព្យតាមប្រព័ន្ធ រាជរដ្ឋាភិបាលនឹងបង្កើតឱ្យមានភាពច្បាស់លាស់ដែលមានចាំបាច់សម្រាប់ដំណើរការរដ្ឋបាលដ៏សំខាន់មួយនេះនឹង ដែលមានផលវិជ្ជមានសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប និងវិនិយោគទុនផ្នែកអចលនទ្រព្យ ពីព្រោះថាអ្នកទិញអចលនទ្រព្យនឹងអាចធ្វើថវិកា និងធ្វើផែនការស្របទៅតាមភាពច្បាស់លាស់នេះ។ ជាងនេះទៅទៀត ការប្រមូលកម្រៃសេវា និងពន្ធតាមមធ្យោបាយអេឡិចត្រូនិក នឹងធ្វើឱ្យកាន់តែមានភាពងាយស្រួល និងកាត់បន្ថយឱកាសនៃការរំលោភបំពានដែលអាចកើតមាន ហើយព្រមទាំងអាចលុបបំបាត់តម្រូវការប្រើសេវាភ្នាក់ងារក្នុងការជួយសម្រួលដល់ដំណើរការផ្ទេរកម្មសិទ្ធិអចលនទ្រព្យនេះ។

យើងខ្ញុំមើលឃើញថា វិធានការនេះនឹងបំពេញបន្ថែមទៅលើកម្មវិធីធ្វើទំនើបកម្មដែលមានស្រាប់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលកន្លងមក គេបានមើលឃើញថាមានដាក់ឱ្យដំណើរការ នូវកម្មវិធីទូរស័ព្ទដៃសំណង់កម្ពុជា និងបច្ចុប្បន្នភាពប័ណ្ណកម្មសិទ្ធិដីធ្លីដោយប្រព័ន្ធលេខកូដ QR។ វិធានការនេះទៀតសោតក៏នឹងស្របទៅតាមកិច្ចប្រឹងប្រែងស្រដៀងគ្នានេះ ដែលបានអនុវត្តដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានកែលម្អប្រសិទ្ធផលដំណើរការរដ្ឋបាលរបស់ខ្លួន និងកាត់បន្ថយតម្រូវការជំនួញ តាមរយៈការធ្វើឌីជីថលនីយកម្មសេវាកម្មរបស់ខ្លួន ។

យើងខ្ញុំទទួលស្គាល់ថា គម្រោងដ៏សំខាន់នេះនឹងត្រូវការធនធានច្រើនគួរឱ្យកត់សម្គាល់ដើម្បីអនុវត្តដោយជោគជ័យ ហើយនឹងផ្តល់ផលប្រយោជន៍ជាច្រើនទៅដល់សេដ្ឋកិច្ចកម្ពុជាទាំងមូល ហើយក៏នឹងលើកទឹកចិត្តឱ្យមានការវិនិយោគកាន់តែច្រើនថែមទៀតទៅក្នុងទីផ្សារអចលនទ្រព្យផងដែរ។

# ៦២

# ការធានាឱ្យមាននូវសំណុំស្តង់ដារអគារដែលមានលក្ខណៈប្រាកដប្រជា

**ធ្វើបច្ចុប្បន្នភាព**

---

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើឱ្យធ្វើការពិគ្រោះយោបល់ជាមួយវិស័យឯកជនដើម្បីធានានូវការបង្កើតសំណុំស្តង់ដារអគារដែលមានលក្ខណៈប្រាកដប្រជា។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*ច្បាប់ស្តីពីការសាងសង់ និងក្រមសំណង់អគារ ដែលអមជាមួយនឹងច្បាប់នេះ កំពុងស្ថិតនៅក្នុងដំណាក់កាលធ្វើសេចក្តីព្រាងនៅឡើយ ខណៈដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បន្តធ្វើការពិនិត្យឡើងវិញយ៉ាងសកម្មទៅលើបទប្បញ្ញត្តិសាងសង់នានា ពីប្រព័ន្ធច្បាប់នៅក្នុងបណ្តាប្រទេសដទៃទៀតដើម្បីទទួលបានធាតុចូល សំខាន់ៗ ដែលអាចអនុវត្តនៅក្នុងបរិបទប្រទេសកម្ពុជា។ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាសូមទទួលស្គាល់នូវជំនួយបច្ចេកទេសដ៏មានតម្លៃ ដែលក្រសួង និងវិទ្យាស្ថានស្តង់ដារនៃកម្ពុជា បានទទួលពីរដ្ឋាភិបាលជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ដែលតែងតែប្រមូលផ្តុំអ្នកជំនាញចូលរួមគាំទ្រដល់ការតាក់តែងក្រមសំណង់អគារ។*

---

**ពិពណ៌នាបញ្ហា**

*ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បច្ចុប្បន្ន កំពុងស្ថិតក្នុងដំណាក់កាលស្រាវជ្រាវ និងធ្វើសេចក្តីព្រាងក្រមសំណង់អគារកម្ពុជា។ គោលបំណងមួយនៃក្រមសំណង់អគារនេះគឺផ្តល់នូវបទប្បញ្ញត្តិកាន់តែរឹងមាំ និងមានប្រសិទ្ធភាពថែមទៀតលើស្តង់ដារសុវត្ថិភាពនៅក្នុងវិស័យសំណង់នៅកម្ពុជា ពីព្រោះ បច្ចុប្បន្ន បទប្បញ្ញត្តិដែលមានស្រាប់ និងអាចអនុវត្តបាន គឺមានតិចតួចណាស់។ សព្វថ្ងៃ អ្នកអភិវឌ្ឍគម្រោងសំណង់ធំៗតែងតែប្រកាន់ខ្ជាប់ដោយស្ម័គ្រចិត្តនូវស្តង់ដារអន្តរជាតិ ប៉ុន្តែនេះគឺជារឿងធម្មតាទៅហើយដែលអ្នកអភិវឌ្ឍ និង/ឬអ្នកម៉ៅការ កាត់បន្ថយស្តង់ដារខ្លះដើម្បីបានប្រាក់ចំណេញខ្ពស់នៅលើគម្រោងតូចៗ។ ជាលទ្ធផលនៃស្តង់ដារសំណង់អគារមិនសូវល្អកន្លងមក គេឃើញមានករណីរាយការណ៍អំពីគ្រោះថ្នាក់ដល់អាយុជីវិតរបស់កម្មករមួយចំនួន ដែលបានកើតឡើងរួចមកហើយ។*

*បច្ចុប្បន្ន រាជរដ្ឋាភិបាលកំពុងស្ថិតក្នុងដំណាក់កាលធ្វើសេចក្តីព្រាងច្បាប់ ស្តីពីការសាងសង់ ដែលនឹងដាក់បញ្ចូលនូវក្រមសំណង់អគារ ដោយកំណត់អំពីស្តង់ដារសុវត្ថិភាព និងគុណភាពសម្រាប់គម្រោងសាងសង់ ដែលមានការគាំទ្រពីសំណាក់អ្នកជំនាញអន្តរជាតិ។ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា សូមស្វាគមន៍គំនិតផ្តួចផ្តើមនេះ និងសង្ឃឹមថា នឹងបន្តជួយសម្របសម្រួលកិច្ចសន្ទនារវាងរាជរដ្ឋាភិបាលជាមួយនឹងវិស័យឯកជន តាមរយៈគណៈកម្មាធិការអចលនទ្រព្យ និងសំណង់របស់យើងដើម្បីធានាថាស្តង់ដារថ្មីនឹងមានលក្ខណៈរឹងមាំ និងប្រាកដប្រជាដើម្បីកុំឱ្យវាជាការបង្អាក់ដល់វិនិយោគនៅក្នុងវិស័យនេះ។*

ជាប្រការចាំបាច់ដែលគេត្រូវពិចារណាអំពីថា តើត្រូវធ្វើដូចម្ដេចដើម្បីអនុវត្តក្រមនេះឱ្យមានប្រសិទ្ធភាព នៅពេលក្រមនេះតាក់តែងរួចរាល់ជាស្ថាពរ។ ការតាមដានអនុលោមភាពនឹងតម្រូវឱ្យមានស្ថាប័នមួយដែលមានបុគ្គលិកជំនាញ ដែលអាចត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ដោយឯករាជ្យទៅលើការអនុវត្តស្តង់ដារសំណង់អគារនៅលើគម្រោងសំណង់។ នៅក្នុងការអនុវត្តជាក់ស្ដែង អាចជាភាពប្រឈមមួយសម្រាប់រដ្ឋាភិបាលក្នុងការអភិវឌ្ឍសមត្ថភាពដើម្បីធ្វើការត្រួតពិនិត្យបែបនេះ ហើយអាជ្ញាធរនៅក្នុងប្រទេសផ្សេងទៀត សម្រេចចិត្តផ្ដល់ការអនុញ្ញាតដល់ស្ថាប័នផ្ទៀងផ្ទាត់ឯករាជ្យមកពីវិស័យឯកជនអនុវត្តកិច្ចការនេះ។

## ផលប៉ះពាល់លើកម្ពុជា

រាជរដ្ឋាភិបាលយល់ច្បាស់ អំពីសារៈសំខាន់នៃការដាក់ឱ្យអនុវត្តក្រមសំណង់អគារដែលមានប្រសិទ្ធភាព ក្នុងការកាត់បន្ថយហានិភ័យសុវត្ថិភាព ការពារប្រជាជននៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ទំនុកចិត្តរបស់វិនិយោគិន ដោយកន្លងមកមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលក៏បានធ្វើការអត្ថាធិប្បាយជាសាធារណៈអំពីហានិភ័យដែលអាចបង្កឡើងដោយសារតែស្តង់ដារសំណង់អគារធូររលុង ដែលអាចធ្វើឱ្យប៉ះពាល់ដល់កំណើន និងនិរន្តរភាពនៃវិស័យអចលនទ្រព្យទាំងមូល។

ចំពោះខ្លឹមសារនៃស្តង់ដារនេះ ចាំបាច់ត្រូវមានការពិចារណាហ្មត់ចត់ ដើម្បីពិនិត្យមើលថាតើស្តង់ដារទាំងនេះមានលក្ខណៈដូចម្ដេចដែរ បើប្រៀបធៀបនឹងស្តង់ដាររបស់ប្រទេសផ្សេងទៀត ពីព្រោះថាការបង្កើតសំណុំឯកសារស្តង់ដារ ដែលវិនិយោគមិនស្គាល់ទាល់តែសោះ នឹងបង្កើតនូវការចំណាយបន្ថែមលើការកែសម្រួល និងការផ្ទៀងផ្ទាត់ ដែលអាចនឹងបន្ទុចបង្អាក់ដល់វិនិយោគបរទេស។ ម្យ៉ាងវិញទៀត សំណុំឯកសារស្តង់ដារដែលរឹងមាំ ប៉ុន្តែប្រាកដប្រជា នឹងបង្កើនទំនុកចិត្តពីសំណាក់វិនិយោគិនដោយមិនបង្កើតនូវការចំណាយដែលជាបន្ទុកច្រើនហួសហេតុពេកដល់ពួកគេ។

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យពិគ្រោះយោបល់ជាមួយវិស័យឯកជនដើម្បីធានានូវការបង្កើតសំណុំស្តង់ដារអគារ ដែលមានលក្ខណៈប្រាកដប្រជា។

ការអនុវត្តឱ្យមានប្រសិទ្ធភាព គឺជាគន្លឹះដ៏សំខាន់ក្នុងការធានានូវភាពជោគជ័យនៃក្រមសំណង់អគារ និងការលើកកម្ពស់ស្តង់ដារសុវត្ថិភាព និងការយល់ឃើញរបស់វិនិយោគិនទៅលើការប្រកួតប្រជែងដោយយុត្តិធម៌នៅក្នុងទីផ្សារអចលនទ្រព្យរបស់កម្ពុជា។ អាស្រ័យហេតុដូច្នេះ យើងខ្ញុំសូមគោរពផ្ដល់ជូនជាអនុសាសន៍ឱ្យរាជរដ្ឋាភិបាលដូចខាងក្រោម៖

- *ផ្អែកលើក្រមសំណង់អគារ ទៅតាមសំណុំស្តង់ដារអន្តរជាតិដែលមានស្រាប់ ដែលទាំងវិនិយោគិនបច្ចុប្បន្ន និងវិនិយោគិននាពេលអនាគត អាចយល់ដឹងបាន។ ផ្អែកលើមូលដ្ឋាននេះ ការកែសម្រួលអាចធ្វើឡើងដើម្បីស្របទៅនឹងភាពជាក់លាក់នៃបរិបទកម្ពុជា។ ឧទាហរណ៍ ភាពរឹងមាំរបស់ដំបូលតាមស្តង់ដារអឺរ៉ុប ដែលត្រូវតែអាចទប់ទល់នឹងការធ្លាក់ព្រិលខ្លាំងបាន អាចមិនមានភាពចាំបាច់សម្រាប់បរិបទនៅកម្ពុជាទេ។ ប៉ុន្តែអាចនឹងមានហានិភ័យផ្សេងពីនេះទៀតដែលត្រូវធ្វើការពិចារណាដែលពុំមានកំណត់នៅក្នុងសំណុំឯកសារស្តង់ដាររបស់ប្រទេសដែលគេប្រើជាមូលដ្ឋាន។ ផលសម្រេចនៃដំណើរការនេះ គឺ "ស្តង់ដារកម្ពុជា" ប៉ុន្តែ យើងសូមផ្តល់ជូនជាអនុសាសន៍ ថា ស្តង់ដារនេះត្រូវតែស្របទៅនឹងស្តង់ដារអន្តរជាតិដែលមានស្រាប់ផងដែរ។*

- *យើងខ្ញុំសូមស្នើឱ្យមានការពិគ្រោះយោបល់ជាមួយវិស័យឯកជនដើម្បីកំណត់ថាតើអ្វីខ្លះដែលជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពបំផុតសម្រាប់ការអនុវត្តក្រមសំណង់អគារថ្មីនេះ។ ការអនុញ្ញាតឱ្យមានស្ថាប័នផ្ទៀងផ្ទាត់ឯករាជ្យមកពីវិស័យឯកជនក៏អាចជាជម្រើសដ៏ល្អមួយគួរពិចាណាផងដែរ។*

- *ដើម្បីជួយដល់ការអនុវត្ត គួរពិចារណាដាក់បញ្ចូល នៅក្នុងក្រមសំណង់អគារនូវលក្ខខណ្ឌតម្រូវមួយដែលតម្រូវឱ្យគម្រោងអភិវឌ្ឍន៍ទាំងអស់បង្ហាញឱ្យឃើញច្បាស់នូវផ្ទាំងប៉ាណូមួយដែលរាយនាមក្រុមហ៊ុនសំណង់ដែលធ្វើការនៅលើគម្រោងនោះ។ ព័ត៌មាននេះគឺដើម្បីបង្កើនតម្លាភាព និងអាចឱ្យស្ថាប័នត្រួតពិនិត្យធានាថាមានតែក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណ និងមានវិញ្ញាបនបត្របញ្ជាក់ប៉ុណ្ណោះ ដែលប្រតិបត្តិការនៅលើគម្រោងសំណង់ណាមួយនោះ។*

៦៣

# វិធានការរយៈពេលខ្លីដើម្បីដោះស្រាយបញ្ហាសុវត្ថិភាពអគ្គិភ័យ

**ធ្វើបច្ចុប្បន្នភាព**

**អនុសាសន៍ឆ្នាំ ២០១៧**

នៅមុនពេលធ្វើការតាក់តែងរួចរាល់ និងការដាក់ឱ្យអនុវត្តនូវក្រមសំណង់អគារ សូមស្នើឱ្យមានការពិគ្រោះយោបល់ជាមួយនឹងវិស័យឯកជន ដើម្បីកំណត់នូវលក្ខណៈវិនិច្ឆ័យសុវត្ថិភាពអគ្គិភ័យ ដែលត្រូវអនុវត្តតាមនៅក្នុងគ្រប់ដំណាក់កាលនៃដំណើរការផ្តល់លិខិតអនុញ្ញាតសាងសង់ និងដែលត្រូវអនុវត្តដោយក្រុមហ៊ុនប្រតិបត្តិនានា។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ ក្រសួងមហាផ្ទៃបានចេញប្រកាសលេខ ៨៧ ដើម្បីលើកកម្ពស់កិច្ចការពារអគ្គិភ័យ សម្រាប់សំណង់អគារនៅក្នុងប្រទេសកម្ពុជា ដោយតម្រូវឱ្យមានការដំឡើងប្រព័ន្ធបង្ការអគ្គិភ័យ ដើម្បីកាត់បន្ថយការខូចខាត និងគ្រោះថ្នាក់ដែលបង្កឡើងដោយអគ្គិភ័យ។ ប្រកាសនេះតម្រូវឱ្យអគារពាណិជ្ជកម្ម និងអគារប្រើប្រាស់ចម្រុះទាំងអស់ត្រូវតែមានប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យឱ្យបានគ្រប់គ្រាន់ និងដាក់ចេញនូវការណែនាំអំពីការគ្រប់គ្រង និងអធិការកិច្ចដោយមន្ត្រី ដើម្បីធានាថាប្រព័ន្ធទាំងនេះស្របទៅតាមស្តង់ដាររបស់រាជរដ្ឋាភិបាល។ អគារនានានឹងត្រូវតម្រូវឱ្យដាក់ផែនការបង្ការអគ្គិភ័យរបស់ខ្លួនទៅឱ្យអាជ្ញាធរនៅមុនពេលចាប់ផ្តើមសាងសង់ ដោយមានការអនុវត្តទោសទណ្ឌ ប្រសិនបើម្ចាស់សំណង់អគារមិនគោរពតាម។ អគារដែលមានស្រាប់ ដែលមិនមានបំពាក់ប្រព័ន្ធបង្ការអគ្គិភ័យ ក៏នឹងត្រូវតម្រូវឱ្យចុះបញ្ជីជាមួយអាជ្ញាធរ ដើម្បីធ្វើឱ្យអគាររបស់ខ្លួនស្របទៅនឹងលក្ខខណ្ឌតម្រូវថ្មីនេះផងដែរ។ ចំណុចសំខាន់គួរកត់សម្គាល់គឺថា បទប្បញ្ញត្តិថ្មីទាំងនេះនឹងមិនអនុវត្តចំពោះលំនៅដ្ឋានឯកជន ដែលមិនជាប់ពាក់ព័ន្ធនឹងសកម្មភាពពាណិជ្ជកម្មឡើយ។ ខណៈដែលបទប្បញ្ញត្តិនេះត្រូវបានស្វាគមន៍ រាជរដ្ឋាភិបាលមិនទាន់បានកំណត់ថាតើស្តង់ដារ ឬប្រព័ន្ធសុវត្ថិភាពអគ្គិភ័យអ្វីខ្លះ ដែលម្ចាស់សំណង់អគារត្រូវបានតម្រូវឱ្យអនុវត្តតាមដើម្បីចាត់ទុកថាបានអនុលោមតាមលក្ខខណ្ឌតម្រូវអធិការកិច្ចនោះឡើយ។*

**ពិពណ៌នាបញ្ហា**

*ចាប់តាំងពីការប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្ការអគ្គិភ័យ ឆ្នាំ២០១៣ រាជរដ្ឋាភិបាលបានចាត់វិធានការគួរឱ្យកោតសរសើរក្នុងការបង្កើនស្តង់ដារសុវត្ថិភាពអគ្គិភ័យនៅកម្ពុជា ដូចដែលបង្ហាញឱ្យឃើញតាមរយៈការដាក់ឱ្យអនុវត្តនូវប្រកាសលេខ ៨៧ ដែលតម្រូវឱ្យអគារពាណិជ្ជកម្ម និងអគារប្រើប្រាស់ចម្រុះទាំងអស់ ត្រូវតែដំឡើងប្រព័ន្ធការពារអគ្គិភ័យ។ ទោះបីជាបទប្បញ្ញត្តិនេះត្រូវបានស្វាគមន៍ ប៉ុន្តែដោយសារតែនៅពុំទាន់មានការបានបញ្ជាក់អំពីស្តង់ដារ ឬប្រព័ន្ធជាក់លាក់ ដែលម្ចាស់សំណង់អគារត្រូវបានតម្រូវឱ្យដំឡើងដើម្បីទទួលបានការអនុញ្ញាតសាងសង់ ឬដើម្បីអាចចាត់ទុកថាបានអនុលោមតាមលក្ខខណ្ឌតម្រូវជាប់ការធ្វើអធិការកិច្ច ចាំបាច់ត្រូវតែមានបទប្បញ្ញត្តិបន្ថែមទៀត។*

*ដោយទទួលស្គាល់ថា ក្រមសំណង់អគារដែលបានលើកឡើងខាងលើ ត្រូវបានរំពឹងថានឹងដាក់បញ្ចូលនូវបទប្បញ្ញត្តិជាក់លាក់ថែមទៀតដែលទាក់ទងនឹងសុវត្ថិភាពអគ្គិភ័យ បច្ចុប្បន្ន ក្រមសំណង់អគារនេះកំពុងស្ថិតនៅក្នុងដំណាក់កាលធ្វើសេចក្តីព្រាង ហើយត្រូវចំណាយពេលមួយរយៈទៀត ទើបក្រមនេះអាចនឹងត្រូវដាក់ចេញឱ្យអនុវត្តពេញលេញ។ ប្រទេសកម្ពុជា កន្លងមក ធ្លាប់ជួយប្រទះករណីសោកនាដកម្មអគ្គិភ័យជាច្រើនករណីរួចមកហើយ ដូច្នេះយើងជឿជាក់ថាចាំបាច់ត្រូវមានវិធានការ*

មួយចំនួនទៀត ដើម្បីដោះស្រាយបញ្ហាសុវត្ថិភាពអគ្គិភ័យឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ខណៈដែលកំពុងរង់ចាំក្រមសំណង់អគារនេះបញ្ចប់ជាស្ថាពរ។

**ផលប៉ះពាល់លើកម្ពុជា**

ការយឺតយ៉ាវក្នុងការអនុម័តបទប្បញ្ញត្តិសុវត្ថិភាពអគ្គិភ័យ នៃក្រមសំណង់អគារនេះ បង្កើននូវលទ្ធភាពអាចកើតមានសោកនាដកម្មនៅក្នុងបណ្តាឆ្នាំនៅមុនការអនុវត្តបទប្បញ្ញត្តិនេះ។ ក្រៅពី ការឈឺចាប់ និងសោកនាដកម្មដែលបានបង្កឡើង ឧបទ្ទវហេតុបែបនេះក៏ផ្តល់ជាផលវិបាកផ្នែកសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរផងដែរ ដោយសារតែវាបានធ្វើឱ្យប៉ះពាល់ដល់ការជឿទុកចិត្តរបស់វិនិយោគិនមកលើប្រទេសកម្ពុជា។

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើថាមុនពេលមានការអនុម័តក្រមសាងសង់អគារ ( Building Code ) គប្បីមានការពិគ្រោះយោបល់ ជាមួយនឹងផ្នែកឯកជនជាមុនសិន ដើម្បីកំណត់លក្ខណៈវិនិច្ឆ័យអន្តរការី សម្រាប់សុវត្ថិភាពអគ្គិភ័យ ដែលនឹងបង្កើតបានជាមូលដ្ឋានសម្រាប់អធិការកិច្ច និងដំណើរការអនុម័ត ដោយស្របតាមលក្ខខណ្ឌតម្រូវកំណត់ដោយប្រកាសលេខ ៨៧។

នៅមុនពេលឈានទៅដល់ការអនុម័តក្រមសំណង់អគារ យើងខ្ញុំសូមសំណូមពរថារាជរដ្ឋាភិបាលគួរតែមានកិច្ចពិគ្រោះយោបល់ជាមួយនឹងវិស័យឯកជនដើម្បីកំណត់លក្ខណៈវិនិច្ឆ័យអន្តរការីសម្រាប់សុវត្ថិភាពអគ្គិភ័យ ដែលនឹងត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់គ្រប់ដំណាក់កាលនៃដំណើរការចេញលិខិតអនុញ្ញាតសាងសង់ (ការធ្វើផែនការការចាប់ផ្តើមសាងសង់ និងការបញ្ចប់ការសាងសង់) និងដែលត្រូវអនុវត្តដោយក្រុមហ៊ុនប្រតិបត្តិការ។ បន្ទាប់មកទៀត ការអនុវត្តស្តង់ដារទាំងនេះអាចត្រូវធ្វើអធិការកិច្ចឱ្យបានសមស្រប និងសម្រេចផ្តល់ការអនុញ្ញាតស្របទៅតាមប្រកាសលេខ ៨៧។

ទោះបីជារាជរដ្ឋាភិបាលជាអ្នកសម្រេចក្នុងការកំណត់ថាតើអ្វីជាស្តង់ដារសុវត្ថិភាពអគ្គិភ័យ និងប្រព័ន្ធបង្ការអគ្គិភ័យសមស្របបំផុតដែលត្រូវអនុវត្តចំពោះសំណង់អគារនានានៅក្នុងប្រទេសកម្ពុជា ប៉ុន្តែដោយសារតែសុវត្ថិភាពអគ្គិភ័យគឺជាកង្វល់ជាសាកល យើងសូមស្នើថាវិធានការបែបនេះគប្បីផ្អែកទៅលើឧត្តមានុវត្តន៍អន្តរជាតិ។

នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ សម្ព័ន្ធស្តង់ដារសុវត្ថិភាពអគ្គិភ័យអន្តរជាតិ (IFSS) ត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្តល់នូវកម្រងវិធានសាកលសម្រាប់សុវត្ថិភាពអគ្គិភ័យ ដែលជានាទូវភាពស៊ីសង្វាក់គ្នាកាន់តែប្រសើរឡើង សម្រាប់កម្រិតអប្បបរមានៃសុវត្ថិភាពអគ្គិភ័យ និងភាពវិជ្ជាជីវៈ នៅក្នុងអគារទាំងឡាយ នៅទូទាំងពិភពលោក ។ ខណៈដែលវាល្បឿនពេកក្នុងការយកសម្ព័ន្ធ IFSS ធ្វើជាមូលដ្ឋានសម្រាប់វិធានការសុវត្ថិភាពអគ្គិភ័យរបស់កម្ពុជា នៅពេលដែលទីផ្សារអចលនទ្រព្យកាន់តែមានចរិតសាកលខ្លាំងឡើងៗ ជាមួយនឹងលំហូរនៃវិនិយោគពីក្រៅប្រទេស វាជាការសំខាន់ដែលកម្ពុជាត្រូវធ្វើឱ្យស្តង់ដាររបស់ខ្លួនបន្តិចម្តងៗឱ្យស្របទៅតាមឧត្តមានុវត្តន៍អន្តរជាតិ ដើម្បីធ្វើយ៉ាងណាឱ្យកម្ពុជានៅតែជាគោលដៅវិនិយោគដែលទាក់ទាញ។

## ៦៤

# ការធានាសុខភាព និងសុវត្ថិភាពការងារនៅការដ្ឋានសំណង់

ធ្វើបច្ចុប្បន្នភាព

**អនុសាសន៍ឆ្នាំ ២០១៧**

សូមស្នើឱ្យបង្កើតអនុគណៈកម្មាធិការនៅក្រោមគណៈកម្មាធិការជាតិដើម្បីសុខភាព និងសុវត្ថិភាពការងារ ដោយផ្តោតជាក់លាក់ទៅលើសុខភាព និងសុវត្ថិភាពការងារនៅការដ្ឋានសំណង់។

**ការឆ្លើយតបផ្នែកគោលនយោបាយ**

*ននៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ (OSH) ដែលស្ថិតក្រោមចំណុះរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីសម្រេចមួយស្តីពីការបង្កើតក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោង (PAB) ដើម្បីលើកកម្ពស់ស្តង់ដារសុខភាព និង សុវត្ថិភាពការងារ នៅក្នុងវិស័យសំណង់នៅកម្ពុជា។ ក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោងនេះ ត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីសំណាក់អង្គការពលកម្មអន្តរជាតិ (ILO) និងប្រទេសជប៉ុន និងរួមមានសមាសភាពតំណាងមកពីរាជរដ្ឋាភិបាល វិស័យឯកជន សហជីព និងអង្គការមិនមែនរដ្ឋាភិបាល។ ក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោងនេះ មានគោលបំណងធ្វើការចែករំលែក ឧត្តមានុវត្តន៍ និងរៀបចំតាក់តែងក្របខ័ណ្ឌច្បាប់ តាមរយៈដំណើរការពិគ្រោះយោបល់ ដែលនឹងអនុវត្តវិធានការត្រួតពិនិត្យដើម្បីកាត់បន្ថយឧប្បត្តិហេតុ និងរបួសនៅការដ្ឋានសំណង់។ ក្រុមប្រឹក្សានេះបានចាប់ផ្តើមធ្វើសេចក្តីព្រាងប្រកាសថ្មីៗដែលទាក់ទងនឹងសុខភាព និងសុវត្ថិភាពការងារស្តីពីឧបករណ៍ការពារ ការធ្វើការនៅទីខ្ពស់ ការស្នាក់នៅ និងសន្តិសុខសង្គម ដែលនេះបង្ហាញអំពីឆន្ទៈរបស់រាជរដ្ឋាភិបាល នៅក្នុងការដោះស្រាយបញ្ហាដែលកើនឡើងនេះ ខណៈដែលកម្ពុជាកំពុងមានភាពរីកចម្រើនលូតលាស់ខ្លាំងក្នុងវិស័យសំណង់។*

*សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា មានសេចក្តីសោមនស្សរីករាយ ដែលបានចូលរួមជាផ្នែកមួយនៃក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោងនេះតាមរយៈគណៈកម្មាធិការអចលនទ្រព្យ និងសំណង់របស់យើង ក្នុងនាមជាតំណាងមកពីវិស័យឯកជន។ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាបន្តអនុវត្តការប្តេជ្ញាចិត្តរបស់យើងក្នុងការលើកកម្ពស់ស្តង់ដារសុខភាព និងសុវត្ថិភាពការងារនៅតាមការដ្ឋានសំណង់នៅកម្ពុជា ដូចដែលបានបង្ហាញឱ្យឃើញជាក់ស្តែងតាមរយៈកម្មវិធី អាហារពេលព្រឹកស្តីពីសុវត្ថិភាព និងសុខភាពការងារ និងការបោះពុម្ពផ្សាយកូនសៀវភៅណែនាំស្តីពីសុវត្ថិភាពក្នុងការដ្ឋានសំណង់ ដោយ សហការជាមួយនឹងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងម្ចាស់ឧបត្ថម្ភកម្មវិធីនានា។ យើងខ្ញុំសង្ឃឹមថាតាមរយៈសកម្មភាពទាំងនេះ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាអាចគាំទ្រដល់កិច្ចប្រឹងប្រែងជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់សារៈសំខាន់នៃសុខភាពនិង សុវត្ថិភាព ការងារនៅតាមការដ្ឋានសំណង់នានា នៅទូទាំងប្រទេសកម្ពុជា និងចូលរួមចំណែកកាត់បន្ថយចំនួនករណីគ្រោះថ្នាក់ និងរបួសនៅកន្លែងធ្វើការផងដែរ។*

**ពិពណ៌នាបញ្ហា**

*សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាសូមស្វាគមន៍ចំពោះគំនិតផ្តួចផ្តើមបុរេសកម្មដែលអនុវត្តដោយរាជរដ្ឋាភិបាល នៅក្នុងការលើកកម្ពស់ស្តង់ដារសុវត្ថិភាព និងសុខភាពការងារនៅតាមការដ្ឋានសំណង់នៅកម្ពុជា និងទទួលស្គាល់ថា កិច្ចការនេះអាចនឹងចំណាយពេលវេលាច្រើនទម្រាំតែអាចអនុវត្តក្របខ័ណ្ឌច្បាប់នៅទូទាំងប្រទេសប្រកបដោយប្រសិទ្ធភាព។ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង សមត្ថភាពនៅមិនទាន់មានគ្រប់គ្រាន់នៅឡើយដើម្បីធានាការអនុវត្តស្តង់ដារថ្មី ហើយការដ្ឋានជាច្រើនអាចដំណើរការដោយមានការត្រួតពិនិត្យតិចតួចប៉ុណ្ណោះ។ ស្រដៀងគ្នានេះដែរ កម្ពុជានៅខ្វះខាតកម្លាំងពលកម្មផ្នែកសំណង់ដែលមានសមត្ថភាពវិជ្ជាជីវៈត្រឹមត្រូវ ដោយកម្មករនៅតាមការដ្ឋានជាច្រើននៅខ្វះការបណ្តុះបណ្តាលស្តីពីសុវត្ថិភាពជាមូលដ្ឋាន ហើយជាទូទៅពួកគេមិនសូវយល់ដឹងអំពីច្បាប់ថ្មីឡើយ ដូច្នេះហើយទើបគេឃើញមានការអនុវត្ត*

*សុវត្ថិភាពនៅតាមការដ្ឋានសំណង់នៅកម្ពុជានៅមានកម្រិតនៅឡើយ។ ការយល់ដឹង និងការអប់រំច្រើនថែមទៀត គឺកត្តាដ៏សំខាន់ខ្លាំងណាស់សម្រាប់ការអនុវត្តបទប្បញ្ញត្តិសុវត្ថិភាព និងសុខភាពការងារថ្មីនេះ និងការលើកកម្ពស់ស្តង់ដារសុវត្ថិភាពនៅតាមការដ្ឋានប្រកបដោយប្រសិទ្ធភាព។*

*អាស្រ័យហេតុនេះ កម្ពុជាត្រូវការជាចាំបាច់នូវយុទ្ធសាស្ត្រ និងកម្មវិធីបណ្តុះបណ្តាលដែលមានប្រសិទ្ធភាពដើម្បីកសាងមូលដ្ឋានចំណេះដឹងទូលំទូលាយអំពីស្តង់ដារសុវត្ថិភាព និងសុខភាពការងារនៅក្នុងក្រុមហ៊ុនសំណង់ ដែលនឹងត្រូវអនុវត្តប្រកបដោយប្រសិទ្ធផលបំផុត តាមរយៈការបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលដែលអនុញ្ញាតដោយរដ្ឋាភិបាល។ យើងជឿជាក់ថា ការបណ្តុះបណ្តាលនេះនឹងសមស្របបំផុត ក្នុងការផ្តល់ទៅឱ្យមន្ត្រីសុវត្ថិភាព ដែលដើរតួនាទីសំខាន់នៅក្នុងការជំរុញសកម្មភាពនានាដើម្បីធ្វើឱ្យសុវត្ថិភាព និងសុខភាពការងារមានភាពប្រសើរឡើងនៅកម្រិតសហគ្រាស។ បន្ទាប់មក រាជរដ្ឋាភិបាលអាចពង្រឹងលក្ខខណ្ឌតម្រូវឱ្យក្រុមហ៊ុននានាត្រូវតែឱ្យមន្ត្រីសុវត្ថិភាពរបស់ខ្លួនចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលដែលមានការយល់ព្រមនៅមុនពេលសំណង់នៅលើគម្រោងណាមួយអាចចាប់ផ្តើមដំណើរការ។ វិធីសាស្ត្រនេះនឹងធានាថាមន្ត្រីសុវត្ថិភាពនឹងដើរតួនាទីជាអ្នកពាំនាំនូវព័ត៌មានសុវត្ថិភាពទៅឱ្យស្ថាប័នរបស់ខ្លួន និងពង្រឹងការអនុវត្តបទប្បញ្ញត្តិសុវត្ថិភាព និងសុខភាពការងារនៅតាមការដ្ឋានដែលខ្លួនគ្រប់គ្រង។ យើងប្រមើលមើលឃើញថា កម្មវិធីបណ្តុះបណ្តាលនេះអាចប្រព្រឹត្តទៅរយៈពេលពី ៣ ទៅ ៥ថ្ងៃ ហើយខ្លឹមសារនៃការបណ្តុះបណ្តាលអាចស្របទៅតាមព័ត៌មានដែលផ្តល់នៅក្នុងសៀវភៅណែនាំសុវត្ថិភាពសំណង់។ នេះរាប់បញ្ចូលទាំងការបណ្តុះបណ្តាលស្តីពីការសង្គ្រោះបឋម ឧបករណ៍ការពារខ្លួន ការកំណត់ហានិភ័យគ្រោះថ្នាក់ ការធ្វើការនៅទីខ្ពស់ និងប្រធានបទផ្សេងៗទៀតដែលពាក់ព័ន្ធផងដែរ។*

*សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ទទួលស្គាល់ថាការប្តេជ្ញាចិត្តធ្វើកិច្ចការនេះនឹងត្រូវចំណាយធនធាន ហិរញ្ញវត្ថុក្នុងចំនួនមួយគួរឱ្យកត់សម្គាល់ ប៉ុន្តែគម្រោងនេះផ្តល់ឱកាសយ៉ាងច្បាស់ដល់រាជរដ្ឋាភិបាល ក្នុងការធ្វើការជាមួយដៃគូអភិវឌ្ឍន៍ក្នុងការកំណត់រកប្រភពហិរញ្ញប្បទានដែលមានសក្តានុពល។ ម្យ៉ាងវិញទៀត គ្រឹះស្ថានបណ្តុះបណ្តាលនេះអាចដាក់ឱ្យដេញថ្លៃជាគម្រោងភាពជាដៃគូរវាងរដ្ឋាភិបាល និងវិស័យឯកជន ដែលប្រតិបត្តិករអាចទាញយកផលចំណេញ ពីការវិនិយោគរបស់ខ្លួនតាមរយៈការគិតប្រាក់សម្រាប់សេវាផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីសុវត្ថិភាពរបស់ក្រុមហ៊ុនសំណង់ទាំងឡាយ។*

**ផលប៉ះពាល់លើកម្ពុជា**

*ប្រសិនបើមិនមានការបណ្តុះបណ្តាល និងការយល់ដឹងគ្រប់គ្រាន់ទេនោះ ការអនុវត្តបទប្បញ្ញត្តិស្តីពីសុវត្ថិភាព និងសុខភាពការងារដែលទើបតែអនុម័តថ្មី នឹងប្រព្រឹត្តទៅដោយអន្ទើ និងមិនមានភាពជាសាកលជាក់ជាមិនខាន ពីព្រោះថាការពង្រឹងការ អនុវត្តនៅតាមការដ្ឋាននឹងនៅតែមានកម្រិត ដូច្នេះ មិនបានផ្តល់ការការពារតាមការគ្រោងទុកដល់កម្មករសំណង់ឡើយ។ អត្រាស្លាប់ និងរបួសនៅតាមការដ្ឋានសំណង់នៅក្នុងប្រទេសកម្ពុជាកាលពីពេលកន្លងមក បានកើតឡើងញឹកញាប់ខ្លាំងណាស់ និងបានប៉ះពាល់ដល់ទំនុកចិត្តរបស់វិនិយោគិននៅក្នុងវិស័យនេះ។ ការបង្កើតឱ្យមានយុទ្ធសាស្ត្រ*

និងកម្មវិធីបណ្តុះបណ្តាល OSH ដែលមានប្រសិទ្ធភាព សម្រាប់មន្ត្រីសុវត្ថិភាព នឹងជំរុញការអនុវត្តយុទ្ធសាស្រ្តបុរេសកម្មដើម្បីលើកកម្ពស់សុវត្ថិភាពតាមការដ្ឋានសំណង់ និងបំពេញបន្ថែមដល់កិច្ចប្រឹងប្រែងដ៏មានតម្លៃ ដែលរាជរដ្ឋាភិបាលបានអនុវត្តស្រាប់ហើយនោះ។ ជាងនេះទៅទៀត នេះនឹងផ្តល់ឱកាសដល់រាជរដ្ឋាភិបាលក្នុងការ ចាប់ផ្តើមពង្រឹងអនុលោមភាពតាមលក្ខខណ្ឌតម្រូវសម្រាប់ការបណ្តុះបណ្តាលនៅតាម ការដ្ឋានសំណង់នៅក្នុងប្រទេសកម្ពុជា។ វិធានការបន្ថែមទាំងនេះនឹងរួមចំណែកយ៉ាងមានប្រសិទ្ធភាពក្នុងការកាត់បន្ថយករណីរបួស និងគ្រោះថ្នាក់នៅតាមការដ្ឋាន។

**អនុសាសន៍ឆ្នាំ ២០១៩**

✓ សូមស្នើកំណត់លក្ខខណ្ឌតម្រូវឱ្យគ្រប់ក្រុមហ៊ុនសំណង់ទាំងអស់ ដែលប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាត្រូវតែមានបុគ្គលិកផ្នែកសុវត្ថិភាព ដែលទទួលបានការបណ្តុះបណ្តាលអំពីសុខភាព និងសុវត្ថិភាពការងារដែលតម្រូវដោយច្បាប់មុនពេលចាប់ផ្តើមគម្រោងថ្មី។

យើងខ្ញុំសូមផ្តល់ជូននូវអនុសាសន៍ថា រាជរដ្ឋាភិបាលគួរធ្វើការពិចារណាអនុវត្តនូវបទប្បញ្ញត្តិថ្មីមួយ ដែលតម្រូវឱ្យមន្ត្រីសុវត្ថិភាពរបស់ក្រុមហ៊ុនសំណង់នៅក្នុងប្រទេសកម្ពុជា ត្រូវតែឆ្លងកាត់វគ្គបណ្តុះបណ្តាល OSH ជាកាតព្វកិច្ចផ្លូវច្បាប់ត្រូវតែអនុវត្តតាម។ ការធ្វើដូច្នេះ នឹងធានាថា មន្ត្រីសុវត្ថិភាពដែលបម្រើការងារនៅតាមក្រុមហ៊ុនសំណង់ នៅកម្ពុជា បានបញ្ចប់វគ្គបណ្តុះបណ្តាលសុវត្ថិភាពកម្រិតមូលដ្ឋានដូចៗគ្នា ហើយនឹងយល់ដឹងអំពីបទប្បញ្ញត្តិ OSH ថ្មី ខណៈដែលបទប្បញ្ញត្តិទាំងនោះកើតមានឡើង ដែលពួកគេនឹងត្រូវប្រើប្រាស់ដើម្បីពង្រឹងការអនុវត្តនៅតាមការដ្ឋានសំណង់។

ខណៈដែលវិស័យឯកជនមានការត្រៀមលក្ខណៈល្អប្រសើរ ដើម្បីផ្តល់ការគាំទ្រ ដល់ការរៀបចំបង្កើតកម្មវិធីបណ្តុះបណ្តាល និងការផ្តល់ការបណ្តុះបណ្តាល យើងក៏សូមលើកទឹកចិត្តដល់រាជរដ្ឋាភិបាល សូមឱ្យរៀបចំកិច្ចពិគ្រោះយោបល់រវាងរដ្ឋាភិបាល និងវិស័យឯកជន នៅមុនពេលបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលណាមួយដែលអនុម័តដោយរដ្ឋាភិបាល។ អត្ថប្រយោជន៍នៃការតម្រូវឱ្យមន្ត្រីសុវត្ថិភាពទាំងអស់ត្រូវតែឆ្លងកាត់វគ្គបណ្តុះបណ្តាលដូចៗគ្នានេះគឺរាជរដ្ឋាភិបាលនឹងអាចពង្រឹងស្តង់ដារសុវត្ថិភាពជាលក្ខណៈសាកល ហើយទន្ទឹមនឹងនេះក៏អាចបង្កើនជំនាញរបស់កម្លាំងពលកម្មនៅក្នុងវិស័យសំណង់កម្ពុជាទៀតផង។

៦៥

# ការធ្វើតេស្តធានាគុណភាពសម្ភារសំណង់

ថ្មី

**ពិពណ៌នាបញ្ហា**

*វិស័យសំណង់បន្តដើរតួនាទីជាចលករជាមវន្តដ៏សំខាន់ ដែលរុញច្រានកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាឱ្យកាន់តែឆ្ពោះទៅមុខយ៉ាងលឿន ពោលគឺនៅក្នុងឆ្នាំ២០១៨ ទឹកប្រាក់ចំនួន ៥,៧ ប៊ីលានដុល្លារអាមេរិក ត្រូវបានវិនិយោគនៅក្នុងវិស័យនេះ ដែលសម្រេចបានអត្រាកំណើនប្រចាំឆ្នាំចំនួន ២៣% ។ កំណើនវិនិយោគនេះបង្កើតឱ្យមានតម្រូវការកើនឡើងគួរឱ្យកត់សម្គាល់ ទៅលើអ្នកផ្គត់ផ្គង់ដើម្បីធានាដល់ការទទួលបានសម្ភារសំណង់ដ៏សំខាន់ ដែលនាំឱ្យកើនឡើងនូវការនាំចូល ហើយអ្នកផ្គត់ផ្គង់កាន់តែច្រើនឡើងបានចូលមកក្នុងទីផ្សារដើម្បីប្រកួតប្រជែងគ្នា បំពេញតម្រូវការដែលកើនឡើងនេះ។ ជាការឆ្លើយតបចំពោះការប្រកួតប្រជែងកើនឡើង នេះ អ្នកផ្គត់ផ្គង់មួយចំនួន បានផ្តល់នូវសម្ភារ ដែលខ្វះស្តង់ដារដើម្បីធ្វើឱ្យខ្លួននៅតែ អាចរក្សាតម្លៃប្រកួតប្រជែងបាន។ អ្នកផ្គត់ផ្គង់ទាំងនេះអាចលក់សម្ភារសំណង់ដែលមានគុណភាពទាប ដោយគ្មានការរាំងនៅក្នុងប្រទេសកម្ពុជា ដោយសារតែច្បាប់ស្តីពីសំណង់ ឬក្រមសំណង់អគារដែលអមច្បាប់នេះ ដែលនឹងកំណត់ស្តង់ដារសុវត្ថិភាព និងគុណភាពអប្បបរមាសម្រាប់សម្ភារសំណង់ទាំងនេះ មិនទាន់ត្រូវបានពិនិត្យបញ្ចប់រួចរាល់នៅឡើយ។*

*ខណៈដែលគ្រឿងបង្គុំអគារ ដូចជា ឥដ្ឋ និងដែកថែប អាចនឹងមើលទៅមានលក្ខណៈប្រហាក់ប្រហែលគ្នាក៏ពិតមែន ប៉ុន្តែ របៀបធ្វើគ្រឿងបង្គុំទាំងនេះគឺផ្អែកលើចំណេះដឹងរបស់រោងចក្រ វត្ថុធាតុដើម និងការត្រួតពិនិត្យគុណភាព ដែលអាចនឹងមានលក្ខណៈខុសៗគ្នា រវាងអ្នកផលិតនីមួយៗ និងអាចធ្វើឱ្យការចំណាយផលិតកើនឡើង។ ក្នុងករណីដែលសម្ភារសំណង់មានគុណភាពខ្ពស់ វានឹងបង្ហាញលទ្ធផលទៅជាផលិតផលសម្រេចមួយដែលមានគុណភាពខ្ពស់ ដែលផលិតឡើង ប្រកបដោយភាពរឹងមាំ និងជាប់បានយូរអង្វែង ដែលធានាថា សម្ភារទាំងនេះនឹងទប់ទល់បានជាមួយនឹងកម្លាំងសំណង់ និងការប្រើប្រាស់រយៈពេលយូរ ផ្ទុយទៅវិញសម្ភារសំណង់ដែលមានគុណភាពទាប នឹងនាំមកនូវលទ្ធផលផ្ទុយពីនេះ។*

*ដោយទទួលស្គាល់ថា អ្នកអភិវឌ្ឍគម្រោងសាងសង់ធំៗ ជារឿយៗ ប្រកាន់ខ្ជាប់តាមស្តង់ដារអន្តរជាតិ និងប្រើប្រាស់ម៉ាកផលិតផលល្បីៗដើម្បីធានាគុណភាព ឬអនុវត្តការធ្វើតេស្តគុណភាពដោយ ខ្លួនឯងដោយស្ម័គ្រចិត្តស្រាប់ អ្នកអភិវឌ្ឍ និង/ឬអ្នកម៉ៅការមួយចំនួន អាចនឹងកេងចំណេញពីសម្ភារសំណង់ដែលមានតម្លៃថោក និងគុណភាពទាប ដើម្បីធ្វើជាការបង្គ្រប់កិច្ច ក្នុងបំណងស្វែងរកប្រាក់ចំណេញឱ្យបានកាន់តែខ្ពស់។ ដោយសារតែ បច្ចុប្បន្ន ពុំទាន់មានលក្ខខណ្ឌច្បាប់ណាមួយដែលតម្រូវឱ្យក្រុមហ៊ុន ផ្តល់ការធានាចំពោះគុណភាពសំណង់របស់ខ្លួននៅឡើយ ទើបក្រុមហ៊ុនទាំងនេះពុំសូវខ្វល់អំពីភាពយូរអង្វែងរបស់គម្រោងនោះទេ ដូច្នេះ ពួកគេមើលឃើញនូវប្រាក់ចំណេញតិចតួចណាស់ក្នុងការប្រើប្រាស់សម្ភារដែលមានគុណភាពខ្ពស់ ពីព្រោះពួកគេនឹងមិនត្រូវ ទទួលខុសត្រូវអ្វីឡើយ នៅក្រោយពីការសាងសង់បានបញ្ចប់ជាស្ថាពររួច។*

ដូចគ្នានេះដែរ ដោយសារតែគ្មានលក្ខខណ្ឌតម្រូវ ឱ្យមានការធ្វើតេស្តដោយឯករាជ្យលើគុណភាពនិងសុវត្ថិភាពរបស់សម្ភារសំណង់ នៅមុនពេលដាក់លក់នៅក្នុងប្រទេសកម្ពុជា ក្រុមហ៊ុននានាអាចនឹងមិនបានដឹងថា ពួកគេកំពុងទិញសម្ភារដែលមានគុណភាពទាប ឬដែលគ្មានសុវត្ថិភាពឡើយ។ រោងចក្រផលិត និង/ឬអ្នកផ្គត់ផ្គង់អាចកេងចំណេញ ពីចំណុចចន្លោះប្រហោងនេះ និងរំលោភសេចក្តីទុកចិត្តរបស់អ្នកប្រើប្រាស់ ដោយធ្វើការផ្សព្វផ្សាយឃោសនាទីផ្សារផលិតផលរបស់ខ្លួនថាមានគុណភាពខ្ពស់ ហើយទន្ទឹមនឹងនេះ ក៏ធ្វើឱ្យទីផ្សារកម្ពុជាងាយរងគ្រោះដោយសារការយកមកលក់ក្នុងតម្លៃថោកជាងទីផ្សារ នូវផលិតផលដែលខ្វះស្តង់ដារពីសំណាក់ប្រទេសផ្សេងៗទៀត ។

នៅក្នុងប្រទេសជាច្រើន សម្ភារសំណង់ត្រូវតែធ្វើតេស្តដើម្បីធានាថា សម្ភារទាំងនោះបំពេញទៅតាមលក្ខខណ្ឌត្រួតពិនិត្យ នឹងធានាគុណភាព ដែលកំណត់ដោយបទដ្ឋានសំណង់ លក្ខណៈបច្ចេកទេស និងក្រមសំណង់អគាររបស់ប្រទេសនីមួយៗ។ បើយើងធ្វើការប្រៀបធៀបនៅថ្នាក់តំបន់ ការនាំចូលសម្ភារសំណង់ មកពីប្រទេសម៉ាឡេស៊ីដែលមិនស្របទៅតាមស្តង់ដារបច្ចេកទេស ត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹង ហើយអ្នកផលិតក្នុងស្រុកត្រូវបានតម្រូវឱ្យចុះបញ្ជីផលិតផលរបស់ខ្លួន ជាមួយនឹង គណៈកម្មាធិការអភិវឌ្ឍន៍វិស័យសំណង់ (CIDB)។ ការធ្វើបែបនេះ គឺដើម្បីធានាថា រោងចក្រផលិតបានបញ្ជាក់ថា សម្ភាររបស់ខ្លួនបានបំពេញតាមស្តង់ដារដែលបានកំណត់ត្រឹមត្រូវ ហើយការផាកពិន័យធ្ងន់ធ្ងរនឹងត្រូវអនុវត្តចំពោះជន ឬក្រុមហ៊ុនទាំងឡាយណាដែលលក់សម្ភារ ដោយគ្មានវិញ្ញាបនប័ត្របញ្ជាក់អនុលោមភាពពី CIDB។

ជាសំខាន់ណាស់ដែលការធ្វើតេស្តនេះ ត្រូវធ្វើឡើងដោយគ្រឹះស្ថានធ្វើតេស្តឯករាជ្យដើម្បីធានាថា លទ្ធផលវាស់វែងត្រឹមត្រូវទៅតាមស្តង់ដារសុវត្ថិភាព និងគុណភាពរបស់ផលិតផល ដោយគ្មានភាពលម្អៀងផ្នែកខាងក្នុង។ នៅកម្ពុជា ក៏មានគ្រឹះស្ថានធ្វើតេស្តឯករាជ្យមួយចំនួនតូចដែរ ប៉ុន្តែ ដោយសារតែពុំទាន់មានលក្ខខណ្ឌច្បាប់ណាមួយដែលតម្រូវឱ្យធ្វើតេស្តសម្ភារសំណង់នោះ គេឃើញមានការវិនិយោគតិចតួចណាស់ទៅលើការធ្វើតេស្តសម្ភារសំណង់នេះ។ ដូច្នេះ ដោយសារតែតម្រូវការមានតិច គ្រឹះស្ថានទាំងនេះផ្តល់សេវាធ្វើតេស្តមានកម្រិតតិចតួចប៉ុណ្ណោះ ដែលបង្ខំឱ្យរោងចក្រផលិតក្នុងស្រុក ដែលចង់ធ្វើតេស្តសម្ភារសំណង់របស់ខ្លួនដោយឯករាជ្យ ត្រូវពឹងផ្អែកលើគ្រឹះស្ថានធ្វើតេស្តនៅក្រៅប្រទេសកម្ពុជា ជារឿយៗ គឺនៅវៀតណាម ឬថៃ ដែលផ្តល់សេវាលើអាជីវកម្មសំខាន់ៗ និងចំណេះដឹងបច្ចេកទេសទាំងនេះ។

**ផលប៉ះពាល់លើកម្ពុជា**

*សម្ភារសំណង់ផលិតផលក្នុងស្រុកដែលខ្វះស្តង់ដារ នឹងជះឥទ្ធិពលអវិជ្ជមានមកលើកេរ្តិ៍ឈ្មោះរបស់កម្ពុជាក្នុងឋានៈជារោងចក្រផលិតដែលទើបលេចមុខឡើង ពីព្រោះសម្ភារទាំងនេះអាចបង្កបញ្ហាសុវត្ថិភាពធ្ងន់ធ្ងរ ជាពិសេស នៅពេលប្រើប្រាស់ជាគ្រឿងបង្គុំតួអគារ ដែលជាគ្រឹះដ៏សំខាន់ខ្លាំងចំពោះការសាងសង់គម្រោងនីមួយៗ។ កង្វល់អំពីសុវត្ថិភាពជុំវិញការប្រើប្រាស់សម្ភារសាងសង់ដែលខ្វះស្តង់ដារ គឺមានសារៈសំខាន់កាន់តែខ្លាំងឡើង ខណៈដែលគម្រោងសាងសង់នៅកម្ពុជាបន្តកើនឡើងយ៉ាងខ្ពស់ ហើយករណីគ្រោះថ្នាក់បាត់បង់ជីវិត ត្រូវបានកត់សម្គាល់ថាបានកើនឡើងរួចជាស្រេចទៅហើយក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប្រសិនបើផលិតផលខ្វះស្តង់ដារចាប់ផ្តើមល្បីថាជាផលិតផលរបស់កម្ពុជា នោះអាចប៉ះពាល់ដល់សេដ្ឋកិច្ចទាំងមូល ពីព្រោះវាកាត់បន្ថយគុណតម្លៃនៃសំណង់ និងតម្លៃលក់របស់ទំនិញផងដែរ។*

*បើទោះបីជាការតម្រូវឱ្យគ្រឿងបង្គុំសំណង់អគារ ដែលផលិតនៅក្នុងប្រទេសកម្ពុជាឱ្យធ្វើតេស្តធានាគុណភាព អាចនាំឱ្យថ្លៃដើមផលិតកើនឡើងក្តី ផលប្រយោជន៍ពីបទប្បញ្ញត្តិបែបនេះ នឹងបង្កើនគុណភាពនៃសម្ភារសំណង់ដែលបានផលិត។ មិនត្រឹមតែរោងចក្រផលិតនឹងត្រូវតម្រូវឱ្យផលិតនូវផលិតផលដែលត្រឹមត្រូវតាមស្តង់ដារអប្បបរមាប៉ុណ្ណោះនោះទេ រោងចក្រផលិតខ្វះទៀតក៏នឹងត្រូវលើកទឹកចិត្តឱ្យផលិតនូវផលិតផលដែលមានគុណភាពកាន់តែខ្ពស់ជាង ដើម្បីទទួលបានអត្ថប្រយោជន៍ផ្នែកប្រកួតប្រជែងទីផ្សារថែមទៀតផង ដែលប្រការនេះនឹងបង្ខំឱ្យផលិតផលដែលមានគុណភាពទាបត្រូវខ្ចាតចេញពីទីផ្សារស្របច្បាប់។ ប្រការនេះក៏បង្កើនការការពារដល់អ្នកប្រើប្រាស់ផងដែរ ពីព្រោះថា ការអះអាងដោយរោងចក្រផលិតត្រូវតែ បង្ហាញឱ្យឃើញច្បាស់តាមរយៈការធ្វើតេស្តឯកទេស ដូច្នេះនឹងធានាដល់អ្នកទិញថា សម្ភារដែលពួកគេទិញនឹងមានគុណភាពដូចការរំពឹងទុក ដែលទន្ទឹមនឹងនេះ ក៏ធានាការការពារដល់កម្មករដែលធ្វើការងារជាមួយនឹងសម្ភារទាំងនេះផងដែរ។*

*ជាងនេះទៅទៀត តាមរយៈការកំណត់ឱ្យគ្រឿងបង្គុំសំណង់តួអគារដែលផលិតនៅក្នុងប្រទេសកម្ពុជាត្រូវតែធ្វើតេស្តឱ្យបានសមស្របនៅមុនការលក់ រាជរដ្ឋាភិបាលនឹងលើកទឹកចិត្តឱ្យមានការវិនិយោគច្រើនថែមទៀតទៅលើគ្រឹះស្ថានធ្វើតេស្តនៅក្នុងស្រុក ពីព្រោះតម្រូវការលើវិស័យនេះប្រាកដជានឹងកើនឡើងខ្ពស់ជាមិនខាន។ ជាលទ្ធផលត្រឡប់មកវិញ នឹងមានការផ្តោតសំខាន់ច្រើនថែមទៀតទៅលើការស្រាវជ្រាវ និងការអភិវឌ្ឍ ដើម្បីគាំទ្រវិស័យនេះឱ្យបង្កើតនូវបច្ចេកវិទ្យានវានុវត្តន៍ថ្មីៗបន្ថែមទៀត ដែលសំខាន់ចាំបាច់សម្រាប់កំណើនសេដ្ឋកិច្ច និងការបង្កើតការងារធ្វើ។*

## អនុសាសន៍ឆ្នាំ ២០១៩

✓ សូមស្នើឱ្យពិចារណាអនុវត្តបទប្បញ្ញត្តិដែលតម្រូវឱ្យសម្ភារសំណង់គ្រឿងបង្គុំអគារដែលផលិតនៅក្នុងប្រទេសកម្ពុជា ត្រូវឆ្លងកាត់ការធ្វើតេស្តធានាគុណភាពឯករាជ្យជាមុនសិនមុននឹងដាក់លក់នៅលើទីផ្សារ។

*ខណៈដែលយើងខ្ញុំទទួលស្គាល់ថា ក្រមសំណង់អគារ* (Building Code) *កម្ពុជានឹងដាក់ចេញនូវស្តង់ដារសម្រាប់សម្ភារសំណង់ដែលត្រូវប្រើប្រាស់នៅក្នុងគម្រោងសាងសង់ក្តី ដោយសារតែដំណើរការនេះអាចនឹងប្រើប្រាស់ពេលវេលាយូរ ហើយសម្ភារដែលខ្វះស្តង់ដារត្រូវបានចរាចរណ៍រួចជាស្រេចទៅហើយ យើងជឿជាក់ថា រាជរដ្ឋាភិបាលគួរតែចាត់វិធានការឱ្យបានឆាប់រហ័ស ដើម្បីរឹតត្បិតការខូចខាតដែលបញ្ហានេះអាចបង្កទៅលើកេរ្តិ៍ឈ្មោះរបស់កម្ពុជា ជារោងចក្រផលិតដែលកំពុងលេចរូបរាងឡើង ។*

*ដូច្នេះហើយ យើងខ្ញុំសូមផ្តល់ជូនអនុសាសន៍ថា រាជរដ្ឋាភិបាលគួរពិចារណាអនុវត្តបទប្បញ្ញត្តិដែលតម្រូវឱ្យសម្ភារសំណង់គ្រឿងបង្គុំអគារ ដូចជា ឥដ្ឋ ដែលផលិតនៅកម្ពុជា ត្រូវឆ្លងកាត់ការធ្វើតេស្តធានាគុណភាពឯករាជ្យជាមុនសិន នៅមុនពេលដាក់លក់។ យើងជឿជាក់ថា ការអនុវត្តនូវលក្ខខណ្ឌតម្រូវនេះចំពោះគ្រឿងបង្គុំដែលមានសារសំខាន់ខ្លាំងចំពោះតួអគារ នឹងជាជំហានដំបូងដ៏សំខាន់ ពីព្រោះថា គុណភាពមិនល្អនៃផលិតផលទាំងនេះនឹងធ្វើឱ្យខូចខាតដល់ស្ថិរភាពតួអគារ។ នៅបន្ទាប់ពីការដាក់ឱ្យអនុវត្តលក្ខខណ្ឌតម្រូវនេះ រាជរដ្ឋាភិបាលគួរពង្រីកចំនួនផលិតផលសម្រាប់ការធ្វើតេស្តជាកាតព្វកិច្ច ពីព្រោះថា នឹងមានហេដ្ឋារចនាសម្ព័ន្ធធ្វើតេស្តគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងតម្រូវការកើនឡើងនេះ។*

# ពាក្យកាត់

| | | | |
|---|---|---|---|
| ACIA | កិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយអាស៊ានស្តីពីការវិនិយោគ | EPO | ស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប |
| AEC | សហគមន៍សេដ្ឋកិច្ចអាស៊ាន | ESG | បរិស្ថាន សង្គម និងអភិបាលកិច្ច |
| AMDD | កិច្ចព្រមព្រៀងស្តីពីឧបករណ៍បរិក្ខារពេទ្យអាស៊ាន | FDI | ការវិនិយោគផ្ទាល់ពីបរទេស |
| APAEC | ផែនការសកម្មភាពអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការ ផ្នែកថាមពល | GDCE | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |
| ASAPCP | ផែនការសកម្មភាពយុទ្ធសាស្ត្រអាស៊ានស្តីពីកិច្ចការពារ អ្នកប្រើប្រាស់ឆ្នាំ២០១៦-២០២៥ | GDT | អគ្គនាយកដ្ឋានពន្ធដារ |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ | GDPR | បទប្បញ្ញត្តិស្តីពីការការពារទិន្នន័យទូទៅ |
| ASYCUDA | ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ | GMO | សរីរាង្គធ្វើកំណែប្រែសេនេទិច |
| CAIF | សហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា | G-PSF | វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន |
| CAMCONTROL | អគ្គនាយកដ្ឋានត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ | HR | វិស័យធនធានមនុស្ស |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ICT | បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន |
| CEC | មជ្ឈមណ្ឌលផ្តល់វិញ្ញាបនបត្រស្លាកសញ្ញាបរិស្ថានចិន | IFSS | បទដ្ឋានសុវត្ថិភាពអគ្គិភ័យអន្តរជាតិ |
| CGBC | ក្រុមប្រឹក្សាអគារបៃតងកម្ពុជា | IPMSC | សម្ព័ន្ធបទដ្ឋានវាស់វែងអចលនទ្រព្យអន្តរជាតិ |
| CIDB | ក្រុមប្រឹក្សាអភិវឌ្ឍន៍វិស័យសំណង់ម៉ាឡេស៊ី | IPR | កម្មសិទ្ធិបញ្ញា |
| CO2 | កាបូនឌីអុកស៊ីត | JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| CPC | ការចាត់ថ្នាក់ផលិតផលថ្នាក់កណ្តាលរបស់ អង្គការសហប្រជាជាតិ | KAMSAB | ទីភ្នាក់ងារកម្ពុជានាវាចរ |
| CSR | ទំនួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន | KHR | ប្រាក់រៀលកម្ពុជា |
| CTA | គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ | KOPIA | កម្មវិធីកូរ៉េស្តីពីវិស័យកសិកម្មអន្តរជាតិ |
| EAC | អាជ្ញាធរអគ្គិសនីកម្ពុជា | MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| EIA | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | MHZ | ម៉េហ្គាហឺត |
| EMA | ទីភ្នាក់ងារឱសថអឺរ៉ុប | MOU | អនុស្សារណៈនៃការយោគយល់ |

| | | | |
|---|---|---|---|
| MSME | សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម | SME | សហគ្រាសធុនតូច និងមធ្យម |
| NSSF | បេឡាជាតិរបបសន្តិសុខសង្គម | UN | អង្គការសហប្រជាជាតិ |
| OSH | សុខភាព និងសុវត្ថិភាពនៅកន្លែងការងារ | UNECE | គណៈកម្មការសេដ្ឋកិច្ចអង្គការសហប្រជាជាតិ សម្រាប់កិច្ចការអឺរ៉ុប |
| OTC | ឱសថមិនចាំបាច់មានវេជ្ជបញ្ជា | USD | ដុល្លារអាមេរិក |
| PV | ថាមពលពន្លឺហ្វូតូវ៉ុលតិច ( Photovoltaic ) | USFDA | រដ្ឋបាលចំណីអាហារ និងឱសថសហរដ្ឋអាមេរិក |
| PPCA | រដ្ឋបាលសាលារាជធានីភ្នំពេញ | VAT | អាករលើតម្លៃបន្ថែម |
| QIP | គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | VIN | លេខអត្តសញ្ញាណយានយន្ត |
| QR | កូដឆ្លើយតបរហ័ស | WTO | អង្គការពាណិជ្ជកម្មពិភពលោក |
| REE | សហគ្រាសអគ្គិសនីជនបទ | WGBC | ក្រុមប្រឹក្សាអគារបៃតងពិភពលោក |
| SEZ | តំបន់សេដ្ឋកិច្ចពិសេស | | |

# ឯកសារយោង


## វិស័យគយ ដឹកជញ្ជូន និងភ័ស្តុភារ

១. ធនាគារជាតិនៃកម្ពុជា ឆ្នាំ២០១៨ ការអភិវឌ្ឍវិស័យម៉ាក្រូសេដ្ឋកិច្ច និងធនាគារឆ្នាំ២០១៨ និងចក្ខុវិស័យសម្រាប់ឆ្នាំ២០១៩ https://www.nbc.org.kh/download_files/other_reports/english/Macroeconomic_and_Banking_Sector_Development_in_2018_and_Prospects_for_2019_ENG.pdf

២. អង្គការគយពិភពលោក ឆ្នាំ២០១៨ គោលការណ៍ណែនាំសម្រាប់ការបញ្ចេញទំនិញពីគយបានឆាប់រហ័សភ្លាមៗដោយអង្គភាពគយ http://www.wcoomd.org/-/media/wco/public/global/pdf/topics/facilitation/instruments-and-tools/tools/immediate-release-guidelines/immediate-release-guidelines.pdf?db=web

## វិស័យយានយន្ត

១. រាជរដ្ឋាភិបាលកម្ពុជា គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥ – ២០២៥, ផ្នែកទី ៦.៣គ http://www.mih.gov.kh/File/UploadedFiles/12_9_2016_4_29_43.pdf

## វិស័យធុរកិច្ចកសិកម្ម

១. Bhuiyan, S, Zahan, A, Khatun, H, Iqbal, M, Alam, F and Manir, R, 2014 ទិន្នផលនៃពូជស្រូវកូនកាត់ខ្វែងដែលបានធ្វើតេស្តថ្មី ទន្និនុប្បវត្តិអន្តរជាតិស្តីពីការស្រាវជ្រាវក្សេត្របរិស្ថាន និងកសិកម្ម

២. Ear, S, Sim, S, Chhim, C and Khiev, P, 2017 ការសិក្សាស្តីពីគោលនយោបាយស្រូវ៖ ផលពាក់ព័ន្ធនៃការផ្លាស់ប្តូរគោលនយោបាយស្រូវនៅប្រទេសវៀតណាមមកលើគោលនយោបាយស្រូវនៅកម្ពុជា និងអ្នកផលិតស្រូវអង្ករក្នុងបណ្តាខេត្តភាគអាគ្នេយ៍នៅកម្ពុជា ឯកសារការងារលេខ ១១៣ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ភ្នំពេញ https://cdri.org.kh/wp-content/uploads/WP113_Ricepolicy.pdf

## វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

១. សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ឆ្នាំ២០១៧ សេចក្តីប្រកាសខេត្តសៀមរាប https://asean.org/wp-content/uploads/2017/12/13-Draft-Declaration_1-December-2017-adopted.pdf

២. Markova, J and Wray, C, 2016, វិស័យបច្ចេកវិទ្យាព័ត៌មានកម្ពុជា៖ ជំនាញសម្រាប់សេដ្ឋកិច្ចឌីជីថល, https://digitalrain.agency/wp-content/uploads/2017/01/IT-Skills-Gap-in-Cambodia-Research-Full-Details.pdf

## វិស័យធុរកិច្ចបៃតង

១. van Mansvelt, R, 2011 ផែនទីថាមពលពន្លឺព្រះអាទិត្យក្នុងប្រទេសកម្ពុជា៖ វិធីសាស្ត្របង្កើនការផ្សព្វផ្សាយថាមពលពន្លឺព្រះអាទិត្យក្នុងប្រទេសកម្ពុជា, http://www.seac-cambodia.org/wp-content/uploads/2016/06/2011-solar-roadmap-cambodia-summary_02.pdf

២. សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ឆ្នាំ២០១៥ ផែនការសកម្មភាពអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការផ្នែកថាមពល (APAEC) ឆ្នាំ២០១៦-២០២៥ http://www.aseanenergy.org/wp-content/uploads/2015/12/HighRes-APAEC-online-version-final.pdf

៣. Dave, R, Keller, S, Koo, B, Fleurantin, G, Portale, E, Rysankova, D, 2018, កម្ពុជា-លើសពីការតភ្ជាប់៖ បាយការណ៍វិភាគការទទួលបាន ថាមពលផ្អែលើក្របខ័ណ្ឌច្រើនកម្រិត រដ្ឋធានីវ៉ាស៊ីនតោនឌីស៊ីគ្រុប ធនាគារពិភពលោក http://documents.worldbank.org/curated/en/141011521693254478/Cambodia-Beyond-connections-energy-access-diagnostic-report-based-on-the-multi-tier-framework

៤. កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៩ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា http://www.kh.undp.org/content/cambodia/en/home/operations/projects/environment_and_energy/cambodia-climate-change-alliance.html

៥. រដ្ឋបាលសាលាក្រុងភ្នំពេញ (PPCA) វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានសកល (IGES)ក្រុមហ៊ុន Nexus for Development កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ឆ្នាំ២០១៨ យុទ្ធសាស្ត្រគ្រប់គ្រងកាកសំណល់នៅក្នុងទីក្រុងភ្នំពេញ និងផែនការសកម្មភាពឆ្នាំ២០១៨-២០៣៥ រាជធានីភ្នំពេញ https://www.ccet.jp/sites/default/files/2018-12/Phnom%20Penh%20Waste%20management%20strategy%20and%20action%20plan%202018-2035_web.pdf

## វិស័យសុខាភិបាល

១. អង្គការសុខភាពពិភពលោក (WHO) ឆ្នាំ២០១៩ បញ្ជីផលិតផលវេជ្ជសាស្ត្រវាយតម្លៃជាមុនរបស់អង្គការសុខភាពពិភពលោក
https://extranet.who.int/prequal/content/general-information-who-list-prequalified-medicinal-products

២. សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ឆ្នាំ២០១៥ កិច្ចព្រមព្រៀងស្តីពីឧបករណ៍បរិក្ខារពេទ្យអាស៊ាន
https://asean.org/wp-content/uploads/2016/06/22.-September-2015-ASEAN-Medical-Device-Directive.pdf

## វិស័យអចលនទ្រព្យ និងសំណង់

១. សម្ព័ន្ធបទដ្ឋានវាយតម្លៃអចលនទ្រព្យអន្តរជាតិ ឆ្នាំ២០១៣ ការបង្ហាញអំពីស្តង់ដារអន្តរជាតិ
https://fastedit.files.wordpress.com/2013/09/ipms-infographic.pdf

២. ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០១៩ សុន្ទរកថាបើកនៅក្នុងវេទិការាជរដ្ឋាភិបាល និងផ្នែកឯកជន ថ្ងៃទី២៩ ខែមីនា វិមានសន្តិភាព រាជធានីភ្នំពេញ។

EUROCHAM
CAMBODIA
eurocham-cambodia.org

**សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា**

អគារលេខ ៣០ មហាវិថីព្រះនរោត្តម
អគារធនាគារ Bred ជាន់ទី៣
ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: +៨៥៥ ០២៣ ៩៦៤ ១៤១
អ៊ីម៉េល: info@eurocham-cambodia.org

9 789924 908142